# មាគ៌ាជីវិតនៃព្រះពោធិសត្វ



កាលព្រះសម្មាសម្ពុទ្ធទីបង្ករព្យាករព្រះសុមេធបណ្ឌិតថា
នឹងបានត្រាស់ជាព្រះពុទ្ធមួយព្រះអង្គព្រះនាមសមណគោតម


រៀបរៀងដោយ
ខ្ញុំព្រះករុណា ខ្ញុំបាទ
**កុល ផេង**



ព.ស. ២៥៥២



មាគ៌ាជីវិតនៃព្រះពោធិសត្វ
ព.ស. ២៥៥២

# មាគ៌ាជីវិតនៃព្រះពោធិសត្វ

*រៀបរៀងដោយ*

*បណ្ឌិត* កុល ផេង

សីល សមាធិ បញ្ញា

*ការផ្សាយរបស់ពុទ្ធិកបណ្ឌិត្យសភា*

*នៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា*

**ព.ស. ២៥៦៥**

ឈ្មោះសៀវភៅ **មាគ៌ាជីវិតនៃព្រះពោធិសត្វ**

រៀបរៀងដោយ បណ្ឌិត **កុល ផេង** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី
ក្រសួងអប់រំ យុវជន និងកីឡា និងជាប្រធាន
ពុទ្ធិកបណ្ឌិត្យសភា នៃសាកលវិទ្យាល័យ
បញ្ញាសាស្ត្រកម្ពុជា

ទីតាំងធ្វើ ពុទ្ធិកបណ្ឌិត្យសភា

ការផ្សាយ របស់ពុទ្ធិកបណ្ឌិត្យសភា
នៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា


បោះពុម្ពលើកទី៨ ៣រោច ខែភទ្របទ ព.ស.២៥៦៥, គ.ស.២០២១

ចំនួនបោះពុម្ព ៣,០០០ ក្បាល



រក្សាសិទ្ធិ ពុទ្ធិកបណ្ឌិត្យសភា



លេខកូដសៀវភៅ ISBN ៩៧៨-៩៩៩៥០-៩៤៦-២-១

# សូមថ្វាយព្រះពរ
# ព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង
# ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
# ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា
# ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត

## បពិត្រព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង

*ក្នុងនាមទូលព្រះបង្គំផ្ទាល់ និងតំណាងសមាជិកសមាជិកា នៃពុទ្ធិក-បណ្ឌិត្យសភា នៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា សូមលំឱនកាយក្រាបបង្គំទូលថ្វាយ ព្រះសព្ទសាធុការពរ បវរមហាប្រសើរ និងប្រកបដោយសិរីសួស្តី ជយមង្គល វិបុលសុខគ្រប់ប្រការ ថ្វាយ* **ព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** *ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត ។*

*ទូលព្រះបង្គំ សូមថ្វាយព្រះរាជកុសល ដែលទូលព្រះបង្គំបានរៀបរៀងនូវសៀវភៅធម៌នេះ តម្កល់ទុកក្នុងព្រះពុទ្ធសាសនា ។ បពិត្រព្រះករុណា ជាអម្ចាស់ជីវិតតម្កល់លើត្បូង សូមព្រះករុណាជាអម្ចាស់ អនុមោទនានូវមហាកុសលនេះ ។ ដោយអំណាចគុណបុណ្យព្រះរតនត្រ័យ ទេវតាថែរក្សាព្រះមហាស្វេតច្ឆត្រ និងបារមី នៃអតីតៈព្រះមហាក្សត្រ ព្រះមហាក្សត្រិយានីគ្រប់ព្រះអង្គ ព្រមទាំងវត្ថុស័ក្តិសិទ្ធិទាំងឡាយក្នុងលោក អភិបាលថែរក្សា*

**ព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង ព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី** *ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត សូមព្រះអង្គទ្រង់មានព្រះរាជសុខភាពល្អបរិបូណ៌ ព្រះកាយ-ពលមាំមួន ព្រះជន្មយឺនយូរ ព្រះបញ្ញាញាណវាងវៃ និងគង់ប្រថាប់ជាម្លប់ដ៏ត្រជាក់ដល់ប្រជារាស្ត្រ ដើម្បីទទួលបាននូវសេចក្តីសុខក្សេមក្សាន្ត ចម្រើនរុងរឿងជានិច្ចនិរន្តរ៍តរៀងទៅ ។*

*សេចក្តីគួរពុំគួរ សូមព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត ទ្រង់ព្រះមេត្តាប្រោសព្រះរាជទានទោស ដោយព្រះរាជហឫទ័យដ៏ខ្ពង់ខ្ពស់បំផុត ៕*

*ក្រាបបង្គំទូលថ្វាយនៅរាជធានីភ្នំពេញ*

*ថ្ងៃ ១៥ កើត ខែ អាសាឍ ព.ស.២៥៥២*



កុល ផេង

**ប្រធានក្រុមប្រឹក្សាភិបាលពុទ្ធិកបណ្ឌិត្យសភា**

**នៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា**

## **សូមថ្វាយព្រះពរ**
## **ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**
## **និងសម្តេចព្រះមហាក្សត្រី នរោត្តម មុនីនាថ សីហនុ**
## **ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត**

បពិត្រព្រះករុណា និងសម្តេចព្រះមហាក្សត្រី ជាអម្ចាស់ជីវិតតម្កល់លើត្បូង

*ក្នុងនាមទូលព្រះបង្គំផ្ទាល់ និងតំណាងសមាជិកសមាជិកា នៃពុទ្ធិកបណ្ឌិត្យសភា នៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា សូមលំឱនកាយក្រាបបង្គំទូលថ្វាយ ព្រះសព្ទសាធុការពរ បវរមហាប្រសើរ និងប្រកបដោយសិរីសួស្តី ជយមង្គល វិបុលសុខគ្រប់ប្រការ ថ្វាយ* **ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ ព្រះមហាវីរក្សត្រ ព្រះវររាជបិតាឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ និងសម្តេចព្រះមហាក្សត្រី នរោត្តម មុនីនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល** *ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត ។*

*ទូលព្រះបង្គំ សូមថ្វាយព្រះរាជកុសល ដែលទូលព្រះបង្គំបានរៀបរៀងនូវសៀវភៅធម៌នេះតម្កល់ទុកក្នុងព្រះពុទ្ធសាសនា ។ បពិត្រព្រះករុណា និងសម្តេចព្រះមហាក្សត្រី ជាអម្ចាស់ជីវិតតម្កល់លើត្បូង សូមទ្រង់អនុមោទនានូវមហាកុសលនេះ ។ ដោយអំណាចគុណបុណ្យព្រះរតនត្រ័យ ទេវតាថែរក្សាព្រះមហាស្វេតច្ឆត្រ និងបារមី នៃអតីតៈព្រះមហាក្សត្រ ព្រះមហាក្សត្រិយានីគ្រប់ព្រះអង្គ ព្រមទាំងវត្ថុស័ក្តិសិទ្ធិទាំងឡាយក្នុងលោក អភិបាលថែរក្សា*

**ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ ព្រះមហាវីរក្សត្រ ព្រះវររាជបិតាឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ និង សម្តេចព្រះមហាក្សត្រី នរោត្តម មុនីនាថ សីហនុ ព្រះវររាជមាតា ជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និង សុភមង្គល** *ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត សូមព្រះអង្គទ្រង់មានព្រះរាជសុខភាពល្អបរិបូណ៌ ព្រះកាយពលមាំមួន ព្រះជន្មយឺនយូរ ព្រះបញ្ញាញាណវាងវៃ និងគង់ប្រថាប់ជាម្លប់ដ៏ត្រជាក់ដល់ប្រជារាស្ត្រ ដើម្បីទទួលបាននូវសេចក្តីសុខក្សេមក្សាន្ត ចម្រើនរុងរឿងជានិច្ចនិរន្តរ៍តរៀងទៅ ។*

*សេចក្តីគួរពុំគួរ សូម* **ព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង និងសម្តេចព្រះមហាក្សត្រី ព្រះវររាជមាតា** *ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត ទ្រង់ព្រះមេត្តាប្រោសព្រះរាជទានទោស ដោយព្រះរាជហឫទ័យដ៏ខ្ពង់ខ្ពស់បំផុត ៕*

*ក្រាបបង្គំទូលថ្វាយនៅរាជធានីភ្នំពេញ*

*ថ្ងៃ ១៥ កើត ខែ អាសាឍ ព.ស.២៥៥២*

**កុល ផេង**

**ប្រធានក្រុមប្រឹក្សាភិបាលពុទ្ធិកបណ្ឌិត្យសភា**

**នៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា**

**សូមគោរពជូន**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**

សម្តេចអគ្គមហាសេនាបតីតេជោ ជាទីគោរពដ៏ខ្ពង់ខ្ពស់

*តាងនាមសមាជិកសមាជិកាពុទ្ធិកបណ្ឌិត្យសភានៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា និងក្នុងនាមខ្ញុំបាទផ្ទាល់ និងភរិយាខ្ញុំបាទ សូមគោរពជូនបុណ្យកុសល និងសព្ទសាធុការពរ បវរមហាប្រសើរ សិរីសួស្តី ជយមង្គលវិបុលសុខគ្រប់ប្រការ ជូនចំពោះ* **សម្តេច** *និង* **លោកជំទាវ** *ជាទីគោរពដ៏ខ្ពង់ខ្ពស់ ។*

*ខ្ញុំបាទសូមគោរពជូនបុណ្យមហាកុសល ដែលខ្ញុំបាទព្យាយាមរៀបរៀងចងក្រងនូវសៀវភៅ "***មាគ៌ាជីវិតនៃព្រះពោធិសត្វ***" តម្កល់ទុកក្នុងព្រះពុទ្ធសាសនានេះ ។ សូម* **សម្តេច** *និង* **លោកជំទាវ** *មេត្តាទទួលអនុមោទនានូវមហាកុសលនេះ ។ ដោយតេជះគុណានុភាពនៃព្រះរតនត្រ័យ ទេវតាថែរក្សាព្រះមហាស្វេតច្ឆត្រ វត្ថុស័ក្តិសិទ្ធិក្នុងលោក ជួយបីបាច់ថែរក្សា និងប្រសិទ្ធពរជ័យជូន* **សម្តេច** *និង* **លោកជំទាវ** *ព្រមទាំង* **បុត្រា បុត្រី** *និង* **ចៅៗ** *ជាទីស្រឡាញ់របស់* **សម្តេច** *សូមមានជន្មាយុយឺនយូរ សុខភាពល្អបរិបូណ៌ បញ្ញាញាណវាងវៃ ដើម្បីដឹកនាំប្រទេសជាតិឆ្ពោះទៅរកត្រើយ*

សុខសន្តិភាព និងការអភិវឌ្ឍឱ្យសម្បូរសប្បាយរុងរឿង ជានិច្ចនិរន្តរ៍តរៀង ទៅ ។

ខ្ញុំបាទសូមកោតសរសើរដោយសុទ្ធចិត្តនូវវីរភាពដ៏អង់អាច របស់ **សម្តេច** ដែលបានបំពេញនូវបេសកកម្មដ៏លំបាក ក្នុងការស្វែងរកសេចក្តីសុខ ជូនចំពោះប្រជាពលរដ្ឋ និងការអភិវឌ្ឍ ក្នុងព្រះរាជាណាចក្រកម្ពុជាយើង ដើម្បីនាំមកនូវភាពចម្រើនរុងរឿងនាសម័យបច្ចុប្បន្ននេះ និងក្នុងអនាគតកាល ។

សូម **សម្តេចអគ្គមហាសេនាបតីតេជោ** និង **លោកជំទាវ** ប្រកបនូវសិរីមង្គល វិបុលសុខ មហាប្រសើរ ព្រមទាំងទទួលបាននូវធម៌ដ៏ប្រសើរ៥ប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ និងបដិភាណៈ កុំបីឃ្លៀងឃ្លាតឡើយ ៕

រាជធានីភ្នំពេញ

ថ្ងៃ ១៥ កើត ខែ អាសាឍ ព.ស.២៥៥២

**កុល ផេង**

**ប្រធានក្រុមប្រឹក្សាភិបាលពុទ្ធិកបណ្ឌិត្យសភា**

**នៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា**

# អនុមោទនាបោះពុម្ពផ្សាយ

*ពុទ្ធិកបណ្ឌិត្យសភា នៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា បានចាត់ចែងបោះពុម្ពសៀវភៅជាច្រើនកន្លងមកហើយ ។*

*នេះជាអត្ថបទមួយកម្រកេបាន ដែលបានរៀបរៀងចងក្រងដោយលោកបណ្ឌិត* **កាុល ផេង** *ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និងកីឡា និងជាប្រធានពុទ្ធិកបណ្ឌិត្យសភានៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា ។*

*ពុទ្ធិកបណ្ឌិត្យសភា បោះពុម្ពសៀវភៅនេះឡើង ដោយមានគោលបំណង :*

- *ជំនួយដល់ការសិក្សាស្វែងយល់ពីជីវិតព្រះពោធិសត្វ*
- *ជាថ្នាលបណ្តុះពោធិចិត្ត ដើម្បីស្វែងរកសេចក្តីសុខ*
- *ជាគោលប្រតិបត្តិនាំមកនូវសុខសន្តិភាព សុភមង្គលដល់ពុទ្ធសាសនិកជន*
- *ថែរក្សាមត៌កព្រះពុទ្ធសាសនាឱ្យគង់វង្ស ។*

*សមាជិក សមាជិកា នៃពុទ្ធិកបណ្ឌិត្យសភា សូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅបំផុត ចំពោះលោកបណ្ឌិត* **កាុល ផេង** *ដែលមាននូវវិរិយៈយ៉ាងអង់អាច ក្នុងការចងក្រងនូវសៀវភៅនេះ ។*

*សូមលោកបណ្ឌិត និងក្រុមគ្រួសារ បានប្រសព្វនូវសេចក្តីសុខសេចក្តីចម្រើន ជានិច្ចនិរន្តរ៍តរៀងទៅ ។*

*សូមលោកបណ្ឌិត មេត្តាទទួលនូវសេចក្តីគោរពដ៏ខ្ពង់ខ្ពស់ ប្រកបដោយសេចក្តីស្រឡាញ់ដ៏ស្មោះ និងកតញ្ញូតាធម៌ ពីសមាជិក សមាជិកា នៃពុទ្ធិកបណ្ឌិត្យសភា ៕*

*ថ្ងៃ ១៥ កើត ខែ អាសាឍ ព.ស.២៥៥២*

*តំណាងសមាជិក សមាជិកា*

*នៃពុទ្ធិកបណ្ឌិត្យសភា*

**ធម្មានន្ទ ទ៉ាន់ ចាន់សារ៉េន**

**អគ្គលេខាធិការពុទ្ធិកបណ្ឌិត្យសភា**

# អារម្ភកថា

មនុស្សសត្វទាំងឡាយ ដែលកើតមកលើលោកនេះ តែងប្រាថ្នាចង់បានសេចក្តីសុខជានិច្ច ។ គ្រប់រូបតែងមានសេចក្តីភ័យខ្លាច និងតក់ស្លុតរន្ធត់ញាប់ញ័រជាខ្លាំង នៅពេលប្រឈមមុខជាមួយគ្រោះថ្នាក់ ជាពិសេសចំពោះក្តីមរណៈ ។

អាស្រ័យហេតុនេះ បានជាព្រះសម្មាសម្ពុទ្ធបរមគ្រូ បានណែនាំឱ្យមនុស្សយើង រកស៊ីដោយសុចរិតត្រឹមត្រូវ ប្រព្រឹត្តតែកុសលធម៌ ចៀសវាងអំពើបាបកម្មគ្រប់បែបយ៉ាង ហើយខំព្យាយាមសម្អាតចិត្តបន្តិចម្តងៗ ដើម្បីស្វែងរកសេចក្តីសុខ ប្រចាំជីវិតលោកិយ ។ ការសម្អាតចិត្តរបស់យើងម្នាក់ៗត្រូវចាប់ផ្តើមឡើង ដោយការសមាទានសីល ដែលជាវិន័យដ៏ប្រពៃបំផុតសម្រាប់ឱ្យមនុស្សយើងត្រួតកាយ វាចា ចិត្តរបស់យើង ។

ឋានមនុស្សលោក ជាឋានមួយដែលប្រកបដោយទុក្ខផង សុខផង ។ បើបុគ្គលណា ប្រកបដោយបញ្ញា ហើយបានសាងបុញ្ញកម្មច្រើន បុគ្គលនោះក៏ជួបប្រទះនឹងសេចក្តីសុខច្រើន ។ ផ្ទុយទៅវិញ អ្នកដែលប្រព្រឹត្តអំពើអកុសលកម្ម អបាយមុខ ហើយខ្វះបញ្ញា មិនយល់ដឹងច្បាស់នូវអ្វីដែលជាគុណ អ្វីជាទោស អ្វីខុស អ្វីត្រូវ បុគ្គលនោះនឹងទទួលបាននូវសេចក្តីទុក្ខច្រើនជាងសេចក្តីសុខក្នុងជីវិតរបស់ខ្លួន ។

សេចក្តីទុក្ខរបស់មនុស្សលោក កើតមានព្រោះតណ្ហា គឺសេចក្តីប្រាថ្នា និងការជាប់ជំពាក់ ដែលមានអវិជ្ជាជាប្រធាន ។ ដោយសេចក្តីប្រាថ្នា

មិនបានសម្រេចនេះហើយ បានជាកើតមានរឿងក្តៅក្រហាយ ច្រណែន ឈ្នានីស ស្អប់ខ្ពើម គុំកួនគ្នា ។ល។ ហេតុនេះហើយ បានជាមនុស្សឈ្លោះគ្នា ដណ្តើមអំណាច កិត្តិយស និងទ្រព្យសម្បត្តិគ្នា ដោយកំណត់ថាជារបស់ រៀងៗខ្លួន រហូតដល់មានចម្បាំង រវាងនគរនិងនគរ ជម្លោះរវាងឪពុកម្តាយ និងកូន រវាងបងនិងប្អូន ព្រមទាំងមិត្តនិងមិត្តជាដើម ។ ម្យ៉ាងទៀត ការជាប់ជំពាក់ និងសេចក្តីស្រឡាញ់ ការព្រាត់ប្រាសនិរាសពីអ្នកជាទីស្រឡាញ់ ឬ របស់ជាទីស្រឡាញ់ ក៏ជាប្រភពនាំមកនូវសេចក្តីទុក្ខដែរ ។ ទាំងអស់នេះ មនុស្សលោកសុទ្ធតែប្រឈមមុខជាមួយនឹងអវិជ្ជា ។

ដោយការបំពេញនូវតណ្ហាមិនបានគ្រប់គ្រាន់ ជាមួយនឹងការជាប់ជំពាក់ចិត្តនេះហើយ ជាដើមហេតុនាំឱ្យសត្វលោកកើត ហើយស្លាប់ រួចត្រឡប់មកកើតវិញ និងកើតហើយស្លាប់វិញ បន្តគ្នាគ្មានទីបំផុត ដែលព្រះសម្មា-សម្ពុទ្ធសម្តែងថា នេះជាដំណើរឆ្លងកាត់សេចក្តីទុក្ខក្នុងវាលវដ្តសង្សារ ។

ដើម្បីរួចផុតចាកពីទុក្ខក្នុងវដ្តសង្សារនេះ ទើបព្រះសម្មាសម្ពុទ្ធទ្រង់ស្វែងរកសេចក្តីត្រាស់ដឹង ឆ្ពោះទៅកាន់ទីបរមសុខជាអមតៈ គឺព្រះនិព្វាន នេះឯង ។

សៀវភៅមាគ៌ាជីវិតនៃព្រះពោធិសត្វនេះ រៀបរៀងឡើងក្នុងគោលបំណង បង្ហាញមាគ៌ាឆ្ពោះទៅកាន់ទីបរមសុខ ដែលព្រះពោធិសត្វ លោកបានឆ្លងកាត់រួចមកហើយ ដើម្បីជាគំរូសម្រាប់យើងទាំងអស់គ្នា ។

បារមីធម៌ដែលព្រះសម្មាសម្ពុទ្ធ ទ្រង់បានអនុវត្តរួចមកហើយនេះ ជាមាគ៌ាដ៏ប្រសើរមួយ សម្រាប់ជីវិតមនុស្សយើង ក្នុងការយកមកប្រតិបត្តិតាម ដើម្បីស្វែងរកសេចក្តីសុខប្រចាំជីវិតបច្ចុប្បន្នផង និងជីវិតអនាគតកាលផង ទោះបីនៅពេលនេះ យើងពុំទាន់បានបណ្តុះពោធិចិត្តនៅឡើយក៏ដោយ ។

**សព្វេ សត្តា អវេរិនោ ហោន្តុ**

*សូមសត្វលោកទាំងឡាយទាំងពួងកុំមានពៀរនឹងគ្នា*

**សព្វេ សត្តា ខេមិនោ ហោន្តុ**

*សូមសត្វលោកទាំងឡាយទាំងពួងបានដល់នូវសេចក្តីក្សេម*

**សព្វេ សត្តា សុខិនោ ហោន្តុ**

*សូមសត្វលោកទាំងឡាយទាំងពួងបានប្រកបដោយសេចក្តីសុខជានិច្ចនិរន្តរ៍!*

*ថ្ងៃ ព្រហស្បតិ៍ ១៥ កើត ខែ អាសាឍ ព.ស.២៥៥២*

*ត្រូវនឹងថ្ងៃទី ១៧ ខែ កក្កដា គ.ស.២០០៨*

**កាុល ផេង**

*ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា*

*និងជាប្រធានក្រុមប្រឹក្សាភិបាលពុទ្ធិកបណ្ឌិត្យសភា*

*នៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា*

# សេចក្ដីថ្លែងកតញ្ញូតាធម៌

ក្នុងការរៀបរៀងសៀវភៅ "**មាគ៌ាជីវិតនៃព្រះពោធិសត្វ**" នេះ ខ្ញុំសូមសម្ដែងនូវកតញ្ញូតាធម៌ និងអំណរគុណដ៏ជ្រាលជ្រៅ ចំពោះលោកអ្នកមានគុណដូចខាងក្រោម :

- ខ្ញុំសូមលើកអញ្ជលី លំឱនកាយគោរពដល់លោកអ្នកដ៏មានគុណរបស់ខ្ញុំគឺ អ្នកម្ដាយឧបាសិកា **ម៉ែន ឡាប់** និង លោកឪពុកធម្មាចារ្យ **ក្រុល ឆាង** ដែលបានបង្កើត ចិញ្ចឹម បីបាច់ថែរក្សា ផ្ដល់នូវសេចក្ដីស្រឡាញ់ ប្រកបដោយព្រហ្មវិហារធម៌ និងអប់រំរូបខ្ញុំឱ្យបានរៀនសូត្រត្រឹមត្រូវតាមគន្លងព្រះពុទ្ធសាសនា ។
- ខ្ញុំសូមលើកអញ្ជលី លំឱនកាយគោរពដល់លោកអ្នកដ៏មានគុណរបស់ខ្ញុំ គឺអ្នកម្ដាយមហាឧបាសិកា **ឧត្តមា ពេជ្រ អូន** និងលោកឪពុកឧបាសក **គឹម ស៊ុមន៍** ដែលបានចិញ្ចឹម ផ្ដល់សេចក្ដីស្រឡាញ់ អប់រំដល់ខ្ញុំឲ្យបានរៀនសូត្រត្រឹមត្រូវតាមគន្លងព្រះពុទ្ធសាសនា ។
- ខ្ញុំសូមលើកអញ្ជលី លំឱនកាយគោរពដល់គ្រូទាំងឡាយរបស់ខ្ញុំ ដែលបានបង្រៀនខ្ញុំខាងផ្លូវលោកក្ដី ផ្លូវធម៌ក្ដី តាំងពីតូចរហូតដល់បច្ចុប្បន្ន រួមទាំងកវី អ្នកនិពន្ធ និងអ្នកប្រាជ្ញ ព្រមទាំងទស្សនវិទូធំៗ

ក្នុងលោក ដែលខ្ញុំបានសិក្សាពីថ្ងៃដែរបស់លោក និងទទួលឱវាទ ដែលជាមាគ៌ាដ៏ល្អប្រចាំជីវិតរបស់ខ្ញុំ ។

- ក្នុងឋានៈខ្ញុំជាប្អូនពៅ ខ្ញុំសូមសម្តែងនូវអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះបងស្រី និងបងប្រុសទាំងអស់ ដែលបានផ្តល់នូវសេចក្តីស្រឡាញ់ និងករុណាធម៌ ហើយផ្តល់ឱកាសឱ្យខ្ញុំបានសិក្សារៀនសូត្រអស់ពេលវេលាយូរជាងបងៗទាំងអស់ ដែលជាប់ទទួលបន្ទុកកិច្ចការគ្រួសារជាមួយឪពុកម្តាយជាទីស្រឡាញ់ ។
- ខ្ញុំសូមសម្តែងនូវអំណរគុណយ៉ាងជ្រាលជ្រៅបំផុត ចំពោះភរិយាជាទីស្រឡាញ់ **ភុល ភឹមផល្លា** ព្រមទាំងបុត្រ និងចៅៗទាំងអស់ ដែលតែងតែផ្តល់នូវកម្លាំងចិត្ត សេចក្តីស្រឡាញ់ដល់ខ្ញុំគ្រប់ពេលវេលាគ្រប់សកម្មភាពក្នុងជីវិតរបស់ខ្ញុំ ។
- ខ្ញុំសូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅ ចំពោះលោកគ្រូ **ធម្មានន្ទ វ៉ាន់ចាន់សារ៉េន** អគ្គលេខាធិការនៃពុទ្ធិកបណ្ឌិត្យសភា នៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា ដែលបានយកចិត្តទុកដាក់ជាទីបំផុត ក្នុងការជួយពិនិត្យនូវអត្ថបទដើម ផ្តល់យោបល់ និងជួយស្រាវជ្រាវឯកសារគោលជាមូលដ្ឋានមួយចំនួន ហើយលោកបានជំរុញឱ្យការរៀបរៀងសៀវភៅមាគ៌ាជីវិតនៃព្រះពោធិសត្វនេះ បានចប់ជាស្ថាពរ ។

- ជាមួយគ្នានេះដែរ ខ្ញុំសូមថ្លែងអំណរគុណដល់ក្រុមប្រឹក្សាភិបាល និង បុគ្គលិកនៃពុទ្ធិកបណ្ឌិត្យសភាទាំងអស់ ដែលបានជួយជ្រោមជ្រែង ក្នុងការរៀបរៀងសៀវភៅនេះ ជាពិសេសក្នុងការយកចិត្តទុកដាក់ ជួយបំពេញបេសកកម្មរបស់ពុទ្ធិកបណ្ឌិត្យសភា ។
- ខ្ញុំសូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅ ចំពោះចៅ **ហន សុខេមន្ទ** លេខាធិការរបស់ខ្ញុំ ដែលខំយកចិត្តទុកដាក់ ប្រកបដោយក្ដីអំណត់ និងការព្យាយាមដ៏មុឺងម៉ាត់ ជួយផ្នែកបច្ចេកទេសកុំព្យូទ័រ ក្នុងការ រៀបរៀងសៀវភៅនេះ លុះបានចប់ជាស្ថាពរ ។
- ខ្ញុំសូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅ ដល់លោក **ជីវ រដ្ឋា** នាយក ខុទ្ទកាល័យរបស់ខ្ញុំ នៅក្រសួងអប់រំ យុវជន និង កីឡា ដែលបាន ផ្ដៀតឱកាសដ៏មមាញឹកក្នុងការបំពេញតួនាទីរបស់ខ្លួន ជួយផ្ទៀង ផ្ទាត់អក្ខរាវិរុទ្ធ និងពាក្យពេចន៍ នៅក្នុងជំពូកមាលាជាតក ។
- ខ្ញុំសូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅ ចំពោះសហការី និងមិត្រភក្ដិជា ច្រើនទៀត ដែលបានលើកទឹកចិត្ត និងផ្ដល់ការពិភាក្សា ផ្លាស់ប្ដូរ ទស្សនៈក្នុងការរស់នៅជាមនុស្សលោក មានជាអាទិ៍: លោកធម្មាចារ្យ **ដាំ កុយ**, បណ្ឌិត **ជា សានច័ន្ទថន**, លោក **អ៊ូ សំអាន**, បណ្ឌិត **សំ សំអាច**, បណ្ឌិត **ប៉ក់ ថាវិន**, និងសាស្ត្រាចារ្យ **ម៉ក់ វ៉ាន់** ជាដើម ។

- ខ្ញុំសូមថ្លែងអំណរគុណដល់ដាផគំនូរ និងនិស្សិតរបស់ខ្ញុំគឺ **ហ៊ឹម ឆវ័ន**, **គឹម ច័ន្ទត្រាបុត្រ** និងកញ្ញា **លឹម ផាន់នី** ដែលបានរចនាយ៉ាង ប្រណីត នូវក្របសៀវភៅមាត់ាជីវិតនៃព្រះពោធិសត្វនេះ ។
- ខ្ញុំសូមថ្លែងអំណរគុណចំពោះសហការីរបស់ខ្ញុំ គឺលោកធម្មាចារ្យ **ទិព្វ សៅ** ដែលបានជួយត្រួតពិនិត្យកែអក្ខរាវិរុទ្ធចុងក្រោយម្តងទៀត និងជួយ Convert ពីអក្សរ Limon ទៅជា Khmer Unicode ដើម្បីងាយ ស្រួលដល់ការរៀបចំបោះពុម្ពលើកក្រោយៗទៀត។
- ទោះបីមានការជួយជ្រោមជ្រែងគាំទ្រពីសហការី និងមិត្តភក្តិដ៏ច្រើន យ៉ាងនេះក្តី ខ្ញុំនៅតែមានក្តីបារម្ភក្នុងការខុសឆ្គង លើសលស់ ខ្វះខាត លើអត្ថន័យ និងការប្រើប្រាស់ពាក្យពេចន៍ទាំងអស់ក្នុងសៀវភៅនេះ។ ការខុសឆ្គងទាំងប៉ុន្មាន ដែលកើតមានដោយអចេតនា គឺជាកំហុស របស់ខ្ញុំផ្ទាល់ ។
- ខ្ញុំសូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅ ចំពោះព្រះសង្ឃ ឧបាសក ឧបាសិកា និស្សិត សិស្សានុសិស្សទាំងឡាយ ដែលយកចិត្តទុកដាក់ តាមដានស្តាប់ "កម្មវិធីអប់រំយុវជន តាមគន្លងព្រះពុទ្ធសាសនា" និង "កម្មវិធីមង្គលជីវិតតាមគន្លងព្រះពុទ្ធសាសនា" របស់ពុទ្ធិកបណ្ឌិត្យ-សភា ដែលផ្សាយតាមវិទ្យុជារៀងរាល់ថ្ងៃ ហើយបានរួមវិភាគទាន

បច្ច័យក្នុងការបោះពុម្ពផ្សាយជាធម្មទាន នូវសៀវភៅ "**មាគ៌ាជីវិតនៃព្រះពោធិសត្វ**" នេះ ។

នៅអវសានកថានេះ ខ្ញុំសូមប្រមូលនូវបុណ្យកុសលដែលបានសម្រេចហើយ ដោយការបោះពុម្ពសៀវភៅនេះ ជូនចំពោះអ្នកដ៏មានគុណទាំងអស់ និងជូនចំពោះភរិយាដ៏ឧត្តមរបស់ខ្ញុំ ព្រមទាំងកូន និងចៅៗជាទីស្រឡាញ់ ព្រមទាំងសហការី មិត្រភក្តិ សមាជិកសមាជិកានៃពុទ្ធិកបណ្ឌិត្យសភា និងពុទ្ធបរិស័ទគ្រប់រូប ជួបប្រទះនូវធម៌ដ៏ប្រសើរ ៤ ប្រការគឺ អាយុ វណ្ណៈ សុខៈ និង ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ហើយសូមបានជាឧបនិស្ស័យនៃបញ្ញា និងសេចក្តីសុខក្នុងសង្សារវដ្ត រហូតបានដល់ត្រើយបរមសុខដ៏ប្រសើរ គឺព្រះនិព្វាន ក្នុងដ៏អនាគតកាលទៅហោង ។

ពីខ្ញុំព្រះករុណា ខ្ញុំបាទ

**កាុល ផេង**

# មាតិកានុក្រម

## ជំពូកទី១

## ព្រះពោធិសត្វ និង ពោធិចិត្ត

ព្រះពោធិសត្វ និង ពោធិចិត្ត........................................................ ១

តើអ្វីទៅដែលហៅថា ពោធិចិត្ត?................................................... ២

តើអ្វីទៅជា បារមី? ................................................................. ៤

## ជំពូកទី២

## អដ្ឋសមោធាន

អដ្ឋសមោធាន .......................................................................... ៩

បច្ច័យ ៤ យ៉ាង.......................................................................... ១២

ហេតុ ៤  យ៉ាង .........................................................................១៥

ពលៈ ៤ យ៉ាង ..........................................................................១៦

## ជំពូកទី៣

## ចិរវេលាសុមេធបណ្ឌិតពោធិសត្វបំពេញពុទ្ធការកធម៌

ក. ចិរវេលាសុមេធបណ្ឌិតពោធិសត្វបំពេញពុទ្ធការកធម៌ ១៦ អសង្ខេយ្យ

ជាអនិយតពោធិសត្វ.............................................................. ២៣

១- មនោបណិធាន................................................................ ២៣

២- វចីបណិធាន ........................................................... ២៥
៣- កាយវចីមនោបណិធាន ................................................... ២៨
ខ. ព្រះពោធិសត្វបំពេញបារមី ៤ អសង្ខេយ្យ ជានិយតពោធិសត្វ........ ២៨
គ. ព្រះពោធិសត្វបំពេញបារមី ១ សែនកប្ប ជានិយតពោធិសត្វ.........៣១

## ជំពូកទី ៤

## សុមេធបណ្ឌិត និងការប្រកាសអភិនីហារ

១. សុមេធបណ្ឌិតចេញសាងផ្នួស.............................................. ៣៩
២. ព្រះសម្មាសម្ពុទ្ធទីបង្ករ ទ្រង់ត្រាស់ដឹងក្នុងលោក ..........................៤៥
៣. សុមេធបណ្ឌិត ទទួលព្យាករណ៍ និងប្រកាសអភិនីហារ ................៤៦
៤. បុព្វនិមិត្ត...........................................................................៥៥
៥. សុមេធតាបសអង្គុយពិចារណានូវពុទ្ធការកធម៌.......................... ៦២

## ជំពូកទី ៥

## ការសាងទសបារមី

ការសាងទសបារមី ..............................................................៧៥
១- ទានបារមី....................................................................... ៧៧
២- សីលបារមី....................................................................... ៨៨
៣- នេក្ខម្មបារមី.................................................................... ៩៣
៤- បញ្ញាបារមី ...................................................................... ៩៥

៥- វីរិយបារមី ............................................................ ១០០
៦- ខន្តិបារមី ............................................................ ១០៤
៧- សច្ចបារមី ............................................................ ១០៧
៨- អធិដ្ឋានបារមី ............................................................ ១០៩
៩- មេត្តាបារមី ............................................................ ១១៤
១០-ឧបេក្ខាបារមី ............................................................ ១១៦
លក្ខណាទិចតុក្កៈ ............................................................ ១២០
១. លក្ខណាទិចតុក្កៈនៃទានបារមី ............................................................ ១២០
២. លក្ខណាទិចតុក្កៈនៃសីលបារមី ............................................................ ១២១
៣. លក្ខណាទិចតុក្កៈនៃនេក្ខម្មបារមី ............................................................ ១២១
៤. លក្ខណាទិចតុក្កៈនៃបញ្ញាបារមី ............................................................ ១២២
៥. លក្ខណាទិចតុក្កៈនៃវីរិយបារមី ............................................................ ១២៣
៦. លក្ខណាទិចតុក្កៈនៃខន្តិបារមី ............................................................ ១២៣
៧. លក្ខណាទិចតុក្កៈនៃសច្ចបារមី ............................................................ ១២៤
៨. លក្ខណាទិចតុក្កៈនៃអធិដ្ឋានបារមី ............................................................ ១២៤
៩. លក្ខណាទិចតុក្កៈនៃមេត្តាបារមី ............................................................ ១២៥
១០.លក្ខណាទិចតុក្កៈនៃឧបេក្ខាបារមី ............................................................ ១២៥
កំណត់ហេតុអ្នកនិពន្ធ ក្នុងការសាងបារមី ............................................................ ១២៧
ទសពលញ្ញាណ ១០ ............................................................ ១២៧
ទសកាយពល ១០ ............................................................ ១៣០

វេសិតា ១០ ............................................................................................ ១៣១

## ជំពូកទី ៦

## ព្រះពោធិសត្វក្នុងអត្តភាពជាព្រះសម្មាសម្ពុទ្ធសមណគោតម

## និមិត្ត ៣២ ប្រការ

ព្រះពោធិសត្វក្នុងអត្តភាពជាព្រះសម្មាសម្ពុទ្ធសមណគោតម ..........១៣៥
និមិត្ត ៣២ ប្រការ......................................................................... ១៣៧
ធម្មនិយាមនៃព្រះពោធិសត្វ..............................................................១៤១
ព្រះពោធិសត្វប្រសូត......................................................................១៤៤
ព្រះពោធិសត្វឃើញទេវទូតទាំង ៤ ....................................................១៥១
ព្រះពោធិសត្វទ្រង់ចេញសាងព្រះផ្នួស .................................................១៥៩
ការបំពេញពុទ្ធកិច្ច..........................................................................១៦៣
កិច្ចក្នុងបុរេភត្ត.............................................................................១៦៤
កិច្ចក្នុងបច្ឆាភត្ត ...........................................................................១៦៦
កិច្ចក្នុងបឋមយាម .........................................................................១៦៦
កិច្ចក្នុងមជ្ឈិមយាម...................................................................... ១៦៧
កិច្ចក្នុងបច្ឆិមយាម ...................................................................... ១៦៧
ប្រតិទិនឆ្នាំព្រះពុទ្ធ........................................................................ ១៧២

## ជំពូកទី ៧

## ព្រះពុទ្ធមេត្តេយ្យ ឬ ព្រះស្រីអារ្យមេត្រី

១. ព្រះស្រីអារ្យមេត្រីត្រាស់ដឹងក្នុងលោក........................................ ១៧៥
២. អតីតជាតិនៃព្រះពោធិសត្វមេត្តេយ្យ ...........................................១៨៤

## ជំពូកទី ៨

## មាលាជាតក

១. សកុណជាតក..........................................................................១៩៩
២. សម្មោទមានជាតក ...................................................................២០២
៣. វដ្តកជាតក ...........................................................................២០៩
៤. មហោសថជាតក (ដោះស្រាយបញ្ហាស្ត្រីពីរនាក់ដណ្ដើមកូន) .. ២១៧
៥. ពានរពារាណសី (មហាកបិជាតក)......................................... ២២៥
៦. អម្ពជាតក ............................................................................២៣៧
៧. ប្រើសមាសសង្គ្រោះជីវិតព្រះបាទព្រហ្មទត្ត..............................២៤៣
៨. មហាពាណិជជាតក ................................................................២៤៧
៩. សុវណ្ណហំសជាតក....................................................................២៥៤
១០. ភិក្ខុនីមានគភ៌ .....................................................................២៦០
និគ្រោធមិគរាជជាតក ...........................................................២៦៦
១១. វណ្ណុបថជាតក ....................................................................... ២៧៥
ធ្វូងផ្លូវខ្សាច់មរណៈ ...............................................................២៧៩
១២. កុក្កុរជាតក (សុនខស្វែងរកយុត្តិធម៌).......................................... ២៨៣
១៣. មហាកបិជាតក (ពានរសង្គ្រោះជីវិតមនុស្សរមិលគុណ) .......... ២៩៤

១៤. សុវណ្ណមិគជាតក (ភក្តីភាព)................................................... ២៩៩
១៥. ខន្តិវាទីជាតក................................................................... ៣០៤
១៦. ផលជាតក......................................................................... ៣១២
១៧. រឿងមាតុបោសកភិក្ខុ (ភិក្ខុកតញ្ញូ)........................................... ៣១៦
សាលិកេទារជាតក (សត្វសេកកតញ្ញូ).......................................... ៣១៨


## ឧបសម្ពន្ធ


ក. ធម៌ជំពូកទី ១ ទសពិធរាជធម៌................................................ ៣២៦
ខ. ធម៌ជំពូកទី ២ ការបំពេញនូវភារកិច្ចរបស់ស្តេចចក្រពត្តិ........ ៣៣១
គ. ធម៌ជំពូកទី ៣ ការអនុវត្តនូវសង្គហធម៌របស់អ្នកដឹកនាំ.......... ៣៣៤
ឃ. ធម៌ជំពូកទី ៤ រាជសង្គហវត្ថុ ៤ របស់អ្នកដឹកនាំ.................... ៣៣៥
ង. ធម៌ជំពូកទី ៥ ការជៀសវាងអគតិធម៌ ៤............................... ៣៣៦
សេចក្តីអធិប្បាយអំពីអសង្ខេយ្យ និងកប្ប.......................................... ៣៣៧
កប្បមាន ៤ យ៉ាង..................................................................... ៣៤២
បទសិក្សាពិចារណា.................................................................... ៣៤៨
ពុទ្ធវង្សតារាងទី១..................................................................... ៣៥៤
អង្គ ៦ របស់បណ្ឌិត.................................................................. ៣៦៥
ពុទ្ធគុណសម្រាប់សូត្ររំលឹកបារមីក្នុងពិធីអភិសេកពុទ្ធប្បដិមា.......... ២៦៧
ឯកសារពិគ្រោះ........................................................................ ៣៧១

*សូមឧទ្ទិសបុណ្យកុសលដែលកើតមានឡើង*

*ដោយការព្យាយាមរៀបរៀងសៀវភៅ*

**មាគ៌ាជីវិតនៃព្រះពោធិសត្វ**

*ចំពោះ*

*មាតាបិតាទាំងឡាយក្នុងលោក ដែលកំពុងស្ថិត*

*នៅក្នុងវដ្តសង្សារ សូមឱ្យបានឆ្លងទៅដល់*

*ត្រើយបរមសុខដ៏កំពូល គឺព្រះនិព្វាន ។*

# អក្សរសង្ខេប និងឈ្មោះគម្ពីរ

*សូមបញ្ជាក់ចំពោះអ្នកអានទាំងឡាយមេត្តាជ្រាបថា **លេខដែលប្រើខាងមុខជាលេខក្បាលគម្ពីរ លេខដែលប្រើខាងក្រោយជាលេខទំព័រ** ដូចជា **សុត្តន្ត. ខុទ្ទក. ធម្ម.៩២/៦០** អានថា **សុត្តន្តបិដក ខុទ្ទកនិកាយ ធម្មបទលេខ ៩២ ទំព័រ ៦០** សូម្បីនៅក្នុងអដ្ឋកថា ដីកា ក៏ដូចគ្នា ។ គម្ពីរតម្រាណា ជាសៀវភៅបាលីខ្មែរ បានបោះពុម្ពរួចស្រេចហើយ ខ្ញុំអាងដល់គម្ពីរតម្រានោះ តែគម្ពីរណាដែលខ្មែរមិនទាន់បានបោះពុម្ពទេ ខ្ញុំអាងគម្ពីរ ច្បាប់ពុទ្ធិកបណ្ឌិត្យសភា នៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា ជាគ្រឿងសាធកៈក្នុងសៀវភៅនេះ ។*

| **អានិសង្ខេត** | **ពាក្យពេញ** |
|---|---|
| *-សុត្តន្ត.* | *សុត្តន្តបិដក* |
| *-ខុទ្ទក.* | *ខុទ្ទកនិកាយ* |
| *-ធម្ម.* | *ធម្មបទ* |
| *-ពុទ្ធ.* | *ពុទ្ធវំស* |
| *-ចរិយា.* | *ចរិយាបិដក* |

# ពុទ្ធភាសិត

យោ សហស្សំ សហស្សេន សង្គាមេ មានុសេ ជិនេ
ឯកញ្ច ជេយ្យមត្តានំ ស វេ សង្គាមជុត្តមោ ។

*អ្នកណាឈ្នះពួកមនុស្សក្នុងសង្គ្រាម អស់មួយពាន់ៗដង គឺមួយលាន បំណែកអ្នកណាឈ្នះខ្លួនឯងម្នាក់ឯងបាន អ្នកនោះឈ្មោះថាជាមនុស្សខ្ពង់ខ្ពស់ ជាងអ្នកដែលឈ្នះក្នុងសង្គ្រាមនោះ ។*

(*សុត្តន្ត.ខុទ្ទក.៥២/៤៤*)

ទិវា តបតិ អាទិច្ចោ រត្តិមាភាតិ ចន្ទិមា
សន្នទ្ធោ ខត្តិយោ តបតិ ឈាយី តបតិ ព្រាហ្មណោ
អថ សព្វមហោរត្តឹ ពុទ្ធោ តបតិ តេជសា ។

*ព្រះអាទិត្យរុងរឿងក្នុងវេលាថ្ងៃ ព្រះចន្ទរុងរឿងក្នុងវេលាយប់ ក្សត្រទ្រង់ប្រដាប់ពេញយសហើយ រមែងរុងរឿង សមណព្រាហ្មណ៍អ្នកមានឈាន រមែងរុងរឿង ឯព្រះសម្ពុទ្ធ រមែងរុងរឿងដោយតេជះរហូតថ្ងៃនិងយប់ទាំងអស់ ។*

(*សុត្តន្ត.ខុទ្ទក.៥២/១០៣*)

# រតនត្តយបណាមគាថា

កុលមលពាដកាញ្ច    កុលវិប្បយុត្តំ ជត្វា

កុលពាដកសារកំ    កុល ផេង ជាមិកោហំ ។

ពុទ្ធិកបណ្ឌិត្យសភាយាភិចាលកណាជាយកោ

មាតាជីវិតព្រះពោធិសត្វជាមិកាចោត្តកំ  លិខេ ។

*ខ្ញុំព្រះអង្គនាមថា* កុល ផេង *ជាប្រធានក្រុមប្រឹក្សាភិបាលនៃពុទ្ធិកបណ្ឌិត្យសភា សូមនមស្ការចំពោះព្រះពុទ្ធជាម្ចាស់ ដែលព្រះអង្គទ្រង់កម្ចាត់បង់នូវមន្ទិល គឺត្រកូលនៃកិលេស និងសូមនមស្ការចំពោះព្រះធម៌ ដែលមិនប្រកបដោយត្រកូលនៃកិលេស ព្រមទាំងព្រះអរិយសង្ឃ ដែលជាសាវ័កនៃព្រះពុទ្ធ ដែលបានកម្ចាត់បង់នូវត្រកូលនៃកិលេសនោះ ហើយនឹងរៀបរៀងចងក្រងនូវសៀវភៅមាគ៌ាជីវិតនៃព្រះពោធិសត្វ ដូចតទៅ ។*

តមុជ្ជិន្ទសុទ្ធជម្ម-    កណ្ហាត្តមានុភាវេន

វិនស្សន្តុ យថាក្កមំ    ទុក្ខភយរោគា ហោ ។

*អានុភាពពុទ្ធរ័ត្នកម្ចាត់ទុក្ខ    នាំឱ្យកើតសុខសិរីក្សេមក្សាន្ត*

*អានុភាពធម្មរ័ត្នកម្ចាត់បាន    នូវក្តីរំខានក្សាន្តចាកភ័យ ។*

*អានុភាពសង្ឃរ័ត្នកម្ចាត់រោគ    ឱ្យអស់វិយោគទុក្ខចង្រៃ*

*អានុភាពត្រៃរ័ត្នវិសេសថ្លៃ    នាំសុខសួស្តីសព្វៗកាល ។*

តតោ មយ្ហំ បរក្កមា មយ្ហញ្ច សត្តានំ ហោតុ
អរិយមេត្តេយ្យស្ស សន្តិកេ អមតមច្ចុតំ ។

*ដោយអំណាចសេចក្តីព្យាយាមក្នុងការរៀបរៀងសៀវភៅរបស់ខ្ញុំនេះ ខ្ញុំសូមប្រាថ្នាគ្រប់ៗជាតិទៅអនាគត ឱ្យបានបំពេញនូវកុសលធម៌ លុះបានសម្រេចនូវបញ្ញាដ៏កំពូលលើលោក ហើយសូមឱ្យខ្ញុំបានជួបថ្វាយបង្គំព្រះពុទ្ធអរិយមេត្តេយ្យ កុំបីអាក់ខានឡើយ ។ សូមសព្វសត្វទាំងឡាយ បានសម្រេចនូវអមតធម៌ គឺព្រះនិព្វាន ក្នុងសំណាក់នៃព្រះពុទ្ធអរិយមេត្តេយ្យ ឬព្រះពុទ្ធអង្គណាមួយ ក្នុងអនាគតកាល កុំបីអាក់ខានឡើយ ៕*

# ជំពូកទី ១

# ព្រះពោធិសត្វ និង ពោធិចិត្ត

**ព្រះពោធិសត្វ** *គឺជាបុគ្គលម្នាក់ ដែលតាំងចិត្តប្រាថ្នាឱ្យបានត្រាស់ដឹងជាព្រះពុទ្ធ ដោយការខិតខំព្យាយាមសាងបុណ្យបារមីយ៉ាងស្វិតស្វាញជាទីបំផុត ។ ពាក្យថា* **ព្រះពោធិសត្វ** *សំដៅដល់បុគ្គល និងមហាសត្វទាំងឡាយ ដែលប្រកបដោយចិត្តបុណ្យដ៏ទូលំទូលាយ ព្រមទាំងមានបញ្ញាដ៏ជ្រាលជ្រៅ ។* **ពោធិ** *ជាពាក្យបាលី មានន័យថា បញ្ញាជាគ្រឿងត្រាស់ដឹង ។* **សត្ត** (*ពាក្យបាលី*) *ឬ* **សត្វ** (*ពាក្យសំស្ក្រឹត*) *មានន័យថា បុគ្គលដែលជាប់ជំពាក់ក្នុងអារម្មណ៍ ឬបំណងណាមួយ ។ ដូច្នេះ ពាក្យថា* **ពោធិសត្វ** *មានន័យថា "បុគ្គលដែលមានចិត្តជាប់ជំពាក់ក្នុងការត្រាស់ដឹង ឬជាបុគ្គលដែលសាងចិត្តដើម្បីត្រាស់ដឹង" ។*

*ក្នុងន័យនេះ គម្ពីរមហាវគ្គដីកា ទីឃនិកាយ បានចែងថា :*

**យាថាវតោ ញេយ្យំ ពុជ្ឈតីតិ ពោធិ សោឍរ សត្តយោគតោ ពោធិសត្តោតិ  អាហ បណ្ឌិតសត្តោ  ពុជ្ឈកសត្តោតិ ។**

*ប្រែ :   បញ្ញាណា ចាក់ធ្លុះនូវធម៌ដែលគួរដឹងតាមសភាពពិត ហេតុនោះ*

ឈ្មោះថា **ពោធិ** ។ បុគ្គលនោះឯង ឈ្មោះថា **ពោធិសត្វ** ព្រោះជាអ្នកអនុគ្រោះនូវសត្វ ។ ហេតុនោះ ទើបលោកហៅថា បណ្ឌិតសត្វ, ពុជ្ឈនកសត្វ គឺជាអ្នកប្រកបដោយ **ពោធិចិត្ត** ។

- តើអ្វីទៅដែលហៅថា **ពោធិចិត្ត** ?

**ពោធិចិត្ត** មានន័យថា សន្តានចិត្តនៃបុគ្គលដែលមានករុណា និងឆន្ទៈខ្ជាប់ខ្ជួនតែមួយគត់ ហើយធំជាងគេប្រចាំជីវិត គឺសេចក្តីប្រាថ្នាឱ្យបានត្រាស់ជាព្រះសម្មាសម្ពុទ្ធ (ព្រះពុទ្ធ) ដើម្បីឱ្យបានរួចផុតចាកទុក្ខក្នុងសង្សារ-វដ្តផង និងដើម្បីជួយសង្គ្រោះដល់សត្វលោកទាំងពួងឱ្យរួចផុតចាកទុក្ខផងដែរ ។

- តើបុគ្គលបែបណា ទើបអាចសាងខ្លួនជា **ពោធិសត្វ** បាន?

មនុស្ស សត្វ បុរស ស្ត្រីទូទៅក្នុងលោក សុទ្ធតែជាអ្នកមានភ័ព្វវាសនាសាងខ្លួនជាពោធិសត្វដោយការសាងពុទ្ធការកធម៌ (ធម៌ធ្វើឱ្យត្រាស់ជាព្រះពុទ្ធ)[១] ហើយអាចចាក់ធ្លុះសព្វញ្ញុតញ្ញាណជាព្រះពុទ្ធ នាអនាគតកាលបាន

[១] ស្ត្រីក៏អាចប្រាថ្នាជាព្រះពោធិសត្វបានដែរ ប៉ុន្តែនិយតពោធិសត្វ ត្រូវបិតនៅក្នុងភាពជាបុរស ។ ព្រះពោធិសត្វ (ព្រះសមណគោតម) ក៏ធ្លាប់មានជាតិជាស្ត្រីភេទដែរ មុនព្រះអង្គជានិយតពោធិសត្វ ។ ស្រង់ពីសៀវភៅ ស្ត្រីក្នុងព្រះពុទ្ធសាសនា ទំព័រ ៧៧ (ដោយលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស) ។

ឱ្យតែបុគ្គលនោះមានឆន្ទៈ (បំណងឬការប៉ងប្រាថ្នា) យ៉ាងមុតមាំក្នុងគោលដៅជីវិត ។ ជនណាក៏ដោយ ក៏អាចប្រាថ្នា និងសាងខ្លួនជាពោធិសត្វបានដូចគ្នា ព្រោះមនុស្សម្នាក់ៗ ដែលកើតមកតែងតែមានសភាវៈពីរនៅក្នុងខ្លួន គឺសភាវៈល្អ និងសភាវៈអាក្រក់ ។ សភាវៈល្អនេះហើយ ដែលមានពូជធម្ម-ជាតិរបស់ព្រះពុទ្ធ ហើយអាចរីកដុះដាលឱ្យមានបំណងដើម្បីបានត្រាស់ដឹងជាព្រះពុទ្ធ ។ ក្នុងចំណុចនេះ ព្រះសម្មាសម្ពុទ្ធទ្រង់សម្តែងថា :

**កិច្ឆោ មនុស្សបដិលាភោ　　កិច្ឆំ មច្ចាន ជីវិតំ**

**កិច្ឆំ សទ្ធម្មស្សវនំ　　កិច្ឆោ ពុទ្ធានមុប្បាទោ ។**

ប្រែ : ការត្រឡប់អត្តភាពជាមនុស្ស បានដោយកម្រ,

ការរស់រានមានជីវិតរបស់សត្វទាំងឡាយ បានដោយកម្រ,

ការស្តាប់ធម៌របស់សប្បុរស បានដោយកម្រ,

ការកើតឡើងនៃព្រះពុទ្ធទាំងឡាយ បានដោយកម្រ[២] ។

ទោះបីមនុស្ស សត្វ ជួបប្រទះនូវការក្រទាំង ៤ ប្រការនេះក្តី ក៏ការបានចាប់កំណើតជាមនុស្ស ចាត់ទុកជាភ័ព្វវាសនាដ៏ខ្ពង់ខ្ពស់ណាស់ ព្រោះ

[២] សុត្តន្ត.ខុទ្ទក.ធម្ម.៥២/៦០ ។

ភពនៃមនុស្សយើងនេះ ជាកន្លែងនៃព្រះពោធិសត្វគ្រប់ៗព្រះអង្គ បាន ឧប្បត្តិឡើង ដើម្បីសាងបារមីឆ្ពោះទៅកាន់ **ពុទ្ធភូមិ** ។

ព្រះពោធិសត្វអាចមានច្រើនអង្គ នៅក្នុងរយៈពេលជាមួយគ្នា តែ កម្រិតនៃការសាងខុសៗគ្នា ។ ដូច្នេះហើយ បានជាព្រះពោធិសត្វទាំងអស់ នោះ ពុំអាចត្រាស់ដឹងជាព្រះពុទ្ធក្នុងពេលជំណាលគ្នា ។ ព្រះពោធិសត្វគ្រប់ៗ ជាតិ តែងតែមានឆន្ទៈយ៉ាងមាំមួនក្នុង **ពោធិចិត្ត** គឺចិត្តដែលជាប់ជំពាក់ក្នុង ការត្រាស់ដឹង (មានបំណងត្រាស់ដឹងជាព្រះពុទ្ធ) និងតែងតែអនុវត្តយ៉ាង ហ្មត់ចត់បំផុតគ្រប់ៗជាតិ នូវសីលធម៌ និងក្រឹត្យវិន័យប្រចាំជីវិត ដែលហៅ ថា **ពុទ្ធការកធម៌** ឬហៅថា **បារមីធម៌** ។

- តើអ្វីទៅជា **បារមី** ?

និយមតាមន័យ **បារមី** គឺជាពាក្យបាលី មកពីពាក្យ **បារ** មានន័យ ថា ត្រើយម្ខាង ឬត្រើយខាងមុខ និងពាក្យ **មី** មានន័យថា គុណជាតិដ៏ ប្រសើរដែលគួរបំពេញ, ផ្លូវដ៏ខ្ពង់ខ្ពស់ដែលគួរដើរ ដូចក្នុងគម្ពីរនេមក្ការដីកា ខែថា **ចារំ និព្វានំ មយតិ កច្ឆតិ សត្តេ ច មាយេតិ កមេតិ វា** = **ចារមី** (គុណជាតិ) ដែលនាំឱ្យដល់ត្រើយនៃព្រះនិព្វាន ឬញ៉ាំងសត្វឱ្យបាន ដល់ត្រើយនៃព្រះនិព្វាន ឈ្មោះថា **បារមី** ។ (និយមតាមសព្ទ ពាក្យថា **បារមី** មកពីពាក្យ **បារម** + **ឈ្ញ** = **បារមី** ) ។

ដូច្នេះ **បារមី** មានន័យថា គុណជាតិដ៏ប្រសើរ ដែលបុគ្គលត្រូវបំពេញ ឬជាគ្រឿងសម្រាប់ញុំាំងសត្វឱ្យដល់ត្រើយបរមសុខ គឺព្រះនិព្វាន ។ តាមពាក្យសាមញ្ញ **ការសាងបារមី** គឺការអប់រំខ្លួនឱ្យបានបរិសុទ្ធ ទាំងផ្លូវកាយ វាចា ចិត្ត ចរិត សតិ និង បញ្ញា ដើម្បីធ្វើខ្លួនឱ្យមានគុណធម៌យ៉ាងល្អប្រសើរប្រចាំជីវិត ។

តើចាប់ពីពេលណាទៅ ដែលបុគ្គលអាចសន្មតខ្លួនថា ជា**ព្រះពោធិ-សត្វ** ?

គេអាចចាត់ទុកមនុស្សម្នាក់ ឬសត្វណាមួយ ជាព្រះពោធិសត្វបាន គឺនៅពេលដែលសតិរបស់មនុស្សនោះ ឬសត្វនោះ ឈានទៅដល់កម្រិតមួយដ៏ខ្ពស់ ដែលពុំអាចដកទឹកចិត្តចេញពីឆន្ទៈពោធិចិត្តបាន គឺមានសេចក្តីប្រាថ្នាតែមួយក្នុងបំណងត្រាស់ដឹងជា **ព្រះសម្មាសម្ពុទ្ធ** ។

ការសាងខ្លួនជាព្រះពោធិសត្វត្រូវឆ្លងកាត់ ៣ ដំណាក់កាល ដ៏សំខាន់ៗ ដូចតទៅ :

**-ដំណាក់កាលទី១** បុគ្គលចិញ្ចឹមចិត្តឱ្យក្លាយជាពោធិចិត្ត ហើយតែនៅពុំអាចហ្វឹកហ្វឺនចិត្តឱ្យជាព្រះពោធិសត្វបាន ហាក់ដូចជាបុគ្គលម្នាក់ព្យាយាមយកគ្រាប់ពូជល្វមកផ្សាំក្នុងសួន តែពុំទាន់បានដុះជាដើមល្វ បុគ្គលនោះនៅតែខំព្យាយាមបន្តកប់គ្រាប់ល្វនៅក្នុងសួននោះទៀត (អាច

ប្រៀបបាននឹងអំឡុងពេលដែលព្រះពោធិសត្វតាំងមនោបណិធាន) ។

**-ដំណាក់កាលទី២** ក្រោយពីការតាំងពោធិចិត្តបានជាច្រើនម៉ឺនសែនជាតិហើយ សតិរបស់បុគ្គលនោះចាប់ផ្ដើមប្រារព្ធចិត្តជាព្រះពោធិសត្វ ហើយចិត្តរបស់បុគ្គលនោះ តែងតែរិះគិតចង់ត្រាស់ជាព្រះពុទ្ធជានិច្ច រហូតដល់មានកម្រិតខ្ពស់បំផុត ដោយដកចិត្តចេញវិញលែងបាន ដូចដើមល្វមានពន្លកដុះចេញជា ដើម ទង ស្លឹក ទន់ខ្ចី (អាចប្រៀបបាននឹងអំឡុងពេលដែលព្រះពោធិសត្វតាំងវចីបណិធាន) ។

**-ដំណាក់កាលទី៣** លុះបានប្រារព្ធចិត្តជាព្រះពោធិសត្វច្រើនកប្បហើយ បុគ្គលនោះក៏ធ្វើសច្ចាប្រណិធាន ដោយប្ដេជ្ញាចំពោះព្រះភក្ត្រនៃព្រះសម្មាសម្ពុទ្ធថា :

> ដោយអំណាចបុញ្ញកម្មដែលខ្ញុំព្រះអង្គបានបំពេញ មានប្រមាណប៉ុណ្ណោះ សូមឱ្យខ្ញុំព្រះអង្គបានត្រាស់ជាព្រះពុទ្ធមួយព្រះអង្គ ក្នុងអនាគតកាល ។

ដំណាក់កាលទី ៣ នេះ ហាក់ដូចជាដើមល្វរឹងមាំ តែជារុក្ខជាតិពុំទាន់មានផ្លែផ្កា (អាចប្រៀបបាននឹងអំឡុងពេលដែលព្រះពោធិសត្វបំពេញបន្តរហូតបានត្រាស់ បន្ទាប់ពីទទួលការព្យាករពីព្រះសម្មាសម្ពុទ្ធរួចហើយ) ។

កាលណាព្រះពុទ្ធអង្គណាមួយទ្រង់ព្យាករបុគ្គលណាម្នាក់ថា អ្នកនឹងបានត្រាស់ជាព្រះពុទ្ធក្នុងពេលខាងមុខ ពេលនោះហើយ បុគ្គលនោះមានឈ្មោះថា **និយតពោធិសត្វ** (បុគ្គលទៀងនឹងត្រាស់ជាព្រះពុទ្ធ) ។ និយត-ពោធិសត្វ តែងតែធ្វើសច្ចាប្រណិធានគ្រប់ៗជាតិ ដើម្បីនឹងបានត្រាស់ជាព្រះពុទ្ធ ដោយព្យាយាមបំពេញពុទ្ធការកធម៌ទាំង ១០ (គឺទសបារមី) បន្តទៀត ។

សេចក្តីពិស្តារ ស្តីពីការធ្វើសច្ចាប្រណិធាននេះ នឹងមានអធិប្បាយក្នុង **សុមេធតាបស**[៣] ដែលទទួលពុទ្ធព្យាករណ៍ពីព្រះសម្មាសម្ពុទ្ធ ជាព្រះពោធិ-សត្វ ក្នុងការសាងពុទ្ធភូមិជា **ព្រះសមណគោតម** ក្នុងដំណាក់កាលចុងក្រោយនៃអភិនីហារ គឺជាការប្រកាសតាំងចិត្តប្រាថ្នាដ៏ឱឡារិក ចំពោះព្រះភក្ត្រនៃព្រះសម្មាសម្ពុទ្ធ ឱ្យបានត្រាស់ជាព្រះសម្មាសម្ពុទ្ធមួយអង្គ ។

គម្ពីរសោតត្ថកីមហានិទាន មានបញ្ជាក់ពីប្រវត្តិសាងបារមីរបស់ព្រះបរមពោធិសត្វ[៤] នៃព្រះពុទ្ធសមណគោតមថា ព្រះពោធិសត្វ គ្រាន់តែមានពោធិចិត្តគិតថា សូមឱ្យបានត្រាស់ជាព្រះសម្មាសម្ពុទ្ធចំនួន ៧ អសង្ខេយ្យ[៥] បញ្ចេញវាចាប្រាថ្នាឱ្យបានត្រាស់ជាព្រះសម្មាសម្ពុទ្ធចំនួន ៩ អសង្ខេយ្យ ។

---

[៣] សុត្តន្ត.ខុទ្ទក.ពុទ្ធ.៧៧/២១។ រឿងសុមេធតាបសនឹងមានអធិប្បាយនៅជំពូកទី៤ ខាងមុខ ។

[៤] សោតត្ថកីមហានិទាន ត្រង់អសង្ខេយ្យកថា ។

[៥] អសង្ខេយ្យ ត្រូវសរសេរលេខ ១ ថែម ១៤០ សូន្យ, មហាកប្ប ឬមួយអាយុផែនដី, សូមមើលត្រង់ឧបសម្ពន្ធខាងមុខ ។

សរុបទាំងអស់ចំនួន ១៦ អសង្ខេយ្យ នេះ ព្រះពោធិសត្វ ស្ថិតនៅជា អនិយតពោធិសត្វ (ជាព្រះពោធិសត្វមិនទាន់ទៀងថាបានត្រាស់) ព្រោះមិនទាន់បានទទួលការព្យាករពីព្រះសម្មាសម្ពុទ្ធអង្គណាមួយនៅឡើយ ។ លុះព្រះពោធិសត្វទ្រង់ទទួលការព្យាករពីព្រះសម្មាសម្ពុទ្ធព្រះនាមទីបង្ករមក ក៏តាំងនៅក្នុងនាមជា **និយតពោធិសត្វ** ។ បន្ទាប់មក ព្រះអង្គត្រូវបំពេញបារមីចំនួន ៤ អសង្ខេយ្យ ១ សែនកប្បទៀត ទើបបានត្រាស់ដឹងជាព្រះពុទ្ធ ។

ដំណាក់កាលនេះ អាចប្រៀបបានថា ដើមល្វដែលដុះយូរណាស់មកហើយនោះ ទើបតែបញ្ចេញនូវផ្កាផ្លែ ៕

# ជំពូកទី ២

# អដ្ឋសមោធាន

មុននឹងបុគ្គលត្រូវបានទទួលការព្យាករពីព្រះសម្មាសម្ពុទ្ធលើកទី១ ដែលជាលក្ខណៈញុំាងឱ្យក្លាយជានិយតពោធិសត្វ បុគ្គលនោះ ត្រូវតែប្រកបដោយអង្គ ៨ ហៅថា អដ្ឋសមោធាន គឺការប្រជុំរួមនូវធម៌ទាំង ៨ ។ ធម៌ទាំង ៨ នេះ មានចែងនៅក្នុងខុទ្ទកនិកាយ ពុទ្ធវំស[៦] ថា :

មនុស្សត្តំ លិង្គសម្បត្តិ ហេតុ សត្ថារទស្សនំ
បព្វជ្ជា គុណសម្បត្តិ អធិការោ ច ឆន្ទតា
អដ្ឋធម្មសមោធានា អភិនីហារោ សមិជ្ឈតិ ។

និយតពោធិសត្វ ត្រូវសម្រេចដោយអភិនីហារប្រជុំដោយធម៌ទាំងឡាយ ៨ ប្រការគឺ

១- ជាមនុស្ស មិនមែនទេវតា ឬ ព្រហ្ម,

២- ដល់ព្រមដោយភេទ គឺបុរស (ប្រុស),

៣- ដល់ព្រមដោយហេតុ ដែលអាចសម្រេចជាព្រះអរហន្តបាន ក្នុងជាតិនេះ គឺឧបនិស្សយសម្បត្តិ,

---

៦ សុត្តន្ត.ខុទ្ទក.ពុទ្ធ.៧៧/៣១ ។

៤- បានជួប និងថ្វាយបង្គំព្រះសម្មាសម្ពុទ្ធដោយផ្ទាល់ ហើយបាន ទទួលព្យាករណ៍ពីព្រះអង្គ,

៥- ក្នុងឋានៈជាតាបស ឬភិក្ខុសង្ឃ,

៦- ដល់ព្រមដោយគុណធម៌ គឺបានសម្រេចនូវអភិញ្ញា,

៧- មានពោធិចិត្តដែលបានសន្សំរួចយូរមកហើយ,

៨- មានឆន្ទៈយ៉ាងខ្លាំងក្លា ដើម្បីបានត្រាស់ជាព្រះពុទ្ធ ។

ធម៌ទាំង ៨ ប្រការនេះ ហៅថា **អដ្ឋសមោធាន** ដែលមានសេចក្តី អធិប្បាយដូចខាងក្រោម :

**១- ជាមនុស្ស** សេចក្តីប្រាថ្នានូវភាពជាព្រះពុទ្ធ រមែងសម្រេចបាន ចំពោះតែបុគ្គលអ្នកប្រាថ្នានៅក្នុងអត្តភាពជាមនុស្សប៉ុណ្ណោះ មិនមែននៅ ក្នុងកំណើតជា ទេវតា ព្រហ្ម នាគ គ្រុឌ ជាដើមឡើយ ។

**២- ជាអ្នកដល់ព្រមដោយភេទ គឺភេទប្រុស** សេចក្តីប្រាថ្នារមែង សម្រេចបានតែចំពោះមនុស្សប្រុសតែម្យ៉ាង, មិនសម្រេចចំពោះមនុស្សស្រី ខ្ទើយ ឧភតោព្យញ្ជនកៈ (អ្នកមានភេទពីរ) ឡើយ ។

**៣- ជាអ្នកដល់ព្រមដោយហេតុ** សំដៅដល់ឧបនិស្សយសម្បត្តិ, សេចក្តីប្រាថ្នាសម្រេចដល់មនុស្សប្រុសដែលដល់ព្រមដោយហេតុនៃ

ឧបនិស្ស័យ, មិនសម្រេចដល់អ្នកគ្មានឧបនិស្ស័យឡើយ ។

**៤- ជាអ្នកបានជួបព្រះសម្មាសម្ពុទ្ធ** គឺជាបានតាំងសេចក្ដីប្រាថ្នាយ៉ាងប្រចក្សនៅចំពោះព្រះភក្ត្រផ្ទាល់នៃព្រះសម្មាសម្ពុទ្ធ ដែលកំពុងគង់ធរមាននៅ, មិនសម្រេចដល់អ្នកប្រាថ្នាចំពោះមុខព្រះចេតិយ ពោធិព្រឹក្ស ព្រះពុទ្ធប្បដិមា ព្រះបច្ចេកពុទ្ធ និងពុទ្ធសាវ័កឡើយ ។

**៥- ជាបព្វជ្ជា** គឺជាអ្នកបួសក្នុងសម្នាក់ព្រះពុទ្ធជាម្ចាស់ ឬជាតាបសស្ថិតនៅក្នុងកម្មកិរិយវាទី, មិនសម្រេចដល់អ្នកស្ថិតនៅក្នុងភេទ ជាគ្រហស្ថទេ ។

**៦- ជាអ្នកមានគុណសម្បត្តិ** ដល់ព្រមដោយគុណ គឺជាអ្នកសម្រេចអភិញ្ញា ៥[៧] សមាបត្តិ ៨[៨], មិនសម្រេចដល់អ្នកគ្មានគុណសម្បត្តិឡើយ ។

---

[៧] **អភិញ្ញា ៥** គឺសេចក្ដីដឹងយ៉ាងខ្ពស់ ដែលកើតអំពីកម្លាំងនៃឈាន មាន**ឥទ្ធិវិធិ** សម្ដែងឫទ្ធិបាន១ **ទិព្វសោត** ត្រចៀកទិព្វ១ **ចេតោបរិយញ្ញាណ** ចេះស្គាល់កំណត់ចិត្តអ្នកដទៃ១ **បុព្វេនិវាសានុស្សតិ** រលឹកអតីតកំណើតរាប់កប្ប (ដឹងជាតិ)១ **ទិព្វចក្ខុ** ភ្នែកទិព្វ១ ។ (ឫទ្ធិអស្ចារ្យទាំង១០) ដែលហៅថា វសិតា (page 110-116 the Bodhisattva Doctrine in Buddhist Sanskrit Literature របស់មហាយាន ) និងក្នុងសៀវភៅនេះ ត្រង់ទំព័រខាងមុខ ។

[៨] **សមាបត្តិ ៨** គឺ រូបជ្ឈាន ៤ ៖ បឋមជ្ឈាន ទុតិយជ្ឈាន តតិយជ្ឈាន ចតុត្ថជ្ឈាន និង អរូបជ្ឈាន ៤ ៖ អាកាសានញ្ចាយតនៈ វិញ្ញាណញ្ចាយតនៈ អាកិញ្ចញ្ញាយតនៈ នេវសញ្ញានាសញ្ញាយតនៈ (សូមអានអភិធម្មត្ថសង្គហៈ) ។

***៧- ជាអ្នកមានអធិការ គឺពោធិចិត្តដែលបានសន្សំមកហើយ*** *ដល់ព្រម ដោយគុណសម្បត្តិដូចពោលមក ហើយហ៊ានលះបង់សូម្បីជីវិតរបស់ខ្លួន ធ្វើឧបការៈដ៏ក្រៃលែងដើម្បីភាពជាព្រះពុទ្ធ ។*

***៨- ជាអ្នកមានឆន្ទៈយ៉ាងខ្លាំងក្លា*** *គឺជាអ្នកប្រាថ្នា និងមានឆន្ទៈដ៏លើសលុបចំពោះប្រយោជន៍ដល់ពុទ្ធការកធម៌ ដើម្បីត្រាស់ដឹងជាព្រះពុទ្ធ ។*

*កាលព្រះពោធិសត្វដល់ព្រមដោយធម៌ទាំង ៨ នេះហើយ ទើបសមគួរដល់ការព្យាករនៃព្រះពុទ្ធទាំងឡាយ ។ ហេតុដូច្នេះ ទើបធម៌នេះ មានឈ្មោះថា* ***អដ្ឋសមោធាន គឺការប្រជុំរួមធម៌ទាំង ៨*** *។*

*ដើម្បីសម្រេចព្រមដោយអភិនីហារនៃធម៌ទាំង ៨ នេះ ព្រះពោធិសត្វត្រូវប្រកបដោយបច្ច័យ ៤, ហេតុ ៤ និងពលៈ ៤ ជាខាងដើមសិន ទើបអាចសម្រេចប្រជុំរួមនូវអដ្ឋសមោធានធម៌ទាំង ៨ នេះបាន[៩] ។*

*បច្ច័យ ៤, ហេតុ ៤ និង ពលៈ ៤ មានអត្ថន័យដូចតទៅ :*

**បច្ច័យ ៤ យ៉ាង**

១- **បស្សតិ តថាគតំ** ***ឃើញព្រះតថាគត*** ។ *មហាបុរសក្នុងលោកនេះ រមែងឃើញព្រះតថាគត ទ្រង់សម្តែងបាដិហារ្យដ៏អស្ចារ្យ ជាពុទ្ធានុភាព*

[៩] *អដ្ឋកថា ចរិយាបិដក ឈ្មោះបរមត្ថទីបនី ។*

ដ៏ក្រៃលែងមិនធ្លាប់មាន ។ ចិត្តរបស់មហាបុរសនោះ រមែងតាំងនៅក្នុងមហាពោធិញ្ញាណ ហើយធ្វើបាដិហារ្យនោះឱ្យជាអារម្មណ៍ ព្រោះអាស្រ័យព្រះដ៏មានព្រះភាគ មានធម៌ដ៏អស្ចារ្យមិនធ្លាប់មាន ។ ទ្រង់មានអានុភាពជា អចិន្តេយ្យ[១០] យ៉ាងនេះ ព្រោះចាក់ធ្លុះនូវធម្មធាតុណា ធម្មធាតុនោះមានអានុភាពច្រើនណាស់ហ្ន ។ ព្រះមហាបុរសនោះ ក៏បង្អោនចិត្តទៅក្នុងសម្ពោធិញ្ញាណ ធ្វើធម្មធាតុនោះឱ្យជាបច្ច័យ ។ ដោយអាស្រ័យការឃើញនូវមហានុភាពនោះឯង រមែងតាំងចិត្តទុកក្នុងអភិនីហារនោះ ។ នេះជាបច្ច័យទី១ នៃមហាភិនីហារ ។

**២- សុណាតិ ឯជិសោ ច ឯជិសោ ច ភគវា បានឮតមកថា ព្រះតថាគតមានសភាពដូច្នេះ ។** មហាបុរសមិនបានឃើញព្រះតថាគតមានអានុភាពធំតាមដែលពោលឡើយ តែធ្លាប់ឮថា ព្រះមានព្រះភាគទ្រង់មានសភាពដូច្នេះ ។ មហាបុរសនោះ បង្អោនចិត្តទៅក្នុងសម្ពោធិញ្ញាណ ធ្វើធម្មធាតុនោះឱ្យជា បច្ច័យ ។ អាស្រ័យព្រះដ៏មានព្រះភាគអង្គនោះ រមែងតាំងចិត្តទុកក្នុងអភិនីហារនោះ ។ នេះជាបច្ច័យទី២ នៃមហាភិនីហារ ។

**៣- ពុទ្ធានុភាវបដិសំយុត្តំ ធម្មំ សុណាតិ បានស្តាប់ធម៌**

[១០] អចិន្តេយ្យ គិតមិនដល់, មិនគួរដល់ការគិតរបស់សត្វលោក ។

**ដែលប្រកបដោយពុទ្ធានុភាព ។** មហាបុរសមិនបានឃើញព្រះតថាគតមានអានុភាពធំតាមដែលពោលនោះឡើយ ហើយទាំងមិនបានឮមហានុភាពនោះអំពីអ្នកដទៃទេ ។ ប៉ុន្តែកាលព្រះតថាគត ទ្រង់សម្តែងធម៌ មហាបុរសរមែងស្តាប់ធម៌បដិសំយុត្តដោយពុទ្ធានុភាព មានន័យជាអាទិ៍ថា "ម្នាលភិក្ខុទាំងឡាយ តថាគតប្រកបដោយកម្លាំង ១០ ដូច្នេះ[១១]" ។

មហាបុរសនោះ រមែងបង្អោនចិត្តទៅក្នុងសម្ពោធិញ្ញាណ ហើយធ្វើនូវធម្មជាតុនោះឱ្យជាបច្ច័យ ។ អាស្រ័យពុទ្ធានុភាពនោះ រមែងតាំងចិត្តទុកក្នុងអភិនីហារនោះ ។ នេះជាបច្ច័យទី៣ នៃមហាភិនីហារ ។

**៤- ឧឡារជ្ឈាសយោ មានអធ្យាស្រ័យខ្ពស់ ។** មហាបុរស មិនបានឃើញព្រះតថាគត មានអានុភាពធំតាមដែលពោលនោះទេ ហើយទាំងមិនបានឮមហានុភាពនោះអំពីអ្នកដទៃដែរ ។ ទាំងមិនបានស្តាប់ធម៌របស់ព្រះតថាគត តែជាអ្នកមានអធ្យាស្រ័យមហាសាល និងមានការតាំងចិត្តស្អាត ហើយគិតថា យើងនឹងរក្សាវង្សព្រះពុទ្ធ តាមបែបផែនពុទ្ធប្បវេណីរបស់ព្រះពុទ្ធ ដែលជាសភាវធម៌របស់ព្រះពុទ្ធ ហើយធ្វើនូវសក្ការៈគោរពរាប់អានបូជាធម៌ ប្រព្រឹត្តធម៌ បង្អោនចិត្តទៅក្នុងសម្ពោធិញ្ញាណ ធ្វើធម្មជាតុ

[១១] កម្លាំង ១០ មានឈ្មោះថា ទសពលញ្ញាណ មានក្នុងសុត្តន្តបិដក លេខ ៥០ ទំព័រ ៧៤-៨០ និងមានក្នុងសៀវភៅនេះត្រង់ទំព័រខាងមុខ ។

នោះឱ្យជាបច្ច័យ, អាស្រ័យធម៌នោះ រមែងតាំងចិត្តទុកក្នុងអភិនីហារនោះ ។ នេះជាបច្ច័យទី៤ នៃមហាភិនីហារ ។

**ហេតុ ៤ យ៉ាង**

**១- ឧបនិស្សយសម្បន្នោ ហោតិ *ជាអ្នកសម្បូរដោយឧបនិស្ស័យ។*** មហាបុរសក្នុងលោកនេះ តាមប្រក្រតីជាអ្នកសម្បូរដោយឧបនិស្ស័យ ហើយបានសន្សំអធិការចំពោះព្រះពុទ្ធទាំងឡាយក្នុងកាលមុន ។ នេះជាហេតុទី១ នៃមហាភិនីហារ ។

**២- ករុណាជ្ឈាសយោ ហោតិ *ជាអ្នកមានអធ្យាស្រ័យករុណា ។*** មហាបុរសតាមប្រក្រតី ជាអ្នកមានអធ្យាស្រ័យក្នុងករុណា តែងបង្អោនចិត្តទៅក្នុងករុណា ប្រាថ្នានឹងនាំទុក្ខរបស់សត្វទាំងឡាយចេញទៅ ដោយហ៊ានលះបង់កាយនិងជីវិតរបស់ខ្លួន ។ នេះជាហេតុទី២ នៃមហាភិនីហារ ។

**៣- វាយមន្តោ អនិព្វិន្នោ ហោតិ *ជាអ្នកមានព្យាយាមមិនញាប់ញ័រ។*** មហាបុរសមានសេចក្តីព្យាយាមឥតងាករេ ដើម្បីរួចចាកទុក្ខក្នុងវដ្តសង្សារ សូម្បីធ្វើនូវកម្មដែលគេធ្វើបានដោយកម្រ ដើម្បីជាប្រយោជន៍ដល់សត្វលោក រហូតអស់កាលដ៏យូរ ហើយមិនបានញាប់ញ័ររហូតសម្រេចប្រយោជន៍ជាទីប្រាថ្នា ។ នេះជាហេតុទី៣ នៃមហាភិនីហារ ។

៤- **កល្យាណមិត្តសន្និស្សិតោ ហោតិ** ***ជាអ្នកអាស្រ័យនឹងកល្យាណមិត្ត*** ។ មហាបុរស ជាអ្នកមានអធ្យាស្រ័យក្នុងកល្យាណមិត្ត និងជាអ្នកហាមចាកវត្ថុមិនជាប្រយោជន៍ ឱ្យតាំងនៅក្នុងវត្ថុជាប្រយោជន៍ ។ នេះជាហេតុទី៤ នៃមហាភិនីហារ ។

**ពលៈ ៤ យ៉ាង**

១- **អជ្ឈត្តិកពលៈ** ***កម្លាំងខាងក្នុង*** បានដល់សេចក្ដីពេញចិត្តដោយគោរពក្នុងធម៌អាស្រ័យខ្លួន ក្នុងសម្មាសម្ពោធិញ្ញាណ ។ មហាបុរសមានខ្លួនជាធំ មានការខ្មាសជាទីពឹងអាស្រ័យ និងដល់ព្រមដោយអភិនីហារបំពេញបារមី ហើយចាក់ធ្លុះនូវសម្មាសម្ពោធិញ្ញាណ ។

២- **ពាហិរកពលៈ** ***កម្លាំងខាងក្រៅ*** បានដល់សេចក្ដីពេញចិត្តអាស្រ័យអ្នកដទៃ ក្នុងសម្មាសម្ពោធិញ្ញាណ ។ មហាបុរសមានលោកជាធំ មានការរាប់អានជាទីពឹងអាស្រ័យ និងដល់ព្រមដោយអភិនីហារបំពេញបារមី ហើយចាក់ធ្លុះនូវសម្មាសម្ពោធិញ្ញាណ ។

៣- **ឧបនិស្សយពលៈ** ***កម្លាំងឧបនិស្ស័យ*** បានដល់សេចក្ដីពេញចិត្ត ដោយឧបនិស្សយសម្បត្តិក្នុងសម្មាសម្ពោធិញ្ញាណ ។ មហាបុរសមានឥន្ទ្រិយកម្រិតខ្ពស់ ឈ្លាសវៃ អាស្រ័យសតិ និងដល់ព្រមដោយអភិនីហារបំពេញបារមី ហើយចាក់ធ្លុះនូវសម្មាសម្ពោធិញ្ញាណ ។

៤- បយោគពលៈ ***កម្លាំងសេចក្តីព្យាយាម*** *សំដៅយកការដល់ព្រមដោយសេចក្តីព្យាយាម ភាពជាអ្នកធ្វើដោយក្តីគោរព ភាពជាអ្នកធ្វើតៗគ្នា ដែលកើតអំពីសេចក្តីព្យាយាមនោះក្នុងសម្មាសម្ពោធិញ្ញាណ ។ មហាបុរសមានសេចក្តីព្យាយាមតាមលំដាប់ និងដល់ព្រមដោយអភិនីហារ បានបំពេញបារមី ហើយចាក់ធ្លុះនូវសម្មាសម្ពោធិញ្ញាណ ។*

*នេះជា* ***បច្ច័យ ហេតុ*** *និង* ***ពលៈ*** *ដែលនាំឱ្យព្រះពោធិសត្វ សម្រេចធម៌អដ្ឋសមោធានទាំង ៨ នេះបាន ។*

*ព្រះពោធិសត្វដែលប្រកបដោយធម៌ទាំង ៨ នេះ ក្នុងពេលជួបព្រះសម្មាសម្ពុទ្ធអង្គណាមួយ ហើយទទួលព្យាករណ៍អំពីព្រះពុទ្ធអង្គនោះរួចហើយ ក៏មានឈ្មោះថា* **និយតពោធិសត្វ** *ឬ* **មហាពោធិសត្វ** *ចាប់តាំងពីពេលនោះមក ។*

*ព្រះពោធិសត្វមាន ៣ ប្រភេទ ដូចលោកចងជាគាថាប្រព័ន្ធថា*[១២] :

ឧគ្ឃដិតញ្ញូ ពោធិសត្តោ បញ្ញាធិកោតិ នាមសោ
វិបច្ចិតញ្ញូ ពោធិសត្តោ វុត្តោ សទ្ធាធិកោ នាម
នេយ្យោ វីរិយាធិកោ នាម ពោធិសត្តោ ឥមេ តយោ ។

[១២] *បរមត្ថទីបនី ចរិយាបិដក, គម្ពីរជិនកាលមាលីបករណ៍, អនាគតវំសបាលិ ។*

ប្រែ : ព្រះពោធិសត្វជាឧគ្ឃដិតញ្ញូ មាននាមថា **បញ្ញាធិក**

ព្រះពោធិសត្វជាវិបច្ចិតញ្ញូ មាននាមថា **សទ្ធាធិក**

ព្រះពោធិសត្វជានេយ្យៈ មាននាមថា **វីរិយាធិក** ។

ព្រះពោធិសត្វទាំង ៣ ប្រភេទ ដូចបានពោលមកនេះ មានន័យដូចតទៅ :

**ឧគ្ឃដិតញ្ញូពោធិសត្វ** គឺជាព្រះពោធិសត្វ ដែលសាងបារមីក្រាស់ដោយបញ្ញា ។ បន្ទាប់ពីបានទទួលព្យាករណ៍អំពីព្រះពុទ្ធអង្គណាមួយមុនគេមក ព្រះពោធិសត្វប្រភេទនេះ ត្រូវបំពេញបារមីបន្ថែមចំនួន ៤ អសង្ខេយ្យ ១ សែនកប្ប ទើបបានចាក់ធ្លុះនូវសម្មាសម្ពោធិញ្ញាណ ។

**វិបច្ចិតញ្ញូពោធិសត្វ** គឺជាព្រះពោធិសត្វ ដែលសាងបារមីក្រាស់ដោយសទ្ធា ។ បន្ទាប់ពីបានទទួលព្យាករណ៍អំពីព្រះពុទ្ធអង្គណាមួយមុនគេមក ព្រះពោធិសត្វប្រភេទនេះ ត្រូវបំពេញបារមីបន្ថែមចំនួន ៨ អសង្ខេយ្យ ១ សែនកប្ប ទើបបានចាក់ធ្លុះនូវសម្មាសម្ពោធិញ្ញាណ ។

**នេយ្យពោធិសត្វ** គឺជាព្រះពោធិសត្វដែលសាងបារមី ក្រាស់ដោយវីរិយៈ។ បន្ទាប់ពីបានទទួលព្យាករណ៍អំពីព្រះពុទ្ធអង្គណាមួយមុនគេមក

ព្រះពោធិសត្វប្រភេទនេះ ត្រូវបំពេញបារមីបន្ថែមចំនួន ១៦ អសង្ខ្មៃយ្យ ១ សែនកប្ប ទើបបានចាក់ធ្លុះនូវសម្មាសម្ពោធិញ្ញាណ ។

ម៉្យាងទៀត គម្ពីរមនោរថបូរណី អដ្ឋកថា អង្គុត្តរនិកាយ ឯកនិបាត បានបញ្ជាក់ថា :

កប្បសតសហស្សាធិកានិ ចត្តារិ វា អដ្ឋ វា សោឡស វា អសង្ខ្យេយ្យានិ ចារមិយោ បូរេត្វា តិណ្ណំ មារានំ មត្ថកំ មទ្ទិត្វា បដិវិទ្ធសព្វញ្ញុតញ្ញាណោ សព្វញ្ញុពុទ្ធោ ឯាម ។

ប្រែ: ព្រះពុទ្ធទ្រង់មានសព្វញ្ញុតញ្ញាណត្រាស់ដឹង ព្រោះទ្រង់បំពេញនូវបារមីធម៌ទាំងឡាយអស់ ៤ អសង្ខ្មៃយ្យ ១ សែនកប្បខ្លះ ៨ អសង្ខ្មៃយ្យ ១ សែនកប្បខ្លះ ១៦ អសង្ខ្មៃយ្យ ១ សែនកប្បខ្លះ ហើយទ្រង់ញាំញីនូវមារ ទើបមានព្រះនាមថា **សព្វញ្ញុពុទ្ធ** ។

អដ្ឋកថាចារ្យបានបញ្ជាក់ក្នុងបរមត្ថទីបនី ចរិយាបិដកដូច្នេះថា :

ហេដ្ឋិមេន តាវ បរិច្ឆេទេន ចត្តារិ អសង្ខ្យេយ្យានិ មហាកប្បានំ សតសហស្សញ្ច, មជ្ឈិមេន អដ្ឋ សង្ខ្យេយ្យានិ មហាកប្បានំ សតសហស្សញ្ច, ឧបរិមេន បន សោឡស អសង្ខ្យេយ្យានិ មហាកប្បានំ សតសហស្សញ្ច ។

*ប្រែ : ព្រះពោធិសត្វ[១៣]ថ្នាក់ទាបបំផុត លោកត្រូវបំពេញអស់កាល ៤ អសង្ខេយ្យ ១ សែនមហាកប្ប, ថ្នាក់កណ្តាល លោកត្រូវបំពេញអស់កាល ៨ អសង្ខេយ្យ ១ សែនមហាកប្ប, ថ្នាក់ខ្ពស់ លោកត្រូវបំពេញអស់កាល ១៦ អសង្ខេយ្យ និង ១ សែន មហាកប្ប ។*

ព្រះពោធិសត្វមួយអង្គៗ មានការបំពេញបារមីធម៌ ខុសៗគ្នាយ៉ាងនេះឯង ។

***សួរថា ហេតុដូចម្តេចបានជាព្រះពោធិសត្វ លោកបំពេញបារមីធម៌ខុសកាលគ្នាយ៉ាងនេះ?***

នៅក្នុងសេចក្តីនេះ លោកបានបញ្ជាក់ក្នុងអដ្ឋកថាដូច្នេះថា :

ធម្មតាបុគ្គលទាំងឡាយ ដែលឈ្មោះថាជា **និយតពោធិសត្វ** ត្រូវរួបរួមប្រកបដោយធម៌ទាំង ៨ ក្នុងពេលជួបព្រះសម្មាសម្ពុទ្ធអង្គណាមួយដោយផ្ទាល់ ។ ក្នុងធម៌ទាំង ៨ នោះ មានធម៌ទី៣ គឺហេតុ សំដៅដល់បុគ្គល ដែលមានឧបនិស្ស័យក្នុងអរហត្តផល "***ភាពជាព្រះអរហន្ត***" ក្នុងអត្តភាពនោះ ។

ដូចមានក្នុងគម្ពីរបរមត្ថជោតិកា អដ្ឋកថា សុត្តនិបាត បញ្ជាក់ថា :

---

*[១៣] ព្រះពោធិសត្វ មាន ៣ កម្រិតគឺ **ថ្នាក់ទាប** សំដៅលើការបំពេញឆាប់ត្រាស់ដឹង ព្រោះត្រាស់ដោយបញ្ញា, **ថ្នាក់កណ្តាល** យូរជាងបន្តិច ព្រោះត្រាស់ទៅដោយសទ្ធា, **ថ្នាក់ខ្ពស់** ប្រើពេលយូរក្រៃលែង ព្រោះត្រាស់ទៅដោយសេចក្តីព្យាយាម ។*

**ហេតូតិ អរហត្តស្ស ឧបនិស្សយសម្បត្តិ ។ យោ ហិ តស្មឹ អត្តភាវេ វាយមន្តោ អរហត្តំ ចាបុណិតុំ សមត្ថោ, តស្ស សមិជ្ឈតិ, នោ ឥតរស្ស ។**

ប្រែ : ឧបនិស្សយសម្បត្តិនៃអរហត្ត ឈ្មោះថា **ហេតុ** ។ បុគ្គលណាមួយមានសេចក្តីព្យាយាមអាចនឹងចាក់ធ្លុះនូវព្រះអរហត្ត ក្នុងអត្តភាពនោះឯង, សេចក្តីតាំងប្រាថ្នានូវពុទ្ធភូមិ តែងសម្រេចដល់បុគ្គលអ្នកដល់ព្រមដោយហេតុគឺអរហត្តនោះ មិនសម្រេចដល់បុគ្គលដទៃដែលមិនមានហេតុនោះឡើយ ។

តាមធម្មនិយាមនៃព្រះធម៌ បុគ្គលដែលត្រូវសម្រេចជាព្រះអរហន្តមាន ៣ ពួក គឺ **ឧគ្ឃដិតញ្ញូបុគ្គល១ វិបច្ចិតញ្ញូបុគ្គល១ នេយ្យបុគ្គល១** ។ ប្រសិនបើក្នុងអត្តភាពនោះ ព្រះពោធិសត្វជា **ឧគ្ឃដិតញ្ញូបុគ្គល** លោកស្តាប់ព្រះធម៌ចំពោះព្រះភក្ត្រព្រះសម្ពុទ្ធអង្គណាមួយ ប្រកបដោយគាថា ៤ បទនៅមិនទាន់ចប់បទគាថាទី៣ លោកអាចសម្រេចជាព្រះអរហន្ត មួយអន្លើដោយអភិញ្ញា ៦ បដិសម្ភិទា ៤ ប្រសិនបើមានបំណងជាសាវកពោធិញ្ញាណ ។ តែបើលោកមិនបង្អោនទៅក្នុងសាវកពោធិញ្ញាណ បែរត្រឡប់មានបំណងដើម្បីសម្រេចជា **សម្មាសម្ពោធិញ្ញាណ** វិញ ។ ព្រោះហេតុនោះ ពោធិសត្វអង្គនោះឈ្មោះថា **ឧគ្ឃដិតញ្ញូពោធិសត្វ ត្រូវបំពេញពុទ្ធការកធម៌ ត្រឹមតែចំនួន ៤ អសង្ខេយ្យ ១ សែនកប្ប នឹងបានត្រាស់ជាព្រះសម្មាសម្ពុទ្ធ** ។

ប្រសិនបើក្នុងអត្តភាពនោះ ព្រះពោធិសត្វជា **វិបច្ចិតញ្ញូបុគ្គល** លោកស្តាប់ព្រះធម៌ចំពោះព្រះភក្ត្រព្រះសម្ពុទ្ធអង្គណាមួយ ប្រកបដោយគាថា ៤ បទ នៅមិនទាន់ចប់បទគាថាទី៤ លោកអាចសម្រេចជាព្រះអរហន្តមួយអន្លើដោយអភិញ្ញា ៦ បដិសម្ភិទា ៤ ប្រសិនបើមានបំណងជាសាវកពោធិញ្ញាណ ។ តែលោកមិនបង្អោនទៅក្នុងសាវកពោធិញ្ញាណ បែរត្រឡប់មានបំណងដើម្បីសម្រេចជា **សម្មាសម្ពោធិញ្ញាណ** វិញ ។ ព្រោះហេតុនោះ ពោធិសត្វអង្គនោះ ឈ្មោះថា **វិបច្ចិតញ្ញូពោធិសត្វ ត្រូវបំពេញពុទ្ធការកធម៌ ត្រឹមតែចំនួន ៨ អសង្ខេយ្យ ១ សែនកប្ប នឹងត្រាស់ជាព្រះសម្មាសម្ពុទ្ធ** ។

ប្រសិនបើក្នុងអត្តភាពនោះ ព្រះពោធិសត្វជា **នេយ្យបុគ្គល** លោកស្តាប់ព្រះធម៌នៅចំពោះព្រះភក្ត្រព្រះសម្ពុទ្ធអង្គណាមួយ ប្រកបដោយគាថា ៤ បទ លុះត្រាតែចប់បទគាថាទី៤ លោកអាចសម្រេចជាព្រះអរហន្ត មួយអន្លើដោយអភិញ្ញា ៦ បដិសម្ភិទា ៤ ប្រសិនបើមានបំណងជាសាវកពោធិញ្ញាណ ។ តែបើលោកមិនបង្អោនទៅក្នុងសាវកពោធិញ្ញាណ បែរត្រឡប់មានបំណងដើម្បីសម្រេចជា **សម្មាសម្ពោធិញ្ញាណ** វិញ ។ ព្រោះហេតុនោះ ពោធិសត្វអង្គនោះ ឈ្មោះថា **នេយ្យពោធិសត្វ ត្រូវបំពេញពុទ្ធការកធម៌ ត្រឹមតែចំនួន ១៦ អសង្ខេយ្យ ១ សែនកប្ប នឹងត្រាស់ជាព្រះសម្មាសម្ពុទ្ធ** ៕

# ជំពូកទី ៣
# ចិរវេលាព្រះសុមេធបណ្ឌិតបំពេញពុទ្ធការកធម៌

ក្នុងការបំពេញបារមីធម៌ដើម្បីត្រាស់ដឹងជាព្រះពុទ្ធ, ព្រះបរមសាស្តាសមណគោតម ត្រូវប្រើពេលវេលាសរុបទាំងអស់ ២០ អសង្ខេយ្យ និង ១ សែនកប្ប ដោយចែកជាវគ្គធំៗ ចំនួន ៣ ដូចខាងក្រោម ៖

## ក. សុមេធបណ្ឌិតពោធិសត្វបំពេញពុទ្ធការកធម៌ ១៦ អសង្ខេយ្យ ជាអនិយតពោធិសត្វ

ព្រះពោធិសត្វ មានមនោបណិធានកើតឡើង ប្រាថ្នាភាពជាព្រះពុទ្ធ (គឺសេចក្តីប្រាថ្នាតែក្នុងចិត្ត) ចំនួន ៧ អសង្ខេយ្យ បញ្ចេញវាចាប្រាថ្នាជាព្រះសម្មាសម្ពុទ្ធ ចំនួន ៩ អសង្ខេយ្យ ។ នៅក្នុង ១៦ អសង្ខេយ្យនេះ ព្រះពោធិសត្វ នៅមានលក្ខណៈជា **អនិយតពោធិសត្វ** គឺមិនទាន់ទៀងប្រាកដថា ត្រូវតែត្រាស់ជាព្រះពុទ្ធនៅឡើយទេ ។

### ១. មនោបណិធាន

ព្រះពោធិសត្វប្រាថ្នាជាព្រះពុទ្ធក្នុងចិត្ត អស់កាល ៧ អសង្ខេយ្យ ។ ចំនួន ៧ អសង្ខេយ្យនោះមាន **នន្ទអសង្ខេយ្យ១ សុនន្ទអសង្ខេយ្យ១ បឋវីអសង្ខេយ្យ១ មណ្ឌអសង្ខេយ្យ១ ធរណីអសង្ខេយ្យ១ សាគរអសង្ខេយ្យ១** និង **បុណ្ឌរិកអសង្ខេយ្យ១** ។

ក្នុងនន្ទអសង្ខៃយ្យនោះ មានកប្បមួយឈ្មោះថា **សារកប្ប** មានព្រះសម្មាសម្ពុទ្ធព្រះនាម **ព្រហ្មទេវៈ** ទ្រង់ឧប្បត្តិឡើងក្នុងលោក ។ ក្នុងកាលនោះ ព្រះពោធិសត្វ បានយោនយកកំណើតជាព្រះចៅផែនដី មានព្រះនាមថា **អតិទេវៈ** ទ្រង់បានបំពេញកុសលធម៌ក្នុងសម្នាក់ព្រះសម្មាសម្ពុទ្ធអង្គនោះ ហើយមានមនោបណិធាន គឺមានសេចក្ដីប្រាថ្នាតែក្នុងចិត្ត សូមឱ្យបាន ត្រាស់ជាព្រះសម្មាសម្ពុទ្ធមួយអង្គក្នុងលោក នាអនាគតកាល ។

ក្នុងអសង្ខៃយ្យនីមួយៗ មានចំនួនព្រះពុទ្ធត្រាស់ដឹងខុសៗគ្នាគឺ

**១- នន្ទអសង្ខៃយ្យ** មានព្រះពុទ្ធត្រាស់ដឹង ៥.០០០ ព្រះអង្គ

**២- សុនន្ទអសង្ខៃយ្យ** មានព្រះពុទ្ធត្រាស់ដឹង ៩.០០០ ព្រះអង្គ

**៣- បឋវីអសង្ខៃយ្យ** មានព្រះពុទ្ធត្រាស់ដឹង ១០.០០០ ព្រះអង្គ

**៤- មណ្ឌអសង្ខៃយ្យ** មានព្រះពុទ្ធត្រាស់ដឹង ១១.០០០ ព្រះអង្គ

**៥- ធរណិអសង្ខៃយ្យ** មានព្រះពុទ្ធត្រាស់ដឹង ២០.០០០ ព្រះអង្គ

**៦- សាគរអសង្ខៃយ្យ** មានព្រះពុទ្ធត្រាស់ដឹង ៣០.០០០ ព្រះអង្គ

**៧- បុណ្ឌរិកអសង្ខៃយ្យ** មានព្រះពុទ្ធត្រាស់ដឹង ៤០.០០០ ព្រះអង្គ ។

សរុបសេចក្ដីថា ក្នុង ៧ អសង្ខៃយ្យនេះ ព្រះពោធិសត្វបានធ្វើមនោ-បណិធាន នៅចំពោះព្រះភក្ត្រព្រះសម្មាសម្ពុទ្ធ ចំនួន ១២៥.០០០ ព្រះអង្គ ។

## ២. វចីបណិធាន

ព្រះពោធិសត្វបញ្ចេញវាចាប្រាថ្នាជាព្រះពុទ្ធ ចំនួន៩ អសង្ខេយ្យគឺ **សព្វកទ្រអសង្ខេយ្យ១ សព្វផុល្លអសង្ខេយ្យ១ សព្វរតនអសង្ខេយ្យ១ ឧសភក្ខន្ធអសង្ខេយ្យ១ មានិកទ្រអសង្ខេយ្យ១ បទុមអសង្ខេយ្យ១ ឧសភអសង្ខេយ្យ១ ខន្ធុត្តមអសង្ខេយ្យ១ សព្វមាលអសង្ខេយ្យ១** ។

ក្នុងសព្វកទ្រអសង្ខេយ្យ ព្រះពោធិសត្វកើតក្នុងរាជត្រកូល នៃនគរធញ្ញវតី ក្នុងកប្បឈ្មោះសារមណ្ឌកប្ប ថ្វាយបង្គំព្រះពុទ្ធចំនួន ៤ ព្រះអង្គ ។ ក្នុងកប្បបន្ទាប់មក ព្រះពោធិសត្វកើតជាស្តេចចក្រពត្តិ ចូលទៅថ្វាយបង្គំព្រះសម្មាសម្ពុទ្ធ ព្រះនាម**បុរាណសក្យមុនី** ដែលទ្រង់ឧប្បត្តិក្នុងលោក ។ ព្រះពោធិសត្វក៏បញ្ចេញវាចា ប្រាថ្នានូវភាពជាព្រះពុទ្ធក្នុងសម្នាក់ព្រះពុទ្ធព្រះនាមបុរាណសក្យមុនីអង្គនោះ មុនដំបូងបង្អស់ ។

១- ក្នុងសព្វកទ្រអសង្ខេយ្យនោះ មានព្រះពុទ្ធឧប្បត្តិឡើងក្នុងលោក ចំនួន ៥០.០០០ ព្រះអង្គ ។

២- ក្នុងសព្វផុល្លអសង្ខេយ្យ មានព្រះពុទ្ធឧប្បត្តិឡើងក្នុងលោក ចំនួន ៦០.០០០ ព្រះអង្គ ។

៣- ក្នុងសព្វរតនអសង្ខេយ្យ មានព្រះពុទ្ធឧប្បត្តិឡើងក្នុងលោក ចំនួន ៧០.០០០ ព្រះអង្គ ។

៤- ក្នុងឧសភក្ខន្ធអសង្ខេយ្យ មានព្រះពុទ្ធឧប្បត្តិឡើងក្នុងលោក ចំនួន ៨០.០០០ ព្រះអង្គ ។

៥- ក្នុងមានិកទ្រអសង្ខេយ្យ មានព្រះពុទ្ធឧប្បត្តិឡើងក្នុងលោក ចំនួន ៩០.០០០ ព្រះអង្គ ។

៦- ក្នុងបទុមអសង្ខេយ្យ មានព្រះពុទ្ធឧប្បត្តិឡើងក្នុងលោក ចំនួន ២០.០០០ ព្រះអង្គ ។

៧- ក្នុងឧសភអសង្ខេយ្យ មានព្រះពុទ្ធឧប្បត្តិឡើងក្នុងលោក ចំនួន ១០.០០០ ព្រះអង្គ ។

៨- ក្នុងខន្ធុត្តមអសង្ខេយ្យ មានព្រះពុទ្ធឧប្បត្តិឡើងក្នុងលោក ចំនួន ៥.០០០ ព្រះអង្គ ។

៩- ក្នុងសព្វមាលអសង្ខេយ្យ មានព្រះពុទ្ធឧប្បត្តិឡើងក្នុងលោក ចំនួន ២.០០០ ព្រះអង្គ ។

ព្រះពោធិសត្វបញ្ចេញវាចា ប្រាថ្នាសូមឱ្យខ្លួនបានត្រាស់ជាព្រះពុទ្ធ ក្នុងសម្នាក់ព្រះសម្មាសម្ពុទ្ធ ចំនួន ៣៨៧.០០០ ព្រះអង្គ[១៨] ។

សរុបព្រះពោធិសត្វ ស្ថិតនៅជាអនិយតពោធិសត្វ ត្រូវថ្វាយបង្គំ និង

[១៨] <u>បញ្ជាក់</u> **៣៨៧.០០០ ព្រះអង្គ**នេះ មិនរាប់ព្រះពុទ្ធតណ្ហង្ករ ព្រះពុទ្ធមេធង្ករ ព្រះពុទ្ធសរណង្ករ ចូលទេ ។

បំពេញអធិការយ៉ាងច្រើន ក្នុងសម្នាក់ព្រះសម្មាសម្ពុទ្ធ ចំនួន ៥១២.០០០ ព្រះអង្គ ។

ព្រះពោធិសត្វបានបំពេញអធិការ គឺការសាងជាឧបនិស្សយសម្បត្តិ ចំនួន ១៦ អសង្ខេយ្យ ដោយប្រការដូច្នេះ ។

កាលដែលសព្វផាលអសង្ខេយ្យបានកន្លងទៅ ក៏មកដល់អសង្ខេយ្យមួយទៀត ហៅថា **សេលអសង្ខេយ្យ** ។ ក្នុងសេលអសង្ខេយ្យនោះ មានកប្បមួយឈ្មោះថា **សារមណ្ឌកប្ប** មានព្រះពុទ្ធ ៤ ព្រះអង្គ ទ្រង់ត្រាស់ដឹងឡើងក្នុងលោកគឺ **ព្រះពុទ្ធតណ្ហង្ករ១ ព្រះពុទ្ធមេធង្ករ១ ព្រះពុទ្ធសរណង្ករ១ និងព្រះពុទ្ធទីបង្ករ១** ។ ព្រះពោធិសត្វបានថ្វាយបង្គំ និងបំពេញអធិការ ក្នុងកាលនៃព្រះពុទ្ធ ៣ ព្រះអង្គខាងដើមដែរ តែមិនទាន់ទទួលការព្យាករនៅឡើយទេ ព្រោះអដ្ឋសមោធាន នៅមិនទាន់គ្រប់គ្រាន់ ។

ក្នុងកាលព្រះពុទ្ធទី៤ **ព្រះនាមទីបង្ករ** ទ្រង់ឧប្បត្តិឡើងក្នុងលោក ព្រះពោធិសត្វ យោនយកកំណើតជា**សុមេធបណ្ឌិត** ប្រកបដោយអដ្ឋសមោធាន ពេញបរិបូណ៌ ក៏ទទួលបានការព្យាករពីព្រះសម្មាសម្ពុទ្ធអង្គនោះ ក្នុងភាពនៃបុគ្គលជា **និយតពោធិសត្វ** គឺព្រះមហាពោធិសត្វដែលនឹងត្រាស់ជាព្រះសម្មាសម្ពុទ្ធលើលោកពិតប្រាកដ ។ សុមេធបណ្ឌិតបានទទួលព្យាករណ៍ក្នុងសំណាក់ព្រះពុទ្ធទីបង្ករ ជាលើកទី១ ។

### ៣. កាយវចីមនោបណិធាន

បន្ទាប់ពីបានទទួលការព្យាករមក ព្រះពោធិសត្វត្រូវបំពេញពុទ្ធការកធម៌ ចំនួន ៤ អសង្ខេយ្យ និង ១ សែនកប្បទៀត[១៥] ។

### ខ. ព្រះពោធិសត្វបំពេញបារមី ៤ អសង្ខេយ្យ ជានិយតពោធិសត្វ

៤ អសង្ខេយ្យនេះមាន :

១. សេលអសង្ខេយ្យ

២. ភាសអសង្ខេយ្យ

៣. ជេយ្យអសង្ខេយ្យ

៤. រុចិយអសង្ខេយ្យ

ក្នុងសេលអសង្ខេយ្យនេះឯង សុមេធបណ្ឌិតបានទទួលព្យាករណ៍ពីព្រះសម្មាសម្ពុទ្ធព្រះនាម **ទីបង្ករ** ។ កាលផុតសេលអសង្ខេយ្យហើយ មានកប្បមួយឈ្មោះ**សារកប្ប** មានព្រះពុទ្ធមួយព្រះអង្គប៉ុណ្ណោះ ដែលទ្រង់ឧប្បត្តិក្នុងលោកគឺ **ព្រះពុទ្ធកោណ្ឌញ្ញៈ** ។ កាលនោះ ព្រះពោធិសត្វ យោនយកកំណើតជាស្តេចចក្រពត្តិ មាននាមថា **វិជិតាវី** សោយរាជ្យក្នុងនគរចន្ទវតី

[១៥] ក្នុងករណីនេះ សំដៅយកតែពោធិសត្វដែលកសាងបុណ្យបារមីជាបញ្ញាធិក ។

ទ្រង់បានថ្វាយទានចំពោះព្រះសង្ឃមានព្រះពុទ្ធកោណ្ឌញ្ញៈជាប្រធាន ។ ព្រះពុទ្ធអង្គនោះ ទ្រង់បានព្យាករលើកទី២ ។

កាលសេលអសង្ខេយ្យកន្លងផុតទៅ មកដល់អសង្ខេយ្យមួយទៀត ឈ្មោះថា **ភាសអសង្ខេយ្យ** ។ ក្នុងភាសអសង្ខេយ្យនោះ ក៏បានកន្លងផុតទៅទៀត មកដល់កប្បមួយឈ្មោះថា**សារមណ្ឌកប្ប** មានព្រះពុទ្ធ ៤ ព្រះអង្គ ត្រាស់ដឹងក្នុងលោកគឺ **ព្រះពុទ្ធមង្គលៈ១ ព្រះពុទ្ធសុមនៈ១ ព្រះពុទ្ធរេវតៈ១ ព្រះពុទ្ធសោភិតៈ១** ។

កាល **ព្រះសម្មាសម្ពុទ្ធមង្គលៈ** ទ្រង់ត្រាស់ដឹងក្នុងលោក ព្រះពោធិសត្វ យោនយកកំណើតជាព្រាហ្មណ៍ឈ្មោះ**សុរុចិ** បានថ្វាយទានចំពោះព្រះសង្ឃមានព្រះពុទ្ធមង្គលៈជាប្រធាន ហើយទទួលព្យាករណ៍លើកទី៣ ។

កាល **ព្រះសម្មាសម្ពុទ្ធសុមនៈ** ទ្រង់ត្រាស់ដឹងក្នុងលោក ព្រះពោធិសត្វ យោនយកកំណើតជានាគមួយឈ្មោះ**អតុលៈ** បានថ្វាយទាន និងធ្វើសក្ការៈយ៉ាងធំ ចំពោះព្រះសង្ឃមានព្រះពុទ្ធសុមនៈជាប្រធាន ហើយទទួលព្យាករណ៍លើកទី៤ ។

កាល **ព្រះសម្មាសម្ពុទ្ធរេវតៈ** ទ្រង់ត្រាស់ដឹងក្នុងលោក ព្រះពោធិសត្វ យោនយកកំណើតជាព្រាហ្មណ៍ឈ្មោះ**អតិទេវៈ** បានថ្វាយចីវរទានចំពោះព្រះពុទ្ធរេវតៈ ហើយទទួលព្យាករណ៍លើកទី៥ ។

កាល **ព្រះសម្មាសម្ពុទ្ធសោភិតៈ** ទ្រង់ត្រាស់ដឹងក្នុងលោក ព្រះពោធិសត្វ យោនយកកំណើតជាព្រាហ្មណ៍ឈ្មោះ**សុជាតៈ** បានថ្វាយមហាទានចំពោះព្រះសង្ឃមានព្រះពុទ្ធសោភិតៈជាប្រធាន ហើយទទួលការព្យាករលើកទី៦ ។

កាលសារមណ្ឌកប្បផុតទៅ ក៏មកដល់អសង្ខេយ្យមួយទៀត ឈ្មោះថា **ជេយ្យអសង្ខេយ្យ** ជាសុញ្ញអសង្ខេយ្យ មិនមានព្រះពុទ្ធត្រាស់ដឹងក្នុងលោកឡើយ ។ កាលសុញ្ញអសង្ខេយ្យនោះកន្លងផុតទៅ ក៏បានមកដល់កប្បមួយទៀតឈ្មោះថា **វរកប្ប** មានព្រះពុទ្ធ ៣ ព្រះអង្គ ត្រាស់ដឹងក្នុងលោកគឺ **ព្រះពុទ្ធអនោមទស្សី១ ព្រះពុទ្ធបទុមៈ១ ព្រះពុទ្ធនារទៈ១** ។

ក្នុងសម័យកាល **ព្រះពុទ្ធអនោមទស្សី** ព្រះពោធិសត្វយោនយកកំណើតជា**យក្ខ** មានតំណែងជាសេនាបតី បាននិម្មិតមណ្ឌបយ៉ាងស្អាតវិចិត្រ ហើយបានថ្វាយមហាទានចំពោះព្រះភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ព្រះពុទ្ធអនោមទស្សី ក៏ទ្រង់ព្យាករលើកទី៧ ។

ក្នុងសម័យ **ព្រះពុទ្ធបទុមៈ** ព្រះពោធិសត្វ យោនយកកំណើតជា **រាជសីហ៍** ឃើញព្រះពុទ្ធបទុមៈអង្គនោះ ទ្រង់ចូលនិរោធសមាបត្តិក្នុងព្រៃ ៧ ថ្ងៃ ហើយក៏នមស្ការធ្វើប្រទក្សិណ រួចបន្លឺសីហនាទ ៣ ដង ក៏ចៀសចេញទៅ។ ព្រះពុទ្ធបទុមៈ ទ្រង់បានព្យាករលើកទី៨ ។

ក្នុងសម័យ **ព្រះពុទ្ធនារទៈ** ព្រះពោធិសត្វបួសជា**ឥសី** បានថ្វាយមហាទាន និងបូជាដោយខ្លឹមចន្ទន៍ចំពោះព្រះភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ។ ព្រះពុទ្ធនារទៈ ក៏ទ្រង់ព្យាករលើកទី៩ ។

កាលវរកប្បកន្លងផុតទៅ ក៏មកដល់អសង្ខេយ្យមួយទៀតឈ្មោះ រុចិយអសង្ខេយ្យ គឺជាសុញ្ញអសង្ខេយ្យដែរ មិនមានព្រះពុទ្ធត្រាស់ដឹងឡើយ ។

ក្នុងអសង្ខេយ្យទាំង ៤ មានព្រះពុទ្ធត្រាស់ដឹងចំនួន ១២ ព្រះអង្គ ។

**គ. ព្រះពោធិសត្វបំពេញបារមី ១ សែនកប្ប ជានិយតពោធិសត្វ**

នៅខាងដើម ១ សែនកប្បនោះ មានកប្បមួយឈ្មោះថា សារកប្ប មានព្រះពុទ្ធ ១ ព្រះអង្គ ទ្រង់ត្រាស់ដឹងក្នុងលោកគឺ ព្រះពុទ្ធបទុមុត្តរៈ ។

ក្នុងសម័យកាល **ព្រះពុទ្ធបទុមុត្តរៈ** ព្រះពោធិសត្វមានឈ្មោះថា **ជដិលៈ** បានថ្វាយមហាទានមានសំពត់ចីវរ និងភត្តាហារចំពោះព្រះភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ។ ព្រះពុទ្ធបទុមុត្តរៈ ទ្រង់បានព្យាករលើកទី១០ ។

កាលតមក ព្រះពុទ្ធជាម្ចាស់មិនឧប្បត្តិឡើងក្នុងលោក មានចំនួន ៦៩.០០០ កប្ប[១៦] ។ តមកទៀត ចូលមកខាងដើម ៣០.០០០ កប្ប ។ ក្នុងមណ្ឌកប្បមានព្រះពុទ្ធទ្រង់ឧប្បត្តិឡើង ២ ព្រះអង្គគឺ **ព្រះពុទ្ធសុមេធៈ១ ព្រះពុទ្ធសុជាតៈ១** ។

ក្នុងសម័យកាល **ព្រះពុទ្ធសុមេធៈ** ព្រះពោធិសត្វយោនយកកំណើតជាមាណពឈ្មោះ **ឧត្តរៈ** បានបរិច្ចាគទ្រព្យ ៨០ កោដិកហាបណៈ ថ្វាយមហាទានចំពោះព្រះភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ។ ព្រះពុទ្ធសុមេធៈ ទ្រង់បានព្យាករលើកទី១១ ។

ក្នុងសម័យកាល **ព្រះពុទ្ធសុជាតៈ** ព្រះពោធិសត្វយោនកំណើតជា **ស្តេចចក្រពត្តិ** លោកថ្វាយរាជសម្បត្តិទាំង ៤ ទ្វីប និងរតនៈ ៧ ប្រការ ចំពោះព្រះភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ហើយក៏ចេញបព្វជ្ជា ។ ព្រះពុទ្ធសុជាតៈ ទ្រង់ព្យាករថា បព្វជិតចក្រពត្តិនេះ នឹងត្រាស់ជាព្រះពុទ្ធមួយអង្គ បន្ទាប់ពីនេះ ៣០.០០០ កប្បទៀត ។ ព្រះពុទ្ធសុជាតៈ ក៏ទ្រង់ព្យាករលើកទី១២ ។ បន្ទាប់ពីមណ្ឌកប្បនោះទៅ មកដល់ខាងដើម ១.៨០០ កប្ប ។ មានកប្បមួយឈ្មោះ **វរកប្ប** មានព្រះពុទ្ធ ៣ ព្រះអង្គទ្រង់ត្រាស់ដឹងគឺ **ព្រះពុទ្ធបិយទស្សី១ ព្រះពុទ្ធអត្ថទស្សី១ ព្រះពុទ្ធធម្មទស្សី១** ។

[១៦] ចន្លោះរវាងកប្បទី ១សែន និងកប្បទី ៣ម៉ឺន អំពីភទ្ទកប្បនេះ ។

ក្នុងសម័យកាល **ព្រះពុទ្ធបិយទស្សី** ព្រះពោធិសត្វយោនយកកំណើតជាព្រាហ្មណ៍ឈ្មោះ **កស្សបៈ** បានកសាងអារាមមួយ អស់ប្រាក់ ១០០.០០០ កោដិកហាបណៈ ថ្វាយចំពោះព្រះភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ។ ព្រះពុទ្ធបិយទស្សី ទ្រង់ព្យាករថា ព្រាហ្មណ៍កស្សបៈនេះនឹងត្រាស់ជាព្រះពុទ្ធមួយព្រះអង្គ បន្ទាប់ពីនេះ ១.៨០០ កប្ប[១៧] ទៀត ។ ព្រះពុទ្ធបិយទស្សី ទ្រង់បានព្យាករជាលើកទី១៣ ។

ក្នុងសម័យកាល **ព្រះពុទ្ធអត្ថទស្សី** ព្រះពោធិសត្វយោនយកកំណើតជា **សុសិមជដិល** បាននាំផ្កាទិព្វពីឋានសួគ៌ (ផ្កាមន្ទារវបុស្ស ផ្កាបទុម និងផ្កាបារិច្ឆត្តកព្រឹក្ស) បូជាចំពោះព្រះសម្មាសម្ពុទ្ធ ។ ព្រះពុទ្ធអត្ថទស្សី ទ្រង់ព្យាករថា ជដិលនេះនឹងត្រាស់ជាព្រះពុទ្ធមួយអង្គ ក្នុងអនាគតកាល បន្ទាប់ពីនេះ ១.៨០០ កប្ប ។ ព្រះពុទ្ធអត្ថទស្សី ទ្រង់បានព្យាករជាលើកទី១៤ ។

[១៧] ក្នុងអដ្ឋកថា ពុទ្ធវំស និងចរិយាបិដក បញ្ជាក់ថា ១.៨០០ កប្ប ។ អដ្ឋកថា មហាវគ្គ បញ្ជាក់ថា តាំងពីកប្បនេះទៅ មិនតិចជាង ១៨.០០០ កប្ប ។ ដីកាបញ្ជាក់ថា មិនតិចជាង ១៨.០០០ កប្បនោះ គឺក្នុងរវាងព្រះពុទ្ធសុជាតៈ និងព្រះពុទ្ធបិយទស្សី ដាច់សូន្យឈឹងអស់ ១២.០០០ កប្ប ជាសុញ្ញកប្ប មិនមានព្រះពុទ្ធត្រាស់ដឹងទេ ។ តែក្នុងអដ្ឋកថា ពុទ្ធវំស និងចរិយាបិដក បញ្ជាក់នោះត្រូវហើយ ព្រោះរវាងព្រះពុទ្ធសុជាតៈ និងព្រះពុទ្ធបិយទស្សី ជាសុញ្ញកប្បនោះ អស់វេលាចំនួន ២៩.៨៨២ កប្ប ។

ក្នុងកាល **ព្រះពុទ្ធធម្មទស្សី** ព្រះពោធិសត្វយោនយកកំណើតជា **ព្រះឥន្ទ** បូជាព្រះសម្មាសម្ពុទ្ធធម្មទស្សី ដោយគ្រឿងសក្ការៈយ៉ាងច្រើន ។ ព្រះពុទ្ធធម្មទស្សី ទ្រង់ព្យាករថា ស្តេចសក្កទេវរាជនេះ នឹងត្រាស់ជាព្រះពុទ្ធ បន្ទាប់ពីនេះ ១.៨០០ កប្បទៀត ។ ព្រះពុទ្ធធម្មទស្សី ទ្រង់ព្យាករជាលើកទី១៥ ។

កាលវរកប្បនោះកន្លងទៅហើយ ក៏ឈានចូលមកខាងដើមនៃ ៩៤ កប្ប ។ មានកប្បមួយឈ្មោះ សារកប្ប ។ ក្នុងសារកប្បនោះ មានព្រះពុទ្ធមួយអង្គព្រះនាម **ព្រះពុទ្ធសិទ្ធត្ថៈ** ទ្រង់ត្រាស់ដឹងក្នុងលោក ។

ក្នុងសម័យកាល **ព្រះពុទ្ធសិទ្ធត្ថៈ** ព្រះពោធិសត្វបួសជាតាបសមានឈ្មោះថា **មង្គលៈ** បានថ្វាយផ្លែព្រីងចំពោះព្រះពុទ្ធអង្គ ។ ព្រះពុទ្ធសិទ្ធត្ថៈ ទ្រង់ព្យាករថា បន្ទាប់ពីនេះ ៩៤ កប្បទៀត តាបសនេះនឹងបានត្រាស់ជាព្រះពុទ្ធមួយអង្គ ព្រះនាមថា **ព្រះពុទ្ធគោតម** ។ ព្រះពុទ្ធសិទ្ធត្ថៈ ទ្រង់បានព្យាករលើកទី១៦ ។

ក្នុងកាលតមក មានកប្បមួយជាសុញ្ញកប្ប គឺកប្បសូន្យ ដែលពុំមានព្រះពុទ្ធត្រាស់ដឹងទេ ។ បន្ទាប់ពីសុញ្ញកប្បនោះ ក៏ឈានចូលមកខាងដើម ៩២ កប្ប មានកប្បមួយឈ្មោះ **មណ្ឌកប្ប** មានព្រះពុទ្ធត្រាស់ដឹង ២ ព្រះអង្គ គឺ **ព្រះពុទ្ធតិស្សៈ** និង **ព្រះពុទ្ធបុស្សៈ**[១៨] ។

---

[១៨] ច្បាប់ខ្លះថា ផុស្សៈ ក៏មាន ។

ក្នុងកាល **ព្រះពុទ្ធតិស្ស:** ព្រះពោធិសត្វជាក្សត្រទ្រង់នាម **សុជាត:** ទ្រង់លះបង់រាជសម្បត្តិបួសជាតាបស បាននាំផ្កាទិព្វមកបូជា ចំពោះព្រះដ៏មានព្រះភាគ ។ ព្រះពុទ្ធតិស្ស: ទ្រង់ព្យាករថា តាបសនេះនឹងត្រាស់ជាព្រះពុទ្ធមួយអង្គព្រះនាមថា គោតម បន្ទាប់ពីនេះទៅ ៩២ កប្បទៀត ។ ព្រះពុទ្ធតិស្ស: ទ្រង់បានព្យាករលើកទី១៧ ។

ក្នុងសម័យកាល **ព្រះពុទ្ធបុស្ស:** ព្រះពោធិសត្វយោនកំណើតជាក្សត្រនាម **វិជិតាវី** បានលះបង់រាជសម្បត្តិហើយចេញបព្វជ្ជា ។ ព្រះពុទ្ធបុស្ស: ទ្រង់ព្យាករថា បព្វជិតរូបនេះ នឹងត្រាស់ដឹងជាព្រះពុទ្ធ បន្ទាប់ពីនេះ ៩២ កប្បទៀត ។ ព្រះពុទ្ធបុស្ស: ទ្រង់បានព្យាករលើកទី១៨ ។

កាលកន្លងមណ្ឌកប្បនោះទៅ ឈានចូលមកខាងដើម ៩១ កប្ប ក៏មានកប្បមួយឈ្មោះ **សារកប្ប** ។ ក្នុងសារកប្បនោះ មានព្រះពុទ្ធមួយអង្គព្រះនាម **ព្រះពុទ្ធវិបស្សី** ត្រាស់ដឹងក្នុងលោក ។ ក្នុងកាលនោះ ព្រះពោធិសត្វយោនយកកំណើតជានាគមួយ ឈ្មោះថា **អតុល:** បានបូជាចំពោះព្រះដ៏មានព្រះភាគនូវតូរ្យតន្ត្រីទិព្វ ។ ព្រះពុទ្ធវិបស្សី ទ្រង់ព្យាករថា នាគនេះនឹងបានត្រាស់ដឹងជាព្រះពុទ្ធ បន្ទាប់ពីនេះ ៩១ កប្បទៀត ។ ព្រះពុទ្ធវិបស្សី ទ្រង់បានព្យាករលើកទី១៩ ។

កាលកប្បនោះកន្លងទៅយ៉ាងយូរ ក៏ឈានចូលមកដល់ខាងដើម នៃ ៣១ កប្ប ។ មានកប្បមួយឈ្មោះ មណ្ឌកប្ប មានព្រះពុទ្ធ ២ ព្រះអង្គទ្រង់ត្រាស់ដឹងក្នុងលោកគឺ **ព្រះពុទ្ធសិខី** និង **ព្រះពុទ្ធវេស្សភូ** ។

ក្នុងសម័យកាល **ព្រះពុទ្ធសិខី** ព្រះពោធិសត្វយោនយកកំណើតជាក្សត្រព្រះនាមថា **អរិន្ទម:** បានថ្វាយសំពត់មានសាច់យ៉ាងល្អ និងពាហនៈដំរីទ្រង់គ្រឿង ចំពោះព្រះភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ។ ព្រះពុទ្ធសិខី ទ្រង់ព្យាករថា ក្សត្រអរិន្ទមៈនេះ នឹងបានត្រាស់ដឹងជាព្រះពុទ្ធមួយអង្គក្នុងលោក បន្ទាប់ពីនេះ ៣១ កប្បទៀត ។ ព្រះពុទ្ធសិខី ទ្រង់ព្យាករលើកទី២០ ។

ក្នុងសម័យកាល **ព្រះពុទ្ធវេស្សភូ** ទ្រង់ត្រាស់ដឹងក្នុងលោក ព្រះពោធិសត្វយោនកំណើតជាក្សត្រ **សុទស្សនៈ** ថ្វាយនូវមហាទានចំពោះព្រះពុទ្ធអង្គ ។ ព្រះពុទ្ធវេស្សភូ ទ្រង់ព្យាករថា ក្សត្រអង្គនេះនឹងត្រាស់ជាព្រះពុទ្ធ បន្ទាប់ពីនេះ ៣១ កប្បទៀត ។ ព្រះពុទ្ធវេស្សភូ ទ្រង់ព្យាករជាលើកទី២១ ។

បន្ទាប់មក មិនមានព្រះពុទ្ធត្រាស់ដឹង អស់ចំនួន ២៩ កប្ប ក៏ឈានចូលមកដល់កប្បមួយឈ្មោះ ភទ្ទកប្ប ដែលមានព្រះពុទ្ធ ៥ ព្រះអង្គត្រាស់ដឹងឡើងក្នុងលោកគឺ **ព្រះពុទ្ធកកុសន្ធៈ១ ព្រះពុទ្ធកោនាគមនៈ១ ព្រះពុទ្ធកស្សបៈ១ ព្រះពុទ្ធគោតម១** (ព្រះពុទ្ធអង្គបច្ចុប្បន្នយើងនេះ) និង**ព្រះពុទ្ធមេត្តេយ្យ១** (នឹងត្រាស់ដឹងក្នុងកាលខាងមុខ) ។

ក្នុងភទ្ទកប្បនេះ កាលមនុស្សមានអាយុ ៤០.០០០ ឆ្នាំ មានព្រះពុទ្ធត្រាស់ដឹងក្នុងលោកគឺ **ព្រះពុទ្ធកក្កុសន្ធៈ** ។ ក្នុងកាលនោះ ព្រះពោធិសត្វយោនកំណើតជាក្សត្រនាម **ខេមៈ** បានថ្វាយមហាទានយ៉ាងច្រើន ចំពោះព្រះសម្មាសម្ពុទ្ធ និងភិក្ខុសង្ឃ ។ ព្រះពុទ្ធកក្កុសន្ធៈ ទ្រង់ព្យាករថា ក្នុងភទ្ទកប្បនេះ ក្សត្រ**ខេមៈ**នេះ នឹងត្រាស់ជាព្រះពុទ្ធ ។ ព្រះពុទ្ធកក្កុសន្ធៈ ទ្រង់បានព្យាករលើកទី២២ ។

បន្ទាប់មក កាលមនុស្សមានអាយុ ៣០.០០០ ឆ្នាំ មានព្រះពុទ្ធអង្គទ្រង់ត្រាស់ដឹងក្នុងលោកគឺ **ព្រះពុទ្ធកោនាគមនៈ** ។ ក្នុងកាលនោះ ព្រះពោធិសត្វយោនកំណើតជាក្សត្រនាម **បព្វតៈ** បានថ្វាយវត្ថុ ៤ មុខគឺ សំពត់ចិនប្រទេស១ សំពត់សូត្រ១ សំពត់កម្ពល១ ស្បែកជើងមាស១ ចំពោះព្រះពុទ្ធកោនាគមនៈ និងភិក្ខុសង្ឃទាំងឡាយជាសាវ័ក ។ ព្រះពុទ្ធកោនាគមនៈ ទ្រង់ព្យាករថា មហាបុរសនេះ នឹងត្រាស់ជាព្រះពុទ្ធក្នុងភទ្ទកប្បនេះ ។ ព្រះពុទ្ធកោនាគមនៈ ទ្រង់ព្យាករលើកទី២៣។

កាលមនុស្សមានអាយុថយចុះ និងចម្រើនឡើង ហើយថយចុះមកត្រឹមអាយុ ២០.០០០ ឆ្នាំ មានព្រះពុទ្ធអង្គទ្រង់ត្រាស់ដឹងឡើងក្នុងលោកគឺ **ព្រះពុទ្ធកស្សបៈ** ។

ក្នុងកាលនោះ ព្រះពោធិសត្វ យោនយកកំណើតជា **ជោតិបាលមាណព** ចេញបួសក្នុងសម្នាក់ព្រះពុទ្ធអង្គនោះ ជាអ្នកមានសីលវត្តបរិសុទ្ធល្អ ។ ព្រះពុទ្ធកស្សបៈ ទ្រង់ព្យាករថា ជោតិបាលភិក្ខុនេះនឹងត្រាស់ជាព្រះពុទ្ធក្នុងភទ្ទកប្បនេះ ។ ព្រះពុទ្ធកស្សបទសពល ទ្រង់ព្យាករជាលើកទី២៤ ។

កាលព្រះពុទ្ធកស្សបៈ ទ្រង់បានបរិនិព្វាន, នៅពេលមនុស្សមានអាយុ ២០.០០០ ឆ្នាំ ក៏ថយចុះមករហូតដល់ ១០ ឆ្នាំ ជាអាយុក្ខ័យ ហើយបានចម្រើនឡើងវិញរហូតដល់អាយុ ១ អសង្ខេយ្យឆ្នាំ ជាអាយុក្ខ័យ ហើយក៏ធ្លាក់ចុះមកដល់ត្រឹម ១០០ ឆ្នាំ ជាអាយុក្ខ័យ ។ គ្រានោះ **ព្រះពុទ្ធសមណគោតម** ក៏ទ្រង់ត្រាស់ដឹងឡើងក្នុងលោកយើងនេះ ។៚

(សូមមេត្តាអានប្រវត្តិព្រះសមណគោតម ត្រង់ជំពូកទី៦ ខាងមុខ) ។

# ជំពូកទី ៤
# សុមេធបណ្ឌិត និងការប្រកាសអភិនីហារ

## ១. សុមេធបណ្ឌិតចេញសាងផ្នួស

មុនភទ្ទកប្បនេះចំនួន ៤ អសង្ខេយ្យ ១ សែនកប្ប មាននគរមួយឈ្មោះថា អមរវតី ។ ក្នុងកាលនោះឯង ព្រះសមណគោតមបរមគ្រូនៃយើង បានយោនយកកំណើតក្នុងត្រកូលព្រាហ្មណ៍ជាឧភតោសុជាត បរិសុទ្ធទាំងខាងមាតាទាំងខាងបិតា រហូត ៧ ជំនាន់ មានឈ្មោះថា **សុមេធបណ្ឌិត** ហើយមិនមានបុគ្គលណាមួយអាចតិះដៀលបានឡើយ ព្រោះមានរូបគួរជាទីរមិលមើល មានសម្បុរគួរជាទីជ្រះថ្លា ជាអ្នកជំនាញក្នុងត្រៃវេទទាំង ៣[១៩] ។ លោកជាអ្នកឈ្លាសក្នុងវេយ្យាករណ៍ទាំងឡាយ មានគម្ពីរសនិឃណ្ឌុសាស្ត្រ កេដុភសាស្ត្រ សាក្ខរប្បភេទសាស្ត្រ និងឥតិហាសៈ និងជំនាញក្នុងលោកាយតមហាបុរិសលក្ខណៈ ជាគម្រប់ ៥ ។ ក្នុងពេលវ័យកំលោះ មាតាបិតាក៏ធ្វើមរណកាលទៅ ។ គ្រានោះ សិរីវឌ្ឍកាមាត្យ បានយកបញ្ជីទ្រព្យមករៀបរាប់ ហើយបើកឃ្លាំងទ្រព្យទាំងនោះ មានរតនៈ មាស ប្រាក់ កែវមណី កែវមុក្តាជាដើម ហើយប្រគល់ឱ្យសុមេធបណ្ឌិត ដោយបញ្ជាក់ថា :

[១៩] មធុរត្ថវិលាសិនី អដ្ឋកថា ពុទ្ធវំស បញ្ជាក់ថា ត្រៃវេទទាំងបីគឺ ឥរុវេទ១ យជុវេទ១ សាមវេទ១ ។

បពិត្រលោកម្ចាស់ ទ្រព្យមានប្រមាណប៉ុណ្ណោះ ជាចំណែកខាងមាតា ឯទ្រព្យមានប្រមាណប៉ុណ្ណោះ ជាចំណែកខាងបិតា និងចំណែកខាងជីដូនជីតា តាទួតយាយទួត រហូតទ្រព្យនេះបន្តមក ៧ តំណមកហើយ ចូរលោកម្ចាស់ទទួលយកប្រើប្រាស់ ចាត់ចែងនូវទ្រព្យនេះចុះ ពីថ្ងៃនេះទៅ លោកម្ចាស់នឹងជាម្ចាស់ទ្រព្យទាំងអស់នេះហើយ ។

គ្រានោះ សុមេធបណ្ឌិតពិចារណាថា :

ញាតិទាំងឡាយមានមាតាបិតាជាដើម ប្រមូលទ្រព្យសម្បត្តិ រួមមានដីស្រែ ចម្ការ គោ ក្របី សេះ ដំរី និងខ្ញុំកំដរទាសាទាសីដ៏ច្រើនឥតគណនា ។ លោកបានលះបង់នូវអត្តភាពរបស់ខ្លួនទៅកាន់លោកខាងមុខ ដោយមិនយកទ្រព្យ សូម្បីត្រឹមមួយកហាបណៈទៅតាមខ្លួនឡើយ ។ បើដូច្នេះ មានតែអាត្មាអញនឹងចាត់ចែងនូវទ្រព្យនេះ ឱ្យសមគួរដល់កុសលកម្មទាំងឡាយ ដើម្បីជាទីពឹងរបស់អាត្មាអញ ។

ក្នុងពេលនោះឯង ព្រះពោធិសត្វឡើងទៅកាន់ប្រាសាទខាងលើ ពួនសំងំអង្គុយពែនភ្នែនក្នុងទីស្ងាត់ ហើយពិចារណាទៀតថា :

ធម្មតាភពថ្មីទៀត តែងនាំមកនូវសេចក្តីទុក្ខ ការបែកធ្លាយសរីរៈ ក៏

នាំមកនូវសេចក្ដីទុក្ខដូចគ្នា ។ សេចក្ដីស្លាប់ប្រកបដោយមោហៈ ក៏នាំមកនូវសេចក្ដីទុក្ខ រូបដែលជរាញាំញី ក៏នាំមកនូវសេចក្ដីទុក្ខ ។ អាត្មាអញមានជាតិជាធម្មតា មានជរាជាធម្មតា មានព្យាធិជាធម្មតា ។ អាត្មាអញនឹងស្វែងរកព្រះនិព្វានដែលមិនចាស់ មិនស្លាប់ ជាទីក្សេមក្សាន្ត ។ បើដូច្នោះ អាត្មាអញគួរតែលះបង់កាយស្អុយនេះ ដែលពោរពេញដោយសាកសពផ្សេងៗ ជាទីមិនគួរឱ្យអាឡោះអាល័យ មិនមានសេចក្ដីត្រូវការ ហើយនឹងចេញទៅ ។ ផ្លូវនោះនឹងមានពិត ផ្លូវនោះមិនមែនគ្មានហេតុនោះទេ អាត្មាអញនឹងស្វែងរកផ្លូវនោះ ដើម្បីដោះខ្លួនចាកភព ។ កាលបើទុក្ខមាន សុខក៏មាន យ៉ាងណាកាលបើភពមាន ការប្រាសចាកភព បុគ្គលគួរតែប្រាថ្នារកក៏យ៉ាងនោះដែរ ។ កាលបើក្ដៅមាន ត្រជាក់ក៏មាន យ៉ាងណា កាលបើភ្លើង ៣ ប្រការ[២០] មាន ប្រភពនៃជាតិដែលជាទឹកត្រជាក់ សម្រាប់ពន្លត់នូវភ្លើងនោះក៏មាន ។ កាលបើបាបមាន បុណ្យក៏មាន យ៉ាងណា កាលបើជាតិមានព្រះនិព្វានដែលពុំមានជាតិ ក៏មានយ៉ាងនោះដែរ ។ បុរសដែលប្រឡាក់លាមក ឃើញស្រះពេញដោយទឹកថ្លា ហើយមិនស្វែងចុះក្នុងស្រះដើម្បីលាងលាមក ទោសនោះមិនមែនជាទោសនៃស្រះទេ

[២០] ភ្លើង ៣ ប្រការគឺ លោភៈ១ ទោសៈ១ មោហៈ១ ។

យ៉ាងណាមិញ កាលបើស្រះ គឺព្រះនិព្វានមានហើយ បុគ្គលមិនស្វែងរកស្រះសម្រាប់លាងនូវកិលេសជាមន្ទិលចេញទេ ទោសនោះមិនមែនជាទោសនៃស្រះ គឺនិព្វានទេ គឺជាទោសរបស់បុរសក៏យ៉ាងនោះដែរ ។ បុរសដែលត្រូវសត្រូវទាំងឡាយចោមព័ទ្ធហើយ កាលបើផ្លូវសម្រាប់រត់ទៅមាន តែបុរសនោះមិនរត់ទៅ ទោសនោះមិនមែនជាទោសនៃផ្លូវទេ យ៉ាងណាបុគ្គលត្រូវកិលេសរួបរឹតហើយ កាលបើផ្លូវព្រះនិព្វានមាន តែបើមិនស្វែងរកផ្លូវនោះ ទោសនោះមិនមែនជាទោសនៃផ្លូវនិព្វានទេ គឺជាទោសរបស់បុគ្គលនោះឯង ក៏យ៉ាងនោះដែរ ។ បុរសដែលមានជំងឺ កាលបើពេទ្យមាន តែមិនឱ្យពេទ្យព្យាបាលជំងឺនោះទេ ទោសនោះមិនមែនជាទោសនៃពេទ្យទេ យ៉ាងណាបុគ្គលមានជំងឺ គឺកិលេសទាំងឡាយបៀតបៀន ហើយដល់នូវសេចក្តីទុក្ខ មិនស្វះស្វែងរកអាចារ្យ ទោសនោះមិនមែនជាទោសនៃអាចារ្យទេ គឺជាទោសរបស់បុគ្គលនោះឯង ក៏យ៉ាងនោះដែរ ។

បន្ទាប់ពីពិចារណាយ៉ាងល្អិតល្អន់ ជ្រាលជ្រៅ លើមូលហេតុនៃទុក្ខទោសកើតកិលេស ដែលតែងតែជាន់ឈ្លីលើសត្វលោកហើយ សុមេធបណ្ឌិតបន្តការត្រិះរិះទៀតថា ៖

គួរតែអាត្មាអញលះបង់កាយស្អុយនេះ ដែលពេញដោយសាកសពផ្សេងៗចេញ គប្បីជាអ្នកមិនមានសេចក្តីអាឡោះអាល័យ មិនមានសេចក្តីត្រូវការរូប ដូចបុរសស្រាយសាកសពដ៏គួរឱ្យខ្ពើមរអើមដែលជាប់ត្រង់ក គប្បីជាអ្នកមានសេចក្តីសុខ ទៅតាមទំនើងខ្លួនមានអំណាចខ្លួនឯង យ៉ាងណាមិញ, អាត្មាអញគួរតែលះបង់នូវកាយស្អុយនេះ ដែលជាទីប្រមូលមកនូវសាកសពផ្សេងៗចេញ ហើយគប្បីជាអ្នកមិនអាឡោះអាល័យ មិនមានសេចក្តីត្រូវការចេញទៅ យ៉ាងនោះដែរ ។ បុរសស្ត្រីទាំងឡាយទៅបន្ទោបង់នូវករីស: (លាមក) ក្នុងបង្គន់ហើយ ឥតមានអាឡោះអាល័យ ឥតមានសេចក្តីត្រូវការ ក៏ដើរចេញទៅ យ៉ាងណាមិញ អាត្មាអញនឹងលះបង់នូវកាយស្អុយនេះ ដែលពេញដោយសាកសពផ្សេងៗចេញទៅ ដូចបុរសស្ត្រីទាំងឡាយដែលបន្ទោបង់វច្ច: (លាមក) ក្នុងបង្គន់ដូច្នោះឯង ។ ម្ចាស់ទូកទាំងឡាយ តែងលះបង់ទូកចាស់ ដែលពុកផុយលេចចូលទឹក ឥតមានអាឡោះអាល័យ ឥតត្រូវការវិញ យ៉ាងណា អាត្មាអញនឹងលះបង់នូវកាយនេះ ដែលមានរន្ធ ៩ ហូរជានិច្ចហើយចេញទៅ ដូចជាម្ចាស់ទូកលះបោលទូកចាស់ដូច្នោះឯង ។ បុរសកាលដើរទៅជាមួយនឹងពួកចោរ ដោយយកទ្រព្យជាប់ទៅ

ផង ឃើញភ័យអំពីការខូចខាតទ្រព្យ ក៏លះបង់ទ្រព្យឱ្យចោរ ហើយដើរទៅយ៉ាងណា កាយនេះក៏មានឧបមាស្មើដោយមហា- ចោរ អាត្មាអញនឹងលះបង់នូវកាយនេះចេញ ព្រោះខ្លាចខូចខាត កុសលធម៌ ក៏យ៉ាងនោះដែរ ។

កាលសុមេធបណ្ឌិតពិចារណាយ៉ាងនេះហើយ ក៏ចូលទៅគាល់ព្រះរាជាក្នុងដែនអមរវតី បានថ្វាយទ្រព្យទាំងអស់ចំពោះព្រះអង្គ តែទ្រង់មិនទទួល  ដោយបដិសេធថា យើងមិនត្រូវការទ្រព្យទាំងនោះឡើយ ចូរអ្នកចាត់ចែងយ៉ាងណា តាមចិត្តរបស់អ្នកចុះ ។

ក្នុងកាលនោះ ព្រះពោធិសត្វបានឱ្យចែកទ្រព្យសម្បត្តិដល់អ្នកបម្រើខ្ញុំកំដរ និងដោះលែងទាសាទាសីឱ្យមានសេរីភាព ហើយឱ្យអ្នកបម្រើដើរវាយស្គរប្រកូកប្រកាសឱ្យមហាជនមកទទួលយកទ្រព្យពីគេហដ្ឋានរបស់លោក ។ កាលបើទ្រព្យដែលមហាជនកំពុងនាំគ្នាមកទទួលយកជាបន្តបន្ទាប់គ្នាមិន ដាច់ នៅមិនទាន់អស់ពីឃ្លាំងផង ព្រះពោធិសត្វ ក៏ធ្វើដំណើរឆ្ពោះទៅភ្នំ**ធម្មិកបព៌ត** ដែលស្ថិតនៅក្នុងព្រៃហេមពាន្ត ហើយបានកសាងអាស្រម គង់នៅក្នុងទីនោះទៅ ។

ព្រះពោធិសត្វ មានចិត្តបញ្ជូនទៅក្នុងកម្មដ្ឋានមិនយូរឡើយ ត្រឹមតែ ៧ ថ្ងៃ អំពីការបួស ក៏សម្រេចនូវអភិញ្ញា ៥ សមាបត្តិ ៨ ក្នុងអាស្រមនោះ ។

## ២. ព្រះសម្មាសម្ពុទ្ធទីបង្ករ ទ្រង់ត្រាស់ដឹងក្នុងលោក

ក្នុងសម័យកាលជាមួយគ្នានោះដែរ ព្រះពុទ្ធទីបង្ករ ទ្រង់យោនយកកំណើតជាព្រះពោធិសត្វនៅស្ថានតុសិត ហើយពួកទេវតាទាំងឡាយបាននាំគ្នាអារាធនា ព្រះអង្គក៏យាងចុះពីឋានតុសិតមកចាប់បដិសន្ធិក្នុងផ្ទៃ **ព្រះនាងសុមេធទេវី** ជាមហេសីព្រះបាទ**សុទេវរាជ** ជាស្តេចក្នុងរម្មវតីនគរ ក្នុងថ្ងៃ ១៥ កើត ខែអាសាឍ ។ ព្រះអង្គទ្រង់ស្ថិតក្នុងផ្ទៃគ្រប់ទសមាស ក៏ប្រសូតចាកគភ៌ព្រះមាតាតាមនិយាមរបស់ព្រះពោធិសត្វទាំងឡាយ គឺថ្ងៃ ១៥ កើតពេញបូណ៌មី ខែពិសាខ ។ ក្រោយមក ព្រះពោធិសត្វនឿយណាយក្នុងភាពជាគ្រហស្ថ ទ្រង់ក៏ចេញសាងផ្នួស រួមជាមួយនឹងបុរស ១ កោដិនាក់ ។ ព្រះពោធិសត្វ ទ្រង់ធ្វើសេចក្តីព្យាយាមអស់ចំនួន ១០ ខែ ។ ក្នុងថ្ងៃ ១៥ កើតពេញបូណ៌មី ខែពិសាខ ទ្រង់ចូលទៅបិណ្ឌបាតក្នុងនគរ រួមជាមួយនឹងបព្វជិតទាំងអស់ ដែលចេញបួសតាមព្រះអង្គ ។ ក្នុងពេលរសៀល ទ្រង់ចូលទៅសម្រាកក្នុងសាលវ័ន ជាមួយនឹងបព្វជិតទាំងអស់នោះ ។ ពេលនោះព្រះពោធិសត្វទីបង្ករ គេចខ្លួនពីពួកគណៈធ្វើដំណើរទៅតែមួយព្រះអង្គឯងក៏ទទួលនូវស្មៅចំនួន ៨ ក្តាប់ ពីសុនន្ទអាជីវក ទ្រង់ក៏យកទៅក្រាលក្រោមដើមបិប្ផលិពោធិព្រឹក្ស (ដើមល្វៀប) ត្រង់ផ្ចិតនៃផែនដី ។ ទ្រង់បានផ្ចាញ់នូវពួកមារ និងសេនាមារហើយ ក្នុងរាត្រីបឋមយាម ទ្រង់ក៏ចាក់ធ្លុះនូវបុព្វេនិវា-

សានុស្សតិញ្ញាណ ក្នុងរាត្រីមជ្ឈិមយាម ទ្រង់ចាក់ធ្លុះនូវចុតូបបាតញ្ញាណ ក្នុងរាត្រីបច្ឆិមយាម ទ្រង់ក៏បានអស់ទៅនូវអាសវក្កិលេសពីខន្ធសន្តាន ។

ក្នុងកាលព្រះអង្គទ្រង់ត្រាស់ដឹងហើយ មានព្រះអរហន្ត ៤០០.០០០ អង្គ ជាបរិវារ ហើយទ្រង់និមន្តតាមលំដាប់មកដល់**រម្មវតីនគរ** ព្រះអង្គក៏គង់អាស្រ័យនៅក្នុងសុទស្សនមហាវិហារ ។ អ្នករម្មវតីនគរទាំងឡាយ បានជ្រាបដំណឹង នៃការយាងមករបស់ព្រះពុទ្ធទីបង្ករនោះ ក៏ចាត់ចែងនូវភេសជ្ជៈទាំងឡាយមានទឹកដោះថ្លា ទឹកដោះខាប់ និងផ្កាកម្រង គ្រឿងក្រអូបជាដើម ចូលទៅក្នុងសុទស្សនមហាវិហារ បូជាចំពោះព្រះដ៏មានព្រះភាគអង្គនោះ ហើយស្តាប់ព្រះសទ្ធម្ម មានសេចក្តីជ្រះថ្លា ក៏អារាធនាព្រះអង្គ ឱ្យទទួលចង្ហាន់នៅក្នុងថ្ងៃស្អែក ។ លុះដល់ថ្ងៃស្អែកឡើង មហាជនក្នុងទីក្រុង បានចាត់ចែងមហាទាន តុបតែងទីក្រុង សម្អាតទីផ្លូវនៅតាមថ្នល់ឱ្យរាបស្មើ ចាក់ដីដែលនៅត្រង់ទីដែលមានជង្ហុក រោយរាយដីខ្សាច់មានពណ៌ដូចជាប្រាក់ ព្រមទាំងចងរំយោលផ្កា ដោតទង់ផ្កាលាយ៉ាងស្រស់ស្អាតនៅក្នុងទីក្រុងនោះ ។

## ៣. សុមេធបណ្ឌិត ទទួលព្យាករណ៍ និងប្រកាសអភិនីហារ

ក្នុងពេលនោះឯង ***សុមេធតាបស*** កំពុងហោះតាមអាកាស បានឃើញមនុស្សទាំងឡាយមានចិត្តរីករាយ កំពុងចាត់ចែងការងារ តាក់តែងទីក្រុង ក៏ចុះពីអាកាស ហើយសាកសួរមនុស្សទាំងឡាយនោះថា :

ការតាក់តែងទីក្រុងដ៏ប្លែកអស្ចារ្យនេះ តើដើម្បីប្រយោជន៍ និង
កិត្តិយសដល់បុគ្គលណា?

មនុស្សទាំងនោះឆ្លើយថា :

យើងនាំគ្នារៀបចំលម្អទីក្រុងនេះ ដើម្បីទទួលព្រះពុទ្ធជាម្ចាស់ ដែល
ទ្រង់ត្រាស់ដឹងឡើងក្នុងលោក! ។

សុមេធបណ្ឌិតក៏គិតឡើងថា សូម្បីត្រឹមតែឮពាក្យថា **ពុទ្ធោ** ជាពាក្យ
ដ៏កម្រក្នុងលោក មិនចាំបាច់ពោលទៅថ្វីដល់កាលមានភាពជាព្រះពុទ្ធ ។ បើ
ដូច្នោះ មានតែអាត្មាអញនឹងចាត់ចែងផ្លូវដើម្បីទទួលព្រះទសពលអង្គនោះ
ដែរ ។ ពេលនោះ **សុមេធបណ្ឌិត** ក៏និយាយសូមផ្លូវមួយចំណែកសម្រាប់ខ្លួន
ដើម្បីចាត់ចែង មនុស្សទាំងនោះក៏ទុកឱកាសដល់សុមេធបណ្ឌិតនូវជង្ហុក
ដែលមានទឹកច្រើន ដោយយល់ឃើញថា សុមេធតាបសនេះ ជាអ្នកមាន
ឫទ្ធិច្រើន អាចនឹងធ្វើយ៉ាងងាយដោយឫទ្ធិរបស់លោក ។

សុមេធតាបស មានព្រះពុទ្ធជាអារម្មណ៍ បានចាត់ចែងផ្លូវនោះ
ដោយកម្លាំងកាយធម្មតា ដោយគិតថា :

ប្រសិនបើអត្មាអញធ្វើទីនេះដោយឫទ្ធិ ហាក់បីដូចជាមិនសមគួរ
សម្រាប់បូជាដល់ព្រះពុទ្ធជាម្ចាស់ឡើយ ។

កាលនោះ សុមេធបណ្ឌិត នៅមិនទាន់ធ្វើផ្លូវហើយផង ស្រាប់តែព្រះពុទ្ធទីបង្ករ ព្រមទាំងព្រះអរហន្ត ៤០០.០០០ អង្គ និមន្តមកដល់ ។ សុមេធ-បណ្ឌិតសម្លឹងឃើញព្រះពុទ្ធទីបង្ករ ដោយភ្នែកទាំងគូ ដែលមានមហាបុរិស-លក្ខណៈ ៣២ ប្រការ អនុព្យញ្ជនៈ ៨០ និងពន្លឺ ១ ព្យាម ផ្សាយចេញពីព្រះវរកាយ ប្រកបដោយពុទ្ធរស្មី (ឆព្វណ្ណរង្សី ៦ ពណ៌) ។ សុមេធបណ្ឌិត មានសេចក្ដីជ្រះថ្លាឥតឧបមា ហើយបានធ្វើទុកក្នុងចិត្តថា :

ថ្ងៃនេះអាត្មាអញ នឹងបរិច្ចាគជីវិតថ្វាយព្រះទសពល សូមព្រះមានព្រះភាគ កុំនិមន្តជាន់ភក់! អាត្មាអញនឹងធ្វើជាស្ពានចម្លងព្រះមានព្រះភាគ និងព្រះភិក្ខុសង្ឃគ្រប់ព្រះអង្គឆ្លងកាត់ ដើម្បីសេចក្ដីចម្រើន ដើម្បីសេចក្ដីសុខសម្រាប់អាត្មាអញ! ។

រំពេចនោះសុមេធបណ្ឌិត រំសាយផ្នួងសក់ ហើយក្រាលនូវសំពត់សំបកឈើ ព្រមទាំងស្បែកសត្វនៅលើភក់ពណ៌ខ្មៅ ហើយក្រាបចុះលើភក់ធ្វើជាស្ពានថ្វាយព្រះសម្មាសម្ពុទ្ធ ។ កាលសុមេធបណ្ឌិត សម្លឹងឃើញនូវពុទ្ធសិរីរបស់ព្រះពុទ្ធទីបង្ករទសពល លោកក៏ពិចារណាគិតក្នុងចិត្តថា :

បើអាត្មាអញ ប្រាថ្នាដុតកិលេសរបស់ខ្លួនក្នុងថ្ងៃនេះ តែថាប្រយោជន៍អ្វី អាត្មាអញធ្វើឱ្យជាក់ច្បាស់នូវធម៌ដោយភេទ ដែលគេមិនស្គាល់ក្នុងទីនេះ អាត្មាអញ គប្បីដល់នូវសព្វញ្ញុតញ្ញាណ ជា

អ្នករួចស្រឡះចាកកិលេស ហើយញ៉ាំងលោក ព្រមទាំងទេវលោក ឱ្យរួចចាកសង្សារវដ្តទើបប្រសើរ ប្រយោជន៍អ្វីអាត្មាអញ ជាបុរសម្តែងកម្លាំងឆ្លងទៅតែម្នាក់ឯង អាត្មាអញគួរដល់នូវសព្វញ្ញុត-ញ្ញាណ ដើម្បីចម្លងមនុស្សលោក ព្រមទាំងទេវលោក ។ អាត្មាអញនឹងដល់នូវសព្វញ្ញុតញ្ញាណ ចម្លងប្រជុំជនច្រើនដោយអធិការនេះ ដែលអាត្មាអញធ្វើចំពោះព្រះពុទ្ធ ជាមហាបុរសដ៏ខ្ពង់ខ្ពស់បំផុត ។

គ្រានោះ មាននាងយុវតីម្នាក់ជាកូនព្រាហ្មណ៍ឈ្មោះ **សុមិត្តា** នៅក្នុងទីប្រជុំមហាជនដែរ ក៏មានចិត្តជ្រះថ្លាចំពោះទង្វើរបស់សុមេធបណ្ឌិត ក៏យកផ្កាឧប្បល ៨ ទង ចូលទៅជិតសុមេធបណ្ឌិត ហើយពោលថា :

បពិត្រឥសី ខ្ញុំមិនឃើញវត្ថុដទៃណាគួរជូនទេ ដូច្នេះ ផ្កា ៥ ទងនេះ សូមជូនដល់លោក ឯផ្កា ៣ ទងទៀត ខ្ញុំទុកសម្រាប់ថ្វាយព្រះសម្មាសម្ពុទ្ធ ។ បពិត្រឥសី ខ្ញុំសូមឱ្យមានអានិសង្សស្មើគ្នា ដើម្បីជាប្រយោជន៍ពោធិញ្ញាណចំពោះលោកចុះ ។ រីឯខ្ញុំវិញ សូមស្ម័គ្រចិត្តជួយបំពេញបារមីរបស់លោក ទោះបីជាមានសេចក្តីលំបាកយ៉ាង

ណា នៅក្នុងសង្សារវដ្ត ក៏ខ្ញុំសុខចិត្តព្រមដែរ សូមឱ្យនាងខ្ញុំបានជាកន្សែរសារពេជ្ជរបស់លោកផង ។[២១]

---

[២១] យោងតាមសៀវភៅ Buddhist Scriptures បោះពុម្ពក្នុងឆ្នាំ ១៩៥៧ ដោយលោកបណ្ឌិត EDWARD CONZE ដែលអធិប្បាយពីការជួបគ្នារវាងសុមេធបណ្ឌិត និងនាងសុមិត្តា មានសេចក្តីខុសគ្នាពីគម្ពីរអដ្ឋកថាត្រង់ចំណុចដូចខាងក្រោម ៖

១. នៅពេលដែលសុមេធតាបសធ្វើដំណើរមកបិណ្ឌបាត្រនៅក្នុងក្រុងអមរវតី លោកបានឃើញយុវតីដ៏ល្អប្រិមប្រិយម្នាក់កាន់ផ្កាឈូក ៧ ទង ធ្វើដំណើរយ៉ាងលឿនឆ្ពោះទៅកាន់ កន្លែងដែលមានមហាជនដ៏សែនកុះករ ។ ខណៈនោះ សុមេធតាបស បានសួរនាងយុវតីនោះថា ៖

"តើនាងមានឈ្មោះអ្វី? ហើយធ្វើដំណើរទៅណាយ៉ាងប្រញាប់យ៉ាងនេះ?"

យុវតីឆ្លើយថា ៖

"នាងខ្ញុំឈ្មោះ សុមិត្តា ។ ថ្ងៃនេះមានព្រះពុទ្ធមួយអង្គ ព្រះនាមទីបង្ករ ទ្រង់យាងមកប្រោសព្រះបិតារបស់ព្រះអង្គ ។ តើលោកតាបស អញ្ជើញមកពីស្រុកឆ្ងាយឬ ទើបបានជាមិនដឹងរឿងនេះ? "

ពេលនោះសុមេធបណ្ឌិត គ្រាន់តែឮពាក្យថាព្រះពុទ្ធភ្លាម លោកមានសេចក្តីរំភើបញាប់ញ័រ និងសោមនស្សយ៉ាងក្រៃលែងស្ទើរទប់ខ្លួនឈរពុំបាន ។ ដោយមានចិត្តជ្រះថ្លានឹងព្រះពុទ្ធ ហើយក៏ពុំមានវត្ថុអ្វីសម្រាប់បូជាថ្វាយព្រះពុទ្ធដែរ ស្រាប់តែឃើញនាងសុមិត្តាកាន់ផ្កាឈូក ៧ ទង លោកតាបសក៏សួរនាងថា ៖

"តើនាងទិញផ្កាឈូក ៧ ទងនេះក្នុងតម្លៃប៉ុន្មាន?"

នាងសុមិត្តាឆ្លើយថា ៖

"ផ្កាឈូក ៥ ទង នាងខ្ញុំទិញក្នុងតម្លៃ ៥០០ កហាបណៈ និង ២ ទងទៀត មិត្តរបស់នាងខ្ញុំឱ្យ ។(មានត...)

ពេលនោះ សុមេធតាបសបានទទួលយកផ្កាឧប្បលចំនួន ៥ ទង ចូលទៅក្រាបថ្វាយបង្គំព្រះពុទ្ធទីបង្ករ ហើយបូជាថ្វាយចំពោះព្រះពុទ្ធអង្គនោះ ។ ចំណែកនាងសុមិត្តា ក៏យកផ្ការបស់ខ្លួនចំនួន ៣ ទង ចូលទៅថ្វាយចំពោះ

---

សុមេធបណ្ឌិតថា ៖

"ខ្ញុំនឹងឱ្យនាង ៥០០ កហាបណៈ សូមនាងឱ្យផ្កាឈូក ៥ ទងមកខ្ញុំ ហើយនាងរក្សាទុក ២ ទងនេះ ដើម្បីថ្វាយព្រះដ៏មានព្រះភាគចុះ" ។

នាងសុមិត្តាតបថា ៖

"លោកតាបស អាចទទួលបានផ្កាឈូក ៥ ទង លុះត្រាតែលោកតាបស យល់ព្រមទទួលនាងខ្ញុំធ្វើជាកន្សែរសារពេជ្ជ សម្រាប់គ្រប់ៗជាតិតទៅ" ។

ខណៈនោះ សុមេធបណ្ឌិតក៏យល់ព្រម ហើយទទួលផ្កាឈូក ៥ ទង ពីនាងសុមិត្តា និងបង់ថ្លៃ ៥០០ កហាបណៈ ហើយធ្វើដំណើរទៅកាន់ទីដែលព្រះសម្មាសម្ពុទ្ធ ទ្រង់គង់ប្រថាប់ ។ ដោយមានមហាជនច្រើនពេក ធ្វើឱ្យសុមេធបណ្ឌិត និងនាងសុមិត្តា មិនអាចចូលដល់ជិតទីកន្លែងរបស់ព្រះសម្មាសម្ពុទ្ធប្រថាប់បាន សុមេធបណ្ឌិត ក៏ប្រាថ្នាបូជាថ្វាយផ្កាឈូករបស់ខ្លួនពីចម្ងាយ ដោយបោះសំដៅឆ្ពោះទៅកាន់ទីតាំងព្រះសម្មាសម្ពុទ្ធ ។ ពេលនោះ ផ្កាឈូកក៏បានហោះជុំវិញព្រះអង្គ ។ នាងសុមិត្តា ឃើញព្រឹត្តិការណ៍ដូច្នោះ ក៏ធ្វើត្រាប់តាមសុមេធបណ្ឌិត ហើយមនុស្សម្នាដ៏ច្រើនក៏បានធ្វើត្រាប់បូជាថ្វាយផ្កាឈូកចំពោះព្រះពុទ្ធពីចម្ងាយដែរ ។ ឯផ្កាទាំងឡាយ បានហោះអណ្តែតជុំវិញទីតាំងដែលព្រះសម្មាសម្ពុទ្ធគង់ប្រថាប់ ។

២. ន័យម៉្យាងទៀត ក៏មានដំណើររឿងប្រហែលគ្នានឹងអដ្ឋកថាដីកាដែរ គឺសុមេធ-តាបសបានធ្វើដំណើរតទៅទៀត រហូតដល់កន្លែងដែលលោកបានជួបមហាជនទាំងឡាយ កំពុងសាងសង់ផ្លូវថ្វាយ និងបានថ្វាយបង្គំព្រះសម្មាសម្ពុទ្ធទីបង្ករផ្ទាល់ ហើយលោកយកដងខ្លួនធ្វើជាស្ពានថ្វាយព្រះសម្មាសម្ពុទ្ធឆ្លង ។

ព្រះសម្មាសម្ពុទ្ធអង្គនោះដែរ ។ បន្ទាប់ពីការថ្វាយផ្កាហើយ សុមេធបណ្ឌិត លើកដៃប្រណម្យអញ្ជលីបញ្ចេញសំឡេងដ៏ក្រអៅក្រអួន ប្រាថ្នានូវភាពជាព្រះពុទ្ធ ចំពោះព្រះភក្ត្រព្រះពុទ្ធជាម្ចាស់ថា :

"បពិត្រព្រះអង្គដ៏ចម្រើន ដោយអំណាចអធិការដែលខ្ញុំព្រះអង្គបានបំពេញហើយមានប្រមាណប៉ុណ្ណោះ ខ្ញុំព្រះអង្គសូមប្រាថ្នាឱ្យត្រាស់ជាព្រះពុទ្ធក្នុងលោកឰដ៏អនាគតកាល ដូចព្រះអង្គត្រាស់ដឹងហើយនាបច្ចុប្បន្ននេះផងចុះ" ។

ក្នុងកាលនោះ ព្រះពុទ្ធទីបង្ករទ្រង់គង់នៅជិតសីសៈរបស់សុមេធបណ្ឌិត ព្រះអង្គពិចារណាដោយអនាវរណញ្ញាណឃើញថា សេចក្ដីប្រាថ្នានេះ មិនមានអ្វីជាគ្រឿងរារាំងឡើយ ហើយព្រះអង្គ ទ្រង់ញាណច្បាស់ថា សុមេធ-បណ្ឌិតនេះ នឹងត្រាស់ដឹងជាព្រះពុទ្ធពិតប្រាកដក្នុងលោក ទើបព្រះអង្គទ្រង់ព្យាករថា :

"ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរមើលតាបសនេះ ជាជដិលមានតបៈដ៏ខ្ពង់ខ្ពស់ តាបសនេះនឹងបានត្រាស់ជាព្រះពុទ្ធក្នុងលោកក្នុងកប្បប្រមាណមិនបានអំពីកប្បនេះទៅ ។ សត្វនេះនឹងចេញចាកក្រុងឈ្មោះកបិលវត្ថុជាទីរីករាយ តម្កល់ព្យាយាមធ្វើទុក្ករកិរិយា ។ សត្វនេះអង្គុយទៀបគល់អជបាលព្រឹក្ស ទទួលមធុបាយាសដែល

នាងសុជាតា ថ្វាយក្នុងទីនោះ រួចចូលទៅកាន់ស្ទឹងនេរញ្ជរា ហើយនឹងត្រឡប់មកតាមផ្លូវ ដែលគេតាក់តែងយ៉ាងប្រសើរ ។ បន្ទាប់មកសត្វនេះ អង្គុយទៀបគល់ពោធិព្រឹក្ស លំដាប់នោះ តាបសមានយសធំនេះ បានធ្វើប្រទក្សិណពោធិមណ្ឌល នឹងត្រាស់ដឹងនូវអនុត្តរសម្មាសម្ពោធិញ្ញាណ ទៀបគល់អស្សត្ថព្រឹក្សៗ ព្រះជនិកាមាតារបស់តាបសនោះ នឹងមាននាមថា ព្រះនាង**មហាមាយាទេវី** ព្រះបិតាព្រះនាម**សុទ្ធោទនៈ** ឯតាបសនេះ នឹងមានឈ្មោះថា **ព្រះគោតម** អគ្គសាវ័កទាំងពីររូបគឺ **ឧបតិស្សៈ១ កោលិតៈ១** ជាអ្នកមិនមានអាសវៈ ប្រាសចាករាគៈ មានចិត្តស្ងប់រម្ងាប់ មានចិត្តខ្ជាប់ខ្ជួន ។ ភិក្ខុជាឧបដ្ឋាកឈ្មោះ **អានន្ទ** នឹងបម្រើព្រះជិនស្រីអង្គនេះ ។ អគ្គសាវិកាពីររូបគឺ**នាងខេមា១ ឧប្បលវណ្ណា១** ជាអ្នកមិនមានអាសវៈ ប្រាសចាករាគៈ មានចិត្តស្ងប់រម្ងាប់ មានចិត្តខ្ជាប់ខ្ជួន ។ ដើមឈើជាទីត្រាស់ដឹងរបស់ព្រះដ៏មានព្រះភាគអង្គនោះ ហៅថា **អស្សត្ថព្រឹក្ស** ឯឧបាសក ជាឧបដ្ឋាកដ៏ប្រសើរពីររូបគឺ **ចិត្តៈ១ ហត្ថាឡវកៈ១** ។ នាង**នន្ទមាតា** និងនាង**ឧត្តរា** ជាឧបដ្ឋាយិកាដ៏ប្រសើរនៃព្រះគោតមដ៏មានយសនោះ" ។

ពួកមនុស្សនិងទេវតា លុះឮពាក្យព្យាករណ៍របស់ព្រះពុទ្ធទីបង្ករហើយក៏មានចិត្តរីករាយ ដោយគិតថា "**សុមេធតាបសនេះ ជាពូជពន្ធកនៃព្រះពុទ្ធ**" ។

សំឡេងហ៊ោទាំងឡាយក៏លាន់ឮឡើង ទាំងក្នុងមនុស្សលោក និងទេវលោក ទាំងមួយម៉ឺនលោកធាតុ បានទះដៃផង សើចផង និងផ្គងអញ្ជលីនមស្ការផង ហើយពោលថា:

"បើពួកយើងឃ្លាងមគ្គផលក្នុងសាសនាព្រះលោកនាថនេះ ក្នុងកាលជាអនាគត ពួកយើងនឹងសម្រេចក្នុងទីចំពោះព្រះភក្ត្រនៃព្រះគោតមអង្គនេះ ។ ពួកមនុស្សកាលឆ្លងស្ទឹង បើឃ្លាងកំពង់ចំពោះមុខហើយ តែងកាន់យកកំពង់ខាងក្រោម ក៏ឈ្មោះថា ឆ្លងស្ទឹងធំដែរ យ៉ាងណាមិញ ពួកយើងទាំងអស់គ្នា បើឃ្លាងព្រះជិនស្រីអង្គនេះហើយ ក្នុងកាលជាអនាគត គង់នឹងបានសម្រេចក្នុងទីចំពោះព្រះភក្ត្រនៃព្រះគោតមអង្គនេះ ក៏យ៉ាងនោះដែរ" ។

មនុស្សទាំងឡាយ មានចិត្តរីករាយប្រកបដោយសោមនស្ស ក៏បានស្រែកប្រកាសថា "**សុមេធតាបសោ កិរ ពុទ្ធពីជង្កុរោ**" មានន័យថា ពួកយើងទាំងអស់គ្នាឮថា "**សុមេធតាបស ជាពូជពន្លកនៃព្រះពុទ្ធហ្ន**" ។ ព្រះពុទ្ធទីបង្ករ ទ្រង់សរសើរព្រះពោធិសត្វហើយ ព្រះអង្គក៏បូជាផ្កាឧប្បល ៨ ក្តាប់មកចំពោះសុមេធតាបសវិញ ។ គ្រានោះ ព្រះអរហន្តខីណាស្រព ចំនួន ៤ សែនអង្គ ក៏ធ្វើការបូជាសុមេធតាបស ដោយផ្កានិងគ្រឿងក្រអូប ហើយធ្វើ

ប្រទក្សិណនិមន្តចេញទៅ ។ ទេវតាទាំងឡាយក្តី មនុស្សទាំងឡាយក្តី ក៏នាំគ្នាយកផ្កានិងគ្រឿងក្រអូបរៀងៗខ្លួន មកបូជាចំពោះសុមេធបណ្ឌិតដែរ ។

បន្ទាប់ពីសុមេធបណ្ឌិតទទួលការព្យាករអំពីព្រះពុទ្ធទីបង្ករ ហើយក៏អង្គុយលើគំនរផ្កា ពិចារណានូវបារមីទាំងឡាយ ។ កាលសុមេធបណ្ឌិតកំពុងអង្គុយនោះ ទេវតាទាំងឡាយទាំងមួយម៉ឺនចក្រវាលឱ្យសាធុការថា :

"បពិត្រសុមេធតាបស លោកអង្គុយពែនភ្នែនពិចារណានូវបារមីទាំងឡាយ ដែលបោរាណកពោធិសត្វទាំងឡាយបានពិចារណាហើយ បុព្វនិមិត្តទាំងឡាយនឹងកើតឡើងប្រាកដ, ការកើតបុព្វនិមិត្តទាំងឡាយ បញ្ជាក់ថា អ្នកនឹងត្រាស់ជាព្រះពុទ្ធពិតប្រាកដ ព្រោះហេតុនោះ ចូរអ្នកផ្គងនូវសេចក្តីព្យាយាមឱ្យមាំមួនចុះ" ។

## ៤. បុព្វនិមិត្ត

តាមនិយាមនៃការត្រាស់ដឹងរបស់ព្រះសម្មាសម្ពុទ្ធ បុព្វនិមិត្តជាព្រឹត្តិការណ៍នៃធម្មជាតិដ៏អស្ចារ្យមួយ ដែលកើតមានឡើងបញ្ជាក់ពីការបានត្រាស់ដឹងប្រាកដនៃព្រះសម្មាសម្ពុទ្ធ ក្នុងអនាគតកាលខាងមុខ ។

***តើបុព្វនិមិត្តទាំងឡាយមានដូចម្តេចខ្លះ?***

បុព្វនិមិត្តទាំងឡាយ ដែលសម្ដែងដោយព្រះសមណគោតម មាន ដូចតទៅ[២២]:

១. និមិត្តទាំងឡាយណា ក្នុងកាលជាទីពត់ក្អែននៃព្រះពោធិសត្វទាំងឡាយប្រាកដក្នុងកាលមុន និមិត្តទាំងនោះ ក៏មានប្រាកដក្នុងថ្ងៃនេះ លោកនឹងត្រាស់ជាព្រះពុទ្ធប្រាកដ ។

២. ត្រជាក់ក៏ស្ងាត់បាត់ទៅ ទាំងក្ដៅក៏ស្ងប់រម្ងាប់ និមិត្តទាំងនោះ ក៏ប្រាកដក្នុងថ្ងៃនេះ លោកនឹងត្រាស់ជាព្រះពុទ្ធប្រាកដ ។

៣. លោកធាតុទាំងមួយម៉ឺន ក៏ឥតមានសំឡេង ឥតរឹករះ និមិត្តទាំងនោះ ក៏ប្រាកដក្នុងថ្ងៃនេះ លោកនឹងត្រាស់ជាព្រះពុទ្ធប្រាកដ ។

៤. ខ្យល់ធំទាំងឡាយក៏ឈប់បក់ ស្ទឹងទាំងឡាយក៏ឈប់ហូរ និមិត្តទាំងនោះក៏ប្រាកដក្នុងថ្ងៃនេះ លោកនឹងត្រាស់ជាព្រះពុទ្ធប្រាកដ ។

៥. ផ្កាទាំងពួងដែលកើតលើគោក កើតក្នុងទឹក ក៏រីកក្នុងខណៈនោះ ផ្កាទាំងអស់នោះ ក៏បញ្ចេញផ្កាក្នុងថ្ងៃនេះ លោកនឹងត្រាស់ជាព្រះពុទ្ធប្រាកដ ។

[២២] ព្រះត្រៃបិដក លេខ ៧៧/៣៥ ។

៦. វល្លិទាំងឡាយក្តី ឈើទាំងឡាយក្តី ទ្រទ្រង់នូវផ្លែក្នុងខណៈនោះ វល្លិនិងឈើទាំងអស់នោះ ក៏បញ្ចេញផ្លែក្នុងថ្ងៃនេះ លោកនឹងត្រាស់ជាព្រះពុទ្ធប្រាកដ ។

៧. កែវទាំងឡាយ ដែលឋិតនៅឯអាកាសក្តី ឋិតនៅលើផែនដីក្តី ដែលរុងរឿងក្នុងខណៈនោះ កែវទាំងនោះ ក៏រុងរឿងក្នុងថ្ងៃនេះ លោកនឹងត្រាស់ជាព្រះពុទ្ធប្រាកដ ។

៨. គ្រឿងតូរ្យតន្ត្រីទាំងឡាយ ជារបស់មនុស្ស និងជាទិព្វ ដែលប្រគំក្នុងខណៈនោះ តូរ្យតន្ត្រីទាំងពីរនោះ ក៏លាន់ឮឡើងក្នុងថ្ងៃនេះ លោកនឹងត្រាស់ជាព្រះពុទ្ធប្រាកដ ។

៩. ផ្កាដ៏វិចិត្រទាំងឡាយ រុះរោយចុះអំពីអាកាសក្នុងខណៈនោះ ផ្កាដ៏វិចិត្រទាំងនោះ ក៏ប្រាកដក្នុងថ្ងៃនេះ លោកនឹងត្រាស់ជាព្រះពុទ្ធប្រាកដ ។

១០. មហាសមុទ្រក៏ស្រកចុះ លោកធាតុទាំងមួយម៉ឺន ក៏ញាប់ញ័រក្នុងខណៈនោះ មហាសមុទ្រនិងលោកធាតុទាំងពីរនោះ ក៏លាន់ឮកងរំពងក្នុងថ្ងៃនេះ លោកនឹងត្រាស់ជាព្រះពុទ្ធប្រាកដ ។

១១. ភ្លើងក្នុងនរកទាំងមួយម៉ឺន ក៏រលត់ក្នុងខណៈនោះ ភ្លើងទាំង

នោះ ក៏រលត់ក្នុងថ្ងៃនេះ លោកនឹងត្រាស់ជាព្រះពុទ្ធប្រាកដ ។

១២.ព្រះអាទិត្យ ប្រាសចាកមន្ទិល ផ្កាយទាំងពួងក៏ប្រាកដ ព្រះអាទិត្យនិងផ្កាយទាំងនោះ ក៏ប្រាកដក្នុងថ្ងៃនេះ លោកនឹងត្រាស់ជាព្រះពុទ្ធប្រាកដ ។

១៣.ក្នុងកាលគ្មានភ្លៀង ទឹកក៏ផុសឡើងលើផែនដី ក្នុងខណៈនោះទឹកក៏ផុសឡើងលើផែនដីក្នុងថ្ងៃនេះ លោកនឹងត្រាស់ជាព្រះពុទ្ធប្រាកដ ។

១៤.ពួកផ្កាយទាំងឡាយក៏រុងរឿង ផ្កាយនក្ខត្តឫក្សទាំងឡាយ ប្រកបដោយព្រះចន្ទ ខែវិសាខ ក៏រុងរឿងក្នុងមណ្ឌលនៃអាកាស លោកនឹងត្រាស់ជាព្រះពុទ្ធប្រាកដ ។

១៥.បំណែកឯពួកសត្វនៅក្នុងរន្ធ ពួកសត្វដេកក្នុងជ្រោះ ក៏ចេញចាកលំនៅរបស់ខ្លួន ពួកសត្វទាំងអស់នោះ ក៏បោះបង់លំនៅចោលក្នុងថ្ងៃនេះ លោកក៏ត្រាស់ជាព្រះពុទ្ធប្រាកដ ។

១៦.សេចក្តីអផ្សុកមិនមានដល់សត្វទាំងឡាយ សត្វទាំងឡាយជាអ្នកត្រេកអរក្នុងខណៈនោះ ពួកសត្វទាំងអស់នោះ ជាអ្នកត្រេកអរក្នុងថ្ងៃនេះ លោកនឹងត្រាស់ជាព្រះពុទ្ធប្រាកដ ។

១៧.រោគទាំងឡាយដ៏ស្រាលៗ ក៏ស្ងប់រម្ងាប់ទៅ ទាំងសេចក្តីស្រេក

ឃ្លានក៏វិនាសទៅ ការស្ងប់រោគ និងការវិនាសនៃសេចក្ដីស្រេកឃ្លានទាំងនោះ ក៏ប្រាកដក្នុងថ្ងៃនេះ លោកនឹងត្រាស់ជាព្រះពុទ្ធប្រាកដ ។

១៨. រោគក៏ស្រាកស្រាន្តទៅ ទោសៈ មោហៈ ក៏បាត់បង់ទៅក្នុងកាលនោះ រោគនិងកិលេសទាំងអស់នោះ ក៏ប្រាសចេញទៅក្នុងថ្ងៃនេះ លោកនឹងត្រាស់ជាព្រះពុទ្ធប្រាកដ ។

១៩. ឯភ័យមិនមានក្នុងកាលនោះ ការមិនមានភ័យនុ៎ះ ក៏ប្រាកដក្នុងថ្ងៃនេះ ព្រោះហេតុនោះទើបយើងដឹងថា លោកនឹងត្រាស់ជាព្រះពុទ្ធប្រាកដ ។

២០.ធូលីក៏ខ្ចាត់ខ្ចាយទៅខាងលើ ការខ្ចាត់ខ្ចាយធូលី ក៏ប្រាកដក្នុងថ្ងៃនេះ ព្រោះហេតុនោះ ទើបពួកយើងដឹងថា លោកនឹងត្រាស់ជាព្រះពុទ្ធប្រាកដ ។

២១.ក្លិនស្អុយក៏ផាត់ចេញ ក្លិនទិព្វក៏ផ្សាយទៅ ក្លិនទិព្វនោះ ក៏ផ្សាយចេញក្នុងថ្ងៃនេះ លោកនឹងត្រាស់ជាព្រះពុទ្ធប្រាកដ ។

២២.ពួកទេវតាទាំងពួង វៀរលែងតែអរូបព្រហ្មចេញដែលប្រាកដ ពួកទេវតាទាំងអស់នោះ ក៏ប្រាកដក្នុងថ្ងៃនេះ លោកនឹងត្រាស់ជាព្រះពុទ្ធប្រាកដ ។

២៣.ពួកសត្វនរកទាំងឡាយអម្បាលម៉ាន ដែលប្រាកដក្នុងខណៈ នោះ ពួកសត្វនរកទាំងអស់នោះឯង ក៏ប្រាកដក្នុងថ្ងៃនេះ លោក នឹងត្រាស់ជាព្រះពុទ្ធប្រាកដ ។

២៤.ជញ្ជាំងទាំងឡាយក្តី សន្ទះទ្វារទាំងឡាយក្តី ភ្នំទាំងឡាយក្តី ជា គ្រឿងរាំងមិនមានឡើយ កំពែង សន្ទះទ្វារ និងភ្នំទាំងឡាយ នោះ ក៏ក្លាយទៅជាអាកាសប្រាកដក្នុងថ្ងៃនេះ លោកនឹងត្រាស់ ជាព្រះពុទ្ធប្រាកដ ។

២៥.ច្យុតនិងឧបបត្តិមិនមានក្នុងខណៈនោះ និមិត្តទាំងនោះក៏ប្រាកដ ក្នុងថ្ងៃនេះ លោកនឹងត្រាស់ជាព្រះពុទ្ធប្រាកដ ។

និមិត្តទាំងនេះ ក៏ប្រាកដដល់សត្វទាំងឡាយ ដើម្បីត្រាស់ដឹងនូវ អនុត្តរសម្មោធិញ្ញាណ ។

ពួកមនុស្ស និងទេវតាទាំងឡាយពោលថា:

"បពិត្រសុមេធតាបស សូមលោកផ្តងព្យាយាមឱ្យមាំមួនឡើង កុំ ត្រឡប់ កុំថយក្រោយឡើយ ពួកយើងដឹងច្បាស់នូវហេតុនុ៎ះថា លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ" ។

លុះសុមេធបណ្ឌិតបានឮពាក្យរបស់ជនទាំងពីរពួក គឺព្រះពុទ្ធ និង

ទេវតាទាំងមួយម៉ឺនចក្រវាលហើយ ក៏ត្រេកអរ ស្រស់ស្រាយ រីករាយ គិតក្នុងកាលនោះយ៉ាងនេះថា ៖

"ធម្មតាព្រះពុទ្ធទាំងឡាយ មិនដែលមានព្រះពុទ្ធដីកាបែកជាពីរទេ ព្រះជិនស្រីទាំងឡាយ មិនដែលមានព្រះពុទ្ធដីកាឥតអំពើទេ ព្រះពុទ្ធដីការបស់ព្រះពុទ្ធទាំងឡាយ មិនដែលឃ្លៀងឃ្លាតទេ អាត្មាអញនឹងត្រាស់ជាព្រះពុទ្ធប្រាកដ ។ ដុំដីដែលគេចោលទៅឰដ៏អាកាស ទៀងតែនឹងធ្លាក់មកលើផែនដីវិញយ៉ាងណា ពាក្យរបស់ព្រះពុទ្ធដ៏ប្រសើរទាំងឡាយ ក៏ទៀងទាត់ប្រាកដយ៉ាងនោះដែរ ។ ព្រះបន្ទូលរបស់ព្រះពុទ្ធទាំងឡាយ មិនចេះឃ្លៀងឃ្លាតទេ អាត្មាអញនឹងត្រាស់ជាព្រះពុទ្ធប្រាកដ សេចក្តីស្លាប់របស់សព្វសត្វ ទៀងទាត់ប្រាកដយ៉ាងណា ព្រះបន្ទូលរបស់ព្រះពុទ្ធដ៏ប្រសើរទាំងឡាយ ក៏ទៀងទាត់ប្រាកដដូច្នេះដែរ ។

កាលដែលរាត្រីអស់ទៅ ព្រះអាទិត្យទៀងតែនឹងរះឡើងយ៉ាងណា ព្រះបន្ទូលរបស់ព្រះពុទ្ធដ៏ប្រសើរទាំងឡាយ ក៏ទៀងទាត់ប្រាកដយ៉ាងនោះដែរ ។ សីហៈ ដែលចេញអំពីដំណេក តែងបន្លឺសំឡេងយ៉ាងណា ព្រះបន្ទូលរបស់ព្រះពុទ្ធដ៏ប្រសើរទាំងឡាយ ក៏ទៀងទាត់ប្រាកដយ៉ាងនោះដែរ ។

*ការសម្រាលគភ៌នៃស្ត្រី ដែលមានគភ៌ធ្ងន់ ជារបស់ទៀងទាត់យ៉ាង ណា ព្រះបន្ទូលរបស់ព្រះពុទ្ធដ៏ប្រសើរទាំងឡាយ ក៏ទៀងទាត់ ប្រាកដយ៉ាងនោះដែរ ។ បើដូច្នោះ អាត្មាអញនឹងជ្រើសរើសរកពុទ្ធ-ការកធម៌ទាំងឡាយ ពីខាងនេះ ពីខាងនោះ គឺខាងលើ ខាងក្រោម ទិសទាំង ១០ ដរាបដល់ធម្មធាតុ" ។*

## ៥. សុមេធតាបសអន្ទោយពិចារណានូវពុទ្ធការកធម៌

*កាលនោះ ព្រះពោធិសត្វជ្រើសរើសរកនូវ**ពុទ្ធការកធម៌**ទាំងឡាយ ក៏ឃើញនូវបារមីដូចខាងក្រោម :*

***១-ទានបារមី*** *ជាដំបូង ជាគន្លងធំ ដែលព្រះពោធិសត្វទាំងឡាយពីបុរាណ ធ្លាប់សន្សំមក ។ ពេលនោះ សុមេធបណ្ឌិតទូន្មានខ្លួនឯងថា :*

*"ម្នាលសុមេធបណ្ឌិត ចូរអ្នកសមាទានធ្វើនូវទានបារមីជាដំបូងនេះ ឱ្យមាំមួន បើអ្នកចង់លុះនូវពោធិញ្ញាណ ចូរបំពេញនូវទានបារមីនេះ ចុះ ។ ក្អមដែលមានទឹកពេញ បុគ្គលណាមួយផ្កាប់ចុះ ចាក់មិនឱ្យ សល់ទឹកមួយតំណក់ យ៉ាងណាមិញ បើអ្នកឃើញពួកស្មូមចូលមក ទោះថោកទាប ខ្ពង់ខ្ពស់ ឬមធ្យម ចូរអ្នកឱ្យទាន កុំឱ្យសេសសល់ ឱ្យដូចជាក្អមដែលគេផ្កាប់ដូច្នោះ" ។*

**២-សីលបារមី** ជាបារមីទី២ ដែលព្រះពោធិសត្វទាំងឡាយពីបុរាណធ្លាប់ប្រារព្ធ ធ្លាប់អាស្រ័យមក ។ ពេលនោះ សុមេធបណ្ឌិតទូន្មានខ្លួនឯងថា :

"ម្នាលសុមេធបណ្ឌិត ចូរអ្នកសមាទាន ធ្វើសីលបារមីនេះឱ្យមាំមួន បើអ្នកចង់លុះនូវពោធិញ្ញាណ ចូរបំពេញនូវសីលបារមីនេះចុះ ។

សត្វចាមរី កាលណារោមកន្ទុយជាប់ជំពាក់នឹងអ្វីមួយ ស៊ូស្លាប់ក្នុងទីនោះ មិនព្រមផ្តាច់កន្ទុយរបស់ខ្លួនចោលឡើយ យ៉ាងណាមិញ ចូរអ្នកបំពេញនូវសីលបារមីទាំងឡាយក្នុងភូមិទាំង ៤ ។ ចូរអ្នករក្សាសីល សព្វកាល ឱ្យដូចជាសត្វចាមរីរក្សាកន្ទុយយ៉ាងនោះចុះ ។

ដូច្នេះ អាត្មាអញត្រូវតាំងចិត្តប្តូរផ្តាច់ការពារសីលរបស់ខ្លួន ដោយប្រុងប្រយ័ត្នគ្រប់ពេលវេលា ហើយកុំធ្វេសប្រហែសឱ្យសោះ" ។

**៣-នេក្ខម្មបារមី** ជាបារមីទី៣ ដែលព្រះពោធិសត្វទាំងឡាយពីបុរាណធ្លាប់ប្រារព្ធ ធ្លាប់អាស្រ័យមក ។ ពេលនោះ សុមេធបណ្ឌិតទូន្មានខ្លួនឯងថា :

"ម្នាលសុមេធបណ្ឌិត ចូរអ្នកសមាទានធ្វើនេក្ខម្មបារមីនេះ ឱ្យមាំមួន បើអ្នកចង់លុះនូវពោធិញ្ញាណ ចូរបំពេញនូវនេក្ខម្មបារមីនេះចុះ ។

បុរសដែលជាប់នៅក្នុងគុកអស់កាលដ៏យូរ ត្រូវសេចក្តីទុក្ខបៀតបៀន ហើយរមែងមិនញុំាងសេចក្តីត្រេកអរ ឱ្យកើតមានឡើងនៅក្នុងគុក

នោះទេ គឺរមែងស្វែងរកការរួចខ្លួនចាកគុកនោះយ៉ាងណា ចូរអ្នកឃើញនូវភពទាំងអស់ ដូចជាគុកចុះ ។ ចូរបែរមុខទៅរក **នេក្ខម្ម:** ដើម្បីរួចចាកភពយ៉ាងនោះដែរ" ។

**៤-បញ្ញាបារមី** ជាបារមីទី៤ ដែលព្រះពោធិសត្វទាំងឡាយពីបុរាណ ធ្លាប់សេព ធ្លាប់អាស្រ័យមក ។ ពេលនោះ សុមេធបណ្ឌិតទូន្មានខ្លួនឯងថា :

"ម្នាលសុមេធបណ្ឌិត ចូរអ្នកសមាទានធ្វើបញ្ញាបារមីនេះឱ្យមាំមួន បើអ្នកចង់ដល់នូវពោធិញ្ញាណ ចូរបំពេញនូវបញ្ញាបារមីនេះចុះ ។ ភិក្ខុកាលប្រព្រឹត្តបិណ្ឌបាត មិនវំលងនូវត្រកូលទាំងឡាយ ទោះថោកទាប ខ្ពង់ខ្ពស់ ឬមធ្យមក្តី រមែងបានចង្ហាន់ល្មមញ៉ាំងអត្តភាពឱ្យប្រព្រឹត្តទៅយ៉ាងណា បើអ្នកសាកសួរជនអ្នកប្រាជ្ញសព្វកាល នឹងដល់នូវបញ្ញាបារមី ហើយបានលុះនូវពោធិញ្ញាណមិនខាន ក៏យ៉ាងនោះដែរ" ។

**៥-វិរិយបារមី** ជាបារមីទី៥ ដែលព្រះពោធិសត្វទាំងឡាយពីបុរាណ ធ្លាប់សេព ធ្លាប់អាស្រ័យមក ។ ពេលនោះ សុមេធបណ្ឌិតទូន្មានខ្លួនឯងថា :

"ម្នាលសុមេធបណ្ឌិត ចូរអ្នកសមាទានធ្វើវិរិយបារមីនេះឱ្យមាំមួន បើអ្នកចង់លុះនូវពោធិញ្ញាណ ចូរបំពេញនូវវិរិយបារមីនេះចុះ ។

សត្វសីហៈ ជាស្តេចម្រឹគមានការព្យាយាមមិនរួញរា មានចិត្តផ្គូផ្គង សព្វកាល ក្នុងការអង្គុយ ឈរ ដើរយ៉ាងណា អ្នកគួរផ្គូផ្គងព្យាយាម ឱ្យមាំមួនក្នុងភពទាំងពួងយ៉ាងនោះចុះ លុះបានដល់នូវវីរិយបារមី ហើយ អ្នកនឹងសម្រេចនូវពោធិញ្ញាណមិនខានឡើយ" ។

**៦-ខន្តិបារមី** ជាបារមីទី៦ ដែលព្រះពោធិសត្វទាំងឡាយពីបុរាណ ធ្លាប់សេព ធ្លាប់អាស្រ័យមក ។ ពេលនោះ សុមេធបណ្ឌិតទូន្មានខ្លួនឯងថា :

"ម្នាលសុមេធបណ្ឌិត ចូរអ្នកសមាទានធ្វើខន្តិបារមីនេះឱ្យបានមាំមួន ចូរអ្នកកុំមានចិត្តបែកជាពីរក្នុងខន្តិបារមីនេះ អ្នកនឹងបានដល់នូវពោធិញ្ញាណមិនខានឡើយ ។

ធម្មតាផែនដី តែងអត់ទ្រាំចំពោះវត្ថុទាំងពួង ទោះស្អាតក្តី មិនស្អាតក្តី ដែលគេដាក់ចុះហើយ រមែងមិនធ្វើនូវសេចក្តីថ្នាំងថ្នាក់ និងសេចក្តីត្រេកអរឡើយ យ៉ាងណាមិញ អ្នកគួរអត់ទ្រាំនូវការរាប់អាន និងការមើលងាយរបស់ពួកជនទាំងពួងយ៉ាងនោះដែរ ។ លុះដល់នូវខន្តិបារមីហើយ អ្នកនឹងសម្រេចនូវពោធិញ្ញាណមិនខានឡើយ" ។

**៧-សច្ចបារមី** ជាបារមីទី៧ ដែលព្រះពោធិសត្វទាំងឡាយពីបុរាណ ធ្លាប់សេព ធ្លាប់អាស្រ័យមក ។ ពេលនោះ សុមេធបណ្ឌិតទូន្មានខ្លួនឯងថា :

"ម្នាលសុមេធបណ្ឌិត ចូរអ្នកសមាទានធ្វើសច្ចបារមីនេះឱ្យមាំមួន អ្នកកុំមានពាក្យបែកជាពីរក្នុងសច្ចបារមីនេះ អ្នកនឹងសម្រេចនូវពោធិញ្ញាណមិនខានឡើយ ។

ធម្មតាផ្កាយព្រឹក ជាជញ្ជីងរបស់លោក ព្រមទាំងទេវលោក រមែងមិនឃ្លាតចាកវិថីក្នុងរដូវភ្លៀង ឬហេមន្តរដូវយ៉ាងណា ចូរអ្នកកុំឃ្លាតចាកវិថីក្នុងសច្ចៈទាំងឡាយយ៉ាងនោះដែរ។ លុះបានដល់នូវសច្ចបារមីហើយ អ្នកនឹងសម្រេចនូវពោធិញ្ញាណមិនខានឡើយ" ។

**៨-អធិដ្ឋានបារមី** ជាបារមីទី៨ ដែលព្រះពោធិសត្វទាំងឡាយពីបុរាណធ្លាប់សេព ធ្លាប់អាស្រ័យមក ។ ពេលនោះ សុមេធបណ្ឌិតទូន្មានខ្លួនឯងថា:

"ម្នាលសុមេធបណ្ឌិត ចូរអ្នកសមាទានធ្វើអធិដ្ឋានបារមីនេះឱ្យមាំមួន អ្នកកុំញាប់ញ័រក្នុងអធិដ្ឋានបារមីនេះ អ្នកនឹងបានសម្រេចនូវពោធិញ្ញាណមិនខានឡើយ ។

ភ្នំថ្មឥតកម្រើក តាំងនៅស៊ប់ មិនរញ្ជួយដោយខ្យល់ដ៏ខ្លាំងក្លា រមែងតាំងនៅក្នុងទីរបស់ខ្លួនដដែលយ៉ាងណា ចូរអ្នកកុំកម្រើកក្នុងអធិដ្ឋានបារមីសព្វកាលយ៉ាងនោះដែរ លុះដល់នូវអធិដ្ឋានបារមីហើយ អ្នកនឹងបានសម្រេចនូវពោធិញ្ញាណមិនខានឡើយ" ។

**៩-មេត្តាបារមី** ជាបារមីទី៩ ដែលព្រះពោធិសត្វទាំងឡាយពីបុរាណ ធ្លាប់សេព ធ្លាប់អាស្រ័យមក ។ ពេលនោះ សុមេធបណ្ឌិតទូន្មានខ្លួនឯងថា :

"ម្នាលសុមេធបណ្ឌិត ចូរអ្នកសមាទានធ្វើនូវមេត្តាបារមីនេះឱ្យមាំមួន ចូរអ្នកផ្តល់ឱ្យមានដល់បុគ្គលដទៃស្មើដោយមេត្តាបារមី បើអ្នកចង់លុះនូវពោធិញ្ញាណ ។

ធម្មតា ទឹករមែងផ្សព្វផ្សាយភាពត្រជាក់ស្មើចំពោះជន ទាំងល្អ ទាំងអាក្រក់ រមែងកម្ចាត់បង់នូវធូលី និងមន្ទិលយ៉ាងណា ចូរអ្នកចម្រើនមេត្តាបារមីឱ្យស្មើចំពោះមិត្រ និងសត្រូវយ៉ាងនោះដែរ លុះដល់នូវមេត្តាបារមីហើយ អ្នកនឹងសម្រេចនូវពោធិញ្ញាណមិនខានឡើយ"។

**១០-ឧបេក្ខាបារមី** ជាបារមីទី ១០ ដែលព្រះពោធិសត្វទាំងឡាយពីបុរាណ ធ្លាប់សេព ធ្លាប់អាស្រ័យមក ។ ពេលនោះ សុមេធបណ្ឌិតទូន្មានខ្លួនឯងថា :

"ម្នាលសុមេធបណ្ឌិត ចូរអ្នកសមាទានធ្វើឧបេក្ខាបារមីនេះឱ្យមាំមួន អ្នកគួរជាបុគ្គលដូចជាជញ្ជីងដ៏មាំមួន អ្នកនឹងបានសម្រេចនូវពោធិ-ញ្ញាណមិនខានឡើយ ។

ធម្មតា ផែនដីតែងព្រងើយកន្តើយចំពោះវត្ថុ ទោះស្អាតក្តី មិនស្អាតក្តី ដែលគេដាក់ចុះហើយ តែងវៀរចាកនូវសេចក្តីក្រោធ និងសេចក្តី

ត្រេកអរ ចំពោះវត្ថុទាំងពីរនោះយ៉ាងណា ចូរអ្នកធ្វើខ្លួនឱ្យដូចជា ជញ្ជីងចំពោះសុខ និងទុក្ខសព្វកាលយ៉ាងនោះដែរ អ្នកនឹងលុះដល់នូវឧបេក្ខាបារមី ហើយអ្នកនឹងបានសម្រេចនូវពោធិញ្ញាណមិនខានឡើយ" ។

បន្ទាប់មកទៀត សុមេធបណ្ឌិតពិចារណាថា :

"ធម៌ទាំងឡាយ ជាគ្រឿងញ៉ាំងពោធិញ្ញាណឱ្យសម្រេច ធម៌ទាំងនោះមានក្នុងលោកត្រឹមប៉ុណ្ណោះ ។ ពុទ្ធការកធម៌ដទៃក្រៅអំពី ១០ នោះ មិនមានឡើយ ។ ចូរអ្នកតាំងនៅក្នុងធម៌ទាំង ១០ នោះ ឱ្យមាំមួនចុះ" ។

នៅពេលដែលសុមេធបណ្ឌិត អធិដ្ឋានប្ដេជ្ញាចិត្តអនុវត្តនូវធម៌ទាំង ១០ នេះចប់ហើយ ផែនដីទាំង ១ ម៉ឺនលោកធាតុ បានរញ្ជួយ ញាប់ញ័រដោយតេជះនៃពុទ្ធការកធម៌ ។ ទេវតា ឥន្ទ្រ ព្រហ្មទាំងអស់ ក៏ប្រកាសត្រេកអរដល់សុមេធបណ្ឌិតម្តងទៀត ដោយបាច់ផ្កាភ្ញី ស្រោចស្រពគ្រប់ទីកន្លែងលើដែនដីទាំងមូល ជាមួយនឹងតូរ្យតន្ត្រីទិព្វ ក៏បានប្រគុំឡើងគ្រប់ទិសទី ។

សូមកត់សម្គាល់ថា ព្រះពោធិសត្វទាំងឡាយ តាំងពីបានទទួលពុទ្ធ-ព្យាករណ៍ហើយ រមែងមិនកើតក្នុងជាតិកំណើតទាំងនេះគឺ[២៣]

១. មិនកើតជាមនុស្សព្រៃ

២. មិនកើតជាទេវបុត្រមារ

៣. មិនកើតជាអសញ្ញីសត្តព្រហ្ម

៤. មិនកើតក្នុងសុទ្ធាវាសព្រហ្ម

៥. មិនទៅកើតក្នុងចក្រវាលដទៃ

៦. មិនទៅកើតក្នុងអរូបព្រហ្ម

៧. មិនទៅកើតជាស្ត្រី

៨. មិនទៅកើតជាមនុស្សខ្ញុំគេ

៩. មិនទៅកើតជាមនុស្សខ្វាក់ ថ្លង់

១០. មិនទៅកើតជាមនុស្សឃ្លង់

១១. មិនផ្លាស់ប្តូរភេទ

[២៣] អដ្ឋកថា ពុទ្ធវំស ឈ្មោះ មធុរត្ថវិលាសិនី ត្រង់ ទូរេ និទានកថា, អដ្ឋកថា បរមត្ថទីបនី ចរិយាបិដក, សីលក្ខន្ធវគ្គ អភិនវដីកា ឈ្មោះសាធុវិលាសិនី ។

១២. មិនធ្វើអនន្តរិយកម្មទាំង ៥

១៣. មិនទៅកើតក្នុងលោកន្តរនរក

១៤. មិនទៅកើតក្នុងអវិចីមហានរក

១៥. មិនទៅកើតជាខុប្បិបាសិកប្រេត

១៦. មិនកើតជានិជ្ឈាមតណ្ហិកប្រេត

១៧. មិនកើតជាកាលកញ្ចិកប្រេត

១៨. មិនសម្រេចជាព្រះអរិយៈក្នុងចន្លោះ ៤ អសង្ខេយ្យ និង ១ សែនកប្ប ។

អត្ថបទមួយទៀត មានសេចក្តីប្រហាក់ប្រហែលគ្នានេះដែរ ដែលបានស្រង់ចេញពីគម្ពីរអដ្ឋកថា ស្តីពីអកព្វដ្ឋានទាំង ១៨ ដូចមានក្នុងទំព័របន្ទាប់នេះ :

# អភព្វដ្ឋាន[២៨] ១៨

ព្រះពោធិសត្វដែលបានសម្រេចហើយដោយអភិនីហារទាំង ៨ យ៉ាងនេះ រមែងមិនគួរដល់អភព្វដ្ឋានទាំង ១៨ គឺ

១. **ន ជច្ចន្ធោ ហោតិ** មិនជាមនុស្សខ្វាក់អំពីកំណើត ។

២. **ន ជច្ចពធិរោ** មិនជាមនុស្សថ្លង់អំពីកំណើត ។

៣. **ន ឧម្មត្តកោ** មិនជាមនុស្សឆ្កួត ។

៤. **ន ឯឡមូគោ** មិនជាមនុស្សគ ។

៥. **ន បីឋសប្បី** មិនជាមនុស្សគម ។

៦. **ន មិលក្ខូសុ ឧប្បជ្ជតិ** មិនកើតជាមនុស្សព្រៃ ។

៧. **ន ទាសិកុច្ឆិយា និព្វត្តតិ** មិនកើតក្នុងផ្ទៃនៃនាងទាសី ។

៨. **ន និយតមិច្ឆាទិដ្ឋិកោ ហោតិ** មិនជាអ្នកមាននិយតមិច្ឆាទិដ្ឋិ ។

៩. **នាស្ស លិង្គំ បរិវត្តតិ** មិនជាមនុស្សត្រឡប់ភេទ (ជាស្ត្រី) ។

១០. **ន បញ្ចានន្តរិយកម្មានិ ករោតិ** រមែងមិនធ្វើអនន្តរិយកម្មទាំង ៥ ។

១១. **ន កុដ្ឋី ហោតិ** មិនជាមនុស្សកើតរោគឃ្លង់ ។

---

[២៨] មានន័យថា ភូមិនិងកំណើត ដែលព្រះពោធិសត្វបានដល់ព្រមដោយអភិនីហារមិនបដិសន្ធិ; អភព្វដ្ឋាននេះដកស្រង់ចាក បរមត្ថជោតិកា អដ្ឋកថា ខុទ្ទកនិកាយ សុត្តនិបាត ឧរគវគ្គ ខគ្គវិសាណសុត្តវណ្ណនា និង វិសុទ្ធជនវិលាសិនី អដ្ឋកថា ខុទ្ទកនិកាយ អបទាន បច្ចេកពុទ្ធាបទាន ខគ្គវិសាណគាថាវណ្ណនា ។

១២. **ន តិរច្ឆានយោនិយំ វដ្ដកតោ បច្ឆិមត្តភាវោ ហោតិ ហត្ថិតោ អធិកត្តភាវោ ហោតិ** ក្នុងកំណើតសត្វតិរច្ឆាន មិនកើតជាសត្វដែលមានអត្តភាពតូចជាងចាប និងមិនកើតជាសត្វដែលមានអត្តភាពធំជាងដំរី ។

១៣. **ន ខុប្បិបាសិកនិជ្ឈាមតណ្ហិកបេតេសុ ឧប្បជ្ជតិ** មិនកើតជាខុប្បិបាសិក-ប្រេត និង និជ្ឈាមតណ្ហិកប្រេត ។

១៤. **ន កាលកញ្ជិកាសុរេសុ** មិនកើតជាកាលកញ្ជិកាសុរ ។

១៥. **ន អវីចិនិរយេ** មិនកើតក្នុងអវិចីនរក ។

១៦. **ន លោកន្តរិកេសុ** មិនកើតក្នុងលោកន្តរនរក ។

១៧. **កាមាវចរេសុ ន មារោ ហោតិ** ក្នុងកាមាវចរភូមិ មិនកើតជាមារ ។

១៨. **រូបាវចរេសុ ន អសញ្ញីភវេ ន សុទ្ធាវាសភវេសុ ឧប្បជ្ជតិ ន អរូបភវេសុ ន អញ្ញំ ចក្កវាឡំ សង្កមតិ** ក្នុងរូបាវចរភូមិ មិនកើតក្នុងអសញ្ញីភព មិនកើតក្នុងសុទ្ធាវាសភូមិ មិនកើតក្នុងអរូបភព និងមិនឈានទៅកាន់ចក្រវាលដទៃ (មិនកើតក្នុងចក្រវាលដទៃ) ។

# អានិសង្សរបស់និយតពោធិសត្វ[២៥]

១. ***អវីចិម្ហិ នុប្បជ្ជន្តិ*** និយតពោធិសត្វទាំងឡាយមិនកើតក្នុងអវិចីនរក ។

២. ***លោកន្តរេសុ នុប្បជ្ជន្តិ*** មិនកើតក្នុងលោកន្តរនរក ។

៣. ***និជ្ឈាមតណ្ហា ន ហោន្តិ*** និយតពោធិសត្វទាំងឡាយមិនកើតជានិជ្ឈាមតណ្ហិកប្រេត ។

៤. ***ខុប្បិបាសិកា ន ហោន្តិ*** មិនកើតជាខុប្បិបាសិកប្រេត ។

៥. ***កាលកញ្ជិកា ន ហោន្តិ*** មិនកើតជាកាលកញ្ជិកាសុរ[២៦] ។

៦. ***ខុទ្ទកា បាណា ន ហោន្តិ*** មិនកើតជាសត្វតូចល្អិត ។

៧. ***ជច្ចន្ធា ន ភវន្តិ*** មិនកើតជាអ្នកខ្វាក់អំពីកំណើត ។

៨. ***សោតវេកល្លតា នត្ថិ*** មិនមានភាពវិកលនៃត្រចៀក(ថ្លង់ត្រចៀក)។

៩. ***មូគបក្ខិកា ន ភវន្តិ*** មិនកើតជាមនុស្សគ ។

១០. ***ឥត្ថិភាវំ ន គច្ឆន្តិ*** មិនកើតជាស្ត្រី ។

---

[២៥] *ស្រង់ចាក ជាតក-អដ្ឋកថា និទានកថា ទូរេ និទានកថា; វិសុទ្ធជនវិលាសិនី អបទាន-អដ្ឋកថា និទានកថា ទូរេ និទានកថា; ធុរត្ថវិលាសិនី ពុទ្ធវំស-អដ្ឋកថា គោតមពុទ្ធវំសវណ្ណនា ទូរេ និទានកថា; បរមត្ថទីបនី ចរិយាបិដក-អដ្ឋកថា បកិណ្ណកកថា; អដ្ឋសាលិនី ធម្មសង្គណី-អដ្ឋកថា និទានកថា និង សីលក្ខន្ធវគ្គអភិនវដីកា ឈ្មោះសាធុវិលាសិនី ។*

[២៦] *អាសុរឈ្មោះកាលកញ្ជិកា ឬ កាលកញ្ជកា ក៏បាន ។*

១១. **ឧកតោព្យញ្ជនបណ្ឌកា ន គច្ឆន្តិ** មិនដល់ភាពជាឧភតោព្យញ្ជនកៈ និង បណ្ឌកៈ ។

១២. **បរិយាបន្នា ន ភវន្តិ** មិនមានចិត្តជាប់ក្នុងវត្ថុណាមួយ ។

១៣. **អនន្តរិកេហិ មុត្តា** ជាអ្នកផុតចាកអនន្តរិយកម្ម ។

១៤. **សព្វត្ថ សុទ្ធគោចរា** ជាអ្នកមានគោចរបរិសុទ្ធក្នុងទីទាំងពួង ។

១៥. **មិច្ឆាទិដ្ឋឹ ន សេវន្តិ កម្មកិរិយទស្សនា** មិនសេពនូវមិច្ឆាទិដ្ឋិ ព្រោះជាអ្នកឃើញនូវកិរិយាធ្វើនៃកម្ម ។

១៦. **អសញ្ញំ នុបបជ្ជរេ** មិនចូលដល់អសញ្ញីភូមិ ។

១៧. **សុទ្ធាវាសេសុ ទេវេសុ ហេតុ នាម ន វិជ្ជតិ** ឈ្មោះថាមិនមានហេតុឲ្យកើតក្នុងសុទ្ធាវាសភូមិ ។

១៨. **នេក្ខម្មនិន្នា សប្បុរិសា ហេតុ នាម ន វិជ្ជតិ** ឈ្មោះថាមិនមានហេតុឲ្យសប្បុរសទាំងឡាយតិះដៀលក្នុងនេក្ខម្មៈ ។

១៩. **វិសំយុត្តា ភវាភវេ** មិនប្រកបក្នុងភពតូច និងភពធំ ។

២០. **លោកត្ថចរិយាយោ ចរន្តិ** តែងប្រព្រឹត្តនូវលោកត្ថចរិយាទាំងឡាយ ។

២១. **សព្វបារមី បូរេន្តិ** រមែងញុំាងបារមីទាំងពួងឲ្យពេញបរិបូរ ៕

# ជំពូកទី ៥
# ការសាងទសបារមី

ព្រះពោធិសត្វគ្រប់ព្រះអង្គ បន្ទាប់ពីទទួលព្យាករណ៍ពីព្រះពុទ្ធអង្គណាមួយរួចហើយ ក្នុងលក្ខណៈជានិយតពោធិសត្វ ត្រូវបំពេញនូវទសបារមី (បារមី ១០) ដែលជាពុទ្ធការកធម៌បន្តទៅទៀត រហូតដល់បានត្រាស់ជាព្រះសម្មាសម្ពុទ្ធ ដូចមានគាថាដូច្នេះថា :

**ទានសីលញ្ច នេក្ខម្មំ បញ្ញាវីរិយេន បញ្ចមំ**
**ខន្តិសច្ចមធិដ្ឋានំ មេត្តុបេក្ខាតិ តេ ទស[២៧] ។**

ពុទ្ធការកធម៌ (បារមី ១០) នោះមានដូចតទៅ :

| | |
|---|---|
| ១-ទានបារមី | ៦-ខន្តិបារមី |
| ២-សីលបារមី | ៧-សច្ចបារមី |
| ៣-នេក្ខម្មបារមី | ៨-អធិដ្ឋានបារមី |
| ៤-បញ្ញាបារមី | ៩-មេត្តាបារមី |
| ៥-វីរិយបារមី | ១០-ឧបេក្ខាបារមី |

[២៧] សីលក្ខន្ធវគ្គដីកា លីនត្ថប្បកាសិនី ត្រង់ព្រហ្មជាលសូត្រ, ទសកថា ព្រះនារទភិក្ខុ នៅស្រុកលង្កា ប្រែសម្រួលដោយព្រះឧត្តមមុនី អ៊ុម ស៊ូរ ទំព័រ ២២ ។

គុណធម៌ដ៏ប្រពៃទាំង ១០ នេះ មានន័យវិសេសវិសាលដ៏ក្រៃលែងណាស់  តែសូមលើកតែន័យសង្ខេបនីមួយៗ មកអធិប្បាយជូនលោកអ្នកអាន ដើម្បីពិចារណា និងសិក្សានូវលក្ខណសម្បត្តិ និងមាគ៌ាជីវិតនៃព្រះពោធិសត្វ ។ ព្រះពោធិសត្វគ្រប់ព្រះអង្គទាំងអស់ ទោះបីយោនកំណើតយ៉ាងយូររាប់កប្ប ជាមនុស្សឬសត្វក៏ដោយ តែងតែព្យាយាមយ៉ាងមុតមាំបំផុត ក្នុងការបំពេញបារមីទាំង ១០ នេះ ដើម្បីលុះនូវសម្ពោធិញ្ញាណជាព្រះសម្មាសម្ពុទ្ធ ប្រៀបដូចបុរសម្នាក់ ដែលយកក្អមទឹកទទេ ចំនួន ១០ មកតម្រៀបគ្នា ដើម្បីរក្សាគ្រាប់ពូជមានសណ្តែកល្ងជាដើម មួយថ្ងៃមួយគ្រាប់ៗលុះត្រាតែក្អមទាំង ១០ នោះ ពេញទៅដោយគ្រាប់សណ្តែក ឬល្ងបាន ដូចក្តីបំណង ។ ការដាក់គ្រាប់សណ្តែក ឬល្ង មានថ្ងៃខ្លះ បុរសនោះអាចរក្សាគ្រាប់ពូជដាក់ក្នុងក្អមទី១ ថ្ងៃខ្លះដាក់ក្នុងក្អមទី២ ជាដើម ។ ក្នុងជាតិនីមួយៗព្រះពោធិសត្វអាចបំពេញបារមីទាំង ១០ ក៏មាន ១ ឬ ២-៣ ក៏មាន តែក្នុងជាតិទាំងនោះ មានបារមីមួយត្រូវមានទម្ងន់ធ្ងន់ជាងបារមីដទៃទាំងអស់ ។ ឧទាហរណ៍ដូចជា កាលសោយព្រះជាតិជាព្រះវេស្សន្តរ ទ្រង់ធ្ងន់ក្នុងការសាងទានបារមីជាងគេ តែព្រះអង្គក៏សាងសីលបារមី នេក្ខម្មបារមី បញ្ញាបារមី វីរិយបារមី ខន្តិបារមី សច្ចបារមី អធិដ្ឋានបារមី មេត្តាបារមី និង

ឧបេក្ខាបារមីដែរ ។ តែក្នុងបារមីទាំងអស់នេះ ព្រះវេស្សន្តរទ្រង់ធ្ងន់ក្នុងទានបារមីជាងគេ ។

## ១-ទានបារមី

**ទាន** មានន័យថា "ទេយ្យវត្ថុ ដែលបុគ្គលគប្បីឱ្យ"[២៨] ។ ការធ្វើទានគឺជាការរំលែកនូវភោគសម្បត្តិ វិជ្ជាសម្បត្តិ កម្លាំងកាយ កម្លាំងចិត្ត ឬពេលវេលាសម្រាប់ជួយសម្រាលការស្រេកឃ្លាន និងរំដោះទុក្ខភ័យរបស់អ្នកដទៃ ។ ពោលដោយសង្ខេប ការធ្វើទាន ជាមធ្យោបាយមួយដ៏ប្រសើរក្នុងការពត់ចិត្តឱ្យចេះស្រឡាញ់ អាណិត និងគិតពីសុខទុក្ខអ្នកដទៃ ។ ជាទូទៅ **ទានបារមី** ដែលព្រះពោធិសត្វបានបំពេញមក គួរកត់សម្គាល់ថា មានលក្ខណៈខុសៗគ្នា ៤ យ៉ាង ដូចខាងក្រោម :

- **ការផ្តល់សម្ភារៈផ្សេងៗ** ដើម្បីសម្រាល ឬរំដោះទុក្ខអ្នកដទៃ, ទានមានដូចជា ចំណីអាហារ ប្រដាប់ប្រដាប្រើប្រាស់ និងទ្រព្យសម្បត្តិនានាជាដើម ហៅថា **សង្គហទាន** ។

- **ទានដែលពុទ្ធបរិស័ទ** តែងតែប្រគេនចំពោះព្រះសង្ឃ និងអ្នកមានគុណធម៌ខ្ពស់ ឬទានដែលព្រះពោធិសត្វ លោកថ្វាយ-ប្រគេន ព្រះពុទ្ធ

[២៨] ការពន្យល់អត្ថន័យនៃបារមីទាំង១០ នេះ ដោយផ្អែកទៅលើទសកថា ដោយព្រះនារទភិក្ខុនៅស្រុកលង្កា ប្រែសម្រួលដោយព្រះឧត្តមមុនីអ៊ុម-ស៊ូរ អធិបតីរងក្រុមជំនុំព្រះត្រៃបិដក ។

ឬតាបស មានភោជនីយាហារ ផ្កាភ្ញី ស្បង់ ចីវរ សេនាសេនៈជាដើម លោកហៅថា **បូជាទាន** គឺទានដែលប្រព្រឹត្តទៅដោយក្ដីគោរព ជាមួយនឹងចិត្តបរិសុទ្ធផូរផង់ ។ បូជាទាន មានកម្រិត និងអានិសង្សខ្ពស់ជាងសង្គហទាន ។

- ***ការអនុគ្រោះ*** មិនខឹងគុំកួន តបត នឹងអ្នកប្រព្រឹត្តកំហុសលើយើង និងការលើកលែងទោស ឬផ្ដល់សេរីភាពដល់មនុស្ស ឬសត្វ ដែលពុំមានសេរីភាព ឧទាហរណ៍ ការដោះលែងអ្នកទោស ឈ្លើយសង្គ្រាម ទាសករ អ្នកជំពាក់បំណុល និងការលើកលែងកំហុសរបស់សត្រូវជាដើម លោកហៅថា **អភយទាន** ។ ព្រះពោធិសត្វ ឬអ្នកដឹកនាំ មានព្រះរាជាជាដើម តែងអនុវត្តនូវអភយទាននេះ ។ យើងទាំងអស់គ្នា ក៏អាចប្រព្រឹត្តនូវធម៌អភយទាននេះក្នុងជីវិតប្រចាំថ្ងៃរបស់យើងបានដែរ ។

- ***ការអប់រំ*** ណែនាំអ្នកដទៃឱ្យចេះប្រកបវិជ្ជាជីវៈ ដោយសម្មាអាជីវោ (វិជ្ជាជីវៈត្រឹមត្រូវ) ដើរតាមគន្លងសុចរិតធម៌ ដោយការសម្ដែងធម៌ទេសនា បង្រៀនសីលធម៌ សុជីវធម៌ផ្សេងៗ ជាពន្លឺចង្អុលបង្ហាញផ្លូវទៅរកសុភមង្គលក្នុងកុសលធម៌ លោកហៅថា **ធម្មទាន** ។ ធម្មទាននេះ ជាទានដ៏ប្រសើរលើសទាននានាក្នុងលោក ដែលព្រះពោធិសត្វទ្រង់បានបំពេញមក ។

# ការឱ្យវត្ថុ ១០ យ៉ាង

ការអធិប្បាយនៃទាន ដោយព្រះមហាភិក្ខុនារទៈ ដែលផ្អែកលើអដ្ឋកថា នៃគម្ពីរចរិយាបិដកបរិយាយថា ព្រះពោធិសត្វ លោកតែងឱ្យវត្ថុ ១០ ប្រការគឺ

**១-អន្នទាន** គឺឱ្យបាយ ឬភោជនាហារ ដល់ស្មូមទាំងឡាយ ដោយសេចក្តីត្រិះរិះរបស់ព្រះអង្គថា អាត្មាអញនឹងញ៉ាំងសម្បត្តិ ៥ យ៉ាង គឺអាយុវែង១ ពណ៌សម្បុរល្អ១ សេចក្តីសុខកាយ សប្បាយចិត្ត១ កម្លាំងកាយ១ ប្រាជ្ញាស្មារតី១ និងសម្បត្តិដ៏ប្រសើរគឺ លោកុត្តរផល ដែលបុគ្គលគប្បីត្រេកអរឱ្យសម្រេចដល់សត្វលោកទាំងពួង ដោយផលនៃទាន ដែលអាត្មាអញឱ្យនេះ ។

**២-បានទាន** គឺឱ្យទឹកក្តៅ ឬទឹកត្រជាក់ ដល់អ្នកសូមទាំងឡាយ ដើម្បីបំបាត់នូវសេចក្តីឃ្លាន គឺកាមកិលេសនៃសត្វទាំងឡាយ ។

**៣-វត្ថទាន** គឺឱ្យសំពត់ សម្រាប់ស្លៀកដណ្តប់ដល់យាចកទាំងឡាយ ដើម្បីរក្សានូវពណ៌សម្បុរឱ្យល្អ ដូចជាពណ៌នៃមាសផង ដើម្បីអភិបាលនូវសេចក្តីខ្មាសបាប និងសេចក្តីតក់ស្លុតចំពោះបាប និងគ្រឿងប្រដាប់សម្រាប់ស្លៀកពាក់នៃសត្វទាំងឡាយផង ។

***៤-យានទាន*** *គឺឱ្យគ្រឿងជិះ គ្រឿងសែង ឬឲ្យស្ពាន ដល់បដិគ្គាហកៈទាំងឡាយ ដើម្បីសម្រេចនូវឥទ្ធិឫទ្ធិផង ដើម្បីសម្រួលឱ្យនូវសេចក្ដីសុខ ក្នុងព្រះនិព្វានផង ។*

***៥-គន្ធទាន*** *គឺឱ្យគ្រឿងក្រអូបជាទាន ដើម្បីសម្រេចកេរ្តិ៍ឈ្មោះ ក្រអូបអំពីសីលគុណ ។*

***៦-មាលាវិលេបនទាន*** *គឺឱ្យផ្កាកម្រងនិងគ្រឿងផ្ទូត គ្រឿងលាបផ្សេងៗជាទាន ដើម្បីសម្រេចនូវសុន្ទរាសីនៃព្រះពុទ្ធគុណ ។*

***៧-អាសនទាន*** *គឺឱ្យទីសម្រាប់អង្គុយជាទាន ដើម្បីសម្រេចនូវពោធិ-មណ្ឌលាសនៈ គឺញាណដ៏ផូរផង់ជាទីត្រាស់ដឹង ឈ្មោះថា ពោធិ ។*

***៨-សេយ្យទាន*** *គឺឱ្យនូវទីសម្រាប់ដេកជាទាន ដើម្បីសម្រេចសម្រាន្តនូវទីក្រឡាព្រះបន្ទំ ឈ្មោះថា តថាគតសេយ្យាសន៍ ។*

***៩-អាវាសថទាន*** *គឺឱ្យលំនៅជាទាន ដើម្បីសម្រេចនូវតេជានុភាពនៃខ្លួនព្រះអង្គ ឱ្យជាទីពឹងទីជ្រកនៃសត្វលោក ។*

***១០-បទីបេយ្យទាន*** *គឺឱ្យនូវគ្រឿងសម្រាប់បំភ្លឺ មានពន្លឺគោម និងពន្លឺចង្កៀងជាដើមជាទាន ដើម្បីសម្រេចនូវចក្ខុ ៥ យ៉ាង មានទិព្វចក្ខុជាដើម ។*

យោងតាមគម្ពីរអដ្ឋសាលិនី អដ្ឋកថាធម្មសង្គណី ព្រះពោធិសត្វទ្រង់តែងតែប្រព្រឹត្តនូវទាន ៦ ប្រការទៀតគឺ

**១-រូបទាន** ជាការបូជានូវវត្ថុ ដែលមានពណ៌ទាំងឡាយ មានកម្រងផ្កា និងសំពត់ដែលមានពណ៌ល្អជាដើម ដល់ព្រះពុទ្ធរតនៈ ដើម្បីឱ្យសម្រេចនូវឆព្វណ្ណរង្សី ។

**២-សទ្ទទាន** ឱ្យសំឡេងជាទាន គឺការបូជាតូរ្យតន្ត្រីដល់ព្រះរតនត្រ័យ និងប្រគេនប្រេង និងទឹកអំពៅ ដែលជាថ្នាំធ្វើឱ្យមានសំឡេងពីរោះ ចំពោះធម្មកថិកទាំងឡាយ ព្រមទាំងជួយឃោសនាឱ្យគេមកប្រជុំស្តាប់ធម៌ និងសម្តែងធម៌ទេសនា ឱ្យអ្នកទាំងពួងស្តាប់ជាដើម ដើម្បីឱ្យមានសំឡេងពីរោះក្បោះក្បាយ ដូចជាសំឡេងមហាព្រហ្ម ។

**៣-គន្ធទាន** ឱ្យក្លិនជាទាន គឺបូជានូវគ្រឿងក្រអូប មានឫសក្រអូបជាដើម ដែលជាទីគាប់ចិត្តដល់ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ដើម្បីឱ្យសម្រេចនូវសីលាទិគុណ ។

**៤-រសទាន** ឱ្យរសជាទាន គឺបូជានូវវត្ថុដែលមានរសឆ្ងាញ់ មានរសមើម និងផ្កាជាដើមដល់ពុទ្ធាទិវត្ថុ ដើម្បីឱ្យសម្រេចនូវគុណវិសេស គ្រាន់បានជាទីស្រឡាញ់ដល់សត្តនិករក្នុងត្រៃភព ។

***៥-ផោដ្ឋព្វទាន*** *ឱ្យនូវវត្ថុផ្សព្វផ្សាយនូវកាយជាទាន គឺបូជានូវទីសេនាសនៈទាំងឡាយមានគ្រែជាដើម ដល់ព្រះរតនត្រ័យ ដើម្បីសេចក្ដីសុខក្សេមក្សាន្ត បានជាសព្វញ្ញុពុទ្ធ ។*

***៦-ភេសជ្ជទាន*** *ឱ្យនូវថ្នាំរម្ងាប់រោគជាទាន គឺបូជានូវវត្ថុ ៣ មុខគឺ[២៩] សប្បិ និងនវនីត១ ទឹកអដ្ឋបាន១ ភត្ត ១៤ ប្រការ១ ដល់ព្រះរតនៈទាំងបី ដើម្បីឃាត់នូវជរា ព្យាធិ មរណៈ និងសេចក្ដីទុក្ខផ្សេងៗ មិនឱ្យកើតមានដល់ព្រះអង្គឡើយ ។*

*ម្យ៉ាងទៀត ព្រះពោធិសត្វ ព្រះអង្គតែងឱ្យនូវទានដទៃទៀត ១០ ប្រការគឺ*

***១-ទាសានំ កុជ្ជិស្សទាន*** *គឺកិរិយាលះបង់នូវបាវព្រាវខ្ញុំកំដរ ឱ្យរួចជាអ្នកជា នេះជាទាន ដើម្បីដោះស្រាយនូវព្រះអង្គ មិនឱ្យជាខ្ញុំនៃកិលេស-តណ្ហា ។*

***២-អនវជ្ជខិឌ្ឌារតិហេតុទាន*** *គឺឱ្យនូវវត្ថុសម្រាប់លេង ដែលមិនមានទោសទៅជាទាន ដើម្បីសេចក្ដីត្រេកអរចំពោះព្រះសទ្ធម្មរបស់ព្រះអង្គ ។*

---

*[២៩] សប្បិ ទឹកដោះថ្លា, នវនីត ទឹកដោះខាប់, អដ្ឋបាន (ទឹក ៨ យ៉ាង), ភត្ត ១៤ គឺ សង្ឃភត្ត១ ឧទ្ទេសភត្ត១ និមន្តនភត្ត១ សលាកភត្ត១ បក្ខិកភត្ត១ ឧបោសថិកភត្ត១ បាដិបទិកភត្ត១ អាគន្តុកភត្ត១ គមិកភត្ត១ គិលានភត្ត១ គិលានុបដ្ឋាកភត្ត១ ធុរភត្ត១ កុដិភត្ត១ វារភត្ត១។*

**៣-បុត្តទាន** គឺឱ្យនូវកូនប្រុសស្រីទៅជាទានដល់ជនទាំងឡាយ ដើម្បីកិរិយានាំចូលទៅជិតកាន់ភាវៈនៃកូននោះ ជាកូននៃព្រះអង្គ ក្នុងជាតិជាអរិយបុគ្គល ។

**៤-ទារទាន** គឺឱ្យនូវប្រពន្ធជាទានដល់ជនទាំងឡាយ ដើម្បីកិរិយាបាននូវភាវៈនៃព្រះអង្គ ជាម្ចាស់នៃសត្វលោកទាំងពួង ។

**៥. រជ្ជទាន** គឺឱ្យនូវរាជសម្បត្តិជាទាន ដើម្បីបាននូវភាវៈនៃព្រះអង្គជាស្តេច ព្រោះព្រះអង្គត្រាស់ដឹងនូវធម៌ ។

**៦.ហត្ថទាន** គឺឱ្យនូវព្រះហស្តជាទាន ដើម្បីឱ្យមានព្រះសទ្ធម្មក្នុងព្រះហស្ត ជាប្រយោជន៍ដល់សត្វទាំងឡាយ និងបានរើខ្លួនចេញចាកអន្ទង់ទាំង[៣០] ៤ មានបញ្ចពិធកាមគុណជាដើម ។

**៧-កណ្ណនាសាទិទាន** គឺឱ្យនូវចំណែករាងកាយ មានត្រចៀកនិងច្រមុះជាដើមទៅជាទាន ដើម្បីបានចំពោះនូវឥន្ទ្រិយជាកុសល មានសទ្ធិន្ទ្រិយជាដើម ។

**៨-ចក្ខុទាន** គឺឱ្យនូវព្រះនេត្រទៅជាទាន ដើម្បីបានចំពោះនូវសមន្តចក្ខុ។

[៣០] អន្ទង់ទាំង ៤ គឺ **កាមោឃៈ** អន្ទង់គឺកាម១ **ភវោឃៈ** អន្ទង់គឺភព១ **ទិដ្ឋោឃៈ** អន្ទង់គឺទិដ្ឋិ១ **អវិជ្ជោឃៈ** អន្ទង់គឺអវិជ្ជា១ ។

ព្រះបរមពោធិសត្វ ព្រះអង្គតែងស្វែងរកនូវប្រយោជន៍ និងសេចក្ដីសុខឱ្យដល់សត្វទាំងឡាយគ្រប់កាលទាំងពួង ។ ម្យ៉ាងទៀត សត្វលោកទាំងឡាយគប្បីចូលទៅជិតរស់នៅក្នុងកិច្ចទាំងឡាយដ៏ឧត្តម មានកិរិយាឃើញ និងព្រមទាំងរលឹករឿយៗ និងបានធ្វើការបម្រើជាដើម ចំពោះព្រះអង្គ ។

**៩-មំសលោហិតទាន** គឺកិរិយាឱ្យនូវសាច់ និងឈាមទៅជាទាន ព្រោះព្រះអង្គមានបំណងថា សូមឱ្យអាត្មាអញមានសរីរកាយបរិបូណ៌ ។

**១០-ឧត្តមង្គទាន** គឺកិរិយាបូជាអវយវៈដ៏ឧត្តម គឺព្រះសីសៈរបស់ព្រះអង្គឱ្យទៅជាទាន ព្រោះព្រះអង្គគិតថា សូមឱ្យអាត្មាអញជាបុគ្គល ឧត្តមខ្ពង់ខ្ពស់ជាងសត្វលោកទាំងពួង ដូចការបំពេញទានរបស់ព្រះពោធិសត្វអរិយមេត្តេយ្យ ដោយទ្រង់មានលក្ខណៈសំខាន់មួយគឺ កាត់ព្រះសីសៈបូជាព្រះពុទ្ធសិរីមត្តៈ មិនមានបំណងចង់បានការដឹងគុណ ឬផលប្រយោជន៍ ពីបដិគ្គាហកៈ (អ្នកទទួលទាន) ក្នុងលោកនេះឡើយ ។

ការបំពេញទានរបស់ព្រះពោធិសត្វ មានពុទ្ធភូមិជាអារម្មណ៍ គឺព្រះទ័យជាប់ជំពាក់ក្នុងសព្វញ្ញុតញ្ញាណ ពោលគឺ ដើម្បីបានសម្រេចជាព្រះពុទ្ធ ។ ទានរបស់ព្រះពោធិសត្វ មានលក្ខណៈលះបង់ខ្ពស់ ដែលមនុស្សធម្មតាមិនអាចធ្វើឱ្យដូចបាន លុះតែបុគ្គលខំព្យាយាមបំពេញទានបន្តិចម្ដងៗ ចាប់ពី

វត្ថុតូចតាចឡើងទៅ ។ ការធ្វើទាននេះ ព្រះពោធិសត្វមានព្រះទ័យក្លាហាន មិនញញាប់ញញ័រ ភិតភ័យ តក់ស្លុត ឬស្ដាយក្រោយឡើយ ។

ក្នុងការរក្សាទាននេះ ព្រះពោធិសត្វហ៊ានលះបង់ជាទាននូវអ្វីៗ ទាំងអស់ ដោយប្រកាន់ជំហរ ៣ កម្រិត ដូចខាងក្រោម :

**កម្រិតទី១ ទានបារមី**

ព្រះពោធិសត្វ ពុំដែលរារែកក្នុងការលះបង់នូវទ្រព្យសម្បត្តិ គ្រឿងប្រើប្រាស់របស់ព្រះអង្គ ធ្វើជាទានលុះអស់រលីងហាក់ដូចជាទឹកដែលហូរចេញអស់ពីក្អមដែលផ្កាប់ យ៉ាងណាមិញ ការលះបង់របស់ព្រះពោធិសត្វ មានរួមទាំងភរិយានិងបុត្រ ជាទាន ក៏យ៉ាងនោះដែរ ។ ទាននេះ ឈ្មោះថា **ទានបារមី** ដែលជាគុណជាតិសម្រាប់នាំសត្វលោកទៅកាន់ត្រើយដ៏ប្រសើរ គឺព្រះនិព្វាន ។

**កម្រិតទី២ ទានឧបបារមី**

ក្នុងការធ្វើទាន ព្រះពោធិសត្វ តែងប្រព្រឹត្តនូវកិរិយាលះបង់អវយវៈមានអង្គតូច អង្គធំរបស់ព្រះអង្គជាទាន ។ ទាននេះ ឈ្មោះថា **ទាន-ឧបបារមី** ដែលជាគុណជាតិសម្រាប់នាំសត្វលោកទៅកាន់ត្រើយដ៏ប្រសើរ គឺព្រះនិព្វាន ។

មានរឿងជាតកជាច្រើន ក្នុងការសាងនូវទានឧបបារមីនេះ ។ ខ្ញុំសូមលើកយករឿងមួយមកបញ្ជាក់ :

កាលព្រះពោធិសត្វសោយជាតិជាស្តេចព្រះនាមសិវិរាជ[៣១] ព្រះអង្គដាក់ទានព្រះនេត្រទាំងគូដល់ឥន្ទព្រាហ្មណ៍ដែលចូលមកសូមព្រះនេត្ររបស់ព្រះអង្គ ។ បន្ទាប់ពីព្រះអង្គទ្រង់ពិចារណាថា យើងដាក់ទានទ្រព្យសម្បត្តិគ្រប់បែបយ៉ាងអស់ហើយ បើមានអ្នកណាមួយមកសូមនូវអវយវៈអង្គតូច អង្គធំរបស់អាត្មាអញ យើងនឹងដាក់ទាននូវអវយវៈតូចធំរបស់យើងជូនអ្នកនោះ ដោយពុំមានការអល់អែកស្តាយក្រោយដ៏តិចតួចឡើយ ។

ត្រង់ចំណុចនេះ ព្រះសម្មាសម្ពុទ្ធទ្រង់រលឹកនូវទាន ដែលព្រះអង្គបានប្រទាននូវចក្ខុទាំងគូ កាលទ្រង់កើតជាព្រះបាទសិវិរាជ :

"ក្នុងកាលមុនឱ្យក្តី កំពុងឱ្យក្តី ឱ្យរួចហើយក្តី ចិត្តរបស់តថាគត ឥតមានការរាយមាយឡើយ ព្រោះហេតុពោធិញ្ញាណតែម្យ៉ាង ។ ចក្ខុទាំងពីរ មិនមែនជាទីស្អប់របស់តថាគតទេ ទាំងខ្លួនសោតទៀត ក៏មិនមែនជាទីស្អប់របស់តថាគតដែរ តែសព្វញ្ញុតញ្ញាណ ទើបជាទីស្រឡាញ់របស់តថាគត ព្រោះហេតុនោះ បានជាតថាគតឱ្យចក្ខុ" ។

---

[៣១] សុត្តន្ត.ខុទ្ទក.ចរិយា.៧៧/២៩០ ។

## ភូមិភាគទី៣ ទានបរមត្ថបារមី

*សូម្បីការលះបង់ដល់ជីវិតរបស់ព្រះអង្គក្តី ក៏ទ្រង់ហ៊ានបរិច្ចាគជីវិតរបស់ព្រះអង្គផ្ទាល់ធ្វើជាទានដែរ ។ ទាននេះ ឈ្មោះថា* ***ទានបរមត្ថបារមី*** *ដែលជាគុណជាតិដ៏ប្រសើរ សម្រាប់នាំសត្វលោកទៅកាន់ត្រើយបរមសុខ គឺព្រះនិព្វាន ។*

*សរុបមក ការធ្វើទានរបស់ព្រះពោធិសត្វ ទាំងអាមិសទានក្តី ធម្មទានក្តី មានលក្ខណៈខុសពីមនុស្សយើងធម្មតា ព្រោះការធ្វើទានរបស់ព្រះអង្គ មានសព្វញ្ញុតញ្ញាណជាអារម្មណ៍ គឺដើម្បីបានចាក់ធ្លុះត្រាស់ដឹងជាព្រះសម្មាសម្ពុទ្ធ ។ ក្នុងការសាងទានបាមរីនេះ ព្រះពោធិសត្វតែងសច្ចាប្រណិធានដូច្នេះថា:*

> *"គ្រប់អនាគតជាតិតទៅ អាត្មាអញសូមឱ្យមានចិត្តល្អជានិច្ច ហើយធ្វើខ្លួនឱ្យជាប្រយោជន៍ដល់សត្វលោកទូទៅ" ។*

## ២-សីលបារមី

***សីល*** *មានន័យថា "កិរិយាប្រព្រឹត្តទៅជាប្រក្រតី ឬការរក្សាកាយ វាចា ចិត្តឱ្យល្អ" ។*

*ព្រះពោធិសត្វបំពេញនូវបារមីទី២ គឺសីល ដែលជាទីតាំងនៃកុសល-ធម៌ទាំងឡាយមាន សីល ៥ សីល ៨ សីល ១០ ឬអធិសីល តាមកម្រិតដែលអាចរក្សាបាន ។ បុគ្គលអាចសាងសីលបារមីក្នុងឋានៈជាឧបាសកក្តី ឧបាសិកាក្តី តែសីលដែលមានកម្រិតខ្ពស់ជាងគេ គឺការរក្សាសីលក្នុងភេទផ្នួស ។ "**ការរក្សាសីល គឺជាវិធីបង្ហាត់ចិត្តឱ្យបរិសុទ្ធបន្តិចម្តងៗ**" ជាពិសេស និច្ចសីល (សីល ៥) ដែលជាវិន័យដ៏សំខាន់បំផុត សម្រាប់ត្រួតនគរទាំង ៣ របស់យើងគឺ* **កាយ វាចា** *និង* **ចិត្ត** *ឱ្យប្រព្រឹត្តទៅក្នុងកុសលកម្ម ។*

*ការរក្សាសីលរបស់ព្រះពោធិសត្វ តាមការកត់សម្គាល់មានលក្ខណៈពិសេស ដូចខាងក្រោម :*

*- **រក្សាសីល** គឺដើម្បីជៀសវាងអំពើអកុសលកម្ម ដែលមិនមែនជាគុណធម៌ ។ អ្នករក្សាសីល ត្រូវធ្វើសច្ចាធិដ្ឋានចំពោះព្រះពុទ្ធបដិមា ព្រះសង្ឃ ឬ អាចារ្យថានឹងលះបង់នូវបាបកម្មដែលមានចែងក្នុងសិក្ខាបទទាំងឡាយ និងឧទ្ទិសខ្លួនថ្វាយចំពោះព្រះរតនត្រ័យជានិច្ច ហើយហ្វឹកហាត់ព្យាយាមបំពេញក្នុង*

កុសលទាំងឡាយមាន **សមាធិ ភាវនា** និង **វិបស្សនា** ជាដើម ។

ក្នុងន័យនេះ ការរក្សាសីល គឺជាការហ្វឹកហាត់ត្រួតចិត្ត ដើម្បីឱ្យមានសេចក្ដីស្ងប់ ។

- **រក្សាសីល** គឺដើម្បីជាប្រយោជន៍ដល់សត្វលោកទូទៅ ។ ការរក្សាសីលនេះមានកម្រិតខ្ពស់ជាងគេ ដោយអធិដ្ឋានចិត្តជួយដោះទុក្ខអ្នកដទៃ មានការណែនាំគេឱ្យរក្សាសីលជាដើម ហើយត្រូវផ្សាយមេត្តា ករុណាធម៌ ចំពោះសព្វសត្វលោកទូទៅដែលរងទុក្ខ ។

- **រក្សាសីល** ឱ្យហ្មត់ចត់ស្អាត មិនឱ្យដាច់វិនាសទៅ ប្រកបដោយចតុប្បារិ-សុទ្ធិសីល ឬ សីល ៨ សីល ៥ ឱ្យបរិបូណ៌ប្រពៃ មានសទ្ធា សតិ វិរិយៈ និងបញ្ញា ជាមូលដ្ឋានគ្រឹះ ។

ក្នុងការរក្សាសីលបារមីនេះ ព្រះពោធិសត្វតែងតែប្រព្រឹត្ត និងរក្សាសីល ដោយប្រកាន់ជំហរ ៣ កម្រិត ដូចខាងក្រោម :

## កម្រិតទី១ សីលបារមី

ព្រះពោធិសត្វ ពុំរារែកក្នុងការប្រព្រឹត្តនូវការរក្សាសីល ទោះបីត្រូវលះបង់នូវរាជសម្បត្តិក្ដី ទ្រព្យសម្បត្តិក្ដី ឬលះបង់នូវភរិយា និងបុត្រយ៉ាងណាក្ដី គឺព្រះអង្គមិនធ្វើឱ្យបាត់បង់នូវសីលរបស់ព្រះអង្គឡើយ ។

សីលនេះ ឈ្មោះថា **សីលបារមី** ដែលជាគុណជាតិសម្រាប់នាំសត្វលោកទៅកាន់ត្រើយដ៏ប្រសើរ គឺព្រះនិព្វាន ។

## កម្រិតទី២ សីលឧបបារមី

ក្នុងការកសាងនិងរក្សាសីល ព្រះពោធិសត្វហ៊ានលះបង់នូវអវយវៈអង្គតូច អង្គធំរបស់ព្រះអង្គយ៉ាងណា គឺព្រះអង្គមិនធ្វើឱ្យបាត់បង់នូវសីលរបស់ព្រះអង្គឡើយ ។ សីលនេះ ឈ្មោះថា **សីលឧបបារមី** ដែលជាគុណជាតិសម្រាប់នាំសត្វលោកទៅកាន់ត្រើយដ៏ប្រសើរ គឺព្រះនិព្វាន ។

## កម្រិតទី៣ សីលបរមត្ថបារមី

សូម្បីការលះបង់ដល់ជីវិតរបស់ព្រះអង្គ ក៏ទ្រង់ហ៊ានបរិច្ចាគជីវិតផ្ទាល់ព្រះអង្គ ដើម្បីរក្សានិងកសាងនូវសីលរបស់ព្រះអង្គយ៉ាងខ្ជាប់ខ្ជួន ដោយការតាំងចិត្តប្តូរផ្តាច់ ការពារសីល គឺព្រះអង្គមិនធ្វើឱ្យបាត់បង់នូវសីលរបស់ព្រះអង្គឡើយ ។ សីលនេះ ឈ្មោះថា **សីលបរមត្ថបារមី** ដែលជាគុណជាតិដ៏ប្រសើរសម្រាប់នាំសត្វលោកទៅកាន់ត្រើយបរមសុខ គឺព្រះនិព្វាន ។

ដូចមានរឿង **ភូរិទត្តនាគរាជ**[៣២] ជាអ្នកកាន់សីលក្នុងសីលបរមត្ថ-បារមី ជាដើម ។ ក្នុងការសាងសីលបារមីឱ្យខ្ជាប់ខ្ជួននេះ យើងត្រូវប្រុងប្រយ័ត្នការពារសីលរបស់យើងឱ្យដូចជា :

**កិកីវ អណ្ឌំ ចមរីវ វាលធឹ**

**បិយំវ បុត្តំ នយនំវ ឯកកំ**

**តថេវ សីលំ អនុរក្ខមានកា**

**សុបេសលា ហោថ សទា សគារវា ។**

ប្រែ: "សត្វត្រដេវវិច រក្សានូវស៊ុតវា យ៉ាងណាមិញ, សត្វចាមរីរក្សានូវកន្ទុយវា យ៉ាងណាមិញ, មាតារក្សានូវកូនប្រុសតែមួយ យ៉ាងណាមិញ, ជនមានភ្នែកតែម្ខាង រក្សានូវភ្នែក យ៉ាងណាមិញ, អ្នកទាំងឡាយកំពុងរក្សាសីល ជាអ្នកមានសីលជាទីស្រឡាញ់ក្រៃលែង ចូរជាអ្នកប្រកបដោយសេចក្តីគោរពសីលឱ្យបានសព្វកាល ក៏យ៉ាងនោះដែរ" ។

ដូច្នេះ យើងត្រូវតាំងចិត្តប្តូរផ្តាច់ការពារសីលរបស់យើង ដោយប្រុងប្រយ័ត្នគ្រប់ពេលវេលា ហើយកុំធ្វេសប្រហែសឱ្យសោះ ។ ខ្ញុំសូមលើក

[៣២] សុត្តន្ត.ខុទ្ទក.ចរិយា.៧៧/២៦៩ ។

ឧទាហរណ៍ជាក់ស្តែងនៃរឿងព្រះពោធិសត្វ កាលលោកយោនយកកំណើត ជាព្រះរាជបុត្រនៃព្រះបាទព្រហ្មទត្ត នៅក្រុងពារាណសី ដែលត្រូវបំពេញតួនាទីជាឧបរាជ[៣៣] ប្រចាំនគរ ។ ក្នុងជាតិនោះ ព្រះពោធិសត្វត្រូវចាប់ជាចំណាប់ខ្មាំងនៃសេចក្តីស្នេហារបស់មហេសីចុងរបស់ព្រះបិតា ។ ដោយប្រកាន់នូវសីលធម៌ដ៏ខ្ពង់ខ្ពស់នោះឯង ព្រះពោធិសត្វ ស៊ូប្តូរជីវិតមិនព្រមប្រព្រឹត្តបាបកម្មជាមួយនឹងព្រះមាតាចុងឡើយ ដោយបញ្ជាក់ថា "ខ្ញុំមិនឱ្យខ្លួនខ្ញុំ លង់ក្នុងអំពើបាបកម្មនៃកាមតណ្ហានេះ ទោះបីម្ចាស់ក្សត្រីកាត់ក្បាលរបស់ទូលបង្គំរាប់រយពាន់ជាតិក៏ដោយ" ។ នេះជាជំហររបស់ព្រះពោធិសត្វក្នុងការរក្សាសីល ។

ក្នុងការសាងសីលបារមីនេះ ព្រះពោធិសត្វតែងតាំងចិត្តសច្ចាប្រណិធានដូច្នេះថា :

> "គ្រប់អនាគតជាតិតទៅ អាត្មាអញសូមរក្សានូវសីល ដែលជាវិន័យដ៏ថ្លៃថ្លាប្រចាំជីវិត ឱ្យខ្ជាប់ខ្ជួនជានិច្ច សូមឱ្យការប្រព្រឹត្តទៅនូវគ្រប់ទង្វើរបស់អាត្មាអញ ស្អាតបរិសុទ្ធសព្វៗកាល ដើម្បីជាប្រយោជន៍ដល់សត្វលោកទូទៅ" ។

[៣៣] មហាបទុមជាតក បិដកលេខ ៥៩ ទំព័រ ២៦០ ។

## ៣-នេក្ខម្មបារមី

**នេក្ខម្មៈ** គឺការចេញសាងផ្នួស មានន័យថា "កិរិយាចេញទៅដើម្បីគុណធំ ឬថាបព្វជ្ជា គឺផ្នួស ឬកិរិយាចេញសាងផ្នួស" ។ ព្រះពោធិសត្វ តែងហ្វឹកហ្វឺនចិត្តព្រះអង្គក្នុងការលះបង់នូវទ្រព្យសម្បត្តិ យសសក្តិ គ្រួសារ និងកាមគុណ គឺការត្រេកត្រអាលក្នុងវត្ថុកាម ដែលជាគ្រឿងជាប់ជំពាក់ក្នុងលោក ។ ការលះបង់នូវវត្ថុកាម និងកិលេសកាម គឺជាការលះបង់ដ៏ប្រសើរបំផុត ដើម្បីឈានទៅសម្រេចនូវពុទ្ធភូមិ ។ ព្រះពោធិសត្វ លះបង់គ្រឿងជាប់ជំពាក់ទាំងនេះ អស់ជាច្រើនអសង្ខេយ្យជាតិ ដោយការចេញសាងផ្នួសជាតាបស ឬជាភិក្ខុសាមណេរ ។ ការប្រព្រឹត្តព្រហ្មចរិយធម៌នេះ ជាតិខ្លះក៏សម្រេចដល់ឈាន អភិញ្ញា សមាបត្តិក៏មាន ដូចជារឿងតេមិយកុមារ[៣៨] ចេញសាងបព្វជ្ជាជាដើម ។

ព្រះពោធិសត្វ តែងប្រព្រឹត្តព្រហ្មចរិយធម៌យ៉ាងហ្មត់ចត់ ដោយប្រកាន់ជំហរ ៣ កម្រិត ដូចខាងក្រោម :

### កម្រិតទី១ នេក្ខម្មបារមី

ព្រះពោធិសត្វ តែងប្រព្រឹត្តនូវនេក្ខម្មបារមី ដោយព្រះអង្គមានការលះបង់នូវរាជសម្បត្តិ ទ្រព្យសម្បត្តិ យសសក្តិ គ្រួសារ និងកាម-

[៣៨] សុត្តន្ត.ខុទ្ទក.ចរិយា.៧៧/២៩៣ ។

គុណ គឺការត្រេកត្រអាលក្នុងវត្ថុកាម ដែលជាគ្រឿងជាប់ជំពាក់ក្នុងលោក ដោយការចេញសាងបព្វជ្ជា ជាតាបស ឬជាភិក្ខុសាមណេរជាដើម ។ នេក្ខម្មៈនេះ ឈ្មោះថា **នេក្ខម្មបារមី** ដែលជាគុណជាតិសម្រាប់នាំសត្វលោកទៅកាន់ត្រើយដ៏ប្រសើរ គឺព្រះនិព្វាន ។

## កម្រិតទី២ នេក្ខម្មឧបបារមី

ក្នុងការប្រតិបត្តិ និងរក្សានេក្ខម្មបារមីនេះ ព្រះពោធិសត្វ ហ៊ានលះបង់នូវអវយវៈ អង្គតូច អង្គធំរបស់ព្រះអង្គយ៉ាងណា គឺទ្រង់តាំងចិត្តមុតមាំបំផុត ដើម្បីរក្សានូវនេក្ខម្មៈរបស់ព្រះអង្គ ។ នេក្ខម្មៈនេះ ឈ្មោះថា **នេក្ខម្មឧបបារមី** ដែលជាគុណជាតិសម្រាប់នាំសត្វលោកទៅកាន់ត្រើយដ៏ប្រសើរ គឺព្រះនិព្វាន ។

## កម្រិតទី៣ នេក្ខម្មបរមត្ថបារមី

សូម្បីការលះបង់ដល់ជីវិតរបស់ព្រះអង្គ ក៏ទ្រង់ហ៊ានបរិច្ចាគជីវិតព្រះអង្គផ្ទាល់ ដើម្បីរក្សានូវការកសាងនេក្ខម្មៈរបស់ព្រះអង្គ ដោយការតាំងចិត្តប្តូរផ្តាច់ការពារព្រះផ្នួស គឺព្រះអង្គមិនធ្វើឱ្យបាត់បង់នូវនេក្ខម្មៈរបស់ព្រះអង្គឡើយ ។ នេក្ខម្មៈនេះ ឈ្មោះថា **នេក្ខម្មបរមត្ថបារមី** ដែលជាគុណជាតិដ៏ប្រសើរសម្រាប់នាំសត្វលោកទៅកាន់ត្រើយបរមសុខ គឺព្រះនិព្វាន ។

ក្នុងការសាងនេក្ខម្មបារមីនេះ ព្រះពោធិសត្វ តែងសច្ចាប្រណិធានថា :

"គ្រប់អនាគតជាតិតទៅ អាត្មាអញសូមកុំឱ្យជាអ្នកមានចិត្តអាត្មា-និយម សូមឱ្យក្លាយជាអ្នកអាចលះបង់នូវការត្រេកត្រអាលសប្បាយផ្ទាល់ខ្លួន និងជាអ្នកសាងប្រយោជន៍ដល់សត្វលោកទូទៅ" ។

## ៤-បញ្ញាបារមី

**បញ្ញា** មានន័យថា "ធម្មជាតិដឹងដោយបការៈ ឬសេចក្ដីយល់ឃើញជាក់ច្បាស់" ។

**បញ្ញាបារមី** គឺជាគុណធម៌ ដែលដឹងច្បាស់នូវសេចក្ដីពិត អាចកម្ចាត់នូវការល្ងិតល្ងង់ ការភាន់ច្រឡំ ឬការសង្ស័យ ។ បុគ្គលណាដែលអាចត្រួតត្រាកាយ វាចា និងចិត្ត តាមវិន័យសីលធម៌ទាំង ៣ ជំពូកខាងលើ មានឈ្មោះថា ជាអ្នករក្សាសីល ឬជាអ្នកដែលប្រកបដោយសីលធម៌ប្រចាំជីវិត គឺជាអ្នកបំពេញសីលបារមី ។ នេះគឺជាសេចក្ដីសុខពិត ដែលអ្នកប្រាជ្ញតែងនិយមស្វែងរកសម្រាប់ជាប្រយោជន៍ខ្លួនឯងផង និងសម្រាប់សង្គមមនុស្ស-ជាតិផង ។ កាលបើបុគ្គលណាមួយ មានសេចក្ដីស្ងប់ក្នុងចិត្តហើយ បុគ្គលនោះ ទើបអាចសាងបញ្ញាបារមីបាន ។

**ប្រភពនៃការបណ្តុះបញ្ញាមាន ៣ យ៉ាង**

១- បញ្ញាអាចកើតឡើងដោយការព្យាយាមសិក្សារៀនសូត្រ ស្តាប់ពីសម្មាក់បណ្ឌិតសប្បុរស ។ បញ្ញានោះ ឈ្មោះថា **សុតមយបញ្ញា** គឺបញ្ញាកើតពីការស្តាប់ ការសិក្សារៀនសូត្រ ។

បញ្ញាកើតឡើងបាន ដោយការខិតខំព្យាយាមសិក្សាក្បួនខ្នាត និងស្តាប់ឱ្យយល់ពីទស្សនៈ និងគតិបណ្ឌិតរបស់គ្រូអាចារ្យ ។

២- ការបានស្តាប់ហើយ គប្បីធ្វើទុកក្នុងចិត្តដោយត្រូវទំនង ត្រិះរិះពិចារណាសព្វគ្រប់ ទើបកើតមានបញ្ញាឡើង ។ បញ្ញានេះ ឈ្មោះថា **ចិន្តមយបញ្ញា** គឺបញ្ញាកើតពីការត្រិះរិះពិចារណារកហេតុផល ។

បញ្ញាអាចធ្វើឱ្យបុគ្គលយល់ច្បាស់ក្នុងចិត្ត នូវបញ្ហាអ្វីមួយដែលត្រូវដោះស្រាយ ។ បញ្ញាអាចញ៉ាំងបុគ្គលឱ្យយល់ត្រូវ គិតត្រូវ និងធ្វើត្រូវ ជាគតិប្រចាំជីវិត ។

៣- បញ្ញាកើតពីការហ្វឹកហាត់ចិត្ត ឱ្យស្ថិតនៅក្នុងអារម្មណ៍តែមួយមិនឱ្យរវើរវាយ បញ្ញានេះឈ្មោះថា **ភាវនាមយបញ្ញា** ។

បញ្ញា ជាពន្លឺដែលនាំឱ្យបុគ្គលចេញចាកផុតពីផ្លូវវង្វេងក្នុងលោកិយនេះ ។ បញ្ញាអាចកើនចម្រើន ដោយបុគ្គលបានខំសន្សំកុសល ដែលជា

ចំណែកនៃញាណសម្បយុត្ត គឺធ្វើនូវកុសល ប្រកបដោយបញ្ញាជារឿយៗ ទើបជាឧបនិស្ស័យនាំឱ្យបុគ្គលនោះ កើតមកសម្បូរដោយបញ្ញា ។

បុគ្គលអ្នកសាងបញ្ញា គឺជាការចម្រើននូវគតិបណ្ឌិតឱ្យបានប្រសើរដោយតែងតែយកបញ្ញានោះ មកជួយរំដោះទុក្ខវេទនារបស់សត្វលោកទាំងពួង ។ បញ្ញាអាចប្រៀបទៅនឹងពន្លឺព្រះអាទិត្យ បើព្រះអាទិត្យរះឡើងកាលណា រស្មីនៃព្រះអាទិត្យនោះ តែងតែញុំាងភាពខ្មៅងងឹតនៃរាត្រី ឱ្យវិនាសអស់ពីលោកនេះទៅយ៉ាងណា បុគ្គលអ្នកមានបញ្ញា តែងតែជួយបំភ្លឺអប់រំណែនាំសត្វលោកគ្រប់គ្នា ដែលកំពុងទទួលរងនូវភាពងងឹត គឺអវិជ្ជាដែលជាសត្រូវនៃបញ្ញា ។ **អវិជ្ជា** គឺសេចក្តីល្ងង់ខ្លៅ ប្រៀបដូចជាភាពងងឹត, រីឯ **បញ្ញា** ប្រៀបដូចជាពន្លឺ ។ ការសាងបញ្ញាបារមី គឺជាការសាងពន្លឺ ដើម្បីបំបាត់អវិជ្ជា ។ បុគ្គលត្រូវសន្សំបញ្ញាបន្តិចម្តងៗ គ្រប់ៗជាតិ ទើបសម្រេចដល់បញ្ញាដ៏កំពូលគឺ **សព្វញ្ញុតញ្ញាណ** ។

ក្នុងការរក្សាបញ្ញាបារមីនេះ ព្រះពោធិសត្វ តែងតែប្រព្រឹត្ត និងរក្សាបញ្ញា ដោយប្រកាន់ជំហរ ៣ កម្រិត ដូចខាងក្រោម :

## កម្រិតទី១ បញ្ញាបារមី

ក្នុងការសាងនូវបញ្ញា គឺព្រះពោធិសត្វ តែងតែលះបង់នូវកម្លាំងកាយ កម្លាំងចិត្ត ខិតខំធ្វើការសិក្សាឈ្វេងយល់ពីគ្រប់ទីកន្លែង និង

សាកសួរអ្នកប្រាជ្ញគ្រប់ជាតិដើម្បីទទួលបាននូវបញ្ញា ទោះបីត្រូវលះបង់នូវទ្រព្យសម្បត្តិ រាជសម្បត្តិ យសសក្តិ និងគ្រួសារក៏ដោយ។ ក្នុងការសាងនូវបញ្ញា ព្រះអង្គខំធ្វើនូវប្រយោជន៍ធំ និងប្រយោជន៍តូចរបស់សត្វលោកទាំងឡាយឱ្យសម្រេច។ កិរិយានោះឯង ហៅថា **បញ្ញាបារមី** ដែលជាគុណជាតិសម្រាប់នាំសត្វលោកទៅកាន់ត្រើយដ៏ប្រសើរ គឺព្រះនិព្វាន ។

## កម្រិតទី២ បញ្ញាឧបបារមី

ការសាងបញ្ញា និងការរក្សាបញ្ញារបស់ព្រះពោធិសត្វ ព្រះអង្គហ៊ានលះបង់នូវអវយវៈ អង្គតូច អង្គធំយ៉ាងណា គឺព្រះអង្គតាំងចិត្តមុតមាំ ដើម្បីរក្សានូវបញ្ញា គឺមិនឱ្យរលត់សាបសូន្យនូវបញ្ញារបស់ព្រះអង្គឡើយ ។ ក្នុងការសាងបញ្ញា ព្រះអង្គខំធ្វើនូវប្រយោជន៍ធំ និងប្រយោជន៍តូចឱ្យសម្រេចដល់សត្វលោកទាំងឡាយ។ ព្រះហឫទ័យយ៉ាងមុតមាំនេះ ឈ្មោះថា **បញ្ញាឧបបារមី** ដែលជាគុណជាតិសម្រាប់នាំសត្វលោកទៅកាន់ត្រើយដ៏ប្រសើរ គឺព្រះនិព្វាន ។

## កម្រិតទី៣ បញ្ញាបរមត្ថបារមី

សូម្បីការលះបង់ដល់ជីវិតរបស់ព្រះអង្គ ក៏ទ្រង់ហ៊ានបរិច្ចាគជីវិតព្រះអង្គផ្ទាល់ ដើម្បីរក្សានូវការសាងបញ្ញារបស់ព្រះអង្គ ដោយព្រះ

អង្គខំប្រឹងប្រែងរហូតដល់ប្តូរជីវិត ដើម្បីបំពេញនូវកិច្ចដល់ជនទាំងឡាយឱ្យសម្រេច ពោលគឺ ព្រះអង្គមិនធ្វើឱ្យបាត់បង់នូវបញ្ញារបស់ព្រះអង្គឡើយ ។ ព្រះហឫទ័យដ៏អង់អាចមុតមាំនេះហើយ ដែលមានឈ្មោះថា **បញ្ញាបរមត្ថបារមី** ដែលជាគុណជាតិដ៏ប្រសើរសម្រាប់នាំសត្វលោកទៅកាន់ត្រើយបរមសុខ គឺព្រះនិព្វាន ។

ក្នុងការបំពេញបញ្ញាបារមីនេះ តួអង្គព្រះពោធិសត្វ សូម្បីលោកយោនយកកំណើតជាសត្វសុនខក្តី ក៏លោកហ៊ានឆ្លងកាត់យ៉ាងមោះមុត នូវឧបសគ្គដល់ជីវិត ប្រឈមមុខជាមួយនឹងស្តេចផែនដី តែដោយឥរិយាបថស្លូតបូតប្រកបដោយបញ្ញា ដើម្បីតវ៉ារកយុត្តិធម៌ជូនសុនខទាំងឡាយ ដែលជាបរិវាររស់នៅតាមព្រៃស្មសាន នាជាយក្រុងពារាណសី ។

ក្នុងការសាងបន្តនូវបញ្ញាបារមី គ្រប់ៗជាតិ ព្រះពោធិសត្វរមែងធ្វើសច្ចាប្រណិធានចំពោះខ្លួនលោកថា :

"គ្រប់អនាគតជាតិតទៅ អាត្មាអញសូមប្រាថ្នាឱ្យមានបញ្ញាបរិបូរ ដើម្បីអាចមើលធ្លុះនូវភាពពិតលើបញ្ហា ឬវត្ថុទាំងឡាយ ដែលកើតមានឡើងចំពោះមុខ សូមឱ្យអាត្មាអញ មើលឃើញនូវពន្លឺសច្ចធម៌ ហើយអាចដឹកនាំសត្វទាំងឡាយ ពីភាពងងឹតទៅរកពន្លឺ អាត្មាអញសូមប្រាថ្នាឱ្យត្រាស់ដឹង ហើយអាចដឹកនាំសត្វលោកទាំងឡាយ

ឱ្យត្រាស់ដឹងផង អាត្មាអញសូមចែករំលែកអានិសង្សនៃការសាង បញ្ញារបស់អាត្មាអញ ដើម្បីជាប្រយោជន៍ដល់សត្វលោកទាំងឡាយ"។

## ៥-វីរិយបារមី

***វីរិយៈ*** *មានន័យថា "សេចក្ដីតស៊ូ ព្យាយាម ប្រឹងប្រែង" ។*

ជាទូទៅ វីរិយៈ មានន័យថា ការខំប្រឹងប្រែង ព្យាយាម តស៊ូ ដោយកម្លាំងកាយ (ជាធំ) ចិត្ត និងប្រាជ្ញា ដើម្បីឱ្យបានសម្រេចនូវគោលបំណងអ្វីមួយ ដែលយើងកំណត់ទុកជាមុន[៣៥] ។ និស្សិតដែលបានខំព្យាយាមសិក្សាអស់ពីសមត្ថភាព ទោះបីជួបប្រទះការលំបាកគ្រប់បែបយ៉ាងក្ដី ក៏ប្រឹងប្រែងព្យាយាមរហូតទទួលបានជោគជ័យក្នុងការសិក្សារបស់ខ្លួន, ឧទាហរណ៍ជាក់ស្ដែងនៃការប្រតិបត្តិវីរិយធម៌ និស្សិតនោះ ត្រូវចាត់ទុកជាអ្នកបានបំពេញនូវវីរិយធម៌ដ៏ប្រសើរ ទើបសម្រេចនូវគោលបំណងដ៏ចម្បងរបស់ខ្លួន ។

ការប្រារព្ធវីរិយធម៌នេះ យើងអាចប្រៀបធៀបនឹងនារី ដែលខំរចនាកម្រងផ្កាដោយរៀបផ្កាមួយទងម្ដងៗ ក៏អាចក្លាយជាកម្រងផ្កាដ៏ល្អប្រណីតបាន ។ នេះក៏មិនខុសគ្នាពីនារី ដែលត្បាញសំពត់សូត្រ នាងតែងបញ្ចូលសូត្រក្នុងត្រល់មួយសរសៃម្ដងៗ រហូតក្លាយជាសំពត់សូត្រដ៏ល្អប្រណីត ចម្រុះ

---

[៣៥] វចនានុក្រមខ្មែររបស់សម្ដេចព្រះសង្ឃរាជថ្នាក់ទី១ **ជួន ណាត** (ជោតញ្ញាណោ) ។

ដោយពណ៌ផ្សេងៗគ្នា ។ សត្វចាបជៀបកប្បាស តែងតែយកស្មៅ ឬវល្លិល្អិតតូចៗ មួយម្ដងៗ សាងជាសំបុកដ៏ល្អសម្រាប់គ្រួសារវាបាន ។ រីឯបុព្វបុរសនៃយើង ក៏សាងប្រាសាទអង្គរវត្តដ៏ល្អខ្ពស់ស្កឹមស្កៃ ល្បីល្បាញលើលោក ដោយយកដុំថ្មមួយដុំម្ដងៗ មកតម្កល់លើគ្នា ក្នុងការសាងសង់អស់ពេលដ៏យូររាប់សតវត្សរ៍ ។ ឧទាហរណ៍ទាំងនេះ បញ្ជាក់អំពីការអនុវត្តនៃវិរិយធម៌ក្នុងជីវិតរបស់សត្វលោក ។

វិរិយបារមីនេះ ជាគុណធម៌មួយដ៏ខ្ពស់ មានន័យទូលំទូលាយណាស់ ដែលព្រះពោធិសត្វ តែងប្រារព្ធព្យាយាមឱ្យបានសម្រេចនូវគោលបំណងក្នុងជីវិត ទោះបីមានឧបសគ្គដ៏ធំមហិមាមកជំទាស់យ៉ាងណាក្ដី ។ ក្នុងការប្រតិបត្តិដើម្បីសាងវិរិយបារមីនេះ ព្រះពោធិសត្វគ្រប់ព្រះអង្គ តែងប្រាថ្នានូវការត្រាស់ដឹងជាព្រះសម្មាសម្ពុទ្ធ ដើម្បីឱ្យរួចផុតចាកទុក្ខក្នុងវដ្ដសង្សារផង និងដើម្បីជួយចម្លងសត្វលោកទាំងពួង ឱ្យឆ្លងផុតចាកទុក្ខទៅកាន់ព្រះនិព្វានផង ។

ដូច្នេះ ដើម្បីសាងវិរិយបារមី ពីជាតិមួយទៅជាតិមួយ ព្រះពោធិសត្វបានសាងកុសលធម៌ និងដុសខាត់សម្អាតសេចក្ដីខ្ជិលច្រអូស ចេញពីព្រះអង្គឱ្យអស់ ។ ព្រះអង្គមិនបណ្ដោយឱ្យពេលវេលា និងអាយុរបស់ព្រះអង្គរសាត់បាត់ទៅ ដោយគ្មានប្រយោជន៍ឡើយ ។ លោកមិនបណ្ដោយឱ្យខ្លួន

លោក វង្វេងដោយការធ្វេសប្រហែស ដូចជាអ្នកដេកលង់លក់ងល់ងប់នា ពាត្រីជ្រៅ ឬអ្នកវង្វេងលង់ខ្លួនក្នុងជ្រោះនៃក្ដីសប្បាយ និងត្រេកត្រអាល ដោយកាមគុណដែលជានីវរណធម៌[៣៦] ដែលជាធម៌រារាំងមិនឱ្យបុគ្គល បានសម្រេចនូវទិសដៅក្នុងជីវិតឡើយ ។

ក្នុងការរក្សាវីរិយបារមីនេះ ព្រះពោធិសត្វ តែងសាងវីរិយបារមី ដោយម៉ត់ចត់ គឺប្រកាន់ជំហរ ៣ កម្រិត ដូចខាងក្រោម :

**កម្រិតទី១ វីរិយបារមី**

ទោះបីការសាងវីរិយបារមី ត្រូវជួបឧបសគ្គដល់ការលះបង់ទ្រព្យ សម្បត្តិ យសសក្តិ ឬប្រពន្ធកូនក្តី ព្រះអង្គពុំលះបង់វីរិយបារមី ឲ្យប្រែ ប្រួលពីគោលដៅដែលលោកប្រកាន់យកយ៉ាងមុតមាំនោះឡើយ។ វីរិយៈនេះ ឈ្មោះថា **វីរិយបារមី** ដែលជាគុណជាតិសម្រាប់នាំសត្វ លោកទៅកាន់ត្រើយដ៏ប្រសើរ គឺព្រះនិព្វាន ។

---

[៣៦] នីវរណធម៌ ធម៌ជាគ្រឿងរារាំងមិនឱ្យសម្រេចកុសលធម៌មាន ៥ យ៉ាងគឺ

១. **កាមច្ឆន្ទៈ** ចិត្តត្រេកត្រអាលក្នុងកាម

២. **ព្យាបាទៈ** ចិត្តអាក្រក់ ស្អប់ខ្ពើម និងមានកំហឹង គុំគួន

៣. **ថីនមិទ្ធៈ** ភាពសោះអង្គើយមិនយកចិត្តទុកដាក់ ងោកងុយ ខ្ជិលច្រអូស

៤. **ឧទ្ធច្ចៈ** សេចក្តីអណ្តែតអណ្តូងរាយមាយ និងរវើរវាយគ្មានទិសដៅ

៥. **វិចិកិច្ឆា** ភាពមន្ទិលសង្ស័យទៅលើអ្វីដែលច្បាស់លាស់ ។

## កម្រិតទី២ វីរិយឧបបារមី

ទោះបីព្រះពោធិសត្វត្រូវលះបង់នូវអង្គាវយវៈ គឺអវយវៈអង្គតូច អង្គធំ មានដៃនិងជើងជាដើម ក៏ព្រះអង្គមិនស្តាយឡើយ ហើយបាន ព្យាយាមចម្រើនវីរិយធម៌ឱ្យសម្រេច នេះឈ្មោះថា **វីរិយឧបបារមី** ដែលជាគុណជាតិសម្រាប់នាំសត្វលោកទៅកាន់ត្រើយដ៏ប្រសើរ គឺព្រះនិព្វាន ព្រោះសេចក្តីព្យាយាម ។

## កម្រិតទី៣ វីរិយបរមត្ថបារមី

ព្រះពោធិសត្វ ព្យាយាមសាងវីរិយបារមី ដោយមិនព្រមលះបង់នូវ ការព្យាយាមរបស់ព្រះអង្គឡើយ ទោះបីព្រះអង្គត្រូវប្រឈមមុខ ចំពោះឧបសគ្គ ដែលមានគ្រោះថ្នាក់ដល់ជីវិតក្តី ព្រះអង្គនៅតែតស៊ូ យ៉ាងស្វិតស្វាញ ទាំងកម្លាំងកាយ (ជាធំ) កម្លាំងចិត្ត និងបញ្ញា ដោយមិនបោះបង់នូវទិសដៅដែលព្រះអង្គប្រាថ្នាទុកពីមុនមក ឡើយ ។ នេះឈ្មោះថា **វីរិយបរមត្ថបារមី** ដែលជាគុណជាតិ សម្រាប់ នាំសត្វលោកទៅកាន់ត្រើយដ៏ប្រសើរ គឺព្រះនិព្វាន ។

ក្នុងការសាងវីរិយបារមីនេះ ព្រះពោធិសត្វឆ្លងកាត់ជាតិជាច្រើន ដូចរឿងព្រះមហាជនកជាតកជាដើម ដែលព្រះអង្គបានហែលឆ្លងកាត់

មហាសមុទ្រដ៏ធំធេង មើលកោះត្រើយមិនឃើញក្តី ក៏ព្រះអង្គនៅតែមិនលះបង់នូវសេចក្តីព្យាយាមដ៏មោះមុតនោះដែរ ។

ក្នុងការសាងបន្តនូវវីរិយបារមី រាល់ៗជាតិ ព្រះពោធិសត្វរមែងធ្វើសច្ចាប្រណិធានចំពោះខ្លួនលោកថា :

"គ្រប់អនាគតជាតិតទៅ អាត្មាអញសូមប្រាថ្នាឱ្យមានកម្លាំងខ្លាំងក្លា ហើយព្យាយាមតស៊ូយ៉ាងស្វិតស្វាញ រហូតអាត្មាអញបានសម្រេចនូវគោលដៅរបស់អាត្មាអញ សូមឱ្យអាត្មាអញមានចិត្តអង់អាចជម្នះគ្រប់គ្រោះថ្នាក់ និងឧបសគ្គទាំងឡាយ សូមឱ្យអាត្មាអញមានលទ្ធភាពបម្រើសត្វលោកទាំងឡាយឱ្យអស់ពីសមត្ថភាព" ។

## ៦-ខន្តិបារមី

**ខន្តិ** គឺជាអំណត់អត់ធន់ ជាគុណធម៌ខាងផ្លូវចិត្ត ក្នុងការអត់ទ្រាំនឹងទុក្ខវេទនាគ្រប់បែបយ៉ាង ដោយយកធម៌ជាគោល ដើម្បីសាងឆ្ពោះទៅកាន់ពុទ្ធភូមិ ។ ការខំសាងខន្តីបារមីនេះ អាចញុាំងឱ្យបុគ្គលរម្ងាប់នូវការព្រួយបារម្ភ ការតូចចិត្ត និងអាចធ្វើឱ្យចិត្តនឹងធឹង ហើយរកសុខក្នុងព្រះហឫទ័យបាន ។ ខន្តី ជាសភាវៈផ្ទុយពីទោសៈ គឺកំហឹង ។ កំហឹងនេះ ជាប្រភពនៃអំពើសាហាវយង់ឃ្នង នៃការកាប់សម្លាប់ និងសង្គ្រាមនានា ។ ការសាងខន្តីបាមរីមានលក្ខណៈសំខាន់ គួរឱ្យកត់សម្គាល់ដូចខាងក្រោម :

-ខន្តិបារមី ដោយមិនប្រព្រឹត្តតបវិញ នឹងអំពើអាក្រក់ដែលគេរំលោកបំពានលើព្រះពោធិសត្វ ។ ព្រះពោធិសត្វតែងតែខំអត់សង្កត់ចិត្ត រាល់អំពើផ្តាំផ្គងទាំងឡាយរបស់មនុស្សសត្វ ដោយចិត្តករុណាដ៏ធំទូលាយ ។

- កាយ វាចា ចិត្ត របស់ព្រះពោធិសត្វ តែងតែប្រព្រឹត្តទៅដោយអាការៈមិនក្រោធ ខឹងច្រឡោត ឆេវឆាវ ជាប្រក្រតី ។

- ព្រះពោធិសត្វ តែងតែចាត់ទុកអ្នកដែលប្រព្រឹត្តអំពើផ្តាំផ្គងលើខ្លួនលោក ទោះបីបងប្អូនជាប់សាច់ឈាមជាមួយនឹងលោកក៏ដោយ ក៏លោកតែងតែអត់ឱនទូវអំពើល្មើសរបស់អ្នកទាំងនោះ ដោយធម៌មេត្តាករុណារបស់លោកដែរ ។

- ក្នុងការសាងខន្តិបារមីនេះ ព្រះពោធិសត្វរមែងមិនខឹងតប រករឿងហេតុទប់ទល់ជាមួយនឹងអ្នកដែលប្រមាថមើលងាយ ខឹងតិះដៀលព្រះអង្គដោយគ្មានកំហុស ឬដោយរំលោកបំពានក្តី ។ នេះមិនមែនមានន័យថា ព្រះពោធិសត្វ មិនមានវាចាតបតនោះឡើយ គឺព្រះពោធិសត្វតែងនិយាយស្តីតបវិញ តែដោយពាក្យពីរោះ និងទឹកចិត្តមិនប្រកាន់ទោសនោះឯង ។

ក្នុងការរក្សាខន្តិបារមីនេះ ព្រះពោធិសត្វហ៊ានលះបង់នូវអ្វីៗទាំងអស់ តែមិនឱ្យដាច់នូវខន្តិធម៌នេះឡើយ ដោយប្រកាន់ជំហរ ៣ កម្រិត ដូចខាងក្រោម :

## កម្រិតទី១ ខន្តិបារមី

*ព្រះពោធិសត្វ មានខន្តិធម៌ចំពោះគ្រប់សត្វ ដែលធ្វើការផ្តាំផ្គងលើព្រះអង្គ ទោះបីចង់បានទ្រព្យសម្បត្តិ ប្រពន្ធកូនរបស់ព្រះអង្គក្តី ក៏ព្រះអង្គមិនមានចិត្តបៀតបៀន ឬខឹងក្រោធចំពោះបុគ្គលទាំងនោះឡើយ គឺព្រះអង្គបានរក្សានូវ**ខន្តិបារមី** ដែលជាគុណជាតិដ៏ប្រសើរសម្រាប់នាំសត្វលោកទៅកាន់ត្រើយបរមសុខ គឺព្រះនិព្វាន ។*

## កម្រិតទី២ ខន្តិឧបបារមី

*ទោះបីមានការបៀតបៀនពីសម្នាក់បុគ្គល ឬសត្វដទៃ ដែលចង់បាន ឬធ្វើឱ្យបាត់បង់និងខូចខាតដល់រាងកាយ អវយវៈ អង្គតូច អង្គធំក្តី ក៏ព្រះអង្គមិនមានការខឹងក្រោធ ចំពោះសត្វលោកទាំងនោះឡើយ គឺព្រះអង្គរក្សានូវ**ខន្តិឧបបារមី** ដែលជាគុណជាតិដ៏ប្រសើរសម្រាប់នាំសត្វលោកទៅកាន់ត្រើយបរមសុខ គឺព្រះនិព្វាន ។*

## កម្រិតទី៣ ខន្តិបរមត្ថបារមី

*ទោះបីមានការបៀតបៀនពីបុគ្គលដទៃ សូម្បីដល់ជីវិតរបស់ព្រះអង្គក្តី ក៏ព្រះអង្គមិនមានការតក់ស្លុត និងការប្រទូស្តតបតវិញឡើយ គឺព្រះអង្គនៅតែរក្សានូវ**ខន្តិបរមត្ថបារមី** ដែលជាគុណជាតិដ៏ប្រសើរសម្រាប់ដឹកនាំសត្វលោកទៅកាន់ត្រើយបរមសុខ គឺព្រះនិព្វាន ។*

*ក្នុងការសាងនូវខន្តិបារមី រាល់ៗជាតិ ព្រះពោធិសត្វរមែងធ្វើសច្ចា-ប្រណិធានចំពោះខ្លួនលោកថា :*

*"គ្រប់អនាគតជាតិតទៅ អាត្មាអញសូមប្រាថ្នាឱ្យជាអ្នកមានអំណត់អត់ធន់ជានិច្ច ហើយអាចអត់ទ្រាំចំពោះពាក្យទ្រគោះបោះបោក និងកំហុសអ្នកដទៃ ដែលមានចំពោះអាត្មាអញ ។ សូមឱ្យជាអ្នកដែលចេះអត់ឱនដល់សត្វលោកទាំងឡាយ ហើយយល់ឃើញនូវចំណុចល្អៗ របស់សត្វលោកទាំងនោះ ជាជាងរកកំហុសរបស់គេ" ។*

*ដូចនៅក្នុង**រឿងខន្តិវាទីតាបស**[៣៧] ព្រះពោធិសត្វ មិនបានខឹងតបតសូម្បីបន្តិចបន្តួចឡើយ ចំពោះស្តេចកលាពុ ដែលបៀតបៀនព្រះអង្គ ។*

## ៧-សច្ចបារមី

***សច្ចៈ** មានន័យថា "ការពិតប្រាកដ សេចក្តីទៀងត្រង់" ។*

***សច្ចៈ** គឺជាកិរិយាប្រព្រឹត្តទៅក្នុងវាចា ដែលមិនព្រមពោលនូវពាក្យមិនពិត ។ **សច្ចបារមី** ជាគុណជាតិ ឬធម៌ដ៏ប្រសើរមួយរបស់ព្រះអរិយបុគ្គលដែលលោកតែងអនុវត្តក្នុងជីវិត ដើម្បីឱ្យត្រាស់ដឹងជាព្រះសព្វញ្ញុពុទ្ធ ។ ការសាងសច្ចបារមីនេះ ព្រះពោធិសត្វ លោកបានទទួលនូវគុណសម្បត្តិដ៏ខ្ពង់*

[៣៧] *សូមមើលក្នុងមាលាជាតក ក្នុងសៀវភៅនេះផ្នែកខាងមុខ ។*

ខ្ពស់បំផុត គឺព្រះនិព្វាន ។ នេះ គឺសំដៅដល់ការប្រកាន់យ៉ាងខ្ជាប់ខ្ជួននូវសច្ចធម៌ គឺការរក្សាពាក្យពិត គ្រប់សកម្មភាពអ្វីៗទាំងអស់ក្នុងជីវិត ទោះបីព្រះពោធិសត្វត្រូវប្រឈមមុខចំពោះគ្រោះថ្នាក់ដ៏ធំដល់ជីវិតក្តី ក៏លោកពុំលះបង់នូវសច្ចធម៌ឡើយ ។ ក្នុងការសាងសច្ចបារមីនេះ ក៏ដូចជាបារមីដទៃទៀតដែរ គឺព្រះពោធិសត្វតែងប្រកាន់ខ្ជាប់នូវកិរិយា "មិនពោលនូវពាក្យខុសពីការពិត" ដោយលោកប្រកាន់ជំហរ ៣ កម្រិត ដូចខាងក្រោម :

**កម្រិតទី១ សច្ចបារមី**

ព្រះពោធិសត្វ លោកស៊ូលះបង់នូវទ្រព្យសម្បត្តិ រាជសម្បត្តិ យសសក្តិគ្រប់បែបយ៉ាង រួមទាំងបុត្រនិងភរិយាផង ដើម្បីរក្សានូវ**សច្ចធម៌** ដែលជាគុណជាតិដ៏ប្រសើរសម្រាប់នាំសត្វលោកទៅកាន់ត្រើយបរមសុខ គឺព្រះនិព្វាន ។

**កម្រិតទី២ សច្ចឧបបារមី**

ព្រះពោធិសត្វ លោកស៊ូលះបង់អវយវៈ អង្គតូច អង្គធំ នៃរាងកាយរបស់ព្រះអង្គ ក្នុងការរក្សាសច្ចធម៌ ដើម្បីសាង**សច្ចឧបបារមី** ដែលជាគុណជាតិដ៏ប្រសើរសម្រាប់ដឹកនាំសត្វលោកទៅកាន់ត្រើយបរមសុខ គឺព្រះនិព្វាន ។

### **គម្រិតទី៣ សច្ចបរមត្ថបារមី**

ព្រះពោធិសត្វ លោកស៊ូលះបង់ជីវិតក្នុងការរក្សាសច្ចធម៌ ដើម្បីសាង **សច្ចបរមត្ថបារមី** ដែលជាគុណជាតិដ៏ប្រសើរ សម្រាប់នាំសត្វលោកឆ្លងទៅកាន់ត្រើយបរមសុខ គឺព្រះនិព្វាន ។

ក្នុងរឿង**ព្រះវិធុរបណ្ឌិត** ព្រះពោធិសត្វបានឱ្យដំបូន្មានព្រះរាជាថា "**ក្នុងព្រះឋានៈជាស្តេចផែនដី ព្រះអង្គត្រូវតែគោរពនូវសច្ចធម៌ ទោះបីព្រះអង្គត្រូវលះបង់រាជសម្បត្តិ នគរ ឬព្រះជន្មក៏ដោយ**" ។

ក្នុងការសាងសច្ចបារមីនេះ គ្រប់ៗជាតិ ព្រះពោធិសត្វតែងតែធ្វើសច្ចាប្រណិធានរបៀបនេះថា :

> "គ្រប់អនាគតជាតិតទៅ អាត្មាអញសូមប្រាថ្នាឱ្យប្រកាន់ខ្ជាប់នូវពាក្យពិត ក្នុងកិរិយាប្រព្រឹត្តទៅនៃជីវិត អាត្មាអញសូមកុំឱ្យវៀចវេរខុសពីការពិត ដើម្បីផ្តល់នូវសេចក្តីសុខដល់មនុស្សសត្វទូទៅ" ។

## **៨-អធិដ្ឋានបារមី**

**អធិដ្ឋាន** មានន័យថា "កិរិយាតាំងចិត្តទទួលកិច្ចដែលគួរកាន់យក" ។ **អធិដ្ឋាន** គឺជាកិច្ចដែលសមាទានប្រកាន់យកយ៉ាងមុតមាំ នូវគោលដៅអ្វីមួយ ហើយមិនងាករេ ផ្លាស់ប្តូរ ប្រែប្រួល ដោយសារជួបប្រទះការលំបាក ឬ

ឧបសគ្គណាមួយឡើយ ។ ព្រះពោធិសត្វ តែងកាន់យកដោយឈ្លាសវៃនូវឧបាយនៃករុណាចិត្ត ហើយមានចិត្ត និងចេតសិក តែងប្រព្រឹត្តទៅតាមអាការៈនៃសេចក្តីអធិដ្ឋាននោះ ។ អំពើនេះហៅថា ការសាង**អធិដ្ឋានបារមី** ដែលជាគុណជាតិសម្រាប់ចម្លងសត្វលោកទៅកាន់ត្រើយបរមសុខ គឺព្រះនិព្វាន ព្រោះសេចក្តីតាំងចិត្តព្យាយាមមុតមាំ ។ ដើម្បីរក្សាឱ្យគង់វង្សនូវអធិដ្ឋាននេះ ព្រះពោធិសត្វតែងប្រកាន់ខ្ជាប់នូវជំហរ ៣ កម្រិត ដូចខាងក្រោម :

**កម្រិតទី១ អធិដ្ឋានបារមី**

ទោះបីការតាំងចិត្តអធិដ្ឋានបារមីនេះ ត្រូវជួបឧបសគ្គរហូតដល់លះបង់នូវទ្រព្យសម្បត្តិ កូន ប្រពន្ធក៏ដោយ ក៏ព្រះពោធិសត្វពុំងាករេប្រែប្រួលពីគោលដៅ ដែលលោកប្រកាន់យកយ៉ាងមុតមាំនោះឡើយ ព្រះអង្គបានរក្សានូវ**អធិដ្ឋានបារមី** ដែលជាគុណជាតិដ៏ប្រសើរ សម្រាប់នាំសត្វលោកទៅកាន់ត្រើយបរមសុខ គឺព្រះនិព្វាន ព្រោះសេចក្តីតាំងចិត្តដ៏មាំនេះ ។

**កម្រិតទី២ អធិដ្ឋានឧបបារមី**

ទោះបីការតាំងចិត្តអធិដ្ឋានបារមីនេះ ជួបការលំបាក ឬឧបសគ្គដែលព្រះពោធិសត្វត្រូវឆ្លងកាត់នោះ សូម្បីព្រះអង្គត្រូវលះបង់

អវយវៈ អង្គតូច អង្គធំ នៃរាងកាយរបស់ព្រះអង្គក៏ដោយក្តី ដើម្បីប្រកាន់យកនូវធម៌ជាកុសលនោះ ព្រះអង្គក៏នៅតែមិនងាករេពីការសម្រេចចិត្តដ៏មុតមាំរបស់ព្រះអង្គឡើយ ។ នេះហៅថា **អធិដ្ឋាន-ឧបបារមី** ដែលជាគុណជាតិដ៏ប្រសើរ សម្រាប់នាំសត្វលោកទៅកាន់ត្រើយបរមសុខ គឺព្រះនិព្វាន ដោយសារការតាំងចិត្តដ៏មុតមាំនេះ ។

**កម្រិតទី៣ អធិដ្ឋានបរមត្ថបារមី**

ក្នុងការតាំងចិត្ត ដែលជាកិរិយាសមាទាននូវកុសលធម៌ (គោលបំណងសាងកុសលធម៌) ណាមួយហើយនោះ ព្រះពោធិសត្វមិនអាចរលាស់ចោលឡើយ ទោះបីព្រះអង្គត្រូវប្រឈមមុខនឹងការលះបង់ជីវិតផ្ទាល់របស់ខ្លួនក្តី ។ សេចក្តីមិនកម្រើក ដោយខ្លាចបាត់បង់ជីវិតនេះហើយ ហៅថា **អធិដ្ឋានបរមត្ថបារមី** ដែលជាគុណជាតិដ៏ប្រសើរសម្រាប់នាំសត្វលោកទៅកាន់ត្រើយបរមសុខ គឺព្រះនិព្វាន។

ក្នុងការសាងអធិដ្ឋានបារមីនេះ ព្រះពោធិសត្វ ត្រូវផ្អែកលើការព្យាយាម ទាំងកម្លាំងកាយ និងកម្លាំងចិត្ត ជាមូលដ្ឋានចម្បង ហើយគ្រប់ៗជាតិ ព្រះពោធិសត្វតែងធ្វើសច្ចាប្រណិធានដូច្នេះថា :

"គ្រប់អនាគតជាតិតទៅ អាត្មាអញសូមឱ្យចិត្តមុតមាំប្តូរផ្តាច់ក្នុងការសម្រេចបំណងកុសលធម៌ សូមឱ្យអាត្មាអញមានចិត្តរឹងមាំដូចដែក តែមានសភាវៈទន់ភ្លន់ដូចផ្កា និងជាអ្នកប្រកាន់សីលធម៌ខ្ពស់ជានិច្ច" ។

## សន្និដ្ឋាន

ដើម្បីជាសក្ខីភាព ក្នុងការបញ្ជាក់ពីកម្រិតនៃអធិដ្ឋានបារមីរបស់ព្រះពោធិសត្វ ខ្ញុំសូមលើកយករឿងសត្វឥន្ទ្រីមួយ (ដែលជាតួអង្គព្រះពោធិសត្វបានយោនកំណើត) មកនិទានដោយសង្ខេបដូចតទៅ :

ក្នុងកាលដ៏យូរលង់កន្លងទៅ ព្រះសម្មាសម្ពុទ្ធសមណគោតម ទ្រង់បានចាប់កំណើតជាសត្វឥន្ទ្រីមួយ ហើយរស់នៅក្បែរក្រុងកបិលពស្តុ ។ ថ្ងៃមួយ សត្វឥន្ទ្រីហើរឆ្លងកាត់ទីក្រុង បានឃើញក្បួនហែព្រះសម្មាសម្ពុទ្ធមួយអង្គ ដែលគង់ប្រថាប់លើបុស្បុក រចនាដោយសំពត់ពណ៌ផ្កាភ្លឺដ៏ប្រណីតឥតមានពីរ ។ សត្វឥន្ទ្រីនោះ បានគយគន់មើលប្រកបដោយចិត្តបីតិរីករាយឥតឧបមា ចំពោះព្រះភក្ត្រដ៏ភ្លឺត្រចះត្រចង់ បញ្ចេញឆព្វណ្ណរង្សីគ្រប់ទិសទីដែលអស្ចារ្យដ៏មហាក្រៃលែង ។ រំពេចនោះ ឥន្ទ្រីក៏មានពោធិចិត្តផុសឡើងភ្លាម ដោយចង់ត្រាស់ដឹងជាព្រះសម្មាសម្ពុទ្ធមួយអង្គ ហើយបានតាំងចិត្តថានឹងទៅថ្វាយបង្គំគោរពព្រះសម្មាសម្ពុទ្ធអង្គនោះ ។ តែយល់ថា ខ្លួនជាសត្វស្លាប តើធ្វើដូចម្តេចទើបអាចចូលជិតព្រះសម្មាសម្ពុទ្ធបាន? គិតដូច្នេះហើយ

ឥន្ទ្រីក៏ត្រឡប់ទៅកាន់កន្លែងដែលធ្លាប់អាស្រ័យនៅតាមមាត់បឹង ឯដាយក្រុងវិញ ហើយប្តេជ្ញាចិត្តថា នឹងគោរពព្រះសម្មាសម្ពុទ្ធឱ្យពេញ ៧ ថ្ងៃ ៧ យប់ ។ បន្ទាប់មក សត្វឥន្ទ្រីក៏អធិដ្ឋានថា :

"តាមសេចក្តីសម្រេចចិត្តដ៏មុតមាំនេះ អាត្មាអញសូមសច្ចាប្រណិធានថា ដោយគុណដែលកើតឡើងពីការគោរពព្រះសម្មាសម្ពុទ្ធ នាពេលនេះ សូមឱ្យអាត្មាអញត្រាស់ជាព្រះពុទ្ធមួយអង្គទៅអនាគត" ។

ប្រាថ្នាដូច្នេះហើយ ក៏លើកស្លាបទាំងពីរសំកាំងឱនក្បាលជាសញ្ញាគោរព ដោយបែរមុខឆ្ពោះទៅទីតាំងដែលឃើញព្រះសម្មាសម្ពុទ្ធ ។ សត្វឥន្ទ្រីឈរជើងស្តាំតែម្ខាងដោយអត់កម្រើក (ដូចដុំថ្មមួយដុំ) ដោយអត់ចំណីអាហារអស់រយៈពេល ៧ ថ្ងៃ ៧ យប់ ។ ពីមួយថ្ងៃ ទៅមួយថ្ងៃ កម្លាំងកាន់តែចុះខ្សោយជាលំដាប់ ។ លុះចប់ថ្ងៃទី៧ សត្វឥន្ទ្រីក៏ស្លាប់ចាកលោក ហើយរំពេចនោះ ក៏បានចាប់កំណើតជាទេវបុត្រមួយអង្គនៅឋានតាវត្តិង្ស[៣៨] ។

នេះបង្ហាញពីកម្លាំងកាយនៃការព្យាយាម និងកម្លាំងចិត្តដ៏មោះមុតអស្ចារ្យ ក្នុងការសាងអធិដ្ឋានបរមត្ថបារមីនៃសត្វឥន្ទ្រី ដែលជាតួអង្គព្រះពោធិសត្វកាលពីអតីតជាតិ ៕

[៣៨] សត្វឥន្ទ្រីបានចាប់បដិសន្ធិ ជាឱបបាតិកៈកំណើត ។

## ៩-មេត្តាបារមី

**មេត្តាបារមី** គឺជាមេត្តាមហាសាល ដោយផ្តល់នូវសេចក្តីស្រឡាញ់គ្មានព្រំដែនដល់សត្វលោកទាំងអស់ ដោយពុំរើសអើងពីជាតិសាសន៍ និងប្រភពកំណើតជាដើម ។ មេត្តាធម៌[៣៩] ជាសេចក្តីស្រឡាញ់បរិសុទ្ធដែលផុសចេញពីបេះដូង ដោយមានសេចក្តីប្រាថ្នាចង់ឱ្យសត្វលោកទូទៅ មានសេចក្តីសុខជានិច្ចនៅក្នុងជីវិត ។ ព្រះពោធិសត្វ ពុំដែលមានចិត្តព្យាបាទដល់អ្នកដទៃឡើយ ទោះបីជាសត្រូវរបស់ព្រះអង្គក៏ដោយ ។ ក្នុងការសាងមេត្តាបារមីនេះ ព្រះពោធិសត្វតែងប្រកាន់យកបញ្ញាឈ្លាសវាងវៃជាឧបាយ ដោយមានមេត្តាធម៌ដ៏ជ្រាលជ្រៅចំពោះសត្វលោកជាមូលដ្ឋាន ។

ការសាងមេត្តាបារមីនេះមាន ៣ កម្រិតដែរគឺ

### កម្រិតទី១ មេត្តាបារមី

ទោះបីព្រះពោធិសត្វ ត្រូវលះបង់បុត្រាបុត្រី និងភរិយាក៏ដោយ ក៏លោកនៅតែរក្សាឱ្យជាប់នូវមេត្តាធម៌ គឺកិរិយាមិនញុំាំងការចម្រើន និងសេចក្តីសុខរបស់សត្វទាំងឡាយឱ្យវិនាស ដោយសារការបៀត

[៣៩] មេត្តាធម៌ ជាធម៌ទី១ នៃព្រហ្មវិហារធម៌គឺ មេត្តា ករុណា មុទិតា ឧបេក្ខា ដែលមាតាបិតា (ព្រះរស់) មានចំពោះកូនប្រុសស្រី ។ តែដោយឡែកព្រះពោធិសត្វ លោកមានមេត្តាចំពោះសព្វសត្វទូទៅទាំងអស់ ។

បៀន ឬសម្លាប់កូន ប្រពន្ធរបស់ព្រះអង្គឡើយ ។ សេចក្តីមិនព្យាបាទតបតដល់អ្នកបៀតបៀនព្រះអង្គនេះហើយ ឈ្មោះថា **មេត្តាបារមី** ដែលជាគុណជាតិធ្វើឱ្យសត្វលោកឆ្លងទៅកាន់ត្រើយដ៏ប្រសើរ គឺព្រះនិព្វាន ។

## កម្រិតទី២ មេត្តាឧបបារមី

ទោះបីព្រះពោធិសត្វ ត្រូវលះបង់អវយវៈ អង្គតូច អង្គធំនៃរាងកាយរបស់ព្រះអង្គ ដោយការបៀតបៀនរបស់អ្នកដទៃក៏ដោយ ក៏ព្រះអង្គមិនមានចិត្តចង់ព្យាបាទដល់អ្នកទាំងនោះឡើយ ។ ការមិនចងពៀរនេះហើយ ឱ្យឈ្មោះថា **មេត្តាឧបបារមី** ដែលជាគុណជាតិសម្រាប់នាំសត្វលោកទៅកាន់ត្រើយដ៏ប្រសើរ គឺព្រះនិព្វាន ។

## កម្រិតទី៣ មេត្តាបរមត្ថបារមី

ទោះបីព្រះពោធិសត្វ ត្រូវលះបង់ជីវិតរបស់ព្រះអង្គ ដោយការប្រមាថបៀតបៀនធ្វើបាបពីសម្នាក់អ្នកដទៃក្តី ក៏ព្រះអង្គមិនប្រព្រឹត្តនូវអំពើតបតឱ្យអ្នកទាំងនោះទទួលការវិនាសខាតបង់នូវប្រយោជន៍ឡើយ ។ ការមិនតបតចងពៀរព្យាបាទចំពោះជននោះវិញដូច្នេះហៅថា **មេត្តាបរមត្ថបារមី** ដែលជាគុណជាតិសម្រាប់នាំសត្វលោកទៅកាន់ត្រើយដ៏ប្រសើរបំផុត គឺព្រះនិព្វាន ។

ក្នុងការសាងមេត្តាបារមីនេះ គ្រប់ៗជាតិ ព្រះពោធិសត្វតែងតែធ្វើសច្ចាប្រណិធានរបៀបនេះថា :

"គ្រប់អនាគតជាតិតទៅ អាត្មាអញសូមប្រាថ្នាឱ្យមានចិត្តល្អ មានករុណាធម៌ និងបានជាទីស្រឡាញ់រាប់អានរបស់មនុស្សទូទៅអាត្មាអញសូមឱ្យមានទឹកចិត្តស្រឡាញ់ និងតម្កល់សត្វលោកទាំងឡាយឱ្យដូចជាម្តាយ ឪពុក បង ប្អូន របស់អាត្មាអញដូចៗគ្នាទាំងអស់" ។

ដើម្បីជាសក្ខីភាពបញ្ជាក់ពីការសាងមេត្តាបារមី សូមលោកអ្នកមេត្តាសិក្សារឿងពលបាលកុមារជាតក និងរឿងព្រះសុវណ្ណសាមកុមារ ជាដើម ។

## ១០-ឧបេក្ខាបារមី

**ឧបេក្ខា** មានន័យថា "សភាពជាកណ្តាល" ។ **ឧបេក្ខា** ជាកិរិយាកម្ចាត់បង់នូវសេចក្តីត្រេកអរ និងការមិនថ្នាំងថ្នាក់ មិនខឹងក្រោធ និងប្រព្រឹត្តទៅស្មើចំពោះសត្វនិងសង្ខារទាំងឡាយ ដោយតម្កល់ចិត្តជាកណ្តាលគ្មានលម្អៀង ។ ក្នុងការសាងឧបេក្ខាបារមីនេះ ព្រះពោធិសត្វតែងហាត់ពត់ចិត្តឱ្យមានតុល្យភាព (កណ្តាល) ដោយមានឧបេក្ខាចិត្តជាឧបាយ ។ សេចក្តីថា គ្មានប្រការអ្វីដែលអាចញ៉ាំងព្រះពោធិសត្វ ឱ្យមានចិត្តអបអរ រំភើបញាប់ញ័រ ឬភ័យខ្លាចដ៏តិចតួចឡើយ ។ ក្នុងស្ថានភាពនៃចិត្តជាឧបេក្ខា ព្រះពោធិសត្វពុំមានការរំភើបញាប់ញ័រ ចំពោះអដ្ឋលោកធម៌ (ធម៌ក្នុងលោកទាំង ៨)មាន :

| | |
|---|---|
| ១. មានលាភ | ២. អត់លាភ |
| ៣. មានយស | ៤. អត់យស |
| ៥. សរសើរ | ៦. និន្ទា |
| ៧. សុខ | ៨. ទុក្ខ |

ក្នុងកាលៈទេសៈណាក៏ដោយ នៅពេលដែលលោកធម៌ទាំង ៨ ប្រការនេះកើតឡើង ព្រះពោធិសត្វលោកគង់ស្ថិតនៅក្នុងសភាពនឹងដដែល ហាក់ដូចជាថ្មដែលត្រូវខ្យល់បក់បោកនៅនឹងថ្កល់យ៉ាងនោះដែរ ។ ការបំពេញឧបេក្ខាបារមី បែកចេញជា ៣ កម្រិត ដូចបារមីដទៃទៀតដែរៈ

**កម្រិតទី១ ឧបេក្ខាបារមី**

ចិត្តនៃព្រះពោធិសត្វតាំងនៅជាកណ្តាលជានិច្ច ចំពោះលោកធម៌ដែលកើតមានឡើងដល់សត្វលោកទាំងឡាយ ទោះបីអ្នកនោះមានឧបការគុណក្តី មិនមានឧបការគុណក្តី មានបុត្រ និងភរិយារបស់លោកជាដើម ។ កិរិយាតាំងនៅជាកណ្តាលចំពោះលោកធម៌នេះឈ្មោះថា **ឧបេក្ខាបារមី** ដែលជាគុណជាតិសម្រាប់ដឹកនាំសត្វលោកឆ្ពោះទៅកាន់ត្រើយដ៏ប្រសើរ គឺព្រះនិព្វាន ដោយសារការតាំងចិត្តជាកណ្តាលនេះឯង ។

## កម្រិតទី២ ឧបេក្ខាឧបបារមី

*ព្រះពោធិសត្វតែងតាំងចិត្តជាមធ្យមកណ្តាលជានិច្ច ចំពោះលោក-ធម៌ដែលកើតឡើងដល់សត្វលោកទាំងឡាយ ទោះបីអ្នកនោះមានឧបការគុណធំក្តី មានឧបការគុណតូចក្តី ទោះបីព្រះពោធិសត្វត្រូវលះបង់ ឬបូជា (បូជនីយកម្ម) នូវអវយវៈ អង្គតូច ឬអង្គធំរបស់ព្រះអង្គក្តី ក៏ព្រះពោធិសត្វលោកតាំងចិត្តក្នុងឧបេក្ខា ហើយព្រះអង្គកាត់ព្រះទ័យលែងជាប់ជំពាក់នឹងអដ្ឋលោកធម៌ (គឺធម៌ទាំង ៨ ប្រការក្នុងលោក) ។ កិរិយាដែលព្រះពោធិសត្វប្រព្រឹត្តនេះ គឺជាការសាង* ***ឧបេក្ខាឧបបារមី*** *ដែលជាគុណជាតិសម្រាប់ដឹកនាំសត្វលោកឆ្ពោះទៅកាន់ត្រើយដ៏ប្រសើរ គឺព្រះនិព្វាន ។*

## កម្រិតទី៣ ឧបេក្ខាបរមត្ថបារមី

*ព្រះពោធិសត្វតែងតម្កល់សន្តានចិត្តឋិតថេរ ជាកណ្តាលជានិច្ច ចំពោះសត្វលោក និងសង្ខារទាំងឡាយ ទោះបីសត្វទាំងនោះមានឧបការគុណស្រាលក្តី ធ្ងន់ក្តី អាចប៉ះពាល់ដល់ជីវិតរបស់ព្រះអង្គក្តី ព្រះអង្គនៅតែរក្សាព្រះទ័យរបស់ព្រះអង្គដដែល ដោយពុំមានការរំភើបញាប់ញ័រដ៏តិចតួចឡើយ ។ កិរិយាដែលព្រះពោធិសត្វប្រព្រឹត្តបែបនេះ គឺជាការសាង* ***ឧបេក្ខាបរមត្ថបារមី*** *ដែលជា*

*គុណជាតិសម្រាប់ដឹកនាំសត្វលោកឆ្ពោះទៅកាន់ត្រើយដ៏ប្រសើរ គឺព្រះនិព្វាន ។*

ក្នុងការសាងឧបេក្ខាបារមីនេះ គ្រប់ៗជាតិ ព្រះពោធិសត្វតែងតែធ្វើសច្ចាប្រណិធានរបៀបនេះថា :

*គ្រប់អនាគតជាតិតទៅ អាត្មាអញសូមប្រាថ្នាជាអ្នកមានសភាវៈនឹងធឹង ស្ងប់ស្ងៀម និងប្រកបដោយសន្តិភាព អាត្មាអញសូមឱ្យមានតុល្យភាពក្នុងចិត្តជានិច្ច អាត្មាអញសូមឱ្យប្រកបនូវឧបេក្ខាដ៏បរិសុទ្ធបំផុត អាត្មាអញសូមប្រាថ្នាឱ្យបានបម្រើសត្វលោកដោយចិត្តបរិសុទ្ធ ហើយសូមឱ្យមានចិត្តបរិសុទ្ធដើម្បីបម្រើសត្វលោក ។*

**(*សូមអាននារទជាតក ដើម្បីបង្ហាញពីការសាងឧបេក្ខាបារមី*)**

## លក្ខណាទិចតុក្កៈនៃទសបារមី

*សភាវធម៌ដែលមានពិត ដោយបរមត្ថធម៌ ឬសាមញ្ញលក្ខណៈនៃធម៌ទាំងនោះ ឈ្មោះថា* **លក្ខណៈ** *។ ពាក្យថា* **រស** មាន ២ គឺ **កិច្ចរស** និង **សម្បត្តិរស** *។ ផល ឬអាការៈប្រាកដ ឈ្មោះថា* **បច្ចុប្បដ្ឋាន** *។ ហេតុជិតនាំឱ្យធម៌នោះកើត ឈ្មោះថា* **បទដ្ឋាន** *។ កន្លែងខ្លះពោលថា ហេតុជិតនៃផល ឈ្មោះថា* **បទដ្ឋាន** *។*

*លក្ខណាទិចតុក្កៈនៃទសបារមី គឺក្នុងបារមីនីមួយៗ ដែលព្រះពោធិសត្វប្រារព្ធ ត្រូវប្រកបដោយលក្ខណៈ ៤ ចំណុចដូចខាងក្រោម :*

### ១. លក្ខណាទិចតុក្កៈនៃទានបារមី

***១-បរិច្ចាគលក្ខណា*** មានការបរិច្ចាគជាលក្ខណៈ ដើម្បីកម្ចាត់នូវតណ្ហា គឺការស្រេកឃ្លាន ។

***២-ទេយ្យធម្មេ លោភវិទ្ធំសនរសា*** មានការកម្ចាត់លោភៈ ក្នុងទេយ្យធម៌ជាកិច្ច គឺឱ្យទានដើម្បីអប់រំចិត្ត កុំឱ្យលោភលន់ចង់បានទ្រព្យអ្នកដទៃ ។

***៣-អនាសត្តិបច្ចុប្បដ្ឋានា*** មានកម្លាំងអាចជាផល ឬដល់ព្រមដោយភព និងការចម្រើនផល គឺអប់រំកុំឱ្យជាប់ជំពាក់នឹងទេយ្យវត្ថុដែលផ្តល់ជាទាន ។

*៤-បរិច្ចជិតព្វវត្ថុបទដ្ឋានា* មានវត្ថុដ៏សមគួរ សម្រាប់ធ្វើជាទានជាហេតុជិត ។

## ២. លក្ខណាទិចតុក្កៈនៃសីលបារមី

*១-សីលនលក្ខណា* មានការវៀរចាកទុច្ចរិត ដោយតម្កល់ចិត្តយ៉ាងមុតមាំក្នុងការរក្សាសីល ជាលក្ខណៈ ។

*២-ទុសីល្យវិទ្ធំសនរសា* កម្ចាត់នូវភាពទ្រុស្តសីល គឺការមិនប្រព្រឹត្តនូវអកុសលកម្ម និងទម្លាប់អាក្រក់ ជាកិច្ច ។

*៣-សោចេយ្យបច្ចុប្បដ្ឋានា* មានសេចក្តីស្អាតទាំងកាយ វាចា ចិត្ត គឺអប់រំចរិតលក្ខណៈ ក្នុងសការៈស្អាតស្អំ ជាផល ។

*៤-ហិរោត្តប្បបទដ្ឋានា* មានការខ្មាសបាប និងខ្លាចបាប ជាហេតុជិត ដោយប្រព្រឹត្តតែកុសលកម្ម ។

## ៣. លក្ខណាទិចតុក្កៈនៃនេក្ខម្មបារមី

*១-កាមតោ ច ភវតោ ច និក្ខម្មលក្ខណា* មានការចេញចាកកាម ជាលក្ខណៈ គឺសេចក្តីត្រេកត្រអាលក្នុងលោក (មានសំឡេង ក្លិន រស ផោដ្ឋព្វៈ និងទ្រព្យសម្បត្តិ បុណ្យសក្តិ កិត្តិយស) ដើម្បីបានរួចផុតពីវដ្តសង្សារ ។

***២-តទាទីនវវិភាវនរសា*** មានការប្រកាសកាមជាទោស គឺចាត់ទុកកាមារម្មណ៍ជាទោស ជាកិច្ច ។

***៣-តតោ ឯវ វិមុខភាវប្បច្ចុបដ្ឋានា*** មានការបែរក្រោយចាកទោសនោះឯង ជាផល គឺគេចចេញពីទោសនៃកាមនោះ ជាបច្ចុប្បដ្ឋាន ។

***៤-សំវេគប្បទដ្ឋានា*** មានសេចក្តីតក់ស្លុត និងសង្វេគដោយការយល់ដឹងតាមការភាវនា ជាហេតុជិត ។

## ៤. លក្ខណាទិចតុក្កៈនៃបញ្ញាបារមី

***១-យថាសភាវបដិវេធលក្ខណា*** មានការចាក់ធ្លុះតាមសភាវៈជាលក្ខណៈ ឬឃើញច្បាស់ប្រាកដជាលក្ខណៈ គឺការដឹងច្បាស់នូវសភាវធម៌ជាលក្ខណៈ ។

***២-វិសយោភាសនរសា បទីបេ វិយ*** មានការភ្លឺច្បាស់ក្នុងអារម្មណ៍ជាកិច្ច ។

***៣-អសម្មោហបច្ចុប្បដ្ឋានា*** មានការមិនវង្វេង ជាផល គឺអស់នូវសេចក្តីវង្វេង ឬមន្ទិលដោយបញ្ញា ។

***៤-សមាធិបទដ្ឋានា, ចតុសច្ចបទដ្ឋានា វា*** មានសមាធិ គឺការតម្កល់ចិត្តត្រូវ មានអរិយសច្ចធម៌ ៤ ជាហេតុជិត ។

## ៥. លក្ខណាទិចតុក្កៈនៃវីរិយបារមី

***១-ឧស្សាហលក្ខណា*** មានសេចក្តីព្យាយាមក្នុងការបំពេញកុសល ជាលក្ខណៈ ។

***២-ឧបត្ថម្ភនរសា*** មានការឧបត្ថម្ភដោយសហជាតធម៌ ជាកិច្ច ឬគុណធម៌ដទៃទៀត ជាកិច្ច ។

***៣-អសំសីទនបច្ចុប្បដ្ឋានា*** មានការមិនធ្លាក់ចុះក្នុងអកុសលធម៌ជាបច្ចុប្បដ្ឋាន ជាផល ។

***៤-វិរិយារម្ភវត្ថុបទដ្ឋានា, សំវេគបទដ្ឋានា វា*** មានវិរិយារម្ភវត្ថុ ឬមានសេចក្តីស្លុតជាហេតុជិត គឺសេចក្តីព្យាយាម និងសង្វេគតាមជំនឿជាហេតុជិត ។

## ៦. លក្ខណាទិចតុក្កៈនៃខន្តិបារមី

***១-ខមនលក្ខណា*** មានសេចក្តីអត់ធន់ ជាលក្ខណៈ ។

***២-ឥដ្ឋានិដ្ឋសហនរសា*** មានការអត់ធន់ក្នុងសភាវៈ ចំពោះរបស់ល្អ និងមិនល្អ ជាកិច្ច ។

***៣-អធិវាសនបច្ចុប្បដ្ឋានា, អវិរោធបច្ចុប្បដ្ឋានា វា*** វៀរចាកពីទំនាស់ និងអត់ធន់ចំពោះសេចក្តីក្រោធរបស់អ្នកដទៃ ជាផល ។

***៤-យថាភូតទស្សនបទដ្ឋានា*** *យល់ដឹងអំពីវត្ថុទាំងឡាយក្នុងសភាវធម៌ពិត ជាហេតុជិត ។*

## ៧. លក្ខណាទិចតុក្កៈនៃសច្ចបារមី

***១-អវិសំវាទនលក្ខណា*** *មិនបំភាន់អ្នកដទៃឱ្យយល់ច្រឡំ ដោយឃ្លាតចាកពីសច្ចធម៌ ជាលក្ខណៈ ។*

***២-យថាសភាវវិភាវនរសា*** *បង្ហាញនូវសភាវៈនៃអ្វីៗទាំងឡាយតាមការពិត ជាកិច្ច ។*

***៣-សាទុតាបច្ចុប្បដ្ឋានា*** *មានភាពរីករាយ និងសម្ដីពីរោះ ជាផល ។*

***៤-សោរច្ចបទដ្ឋានា*** *ជៀសវាងនូវអំពើខុសឆ្គងពីសច្ចធម៌ ជាហេតុជិត ។*

## ៨. លក្ខណាទិចតុក្កៈនៃអធិដ្ឋានបារមី

***១-ពោធិសម្ភារេសុ អធិដ្ឋានលក្ខណា*** *មានការតាំងមាំក្នុងការសម្រេចពោធិ (គឺការត្រាស់ដឹង) ជាលក្ខណៈចាំបាច់ ។*

***២-តេសំ បដិបក្ខាភិភវនរសា*** *មានការគ្របសង្កត់លើឧបសគ្គ ដើម្បីបំពេញការតាំងមាំនោះ ជាកិច្ច ។*

***៣-តត្ថ អចលតាបច្ចុប្បដ្ឋានា*** *មានការមិនកម្រើកញាប់ញ័រ ចំពោះឧបសគ្គនោះ ជាផល ។*

***៤-ពោធិសម្ភារបទដ្ឋានា*** *មានពោធិសម្ភារ (ជាគ្រឿងត្រាស់ដឹង) ជាហេតុជិត ។*

## ៩. លក្ខណាទិចតុក្កៈនៃមេត្តាបារមី

***១-ហិតាការប្បវត្តិលក្ខណា*** *មានសភាពប្រព្រឹត្តទៅក្នុងការចង់ជួយអ្នកដទៃ ជាលក្ខណៈ ។*

***២-ហិតូបសំហាររសា, អាឃាតវិនយរសា វា*** *ប្រកបដោយសភាវៈសប្បុរស និងកម្ចាត់បង់នូវសេចក្ដីស្អប់ខ្ពើម ជាកិច្ច ។*

***៣-សមភាវបច្ចុប្បដ្ឋានា*** *មានសេចក្ដីស្ងប់ ឬសភាវៈត្រជាក់ ក្នុងការប្រាស្រ័យទាក់ទងជាមួយនឹងអ្នកដទៃ ជាផល ។*

***៤-សត្តានំ មនាបភាវទស្សនបទដ្ឋានា*** *មានសេចក្ដីរីករាយចំពោះសត្វលោក ជាហេតុជិត ។*

## ១០. លក្ខណាទិចតុក្កៈនៃឧបេក្ខាបារមី

***១-មជ្ឈត្តាការប្បវត្តិលក្ខណា*** *មានការប៉ិនប្រសប់ក្នុងការរក្សាអាការៈជាកណ្ដាល ជាលក្ខណៈ ។*

***២-សមភាវទស្សនរសា*** *ក្នុងការរក្សាឬទទួលភាពជាកណ្ដាល ចំពោះវត្ថុដែលពេញចិត្តឬមិនពេញចិត្ត ជាកិច្ច ។*

**៣-បដិឃានុនយរូបសមបច្ចុប្បដ្ឋានា** មានការស្ងប់សេចក្តីក្រោធ ដែលជាប់ជំពាក់នឹងសេចក្តីត្រេកអរ ជាផល ។

**៤-កម្មស្សកតាបច្ចវេក្ខណាបទដ្ឋានា** មានការពិចារណាលើកម្មផល របស់សត្វលោក ជាហេតុជិត ។

(ចប់លក្ខណាទិចតុក្កៈ)

# កំណត់ហេតុអ្នកនិពន្ធ
# ក្នុងការសាងបារមី

ការសាងបារមីទាំង ១០ នេះ បានចប់បរិបូរហើយ នឹងញ៉ាំងអង្គព្រះសម្មាសម្ពុទ្ធឱ្យទទួលនូវគុណធម៌ដ៏មហាវិសេសវិសាលខ្ពស់បំផុតលើលោក គឺការត្រាស់ដឹងជាព្រះសព្វញ្ញុពុទ្ធ កម្ចាត់បង់នូវអវិជ្ជាគ្រប់បែបយ៉ាង ។ ពេលនោះ ព្រះអង្គទ្រង់ប្រកបដោយទិព្វញ្ញាណ ១០ គឺ **ទសពលញ្ញាណ** ។ តើទសពលញ្ញាណទាំង ១០ មានអ្វីខ្លះ? ទសពលញ្ញាណនៃព្រះសម្មាសម្ពុទ្ធមានដូចតទៅ :

១- ព្រះសម្មាសម្ពុទ្ធ ទ្រង់ជ្រាបច្បាស់នូវហេតុតាមហេតុផង ទ្រង់ជ្រាបច្បាស់នូវអំពើមិនមែនជាហេតុ តាមអំពើមិនមែនជាហេតុផង គឺព្រះអង្គទ្រង់ជ្រាបនូវអ្វីដែលត្រូវ អ្វីដែលខុសតាមសេចក្ដីពិត ។

២- ព្រះសម្មាសម្ពុទ្ធទ្រង់ជ្រាបច្បាស់នូវវិបាកនៃកុសលកម្ម និងអកុសលកម្ម ដែលសត្វលោកបានធ្វើហើយទាំងអតីត អនាគត និងបច្ចុប្បន្ន តាមបច្ច័យ តាមហេតុ តាមសេចក្ដីពិត ។

៣- ព្រះសម្មាសម្ពុទ្ធទ្រង់ជ្រាបច្បាស់នូវបដិបទា ជាដំណើរទៅកាន់សុគតិនិងទុគ្គតិក្នុងទីទាំងពួង (នៃសត្វលោក) តាមសេចក្ដីពិត ។

៤- ព្រះសម្មាសម្ពុទ្ធទ្រង់ជ្រាបច្បាស់នូវលោក (**បានដល់ខន្ធ ធាតុ អាយតនៈ**) ដែលមានធាតុ (**បានដល់ចក្ខុធាតុ ឬកាមធាតុជាដើម**) ច្រើនយ៉ាង មានធាតុ (**បានដល់លក្ខណៈផ្សេងៗរបស់ធាតុទាំងនោះ**) ផ្សេងៗគ្នា តាមសេចក្ដីពិត ។

៥- ព្រះសម្មាសម្ពុទ្ធទ្រង់ជ្រាបច្បាស់នូវអធ្យាស្រ័យផ្សេងៗគ្នា របស់សត្វទាំងឡាយតាមសេចក្ដីពិត ។

៦- ព្រះសម្មាសម្ពុទ្ធទ្រង់ជ្រាបច្បាស់នូវឥន្ទ្រិយក្លៀវក្លា និងទន់ខ្សោយរបស់ពួកសត្វដទៃ ពួកបុគ្គលដទៃ តាមសេចក្ដីពិត ។

៧- ព្រះសម្មាសម្ពុទ្ធទ្រង់ជ្រាបច្បាស់នូវសេចក្ដីសៅហ្មង សេចក្ដីផូរផង់ និងការចេញចាកឈាន វិមោក្ខ សមាធិ និងសមាបត្តិ តាមសេចក្ដីពិត ។

៨- ព្រះសម្មាសម្ពុទ្ធរលឹកឃើញជាតិដែលនៅអាស្រ័យក្នុងអតីតកាលកន្លងមកជាអនេកជាតិ គឺរលឹក ១ ជាតិ ២ ជាតិ ៣ ជាតិ ៤ ជាតិ ៥ ជាតិ ១០ ជាតិ ២០ ជាតិ ៣០ ជាតិ ៤០ ជាតិ ៥០ ជាតិ ១០០ ជាតិ ១.០០០ ជាតិ ១ សែនជាតិក៏បាន ច្រើនសំវដ្តកប្ប ច្រើនវិវដ្ត-កប្ប ច្រើនសំវិវដ្តកប្បក៏បាន ថាក្នុងភពឯនោះ អាត្មាអញមាន

ឈ្មោះយ៉ាងនេះ មានគោត្រយ៉ាងនេះ មានសម្បុរយ៉ាងនេះ មានអាហារយ៉ាងនេះ បានទទួលសុខទុក្ខយ៉ាងនេះ មានកំណត់អាយុត្រឹមប៉ុណ្ណោះ អាត្មាអញលុះច្យុតចាកអត្តភាពនោះហើយ បានទៅកើតក្នុងភពឯណោះ ហើយទៅកើតក្នុងភពឯណោះទៀត អាត្មាអញក៏មានឈ្មោះយ៉ាងនេះ មានគោត្រយ៉ាងនេះ មានសម្បុរយ៉ាងនេះ មានអាហារយ៉ាងនេះ បានទទួលសុខទុក្ខយ៉ាងនេះ មានកំណត់អាយុត្រឹមប៉ុណ្ណោះ លុះអាត្មាអញច្យុតចាកអត្តភាពនោះហើយ ទើបបានមកកើតក្នុងភពនេះឯង ។

៩- ព្រះសម្មាសម្ពុទ្ធមានចក្ខុជាទិព្វ បរិសុទ្ធកន្លងហួសចក្ខុរបស់មនុស្សធម្មតា ព្រះអង្គតែងឃើញនូវសត្វទាំងឡាយ ដែលច្យុត ដែលកើតជាសត្វទាបថោកខ្លះ ខ្ពង់ខ្ពស់ខ្លះ មានសម្បុរល្អខ្លះ មានសម្បុរអាក្រក់ខ្លះ មានគតិល្អខ្លះ មានគតិអាក្រក់ខ្លះ ព្រះអង្គជ្រាបច្បាស់នូវសត្វទាំងឡាយដែលអន្ទោលទៅតាមកម្ម (របស់ខ្លួន) ថាអើហ្ន! សត្វទាំងអម្បាលនេះ ។ល។ រមែងជ្រាបច្បាស់ (យ៉ាងនេះ) ។

១០- ព្រះសម្មាសម្ពុទ្ធទ្រង់ជ្រាបច្បាស់នូវចេតោវិមុត្តិ នូវបញ្ញាវិមុត្តិ មិនមានអាសវៈ ព្រោះអស់ទៅនៃអាសវៈទាំងឡាយ ដោយប្រាជ្ញារបស់

ខ្លួនក្នុងបច្ចុប្បន្នហើយ សម្រេចសម្រាន្តនៅដោយឥរិយាបថ ៤ ។ នេះឯងគឺទសពលញ្ញាណទាំង ១០ ដែលព្រះពុទ្ធសម្រេចបាន ។

ជាមួយគ្នានេះដែរ ព្រះសម្មាសម្ពុទ្ធទ្រង់សម្រេចនូវ **ទសកាយពល** (***កម្លាំងកាយ ១០***) ដែលអាចប្រៀបធៀបជាមួយនឹងកម្លាំងដំរី ១០ ត្រកូល (ពូជ) ដូចខាងក្រោម :

១- កម្លាំងដំរីត្រកូលកាឡាវកដំរីប្រក្រតី ១០ ស្មើនឹងកម្លាំងដំរីត្រកូលគង្គេយ្យ ១

២- កម្លាំងគង្គេយ្យ ១០ ស្មើនឹងកម្លាំងដំរីត្រកូលបណ្ឌរ ១

៣- កម្លាំងបណ្ឌរ ១០ ស្មើនឹងកម្លាំងដំរីត្រកូលតម្ព ១

៤- កម្លាំងតម្ព ១០ ស្មើនឹងកម្លាំងដំរីត្រកូលបិង្គល ១

៥- កម្លាំងបិង្គល ១០ ស្មើនឹងកម្លាំងដំរីត្រកូលគន្ធ ១

៦- កម្លាំងគន្ធ ១០ ស្មើនឹងកម្លាំងដំរីត្រកូលមង្គល ១

៧- កម្លាំងមង្គល ១០ ស្មើនឹងកម្លាំងដំរីត្រកូលហេមវត ១

៨- កម្លាំងហេមវត ១០ ស្មើនឹងកម្លាំងដំរីត្រកូលឧបោសថ ១

៩- កម្លាំងឧបោសថ ១០ ស្មើនឹងកម្លាំងដំរីត្រកូលឆទ្ទន្ត ១

១០-កម្លាំងដំរីឆទ្ទន្ត ១០ ស្មើនឹងកម្លាំងកាយព្រះពុទ្ធ ១ អង្គ ។

ដោយទំនងនេះ កម្លាំងកាយព្រះសម្មាសម្ពុទ្ធ ១ ព្រះអង្គ ស្មើនឹងកម្លាំងដំរីប្រក្រតី ១ ពាន់កោដិ ឬស្មើនឹងកម្លាំងបុរស ១០ ពាន់កោដិ ។

ខាងលើនេះ ជាទសពលញ្ញាណ និងទសកាយពលរបស់ព្រះពុទ្ធដែលបានត្រាស់ដឹងរួចហើយ ។ ចំពោះព្រះពោធិសត្វ ដែលពុំទាន់ត្រាស់ដឹង គឺក្នុងសភាវៈជានិយតពោធិសត្វ ដូចជាព្រះវេស្សន្តរ ព្រះតេមិយៈ ព្រះមហាជនក ។ល។ ក៏ព្រះអង្គទ្រង់សម្រេចបាននូវញាណ និងឫទ្ធិដ៏ខ្លាំងក្លាជាពន់ពេក ។

ខ្ញុំសូមលើកតែ **វសិតា ១០** ដែលព្រះមហាភិក្ខុវសុពន្ធុ[៤០] អធិប្បាយថា ព្រះពោធិសត្វដែលចម្រើនខាងផ្លូវចិត្តបានខ្ពស់ហើយ ទ្រង់អាចសម្តែងឫទ្ធិឱ្យឃើញបាន ចំពោះអ្នកដែលមានសេចក្តីជឿងធ្ងល់ទាំងពួង ពីព្រោះព្រះអង្គបានសម្រេចនូវវសិតា ១០ យ៉ាង[៤១] ។ ឫទ្ធិ ១០ យ៉ាងនេះ មានចែងក្នុងគម្ពីរឈ្មោះទសភូមិកសូត្រ, មហាវ្យុត្តប្បត្តិ, និងធម្មសង្គហៈ[៤២] ។

[៤០] វសុពន្ធុនេះ ជាព្រះភិក្ខុមហាយានដ៏ល្បីមួយអង្គក្នុងប្រទេសឥណ្ឌានាសម័យបុរាណកាល ហើយលោកមានជីវិតរស់នៅក្នុងសម័យកាលសាកលវិទ្យាល័យនាលន្ទា ។

[៤១] ស្រង់ពី "The Bodhisattva Doctrine in Buddhist Sanskrit Literature" ទំព័រ ១៤០-១៤១ ខាងផ្នែកមហាយាន ។ វសិតា មានន័យថា ឫទ្ធិ អំណាច អានុភាព ឬ អធិបតេយ្យ ។

[៤២] គម្ពីរទាំង ៣ នេះ ជាច្បាប់មហាយាន មិនមែនជាថេរវាទទេ ។

យោងទៅតាមគម្ពីរទសភូមិកសូត្រ នៅពេលដែលព្រះពោធិសត្វលោកបានឈានដល់ភូមិទី៨ គឺ ជនមានិទេស (ការចាប់កំណើតដែលលែងធ្លាក់ចុះ) ព្រះអង្គបានសម្រេចនូវឫទ្ធិ ១០ មានដូចខាងក្រោម :

**១-អាយុវសិតា** (ឫទ្ធិអាយុវែង) ព្រះពោធិសត្វមានអធិបតេយ្យទៅលើក្រសែនៃជីវិត បានសេចក្ដីថា ព្រះអង្គអាចបន្តជីវិតរបស់ព្រះអង្គ ឱ្យរស់វែងឆ្ងាយលើសអាយុកប្ប ហួសពីការគណនាក៏បាន ។

**២-ចេតោវសិតា** ព្រះអង្គមានអធិបតេយ្យទៅលើចិត្ត ព្រោះព្រះអង្គបានសម្រេចនូវវិជ្ជាគ្មានព្រំដែន ពោលគឺសមាធិគ្រប់ប្រភេទ ។

**៣-បរិក្ខារវសិតា** ព្រះអង្គទ្រង់មានជំនាញខាងការផ្គត់ផ្គង់ ព្រោះព្រះអង្គទ្រង់ជ្រាបសព្វកិច្ចការដែលត្រូវរៀបចំ និងសម្ពិតសម្ពាងផ្នែកខាងផ្លូវលោក និងចក្រវាល ។

**៤-កម្មវសិតា** ព្រះអង្គមានអធិបតេយ្យទៅលើទង្វើ ព្រោះព្រះអង្គយល់ច្បាស់ថា ផលទាំងឡាយសុទ្ធតែកើតចេញពីទង្វើ ក្នុងពេលដ៏សមគួរ ។

**៥-ឧប្បត្តិវសិតា** ព្រះអង្គមានចំណេះស្ទាត់ខាងកំណើត ព្រោះព្រះអង្គឈ្វេងយល់ពីដើមកំណើតនៃពិភពលោក និងចក្រវាល ។

**៦-អធិមុត្តិវសិតា** ព្រះអង្គមានអធិបតេយ្យទៅលើជំនឿ ឬទៅលើការតាំងប្រាថ្នា ព្រោះព្រះអង្គឃើញដោយប្រពៃ នូវព្រះសម្មាសម្ពុទ្ធគ្រប់ព្រះអង្គលើពិភពលោក និងចក្រវាល ។

**៧-បណិធានវសិតា** ព្រះអង្គមានអំណាចទៅលើរាល់ការតាំងសត្យាធិដ្ឋាន ព្រោះព្រះអង្គឃើញដោយប្រពៃ នូវសម័យដែលនឹងត្រូវត្រាស់ដឹងជាព្រះសម្មាសម្ពុទ្ធ ក្នុងកំឡុងព្រះពុទ្ធអង្គណាមួយ ដែលជាការសមតាមការតាំងប្រាថ្នារបស់ព្រះអង្គ ។

**៨-ឥទ្ធិវសិតា** ព្រះអង្គជាអ្នកកំពូលខាងឫទ្ធិ សម្រាប់សម្ដែងឱ្យអ្នកធ្ងល់អស់ចម្ងល់ ព្រោះព្រះអង្គឃើញដោយប្រពៃ នូវរាល់ការធ្វើបាដិហារ្យរបស់ព្រះសម្មាសម្ពុទ្ធទាំងឡាយ ។

**៩-ធម្មវសិតា** ព្រះអង្គមានអានុភាពទៅលើធម្មទេសនា ព្រោះព្រះអង្គសម្ដែងធម៌មានលម្អ និងពីរោះ ទាំងបទដើម ទាំងបទកណ្ដាល និងបទចុង ។

**១០-ញាណវសិតា** ព្រះអង្គទ្រង់យល់យ៉ាងល្អិតល្អន់នូវគុណសម្បត្តិរបស់ព្រះពុទ្ធ ទាំងឫទ្ធិ ហេតុជាទីតាំងជំនឿ ទាំងលក្ខណៈពិសេស ដែល

មានចំពោះតែអង្គ និងសញ្ញាសម្គាល់ធំតូចលើកាយព្រះអង្គ ។ ដូច្នេះ ព្រះអង្គជាម្ចាស់លើវិជ្ជា ៕

# ជំពូកទី ៦

# ព្រះពោធិសត្វក្នុងអត្តភាពជាព្រះសម្មាសម្ពុទ្ធសមណគោតម

## (សង្ខេប)

***ព្រះពោធិសត្វ*** *លោកបំពេញបារមី ដែលជាពុទ្ធការកធម៌ រហូតមកដល់អតត្តាពជា* ***ព្រះវេស្សន្តរ*** *បានបំពេញទានដ៏ប្រសើរ ហើយបានច្យុត រួចក៏យាងទៅចាប់បដិសន្ធិក្នុងស្ថានតុសិត មានឈ្មោះថា* ***សន្តុសិតទេវបុត្រ*** *។ ក្រោយមក ទេវតាទាំងឡាយមួយសែនចក្រវាលបានដឹងថា* ***សន្តុសិតទេវបុត្រ*** *នឹងត្រាស់ជាព្រះពុទ្ធមួយអង្គក្នុងលោក ទើបនាំគ្នាចូលទៅអារាធនាព្រះពោធិសត្វ ឱ្យចុះចាប់បដិសន្ធិក្នុងមនុស្សលោក ។ ព្រះពោធិសត្វមិនទាន់ទទួលពាក្យប្តេជ្ញារបស់ទេវតាភ្លាមនោះទេ ព្រះអង្គសម្ទឹងមើលមហាវិលោកនៈទាំង ៥ គឺ* ***កាល១ ទ្វីប១ ប្រទេស១ ត្រកូល១ ព្រះមាតា១*** *។*

***១-កាល*** *ធម្មតាព្រះពុទ្ធទាំងឡាយ ព្រះអង្គមិនត្រាស់ដឹងក្នុងកាលនៃមនុស្សមានអាយុលើសពីមួយសែនឆ្នាំ និងតិចជាងមួយរយឆ្នាំទេ ។ ព្រះពោធិសត្វតែងតែចុះមកត្រាស់ដឹងក្នុងលោក ក្នុងកាលមនុស្សមានអាយុចន្លោះពីមួយរយឆ្នាំ ទៅមួយសែនឆ្នាំ ។*

***២-ទ្វីប*** *ព្រះពុទ្ធទាំងឡាយ ទ្រង់ត្រាស់ដឹងក្នុងជម្ពូទ្វីបតែម៉្យាងប៉ុណ្ណោះ ។*

***៣-ប្រទេស*** *ព្រះពុទ្ធទាំងឡាយ ទ្រង់ត្រាស់ដឹងក្នុងមជ្ឈិមប្រទេសប៉ុណ្ណោះ ។*

***៤-ត្រកូល*** *ព្រះពុទ្ធទាំងឡាយ មិនបដិសន្ធិក្នុងត្រកូលវេស្សៈ និងសូទ្រៈឡើយ ។ លោកបដិសន្ធិតែក្នុងត្រកូលក្សត្រ និងត្រកូលព្រាហ្មណ៍ប៉ុណ្ណោះ ។*

***៥-ព្រះមាតា*** *ពុទ្ធមាតាមិនមែនជាអ្នកមានលក្ខណៈឡេះឡោះ មិនសេពសុរាជាដើម ជាអ្នកបានប្រតិបត្តិធម៌មួយសែនកប្បមកហើយ និងជាអ្នកមានសីល ៥ ស្អាតបរិសុទ្ធជានិច្ច ។*

*បន្ទាប់ពីព្រះពោធិសត្វប្រមើលមើលមហាវិលោកនៈទាំង ៥ ហើយ ទ្រង់ឃើញជម្ពូទ្វីបជាមណ្ឌលចក្រវាល ឃើញកបិលពស្តុនគរ ស្ថិតនៅក្នុងមជ្ឈិមប្រទេស ឃើញត្រកូលក្សត្រដ៏ល្អ ឃើញព្រះមាតាដ៏បវរ ក៏បង្អោនចិត្តមកបដិសន្ធិក្នុងមនុស្សលោក គឺក្នុងត្រកូលក្សត្រ ដែល**ព្រះបាទសុទ្ធោទនៈ** និង**ព្រះនាងសិរិមហាមាយា** ជាគោតមគោត្រ ។*

***ព្រះពោធិសត្វ ចុះចាប់បដិសន្ធិក្នុងផ្ទៃព្រះនាងសិរិមហាយា នៅថ្ងៃ ១៥ កើត ពេញបូណ៌មី ខែអាសាឍ មុនពុទ្ធសករាជ ៨០ ឆ្នាំ និង ១០ ខែ ។***

*ក្នុងខណៈព្រះពោធិសត្វចុះចាប់បដិសន្ធិនោះ លោកធាតុទាំង*

១០.០០០ ចក្រវាល បានកម្រើករំពើកញាប់ញ័រ មាន**និមិត្ត ៣២ ប្រការ** កើតឡើងប្រាកដក្នុងខណៈនោះគឺ

១- ពន្លឺរកប្រមាណមិនបាន គឺផ្សាយពេញ ១ សែនចក្រវាល

២- មនុស្សងងឹតភ្នែក មានពន្លឺមើលឃើញបាន

៣- មនុស្សថ្លង់ អាចស្តាប់ឮបាន

៤- មនុស្សគ អាចនិយាយបាន

៥- មនុស្សគម មានខ្លួនត្រង់

៦- មនុស្សខ្វិន អាចដើររួច

៧- សត្វជាប់ចំណង ក៏រួចផុតចំណង

៨- ភ្លើងក្នុងនរករលត់

៩- ពួកសត្វមិនមានសេចក្តីស្រេកឃ្លាន

១០-សត្វតិរច្ឆានមិនមានសេចក្តីខ្លាចគ្នា

១១- ជំងឺរបស់សត្វទាំងពួងជាសះស្បើយ

១២- សព្វសត្វទាំងអស់និយាយគ្នាដោយសេចក្តីស្រឡាញ់

១៣- សេះទាំងឡាយបញ្ចេញសម្រែកដ៏ពីរោះ

១៤- ដំរីទាំងឡាយបានបញ្ចេញសំឡេងស្រែកឡើង

១៥- តន្ត្រីគ្រប់ប្រភេទបានបញ្ចេញសំឡេងគឹកកងដោយខ្លួនឯង

១៦- កងដៃរបស់មនុស្សប៉ះទង្គិចគ្នាបញ្ចេញសំឡេងយ៉ាងពីរោះ

១៧- គ្រប់ទិសទាំងអស់មានសភាពច្បាស់ល្អ មិនស្រអាប់

១៨- ខ្យល់ដ៏ត្រជាក់បក់មកធ្វើឱ្យមានសេចក្តីសុខដល់សព្វសត្វ

១៩- ភ្លៀងមិនត្រូវកាល ក៏ធ្លាក់ចុះមក

២០- ទឹកផុសចេញអំពីផែនដី ហើយហូរ

២១- សត្វមិនមានហើរលើអាកាស

២២- ទឹកស្ទឹងឈប់នឹងថ្កល់មិនហូរ

២៣- ទឹកមហាសមុទ្រមានរសផ្អែម

២៤- ផ្កាបទុម ៥ ប្រភេទ ផុសរីកដេរដាសពេញទឹកគ្រប់កន្លែង

២៥- ផ្កាឈើគ្រប់ប្រភេទ ទាំងលើគោក ទាំងក្នុងទឹក ក៏រីកឡើង

២៦- ផ្កាបទុម ប្រភេទដើមក៏រីកតាមដើម

២៧- ផ្កាបទុម ប្រភេទមែកក៏រីកតាមមែក

២៨- ផ្កាបទុម ប្រភេទវល្លិក៏រីកតាមវល្លិ

២៩- ផ្កាបទុម ប្រភេទជាង៍ជ្រែកផ្ទៃសិលាចេញជាផ្កាមួយរយជាន់ៗ

៣០- ផ្កាបទុម ប្រភេទសំយុងចុះក៏កើតឡើង

៣១- ភ្លៀងផ្កាក៏ធ្លាក់ចុះពីលើអាកាស

៣២- តន្ត្រីដ៏ជាទិព្វ ក៏បញ្ចេញសូរសៀងសំឡេងយ៉ាងពីរោះ ។

សម័យនោះ ក្រុងកបិលពស្តុមានប្រារព្ធពិធីបុណ្យនក្ខត្តឫក្ស ក្នុងខែអាសាឍ យ៉ាងគគ្រឹកគគ្រេង ។ មហាជនទាំងឡាយមានចិត្តរីករាយ បាននាំគ្នាចូលរួមពិធីបុណ្យនក្ខត្តឫក្សនោះ ។ ចំណែកព្រះនាងមហាមាយាទេវី តាំងពីថ្ងៃទី៧ មុនថ្ងៃពេញបូណ៌មី ព្រះនាងក៏ចូលរួមបុណ្យដ៏នក្ខត្តឫក្សនោះ ជាមួយនឹងមហាជនដែរ ។ តែដល់ថ្ងៃពេញបូណ៌មី ព្រះនាងក៏ស្រង់ទឹកក្រអូប ទ្រង់លះបង់ព្រះរាជទ្រព្យចំនួន ៤០០.០០០ កហាបណៈ ធ្វើជាទាន ។ ព្រះនាងទ្រង់អធិដ្ឋានឧបោសថ ហើយយាងចូលទៅក្នុងក្រឡាព្រះបន្ទំ ផ្ទំលើព្រះសិរីសេយ្យាសនា ទ្រង់ក៏សុបិនឃើញហេតុដូចតទៅនេះ :

ស្តេចមហារាជទាំង ៤ បានមកលើកព្រះនាង ព្រមទាំងសេយ្យាសនា នាំទៅព្រៃហេមពាន្ត ហើយដាក់លើផ្ទៃមនោសិលាមានប្រមាណ ៦០ យោជន៍ ខាងក្រោមដើមសាលព្រឹក្សដ៏ធំមានទំហំ ៧ យោជន៍ ហើយបាននាំគ្នាឈរក្នុងទីដ៏សមគួរ ។ លំដាប់នោះឯង ព្រះទេវីរបស់ស្តេចមហារាជទាំង ៤ ក៏នាំ

ព្រះនាងចុះទៅកាន់អនោតត្តស្រះ ហើយបានស្រង់ទឹកថ្វាយព្រះនាង ដើម្បីជម្រះមន្ទិលរបស់មនុស្សចេញ បន្ទាប់មកក៏ថ្វាយសំពត់ទិព្វ និងយកគ្រឿងក្រអូបផ្សេងៗ មកលាបព្រះកាយ ហើយយកផ្កាឈើទិព្វមកថ្វាយព្រះនាងសម្រាប់ទ្រង់គ្រឿងផងដែរ ។ មិនឆ្ងាយអំពីទីនោះ មានកូនភ្នំប្រាក់មួយដ៏ស្អាត ដែលមានវិមានមាសដ៏ប្រណីតមួយស្ថិតក្នុងនោះ ។ ស្តេចមហារាជទាំង ៤ នាំព្រះនាងទៅកាន់ព្រះក្រឡាបន្ទំលើសេយ្យាសនាទិព្វ មានសីសៈបែរទៅទិសខាងកើត ក្នុងវិមានមាសនោះ ។ លំដាប់នោះឯង មានដំរីពណ៌សដ៏ប្រសើរ បានដើរចុះពីកូនភ្នំមាស ដែលមិនឆ្ងាយអំពីវិមាននោះ ហើយក៏ឡើងមកកាន់ភ្នំប្រាក់ នាទិសខាងជើង បានយកប្រមោយមានពណ៌ដូចជាប្រាក់ចាប់ផ្កាឈូកពណ៌ស បញ្ចេញសំឡេងកោញ្ចនាទ រួចចូលទៅកាន់វិមានមាសនោះ ហើយប្រទក្សិណជុំវិញសេយ្យាសនាព្រះនាងបីជុំ ហាក់បីដូចជាជ្រែកចូលតាមផ្ទៃពោះព្រះនាងខាងស្តាំក្នុងខណៈនោះឯង ។

លុះព្រឹកឡើង ព្រះនាងបានយកសុបិននោះ ទៅក្រាបទូលព្រះភស្តាឱ្យទ្រង់ជ្រាប ។ ព្រះបាទសុទ្ធោទនៈជាព្រះស្វាមី បានហៅពួកព្រាហ្មណ៍មកទស្សន៍ទាយនូវសុបិននិមិត្តនោះ ។ ពួកព្រាហ្មណ៍ហោរាទាំងឡាយក៏បានទស្សន៍ទាយថា "**ព្រះនាងនឹងមានបុត្រជាអ្នកមានបុណ្យដ៏អស្ចារ្យម្នាក់**" ។

***ព្រះពោធិសត្វ ចុះចាប់បដិសន្ធិក្នុងផ្ទៃព្រះនាងសិរិមហាមាយា នៅថ្ងៃព្រហស្បតិ៍ ១៥ កើត ពេញបូណ៌មី ខែអាសាឍ ឆ្នាំរកា ។***

*កាលព្រះពោធិសត្វចុះចាប់បដិសន្ធិនោះ ស្តេចមហារាជទាំង ៤ គឺ **ព្រះបាទធតរដ្ឋៈ វិរុឡ្ហកៈ វិរូបក្ខៈ កុវេរៈ** បានតាមថែរក្សាព្រះគភ៌ជានិច្ច ។*

## ធម្មនិយាមនៃព្រះពោធិសត្វ

*ព្រះពោធិសត្វចាប់បដិសន្ធិប្រកបដោយធម្មនិយាមដូចតទៅ :*

*១- ព្រះពោធិសត្វច្យុតចាកស្ថានតុសិត ទ្រង់មានសតិសម្បជញ្ញៈ នៅពេលចុះកាន់ផ្ទៃនៃព្រះមាតា ។ នេះជាធម្មតា (របស់ព្រះពោធិសត្វ) ក្នុងវេលាដែលចុះកាន់ផ្ទៃនៃព្រះមាតានុ៎ះ ។*

*២- ព្រះពោធិសត្វច្យុតចាកស្ថានតុសិត ចុះកាន់ផ្ទៃនៃព្រះមាតា, គ្រានោះ មានពន្លឺភ្លឺស្វាងច្បាស់រកប្រមាណមិនបានក្នុងមនុស្សលោក ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ក្នុងពពួកសត្វ និងសមណព្រាហ្មណ៍ ព្រមទាំងមនុស្សជាសម្មតិទេព ក៏កើតប្រាកដឡើងក្នុងលោក គ្របសង្កត់នូវពន្លឺនៃទេវតាទាំងឡាយ ។ នៅគ្រប់ច្រកល្ហក ចន្លោះភ្នំ ឬក្នុងរូងភ្នំដែលធ្លាប់មានអព្ទង់ងឹតពីមុនមក ពន្លឺព្រះអាទិត្យនិងព្រះចន្ទដែលមិនអាចបំភ្លឺ ក៏*

ទទួលពន្លឺដ៏ត្រចះត្រចង់ដោយអានុភាពរបស់ព្រះពោធិសត្វក្នុងពេលនោះ។ ពួកសត្វណា ដែលកើតឡើងក្នុងទីទាំងនោះ សត្វអម្បាលនោះ ក៏ស្គាល់គ្នានឹងគ្នាច្បាស់ដោយសារពន្លឺនោះថា "អើហ្នមានពួកសត្វឯទៀតកើតក្នុងទីនេះដែរ" ។

លោកធាតុទាំងមួយម៉ឺននេះ ក៏កក្រើករំពើកញាប់ញ័រ ទាំងពន្លឺដ៏ភ្លឺស្វាងច្បាស់រកប្រមាណមិនបាន ក៏កើតប្រាកដឡើងក្នុងលោក កន្លងទេវានុភាពនៃទេវតាទាំងឡាយ ។ នេះជាធម្មតា (របស់ព្រះពោធិសត្វ) ក្នុងវេលាដែលចុះកាន់ផ្ទៃនៃព្រះមាតានុ៎ះ ។

៣- ព្រះពោធិសត្វចុះកាន់ផ្ទៃព្រះមាតា មានទេវបុត្រ ៤ អង្គ តែងចូលទៅរក្សាក្នុងទិសទាំង ៤ ដោយគិតថា កុំឱ្យមនុស្ស និងអមនុស្សណានីមួយ បៀតបៀនព្រះពោធិសត្វ និងព្រះមាតានៃព្រះពោធិសត្វនោះឡើយ។ នេះជាធម្មតា ក្នុងវេលាដែលព្រះពោធិសត្វ ចុះកាន់ផ្ទៃនៃព្រះមាតានុ៎ះ ។

៤- ព្រះពោធិសត្វចុះកាន់ផ្ទៃនៃព្រះមាតា ព្រះមាតានៃព្រះអង្គ គឺជាអ្នកមានសីល ដោយប្រក្រតីជាអ្នកវៀរចាកបាណាតិបាត វៀរចាកអទិន្នាទាន វៀរចាកកាមេសុមិច្ឆាចារ វៀរចាកមុសាវាទ វៀរចាកសុរាមេរយមជ្ជប្បមាទដ្ឋាន ។ នេះជាធម្មតា ក្នុងវេលាដែលព្រះពោធិសត្វចុះកាន់ផ្ទៃនៃព្រះមាតានុ៎ះ ។

៥- ព្រះពោធិសត្វចុះកាន់ផ្ទៃព្រះមាតា ព្រះមាតានៃព្រះពោធិសត្វមិនមានចិត្តប្រកបដោយកាមគុណក្នុងបុរសទាំងឡាយទេ ហើយព្រះមាតានៃព្រះពោធិសត្វ ក៏មិនដែលមានបុរសណាមួយ មានចិត្តត្រេកអរប្រព្រឹត្តកន្លងឡើយ ។ នេះជាធម្មតា ក្នុងវេលាដែលព្រះពោធិសត្វ ចុះកាន់ផ្ទៃនៃព្រះមាតាន៊ុះ ។

៦- ព្រះពោធិសត្វចុះកាន់ផ្ទៃនៃព្រះមាតា ព្រះមាតានៃព្រះពោធិសត្វតែងបាននូវកាមគុណទាំង ៥ ជាប្រក្រតី ។ ព្រះមាតានៃព្រះពោធិសត្វនោះតែងស្កប់ស្កល់ប្រកបព្រម មានអ្នកផ្គាប់បម្រើដោយកាមគុណទាំង ៥ ។ នេះជាធម្មតា ក្នុងវេលាដែលព្រះពោធិសត្វ ចុះកាន់ផ្ទៃនៃព្រះមាតាន៊ុះ ។

៧- ព្រះពោធិសត្វចុះកាន់ផ្ទៃនៃព្រះមាតា អាពាធណាទីមួយ ក៏មិនបានកើតឡើងដល់ព្រះមាតានៃព្រះពោធិសត្វឡើយ ព្រះមាតានៃព្រះពោធិសត្វ មានតែសេចក្តីសុខជាប្រក្រតី មានកាយមិនលំបាក ។ ព្រះមាតានៃព្រះពោធិសត្វ តែងមើលឃើញព្រះពោធិសត្វ ហាក់ដូចជាឋិតនៅក្រៅផ្ទៃ សព្វអវយវៈទាំងឡាយ ប្រកបដោយឥន្ទ្រិយដ៏បរិបូរ ។

## ព្រះពោធិសត្វប្រសូត

ព្រះនាងមហាមាយាទេវីបានទ្រទ្រង់គភ៌ចំនួន ១០ ខែគត់ ហើយមានបំណងដើម្បីទៅប្រសូតបុត្រ នៅឯនគរខាងព្រះបិតាគឺ **នគរទេវទហៈ** ។ ព្រះនាងបានការអនុញ្ញាតពីព្រះភស្តា ក៏នាំបរិវារយ៉ាងច្រើនទៅជាមួយ ព្រមទាំងមានអាមាត្យចំនួន ១.០០០ នាក់ តាមការពារព្រះនាងផងដែរ ។ លុះព្រះនាងយាងដល់ព្រៃមង្គលសាលវ័ន ដែលមានឈ្មោះថា **ព្រៃលុម្ពិនី** ស្រាប់តែដើមសាលព្រឹក្ស (ដើមរាំង) ទាំងឡាយ ក៏រីកផ្កាឡើង តាំងពីគល់រហូតដល់ចុង ទាំងមែកក៏មានផ្កាគួរឱ្យគយគន់ ចម្រុះដោយផ្កាមានពណ៌ ៥ ប្រភេទ ។ ពួកភមរជាតិទាំងឡាយនាំគ្នាហើរមកក្រេបលម្អងផ្កា ដ៏មានក្លិនក្រអូបឈ្ងុយឈ្ងប់ ។ ពួកសកុណជាតិទាំងឡាយ ស្រែកបញ្ចេញសំឡេងសែនពីរោះគួរឱ្យចង់ស្តាប់ ។ ព្រះនាងគ្រាន់តែឃើញផ្កាដ៏ស្រស់ស្អាតនិងឮសំឡេងយ៉ាងពីរោះដូច្នោះ ក៏មានចិត្តរីករាយចង់ចុះពីគ្រែស្នែង ដើម្បីក្រសាលក្នុងព្រៃសាលព្រឹក្សនោះ ។ ពួកអាមាត្យក៏នាំព្រះនាងចូលទៅកាន់ព្រៃលុម្ពិនីនោះ ។ ព្រះនាងទ្រង់យាងចូលជិតគល់មង្គលសាលព្រឹក្សមួយដើម ហើយមានបំណងឈោងចាប់មែកសាលព្រឹក្ស ។ ស្រាប់តែមែកសាលព្រឹក្សនោះបង្អោនចុះមកជិតព្រះហស្តរបស់ព្រះនាង ធ្វើឱ្យព្រះនាងតោងចាប់បានយ៉ាងងាយ ។ គ្រាន់តែព្រះនាងចាប់ភ្លាម ខ្យល់កម្មជ្ជវាតក៏កម្រើកឡើង ។

ពេលនោះ ពួកបរិវារនាំគ្នាយករាំងនន មកបិទបាំងព្រះនាង ។ ព្រះនាងក៏ប្រសូតព្រះពោធិសត្វ ដោយទ្រង់ឈរ និងមានដៃកំពុងតោងមែកសាល-ព្រឹក្សនោះឯង ។ ព្រះពោធិសត្វប្រសូតចាកផ្ទៃមាតា ហាក់ដូចជាធម្មកថិកចុះពីធម្មាសនៈ ។ សត្វទាំងឡាយប្រសូតមក តែងប្រឡាក់ដោយគ្រឿងបដិកូលមិនស្អាត តែព្រះពោធិសត្វបានប្រសូតចាកផ្ទៃព្រះមាតាដ៏ល្អល្អះស្រស់បស់ មិនប្រឡាក់ដោយទឹក (ភ្លោះ) មិនប្រឡាក់ដោយស្លេស្ម ឈាម និងគ្រឿងអសោចណានីមួយឡើយ ជាអ្នកស្អាតល្អបរិសុទ្ធ ។

ខណៈនោះ មហាព្រហ្មមានចិត្តដ៏បរិសុទ្ធ ៤ រូប បានយកស្បៃមាសមកទទួលព្រះពោធិសត្វ ហើយលើកបង្ហាញចំពោះព្រះភក្ត្រព្រះនាងថា បពិត្រព្រះទេវី សូមព្រះនាងមានចិត្តរីករាយចុះ បុត្ររបស់ព្រះនាង ជាអ្នកមានសក្តិធំ ទ្រង់កើតឡើងហើយ ។ ស្តេចមហារាជទាំង ៤ បានទទួលព្រះពោធិសត្វអំពីព្រហ្ម ដោយគ្រឿងដណ្តប់ធ្វើពីស្បែកខ្លា ដែលមានសម្ផស្សដ៏ជាសុខ ដែលសន្មតថាជាមង្គល ។ មនុស្សបានទទួលពីស្តេចមហារាជដោយសំពត់ទុកូលពស្ត្រ ហើយក៏ដាក់ព្រះពោធិសត្វនៅលើផែនដី ។ ពេលនោះ ព្រះពោធិសត្វសម្លឹងមើលទិសទាំងអស់ រួចហើយមានព្រះភក្ត្រឆ្ពោះទៅកាន់ឧត្តរទិស (ទិសខាងជើង) យាងឈានដើរបាន ៧ ជំហាន ហើយស្រែកអាសភិវាចា គឺវាចាដ៏ឧត្តមដូច្នេះថា :

"អគ្គោហមស្មិ លោកស្ស ជេដ្ឋោហមស្មិ លោកស្ស សេដ្ឋោហមស្មិ លោកស្ស អយមន្តិមា ជាតិ នត្ថិទានិ បុនព្ភវោ" ។

ប្រែ : អាត្មាអញ ជាបុគ្គលខ្ពង់ខ្ពស់លើលោក អាត្មាអញជាបុគ្គលធំបំផុតលើលោក អាត្មាអញជាបុគ្គលប្រសើរបំផុតលើលោក នេះជាកំណើតចុងក្រោយបំផុតរបស់អាត្មាអញ អំណឹះតទៅ អាត្មាអញលែងមានភពថ្មីទៀតហើយ ។

ខណៈដែលព្រះពោធិសត្វប្រសូតចាកផ្ទៃនៃព្រះមាតា ស្រាប់តែមានពន្លឺភ្លឺស្វាងច្បាស់រកប្រមាណមិនបាន កើតប្រាកដឡើងក្នុងមនុស្សលោក ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ក្នុងពពួកសត្វ និងសមណ-ព្រាហ្មណ៍ ទាំងមនុស្សជាសម្មតិទេពនិងមនុស្សដ៏សេស កន្លងនូវទេវានុភាពនៃទេវតាទាំងឡាយ ។ នៅគ្រប់ច្រកល្ហក ចន្លោះភ្នំ ឬក្នុងរូងភ្នំដែលធ្លាប់មានអព្ធងងឹតពីមុនមក ដែលពន្លឺព្រះអាទិត្យ និងព្រះចន្ទមិនអាចបំភ្លឺបាន ក៏ទទួលពន្លឺដ៏ត្រចះត្រចង់នៃអានុភាពរបស់ព្រះពោធិសត្វក្នុងពេលនេះ ។ ពួកសត្វណាដែលកើតក្នុងទីទាំងឡាយ សត្វទាំងអម្បាលនោះ ក៏ស្គាល់ច្បាស់នូវគ្នានឹងគ្នា ដោយសារពន្លឺនោះថា "អើហ្ន មានពួកសត្វឯទៀតកើតក្នុងទីនេះដែរ" ។ លោកធាតុទាំងមួយម៉ឺននេះ ក៏កក្រើករំពើកញាប់ញ័រ ទាំង

ពន្លឺដ៏ភ្លឺស្វាងច្បាស់រកប្រមាណមិនបាន ក៏កើតប្រាកដឡើងក្នុងលោក ដោយកន្លងទេវានុភាពនៃទេវតាទាំងឡាយ ។ នេះជាធម្មតា ក្នុងវេលាដែលព្រះពោធិសត្វទ្រង់ប្រសូតចាកផ្ទៃនៃព្រះមាតានុ៎ះ ។

**ព្រះពោធិសត្វប្រសូត ក្នុងថ្ងៃ សុក្រ ១៥ កើត ពេញបូណ៌មី ខែពិសាខ ឆ្នាំ ច មុនពុទ្ធសករាជ ៨០ ឆ្នាំ ។**

កាលនោះ ពួកអាមាត្យ និងបរិពារទាំងឡាយ ក៏បានយាងព្រះនាង និងព្រះរាជឱរស ត្រឡប់ចូលទៅកាន់ក្រុងកបិលពស្តុវិញ ។

ក្នុងថ្ងៃព្រះពោធិសត្វប្រសូតនោះ មានសហជាត ៧ កើតរួមដែរគឺ **រាហុលមាតា១ អានន្ទ១ ឆន្នអាមាត្យ១ កាឡុទាយីអាមាត្យ១ សេះកណ្ឋកៈ១ ព្រះពោធិព្រឹក្ស១ កំណប់ទ្រព្យ ៤ យ៉ាង១ ។**

ក្នុងថ្ងៃព្រះពោធិសត្វប្រសូត ពួកទេវតាទាំងឡាយ មានចិត្តរីករាយ បានស្រែកសំឡេងខ្ទរខ្ទារប្រាប់គ្នាក្នុងស្ថានសួគ៌ថា បុត្ររបស់ព្រះបាទសុទ្ធោ-ទនមហារាជ ប្រសូតហើយក្នុងនគរកបិលពស្តុ រាជកុមារនេះ នឹងអង្គុយទៀបគល់ពោធិមណ្ឌល ហើយនឹងបានត្រាស់ជាព្រះពុទ្ធ ។ គាប់ជួនកាលនោះ **កាឡទេវិលតាបស** អ្នកមានសមាបត្តិ ៨ ជាជីតុន[៩៣] របស់ព្រះបាទ

[៩៣] តាបស ឬសមណៈ ដែលព្រះរាជាទ្រង់គោរព និងឧបត្ថម្ភ ។

សុទ្ធោទនៈ បានចូលទៅសម្រាកក្នុងស្ថានតាវត្តិង្ស ឮសំឡេងស្រែកប្រកាសគ្នានោះឡើង ក៏ចុះពីស្ថានតាវត្តិង្សមកកាន់រាជនិវេសន៍របស់ព្រះបាទសុទ្ធោ-ទនៈ ហើយអង្គុយលើអាសនៈដែលគេក្រាលថ្វាយហើយ ។ ពេលនោះ កាឡទេវិលតាបសមានបំណងចង់ឃើញព្រះរាជបុត្រ ក៏ពោលឡើងថា :

"បពិត្រមហារាជ អាត្មាចង់ឃើញព្រះរាជឱរសរបស់ព្រះអង្គ" ។

ព្រះបាទសុទ្ធោទនៈ ក៏បញ្ជាឱ្យពួកបរិពារ តាក់តែងគ្រឿងអលង្ការ ហើយឱ្យយករាជឱរសចូលមកថ្វាយបង្គំតាបស ។ គ្រាន់តែពួកបរិពារ នាំព្រះរាជឱរសមកចំពោះមុខតាបសនោះភ្លាម ស្រាប់តែរាជឱរស អណ្ដែតត្រសែតឡងអាកាស ទៅតាំងនៅពីលើផ្នួងសក់តាបសនោះទៅវិញ។ តាបសបានឃើញហេតុអស្ចារ្យដូច្នោះ ក៏ផ្គងអញ្ជលីចំពោះព្រះពោធិសត្វ ។ សូម្បីព្រះរាជាក៏លុតជង្គង់ចុះ ថ្វាយបង្គំព្រះរាជឱរសក្នុងពេលនោះផងដែរ ។

កាឡទេវិលតាបស លោកមានឫទ្ធិ អភិញ្ញា អាចរលឹកនូវអតីតកាលបាន ៤០ កប្ប និងអនាគតកាល ៤០ កប្ប ។ ខណៈនោះ តាបសក៏ពិចារណានូវលក្ខណសម្បត្តិរបស់ព្រះពោធិសត្វថា :

"តើព្រះរាជកុមារនេះ នឹងត្រាស់ដឹងជាព្រះពុទ្ធ បានឬមិនបានទេហ្ន?

ក្រោយតាបសពីពិចារណារួច ក៏ដឹងថា ព្រះរាជឱរសអង្គនេះ នឹងត្រាស់ដឹងជាព្រះពុទ្ធពិតប្រាកដ ហើយក៏ញញឹមឡើង ។ តាបសនោះ បានពិចារណាជាបន្តទៀតថា :

តើអាត្មាអញ អាចទាន់ឃើញព្រះពុទ្ធ ដែលជាអច្ឆរិយបុគ្គលយ៉ាងនេះបានដែរឬទេ?

ពិចារណាទៅ ឃើញថាខ្លួននឹងស្លាប់ទៅកើតក្នុងអរូបភព មិនអាចបានឃើញព្រះពុទ្ធត្រាស់ដឹងក្នុងលោករាប់រយពាន់ព្រះអង្គ ។ គ្រានោះតាបសក៏យំខ្សឹកខ្សួលឡើង ។

នៅថ្ងៃ ៥ កើត ខែពិសាខនោះដដែល ជាថ្ងៃ**នាមគ្គហណទិវា** (ថ្ងៃដាក់ឈ្មោះ) ។ ព្រះវររាជបិតា ទ្រង់បានឱ្យអញ្ជើញព្រាហ្មណ៍ ១០៨ នាក់ ដែលជាអ្នកជំនាញក្នុងត្រៃវេទ មកមើលលក្ខណៈព្រះរាជឱរស ។ ព្រះរាជាទ្រង់បានចំណាយទ្រព្យធនយ៉ាងច្រើន ធ្វើពិធីលៀងពួកព្រាហ្មណ៍ទាំងនោះ ហើយទុកព្រាហ្មណ៍ត្រឹមតែ ៨ នាក់ប៉ុណ្ណោះគឺ **រាមព្រាហ្មណ៍១ ធជព្រាហ្មណ៍១ លក្ខណព្រាហ្មណ៍១ យញ្ញព្រាហ្មណ៍១ សុភោជព្រាហ្មណ៍១ សុយាម-ព្រាហ្មណ៍១ សុទត្តព្រាហ្មណ៍១ និងកោណ្ឌញ្ញព្រាហ្មណ៍១** ។

ពួកព្រាហ្មណ៍ទាំង ៧ នាក់ខាងដើមបានព្យាករលក្ខណៈព្រះពោធិសត្វនូវគតិពីរគឺ

១- បើនៅយរាវាស រាជកុមារនេះនឹងបានជាស្ដេចចក្រពត្តិ

២- បើចេញសាងផ្នួស នឹងបានត្រាស់ជាព្រះពុទ្ធ ។

ចំណែកកោណ្ឌញ្ញព្រាហ្មណ៍ បានព្យាករលក្ខណៈរាជឱរសឃើញត្រឹមតែគតិមួយថា :

មហាបុរសនេះ នឹងចេញបួសឥតសង្ស័យ ហើយនឹងត្រាស់ដឹងជាព្រះសម្មាសម្ពុទ្ធពិតប្រាកដ ។

បន្ទាប់ពីព្រាហ្មណ៍ទាំងនោះព្យាករហើយ ក៏ប្រសិទ្ធនាមព្រះពោធិសត្វថា **សិទ្ធត្ថៈ** មានន័យថា "**ជាអ្នកធ្វើប្រយោជន៍ឱ្យសម្រេចដល់សត្វលោកទាំងពួង**" ។

កាលព្រះពោធិសត្វប្រសូតមកបានត្រឹម ៧ ថ្ងៃ ព្រះមាតាក៏ទ្រង់សោយព្រះវិលាល័យ ទៅកើតក្នុងស្ថានតុសិត ។

**ព្រះនាងសិរិមហាមាយា ទ្រង់សោយព្រះវិលាល័យ នៅថ្ងៃ ៧ រោច ខែពិសាខ ឆ្នាំ ច ។**

ព្រះពោធិសត្វមានវ័យវឌ្ឍនាការរហូតមកដល់អាយុ ១៦ ឆ្នាំ ។ ព្រះបិតាបានចាត់ចែងកសាងប្រាសាទ ៣ ថ្វាយដល់ទ្រង់គឺ **នវភូមិកប្រាសាទ១ សត្តភូមិកប្រាសាទ១ បញ្ចភូមិកប្រាសាទ១** និងមានស្ត្រីបម្រើចំនួន ៤ ម៉ឺននាក់ ។ ព្រះរាជាក៏រៀបចំអភិសេកព្រះពោធិសត្វ ជាមួយនឹងព្រះនាង **ភទ្ទាកច្ចាយនា** ហៅព្រះនាង**ពិម្ពាយសោធរា** ។ ព្រះរាជបិតាតែងតែរកគ្រប់មធ្យោបាយធ្វើឱ្យព្រះសិទ្ធត្ថ មានសេចក្តីសប្បាយរីករាយនៅក្នុងព្រះបរមរាជវាំង ដោយការរាំច្រៀងជាមួយតូរ្យតន្ត្រី និងស្រីស្នំជាដើម ។ តែព្រះពោធិសត្វពុំបានរវើរវាយលង់ក្នុងឧបាយទាំងនោះឡើយ ។ ផ្ទុយទៅវិញ ព្រះអង្គតែងតែចង់យាងចេញទៅទតផ្ទាល់ នូវស្ថានភាពខាងក្រៅព្រះរាជវាំង ។

**ព្រះពោធិសត្វទ្រង់បានរៀបអភិសេក និងគ្រងរាជ្យសម្បត្តិ ក្នុងព្រះជន្ម ១៦ វស្សា នាឆ្នាំធ្នូវ ។**

## ព្រះពោធិសត្វឃើញទេវទូតទាំង ៤

ក្នុងកាលខាងក្រោយមក ព្រះពោធិសត្វទ្រង់ស្តេចយាងទៅក្រសាលឧទ្យានជាមួយនឹងឆន្នអាមាត្យ បានប្រទះឃើញនូវបុរសដែលមានភាពជរា សក់ស្កូវ ខ្នងកោង ដៃកាន់ឈើច្រត់ កំពុងដើរក្នុងឧទ្យាន ក៏ឆ្ងល់ក្នុងព្រះចិន្តា ទើបសួរអាមាត្យថា :

"នែនាយសារថីសម្លាញ់ស្មើចិត្តអើយ! ចុះបុរសនេះធ្វើដូចម្ដេច បានជាសក់គាត់មិនដូចសក់អ្នកឯទៀត ទាំងកាយគាត់ ក៏មិនដូចកាយអ្នកឯទៀតដែរ?"

នាយសារថី :

"បពិត្រព្រះសម្មតិទេព នេះឯងហៅថាបុរសចាស់" ។

ព្រះពោធិសត្វ :

"នែនាយសារថី ចុះដូចម្ដេចបុរសនុ៎ះបានជាឈ្មោះថាបុរសចាស់?"

នាយសារថី :

"បពិត្រព្រះសម្មតិទេព បានជាឈ្មោះថាបុរសចាស់ តពីនេះទៅនុ៎ះគាត់នឹងមិនរស់នៅយូរប៉ុន្មានទៀតទេ" ។

ព្រះពោធិសត្វ : "ចុះយើងចាស់ដែរទេ?"

នាយសារថី :

"បពិត្រព្រះសម្មតិទេព មនុស្សទាំងអស់គ្នា ទោះព្រះអង្គក្ដី យើងខ្ញុំទាំងឡាយក្ដី សុទ្ធតែមានសភាពចាស់ជរាជាធម្មតា មិនអាចកន្លងសភាពចាស់ជរាទៅបានទេ" ។

ព្រះពោធិសត្វក៏បានត្រឡប់ពីឧទ្យានមកវិញ ទ្រង់ឡើងកាន់ប្រាសាទ ហើយត្រិះរិះថា :

**ធិរត្ថុ វត ភោ ជាតិ យត្រ ហិ ជាម ជាតស្ស ជរា បញ្ញាយិស្សតិ ។**

ប្រែ : ថ្វីយ! យីអើ! សភាវៈចាស់ជរា តែងមានប្រាកដដល់សត្វលោកដែលបានកើតហើយ ។

៤ ខែក្រោយមកទៀត ព្រះពោធិសត្វទ្រង់យាងទៅទតឧទ្យានម្តងទៀត ក៏ប្រទះឃើញនូវមនុស្សមានជំងឺ ហើយសួរនាយសារថីថា :

"នៃនាយសារថី ចុះបុរសនេះ មានហេតុដូចម្តេចបានជាភ្នែករបស់គាត់ មិនដូចភ្នែកពួកជនដទៃ ទាំងក្បាលរបស់គាត់ ក៏មិនដូចក្បាលនៃពួកជនដទៃដែរ?"

នាយសារថី : "បពិត្រព្រះសម្មតិទេព បុរសនុ៎ះ ឈ្មោះថាបុរសឈឺ" ។

ព្រះពោធិសត្វ :

"ចុះបុរសនុ៎ះធ្វើដូចម្តេចនឹងឱ្យរួចចាកជំងឺនោះ តើយើងមានជំងឺដូចគេដែរទេ?"

នាយសារថី :

"បពិត្រព្រះសម្មតិទេព មនុស្សទាំងឡាយគ្រប់គ្នា ទោះព្រះអង្គក្តី ទោះយើងខ្ញុំព្រះអង្គទាំងឡាយក្តី សុទ្ធតែជាអ្នកមានជំងឺជាធម្មតា មិនអាចកន្លងការឈឺថ្កាត់បានឡើយ" ។

ព្រះពោធិសត្វក៏ត្រឡប់មកកាន់រាជនិវេសន៍វិញ ហើយយាងឡើងកាន់ប្រាសាទ ត្រិះរិះថា :

**ធិរត្ថុ កិរ ភោ ជាតិ នាម យត្រ ហិ នាម ជាតស្ស ជរា បញ្ញាយិស្សតិ ព្យាធិ បញ្ញាយិស្សតិ ។**

ប្រែ : "ថ្វីយ! យីអើ! ជរាតែងមានប្រាកដ ព្យាធិតែងមានប្រាកដដល់សត្វលោកដែលបានកើតហើយ" ។

៤ ខែខាងក្រោយមកទៀត ព្រះពោធិសត្វយាងទៅក្រសាលឧទ្យាន បានជួបប្រទះឃើញមនុស្សស្លាប់ ក៏សួរនាយសារថីថា :

"តើមហាជន កំពុងសែងបុរសនុ៎ះធ្វើអ្វី?"

នាយសារថី :

"បពិត្រព្រះសម្មតិទេព បុរសនុ៎ះឈ្មោះថា ធ្វើមរណកាលហើយ" ។

ព្រះពោធិសត្វ :

"ចុះបុរសនុ៎ះដូចម្ដេច បានជាហៅថាផ្ញើមរណកាល?"

នាយសារថី :

"បពិត្រព្រះសម្មតិទេព បុរសនុ៎ះឯង បានជាឈ្មោះថា ផ្ញើមរណកាល ព្រោះថា ក្នុងកាលឥឡូវនេះ មាតាក្ដី បិតាក្ដី ញាតិសាច់សាលោហិតទាំងឡាយក្ដី លែងឃើញបុរសនោះហើយ ទាំងបុរសនោះសោត ក៏លែងឃើញមាតាបិតា និងញាតិសាច់សាលោហិតទាំងឡាយដែរ"។

ព្រះពោធិសត្វ : "នែនាយសារថី តើយើងនឹងស្លាប់ដែរទេ?"

នាយសារថី :

"បពិត្រព្រះសម្មតិទេព មនុស្សទាំងឡាយគ្រប់គ្នា ទោះព្រះអង្គក្ដី ទោះយើងខ្ញុំព្រះអង្គទាំងឡាយក្ដី សុទ្ធតែមានសេចក្ដីស្លាប់ជាធម្មតា មិនអាចកន្លងសេចក្ដីស្លាប់ទៅបានឡើយ" ។

ព្រះពោធិសត្វត្រឡប់ពីឧទ្យាន ទ្រង់ឡើងកាន់ប្រាសាទពិចារណាត្រិះរិះថា :

**ធិរត្ថុ កិរ ភោ ជាតិ ជាម យត្រ ហិ ជាម ជាតស្ស ជរា បញ្ញាយិស្សតិ ព្យាធិ បញ្ញាយិស្សតិ មរណំ បញ្ញាយិស្សតិ ។**

ប្រែ : "ថ្វីយ! យីអើ! ជរាតែងមានប្រាកដ ព្យាធិតែងមានប្រាកដ មរណៈ តែងមានប្រាកដដល់សត្វលោកដែលបានកើតហើយ" ។

៤ ខែខាងក្រោយមកទៀត ព្រះពោធិសត្វយាងទៅក្រសាលឧទ្យានទៀត ក៏បានឃើញភេទបព្វជិត ទើបសួរឆន្នអាមាត្យថា នៃនាយសារថី ចុះបុរសនុ៎ះ ហេតុដូចម្តេចបានជាក្បាលរបស់គាត់ មិនដូចជាក្បាលពួកជនដទៃ ទាំងសំពត់របស់គាត់ ក៏មិនដូចជាសំពត់ជនដទៃដូច្នេះ?

នាយសារថី :

"បពិត្រព្រះសម្មតិទេព បុរសនុ៎ះឯងឈ្មោះថាអ្នកបួស" ។

ព្រះពោធិសត្វ :

"ចុះបុរសនុ៎ះ ហេតុដូចម្តេចបានជាឈ្មោះថាអ្នកបួស?"

នាយសារថី :

"បពិត្រព្រះសម្មតិទេព បុរសនុ៎ះឯងបានជាមានឈ្មោះថាជាបួស ព្រោះប្រព្រឹត្តព្រហ្មចរិយធម៌ដោយប្រពៃ ព្រោះប្រព្រឹត្តព្រហ្មចរិយធម៌ដ៏ស្មើដោយប្រពៃ ព្រោះប្រព្រឹត្តព្រហ្មចរិយកុសលដោយប្រពៃ ព្រោះធ្វើអំពើបុណ្យដោយប្រពៃ ព្រោះមិនបៀតបៀនដោយប្រពៃ ព្រោះអនុគ្រោះដល់សត្វដោយប្រពៃ" ។

ព្រះពោធិសត្វឃើញបព្វជិតនោះហើយ ក៏សរសើរថា ការបួសជាគុណធម៌មួយដ៏ប្រសើរណាស់ រួចក៏យាងត្រឡប់ចូលព្រះរាជនិវេសន៍វិញ ។

ក្នុងថ្ងៃនោះ កាលព្រះអាទិត្យអស្តង្គតទៅ ព្រះពោធិសត្វបានយាងចុះទៅស្រង់ទឹកក្នុងស្រះមង្គលបោក្ខរណី រួចហើយឡើងគង់លើផ្ទៃថ្មមង្គលសិលា ។ កាលនោះ ព្រះបាទសុទ្ធោទនៈបញ្ជូនដំណឹងឱ្យទ្រង់បានជ្រាបនូវការប្រសូតបុត្រ ។ ព្រះពោធិសត្វ ក៏ពោលឡើងពេលនោះថា :

"រាហុ ជាតោ ពន្ធនំ ជាតំ" ។

ប្រែ : "អន្ទាក់កើតឡើងហើយ ចំណងកើតឡើងហើយ ដល់អាត្មាអញ!" ។

**រាហុលកុមារបានប្រសូត នៅថ្ងៃ អាទិត្យ ១៥ កើត ខែអាសាឍ ឆ្នាំខាល ។**

កាលរាជបុរសត្រឡប់ទៅវិញ បានយកដំណឹងនៃការពោលនោះដល់ព្រះបាទសុទ្ធោទនៈ ទ្រង់ក៏ដាក់ឈ្មោះព្រះរាជនត្តាថា **រាហុលកុមារ** ។

ព្រះពោធិសត្វបានយាងចូលក្នុងព្រះនគរវិញ មានបរិវារហែហមយ៉ាងច្រើន ។ លុះដល់ហើយ ទ្រង់ឡើងទៅកាន់ប្រាសាទដ៏មានសិរី នឿយណាយក្នុងគ្រឿងអលង្ការគ្រប់ប្រភេទ ដោយមិនមានចិត្តត្រេកអរក្នុងរបាំ

ទាំងឡាយ ហើយក៏ទ្រង់ចូលកាន់និទ្រាផ្ទំលក់មួយស្របក់ទៅ ។ ស្រីរបាំទាំងឡាយ ពេលឃើញព្រះពោធិសត្វទ្រង់ផ្ទំលក់ ក៏គិតថា :

"តើយើងនាំគ្នាលេងរបាំដើម្បីអ្នកណាទៀត បើព្រះអយ្យបុត្រផ្ទំលក់ហើយនោះ" ស្ត្រីទាំងឡាយក៏នាំគ្នាពន្លត់ភ្លើង ហើយដេកលក់ទាំងអស់គ្នា ។ កាលព្រះពោធិសត្វភ្ញាក់រលឹកឡើងវិញ ទ្រង់អង្គុយពែនភ្នែនលើសេយ្យាសនា សម្លឹងមើលទៅស្រីរបាំទាំងនោះ ដែលមានអាការៈដូចសាកសព ស្រីខ្លះដេកហៀរទឹកមាត់ ខ្លះទៀតសង្កៀតធ្មេញ ខ្លះដេកចំហមាត់ ខ្លះដេកផ្កាប់មុខ ខ្លះដេករបូតសំពត់ ។ កាលព្រះពោធិសត្វ ឃើញដូច្នោះ ក៏កើតអារម្មណ៍នឿយណាយក្នុងបញ្ចកាមគុណ ទ្រង់មានបំណងចេញសាងផ្នួសដើម្បីស្វែងរកមោក្ខធម៌ ដែលនាំឱ្យរួចផុតពី**ជាតិ ជរា ព្យាធិ** និង **មរណៈ** ក៏ស្ដេចយាងទៅបន្ទប់នាយឆន្នអាមាត្យ ហើយដាស់**ឆន្ន**ឱ្យក្រោកឡើង ។

នាយឆន្នក៏សួរថា : "អ្នកណាគេហ្នឹង?"

ព្រះពោធិសត្វ : "យើងជាព្រះអយ្យបុត្រ" ។

នាយឆន្ន : "ព្រះអង្គស្ដេចយាងមកមានការអ្វី?"

ព្រះពោធិសត្វ :

"យើងមានបំណងទៅសាងផ្នួស ចូរអ្នករៀបចំរាជរថឱ្យយើង" ។

## ព្រះពោធិសត្វទ្រង់ចេញសាងព្រះផ្នួស

នាយឆន្នអាមាត្យក៏ទៅរៀបចំសេះកណ្ឋកៈ ដោយរៀបចំតាក់តែងគ្រឿងអលង្ការយ៉ាងស្រស់ស្អាត ។ ពេលនោះ **សិទ្ធត្ថពោធិសត្វ** មានចិត្តរីករាយបានអធិដ្ឋានក្នុងចិត្តយ៉ាងមាំក្នុងការចេញសាងបព្វជ្ជា ។ គ្រានោះ ព្រះពោធិសត្វមានបំណងយាងចូលទៅមើលព្រះរាជបុត្រ ដែលបានប្រសូតរួចមកហើយ ទើបស្ដេចយាងចូលទៅក្នុងបន្ទប់ព្រះនាង**យសោធរា** ។ ស្រាប់តែព្រះនាងយកព្រះហស្តដាក់ជិតព្រះរាជបុត្រ មិនអាចឱ្យព្រះអង្គចាប់លើករាជបុត្របាន ។ ព្រះពោធិសត្វ ទ្រង់ត្រិះរិះថា :

> “ប្រសិនបើអាត្មាអញលើករាជបុត្រ ប្រាកដជាព្រះនាងទេពីនឹងភ្ញាក់មិនខាន នាំឱ្យអាក់ដំណើរក្នុងការចេញបួសរបស់អាត្មាអញ បើដូច្នោះ មានតែអាត្មាអញចេញសាងផ្នួសសិន កាលណាអាត្មាអញត្រាស់ជាព្រះពុទ្ធហើយ អាត្មាអញនឹងត្រឡប់មកមើលរាជបុត្រវិញ” ។

ព្រះពោធិសត្វក៏ចុះចាកប្រាសាទយាងទៅសាងផ្នួស បន្ទាប់ពីរាជបុត្ររបស់ព្រះអង្គ គឺរាហុលកុមារប្រសូតបានចំនួន ៧ ថ្ងៃ[៨៨] ។ ព្រះពោធិសត្វ ធ្វើដំណើរចេញពីនគរអស់ចម្ងាយផ្លូវ ៣០ យោជន៍ គឺស្មើនឹង ៤៨០ គីឡូម៉ែត្រ

[៨៨] អដ្ឋកថាជាតកបញ្ជាក់ថា **តទា សត្តាហជាតោ រាហុលកុមារោ ហោតិ** «ក្នុងកាលនោះ រាហុលកុមារ ប្រសូតបានចំនួន ៧ ថ្ងៃ» ព្រះពោធិសត្វចេញសាងផ្នួស ។ តែក្នុងន័យខ្វះបញ្ជាក់ថា ព្រះពោធិសត្វចេញបព្វជ្ជា នៅថ្ងៃដែលរាហុលកុមារប្រសូតនោះឯង ។

*រហូតដល់ស្ទឹងអនោមា ក៏សាងផ្នួសត្រង់ស្ទឹងនោះឯង ។ ព្រះពោធិសត្វបាន ចាប់ដាវដោយព្រះហស្តស្តាំ ចាប់ផ្នួងសក់ដោយព្រះហស្តឆ្វេង ហើយកាត់ ព្រះកេសា បន្សល់ទុកត្រឹមពីរធ្នាប់ដែលវិលទៅខាងស្តាំ[៨៥] ។ ព្រះពោធិសត្វ កាត់ព្រះកេសាហើយកាលណា ទ្រង់អធិដ្ឋានថា :*

> *"ប្រសិនបើអាត្មាអញបានត្រាស់ជាព្រះពុទ្ធពិតប្រាកដមែន សូមឱ្យ កេសានេះស្ថិតជាប់នៅលើអាកាស កុំធ្លាក់មកលើផែនដីឡើយ" ។*

*ពេលនោះ ព្រះពោធិសត្វបោះទៅឰដ៏អាកាស ស្រាប់តែព្រះកេសា ជាប់នៅនឹងថ្កល់ក្នុងអាកាស ។* ***សក្កទេវរាជ*** *បានឃើញភាពអស្ចារ្យដោយ ទិព្វចក្ខុ ក៏ស្ដេចយាងមកទទួលកេសានោះ ទៅបញ្ចុះទុកក្នុង**ចូឡាមណិចេតិយ** នាស្ថានតាវត្តិង្ស ។*

***ព្រះពុទ្ធជាម្ចាស់ ទ្រង់សាងព្រះផ្នួស នៅថ្ងៃចន្ទ ១៥ កើត ពេញបូណ៌មី ខែអាសាឍ ឆ្នាំខាល ក្នុងព្រះជន្ម ២៩ វស្សា[៨៦] ។***

*បន្ទាប់ពីព្រះអង្គសាងព្រះផ្នួស ទ្រង់បានយាងទៅកាន់ក្រុងរាជគ្រឹះ ដើម្បីសិក្សាស្វែងរកមោក្ខធម៌ ដែលនាំឱ្យបានត្រាស់ដឹងជាព្រះសម្មាសម្ពុទ្ធ*

---

*[៨៥] ព្រះកេសារបស់ព្រះអង្គ ចាប់តាំងពីកាត់មក នៅត្រឹមពីរធ្នាប់រហូត មិនមានការដុះបន្ថែម ទៀតឡើយ រហូតអស់ព្រះជន្មសង្ខារ ក៏មិនត្រូវការកាត់ ឬកោរឡើយ ។*

*[៨៦] ក្នុងព្រះត្រៃបិដកលេខ ១៦ ទំព័រ ៣១៧ និងអដ្ឋកថាសម្ដែងថា ព្រះពុទ្ធជាម្ចាស់ចេញ សាងផ្នួស ក្នុងព្រះជន្ម ២៩ ។ មានប្រព័ន្ធគាថានៅខាងមុខ សូមពិចារណាមើលផងចុះ ។*

ក្នុងសម្នាក់បដិបត្តិផ្សេងៗ ដូចជាសម្នាក់បដិបត្តិជាមួយនឹងលោកអាចារ្យ **អាឡារកាលាមតាបស** និង**ឧទករាមបុត្តតាបស**ជាដើម រហូតបានសម្រេចនូវសមាបត្តិ ។ តែផ្លូវទាំងនោះ មិនមែនជាបដិបទាដែលនាំឱ្យបានត្រាស់ដឹងជាព្រះអរហន្តសម្មាសម្ពុទ្ធក្នុងលោកនោះទេ ។

សម័យខាងក្រោយមក ព្រះពោធិសត្វក៏យាងទៅប្រតិបត្តិជាមួយនឹងពួកបញ្ចវគ្គិយតាបស ៥ រូប ក្នុងផ្លូវអត្តកិលមថានុយោគ នាដងភ្នំទុក្ករ-កិរិយាបព៌ត (ដង្កេស្វារី) តំបន់គយាសីស: ។ ការប្រតិបត្តិនោះ អស់វេលាចំនួន ៦ ឆ្នាំ នៅតែមិនបានសម្រេចនូវសម្ពោធិញ្ញាណ ទើបព្រះអង្គបង្វែនព្រះទ័យទៅក្នុងផ្លូវមជ្ឈិមបដិបទា ។ ព្រះពោធិសត្វបានចុះចាកភ្នំនោះយាងចូលទៅកាន់តំបន់ឱរុវេលាសេនានិគម ទទួលចង្ហាន់បិណ្ឌបាតពីនាង**សុជាតា** ។ ព្រះអង្គសោយក្រយាហាររួចហើយ ប្រទក្សិណ**អស្សត្ថព្រឹក្ស**កាន់យកថាសមាសឆ្ពោះទៅកាន់ស្ទឹង**នេរញ្ជរា** ។ លុះទ្រង់យាងដល់ស្ទឹងនេរញ្ជរា ក៏បណ្តែតថាសមាសទៅក្នុងស្ទឹង ដើម្បីផ្សងនូវបារមីដែលបំពេញមកក្នុងការសម្រេចនូវសម្ពោធិញ្ញាណ ជាព្រះពុទ្ធក្នុងលោក ។ ក្នុងសាយ-ណ្ហសម័យ ទ្រង់ទទួលស្មៅចំនួន ៨ ក្តាប់ ពី**សោត្ថិយព្រាហ្មណ៍** ដើម្បីយកទៅក្រាលនៅក្រោមដើមអស្សត្ថព្រឹក្ស គឺដើមពោធិព្រឹក្សនេះឯង ។ ក្នុងថ្ងៃ ១៥ កើត ពេញបូណ៌មី ខែពិសាខ ព្រះអង្គទ្រង់បានផ្ចាញ់នូវមារាធិរាជ ព្រម

ទាំងពួកសេនា ហើយបានសម្រេចនូវបុព្វេនិវាសានុស្សតិញ្ញាណ ក្នុងបឋម-យាម, បានសម្រេចនូវចុតូបបាតញ្ញាណ គឺទិព្វចក្ខុ ក្នុងមជ្ឈិមយាម, បានសម្រេចនូវអាសវក្ខយញ្ញាណ ក្នុងបច្ឆិមយាមនៃរាត្រី ។

**ព្រះពុទ្ធជាម្ចាស់ ទ្រង់ធ្វើទុក្ករកិរិយា អស់ចំនួន ៦ ឆ្នាំ ។**

**ព្រះសម្មាសម្ពុទ្ធ ទ្រង់បានត្រាស់ជាព្រះពុទ្ធ ក្នុងថ្ងៃ ពុធ ១៥ កើតពេញបូណ៌មី ខែពិសាខ ឆ្នាំរក មុនពុទ្ធសករាជ ៤៥ ឆ្នាំ ។**

បន្ទាប់ពីព្រះអង្គបានត្រាស់ដឹង ទ្រង់បានគង់សោយវិមុត្តិសុខ អស់ ៧ សប្តាហ៍ ស្មើនឹង ៤៩ ថ្ងៃគឺ

-សប្តាហ៍ទី ១ ត្រង់គល់ពោធិព្រឹក្ស

-សប្តាហ៍ទី ២ អនិមិសចេតិយ

-សប្តាហ៍ទី ៣ រតនចង្កមចេតិយ

-សប្តាហ៍ទី ៤ រតនឃរចេតិយ

-សប្តាហ៍ទី ៥ អជបាលនិគ្រោធ

-សប្តាហ៍ទី ៦ ស្រះមុចលិន្ទ

-សប្តាហ៍ទី ៧ រាជាយតនចេតិយ ។

## ការបំពេញពុទ្ធកិច្ច

បន្ទាប់ពីព្រះពុទ្ធជាអម្ចាស់ ទ្រង់គង់ជាសុខអស់ ៧ សប្តាហ៍ ព្រះអង្គយាងទៅគង់ក្រោមដើមអជបាលនិគ្រោធវិញ ដោយទ្រង់បង្អោនព្រះទ័យក្នុងការមិនសម្តែងព្រះធម៌ឡើយ ។ ទើបសហម្បតីព្រហ្ម មកអារាធនាព្រះអង្គ ដើម្បីប្រកាសសច្ចធម៌ដល់វេនេយ្យសត្វក្នុងលោក ។ ព្រះពុទ្ធជាម្ចាស់ទ្រង់បានបំពេញពុទ្ធកិច្ច ៥ យ៉ាង ចាប់តាំងពីព្រះអង្គទ្រង់ប្រកាសសម្តែងនូវបឋមទេសនា គឺធម្មចក្កប្បវត្តនសូត្រ ប្រោសបញ្ចវគ្គិយភិក្ខុ នាព្រៃឥសិបតនមិគទាយវ័ន ទៀបក្រុងពារាណសី ក្នុងដែនដីកាសី ។

**ព្រះអរហន្តសម្មាសម្ពុទ្ធ ទ្រង់បានបំពេញពុទ្ធកិច្ចទាំង ៥ អស់ថិរវេលាចំនួន ៤៥ វស្សា ដើម្បីប្រយោជន៍ដល់សត្វលោក ។**

ព្រះពុទ្ធកិច្ចទាំង ៥ នោះគឺ

**១-កិច្ចក្នុងបុរេភត្ត** កិច្ចពេលព្រឹក ទ្រង់និមន្តបិណ្ឌបាត

**២-កិច្ចក្នុងបច្ឆាភត្ត** កិច្ចពេលរសៀល ទ្រង់សម្តែងព្រះធម៌ដល់ពុទ្ធបរិស័ទ

**៣-កិច្ចក្នុងបឋមយាម** ព្រលប់ទ្រង់ប្រទានឱវាទចំពោះភិក្ខុសង្ឃ

**៤-កិច្ចក្នុងមជ្ឈិមយាម** អធ្រាត្រទ្រង់ដោះប្រស្នាដល់ទេវតា

**៥-កិច្ចក្នុងបច្ឆិមយាម** ពេលទៀបភ្លឺប្រមើលមើលឧបនិស្ស័យសត្វ ។

## កិច្ចក្នុងបុរេភត្ត

### ពេលព្រឹក ព្រះសម្មាសម្ពុទ្ធទ្រង់និមន្តបិណ្ឌបាត

ព្រះដ៏មានព្រះភាគទ្រង់តើនចាកព្រះបន្ទំ បដិបត្តិសរីរៈហើយ ក៏ទ្រង់ប្រថាប់លើពុទ្ធាសនៈ ដើម្បីរង់ចាំវេលាត្រាច់ទៅបិណ្ឌបាត ក្នុងស្រុកឬនិគម ។ ជួនកាល ព្រះអង្គទ្រង់និមន្តតែមួយអង្គឯង ជួនកាលទ្រង់និមន្តទៅជាមួយនឹងសាវ័ក ។ មនុស្សទាំងឡាយបាននាំគ្នាបូជាផ្កាភ្ញី និងគ្រឿងក្រអូបជាដើមចំពោះព្រះអង្គ ហើយក្រាបទូលអារាធនាថា "បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះអង្គប្រោសប្រទានភិក្ខុឱ្យខ្ញុំព្រះអង្គ ១០ អង្គខ្លះ ២០ អង្គខ្លះ ៣០ អង្គខ្លះជាដើម ដើម្បីទទួលបិណ្ឌបាតក្នុងផ្ទះរបស់ខ្ញុំព្រះអង្គ" ។ ហើយក៏ទទួលបាត្រពីព្រះមានព្រះភាគ រួចក្រាលអាសនៈបង្អោនអាហារបិណ្ឌបាតថ្វាយចំពោះព្រះអង្គដោយសេចក្ដីគោរព ។ កាលភត្តកិច្ចសម្រេចហើយ ទ្រង់បានសម្ដែងធម្មទេសនាប្រោសជនទាំងនោះ អ្នកខ្លះតាំងនៅក្នុងសរណគមន៍ សោតាបត្តិផល សកទាគាមិផល និងអនាគាមិផលជាដើម ។ ព្រះដ៏មានព្រះភាគទ្រង់បានអនុគ្រោះមហាជនដូច្នេះហើយ ក៏ទ្រង់និមន្តត្រឡប់ទៅវត្តវិញ ដើម្បីរង់ចាំភិក្ខុទាំងឡាយត្រឡប់ពីបិណ្ឌបាត ។ គ្រាភិក្ខុទាំងឡាយធ្វើភត្តកិច្ចស្រេចហើយ ទើបភិក្ខុជាឧបដ្ឋាកក្រាបទូលឱ្យទ្រង់ជ្រាប ។ បន្ទាប់ពីព្រះពុទ្ធទ្រង់យាងទៅគង់ក្នុងសាលាហើយ ទ្រង់ផ្ដល់នូវឱវាទដល់ព្រះភិក្ខុសង្ឃថា ៖

" ការកើតជាមនុស្ស រកបានដោយកម្រ

ការត្រាស់ដឹងជាព្រះពុទ្ធ ក៏រកបានដោយកម្រ

ព្រះសទ្ធម្ម រកបានដោយកម្រក្រៃលែង

ការដល់ព្រមដោយសទ្ធា រកបានដោយកម្រ

ការបានបព្វជ្ជា រកបានដោយកម្រ

ការស្តាប់ព្រះសទ្ធម្ម រកបានដោយកម្រក្រៃលែង" ។

ក្នុងទីនោះ ភិក្ខុបានទូលសួរកម្មដ្ឋានចំពោះព្រះដ៏មានព្រះភាគ ព្រះអង្គក៏ទ្រង់ប្រទានកម្មដ្ឋានសមគួរដល់ចរិតរបស់ភិក្ខុទាំងនោះ ។ បន្ទាប់មកភិក្ខុទាំងនោះក៏ថ្វាយបង្គំលាព្រះដ៏មានព្រះភាគ ហើយទៅកាន់ទីសម្រាករៀងៗខ្លួន គឺក្នុងព្រៃខ្លះ ទៀបគល់ឈើខ្លះ តាមភ្នំ និងគុហាខ្លះ ។

លំដាប់នោះ ព្រះដ៏មានព្រះភាគទ្រង់យាងចូលទៅកាន់ព្រះគន្ធកុដិ ប្រសិនបើទ្រង់សព្វព្រះទ័យនឹងសិង ក៏ទ្រង់សិងមួយស្របក់ទើបតើនឡើង ដើម្បីប្រមើលមើលឧបនិស្ស័យរបស់សត្វ ក្នុងស្រុកឬតំបន់ ដែលព្រះអង្គទ្រង់និមន្តទៅគង់នោះ **នេះជាកិច្ចក្នុងបុរេភត្ត** ។

## កិច្ចក្នុងបច្ឆាភត្ត

### *ពេលល្ងាច ព្រះសម្មាសម្ពុទ្ធទ្រង់សម្ដែងធម្មទេសនា*

*ក្នុងពេលល្ងាច កាលវេលាសមគួរហើយ មហាជននាំគ្នាកាន់យកផ្កាឈើ និងគ្រឿងក្រអូបជាដើម ចូលទៅទីប្រជុំក្នុងព្រះវិហារ ។ កាលបរិស័ទជួបជុំគ្នាហើយ ព្រះដ៏មានព្រះភាគទ្រង់និមន្តមកគង់លើពុទ្ធាសនៈដ៏ប្រសើរ ដើម្បីសម្ដែងព្រះធម៌ដ៏សមគួរតាមពេលវេលា និងចរិតរបស់ជនទាំងនោះ ។ កាលចប់ធម្មទេសនាហើយ មហាជនទាំងនោះ ក៏ថ្វាយបង្គំលាព្រះដ៏មានព្រះភាគ ហើយចៀសចេញទៅរៀងៗខ្លួន* ***នេះជាកិច្ចក្នុងបច្ឆាភត្ត*** *។*

## កិច្ចក្នុងបឋមយាម

### *ពេលព្រលប់ ព្រះសម្មាសម្ពុទ្ធទ្រង់ប្រទានឱវាទដល់ភិក្ខុសង្ឃ*

*ក្រោយពីទ្រង់សម្រេចកិច្ចក្នុងបច្ឆាភត្តរួចហើយ បើទ្រង់មានបំណងស្រង់ទឹក ទ្រង់ក៏ចូលទៅកាន់បន្ទប់ទឹកស្រោចស្រពព្រះវរកាយ ។ បន្ទាប់មកទ្រង់គ្រងចីវរឆៀងស្មាម្ខាង និមន្តទៅគង់លើពុទ្ធាសនៈ ដែលភិក្ខុជាឧបដ្ឋាកចាត់ចែងទុកហើយស្រេច ។ កាលភិក្ខុទាំងឡាយនាំគ្នាមកគាល់ ភិក្ខុខ្លះទូលសួរបញ្ហា ភិក្ខុខ្លះទូលសូមស្ដាប់ធម៌ ។ ព្រះដ៏មានព្រះភាគទ្រង់បានអនុគ្រោះដល់ភិក្ខុទាំងនោះ ដោយទ្រង់កែបញ្ហា សម្ដែងព្រះធម៌ និងប្រទានឱវាទ ។ កិច្ចនេះ ព្រះអង្គទ្រង់គង់នៅរហូតអស់បឋមយាម ។ ដល់វេលាសមគួរ*

ហើយ ភិក្ខុទាំងឡាយក៏ថ្វាយបង្គំលា ហើយចៀសចេញទៅរៀងៗខ្លួន **នេះជាកិច្ចក្នុងបឋមយាម ។**

## កិច្ចក្នុងមជ្ឈិមយាម

### វេលាអធ្រាត្រ ទ្រង់ដោះប្រស្នាដល់ទេវតា

កាលព្រះពុទ្ធ ទ្រង់បញ្ចប់កិច្ចក្នុងបឋមយាមហើយ ទេវតាទាំងមួយម៉ឺនលោកធាតុ បានឱកាសនាំគ្នាចូលទៅគាល់ព្រះដ៏មានព្រះភាគ ។ ទេវតាទាំងនោះនាំគ្នាសួរបញ្ហារៀងៗខ្លួន តាមដែលខ្លួនត្រៀមទុកមក ដោយហោចទៅ សូម្បីបញ្ហាត្រឹមអក្ខរៈ ៤ តួ ព្រះដ៏មានព្រះភាគ ក៏ទ្រង់កែបញ្ហាដល់ទេវតាទាំងនោះដែរ រហូតញ៉ាំងមជ្ឈិមយាមនៃរាត្រីឱ្យកន្លងទៅ ដោយអនុគ្រោះដល់ទេវតាទាំងឡាយដូច្នេះ **នេះជាកិច្ចក្នុងមជ្ឈិមយាម ។**

## កិច្ចក្នុងបច្ឆិមយាម

### ពេលទៀបភ្លឺ ព្រះពុទ្ធទ្រង់ប្រមើលមើលសត្វលោក

កិច្ចក្នុងបច្ឆិមយាម ព្រះដ៏មានព្រះភាគទ្រង់បែងចេញជា ៣ រយៈកាលគឺ

**រយៈកាលទី ១** ព្រះអង្គទ្រង់ចង្រ្កម

**រយៈកាលទី ២** ព្រះអង្គសម្រេចសីហសេយ្យា (ទ្រង់ផ្ទំ)

**រយៈកាលទី ៣** ព្រះអង្គតើនឡើងប្រមើលមើលសត្វលោក ។

នៅក្នុងគម្ពីរសុមង្គលវិលាសិនី អដ្ឋកថាព្រហ្មជាលសូត្រ និង អដ្ឋកថាធម្មបទពោលថា :

ព្រះសម្មាសម្ពុទ្ធគ្រប់ៗព្រះអង្គ ទ្រង់ផ្សាយសំណាញ់ញាណប្រមើល មើលសត្វលោក ក្នុងមួយថ្ងៃពីរដងគឺ ក្នុងវេលាជិតភ្លឺ និងក្នុងវេលាល្ងាច ។ ទ្រង់បានពិចារណាចំពោះបុគ្គលដែលមានបុញ្ញាធិការសន្សំមក ដោយអំណាចទាននិងសីល ក្នុងសម្នាក់ព្រះពុទ្ធអង្គមុនៗ ដើម្បីទ្រង់និមន្តទៅប្រោសជនទាំងនោះឱ្យបានសម្បត្តិមនុស្ស សម្បត្តិទេវតា សម្បត្តិព្រះនិព្វាន តាមបុណ្យរបស់មនុស្សម្នាក់ៗ ដោយទ្រង់មិនគិតថា ផ្លូវនោះជិត ឬឆ្ងាយទេ **នេះជាកិច្ចក្នុងបច្ឆិមយាម ។**

លោកពោលថា "គ្រាពុទ្ធកាល សូម្បីក្នុងទីដែលមានភិក្ខុត្រឹមតែមួយអង្គ លោកក៏ចាត់ចែងពុទ្ធាសនៈទុកដើម្បីទទួលព្រះសម្មាសម្ពុទ្ធ ព្រោះកាលព្រះសាស្តាទ្រង់មនសិការៈចំពោះភិក្ខុអ្នកទទួលកម្មដ្ឋានពីព្រះអង្គទៅហើយ ក៏នឹងប្រមើលមើលថា តើភិក្ខុនោះនឹងអាចញុំាងគុណដ៏វិសេសឱ្យកើតឡើងបានដែរឬទេ" ។

លុះទ្រង់ជ្រាបថា ភិក្ខុណាលះកម្មដ្ឋានចោល ត្រិះរិះអកុសលវិតក្កៈជាដើម ព្រះអង្គទ្រង់នឹងនិមន្តទៅទីនោះ ដោយពុទ្ធានុភាពគង់លើពុទ្ធាសនៈ

ដែលភិក្ខុបានចាត់ចែងទុក ដើម្បីទ្រង់ប្រទានឱវាទអនុគ្រោះភិក្ខុនោះ ឱ្យបានសម្រេចប្រយោជន៍ហើយ ទើបនិមន្តត្រឡប់ទៅកាន់ទីគង់ព្រះអង្គវិញ ។

ព្រះអរហន្តសម្មាសម្ពុទ្ធ ទ្រង់បានបំពេញពុទ្ធកិច្ចទាំង ៥ នេះ អស់ ៤៥ វស្សា ដើម្បីប្រយោជន៍ដល់សត្វលោកតែម៉្យាង មិនមានបំណងប៉ង ប្រាថ្នាអ្វីបន្តិចបន្តួចពីសត្វលោកឡើយ ដោយព្រះអង្គទ្រង់បំពេញពុទ្ធចរិយា មិនគិតពីការនឿយហត់លំបាកព្រះកាយឡើយ ឱ្យតែសត្វលោកបានរួចផុតចាកទុក្ខ បានត្រាស់ដឹងនូវអរិយសច្ចធម៌ ។ ក្រោយពីព្រះអង្គទ្រង់បំពេញពុទ្ធកិច្ចអស់ ៤៥ ឆ្នាំហើយ នៅក្នុង**ថ្ងៃ អង្គារ ១៥ កើត ពេញបូណ៌មី ខែ ពិសាខ ឆ្នាំ ម្សាញ់ មុនពុទ្ធសករាជ ១ ថ្ងៃ** ព្រះអង្គក៏បានចូលបរិនិព្វានក្រោមសាលព្រឹក្សទាំងគូ ដោយអនុបាទិសេសនិព្វាន នៅក្នុងនគរកុសិនារា ។

**(ចប់ពុទ្ធប្បវត្តិដោយសង្ខេប)**

**សូមពិចារណានូវគាថាពុទ្ធប្បវត្តិនេះផងចុះ**

**កុក្កដេ  គព្ភាសោ  ច    សោណោ  ចុតវជិក្ខមិ**
**ឧសភេ  រាជសម្បត្តិ     សសេ  បព្វជិតោ  ជិនោ ។**

ប្រែ : *ព្រះវិជិតមារទ្រង់យាងចុះមកអាស្រ័យនៅក្នុងព្រះគភ៌ (នៃព្រះវរ-មាតា) ក្នុងឆ្នាំរកា ទ្រង់ប្រសូតចាកព្រះគភ៌ក្នុងឆ្នាំច ទ្រង់សោយរាជ-សម្បត្តិក្នុងឆ្នាំឆ្លូវ ទ្រង់ព្រះផ្នួសក្នុងឆ្នាំថោះ ។*

**កុក្កដេ  សព្វញ្ញូ  ពុទ្ធោ    តត្ថ  ចក្កំ  បវត្តយិ**
**និព្វានគមនំ  សប្បេ     សហស្សេ  បញ្ច  មូសិកោ ។**

ប្រែ : *ទ្រង់ត្រាស់ដឹងជាព្រះសព្វញ្ញុពុទ្ធ ក្នុងឆ្នាំរកា ទ្រង់សម្ដែងនូវព្រះធម្មចក្រក្នុងឆ្នាំនោះ ទ្រង់យាងចូលកាន់ព្រះនិព្វានក្នុងឆ្នាំម្សាញ់ ព្រះពុទ្ធសាសនានឹងគ្រប់ ៥.០០០ វស្សាគត់ ក្នុងឆ្នាំជូត ។*

**ឱក្កន្តោ  ច  គរុវារស្មឹ     សុក្រវារេ  ច  និក្ខមិ**
**សម្ពុទ្ធោ  ពុធវារស្មឹ      អង្គារេ  បរិនិព្វុតោ ។**

ប្រែ : *ទ្រង់យាងចុះកាន់ព្រះគភ៌ (នៃព្រះវរមាតា) ក្នុងថ្ងៃព្រហស្បតិ៍ ប្រសូតក្នុងថ្ងៃសុក្រ ត្រាស់ជាព្រះសម្ពុទ្ធក្នុងថ្ងៃពុធ បរិនិព្វានក្នុងថ្ងៃអង្គារ ។*

អាសាឡ្ហបុណ្ណមោកន្តោ  វិសាខេយេវ  ជាតោ ច
វិសាខបុណ្ណមី  សម្ពុទ្ធោ  វិសាខេ  បរិនិព្វុតោ ។

ប្រែ : ព្រះអង្គយាងចុះកាន់ព្រះគភ៌ (នៃព្រះវរមាតា) ក្នុងថ្ងៃពេញបូណ៌មី ខែអាសាឍ ប្រសូតក្នុងថ្ងៃពេញបូណ៌មី ខែវិសាខ ត្រាស់ជាព្រះសម្ពុទ្ធ ក្នុងថ្ងៃពេញបូណ៌មី ខែពិសាខ បរិនិព្វានក្នុងថ្ងៃពេញបូណ៌មី ខែវិសាខ ។

និព្វុតេ  លោកនាថម្ហិ  សម្ពុទ្ធេ  អគ្គបុគ្គលេ
បដិមា  ពោធិរុក្ខា ច  ថូបា ច  ជិនធាតុយោ ។
ចតុរាសីតិសហស្ស-  ធម្មក្ខន្ធា  សុទេសិតា
អគ្គប្បវត្តនដ្ឋានេ  ឋបិតា  ហោន្តិ  ចាណិនំ ។

ប្រែ : កាលព្រះសម្មាសម្ពុទ្ធជាអគ្គបុគ្គល ជាទីពឹងនៃសត្វលោកបរិនិព្វានទៅហើយ ព្រះបដិមាផង ព្រះពោធិព្រឹក្សផង ព្រះស្តូប[៨៧]ផង ព្រះជិនធាតុផង ព្រះធម៌ ៨៤.០០០ ធម្មក្ខន្ធ ដែលព្រះអង្គទ្រង់សម្តែងហើយដោយប្រពៃផង ជាវត្ថុគឺព្រះសម្មាសម្ពុទ្ធ ទ្រង់ប្រតិស្ឋានទុកដើម្បីជាបុញ្ញក្ខេត្តដ៏ប្រសើររបស់សត្វទាំងឡាយ ។

[៨៧] (ន.) (សំ.), (ជើង ត) (ថូប) គំនរ ឬពំនូកដីជាដើម ដែលមានប៉ែកខាងលើខ្ពស់ស្រួច ។ ចេតិយតូចទាបដែលមានរាងស្រដៀងនឹងសណ្ឋានអកកំបោរ ឬសណ្ឋានចេតិយខ្សាច់ (ប្រើជា ស្តូបៈ ក៏បាន, អានថា --ប៉ៈ; ខ្មែរច្រើនហៅក្លាយជា សថូប ។

# ប្រតិទិនឆ្នាំព្រះពុទ្ធ

| ជូត | ឆ្លូវ | ខាល | ថោះ | រោង | ម្សាញ់ | មមី | មមែ | វក | រកា | ច | កុរ |
|---|---|---|---|---|---|---|---|---|---|---|---|

| ច | កុរ | ជូត | ឆ្លូវ | ខាល | ថោះ | រោង | ម្សាញ់ | មមី | មមែ | វក | រកា |
|---|---|---|---|---|---|---|---|---|---|---|---|
| **១** ប្រសូត | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ |
| ១៣ | ១៤ | ១៥ | **១៦** អភិសេក | ១៧ | ១៨ | ១៩ | ២០ | ២១ | ២២ | ២៣ | ២៤ |
| ២៥ | ២៦ | ២៧ | ២៨ | **២៩** ចេញបួស | ៣០ | ៣១ | ៣២ | ៣៣ | ៣៤ | **៣៥** ត្រាស់ដឹង | ៣៦ |
| ៣៧ | ៣៨ | ៣៩ | ៤០ | ៤១ | ៤២ | ៤៣ | ៤៤ | ៤៥ | ៤៦ | ៤៧ | ៤៨ |
| ៤៩ | ៥០ | ៥១ | ៥២ | ៥៣ | ៥៤ | ៥៥ | ៥៦ | ៥៧ | ៥៨ | ៥៩ | ៦០ |
| ៦១ | ៦២ | ៦៣ | ៦៤ | ៦៥ | ៦៦ | ៦៧ | ៦៨ | ៦៩ | ៧០ | ៧១ | ៧២ |
| ៧៣ | ៧៤ | ៧៥ | ៧៦ | ៧៧ | ៧៨ | ៧៩ | **៨០** បរិនិព្វាន | | | | |

**បញ្ជាក់**: *ការប្រសូតនៃព្រះសម្មាសម្ពុទ្ធ បុរាណាចារ្យពោលតៗគ្នាថា ព្រះអង្គទ្រង់ប្រសូត ក្នុងឆ្នាំ* **ច** *ដូចមានគាថាពោលខាងដើមស្រាប់ ។ តែឆ្នាំ* **ច** *នេះមិនមានប្រាកដក្នុងព្រះត្រៃបិដក និងអដ្ឋកថាទាំងឡាយទ្បើយ ។ ចំណែកព្រះជន្មរៀបអភិសេក មានប្រាកដក្នុងអដ្ឋកថា ពុទ្ធវិសមធុរត្ថវិលាសិនីថា* "**អថ មហាបុរិសោ អនុក្កមេន សោឡសវស្សុទ្ទេសិកោ អហោសិ**" *"គ្រានោះ មហាបុរសមានព្រះជន្ម ១៦ វស្សា តាមលំដាប់" ។ ចំណែកក្នុងព្រះត្រៃបិដក លេខ ១៦ ទំព័រ ៣១៧ មានបញ្ជាក់ច្បាស់អំពីព្រះជន្មព្រះអង្គ*

*យាងចេញសាងផ្នួសថា* "**ឯកូនតឹស វយសា សុភទ្ទ យំ បព្វជឹ កឹំ កុសលានុឯសី**" *"ម្នាលសុភទ្ទ កាលតថាគតមានវ័យ ២៩ វស្សា បាន បួសហើយ ជាអ្នកស្វែងរកនូវកុសល" ។ ក្នុងអដ្ឋកថា មនោរថបូរណី បញ្ជាក់ ឆ្នាំធ្វើទុក្ករកិរិយាថា* "**ឆព្វស្សានិ មហាបធានំ ករោន្តោបិ ឧប្បជ្ជមានោ ជាម**" *"ព្រះមានព្រះភាគទ្រង់បំពេញទុក្ករកិរិយាអស់ ៦ វស្សា ឈ្មោះថា កើតឡើងដើម្បីប្រយោជន៍សត្វលោក" ។ ក្នុងព្រះត្រៃបិដក លេខ ១៦ ទំព័រ ២១៣ បញ្ជាក់ឆ្នាំព្រះជន្មបរិនិព្វានរបស់ព្រះអង្គថា* "**អហំ ខោ បនានន្ទ ឯតរហិ ជិណ្ណោ វុឌ្ឍោ មហល្លកោ អទ្ធគតោ វយោ អនុប្បត្តោ អាសីតិកោ មេ វយោ វត្តតិ**" *"ម្នាលអានន្ទ ឥឡូវនេះ តថាគតគ្រាំគ្រា ហើយ ចម្រើនហើយ ចាស់ហើយ កន្លងអាយុកាលដល់បច្ឆិមវ័យហើយ វ័យតថាគត ៨០ វស្សាហើយ ។ នៅក្នុងអដ្ឋកថា បបញ្ចសូទនី នៃសំសារ-សុទ្ធិអាទិវណ្ណនាខែថា* "**អាសីតិកោ មេ វយោ វត្តតីតិ ឥមំ កិរ សុត្តំ ភគវា បរិនិព្វានសំវច្ឆរេ កថេសិ**" *"បទថា វ័យតថាគត ៨០ ឆ្នាំហើយ មានសេចក្ដីថា ព្រះដ៏មានព្រះភាគ ទ្រង់សម្ដែងនូវសូត្រនេះ ក្នុងឆ្នាំបរិនិព្វាន របស់ព្រះអង្គ គឺក្នុងព្រះជន្ម ៨០ វស្សា" ។*

*ចំណុចខាងលើនេះបញ្ជាក់ថា ព្រះពុទ្ធជាម្ចាស់ទ្រង់អភិសេកក្នុង ព្រះជន្ម ១៦ វស្សា, ទ្រង់ចេញសាងផ្នួសក្នុងព្រះជន្ម ២៩ វស្សា, បន្ទាប់មក*

៦ វស្សា ទ្រង់ត្រាស់ដឹងគឺព្រះជន្ម ៣៥ វស្សា, ព្រះជន្ម ៨០ វស្សា ទ្រង់បរិ-និព្វានពិតប្រាកដមែន។

ដើម្បីឱ្យឃើញថា ព្រះជន្មប៉ុន្មាន ត្រូវឆ្នាំណានោះ មានតែធ្វើជាប្រតិទិនឆ្នាំព្រះពុទ្ធទេ ទើបច្បាស់ ។ ក្នុងប្រតិទិនដែលរៀបចំឡើងឃើញថា ព្រះជន្ម ១៦ ស្ថិតនៅក្នុងឆ្នាំ **ឆ្លូវ**, ព្រះជន្ម ២៩ ស្ថិតនៅក្នុងឆ្នាំ **ខាល**, ព្រះជន្ម ៣៥ ត្រាស់ដឹងនៅក្នុងឆ្នាំ **វក**, ព្រះជន្ម ៨០ បរិនិព្វាននៅក្នុងឆ្នាំ **ម្សាញ់** ។ ទាំងនេះដោយសម្អាងថា "ព្រះពុទ្ធជាម្ចាស់ទ្រង់ប្រសូតក្នុងឆ្នាំ **ច**" ។ ចំណែកគាថាពោលត្រង់ទំព័រ ១៦៨ ថា "ទ្រង់ព្រះផ្នួសក្នុងឆ្នាំ **ថោះ**, ទ្រង់ត្រាស់ដឹងជាព្រះសព្វញ្ញុពុទ្ធ ក្នុងឆ្នាំ **រកា**" នោះជាពាក្យសូធ្យតៗគ្នា ពុំមានមូលដ្ឋានពិតប្រាកដ ។

ហេតុដូច្នេះ ទើបអ្នកនិពន្ធសិក្សាស្រាវជ្រាវ ក្នុងព្រះត្រៃបិដក អដ្ឋកថា និងដីកា គប្បីបង្ហាញតាមបែបប្រតិទិន ដើម្បីឱ្យមានគោលស្ពានត្រឹមត្រូវ ។ សេចក្តីនេះ សូមជូនលោកអ្នកសប្បុរសជាអ្នកអាន ធ្វើការពិចារណាតាមព្រះជន្មក្នុងព្រះត្រៃបិដក និងអដ្ឋកថា ដូចមានតារាងប្រតិទិនខាងលើនោះស្រាប់ ៕

# ជំពូកទី ៧

# ព្រះពុទ្ធមេត្តេយ្យ ឬ ព្រះស្រីអារ្យមេត្រី

## ១-ព្រះស្រីអារ្យមេត្រីត្រាស់ដឹងក្នុងលោក

*ថ្ងៃមួយ ព្រះធម្មសេនាបតីសារីបុត្រ បានក្រាបបង្គំទូលសួរព្រះបរមសាស្តាថា :*

*បពិត្រព្រះអង្គដ៏ចម្រើន ព្រះអជិតតាបស នឹងសម្រេចជាព្រះពុទ្ធស្រីអារ្យមេត្រីដ៏ចម្រើនក្នុងភទ្ទកប្បមែនឬទេ?*

*គ្រានោះ ព្រះមានព្រះភាគទ្រង់ត្រាស់តបព្រះសារីបុត្រថា :*

*ម្នាលសារីបុត្រ អ្នកចូរកំណត់ទុកក្នុងចិត្ត ហើយស្តាប់តថាគតចុះ ។*

*កាលតថាគតបរិនិព្វានហើយ សាសនាតថាគតកន្លងបាន ៥.០០០ ព្រះវស្សា ។ មនុស្សម្នាទាំងឡាយក្នុងលោក ធ្លាក់ចុះនូវសីលធម៌បន្តិចម្តងៗ រហូតដល់លែងគោរព លែងដឹងគុណឪពុកម្តាយ លែងស្គាល់គុណគ្រូ លែងស្គាល់គុណ ស្គាល់ទោស លែងដឹងខុស ដឹងត្រូវ ។ មនុស្សទាំងឡាយនឹងថយអាយុចុះរហូតដល់ទៅ ១០ ឆ្នាំ[៤៨] ។ ក្នុងកាលនោះ មនុស្សអាយុត្រឹម ៥ ឆ្នាំ ក៏*

*[៤៨] បច្ចុប្បន្នកាល អាយុកប្បរបស់មនុស្សមានត្រឹម ៧៥ ឆ្នាំ ដូច្នេះ ១០០ ឆ្នាំ ចុះ ១ ឆ្នាំ រហូតដល់អាយុកប្បរបស់មនុស្សត្រឹម ១០ ឆ្នាំ គិតពីឆ្នាំនេះទៅ នៅសល់ ៦.៧០០ ឆ្នាំទៀត មនុស្សនឹងមានអាយុកប្បត្រឹម ១០ ឆ្នាំ ។*

រៀបការមានគ្រួសារ ។ ពេលនោះ មានព្រឹត្តិការណ៍ចម្លែក ៣ នឹងកើតមាន ឡើងក្នុងសង្គមមនុស្សគឺ

១- មនុស្សទាំងឡាយ ប្រព្រឹត្តខុសសីលធម៌ គឺឪពុកម្តាយនិងកូន បងនិងប្អូន បានសេពសន្ថវៈជាមួយគ្នាដូចសត្វតិរច្ឆាន ។

២- មនុស្សនិងមនុស្សស្អប់គ្នា ដោយឃើញមុខគ្នាមិនបាន ។

៣-មនុស្សកាប់សម្លាប់គ្នាដូចសត្វ ដែលគួរឱ្យខ្លាចតក់ស្លុតយ៉ាងខ្លាំង។

ពេលនោះ **សត្ថន្តរកប្ប**[៩៩] ក៏កើតឡើង មនុស្សទាំងឡាយក៏សម្លាប់គ្នា ដូចជាសត្វតិរច្ឆាន ។ មនុស្សខ្លះមាននិស្ស័យល្អ រត់គេចទៅនៅតាមញកភ្នំ ឬដងព្រៃជាដើម ដោយមិនបានបង្កវិវាទសម្លាប់គ្នាឡើយ ។ ចំណែកឯជនពាលទាំងឡាយបាញ់កាប់សម្លាប់គ្នាវិនាសអស់ ។

(**អ្នកប្រាជ្ញលោកណែនាំថា** : "នរជនឯណា ដែលប្រាថ្នាកុំឱ្យជួប សត្ថន្តរកប្បនោះ ត្រូវធ្វើទាន រក្សាសីល សាងកុសលធម៌ ដើម្បីទៅកើតនូវទីខ្ពស់ មានស្ថានតាវត្តិង្សជាដើម")។

ពេលនោះ កន្លងទៅបាន ៧ ថ្ងៃ មនុស្សល្អក៏ចេញអំពីព្រៃ ឃើញគ្នាញញឹមញញែមរាក់ទាក់រកគ្នា ហើយបបួលគ្នារក្សាសីល ចម្រើនកម្មដ្ឋាន ។

---

[៩៩] សត្ថន្តរកប្ប បានដល់ លោកវិនាសទៅដោយគ្រឿងសស្ត្រាវុធ ។

*សំណួរថា* :   *តើចម្រើនកម្មដ្ឋានដូចម្ដេច?*

*ចម្លើយថា* :   *ចម្រើនកម្មដ្ឋាន ពិចារណានូវអត្តភាពនេះថា មិនទៀង ជាទុក្ខ ជាអនត្តា មិនស្អាត គួរខ្ពើម ។*

*គ្រានោះ មនុស្សទាំងឡាយបាននាំគ្នារក្សាសីលជានិច្ច នាំឱ្យមានអាយុចម្រើនឡើងវិញ កូនរបស់មនុស្សដែលមានអាយុ ១០ ឆ្នាំ ឡើងរហូតដល់២០ ឆ្នាំ, កូនរបស់មនុស្ស ២០ ឆ្នាំ ឡើងរហូតដល់ ៣០ ឆ្នាំ, កូនរបស់មនុស្ស ៣០ ឆ្នាំ ឡើងរហូតដល់ ៤០ ឆ្នាំ, កូនរបស់មនុស្ស ៤០ ឆ្នាំ ឡើងរហូតដល់ ៥០ ឆ្នាំ, កូនរបស់មនុស្ស ៥០ ឆ្នាំ ឡើងរហូតដល់ ១០០ ឆ្នាំ, កូនរបស់មនុស្ស ១០០ ឆ្នាំ ឡើងរហូតដល់ ១.០០០ ឆ្នាំ, កូនរបស់មនុស្ស ១.០០០ ឆ្នាំ ឡើងរហូតដល់ ១០.០០០ ឆ្នាំ, កូនរបស់មនុស្ស ១០.០០០ ឆ្នាំ ឡើងរហូតដល់ ១០០.០០០ ឆ្នាំ, កូនរបស់មនុស្ស ១០០.០០០ ឆ្នាំ ឡើងរហូតដល់ ១ អសង្ខេយ្យឆ្នាំ[៥០] ។*

*ក្នុងកាលដែលមនុស្សមានអាយុវែងយ៉ាងនេះ ក៏នាំឱ្យមានសេចក្ដីប្រមាទដោយសម្គាល់ថា ខ្លួនមិនចាស់ មិនស្លាប់ បណ្ដាលឱ្យអាយុថយចុះពី១ អសង្ខេយ្យមកវិញគឺ (១០០ឆ្នាំ ចុះ ១ ឆ្នាំ) រហូតមកដល់អាយុ ៨០.០០០ ឆ្នាំ ។*

[៥០] *ចូរមើលពាក្យ **អសង្ខេយ្យឆ្នាំ** ត្រង់ឧបសម្ពន្ធខាងមុខ ។*

កាលមនុស្សអាយុចុះមកដល់ ៨០.០០០ ឆ្នាំនោះ បុរសស្ត្រីមានអាយុ ៥០០ ឆ្នាំ ទើបរៀបការជាគ្រួសារ ។ ពេលនោះ សូម្បីភ្លៀងទាំងឡាយក៏ភ្លៀងត្រូវកាល គឺ ១០ ថ្ងៃភ្លៀងម្ដងៗ ឬ ១៥ ថ្ងៃភ្លៀងម្ដង ។ សម័យកាលនោះ ក្នុងជម្ពូទ្វីប មនុស្សប្រុសស្រស់ស្អាតដូចជាទេវបុត្រ មនុស្សស្រីរូបស្រស់ស្អាតដូចជាទេពអប្សរក្នុងសួគ៌ា ។ កាលនោះឯង ក្រុងពារាណសី មានឈ្មោះថា **កេតុមតី** មានបណ្ដោយ ១៦ យោជន៍ ទទឹង ១ យោជន៍ មានទ្វារក្រុង ៤ និងដើមឈើកប្បព្រឹក្ស ៤ ដើម កំពែង ៧ ជាន់ សាងដោយកែវ ៧ ប្រការ[៩១] ។

គ្រានោះ **នឡការទេវបុត្រ** សោយសិរីសម្បត្តិក្នុងសួគ៌ានាទេវលោក ៦ ជាន់ បានច្យុតចាកអត្តភាពនោះ មកកើតជាស្ដេចចក្រពត្តិឈ្មោះ **សង្ខ:** ក្នុងក្រុងកេតុមតីនោះ ។ ដោយរាជានុភាពនៃស្ដេចចក្រពត្តិនោះ ប្រាសាទមាសសម្រេចហើយដោយកែវ ៧ ប្រការ ផុសចេញពីទន្លេគង្គា អណ្ដែតមកតាមអាកាស ប្រតិស្ឋានចំកណ្ដាលក្រុងកេតុមតី ។ ស្រះកែវបានកើតឡើងប្រាកដជិតប្រាសាទនោះ មានក្លិនក្រអូបគួរជាទីរីករាយ ដេរដាសទៅដោយផ្កាបទុម ៥ ប្រភេទគឺ **ឧប្បលខៀវ ឧប្បលស ឧប្បលក្រហម ឈូកក្រហម ឈូកស** ។ កំពែងស្រះបានសាងដោយមាស កែវពិទូរ្យ និងប្រាក់ ។ **ព្រះបាទសង្ខ:** មានជាយា ៨៤.០០០ នាក់ គង់នៅក្នុងប្រាសាទនោះ។ ព្រះរាជឱរស ១.០០០ អង្គ។

[៩១] កែវ ៧ ប្រការគឺ មាស ប្រាក់ កែវមុក្ដា កែវមណី កែវពិទូរ្យ ពេជ្រ កែវប្រពាឡ ។

ព្រះរាជឱរសច្បង មាននាមថា **អជិតកុមារ** ជាឧបយុវរាជ ។ ព្រះរាជាទ្រង់មានរតនៈ ៧ ប្រការគឺ **ចក្ករ័តន៍១ ហត្ថិរ័តន៍១ អស្សរ័តន៍១ មណិរ័តន៍១ ឥត្ថីរ័តន៍១ គហបតិរ័តន៍១** រាប់**បរិនាយករ័តន៍១** ផង ជាគម្រប់ ៧ ។ ព្រះបាទសង្ខៈនោះ ទ្រង់ត្រួតត្រាគ្រប់គ្រងដែនចក្រភព ប្រកបដោយធម៌ ដោយមិនបាច់ប្រើអាជ្ញា និងប្រើគ្រឿងសស្ត្រាវុធឡើយ ។ ក្នុងសម័យកាលនោះ មនុស្សទាំងឡាយក្នុងជម្ពូទ្វីប នឹងមានតែរោគជម្ងឺជាតិ ៣ យ៉ាងគឺ **ឃ្លានអាហារ១ បន្ទោបង់ទឹកមូត្រ (ទឹកនោម) និងលាមក១ និងចាស់ជរាមរណៈ១** ក្រៅពីនេះ ពុំមានជំងឺអ្វីផ្សេងទៀតមកបៀតបៀនឡើយ ។

## ព្រះពុទ្ធមេត្តេយ្យ ឬ ព្រះស្រីអារ្យមេត្រី

សម័យនោះ បុរោហិតរបស់ស្ដេចចក្រពត្តិ មាននាមថា **សុព្រហ្មព្រាហ្មណ៍** ជាអ្នកមានយសធំបន្ទាប់ពីព្រះរាជា ។ ភរិយារបស់បុរោហិតនោះ មាននាមថា **ព្រហ្មវតី** ។ ពេលនោះ ព្រះមេត្តេយ្យពោធិសត្វ ដែលពួកទេវតាទាំងឡាយអារាធនាហើយ ទ្រង់បានច្យុតចាកតុសិតបុរី មកចាប់បដិសន្ធិក្នុងគភ៌ព្រះនាងព្រហ្មវតីពេលជិតភ្លឺ ក្នុងថ្ងៃ ១៥ កើត ពេញបូណ៌មី ខែអាសាឍ។ ស្ដេចចាតុម្មហារាជិកា ក៏ចុះមកថែរក្សាគភ៌ព្រះនាងព្រហ្មវតី ។ គ្រប់ ១០ ខែបរិបូរ ទ្រង់ក៏ប្រសូតចាកគភ៌ព្រះមាតា ។ ព្រះមេត្តេយ្យពោធិសត្វទ្រង់គង់នៅ

ជាសុខក្នុងភាពជាយរាវាសធម៌ ក្នុងប្រាសាទ ៣ គឺ **សិរីវឌ្ឍនៈ១ សិទ្ធត្ថៈ១ ចន្ទកៈ១** ។ ព្រះពោធិសត្វមានស្នំ ១០០.០០០ នាក់ ចាំគាល់បម្រើ ។ មហេសីជាប្រធានលើស្នំទាំងនោះ មាននាមថា **ចន្ទមុខី** ។ បុត្ររបស់ព្រះពោធិសត្វមាននាមថា **ព្រហ្មវឌ្ឍនកុមារ** ។ ព្រះពោធិសត្វទ្រង់ឡើងកាន់រាជរថ ឆ្ពោះទៅឧទ្យាន ឃើញនូវនិម្មិត ៤ ប្រការគឺ **មនុស្សចាស់ មនុស្សឈឺ មនុស្សស្លាប់** និង **ភេទបព្វជិត** ក៏ទ្រង់នឿយណាយក្នុងភាពជាយរាវាស ដោយទ្រង់សព្វព្រះហឫទ័យក្នុងភេទបព្វជិត រួចក៏ត្រឡប់មកកាន់ប្រាសាទវិញ ។ ពេលនោះស្រាប់តែប្រាសាទអណ្តែតហោះឡើងឰដ៏អាកាស ដូចជាសត្វហង្ស ។ ពួកទេវតាទាំងឡាយបាននាំគ្នាយកកម្រងផ្កា មកបូជាចំពោះព្រះពោធិសត្វ ។ ស្តេចសង្ខចក្រពត្តិ ព្រមទាំងអ្នកនិគមជនបទ ៨៤.០០០ ក្រុង ក៏នាំគ្នាធ្វើការបូជាចំពោះព្រះពោធិសត្វដូចគ្នា ។ **ស្តេចអសុររាជ** ជាអ្នកថែរក្សាប្រាសាទ **ស្តេចនាគរាជ** បានកាន់យកកែវមណី **ស្តេចគ្រុឌ** កាន់យកខ្សែសង្វារក និង **ស្តេចគន្ធព្វ** លេងតូរ្យតន្ត្រីបូជាថ្វាយ ។ ស្តេចសង្ខចក្រពត្តិ ព្រមទាំងបរិវារបានប្រថាប់នៅជិតព្រះពោធិសត្វ ។ ដោយអានុភាពព្រះមហាពោធិសត្វ និងបរមរាជានុភាពស្តេចចក្រពត្តិ មហាជនដែលមានបំណងបព្វជ្ជា អាចហោះឡើងពីផែនដី ចូលទៅកាន់ប្រាសាទដែលកំពុងអណ្តែតឰដ៏អាកាស ។ កាលនោះឯង **ស្តេចមហាព្រហ្ម**កាន់យកឆត្រ ៦០ យោជន៍ មកបាំងពីលើប្រាសាទ។ **ស្តេចសក្កទេវរាជ** ទ្រង់វាយវិជ័យយុត្តរសង្ខ ។ **ស្តេចសុយាមទេព** ទ្រង់កាន់

ផ្ចិតវិជនីបក់ថ្វាយព្រះពោធិសត្វ ។ **ស្តេចតុសិតទេព** ទ្រង់ថ្វាយបាត្រកែវមណី ដល់ព្រះពោធិសត្វ ។ **បញ្ចសិខគន្ធព្វទេព** ឈរដេញពិណពណ៌លឿង ដែល ធ្វើពីកែវពិទូរ្យ ។ **ស្តេចមហាព្រហ្ម** កាន់ព្រះខ័នឈរការពារក្នុងទិសទាំង ៤ ។ ពួកមនុស្ស ទេវតា គន្ធព្វ យក្ខ នាគ និងគ្រុឌទាំងនោះ សុទ្ធតែចោមរោមព្រះ ពោធិសត្វ ។ កាលប្រាសាទហោះជិតដល់ពោធិមណ្ឌលហើយ ស្តេចមហា-ព្រហ្ម ក៏បង្អោនគ្រឿងបរិក្ខារ[៥២] ៨ ដែលសម្រេចអំពីឫទ្ធិថ្វាយព្រះពោធិសត្វ។

លំដាប់នោះឯង ព្រះពោធិសត្វសាងព្រះផ្នួស ដោយកាត់ព្រះមោលី (ផ្នួងសក់) ដោយព្រះខ័ន រួចបោះឡើងទៅឰដ៏អាកាស ។ បុរសជាច្រើន ក៏ បួសតាមព្រះពោធិសត្វ ។ ព្រះពោធិសត្វបំពេញព្យាយាមក្នុងព្រះផ្នួសអស់ ៧ ថ្ងៃ ទ្រង់ចូលទៅគង់ក្រោមដើមខ្នឹង ដែលមានកម្ពស់ពីគល់ដល់ចុង ២៤០ ហត្ថ មានមែកបែកជាបួន ។ ក្នុងមែកនីមួយៗ ប្រវែង ១២០ ហត្ថ មានស្លឹក ស្រស់ខ្ចីជានិច្ច ។ ព្រះពោធិសត្វទ្រង់គង់លើ **អបរាជិតបល្ល័ង្ក** ក្នុងបឋមយាម សម្រេចបុព្វេនិវាសានុស្សតិញ្ញាណ, ក្នុងមជ្ឈិមយាម សម្រេចនូវទិព្វចក្ខុញ្ញាណ, ក្នុងបច្ឆិមយាមនៃរាត្រី ទ្រង់ពិចារណានូវបច្ចយាការៈ ១២ ប្រការ[៥៣] ជាអនុ-លោមបដិលោមត្រឡប់ចុះឡើង ទ្រង់សម្រេចនូវសព្វញ្ញុតញ្ញាណ ក្នុងវេលា

---

[៥២] គ្រឿងបរិក្ខារ ៨ មានៈ សង្ឃាដី១ ចីវរ១ ស្បង់១ វត្ថពន្ធបង្កេះ១ បាត្រ១ កាំបិតកោរ១ ម្ជុល១ ធម្មក្រក ឬតម្រងទឹក១ ។

[៥៣] សូមមើលក្នុងបដិច្ចសមុប្បាទធម៌ ។

ជិតភ្ញី ក៏ត្រាស់ដឹងជាព្រះសម្មាសម្ពុទ្ធក្នុងលោក មានព្រះនាមថា **ព្រះអរិយ-មេត្តេយ្យ** ឬ **ព្រះស្រីអារ្យមេត្រី** ។ បន្ទាប់ពីព្រះអង្គទ្រង់ត្រាស់ដឹង ទ្រង់ប្រកាសសម្ដែងព្រះធម៌ ញ៉ាំងមនុស្សមួយសែនកោដិ និងទេវតារាប់ប្រមាណមិនបាន ឱ្យដល់នូវ**អមតរស** ពោលគឺ **ព្រះនិព្វាន** ។

ព្រះពុទ្ធអរិយមេត្តេយ្យនោះ មានព្រះវរកាយកម្ពស់ ៨៨ ហត្ថ ទទឹង ២៥ ហត្ថ ។ ពីផ្ទៃព្រះបាទរហូតដល់ព្រះជានុ ប្រវែង ២២ ហត្ថ, ពីព្រះជានុមណ្ឌលដល់ព្រះនាភី ប្រវែង ២២ ហត្ថ, ពីព្រះនាភី មកដល់ព្រះអក្ខកៈ ប្រវែង ២២ ហត្ថ ។ ពីព្រះអក្ខកៈមកដល់ឧណ្ហីសៈប្រវែង ២២ ហត្ថ ។ ព្រះហស្ថទាំង ២ ម្ខាងៗ ប្រវែង ៤០ ហត្ថ, ចន្លោះព្រះពាហាទាំង ២ ម្ខាងៗ ប្រវែង ២៥ ហត្ថ, ចន្លោះអក្ខកៈម្ខាងៗ ប្រវែង ៥ ហត្ថ, នៅចន្លោះពីព្រះអង្សាម្ខាងទៅព្រះអង្សាម្ខាង ប្រវែង ៥ ហត្ថ, ចន្លោះម្រាមព្រះហស្ថមួយទៅម្រាមព្រះហស្ថមួយ ប្រវែង ៤ ហត្ថ, ផ្ទៃព្រះហស្ថប្រវែង ៥ ហត្ថ, ព្រះសុរង់ប្រវែង ៥ ហត្ថ, ព្រះឱស្ឋខាងលើប្រវែង ១៥ ហត្ថ, ព្រះឱស្ឋខាងក្រោមប្រវែង ១៥ ហត្ថ, ព្រះជិវ្ហាប្រវែង ១០ ហត្ថ, ព្រះនាសកៈប្រវែង ៧ ហត្ថ, ព្រះនេត្រទាំងពីរម្ខាងៗ ប្រវែង ៧ ហត្ថ, ព្រះភមុកៈម្ខាងៗ ប្រវែង ៥ ហត្ថ, ចន្លោះភមុកៈទាំងពីរប្រវែង ៤ ហត្ថ, ព្រះកាណ៌ម្ខាងៗ ប្រវែង ៧ ហត្ថ, ដួងព្រះភក្ត្រ

ប្រវែង ២៥ ហត្ថ, ឧណ្ហីសៈជុំវិញប្រវែង ២៥ ហត្ថ ។ ព្រះពុទ្ធជាម្ចាស់ ទ្រង់ប្រកបព្រមដោយ**មហាបុរិសលក្ខណៈ ៣២ ប្រការ** និង**អនុព្យញ្ជនៈ ៨០** ។

ព្រះឆព្វណ្ណរង្សីបញ្ចេញរស្មី អំពីព្រះវរកាយរបស់ព្រះមានព្រះភាគជាម្ចាស់អង្គនោះ ហាក់ដូចជាខ្សែទឹកហូរធ្លាក់អំពីផ្ទាំងមាស មានពន្លឺភ្លឺលើសលុប លើសពន្លឺរបស់ដួងចន្ទ និងដួងអាទិត្យ ផ្សាយទៅក្នុងម៉ឺនចក្រវាល ពន្លឺភ្លឺស្វាងច្បាស់ប្រាកដតាំងនៅ រហូតអស់កាលទាំងយប់ទាំងថ្ងៃ ។ មនុស្សទាំងឡាយមិនអាចកំណត់ដឹងថា ពេលនេះជាពេលថ្ងៃ ឬពេលយប់ឡើយ ដោយព្រះពុទ្ធរស្មីបំភ្លឺក្នុងលោក ទាំងថ្ងៃទាំងយប់ ។ មនុស្សទាំងពួងដឹងថា នេះជាយាមយប់ នៅពេលដែលព្រះអាទិត្យអស្តង្គត ដោយសំឡេងសត្វមកកាន់សំបុក និងដោយត្របកស្រទាប់នៃផ្កាបទុម និងស្រទាប់នៃផ្កាឈើដែលបិទ ។ មនុស្សទាំងឡាយដឹងថា នេះជាពេលថ្ងៃ ជាពេលដែលព្រះអាទិត្យរះឡើង ដោយសំឡេងសត្វចេញហើរទៅរកស៊ី និងដោយស្រទាប់នៃផ្កាបទុម និងផ្កាឈើរីកឡើង ។ លំដាប់នោះ បទុមផ្កាធំៗ មានត្របកស្រទាប់ក្រៅ ៣០ ហត្ថ ស្រទាប់ខាងក្នុង ២៥ ហត្ថ កេសរ ២០ ហត្ថ មានទង ១៦ ហត្ថ លម្អងកេសរបានផ្សាយទៅក្នុងអាកាស ជ្រែកប្រឹថពីដុះឡើងរង់ចាំទទួលស្នាមព្រះបាទដែលទ្រង់ឈានទៅហើយ គ្រប់ៗជំហាននៃការឈានព្រះបាទរបស់ព្រះសម្មាសម្ពុទ្ធអង្គនោះ ។

មនុស្សទាំងពួង មិនចាំបាច់ត្រូវទៅភ្ជួរស្រែ ធ្វើចម្ការ ជួញដូរ និងមិនមានរោគភ័យបៀតបៀនឡើយ គឺសម្បូរដោយភោគផលទ្រព្យសម្បត្តិ និងសេចក្តីសុខ មានពុទ្ធានុស្សតិជាអារម្មណ៍ បរិភោគបាយនៃអង្ករស្រូវសាលីដែលជាភោជនាហារកើតដោយពុទ្ធានុភាព ស្លៀកពាក់សំពត់អាវ គ្រឿងអាភរណៈ និងគ្រឿងរក្សាជីវិតកើតឯងពីផ្កា ស្លឹក និងដើមនៃរុក្ខជាតិ ។ កាលព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់សម្តែងធម្មចក្រ ទេវតាប្រមាណ ៣០ កោដិ បានត្រាស់ដឹងធម៌ ។

## ២-អតីតជាតិនៃព្រះពោធិសត្វអរិយមេត្តេយ្យ

ព្រះពុទ្ធបរមគ្រូនៃយើង ទ្រង់ត្រាស់ជាមួយនឹងព្រះសារីបុត្រថា :

"ម្នាលសារីបុត្រ ព្រះពុទ្ធអរិយមេត្តេយ្យអង្គនោះ ទ្រង់បានបំពេញបារមី ១០ ប្រការ មានបារមីមួយប្រាកដជាក់ច្បាស់ជាងគេ ទ្រង់បានទទួលពុទ្ធសម្បត្តិក្នុងលោក ដោយពុទ្ធសិរីដែលមិនមានអ្វីប្រៀប ដោយពុទ្ធលីលារកទីបំផុតគ្មាន ដោយប្រការដូច្នេះ" ។

លំដាប់នោះ ព្រះសារីបុត្រក្រាបទូលព្រះបរមសាស្តាថា :

"បពិត្រព្រះអង្គដ៏ចម្រើន បារមីមួយប្រាកដដល់ព្រះអរិយមេត្តេយ្យ តើដូចម្តេច?"

ព្រះបរមសាស្តា ទ្រង់នាំយកអតីតនិទានមកសម្តែងថា :

"ម្នាលសារីបុត្រ ក្នុងសម័យកាល **ព្រះពុទ្ធសិរិមត្តៈ** ទ្រង់ត្រាស់ដឹងក្នុងលោក កាលនោះ អរិយមេត្តេយ្យពោធិសត្វ ទ្រង់កើតជាស្តេចនាមព្រះបាទសង្ខចក្រពត្តិរាជ[៥៨] ក្នុងឥន្ទបត្តនគរ ។ ព្រះរាជាអង្គនោះទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការគឺ **ចក្ករ័តន៍១ ហត្ថិរ័តន៍១ អស្សរ័តន៍១ មណិរ័តន៍១ ឥត្ថីរ័តន៍១ គហបតិរ័តន៍១ បរិនាយករ័តន៍១** ។ ឥន្ទបត្តនគរមានបណ្តោយ ៧ យោជន៍ ទទឹង ៣ យោជន៍ មានទ្វារក្រុង ៤ និងដើមកប្បព្រឹក្ស ៤ ដើម ដុះត្រង់កណ្តាលក្រុងមានប្រាសាទមួយខ្ពង់កម្ពស់ ៧ ជាន់ បណ្តោយ ២ យោជន៍ ហើយព្រះបាទសង្ខៈទ្រង់សោយមហាសម្បត្តិក្នុងប្រាសាទនោះ ។ សម័យនោះ **ព្រះពុទ្ធសិរិមត្តៈ** ទ្រង់ឧប្បត្តិឡើងក្នុងលោក ។ ព្រះពុទ្ធអង្គនោះទ្រង់គង់ប្រថាប់ឆ្ងាយអំពីឥន្ទបត្តនគរ ប្រមាណ ១៦ យោជន៍ ។ ព្រះរាជា

[៥៨] ព្រះបាទសង្ខចក្រពត្តិរាជ ជាអង្គពោធិសត្វអរិយមេត្តេយ្យ ដែលមាននាមដូចព្រះបាទសង្ខចក្រពត្តិ នៃក្រុងកេតុមតី នាសម័យព្រះមេត្តេយ្យសម្ពុទ្ធទ្រង់ត្រាស់ដឹងដែរ ។

ទ្រង់មិនបានជ្រាបថា ព្រះពុទ្ធជាម្ចាស់ទ្រង់ត្រាស់ដឹងក្នុងលោក ឡើយ"។

សម័យកាលនោះ ថ្ងៃមួយ ព្រះបាទសង្ខចក្រពត្តិប្រថាប់លើបល្ល័ង្ក នៅខាងក្រោមម្លប់នៃស្វេតច្ឆត្រ ទ្រង់តាំងសេចក្តីប្រាថ្នាទុកយ៉ាងនេះថា៖

"យើងនឹងប្រគល់រាជសម្បត្តិរបស់ស្តេចចក្រពត្តិ ដល់អ្នកដែលប្រាប់អំពីដំណឹង **ព្រះពុទ្ធរតនៈ ព្រះធម្មរតនៈ ព្រះសង្ឃរតនៈ** ដល់យើង ហើយយើងនឹងទៅកាន់សម្នាក់របស់ព្រះពុទ្ធអង្គនោះ"។

មាន**កុលបុត្រទលិទ្ទកជន** (អ្នកក្រីក្រ) ម្នាក់បានបួសជាសាមណេរក្នុងសាសនាព្រះពុទ្ធជាម្ចាស់អង្គនោះ មាតារបស់សាមណេរនោះ ជាទាសីរបស់អ្នកដទៃ ។ សាមណេរនោះគិតថា៖

"អាត្មាអញនឹងស្វែងរកទ្រព្យ ជួយរំដោះញោមស្រីចេញពីទាសីរបស់អ្នកដទៃ ដើម្បីឱ្យញោមស្រីរបស់អាត្មាអញមានសេរីភាព"។

កាលស្វែងរកទ្រព្យ សាមណេរនោះក៏និមន្តចូលទៅកាន់នគរនោះ។ អ្នកនៅក្នុងនគរបានឃើញសាមណេរ មិនស្គាល់លោក (ថាជាអ្វី) ឡើយ ក៏នាំគ្នាយកដំបងដេញវាយសាមណេរនោះ ដោយយល់ឃើញថា "**សាមណេរនោះជាយក្ស**" ទៅវិញ ។ សាមណេរមានការភ័យខ្លាចជាខ្លាំង ក៏រត់ចូលទៅ

កាន់ព្រះរាជវាំង ឈរនៅចំពោះព្រះភក្ត្រព្រះរាជា ។ កាលព្រះរាជាទត ឃើញសាមណេរ ទើបត្រាស់សួរថា :

"នែមាណព អ្នកចូរមកចុះ! តើអ្នកមានឈ្មោះអ្វី?"

សាមណេរទូលថា :

"បពិត្រមហារាជ អាត្មាភាពឈ្មោះសាមណេរ" ។

ព្រះរាជា :

"នែមាណព ហេតុដូចម្ដេចបានជាអ្នកមានឈ្មោះថាសាមណេរ?"

សាមណេរ :

"បពិត្រមហារាជ អាត្មាភាពជាអ្នកមិនធ្វើអំពើបាប ទាំងផ្លូវកាយ វាចា និងចិត្ត ជាអ្នកញុំាំងកុសលឱ្យតាំងនៅមាំ ដូច្នេះទើបមានឈ្មោះថា **សាមណេរ**" ។

ព្រះរាជា :

"បុគ្គលណាជាអ្នកដាក់ឈ្មោះឱ្យអ្នក?"

សាមណេរ :

"បពិត្រមហារាជ អាចារ្យរបស់អាត្មាភាពបានដាក់ឱ្យឈ្មោះនេះ ដល់អាត្មាភាព" ។

ព្រះរាជា :

"នែមាណព អាចារ្យរបស់អ្នកមានឈ្មោះដូចម្ដេច?"

សាមណេរ :

"បពិត្រមហារាជ អាចារ្យរបស់អាត្មាភាពមានឈ្មោះថា **ភិក្ខុ**" ។

ព្រះរាជា :

"អាចារ្យរបស់អ្នកមានឈ្មោះថា **ភិក្ខុ** ព្រោះហេតុដូចម្ដេច?"

សាមណេរ :

"មហាបពិត្រ អាចារ្យរបស់អាត្មាភាព ឈ្មោះថា **ភិក្ខុ** ព្រោះជា **ព្រះសង្ឃរតនៈ** ដែលរកអ្វីកាត់ថ្លៃមិនបាន" ។

ព្រះរាជា ទ្រង់ស្ដាប់ព្ទដំណឹងដែលកម្រព្ទ ស្រាប់តែស្រាលខ្លួន ហោះឡើងផុតអំពីបល្ល័ង្ក ទៅធ្លាក់ចុះក្នុងសម្នាក់សាមណេរ ។ ក្នុងពេលដែលព្រះរាជាប្រថាប់ឈរក្បែរជើងសាមណេរ ផ្កាឈូកប៉ុនកង់រទេះផុសចេញអំពីផែនដី ទ្រទទួលព្រះរាជានោះ ដោយអានុភាពបីតិរបស់ព្រះអង្គ ។

ព្រះរាជាបានគង់ប្រថាប់លើផ្កាឈូក ផ្គងអញ្ជលីសំពះសាមណេរ ហើយត្រាស់សួរថា :

"បពិត្រសាមណេរ អ្នកណាឲ្យនាមលោកអាចារ្យរបស់លោកថា **ភិក្ខុជាសង្ឃរតនៈ**ដែលរកអ្វីប្រៀបមិនបានដូច្នេះ?"

សាមណេរទូលថា :

"បពិត្រមហារាជ ព្រះនាមនេះ គឺព្រះពុទ្ធជាម្ចាស់ព្រះនាម **សិរិមត្តៈ** ទ្រង់ប្រទានឱ្យ" ។

ព្រះរាជាគ្រាន់តែស្តាប់ឮសំឡេងថា **ពុទ្ធោ** ក៏ទ្រង់មានវិសញ្ញិភាព (សន្ធប់) ព្រោះទ្រង់រន្ធត់ដោយសេចក្តីត្រេកអរដ៏ខ្លាំង ។

ក្រោយមក ព្រះរាជាទ្រង់ដឹងខ្លួន ទើបត្រាស់សួរសាមណេរបន្តទៀតថា :

"បពិត្រសាមណេរដ៏ចម្រើន ព្រះពុទ្ធជាម្ចាស់ទ្រង់គង់ប្រថាប់នៅទីណា?"

សាមណេរ :

"បពិត្រមហារាជ ព្រះដ៏មានព្រះភាគជាម្ចាស់ ទ្រង់គង់ប្រថាប់នៅក្នុងបុព្វារាម ចម្ងាយ ១៦ យោជន៍ អំពីទិសខាងជើងនៃនគរនេះ" ។

ព្រះរាជាត្រាស់ថា :

"បពិត្រសាមណេរ យើងនឹងទៅតាមទិសដែលមានព្រះពុទ្ធជាម្ចាស់ គង់ប្រថាប់" ។

ខណៈនោះ ព្រះរាជាទ្រង់គង់នៅស្ងៀមមួយស្របក់ មិនអើពើ ហើយទ្រង់បានអភិសេកសាមណេរឲ្យជាព្រះចៅចក្រពត្តិជំនួសព្រះអង្គ ដោយព្រះទ័យរីករាយ ឥតមានអាឡោះអាល័យសូម្បីតែបន្តិចឡើយ ។

ព្រះរាជា កាលទ្រង់អភិសេកសាមណេរក្នុងរាជសម្បត្តិហើយ ព្រះអង្គទ្រង់ឆ្ពោះព្រះភក្ត្រទៅទិសឧត្តរ ដើម្បីយាងទៅកាន់ទីគង់អាស្រ័យរបស់ព្រះពុទ្ធសិរិមត្តៈជាម្ចាស់តែមួយព្រះអង្គឯង ។ កាលព្រះរាជាអង្គនោះ ទ្រង់ជាក្សត្រសុខុមាលជាតិ ស្ដេចយាងទៅដោយព្រះបាទផ្ទាល់ក្នុងរយៈពេលត្រឹមតែមួយថ្ងៃ ព្រះបាទក៏បែកព្រះលោហិតហូរចេញអំពីព្រះបាទទាំងគូ កាលព្រះបាទទាំងគូបែកហូរព្រះលោហិតហើយ ព្រះរាជាទ្រង់វារដោយព្រះជានុនិងព្រះហស្តទាំង ២ អស់រយៈពេល ៣ ថ្ងៃ ។ ក្នុងថ្ងៃទី៤ ព្រះលោហិតទើបហូរចេញអំពីព្រះហស្ត និងព្រះជានុទាំង ២ ។

ក្នុងកាលនោះ ព្រះរាជាទ្រង់មានព្រះតម្រិះថា :

**"យើងនឹងទៅដោយការលូនយ៉ាងនេះ"** ។

ទើបទ្រង់ធ្វើដំណើរដោយការលូនដោយព្រះឱរៈ (ទ្រូង) ក្នុងពេលជាខាងក្រោយ ។ កាលព្រះរាជាលូនទៅដោយព្រះឱរៈនោះ ទ្រង់លំបាកយ៉ាងខ្លាំងក្លា តែក៏ទ្រង់មិនមានឆន្ទៈដាក់ចុះ ដោយមានព្រះទ័យមោះមុត ដើម្បីឆ្ពោះទៅគាល់ព្រះពុទ្ធសិរិមត្តៈ ដែលជាគោលសំខាន់ ទើបទ្រង់ខំអត់ទ្រាំទាំងទុក្ខវេទនា ក្នុងការធ្វើដំណើរដោយលូនបន្តទៅទៀត ។

ក្នុងកាលនោះ ព្រះដ៏មានព្រះភាគជាម្ចាស់ **ព្រះសិរិមត្តៈ** ទ្រង់មានព្រះមហាករុណាទិគុណ ប្រមើលមើលសត្វលោកដោយសព្វញ្ញុតញ្ញាណ ឃើញនូវកម្លាំងនៃវីរភាពរបស់ព្រះរាជាអង្គនោះ ទើបទ្រង់ព្រះចិន្តាថា :

> "ព្រះរាជាអង្គនេះ **ជាពុទ្ធង្កូរ ពុទ្ធពីជ និងជាពុទ្ធវង្ស** ព្រោះអាស្រ័យតថាគត ទើបសោយទុក្ខដ៏ធ្ងន់ ដូច្នេះ តថាគតនឹងទៅកាន់សម្នាក់របស់ព្រះរាជាអង្គនោះ" ។

ខណៈនោះ ទើបព្រះពុទ្ធដ៏មានសិរីប្លែងអត្តភាព ជាបុរសម្នាក់បររថឆ្ពោះទៅកាន់ទីព្រះបាទសង្ខៈនោះ ។ កាលព្រះពុទ្ធជាម្ចាស់យាងទៅដល់បានប្រថាប់ឈប់នៅចំពោះព្រះភក្ត្រស្តេចចក្រពត្តិ ។ ព្រះដ៏មានព្រះភាគជាម្ចាស់ ក៏ទ្រង់ត្រាស់ថា :

"ម្នាលអ្នកដ៏ចម្រើន ហេតុអ្វីបានជាអ្នកមកដេកត្រង់កណ្តាលផ្លូវបែប ហ្នឹង ចូរអ្នកក្រោកចេញឲ្យឆាប់ យើងប្រញាប់បររថទៅមុខ" ។

ព្រះរាជាទ្រង់ស្តាប់ព្រះតម្រាស់នេះហើយ ត្រាស់ថា ៖

"ម្នាលនាយសារថីដ៏ចម្រើន យើងដើរចំផ្លូវឆ្ពោះមុខត្រង់ទីដែលគួរ ទៅ ហេតុអ្វីទើបត្រូវថយចេញ យើងប្រកាន់យកព្រះពុទ្ធជាម្ចាស់ជា ប្រមុខ មានព្រះពុទ្ធជាម្ចាស់ជាអារម្មណ៍ ទោះបីអ្នកបញ្ជាររថរបស់ អ្នកឱ្យជាន់លើខ្លួនប្រាណរបស់យើងក្តី យើងនឹងមិនចៀសចេញ អំពីផ្លូវនេះទេ" ។

ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា ៖

"ម្នាលមាណពដ៏ចម្រើន ប្រសិនបើអ្នកទៅកាន់សម្នាក់របស់ព្រះពុទ្ធ ជាម្ចាស់នុ៎ះ ចូរអ្នកឡើងរថយើងចុះ យើងនឹងទៅកាន់សម្នាក់របស់ ព្រះពុទ្ធជាម្ចាស់ដែរ" ។

ព្រះរាជាទ្រង់ស្តាប់ពាក្យនោះហើយ ទ្រង់ទទួលពាក្យថា "**ល្អហើយ យើងនឹងឡើងលើរថរបស់អ្នក**" ។ គ្រានោះ ព្រះមានព្រះភាគជាម្ចាស់ ស្តេច បែរព្រះភក្ត្រទៅកាន់វត្តបុព្វារាម ជាមួយនឹងព្រះរាជា ។ កាលព្រះសាស្តាយាង

ដល់ត្រឹមកណ្តាលផ្លូវ ក្នុងកាលនោះ នាងសុជាតាចុះអំពីឋានតាវត្តិង្ស បាន និម្មិតភេទជាបុរសកាន់ផ្នាំងបាយទិព្វ១ មកឈរពីមុខរថ ហើយពោលថា :

"ម្នាលនាយសារថីដ៏ចម្រើន ប្រសិនបើលោកត្រូវការបាយទិព្វមួយ ផ្នាំងនុ៎ះ យើងនឹងឱ្យដល់លោក តែបើលោកមិនត្រូវការទេ យើងនឹងបោះចោល" ។

នាយសារថីពោលថា :

"ម្នាលមាណពដ៏ចម្រើន ខ្ញុំមានបុរសម្នាក់មានទុព្វលភាព សូមអ្នកឱ្យបាយដល់យើង ដើម្បីបុរសនេះចុះ" ។

នាងសុជាតា ក៏បានឱ្យភត្តដល់នាយសារថី ហើយរំពេចនោះ ក៏រលាយខ្លួនបាត់ទៅ ។

លំដាប់នោះ ព្រះមានព្រះភាគជាម្ចាស់ទទួលភត្តហើយ ក៏ប្រទានដល់ព្រះរាជា ។ ក្នុងកាលនោះ សក្កទេវរាជទ្រង់បានយកទឹកទិព្វ យាងចុះអំពីសួគ៌ជាន់តាវត្តិង្ស ប្លែងភេទជាបុរសស្ពាយទឹកមួយបំពង់មកឈប់មុខរថ រួចមានព្រះឱង្ការនឹងនាយសារថី ដូចដំណើរនាងសុជាតាដែរ ។

ព្រះបាទសព្វចក្រពត្តិ ទ្រង់ក៏បានសោយព្រះក្រយាទិព្វ ទឹកទិព្វ ។ ក្នុងពេលដែលសោយរួចស្រេចហើយ ដោយអានុភាពព្រះក្រយាទិព្វ ទឹក

ទិព្វ ស្នាមរបួសទាំងពួងក៏វិនាសអស់ទៅ ។ ពេលនោះ ព្រះរាជាមានសេចក្ដីសុខ ទាំងផ្លូវកាយ និងផ្លូវចិត្តឡើងវិញ ។

ក្រោយពី **ព្រះពុទ្ធសិរិមត្តៈ** យាងទៅដល់វត្តបុព្វារាមហើយ ព្រះអង្គត្រឡប់ពីភេទនាយសារថីមកជាពុទ្ធអង្គវិញ ហើយគង់ប្រថាប់លើពុទ្ធាសនៈដែលក្រាលទុក ។ ក្នុងវេលាដែលព្រះដ៏មានព្រះភាគជាម្ចាស់គង់ប្រថាប់ក្នុងវត្តបុព្វារាម ព្រះរាជាស្ដេចចុះអំពីរថ ទ្រង់ចូលទៅក្នុងវត្តបុព្វារាម គ្រាន់តែទតព្រះនេត្រឃើញពុទ្ធរស្មីភ្លាម ទ្រង់ក៏មានវិសញ្ញីភាពម្ដងទៀត ។ ព្រះសាស្ដាត្រាស់ថា "ម្នាលមហាបុរស ព្រះពុទ្ធជាម្ចាស់គង់ប្រថាប់នៅក្នុងទីនេះ" ។ ភ្លាមនោះ ព្រះរាជាក៏ទ្រង់ដឹងព្រះកាយឡើង ហើយស្ដេចយាងចូលទៅជិតព្រះបរមសាស្ដា ប្រថាប់ក្នុងទីដ៏សមគួរ រួចផ្គងអញ្ជលី ក្រាបបង្គំទូលព្រះដ៏មានព្រះភាគជាម្ចាស់ដូច្នេះថា :

"បពិត្រព្រះអង្គដ៏ចម្រើន ព្រះអង្គជាប្រធាននៃលោក ព្រះអង្គជាទីពឹងរបស់សត្វលោក សូមព្រះអង្គទ្រង់សម្ដែងធម៌ដ៏ខ្ពស់បំផុត (អមតធម៌) មួយគាថា ដល់ខ្ញុំព្រះអង្គផងចុះ" ។

ព្រះពុទ្ធជាម្ចាស់ ទ្រង់ត្រាស់ថា :

"មហាបពិត្រ សូមព្រះអង្គទ្រង់ព្រះសណ្ដាប់ ពិចារណានូវធម្មកថាគឺ **និព្វាន** ចុះ" ។

គ្រានោះ ព្រះអង្គក៏ទ្រង់សម្តែងព្រះធម៌ប្រោសដល់ព្រះរាជាថាៈ

"**និព្វានំ បរមំ សុខំ** = ព្រះនិព្វានជាបរមសុខដ៏ក្រៃលែង"[៥៥] ។

ព្រះរាជាទ្រង់ស្តាប់ព្រះធម្មកថាហើយ ទូលឃាត់ថា :

"បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះដ៏មានព្រះភាគសម្តែងធម៌ ត្រឹមប៉ុណ្ណោះចុះ សូមព្រះអង្គកុំសម្តែងព្រះធម្មកថាដទៃទៀតឡើយ" ។

**សំណួរថា** : "ព្រោះហេតុអ្វី ទើបព្រះរាជាទ្រង់អង្វរឃាត់ព្រះពុទ្ធជាម្ចាស់មិនឱ្យព្រះអង្គសម្តែងព្រះធម៌បន្តទៀត ?"

**ចម្លើយថា** : ព្រះរាជាទ្រង់ព្រះតម្រិះថា :

"ប្រសិនបើព្រះពុទ្ធជាម្ចាស់ ទ្រង់សម្តែងព្រះធម៌ច្រើនជាងនេះ យើងនឹងមិនមានទេយ្យធម៌ដែលគួរដល់ការបូជាទេ យើងស្តាប់ព្រះធម៌មួយបទនេះ យើងនឹងថ្វាយទានដ៏លើសលប់របស់យើង ដែលគួរដល់ការបូជា ព្រោះហេតុនេះបានជាព្រះរាជាទ្រង់ទូលអង្វរឃាត់"។

ក្នុងកាលនោះ ព្រះបាទសង្ខចក្រ ទ្រង់ក្រាបទូលព្រះដ៏មានព្រះភាគជាម្ចាស់ដូច្នេះថា :

[៥៥] បិដកលេខ ៥២ ទំព័រ ៦៤ ។

"បពិត្រព្រះអង្គដ៏ចម្រើន កាលព្រះអង្គទ្រង់សម្តែងព្រះនិព្វាន ដែលជាធម៌វិសេសលើសលប់ ជាធម៌ខ្ពស់បំផុតជាងធម៌ទាំងពួង ខ្ញុំព្រះអង្គសូមកាត់សីសៈ ដែលជាអវយវៈដ៏ខ្ពស់បំផុត ជាងអវយវៈទាំងពួងរបស់ខ្ញុំព្រះអង្គ ដើម្បីបូជាព្រះធម៌ចំពោះព្រះអង្គ ដែលជាការបូជាដ៏វិសេសណាស់" ។

ពេលដែលត្រាស់ហើយ ទើបទ្រង់កាត់ព្រះសីសៈដោយក្រចក រួចដាក់ព្រះសីសៈនោះលើបាទព្រះហស្ត ហើយទ្រង់ត្រាស់គាថាមួយថា :

ភន្តេ សិរិមត្តពុទ្ធ អមតំ យាជ ប្បរតោ
ឥមិនា សីសទានេន បច្ឆតោ យាមិ និព្វានំ ។

ប្រែ : បពិត្រព្រះពុទ្ធសិរិមត្តៈដ៏ចម្រើន សូមព្រះអង្គទ្រង់ទម្លុះនូវអមតធម៌មុនចុះ ដោយការថ្វាយសីសៈនេះ ខ្ញុំព្រះអង្គសូមសម្រេចព្រះនិព្វានក្នុងកាលជាខាងក្រោយ ។

***នេះជាភាពអស្ចារ្យរបស់ព្រះពោធិសត្វមេត្តេយ្យ ទោះបីព្រះសីសៈត្រូវកាត់ចេញពីព្រះសូរងហើយក៏ដោយ ក៏ព្រះពោធិសត្វនៅមិនទាន់ចូលទិវង្គតភ្លាមឡើយ ទ្រង់អាចពោលគាថាថ្វាយព្រះពុទ្ធសិរិមត្តៈបានយ៉ាងនេះទៀត ។***

ក្នុងវេលាចប់ព្រះគាថា ដូចបានពណ៌នាមក ព្រះរាជាក៏ច្យុតទៅកើតក្នុងតុសិតបុរី ។

ព្រះពុទ្ធសមណគោតមបរមគ្រូ ទ្រង់ត្រាស់បន្តទៀតថា :

"ម្នាលសារីបុត្រ បារមីមួយដែលប្រាកដជាក់ច្បាស់ គឺមានប្រការដូចបានបរិយាយមកយ៉ាងនេះឯង ។ ម្នាលសារីបុត្រ ព្រះមានព្រះភាគជាម្ចាស់ ទ្រង់ព្រះនាមថា **អរិយមេត្តេយ្យ** ព្រោះផលនៃការថ្វាយសីសៈឱ្យជាទាន ទ្រង់មានព្រះវរកាយខ្ពស់ ៨៨ ហត្ថ ព្រោះផលនៃការហូរឈាមធ្លាក់អំពីព្រះបាទ និងព្រះជានុ (ជង្គង់) ទើបទ្រង់មានពន្លឺភ្លឺទាំងយប់ទាំងថ្ងៃ ។ ព្រោះផលនៃលោហិត ដែលហូរធ្លាក់អំពីព្រះសីសៈ ព្រះពុទ្ធរស្មីនឹងមានដល់**អវិចីនរក** និង**ភវគ្គព្រហ្ម** ។ ព្រោះផលនៃលោហិតលើព្រះសីសៈ នឹងមានពន្លឺភ្លឺស្វាងអំពីព្រះឧណ្ណាលោម (រោមប្រជុំចិញ្ចើម) មិនអាចកំណត់បាន ។ ព្រោះផលដែលទ្រង់យាងដើរ ១ សប្តាហ៍ ទើបកើតឡើងនូវដើមកប្បព្រឹក្សមួយដើម ។ ម្នាលសារីបុត្រ ជនទាំងឡាយដែលមិនបានឃើញតថាគតក្នុងកាលឥឡូវនេះ ប្រសិនបើជនទាំងនោះធ្វើទាន រក្សាសីល ចម្រើនភាវនា ដោយផលនៃកុសលកម្មនោះ នឹងបានកើត

ក្នុងសម័យកាលនៃព្រះពុទ្ធជាម្ចាស់ព្រះនាម **អរិយមេត្តេយ្យ** ជាក់ជាមិនខាន" ។

ដូចបានអធិប្បាយកន្លងមក យើងអាចសន្និដ្ឋានថា :

" ព្រះអរិយមេត្តេយ្យ ទ្រង់បានសាងពុទ្ធការកធម៌ ក្រាស់ដោយវិរិយៈ គឺការព្យាយាមជាវិរិយាធិក អស់ ១៦ អសង្ខេយ្យ និង ១ សែនកប្ប បន្ទាប់ពីបានទទួលព្យាករណ៍លើកទី១" ៕

(ចប់ប្រវត្តិព្រះអរិយមេត្តេយ្យដោយសង្ខេប)

# ជំពូកទី ៨

# មាលាជាតក

សូមលើកករម្រង់ជាតកដែលសម្ដែងដោយព្រះសម្មាសម្ពុទ្ធ ដូចតទៅ:

## ១. សកុណជាតក

មានរឿងតំណាលថា តាំងពីយូរលង់ណាស់មកហើយ មានសត្វចាបមួយហ្វូង រស់នៅដោយសុខសាន្តនាព្រៃមួយ ក្បែរក្រុងពារាណសី ។ សត្វចាបទាំងនោះ តែងមកស្នាក់អាស្រ័យលើដើមឈើមួយដើម ដែលមានស្លឹកស៊ុបទ្រុប ព្រមទាំងបែកមែកសាខាចេញគ្រប់ទិស ។

ថ្ងៃមួយ មេហ្វូងនៃសត្វចាបសង្កេតឃើញនៅពេលខ្យល់បក់មកម្ដងៗ នាំឱ្យមែកឈើពីរកូតគ្នាធ្លាក់ធូលីចុះមក ព្រមទាំងមានផ្កាភ្លើង ខ្ទាតធ្លាក់លើស្លឹកឈើងាប់ទៀតផង ។ ដោយឃើញនូវព្រឹត្តិការណ៍យ៉ាងនេះ មេហ្វូងចាបក៏ពិចារណាថា :

ពេលនេះជារដូវប្រាំងក្ដៅរីងហួតហែង ផ្កាភ្លើងនេះនឹងអាចបណ្ដាលឱ្យមានភ្លើងឆេះព្រៃនៅទីនេះជាមិនខាន ហើយដើមឈើនេះ នឹងក្លាយជាចំណីភ្លើង ។ ពួកយើងមិនអាចនៅទីនេះតទៅទៀតទេ យើងត្រូវតែហើរស្វែងរកទីកន្លែងថ្មីទៀត ។

មេហ្វូងចាបពិចារណាដូច្នោះហើយ ក៏ពោលទៅកាន់ហ្វូងរបស់ខ្លួនដូច្នេះថា :

ម្នាលអ្នកទាំងឡាយ ផែនដីបង្កើតដើមឈើ ដែលយើងទាំងអស់គ្នាពឹងស្នាក់អាស្រ័យនៅ ហើយដើមឈើនេះ នឹងត្រូវភ្លើងឆាបឆេះនៅពេលដ៏ខ្លីខាងមុខ ។ បើដូច្នេះ ចូរយើងទាំងអស់គ្នាត្រូវប្រយ័ត្នចំពោះទីជ្រករបស់យើង ព្រោះវានឹងក្លាយជាទីគ្រោះថ្នាក់ជាមិនខាន ។ ចូរអ្នកទាំងអស់គ្នា ប្រញាប់ហើរចេញពីទីនេះ ឱ្យឆ្ងាយបំផុត ។

ពោលដូច្នេះហើយ មេហ្វូងចាបក៏ហើរចេញពីទីនោះ ដោយមានសត្វចាបមួយហ្វូងធំហើរទៅតាមជាមួយផង ។

ឯសត្វចាបមួយក្រុមទៀតឃើញដូច្នេះ ក៏នាំគ្នាពោលចំអកថា :

គ្រាន់តែអ៊ីចឹងសោះ ក៏នាំគ្នាផ្អើលឆោឡោដែរ ។ កុំឆោតពេកពួកយើង អាគាត់ហ្នឹង សូម្បីតែទឹកមួយដំណក់ ក៏គាត់មើលឃើញមានក្រពើដែរ ។

ពោលរួចហើយ ពួកគេក៏នាំគ្នាសើចអឺងកងឡើង ។ សំណើចចំអកក្អាកក្អាយរបស់គេមិនទាន់ចប់ស្រួលបួលផង ភ្លើងព្រៃក៏ឆាបឆេះសន្ធោសន្ធៅឡើង ពេញដើមឈើទាំងមូល ។ ផ្សែងនិងអណ្តាតភ្លើង ឆេះអួអាប់ខ្មៅងងឹត

បណ្តាលឱ្យសត្វទាំងនោះមានការភិតភ័យតក់ស្លុតស្រឡាំងកាំង រកច្រក ហើរចេញពីទីនោះពុំរួច ហើយក៏ត្រូវអណ្តាតភ្លើងដ៏សាហាវ ឆាបឆេះក្សិណក្ស័យក្នុងគ្រានោះទៅ ។

ព្រះសម្មាសម្ពុទ្ធទ្រង់មានពុទ្ធដីកាបញ្ចប់នូវរឿងចាបមានប្រាជ្ញានោះថា :

សូម្បីតែសត្វចាប ដែលរស់នៅតាមចុងឈើ ក៏អាចយល់ឃើញថា នៅទីណាមានសេចក្តីសុខ ទីណាពុំមានសេចក្តីសុខ សម្រាប់ជីវិតរបស់គេដែរ ។

**ចុះចំណង់បើយើងជាមនុស្ស យើងត្រូវដឹងថា ទីណាដែលអាចផ្តល់សេចក្តីសុខដល់យើងបាន ។**

ព្រះអង្គទ្រង់ត្រាស់បញ្ជាក់ថា មេហ្វូងនៃសត្វចាប ជាតួអង្គព្រះពោធិសត្វ ដែលសរជាតិមកកើតជាតួអង្គនៃតថាគតនេះឯង ៕

## កំណត់ពីអ្នកនិពន្ធ

សូមលោកអ្នកអានជាទីគោរព មេត្តាពិភាក្សានូវគតិបណ្ឌិតនៃរឿងនេះ ព្រមទាំងលក្ខណៈនៃតួអង្គ ដើម្បីយកមកអនុវត្តក្នុងមាគ៌ាជីវិត ។

**តើព្រះពោធិសត្វទ្រង់បានសាងបារមីអ្វីក្នុងជាតិនេះ ?**

## ២. សម្មោទមានជាតក

មានរឿងតំណាលថា កាលពីព្រេងនាយ ព្រះពោធិសត្វចាប់កំណើតជាសត្វក្រួចនៅក្នុងព្រៃមួយនាក្រុងពារាណសី ហើយមានសត្វក្រួចជាច្រើនពាន់ នៅក្រោមការដឹកនាំរបស់សត្វក្រួចជាព្រះពោធិសត្វ ។ កាលនោះមានព្រានព្រៃម្នាក់តែងតែទៅរកទាក់សត្វក្រួច ដោយបញ្ចេញសំឡេងអ៊ឹតបន្លំជាសត្វក្រួចដែលវង្វេងដាច់ហ្វូង ដែលយំហៅរកគ្នា ។ នៅពេលដែលសត្វក្រួចហើរមកចុះជុំហើយ ព្រានព្រៃក៏ប្រញាប់បោះលប់ ដើម្បីសង្គ្រុបចាប់សត្វក្រួចទាំងហ្វូងនោះដាក់ទ្រុង រួចយកទៅលក់ឯផ្សារ ព្រោះនេះជារបរចិញ្ចឹមជីវិតរបស់គាត់ ។

ថ្ងៃមួយ ព្រះពោធិសត្វដែលជាមេហ្វូង ដឹងហេតុការណ៍នៃមហន្តរាយនេះ ក៏ពិចារណាថា ៖

> អំពើរបស់ព្រានព្រៃនេះ ថ្ងៃណាមួយប្រាកដជាធ្វើឱ្យហ្វូងសត្វក្រួចទាំងអស់ វិនាសផុតពូជជាមិនខាន ។

បន្ទាប់មក មេក្រួចក៏កោះហៅពួកសត្វក្រួចទាំងអស់ ឱ្យមកចូលរួមប្រជុំ ដើម្បីរកវិធានការដោះស្រាយពីបញ្ហាគ្រោះថ្នាក់នេះ ។ ក្រោយពីបានពិភាក្សាគ្នារួចមក សត្វក្រួចដែលជាព្រះពោធិសត្វសម្រេចចិត្តថា ៖

ចូរអ្នកទាំងឡាយធ្វើតាមបណ្ដាំយើងយ៉ាងនេះ ពីពេលនេះតទៅ បើមានព្រានព្រៃបោះលប់មកលើក្រុមយើងកាលណា យើងម្នាក់ៗត្រូវតាំងស្មារតីឱ្យរឹងប៉ឹង កុំតក់ស្លុតឱ្យសោះ យើងត្រូវបញ្ចេញក្បាលតាមចន្លោះលប់ រួចយើងទាំងអស់គ្នាខំប្រឹងទទះស្លាបហើរឱ្យខ្លាំង ។ ធ្វើយ៉ាងនេះ យើងអាចស្ទួយនាំលប់យកទៅលើអាកាស រួចយើងនឹងនាំលប់នោះទៅជម្រុះចោលក្នុងគុម្ពោតព្រៃណាមួយ ដែលមានស្លឹកក្រាស់ ហើយពួកយើងក៏អាចគេចចេញពីលប់នោះបាន ។ បើយើងធ្វើដូច្នេះឱ្យស្រុះៗគ្នា នោះយើងប្រាកដជាអាចរំដោះខ្លួន រួចពីកម្លាំងដៃព្រាន បានដូចបំណងជាមិនខាន ។

សត្វក្រួចទាំងអស់ ក៏សន្យាយល់ព្រមធ្វើតាមបញ្ជារបស់សត្វក្រួចមេហ្វូងដែលជាព្រះពោធិសត្វ ដោយប្រុងប្រយ័ត្ន ហើយតែងតែគេចរួចខ្លួនពីគ្រោះថ្នាក់ជាដរាបតរៀងទៅ ។ នៅពេលដែលសត្វក្រួចទាំងអស់ស្ទុះហើរនាំលប់ទៅលើអាកាស នាយព្រានព្រៃខំរត់តាមយកលប់ពីក្នុងបន្ទាក៏មិនបាន ។ រៀងរាល់ថ្ងៃ ព្រានព្រៃតែងតែត្រឡប់មកផ្ទះវិញដោយដៃទទេ ។ ចំណែកប្រពន្ធព្រានព្រៃ កាលឃើញប្ដីត្រឡប់មកផ្ទះវិញដោយដៃទទេគ្មានប្រាក់ដូចសព្វដង ក៏កើតក្ដីមួម៉ៅ ក្ដៅក្រហាយ ហើយចោទប្ដីថា :

នៃលោកប្តី... រាល់ថ្ងៃត្រឡប់មកផ្ទះវិញដៃទទេដូច្នេះ តើអ្នកអាល័យទៅជាប់ដៃវល់ជាមួយនឹងស្រីថ្មីទេដឹង?

ព្រានព្រៃក៏ឆ្លើយថា :

ឱ! អូនសម្លាញ់អើយ... បងគ្មានទៅមានស្រីឯណាទេ សូមកែវមាសមេជឿបងចុះ ។ ការពិត គឺហ្វូងសត្វក្រួចទាំងអស់នោះ វាឆ្លាតណាស់ឥឡូវនេះ ពួកវាស្រុះស្រួលរស់នៅជាមួយគ្នា ដូចក្បាលមួយអ៊ីចឹង ។ នៅពេលដែលបងបោះលប់គ្របហ៊ុំពទ្ធលើពួកវាភ្លាម ពួកវាស្ទុះហើរដំណាលគ្នា ហើយហើរនាំទាំងលប់ឡើងយកទៅជាមួយ រួចទម្លាក់ចោលលើគុម្ពោតព្រៃដែលមានសុទ្ធតែបន្លា ។ ប៉ុន្តែ សូមពៅព្រលឹងអូនកុំព្រួយ ថ្ងៃណាមួយដែលពួកវាបែកបាក់សាមគ្គីគ្នា ថ្ងៃនោះសូម្បីតែកូនក្រួចមួយ ក៏មិនអាចហក់រួចពីកណ្តាប់ដៃបងបានដែរ ហើយអូននឹងញញឹមវិញជាមិនខាន ។

ពោលដូច្នោះហើយ នាយព្រានព្រៃក៏ច្រៀងតិចៗ ដោយរីករាយថា :

ឱ្យតែពួកឯង នៅខំប្រឹងប្រែង
ស្រុះស្រួលនឹងគ្នា ឯងអាចគេចផុត
ពីក្តីមរណា បើឯងឈ្លោះគ្នា

ជាថ្ងៃអង្គារ ថ្ងៃនោះហើយណា

ឯងជាប់លប់អញ គ្មានរួចមួយឡើយ...! ។

ក្រោយមក មានសត្វក្រួចមួយ កំពុងចឹកសំបុកកណ្តៀររកចំណី ស្រាប់តែរបូតជើងធ្លាក់មកក្រោមប៉ះក្បាលសត្វក្រួចមួយទៀត ។ ពេលនោះ ក៏មានសំឡេងក្រួចនៅពីខាងក្រោមបន្ទរឡើងថា :

- អាណាជាន់ក្បាលអញហ: ?

- សូមទោសលោក ខ្ញុំគ្មានបំណងទេ គឺខ្ញុំរបូតជើងធ្លាក់ពីសំបុក កណ្តៀរដោយអចេតនាទេ សូមលោកមេត្តាកុំខឹងអី ។

- មិនបានទេ ឯងនេះព្រហើនណាស់ រញ៉េរញ៉ៃបែបឯងហ្នឹងឬ ដែល ជាអ្នកមានកម្លាំងរើខ្លួនឱ្យរួចផុតពីលប់របស់ព្រានព្រៃនោះ? (ក្រួចទីពីរ ឆ្លើយតបទាំងកំរោល) ។

ជម្លោះរវាងសត្វក្រួចទាំងពីរចេះតែរាលដាលបន្តទៅទៀត បណ្តាល ឱ្យបរិយាកាសកាន់តែអាប់អួ ដោយមានក្រុមកាន់ជើងគ្នាទាំងសងខាង កាន់តែច្រើនឡើងៗ ។ ដោយពុំអាចសម្រុះសម្រួលបាន ក្រួចដែលជាព្រះ ពោធិសត្វយល់ឃើញនូវស្ថានភាពមិនស្រួល ក៏នាំគ្នាមួយក្រុមហើរចេញពី ទីនោះទៅ ។ ស្ថិតនៅក្នុងភាពច្របូកច្របល់នោះ ស្រាប់តែលប់របស់នាយ

ព្រានព្រៃធ្លាក់ព្រឹប លើសត្វក្រួចទាំងពីរក្រុម ដែលកំពុងតែឈ្លោះគ្នានោះ ។ ដោយការភិតភ័យតក់ស្លុត ស្រឡាំងកាំងក្នុងភាពអាសន្ននោះ សត្វក្រួចទាំងពីរក្រុម ភ្លេចអស់បណ្ដាំព្រះពោធិសត្វ ហើយក៏ស្រែកប្រចាំគ្នាថា :

"បើឯងពូកែណាស់ ឥឡូវម្ដេចក៏មិនហើរនាំលប់នេះមុនអញទៅ?"

"ចុះឯង ម៉េចក៏មិនស្ទុះមុនអញទៅ ?"

នៅពេលដែលសត្វក្រួចទាំងពីរក្រុម កំពុងតែឈ្លោះប្រកែកគ្នាដូច្នេះ ព្រានព្រៃក៏ក្រសោបលើកលប់ ចាប់ក្រួចទាំងអស់នោះបញ្ចូលក្នុងទ្រុង រួចត្រឡប់ទៅផ្ទះវិញដោយក្ដីរីករាយ ។

ថ្ងៃនេះ កិរិយារបស់ព្រានញញឹមដូចបំណងរបស់គេមែន ។

លុះព្រះអង្គសម្ដែងរឿងអតីតកាលរួច សម្ដេចព្រះបរមសាស្ដាចារ្យទ្រង់ត្រាស់បញ្ជាក់ថា :

ម្នាលភិក្ខុ[៥៦] ទាំងឡាយ ការឈ្លោះគ្នារវាងបងប្អូនឯង រមែងតែងតែនាំមកនូវសេចក្ដីវិនាស ។ សូម្បីតែសត្វក្រួចក៏ដោយ ក៏គេអាចយកជ័យជម្នះលើសត្រូវបាន ឱ្យតែគេចេះសាមគ្គី (ត្រូវរ៉ូវ) គ្នា ។ ផ្ទុយទៅវិញ

[៥៦] ពាក្យថា **ភិក្ខុ** ក្នុងទីនេះ គឺរាប់ទាំងបរិស័ទទាំងអស់ ។

គេអាចធ្លាក់ក្នុងក្ដីមហន្តរាយ បើកាលណាគេនៅតែឈ្លោះគ្នា ហើយប្រកាន់អាកប្បកិរិយារឹងរូស យកឈ្នះយកចាញ់រវាងគ្នាឯងជាធំ ។

បន្ទាប់មក ព្រះសម្មាសម្ពុទ្ធទ្រង់ប្រជុំជាតកថា សត្វក្រួចដែលពោរពេញទៅដោយកំហឹងក្ដៅក្រហាយនោះ គឺជាតួអង្គនៃភិក្ខុទេវទត្ត ។ រីឯព្រះពោធិសត្វជាមេដឹកនាំនៃហ្វូងក្រួច ដែលមានប្រាជ្ញានោះ គឺតួអង្គតថាគតនេះឯង ៕

## កំណត់ពីអ្នកនិពន្ធ

១- តើហេតុអ្វីបានជាសត្វក្រួច ចុះមកទាំងហ្វូងតាមព្រៃ នៅពេលដែលឮសំឡេងមនុស្សអ៊ីតបន្ធំយ៉ាងដូច្នេះ?

២- ការប្រព្រឹត្តនូវអំពើដែលសម្ដែងនូវរឿង ក្នុងសំណួរទីមួយខាងលើនេះ តើអាចបង្ហាញនូវធម៌អ្វីខ្លះសម្រាប់ក្រុមរបស់គេ?

៣- ដំណើររឿងបាននាំសង្គមសត្វក្រួចឈ្លោះទៅកាន់សេចក្ដីវិនាសពិត តើយើងអាចការពារកុំឱ្យសេចក្ដីវិនាសកើតឡើងទាន់ដែរឬទេ?

៤- ដំណើររឿងនេះ សមដូចន័យសុភាសិតខ្មែរ ដែលពោលដូចខាងក្រោមនេះឬទេ?

ឈ្លោះគ្នាក្នុងគ្រួសារ ដូចស្រាតកាយាបង្ហាញញាតិ
ឈ្លោះគ្នាក្នុងសង្គមជាតិ ដូចលាតកំណាប់បង្ហាញចោរ ។

៥- ចូរសិក្សាពីលក្ខណសម្បត្តិនៃសត្វក្រួចជាមេដឹកនាំ និងគុណវិបត្តិនៃសត្វក្រួចដែលមានចិត្តក្រេវក្រោធ ។

៦- ចូរសិក្សាពីលក្ខណៈរបស់តួអង្គព្រានព្រៃ និងកិរិយារបស់គាត់ ។

៧- ចូរសិក្សាពីការព្យាយាមរបស់នាយព្រានព្រៃ ទៅរកជ័យជម្នះរបស់គេលើហ្វូងនៃសត្វក្រួច ។

៨- ចំពោះចំណុចនីមួយៗខាងលើនេះ តើយើងអាចដកស្រង់នូវមេរៀនអ្វីមកអនុវត្តប្រចាំថ្ងៃក្នុងជីវិតរបស់យើង?

## ៣. វដ្ដកជាតក

ព្រះសម្មាសម្ពុទ្ធទ្រង់សម្ដែងធម៌ទេសនាថា "ស្លាបខ្ញុំនៅខ្ចីពុំអាចហើរ.." ដូច្នេះ ។ នេះជាព្រះពុទ្ធដីកាដែលព្រះអង្គបន្ទឺឡើងតិចៗ នៅពេលមួយដែលភ្លើងព្រៃកំពុងឆេះយ៉ាងសន្ធោសន្ធៅ ។ ភ្លើងឆេះព្រៃកាន់តែឆាបឆ្លួលខ្លាំងឡើងៗ តម្រង់ឆ្ពោះមកកាន់ទីកន្លែងដែលព្រះអង្គគង់ប្រថាប់ ។ ព្រះភិក្ខុសង្ឃនិងពុទ្ធបរិស័ទផ្អើលឆោឡោភិតភ័យជាខ្លាំង ខ្លះរត់រកវិធីទប់ទល់ពន្លត់ភ្លើង ។ ភ្លើងកាន់តែឆេះរាលដាលចូលមកកាន់តែជិតឡើងៗ ភិក្ខុទាំងឡាយក៏នាំគ្នាចូលទៅក្រាបបង្គំព្រះពុទ្ធបរមគ្រូថា :

> បពិត្រព្រះអង្គដ៏ចម្រើន ភ្លើងឆេះនៅទីនេះ កំពុងតែមានសន្ទុះដូចខ្យល់ព្យុះសង្ឃរា ហើយចែងចាំងពេញផ្ទៃមេឃ ហាក់ដូចជាព្រះសុរិយាដែលកំពុងតែជះកម្ដៅរស្មីលើលោក ។

តែព្រះសម្មាសម្ពុទ្ធទ្រង់គង់ស្ងៀម ដោយពុំសម្ដែងអាការៈភ្ញាក់ផ្អើលតក់ស្លុតបន្តិចបន្តួចសោះ ។ នៅពេលដែលភ្លើងឆេះមកជិតដល់ ដោយនៅសល់ប្រវែង ១៦ ករីសៈ[៥៧] (៨០.៤៦៧២ ម៉ែត្រ) ពីកន្លែងដែលព្រះអង្គទ្រង់គង់

---

[៥៧] ក្នុងអភិធានប្បទីបិកាថា ៤ អម្ពណៈគឺ ៤៤ នាឡិ ស្មើ ១ ករីសៈ ត្រូវ ៣៩.៩៨៤ ម៉ែត្រការ៉េ។ នៅក្នុងសៀវភៅ Buddhist Birth Stories លោកបណ្ឌិត Rhys Davids ប្រែថា sixteen rods (១៦ rods)។ ១ rod ស្មើ ៥.០២៩២ ម៉ែត្រ ។ The rod is a unit of length equal to 5.5 yards, 11 cubits, 5.0292 merters, 16.5 feet, or 1/320 of a statute mile. A rod is the same length as a perch and a pole.

នោះ ភ្លើងក៏រលត់សូន្យតែម្ដង ហាក់ដូចជាគេយកចន្ទុះ ដែលកំពុងឆេះទៅជ្រលក់ក្នុងទឹក ។

នៅចំពោះព្រឹត្តិការណ៍ដ៏អស្ចារ្យនេះ ភិក្ខុទាំងឡាយក៏ចូលទៅថ្វាយបង្គំព្រះសម្មាសម្ពុទ្ធ ហើយពោលសរសើរតេជះនៃព្រះអង្គថា :

ឱហ្ន៎! អស្ចារ្យមែន នេះគឺជាតេជះនៃព្រះពុទ្ធអង្គហើយ ។ សូម្បីតែភ្លើងដែលគ្មានវិញ្ញាណសោះ ក៏ខ្ទបខ្ទាចបារមីនៃព្រះអង្គដែរ ។ ឱបារមីនៃព្រះសម្មាសម្ពុទ្ធ ពិតជាពុំអាចរកអ្វីប្រៀបផ្ទឹមបានឡើយ ។

ពេលនោះ ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់តបទៅនឹងភិក្ខុទាំងឡាយថា :

ម្នាលភិក្ខុទាំងឡាយ នេះពុំមែនជាបារមីនៃតថាគតបច្ចុប្បន្នទេ ដែលបានបណ្ដាលឱ្យភ្លើងព្រៃនេះរលត់នោះ គឺជាតេជះនៃអំពើពីអតីតកាលរបស់តថាគត ហើយកន្លែងនេះពុំអាចមានភ្លើងឆេះមកដល់រហូតដល់កប្បវិនាស ព្រោះជាអច្ឆរិយកម្មមួយ ដែលបានកើតមានតាំងពីអតីតកាលមក ។

ពេលនោះ ព្រះអានន្ទត្ថេរយកសង្ឃាដីមកក្រាលថ្វាយព្រះសម្មាសម្ពុទ្ធគង់ប្រថាប់ ។ ព្រះអង្គគង់ពែនព្រះភ្នែនសម្រួលឥរិយាបថរួចហើយ ភិក្ខុសង្ឃចង់ជម្រះចម្ងល់នៃអច្ឆរិយកម្ម ដែលកើតមានឡើងកាលពីអតីតកាលនោះ ក៏

សូមអារាធនាព្រះពុទ្ធបរមគ្រូ សូមឲ្យទ្រង់សម្តែងនូវរឿងហេតុដ៏អស្ចារ្យពីអតីតកាលនោះ ។

ព្រះពុទ្ធបរមគ្រូ ក៏ទ្រង់សម្តែងនូវរឿងអតីតកាលនោះ ដូចតទៅ:

ក្នុងអតីតកាលកន្លងទៅ ព្រះពោធិសត្វបានចាប់កំណើតជាសត្វក្រួចមួយ ក្នុងវដ្តមគធៈនេះឯង ។ នៅពេលកូនក្រួចដ៏តូចនោះ ទើបកើតមកថ្មីៗ មានស្លាប និងជើងនៅទន់ខ្ចី មិនអាចហើរទៅកាន់ទីណាមួយបានឡើយ ។ មេបារបស់គេ តែងតែទៅរកចំណី ពាំយកមកបញ្ចុកកូននៅក្នុងសំបុករាល់ៗថ្ងៃ ។ ថ្ងៃមួយ ស្រាប់តែមានភ្លើងឆេះព្រៃយ៉ាងសន្ធោសន្ធៅដូចថ្ងៃនេះ ។ នៅពេលដែលភ្លើងបានឆេះព្រៃភ្លាម សត្វស្លាបទាំងអស់នៅក្នុងព្រៃនោះ ក៏ផ្អើលឆោឡោហើរចោលសំបុកទាំងក្តីតក់ស្លុត ។ មេបារបស់កូនក្រួច មកអង្រួនកូនឱ្យខំហើរចេញពីសំបុកដូចសត្វដទៃដែរ ។ ពេលដែលដឹងថា មិនអាចជួយកូនរបស់ខ្លួនបាន មេបាកូនក្រួចក៏ដាច់ចិត្តហើរចោលកូននិងសំបុក ដោយទុកឱ្យកូនដែលមានស្លាបដ៏ខ្ចីនោះ នៅតែម្នាក់ឯង ។ កាលដែលកូនក្រួចនៅក្នុងសំបុកតែម្នាក់ឯង គេក៏ខំអើតកចេញពីសំបុក ដើម្បីពិនិត្យមើលស្ថានភាពខាងក្រៅ បានឃើញសន្ទុះភ្លើង និងខ្យល់បោកបក់ ហាក់ដូចជាព្យុះសង្ឃរាកំពុងឆាបឆេះព្រៃ សំដៅឆ្ពោះមកចំកន្លែងរបស់គេ ។ ពេលនោះ កូនក្រួចគិតក្នុងចិត្តថា:

ស្លាបខ្ញុំនៅខ្ចីពុំអាចហើរបាន...ឱ! ប្រសិនបើខ្ញុំអាចទទះស្លាបហើរ ខ្ញុំនឹងហើរទៅលើមេឃ ឬបើខ្ញុំអាចបោះជំហានដើរ ខ្ញុំនឹងរត់ទៅកាន់កន្លែងផ្សេងទៀតដូចសត្វទាំងឡាយដែរ ។ ប៉ុន្តែខ្ញុំពុំអាចធ្វើដូច្នោះឡើយ ។ ដោយខ្លាចនូវសេចក្តីស្លាប់ មេបារបស់ខ្ញុំ ក៏ហើរចោលខ្ញុំទៀត ។ នៅពេលនេះ ពុំមានអ្នកណាមួយ អាចជួយខ្ញុំបានឡើយ ។ រីឯខ្ញុំវិញ ក៏មិនអាចជួយខ្លួនឯងបានដែរ ។ តើខ្ញុំត្រូវធ្វើដូចម្តេចទៅហ្ន៎ នៅពេលនេះ?

នៅគ្រាដ៏មានអាសន្ននោះ កូនក្រួចគិតឃើញថា :

នៅក្នុងលោកនេះ មានវត្ថុសក្តិសិទ្ធិជាច្រើន ដូចជាគុណធម៌ សច្ចធម៌ជាដើម ។ មានមហាបុរសជាច្រើនរូប ដែលត្រាស់ជាព្រះពុទ្ធដ៏មានឫទ្ធិ ក៏ដោយសារអនុវត្តគុណធម៌ ដែលលោកសាងទុកជាច្រើនអាយុកប្បមកហើយដែរ ។ មហាបុរសដែលប្រកបដោយគុណធម៌ទាំងនោះ តែងតែមានសន្តានចិត្តពោរពេញដោយធម៌មាន សច្ចៈ មេត្តា ករុណា មុទិតា និងឧបេក្ខាជាដើម ព្រមទាំងធ្លាប់ទ្រាំតស៊ូនូវការលំបាកតាំងពីអតីតជាតិមក ។ ចិត្តដ៏បរិសុទ្ធរបស់មហាបុរសទាំងនោះ តែងតែផ្តល់ក្តីមេត្តាដល់សត្វលោកទូទៅ ដោយគ្មានរើសមុខ ។ ចំពោះខ្ញុំវិញ ក៏ដូច្នោះដែរ មានតែសច្ចធម៌នេះទេ ដែលជាអមតៈ និងជាជំនឿ

ប្រាកដរបស់ខ្ញុំ ។ ដូច្នេះហើយ ខ្ញុំត្រូវតែភាវនាចំពោះមុខគុណសម្បត្តិនៃព្រះពុទ្ធអង្គដែលបានសាងរួចមកហើយ និងអាងទៅលើជំនឿប្រាកដដ៏ធំក្នុងខ្លួនខ្ញុំ ដើម្បីសម្ដែងនូវសច្ចធម៌នេះ ។ ដូច្នេះ សូមឱ្យភ្លើងដ៏កំណាច ចៀសឆ្ងាយពីកន្លែងនេះ ដើម្បីនាំមកនូវសុវត្ថិភាពដល់ខ្លួនខ្ញុំផង និងដល់សត្វទាំងពួងផង ។

ពេលនោះ ក្រួចពោធិសត្វបានរលឹកដល់សច្ចៈនិងសីលក្នុងលោក ជាភាសាបាលីថា :

អត្ថិ លោកេ សីលគុណោ  សច្ចំ សោចេយ្យនុទ្ទយា
តេន សច្ចេន កាហាមិ  សច្ចកិរិយមុត្តមំ ។

នៅក្នុងលោកនេះ  ពិតមានសព្វញ្ញូ
ត្រាស់ជាគ្រូ  លើមនុស្សទេព្ដា
មានសីលគុណ  ប្រសើរអស្ចារ្យ
ទ្រង់ព្រះនាមថា  សម្មាសម្ពុទ្ធ ។
និងសច្ចធម៌  បវរបំផុត
សោចេយ្យបរិសុទ្ធ  មានក្នុងលោកា

សូមភ្លើងរលត់ ដោយសច្ចកិរិយា
ឧត្តមនេះណា ភ្លើងចូរចៀសចេញ ។

គិតដូច្នេះហើយ កូនក្រួចពោធិសត្វ ក៏ពោលពាក្យបន្តទៀតថា :

ខ្ញុំមានស្លាបដែរ តែហើរពុំរួច
ជើងខ្ញុំទន់តូច ពុំអាចដើរបាន
មេបានៃខ្ញុំ បានរត់ប្រាសប្រាណ
អគ្គីហោហាន ចូរអ្នកចៀសឆ្ងាយ ។

រំពេចនោះ ភ្លើងព្រៃដែលឆេះនៅប្រមាណ ១៦ករីស: ពីសំបុក ក៏រលត់បាត់សូន្យឈឹងដូចក្តីប្រាថ្នារបស់កូនក្រួច ។ បន្តិចម្តងៗ សត្វនានាបានអើតកចេញពីសំបុក ដើម្បីពិនិត្យមើលស្ថានការណ៍ ។ កង្កែបស្រែកបង្ហូកប្រាប់សត្វនានាថា ភ្លើងរលត់ហើយ ។ ឯសត្វចង្រិតស្រែកច្រេចៗ ជាសញ្ញាឱ្យសត្វនានាចេញពីរន្ធរបស់ខ្លួន ។ បន្ទាប់មក សត្វនានាបានយំរត់រកគ្នាលាន់ឮពេញព្រៃ ។ មេបារបស់កូនក្រួច ក៏វិលមកកាន់ទ្រនំវិញ ហើយមានសេចក្តីត្រេកអរឥតគណនា នៅពេលដែលបានឃើញកូនរបស់ខ្លួន មានជីវិតរស់នៅដោយសុវត្ថិភាព ។

បន្ទាប់មក ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់បញ្ជាក់ថា :

កន្ទ្វេងដែលតថាគតកំពុងគង់ប្រថាប់នេះឯង ជាកន្ទ្វេងសំបុកកូនក្រួចមានឫទ្ធិនោះ ។

រួចព្រះពុទ្ធអង្គទ្រង់សម្តែងថា :

ម្នាលភិក្ខុទាំងឡាយ តថាគតបានប្រារព្ធនៃសច្ចធម៌នោះ ក្នុងជាតិដ៏ច្រើនទៀត មិនមែនត្រឹមតែក្នុងជាតិជាកូនសត្វក្រួចនោះឡើយ ។

អវសានកថា ព្រះពុទ្ធទ្រង់បញ្ចប់ព្រះធម៌ទេសនា ដោយបានប្រជុំជាតកថា :

មេបារបស់កូនក្រួចនោះ បានមកជាមាតាបិតារបស់តថាគតសព្វថ្ងៃនេះ ។ រីឯកូនក្រួច ដែលសម្តែងគុណសច្ចៈរបស់ព្រះពុទ្ធអង្គពីអតីត-កាលនោះ គឺជាតួអង្គតថាគតនេះឯង ៕

## **កំណត់បន្ថែម**

តាមរឿងជាតក ដែលបកប្រែដោយអ្នកនិពន្ធ Tomas William Rhys Davids បានបញ្ជាក់ថា តាមសិលាចារឹក នាវត្តជេតពន គេឃើញកំណាព្យមួយវគ្គ ដែលមានការទាក់ទងជាមួយនឹងរឿងព្រះមហាសត្វក្រួចសូធ្យគាថាដេញភ្លើងព្រៃនោះ មានសេចក្តីថា :

"ក្នុងលោក ដែលសត្វស្វែងរក

ដោយកម្រ មានតែសច្ចៈ

គុណធម៌បវរ សច្ចាស្មោះសរ

ប្រសើរថ្លៃថ្លៃ” ។

## កំណត់ពីអ្នកនិពន្ធ

១- សូមលោកអ្នកអានជាទីគោរព មេត្តាត្រិះរិះពិចារណាពីគុណធម៌ និង កុសលផលបុណ្យ ដែលអាចកើតមកពីការប្រកាន់ ដោយខ្ជាប់ខ្ជួននូវ សច្ចធម៌ និងមេត្តាធម៌ក្នុងមាគ៌ាជីវិត ។

២- តើវត្ថុអ្វីខ្លះ ដែលបុគ្គលម្នាក់ៗអាចយកទៅជាមួយ នៅពេលចាកលោក នេះទៅ?

៣- ក្នុងរឿងមហាសត្វក្រួចមានបុណ្យនេះ តើយើងសម្គាល់នូវអ្វីខ្លះ ដែល ព្រះពោធិសត្វសម្ដែងជាបាដិហារ្យ?

៤- សូមធ្វើការសិក្សាពីគុណសម្បត្តិនៃមហាសត្វដែលមានលក្ខណៈជាមេ ដឹកនាំ ។ នៅពេលដែលមានគ្រោះថ្នាក់ដល់ជីវិត ហើយមហាសត្វនៅ គិតចង់ជួយសង្គ្រោះជីវិតសត្វដទៃទៀត ។ តើឃ្លាណាមួយដែលបញ្ជាក់ ពីឧត្តមគតិនេះ ទាក់ទងនឹងមេត្តាធម៌នេះ?

## ៤. មហោសថជាតក

## (ដកស្រង់យកត្រង់ស្ត្រីពីរនាក់ដណ្ដើមកូនគ្នា)

មានស្ត្រីពីរនាក់ដណ្ដើមកូនគ្នា ក្នុងរឿងមហោសថជាតកថា :

កាលពីយូរលង់ណាស់មកហើយ ព្រះពោធិសត្វបានចាប់កំណើតជាកូនមហាសេដ្ឋី នៅនគរមិថិលា មាននាមថា **ព្រះមហោសថ**[៥៨] ។ ព្រះមហោសថ ជាបណ្ឌិតពីកំណើត ហើយមានប្រាជ្ញាឈ្លាសវៃជាទីបំផុត ក្នុងការដោះស្រាយបញ្ហាសង្គ្រោះអ្នកស្រុក និងការពារនគរ ឱ្យថ្កុំថ្កើងរុងរឿង ។

មានស្ត្រីម្នាក់ ពកូនមកដល់ស្រះបោក្ខរណីរបស់ព្រះមហោសថ ក៏ឈប់សម្រាកងូតទឹកឱ្យខ្លួនប្រាណកូន ។ លុះនាងងូតទឹកឱ្យកូនស្អាតបាតហើយ នាងក៏ផ្ដេកទារកនៅលើកម្រាលសំពត់សូត្រដ៏ស្អាតមួយនៅទីនោះ ។ បន្ទាប់មក ទើបនាងចុះទៅងូតទឹកខ្លួនឯងម្ដង ។ ពេលនោះ មានស្រីម្នាក់ដើរមកទីនោះ ហើយស្រែកសួរថា :

[៥៨] ព្រះមហោសថ គឺមកពីពាក្យ **មហា** និង **ឱសថ** ។ កាលព្រះមហោសថប្រសូតមក ម្ដាយរបស់ព្រះពោធិសត្វ ឃើញមានថ្នាំទិព្វជាប់នូវបាតដៃ ។ ថ្នាំនោះក៏បានយកទៅព្យាបាលជំងឺឈឺក្បាលរ៉ាំរ៉ៃរបស់មហាសេដ្ឋីជាឪពុក ជាសះស្បើយភ្លាម ។ ជាហេតុអស្ចារ្យណាស់ ទើបឪពុកម្ដាយប្រសិទ្ធនាមព្រះពោធិសត្វថា "**ព្រះមហោសថ**" ។

- នែនាងសម្លាញ់ កូននេះស្អាតណាស់ ជាកូនរបស់នាងឬ? ឱ្យយើងសុំបីបមថ្នមទារករបស់នាងបន្តិចបានទេ?

- ចាះ មានអីនាង សូមអញ្ជើញបីចុះ (ម្តាយទារកនិយាយ) ។

ឱកាសនោះ ស្ត្រីអ្នកដំណើរក៏លើកទារកព ហើយដើរចេញពីទីនោះភ្លាមតែម្តង ។ ឃើញដូច្នេះ នាងជាម្តាយខំប្រញាប់ប្រញាល់ស្ទុះឡើងពីទឹក ហើយរត់តាមស្ត្រីដែលយកកូននាងទៅ ។ ម្តាយទារកនោះ ក៏ស្រែកសួរថា :

- នែនាង! នាងយកកូនយើងទៅណាហ្នឹង?

- ស្ត្រីអ្នកដំណើរឆ្លើយថា "កូនឯងឯណា? កូននេះជាកូនរបស់យើងទេតើ? ពោលដូច្នោះហើយ ស្ត្រីនោះក៏ចេញដំណើរឆ្ពោះទៅកាន់ទីក្រុងភ្លាមតែម្តង ។ ស្ត្រីជាម្តាយទារក មានការភ័យតក់ស្លុតជាខ្លាំង ដោយឃើញគេមកដណ្តើមកូនពីខ្លួនយកទៅដូច្នេះ ។ នាងយំផង រត់ផង តាមស្ត្រីដែលយកកូននាងរហូតដល់ទីក្រុង ។ ពេលនោះ អ្នករក្សាសន្តិសុខក្រុងឃើញស្ត្រីទាំងពីរនាក់កំពុងឈ្លោះប្រកែកគ្នាយ៉ាងដូច្នេះ ក៏នាំនាក់ទាំងពីរទៅកាន់សាលាក្តីរបស់ព្រះមហោសថ ដើម្បីសុំឱ្យព្រះពោធិសត្វជួយរកយុត្តិធម៌ ។

ក្រោយពីជ្រាបនូវបញ្ហាដណ្តើមកូននេះហើយ ព្រះមហោសថសួរដល់ស្ត្រីទាំងពីរនាក់ថា :

តើអ្នកទាំងពីរ យល់ព្រមគោរពតាមការវិនិច្ឆ័យរបស់យើងដែរឬទេ?

ស្ត្រីទាំងពីរឆ្លើយស្របគ្នាថា "ចា៎ះ យើងខ្ញុំទាំងពីរនាក់យល់ព្រមគោរពតាមការវិនិច្ឆ័យរបស់លោកម្ចាស់ហើយ" ។

បន្ទាប់មក ព្រះមហោសថបង្គាប់ឱ្យអ្នកមុខអ្នកការ ក្នុងសាលាជំនុំគូសបន្ទាត់មួយចំពាក់កណ្ដាលសាលា រួចបង្គាប់នាងដែលកំពុងបីទារកឱ្យយកទារកនោះមកដាក់ទទឹងបន្ទាត់ដែលទើបនឹងគូស រួចព្រះមហោសថបង្គាប់ឱ្យស្ត្រីម្នាក់កាន់ដៃទាំងពីររបស់ទារក ឯស្ត្រីម្នាក់ទៀត កាន់ជើងទាំងពីររបស់ទារក ។ ហើយព្រះពោធិសត្វបញ្ជាក់ថា :

ចូរអ្នកទាំងពីរស្ដាប់ខ្ញុំឱ្យច្បាស់ ឥឡូវនេះ កូននាងនៅចំកណ្ដាលបន្ទាត់ បើអ្នកណាទាញកូន ឱ្យចេញផុតពីបន្ទាត់មុនគេ អ្នកនោះ គឺជាអ្នកឈ្នះ ។ ដូច្នេះ ចូរអ្នកទាំងពីរចាប់ផ្ដើមទាញទារកនោះចុះ" ។

នៅពេលចាប់ផ្ដើមទាញទារកភ្លាម ទារកក៏ចាប់ផ្ដើមយំ ហើយយំកាន់តែខ្លាំងឡើងៗ ។ ស្ត្រីម្នាក់ដែលកាន់ខាងជើងទារក ដោយនាងខ្លាចកូនឈឺ ក្នុងការប្រទាញប្រទង់នោះ នាងក៏សុខចិត្តលែងជើងទារក បណ្ដោយឱ្យស្ត្រីម្នាក់ទៀតទាញយកទារកដោយស្រួល ហើយនាងបែរជាអង្គុយស្ងៀមស្រែកយំសម្រក់ទឹកភ្នែកទៅវិញ ។

ពេលនោះ ព្រះពោធិសត្វសួរទៅកាន់មហាជនទាំងអស់ដែលនៅក្នុងរោងជំនុំថា :

"តាមធម្មតា តើអ្នកណាមានចិត្តទន់ភ្លន់ជាងចំពោះកូន ម្តាយឬអ្នកដទៃ?"

"ម្តាយជាអ្នកដែលមានចិត្តទន់ជាង លោកម្ចាស់!" (មហាជនទាំងអស់ដែលនៅក្នុងរោងជំនុំបានឆ្លើយព្រមគ្នាឡើង) ។

ព្រះមហោសថក៏សួរបន្តថា :

"ដូច្នេះ តើអ្នកទាំងអស់គ្នាអាចសន្និដ្ឋានបានដែរឬទេ ថាអ្នកណាមួយជាម្តាយបង្កើតរបស់ទារកតូចនេះ?"

"អ្នកដែលសុខចិត្តចាញ់នោះហើយជាម្តាយ លោកម្ចាស់!" (មហាជនទាំងអស់ដែលនៅក្នុងរោងជំនុំបានឆ្លើយព្រមគ្នាឡើង) ។

ព្រះមហោសថសួរទៀតថា :

"បើដូច្នេះ តើអ្នកទាំងអស់គ្នាយល់ថា ស្ត្រីដែលទាញទារកយកមុននោះ ពិតជាចោរមែនទេ?"

"លោកម្ចាស់ជាទីគោរព! យើងទាំងអស់គ្នាមិនអាចឆ្លើយទេ" (មហាជនទាំងអស់ដែលនៅក្នុងរោងជំនុំឆ្លើយដោយស្ទាក់ស្ទើរ) ។

បន្ទាប់មក ទើបព្រះមហោសថមានវាចាថា :

"ពិតណាស់! នេះហើយជាយក្ខិនី ដែលលួចយកទារក បម្រុងនឹងយកទៅធ្វើជាចំណី" (ព្រះពោធិសត្វនិយាយផង ដៃចង្អុលទៅស្ត្រីដែលដណ្តើមកូនគេនោះផង) ។

"ហេតុអ្វី ក៏លោកម្ចាស់ជ្រាបច្បាស់ថា នាងមិនមែនជាម្តាយនៃទារក?" (សមាជិកម្នាក់នៃពេលជំនុំសួរឡើង) ។

ព្រះមហោសថឆ្លើយតបថា :

"អ្នកទាំងឡាយចូរពិនិត្យមើលចុះ ភ្នែកនាងក្រហម ឥតប៉ប្រិចបន្តិចសោះ នាងគ្មានខ្លាច គ្មានការតក់ស្លុត គ្មានការខ្មាសអៀន គ្មានសេចក្តីករុណាក្នុងខ្លួនអ្វីបន្តិចបន្តួចសោះ ។ រីឯនាងជាម្តាយវិញ ចិត្តនាងពោរពេញទៅដោយសេចក្តីស្រឡាញ់ និងអាណិតចំពោះកូន ។ នាងសុខចិត្ត ចុះចាញ់ក្នុងការដណ្តើមកូនគ្នា ដើម្បីចៀសវាងកុំឱ្យកូននាងឈឺ ក្នុងការប្រទាញប្រទង់ ។ នេះទើបពិតជាទឹកចិត្តស្នេហារបស់ម្តាយចំពោះកូនយ៉ាងពិតប្រាកដមែន" ។

ព្រះពោធិសត្វក៏ងាកទៅកាន់នាងយក្ខិនី ហើយពោលថា :

- នែនាង! តើនាងជាអ្នកណា?

- ឱ! លោកម្ចាស់អើយ នាងខ្ញុំពិតជាយក្ខិនីមែន (យក្ខិនីស្រីចោរឆ្លើយដោយធ្លាក់ទឹកមុខ) ។

ព្រះមហោសថបន្ទោសថា ហេតុអ្វីបានជានាងលួចកូនគេដូច្នេះ?

- ខ្ញុំម្ចាស់នឹកថា នឹងយកទារកនេះទៅធ្វើចំណីធីនៅពេលល្ងាចនេះ (យក្ខិនីឆ្លើយ) ។

- (ព្រះមហោសថ) នែនាងយក្ខិនី! នាងវង្វេងជ្រៅណាស់ នាងមានបាបកម្មពីជាតិមុនច្រើនណាស់ ទើបបានជានាងមកកើតជាយក្ខិនីនេះ តើនាងដឹងឬទេ? ហើយឥឡូវនេះ នាងនៅតែប្រព្រឹត្តអំពើចោរកម្ម និងបាបកម្មបែបនេះទៀត ។ តើជាតិណាទៅ ទើបនាងកើតជាមនុស្សពេញលក្ខណៈនឹងគេ? បើនាងសុខចិត្តប្ដេជ្ញាជាមួយនឹងយើង ថានាងនឹងរក្សាសីល ៥ ចាប់ពីពេលនេះតទៅ យើងនឹងលើកលែងទោសឱ្យនាងរួចខ្លួន ឥឡូវនេះ ចូរនាងប្រគល់ទារកឱ្យទៅម្ដាយគេតាមសម្រួលទៅ ។

នាងយក្ខិនី ស្ដាប់ការប្រៀនប្រដៅរបស់ព្រះពោធិសត្វហើយ បីដូចជាភ្ញាក់ពីការវង្វេងក្នុងអំពើបាប ។ នាងបានយល់ឃើញនូវទោសរបស់ខ្លួនហើយសុខចិត្តប្រគល់ទារកឱ្យម្ដាយគេវិញ ។ ហើយនាងក៏ព្រមសន្យាជាមួយព្រះមហោសថថា នឹងទទួលកាន់សីល ៥ តាមការប្រៀនប្រដៅរបស់

ព្រះពោធិសត្វតរៀងទៅ ។ រីឯនាងជាម្ដាយ កាលបើបានទទួលនូវការកាត់ក្ដី ដោយយុត្តិធម៌នេះហើយ នាងបានយកកូនសម្លាញ់មកបីថ្នាក់ថ្នមឱបថើប ឡើងវិញ ដោយក្ដីត្រេកអររំភើបក្នុងចិត្តឥតគណនា ។ បន្ទាប់មក នាងក៏ថ្វាយបង្គំលាព្រះពោធិសត្វ ដោយជូនពរថា :

"សូមលោកម្ចាស់ ប្រកបដោយអាយុយឺនយូរតរៀងទៅ ដើម្បីជាម្ចប់យុត្តិធម៌សម្រាប់ជនទូទៅនៃនគរមិថិលានេះ ។ សូមអរព្រះគុណជាអនេកប្បការ" ។

ព្រះពោធិសត្វ តបពរទៅនាងវិញដោយក្ដីករុណាធម៌ថា :

"ចូរនាងថែរក្សាកូនសម្លាញ់របស់នាង ឱ្យសុខជានិរន្តរ៍តរៀងទៅ" ។

ព្រះមហោសថ ជាតួអង្គព្រះពោធិសត្វ ដែលបានត្រាស់ជាព្រះពុទ្ធបរមគ្រូរបស់យើងនេះឯង ៕

## កំណត់នៃអ្នកនិពន្ធ

ការដោះស្រាយបញ្ហានេះ គ្រាន់តែជាចំណុចមួយនៃសកម្មភាពរបស់ព្រះពោធិសត្វ ។ ព្រះមហោសថដែលខ្ញុំបាទចង់លើកយកមកជូនលោកអ្នកអានបានជ្រាបនេះ ដើម្បីពិចារណាអំពីវិធីសាស្រ្ដឈ្លាសវៃរបស់ព្រះពោធិសត្វ ។ សូមអានសេចក្ដីពិស្ដារក្នុងទសជាតកផងចុះ ។

សូមលោកអ្នកអានជាទីគោរព មេត្តាពិចារណានូវចំណុចសំខាន់ៗ នៃរឿង ដូចតទៅ :

១- លក្ខណសម្បត្តិរបស់ព្រះមហោសថ ។

២- លក្ខណៈរបស់ម្តាយបង្កើត និងនាងយក្ខិនី ។

៣- វិធីប្រើបញ្ញារកយុត្តិធម៌ ជាពិសេសការពិន័យទោសដល់អ្នកដែលប្រព្រឹត្តខុស ។

៤- សូមធ្វើការប្រៀបធៀបរវាងការស្រឡាញ់កូន ឬស្រឡាញ់ម្តាយជាមួយនឹងការស្រឡាញ់មាតុភូមិរបស់យើង ។

## ៥. ពានរពារាណសី

(មហាកបិជាតក)

ព្រះសម្មាសម្ពុទ្ធ ទ្រង់សម្ដែងព្រះធម៌ទេសនាថា "អ្នកយកដងខ្លួនអ្នកធ្វើជាស្ពាន សម្រាប់ចម្លងទុក្ខអ្នកដទៃ..." ។

នេះជាព្រះពុទ្ធដីកា ដែលព្រះសម្មាសម្ពុទ្ធ ព្រះអង្គថ្លែងនៅក្នុងវត្តជេតពន អំពីការលះបង់ដ៏អស្ចារ្យមួយដែលព្រះពោធិសត្វបានសាង ដើម្បីស្វែងរកសេចក្ដីសុខជូនអ្នកដែលរស់នៅក្រោមការគ្រប់គ្រងរបស់ព្រះអង្គ ។ នៅពេលដែលព្រះភិក្ខុទាំងឡាយ កំពុងពិភាក្សាអំពីគុណសម្បត្តិនៃព្រះសម្មាសម្ពុទ្ធ ព្រះអង្គទ្រង់ថ្លែងទៅកាន់ភិក្ខុទាំងនោះថា :

> មិនមែនតែក្នុងជាតិនេះទេ ដែលតថាគតបានជួយសង្គ្រោះសត្វលោក សូម្បីតែពីអតីតជាតិស្ថិតក្នុងឋានៈជាសត្វក្ដី ក៏តថាគតធ្លាប់បូជាជីវិតផ្ទាល់ ដើម្បីផ្ដល់សេចក្ដីសុខដល់អ្នកដទៃដែរ ។

បន្ទាប់មក ព្រះពុទ្ធបរមគ្រូទ្រង់សម្ដែងព្រះធម្មទេសនា ដែលមានអត្ថន័យ ដូចតទៅ :

មានរឿងតំណាលថា កាលពីអតីតកាលយូរលង់ណាស់មកហើយ នៅក្នុងដែនកាសី មានស្ដេចពានរមួយ រស់នៅដោយសុខសាន្តជាមួយនឹង

ពានរទាំងឡាយចំនួន ៨០.០០០ ។ នៅតាមមាត់ទន្លេគង្គា នាព្រៃហេមពាន្ត មានដើមស្វាយមួយដើមដ៏ធំខ្ពស់ មានមែកសាខាគួរជាទីមនោរម្យ ។ ដើមស្វាយដ៏ធំនេះ ជាជម្រកប្រចាំជីវិតផង ជាកន្លែងផ្តល់អាហារដល់សត្វពានរទាំងឡាយនោះផង ។ នៅក្បែរគល់ស្វាយ តែងមានផ្លែខ្ចីទុំធ្លាក់ដេរដាស ជាចំណីដ៏បរិបូរសម្រាប់សត្វពានរទាំងឡាយនោះ ។

ថ្ងៃមួយ ស្តេចពានរពិចារណាក្នុងចិត្តថា :

> ថ្ងៃណាមួយ ពួកយើងប្រាកដជាមានគ្រោះថ្នាក់ជាមិនខាន ប្រសិនបើមានស្វាយទុំណាមួយ ខាងមែកលើមាត់ទន្លេធ្លាក់ចុះទៅក្នុងទឹក។

គិតដូច្នេះហើយ ស្តេចពានរបានប្រមូលពានរទាំងអស់មក ហើយប្រាប់ថា :

> នែអ្នកទាំងអស់គ្នា ចូរប្រយ័ត្នឱ្យហ្មត់ចត់ជាទីបំផុត កុំឱ្យស្វាយទុំខាងនៅមែកដែលដុះលើមាត់ទន្លេនោះ ជ្រុះធ្លាក់ទៅក្នុងទឹកឱ្យសោះ ។ យើងអាចនឹងទទួលគ្រោះមហន្តរាយដល់ជីវិតបាន បើកាលណាពួកមនុស្សរើសផ្លែស្វាយនេះ ។ ដូច្នេះ ចូរអ្នកទាំងអស់គ្នាធាប់បេះ ឬកម្ទេចចោលនូវផ្លែឈើខ្ចីៗ ដែលដុះចេញពីមែកនៅខាងលើមាត់ទន្លេ ។ យើងធ្វើយ៉ាងនេះ ដើម្បីចៀសវាងកុំឱ្យមានផ្លែណាមួយទុំ

ជ្រុះទៅក្នុងទឹក ហើយវាអាចរសាត់តាមទឹក ហូរធ្លាក់ដល់ដៃមនុស្ស ដែលរស់នៅតាមមាត់ទន្លេគង្គាខាងក្រោម ។

សត្វពានរទាំងឡាយ ក៏ខំប្រុងប្រយ័ត្នធ្វើតាមបញ្ជាស្តេចពានរ ហើយបានរស់នៅដោយសុខសាន្តតរៀងមក ។

ព្រះបាទព្រហ្មទត្ត ទ្រង់គង់នៅក្រុងពារាណសី ហើយទ្រង់បាន គ្រប់គ្រងព្រះរាជាណាចក្រទាំងមូល ដោយសុខក្សេមក្សាន្ត ។

ថ្ងៃនេះ ព្រះរាជា ហែហមដោយនាម៉ឺនសព្វមុខមន្ត្រីជាច្រើន យាង ទៅក្រសាលស្រង់ទឹកនៅទន្លេគង្គា ដែលហូរកាត់មុខព្រះបរមរាជវាំង ពួក សេនាប្រុសស្រីទាំងឡាយ មានសេចក្តីរីករាយក្នុងថ្ងៃសម្រាកនេះជាពន់ ពេក ។ អ្នកខ្លះមុជហែលលេង តាមចរន្តទឹកដ៏ថ្លាឆ្វង់ ដែលហូរធ្លាក់មកពីភ្នំ ហេមពាន្ត ។ អ្នកខ្លះទៀតស្ងួចត្រី អ្នកខ្លះបង់សំណាញ់ រាយមង ឬចែវទូក លេងបញ្ចេញសំឡេងខ្សៀវខ្សារឮរំពងអឺងកងក្នុងទន្លេគង្គា ហាក់ដូចជាមាន សេចក្តីសុខសាន្តដ៏ប្រពៃណាស់ ។ ឋិតក្នុងសភាពដ៏សប្បាយរីករាយនោះ ស្រាប់តែមានសេនាពីរនាក់ ស្រែកឆោឡោឡើងថា :

"នៃអ្នករាល់គ្នាមកនេះ យើងបង់សំណាញ់ទៅបានជាប់ផ្លៃឈើមួយធំណាស់ ហើយមានក្លិនក្រអូបឈ្ងុយឈ្ងប់តែម្តង ។ ចម្លែកណាស់ យើងពុំដែលជួបផ្លៃឈើដូច្នេះទេពីមុនមក" ។

បន្ទាប់មក គេក៏យកផ្លៃឈើដ៏ចម្លែកនោះ ទៅថ្វាយដល់ព្រះរាជា ។ ព្រះបាទព្រហ្មទត្ត ទ្រង់ទតផ្លៃឈើនោះហើយ ព្រះអង្គទ្រង់ចូល់ជាពន់ពេកអំពីប្រភពនៃដើមឈើនោះ ។ ព្រះអង្គក៏ទ្រង់បញ្ជាឱ្យសេនាម្នាក់ទៅអញ្ជើញព្រានព្រៃមកសួរពីប្រភពនៃផ្លៃឈើនោះ ។ ក្រោយពីពិនិត្យផ្លៃឈើរួចហើយនាយព្រានព្រៃទូលថ្វាយព្រះបាទព្រហ្មទត្តថា :

"ផ្លៃឈើនេះ ពិតជាផ្លៃស្វាយ ដែលដុះតាមមាត់ទន្លេគង្គា នាព្រៃហេមពាន្តប្រាកដមែន ក្រាបទូល!" ។

ដោយទទួលរាជានុញ្ញាតពីព្រះបាទព្រហ្មទត្ត ព្រានព្រៃក៏ភ្លក្សផ្លៃស្វាយនោះ ហើយព្រះរាជា ព្រមទាំងនាម៉ឺនសព្វមុខមន្ត្រីធំៗ ក៏ភ្លក្សរសជាតិស្វាយទុំនោះបន្តិចម្នាក់គ្រប់ៗគ្នាដែរ ។ ដោយត្រូវទឹកសន្សើមនៃព្រៃហេម-ពាន្តវេលាយប់ និងកម្តៅព្រះអាទិត្យនៅពេលថ្ងៃ ផ្លៃស្វាយនោះមានរសជាតិផ្អែមពិសេស ហើយធំជាងផ្លៃស្វាយនានា ដែលធ្លាប់មាននៅដែនកាសី ។ រសជាតិស្វាយដ៏ផ្អែមឈ្ងុយឈ្ងប់នោះ ធ្វើឱ្យព្រះបាទព្រហ្មទត្ត ទ្រង់ជិតអារម្មណ៍ រហូតបណ្តាលឲ្យព្រះអង្គរវើរវាយ សឹងតែធ្វើការអ្វីលែងកើត ។

ព្រះអង្គគិតតែអំពីផ្លែស្វាយនោះ រហូតយល់សប្តិឃើញទាំងដើម ទាំងផ្លែ លឿងទុំ យោលរយីងរយោងតាមខ្យល់ គួរជាទីរីករាយពន់ពេក ។ បន្ទាប់មក ព្រះបាទព្រហ្មទត្តទ្រង់ត្រាស់បង្គាប់ឲ្យនាយព្រានព្រៃ និងពលសេនា រៀបចំក្បួនទ័ពសំពៅមួយ នាំព្រះអង្គឡើងទៅកាន់ព្រៃហេមពាន្ត ។ ការធ្វើដំណើរ ត្រូវចំណាយពេលអស់មួយថ្ងៃគត់ ។ ក្បួនទ័ពសំពៅ ក៏នាំព្រះរាជាមកដល់ដែនទន្លេគង្គានៃព្រៃហេមពាន្ត ដូចបំណងដោយសុវត្ថិភាព ។

ពេលនោះ នាយព្រានព្រៃទូលថ្វាយព្រះបាទព្រហ្មទត្ត ដោយចង្អុលទៅដើមស្វាយពីចម្ងាយថា "បពិត្រព្រះរាជា នុ៎ះហ្ន គឺជាដើមស្វាយទិព្វដែលព្រះអង្គកំពុងស្វែងរកក្រាបទូល! វាជាដើមឈើមួយដ៏ធំខ្ពស់ត្រដូចផុតដើមឈើនានា ប្រកបដោយមែកស៊ុបទ្រុប គ្របលើមាត់ច្រាំងទន្លេគង្គា ។

ព្រះរាជាទ្រង់សព្វព្រះរាជហឫទ័យឥតគណនា ហើយក៏ទ្រង់មានព្រះបន្ទូលថា :

ប្រសើរណាស់នាយព្រានព្រៃ តែយើងពុំអាចចូលទៅបេះផ្លែវាបានទេ ព្រោះរាត្រីកាលក៏ឈានចូលមកដល់ដែរ ។ យើងត្រូវតែបោះជំរំសម្រាកនៅទីនេះសិនចុះ ព្រឹកឡើងចាំយើងនាំគ្នាទៅបេះផ្លែស្វាយ ។

ខណៈនោះ អាមាត្យម្នាក់បានទូលថ្វាយព្រះបាទព្រហ្មទត្តថា :

ក្រាបទូលព្រះអង្គ! នៅលើដើមស្វាយនោះហាក់ដូចជាមានសត្វអ្វី ស្កុំៗ លោតចុះឡើងនៅលើមែក ទំនងដូចជាសត្វស្វា ។

ព្រះរាជាទ្រង់ទតទៅកាន់ដើមស្វាយហើយ ក៏មានព្រះបន្ទូលថា :

អើស្វាមែនទេតើ! មានស្វាច្រើនណាស់ ។ ពួកវាហ៊ានមកបេះផ្លែស្វាយយើងស៊ីផង ។ ពួកទាហាន! ចូរអ្នកដុតភ្លើងគប់ឱ្យច្រើន ដាំលំពែង ៥០០ ដើម រៀបចំក្បួនព្យូហៈ ឡោមព័ទ្ធជុំវិញដើមស្វាយ ហើយយាមការពារដោយប្រុងប្រយ័ត្ន កុំឱ្យពួកវារត់រួច ។ លុះដល់ព្រឹកឡើង ពួកយើងនឹងបេះផ្លែស្វាយផង បាញ់ពួកវាយកសាច់ធ្វើអាហារផង ។

សកម្មភាពជុំវិញដើមស្វាយ ព្រមទាំងសំឡេងអ៊ូអររបស់ពលទាហាន ធ្វើឱ្យស្វាទាំងអស់មានការភិតភ័យញ័ររន្ធត់យ៉ាងខ្លាំង ។ ពួកគេយករឿងអាសន្ននេះទៅទូលស្ដេចពានរថា :

ក្រាបទូលព្រះអង្គ ពេលនេះយើងមានគ្រោះថ្នាក់ដល់ជីវិតហើយ ។ ព្រឹកឡើងពួកទាហានមុខជានឹងបាញ់ធ្នូសម្លាប់ពួកយើងជាមិនខាន។ តើមានមធ្យោបាយណា ដើម្បីគេចខ្លួនឱ្យរួចពីទីនេះបានឬទេ បើគ្នាយើងមានច្រើនម៉្លឹងនោះ ព្រមទាំងមានកូនចៅតូចៗទៀតផង?

ស្ដេចពានរបានធានាអះអាង ដោយគ្មានតក់ស្លុតចំពោះគ្រោះថ្នាក់នោះឡើយ ហើយពោលថា :

ចូរអ្នកទាំងអស់គ្នា កុំអាលផ្អើលឆោឡោអី ហើយចូរតាំងចិត្តឱ្យស្ងប់ស្ងាត់ ធ្វើហាក់ដូចជាមិនឃើញព្រឹត្តិការណ៍អ្វីកើតឡើង ។ ខ្ញុំនឹងរកមធ្យោបាយដោះស្រាយជួយសង្គ្រោះជីវិតអ្នកទាំងអស់គ្នាឱ្យ ។

នៅពេលដែលស្ដេចពានរពិនិត្យរកហេតុផលដែលនាំឱ្យផ្លែស្វាយធ្លាក់ដល់ដៃមនុស្ស នៅតាមមាត់ទន្លេគង្គាខាងក្រោម ក៏សង្កេតឃើញសំបុកអង្ក្រងមួយដ៏ធំ ។ ទើបស្ដេចពានរវិនិច្ឆ័យថា សំបុកអង្ក្រងនោះហើយ ដែលអាចបិទបាំងឱ្យស្វាយទុំក្នុងនោះ ព្រោះស្វាទាំងឡាយមិនអាចចូលជិតបាន ។ រីឯស្វាយនោះ លុះទុំហើយ ក៏ជ្រុះធ្លាក់ចូលទៅក្នុងទឹករសាត់ដល់ដៃមនុស្ស ទើបបណ្ដាលឱ្យយើងមានរឿងដូច្នេះឯង ។ ពិចារណារួចហើយ ស្ដេចពានរក៏ឡើងទៅកាន់មែកស្វាយយ៉ាងខ្ពស់មួយ ដែលដុះទេរទៅលើមាត់ទឹកទន្លេ ។ រួចហើយស្ដេចពានរ[៥៩] លោតបោះពួយយ៉ាងខ្លាំង សំដៅទៅកាន់ត្រើយម្ខាងទៀតនៃមាត់ទន្លេ ។ ស្ដេចពានរធ្លាក់ចូលទៅក្នុងគុម្ពោតព្រៃឫស្សីមួយដ៏ក្រាស់ ។ ស្ដេចពានរបានដកយកវល្លិផ្ដៅធំមួយប្រវែង ១០០ ជួរធ្នូ[៦០] មកចង

[៥៩] អដ្ឋកថាបញ្ជាក់ថា ស្ដេចពានរ មានកម្លាំងស្មើនឹងកម្លាំងដំរី ៥ ។

[៦០] ១០០ ជួរធ្នូ ស្មើនឹង ២០០ ម៉ែត្រ ។

ពន្ធជុំវិញចង្កេះ រួចឡើងផុតកំពូលដើមឈើមួយដើមទៀតពីត្រើយម្ខាង ។ ស្ដេចពានរយកវល្លិម្ខាង ចងភ្ជាប់នឹងមែកឈើដែលទេរមកកាន់មាត់ទន្លេ រួចហើយស្ដេចពានរយោលខ្លួន លោតបោះពួយយ៉ាងខ្លាំង សំដៅទៅកាន់ដើមស្វាយធំរបស់ខ្លួនវិញ ។ តែគួរឱ្យស្ដាយណាស់ ស្ដេចពានរលោតពុំដល់កន្លែងវិញ ដូចបំណងឡើយ ព្រោះវល្លិខ្លីជាងការស្មានទុក ។ ស្ដេចពានរត្រូវធ្លាក់មកប៉ះចុងមែកស្វាយមួយ ហើយខ្លួនខំប្រឹងប្រវាតោងជាប់ដោយដៃទាំងពីរ ។ ស្ដេចពានរយកដៃទាំងពីរមកតោងបន្តភ្ជាប់ ជាមួយនឹងមែកស្វាយជំនួសវល្លិផ្ដៅវិញ ។ នៅពេលដែលតោងមែកស្វាយជាប់ហើយ ស្ដេចពានរបញ្ជាទៅកាន់ពលសេនារបស់ខ្លួន ឱ្យនាំគ្នាប្រញាប់ប្រញាល់ឆ្លងលើខ្នងទៅកាន់ត្រើយម្ខាងទៀត ។ ពានរទាំងឡាយក៏នាំគ្នាឱនគោរព សូមខមាទោសស្ដេចរបស់ខ្លួន ហើយនាំគ្នាឆ្លងលើខ្នងស្ដេចពានរ ធ្វើជាស្ពានបន្តជាមួយនឹងវល្លិទៅកាន់ត្រើយម្ខាងទៀត ។ ក្នុងពេលឆ្លងនោះ មាននាយក្រុមមួយឈ្មោះ **លោលកបិ** មានចិត្តប្រណែននឹងស្ដេចពានរពីមុនស្រាប់ ក៏ឆ្លៀតឱកាសព្យាបាទនាយរបស់ខ្លួន ដោយលោតទម្លាក់ខ្លួនយ៉ាងខ្លាំងលើខ្នងនាយរបស់ខ្លួន បណ្ដាលឱ្យស្ដេចពានរបាក់ឆ្អឹងខ្នង និងប្រេះបេះដូង ហើយឈឺចុកចាប់យ៉ាងខ្លាំង ។ ពេលនោះ ស្ដេចពានរធ្លាក់ឈាមចេញតាមភ្នែកខ្លះ តាមមាត់ខ្លះ ច្រមុះខ្លះ ទុក្ខវេទនាដ៏ខ្លាំងក្លាបានកើតឡើង ។ តែទោះបីមានរបួសធ្ងន់

យ៉ាងណាក្ដី ស្ដេចពានរនៅតែខំទ្រាំតោងមែកឈើ ដើម្បីឱ្យបរិវារទាំងអស់បានឆ្លងលើខ្នងតទៅទៀត ។ ដោយខំប្រឹងតោងមែកស្វាយទប់ខ្លួនឱ្យបរិវារឆ្លងផង និងមានរបួសក្នុងខ្លួនយ៉ាងខ្លាំងផង ស្ដេចពានរក៏សន្ធប់បាត់ស្មារតី តែដៃទាំងពីរ នៅតែតោងមែកឈើដដែល ហាក់ដូចជារង់ចាំរេហ៍ពលទាំងអស់ឆ្លងបន្តទៀត ។ ពេញមួយរាត្រី ស្វាទាំង ៨០.០០០ ក៏បានឆ្លងផុតពីគ្រោះអាសន្នទាំងអស់គ្នា ។

ព្រះបាទព្រហ្មទត្តទ្រង់ឃើញព្រឹត្តិការណ៍ដ៏អស្ចារ្យនេះ មានការរន្ធត់ហឫទ័យ ស្រក់ទឹកព្រះនេត្រកោតសរសើរព្រមទាំងអាណិតស្ដេចពានរនេះជាខ្លាំង ។ ព្រះអង្គពុំផ្ទំពេញមួយរាត្រី ។ ព្រះរាជាទ្រង់ពិចារណាថា :

នេះគ្រាន់តែជាសត្វពានរសោះ ព្យាយាមប្រឹងប្រែងបណ្ដោះគ្នាគេ
ឱ្យឆ្លងផុតពីគ្រោះថ្នាក់ សូម្បីជីវិតរបស់ខ្លួនឯង ក៏មិនគិតឡើយ ។

គិតដូច្នោះហើយ ព្រះរាជាបានប្រើឱ្យនាយទាហានដ៏ចំណាន យកស្នែងឡើងទៅលើដើមស្វាយ ហើយនាំគ្នាគ្រាហ៍យកពានរចុះមកក្រោម ។ ព្រះរាជាក៏បានបញ្ជាឱ្យគ្រូពេទ្យព្យាបាលរបួសពានរ ។ គេនាំគ្នាជូតសម្អាតឈាមលើខ្នង លាបប្រេងក្រអូប និងដណ្ដប់នូវផាហ៊ុមពណ៌លឿង ហើយផ្ដេកស្ដេចពានរទៅលើគ្រែមួយដ៏ប្រណីត ។ ព្រះរាជាទ្រង់គង់នៅក្បែរពានរដែលសន្លប់ពុំដឹងខ្លួន ដោយព្រះទ័យញាប់ញ័រយ៉ាងខ្លាំង ។ ព្រះអង្គទ្រង់

គង់រង់ចាំដោយសង្ឃឹមថា ស្តេចពានរនឹងបើកភ្នែករស់ឡើងវិញ ។ បន្ទាប់មក ប្រមាណជាងពីរយាមក្រោយមក ស្តេចពានររើខ្លួនបន្តិចម្តងៗ ហើយបើកភ្នែកសម្លឹងមើលអ្នកជុំវិញខ្លួន ។ ព្រះរាជាឃើញដូច្នោះ ក៏មានព្រះរាជហឫទ័យត្រេកអរជាពន់ពេក ទ្រង់បានឱនជិតត្រចៀកស្តេចពានរ ហើយមានព្រះបន្ទូលដោយរំភើបថា :

អ្នកយកដងខ្លួនអ្នកធ្វើជាស្ពាន សម្រាប់ចម្លងជីវិតអ្នកដទៃ ដោយអ្នកសុខចិត្តប្តូរជីវិតខ្លួនឯង ។ តើអ្នកជាអ្នកណាដែរ? ដោយគ្មានសម្តែងនូវការតក់ស្លុតបន្តិចបន្តួចសោះឡើយ ។

ស្តេចពានរក៏ឆ្លើយទៅកាន់ព្រះរាជាវិញ ដោយទន់ភ្លន់ថា :

បពិត្រព្រះរាជាដ៏ធំលើមនុស្សនានានៃដែនកាសី ទូលព្រះបង្គំជាស្តេចពានរ ។ ពានរទាំងឡាយនោះ ជាពលបរិវារកូនចៅរបស់ទូលព្រះបង្គំ ។ គេទាំងឡាយផ្ញើសេចក្តីទុកចិត្ត និងវាសនារបស់ពួកគេមកលើទូលព្រះបង្គំ ។ ទូលព្រះបង្គំមិនបារម្ភពីសេចក្តីស្លាប់ផ្ទាល់ខ្លួនឡើយ ឱ្យតែទូលព្រះបង្គំអាចរកសេរីភាព ជូនពលបរិវាររបស់ទូលព្រះបង្គំបាន ព្រោះទូលព្រះបង្គំ មានតួនាទីជាអ្នកគ្រប់គ្រងថែរក្សាសុខុមាលភាពរបស់ពួកគេ ។ ទូលព្រះបង្គំសប្បាយចិត្តណាស់ ដែលទូលបង្គំបានចម្លងពួកគេឱ្យផុតពីមហន្តរាយ ។ ឱ! ព្រះរាជា ទូលព្រះបង្គំ និងព្រះអង្គ មានមុខតួនាទីដូចគ្នា ។ បើអំពើរបស់ទូលព្រះបង្គំ

ថ្ងៃនេះ អាចចាត់ទុក ជាមេរៀនសម្រាប់ព្រះអង្គ និងអ្នកគ្រប់គ្រងព្រះរាជាណាចក្រនានាក្នុងលោកទៅអនាគត សូមព្រះអង្គជ្រាបថា មិនមែនព្រះខ័ន ឬមកុដ របស់ព្រះអង្គទេ ដែលធ្វើឱ្យព្រះអង្គទ្រង់ក្លាយជាព្រះមហាក្សត្រនោះ មានតែសេចក្ដីមេត្តានិងករុណាចំពោះប្រជានុរាស្ត្ររបស់ព្រះអង្គប៉ុណ្ណោះ ដែលធ្វើឱ្យព្រះអង្គក្លាយជាព្រះមហាក្សត្រពិត សូមព្រះអង្គទ្រង់ជ្រាប! ។ សូមព្រះអង្គ កុំយកព្រះរាជអំណាចមកត្រួតត្រាលើប្រជារាស្ត្ររបស់ព្រះអង្គ ដោយសារតែគ្នាជាប្រជារាស្ត្ររបស់ព្រះអង្គនោះ ។ ផ្ទុយទៅវិញ សូមព្រះអង្គយកធម៌មេត្តា និងករុណា មកអនុវត្តសម្រាប់គ្រប់គ្រងវិញ ទើបប្រសើរជាង ។ សូមមហាបពិត្រ គ្រប់គ្រងរដ្ឋប្រកបដោយទសពិធរាជធម៌[៦១] និងមាននូវសង្គហធម៌ទាំង ៤ គឺ **ទាន១ បិយវាចា១ អត្ថចរិយា១** និង **សមានត្តតា១** ចំពោះប្រជារាស្ត្ររបស់ព្រះអង្គសព្វកាល ។

ពោលតែប៉ុណ្ណោះ មហាពានរក៏បិទភ្នែកផុតដង្ហើមលាចាកលោកទៅ។ ព្រះរាជា និងពលសេនាប្រុសស្រីទាំងឡាយ កើតទុក្ខក្រៀមក្រំ យំសោកស្ដាយមហាពានរជាពន់ពេក ។ ព្រះបាទព្រហ្មទត្ត ទ្រង់ហែសពមហាពានរយកមកធ្វើបុណ្យយ៉ាងអធិកអធម អស់រយៈពេល ៧ យប់ ៧ ថ្ងៃ នៅឯក្រុងពារាណសី ។

[៦១] សូមមើលទសពិធរាជធម៌ ត្រង់ឧបសម្ពន្ធខាងមុខ ។

ដើម្បីរលឹកដល់គុណធម៌ដ៏ខ្ពង់ខ្ពស់របស់មហាពានរ ដែលផ្តល់ឱវាទសម្រាប់គ្រប់គ្រងរដ្ឋដល់ព្រះរាជា និងរលឹកដល់គុណធម៌ដ៏ខ្ពង់ខ្ពស់របស់មហាពានរដែលលះបង់ជីវិត ក្នុងភាពជាអ្នកដឹកនាំផងនោះ ព្រះរាជាទ្រង់បានសាងមហាចេតិយមួយដ៏ប្រណីត ថ្វាយដល់មហាពានរ ដោយចារឹកនាម និងឧទ្ទិសទុកថា "**ចេតិយមហាពានរពារាណសី**" ។

តាំងពីពេលនោះមក ព្រះបាទព្រហ្មទត្តទ្រង់គ្រប់គ្រងព្រះរាជាណាចក្រ ប្រកបដោយធម៌ដ៏ប្រពៃ តាមបណ្តាំស្តេចពានរ ។ អំពើដ៏ប្រសើរនេះនាំឱ្យរដ្ឋកាសីទាំងមូល កាន់តែជួបនូវសេចក្តីសុខ សេចក្តីចម្រើន រុងរឿង ហើយរឹតតែមានកិត្តិយសល្បីល្បាញលើសនគរនានា ក្នុងសម័យនោះ ។

នៅអវសានកថា ព្រះសម្មាសម្ពុទ្ធទ្រង់ប្រជុំជាតកថា ស្តេចពានរនោះ ជាព្រះពោធិសត្វ ដែលអន្ទោលជាតិមកកើតជាតួអង្គនៃតថាគតនេះឯង ។ ដោយការខំសាងបុណ្យក្នុងជាតិបន្តបន្ទាប់មក ហើយដោយជាប់ចិត្តស្រឡាញ់គោរពមហាសត្វពានរនោះផង ព្រះបាទព្រហ្មទត្ត ក៏យោនកំណើតមកកើតជាព្រះអានន្ទត្ថេរនេះឯង ។ ចំណែកឯ**លោលកបិ** ដែលបៀតបៀនស្តេចពានរនោះ ក៏បានមកកើតជាភិក្ខុទេវទត្ត ៕

## ៦. អម្ពជាតក

មានរឿងតំណាលថា កាលពីព្រេងនាយ នៅនគរពារាណសី មានព្រាហ្មណ៍ម្នាក់បានរៀនចេះមន្តអាគមពិសេសមួយ ។ មន្តនេះ អាចធ្វើឱ្យព្រាហ្មណ៍ជប់រុក្ខជាតិឱ្យដុះ ហើយមានផ្លែផ្ការហ័សទាន់ចិត្តដូចបំណង ។ ដោយអានុភាពនៃមន្តអាគមដែលរៀនចេះនោះ នាយព្រាហ្មណ៍ក៏ជប់ដើមស្វាយទិព្វមួយដើម ។ អស់រយៈកាលតែមួយដង្ហើមប៉ុណ្ណោះ ដើមស្វាយក៏បានដុះផុតពីដី ហើយបែកមែកសាខា មានស្លឹកផ្លែផ្កា គួរឱ្យចាប់អារម្មណ៍ជាពន់ពេក ។ ផ្លែស្វាយទុំមានពណ៌ល្អ ស្រស់ភ្លឺដូចមាស ក្លិនក្រអូបឈ្ងុយឈ្ងប់ ព្រមទាំងមានរសជាតិផ្អែមដូចទឹកឃ្មុំ ។

ដោយឃើញនូវផលដ៏ប្លែកអស្ចារ្យនេះ នាយព្រាហ្មណ៍ក៏បេះផ្លែស្វាយទិព្វនោះ ទៅថ្វាយដល់ព្រះរាជានៃក្រុងពារាណសី ។ ព្រះអង្គទ្រង់សព្វព្រះហឫទ័យចំពោះរសជាតិនៃផ្លែស្វាយនោះឥតឧបមា ។ បន្ទាប់មកព្រះអង្គទ្រង់ព្រះរាជទាននូវកិត្តិយសដ៏ពិសេស និងទ្រព្យសម្បត្តិជាច្រើនដល់នាយព្រាហ្មណ៍ ហើយនាយព្រាហ្មណ៍តែងតែបេះផ្លែស្វាយទិព្វទៅថ្វាយព្រះរាជា ជារៀងរាល់ថ្ងៃ ។

លុះច្រើនខែកន្លងមក ស្រាប់តែនាយព្រាហ្មណ៍ឈប់យកផ្លែស្វាយទៅថ្វាយព្រះរាជាដូចសព្វដង ។ ព្រះរាជាទ្រង់មានចម្ងល់ជាខ្លាំង ចំពោះ

អាកប្បកិរិយាដ៏ចម្លែកនេះ ទើបព្រះអង្គទ្រង់ចាត់នាយអាមាត្យម្នាក់ ឱ្យទៅអញ្ជើញនាយព្រាហ្មណ៍មកចូលគាល់ ។ ព្រះរាជា ទ្រង់ត្រាស់សួរនាយព្រាហ្មណ៍ថា :

ម្នាលព្រាហ្មណ៍ ជាអ្នកប្រព្រឹត្តធម៌ដ៏ប្រសើរ ពីមុនមកអ្នកធ្លាប់យកផ្លែស្វាយដ៏មានរសជាតិមកថ្វាយយើងជារៀងរាល់ថ្ងៃ ។ ចុះហេតុអ្វីឥឡូវនេះ បានជាអ្នកឈប់យកស្វាយមកថ្វាយយើងដូចកាលសព្វដងទៀត? តើអ្នកមានការអាក់អន់ស្រពន់ចិត្តដោយប្រការអ្វីខ្លះ ចូរអ្នកប្រាប់យើងតាមត្រង់មក ។

ពេលនោះ ព្រាហ្មណ៍មានការតក់ស្លុតយ៉ាងខ្លាំង ហើយទូលតប ព្រះរាជាវិញថា :

បពិត្រព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង ទូលបង្គំកំពុងតែគិតគូររកថ្ងៃដែលប្រកបដោយនក្ខត្តឫក្ស ដើម្បីសូធ្យមន្តដាំដើមស្វាយ ព្រោះមន្តនោះអាចប្រើបានតែមួយរយៈតែប៉ុណ្ណោះ ។ កាលណាទូលបង្គំរើសថ្ងៃហើយ ទូលបង្គំនឹងយកស្វាយទិព្វនោះ មកថ្វាយព្រះអង្គដូចប្រក្រតីវិញ សូមព្រះអង្គទ្រង់ព្រះរាជទានទោស! ។

ព្រះរាជាទ្រង់មានព្រះតម្រិះមួយសន្ទុះ ទើបទ្រង់មានព្រះរាជបន្ទូល តបទៅនាយព្រាហ្មណ៍វិញថា :

នៃព្រាហ្មណ៍! កាលពីដើមឡើយ ផ្លែស្វាយទាំងឡាយមានតូចមានធំ កើតដោយប្រាកដពីការសូធ្យមន្តរបស់អ្នក អ្នកពុំដែលរើសរកថ្ងៃនក្ខត្តឫក្សអ្វីឡើយ ។ ចូរអ្នកប្រាប់យើងតាមត្រង់មកចុះ តើថ្ងៃនេះមានហេតុការណ៍អ្វីប្លែកពីធម្មតាឬ?

ព្រាហ្មណ៍ផ្អើអេះអុះដោយទាល់ប្រាជ្ញា ក៏សម្រេចចិត្តទូលព្រះរាជាតាមត្រង់ថា :

បពិត្រព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង ទូលបង្គំជាខ្ញុំ បានរៀនមន្តអាគមនេះ ពីមាណពម្នាក់ជាកូននៃគ្រួសារចណ្ឌាល ដែលមានចិត្តប្រកបដោយធម៌ និងបានយកចិត្តទុកដាក់បង្រៀនដល់ទូលបង្គំឱ្យចេះមន្តអាគមនេះ ។ នៅពេលដែលទូលបង្គំរៀនចេះសព្វគ្រប់ហើយ ចណ្ឌាលមាណពជាគ្រូផ្តាំទូលបង្គំថា បើមានអ្នកណាម្នាក់ចង់រៀនមន្តអាគមនេះក្តី ចង់ដឹងពីគ្រូរបស់អ្នកក្តី ចូរអ្នកកុំលាក់ក្បួន និងនាមត្រកូលរបស់គ្រូអ្នកឱ្យសោះ បើមិនប្រតិបត្តិដូច្នោះទេមន្តអាគមទាំងនោះ មុខជាសាបវិនាសជាមិនខាន ។

បពិត្រព្រះករុណាថ្លៃវិសេស ពេលដែលទូលបង្គំបានទទួលមហា-កិត្តិយសពីព្រះអង្គហើយ កិត្តិយសរបស់ទូលបង្គំនេះក៏ទទួលការអញ្ជើញពីព្រះជនិន្ទ្រាធិរាជ ឱ្យចូលរួមប្រជុំជាមួយនឹងអ្នកប្រាជ្ញវិទ្យា-សាស្ត្រទាំងឡាយ និងនាម៉ឺនសព្វមុខមន្ត្រីរបស់ព្រះអង្គជាច្រើនរូប។ បន្ទាប់ពីសម្តែងមន្តអាគមក្នុងការដាំស្វាយទិព្វរួចហើយ ដោយលង់ក្នុងមហាកិត្តិយសដ៏ធំធេងនោះ ទូលបង្គំជាខ្ញុំ បានឆ្លើយទូលកុហកព្រះជនិន្ទ្រាធិរាជថា មន្តទិព្វទាំងឡាយដែលទូលបង្គំចេះនេះ ជាមន្តអាគមប្រចាំគ្រួសារព្រាហ្មណ៍របស់ទូលបង្គំ ។ ដោយខុសនឹងបណ្តាំរបស់គ្រូមន្តគាថាទាំងឡាយ ក៏វិនាសបង់សាបសូន្យ តាំងពីពេលនោះមក ។ ទូលបង្គំក៏ក្លាយខ្លួនជាបុគ្គលកំព្រាអភព្វម្នាក់ សំងំពួនយំតែម្នាក់ឯងមកដល់ថ្ងៃនេះ ។ ទូលបង្គំយល់ពីកំហុសដ៏ធ្ងន់របស់ខ្លួនហើយនេះជាការពិត ។ សូមព្រះអង្គទ្រង់ជ្រាប និងព្រះរាជទានទោសដល់ទូលព្រះបង្គំ ចំពោះកំហុសដ៏ធ្ងន់លើសលប់នេះផង ។

ព្រះរាជាទ្រង់បានជ្រាបហេតុការណ៍សព្វគ្រប់ហើយ ទ្រង់ក៏មានព្រះរាជបន្ទូលថា :

ម្នាលនាយព្រាហ្មណ៍ បុគ្គលណាដែលត្រូវការទឹកឃ្មុំ ទោះបីយកទឹកឃ្មុំពីដើមល្ហុងខ្វែក្តី ដើមឈើនោះ គឺជាឈើដ៏ប្រសើរ សម្រាប់បុគ្គល

នោះ ។ បុគ្គលដែលរៀនចេះដឹងធម៌ពីជនណាមួយ ទោះបីព្រះមហាក្សត្រក្តី មហាឥសីក្តី ចណ្ឌាលក្តី អ្នករើសសំរាមក្តី ជននោះយើងត្រូវចាត់ទុកជាគ្រូ ដែលជាជនដ៏ប្រសើរសម្រាប់បុគ្គលនោះ ។ ជនណាដែលញ៉ាំងប្រយោជន៍ដ៏ឧត្តម ដែលខ្លួនខំរកមកដោយលំបាកឱ្យវិនាសទៅវិញ ជននោះចាត់ទុកជាជនមានអតិមានះ ជាជនអាក្រក់ ជាជនអកតញ្ញូ ។ យើងគួរឱ្យអាជ្ញាធរចាប់ជននោះ យកមកផ្តន្ទាទោសទើបសម ។ នែនាយព្រាហ្មណ៍ ពេលនេះអ្នកមិនបាច់មកសុំទោសពីយើងទេ ជនដែលអ្នកត្រូវទៅសុំទោសនោះ គឺមាណពចណ្ឌាលនោះវិញទេ ចូរអ្នកទៅរកគ្រូអ្នកចុះ ។

នាយព្រាហ្មណ៍ មានការខ្មាសអៀនព្រះរាជាជាខ្លាំង ហើយថ្វាយបង្គំលាព្រះរាជា ចាកចេញពីព្រះបរមរាជវាំងយ៉ាងប្រញាប់ ។ នាយព្រាហ្មណ៍ក៏ទៅរកចណ្ឌាលមាណព ហើយអង្វរសុំទោសដោយប្រៀបខ្លួនហាក់ដូចជារឿងមនុស្សខ្វាក់ដើរជាន់ពស់វែក ដោយស្មានថាជាខ្សែគោ ។ ព្រាហ្មណ៍ខំអង្វរឱ្យចណ្ឌាលមាណពបង្រៀនមន្តអាគមសាជាថ្មីម្តងទៀត ។ តែចណ្ឌាលមាណពពោលតបវិញថា :

យើងបានបង្រៀនមន្តអ្នកដោយធម៌ អ្នកក៏បានខំសង្វាតសិក្សាដោយធម៌ដែរ ។ យើងពុំបានយករង្វាន់អ្វីពីអ្នកឡើយ បើអ្នកតាំងចិត្តរបស់

អ្នកនៅក្នុងធម៌ មន្តអាគមដែលកើតឡើងដោយធម៌នោះ ពុំអាចរត់ចោលអ្នកឡើយ ។ ដោយសារតែអ្នកខ្វះសីលធម៌ក្នុងខ្លួន រកបានសម្បត្តិដោយកម្រហើយ ហើយពុំចេះរក្សាទុក យើងចាត់ទុកអ្នកជាជនអកតញ្ញូ និងជាអ្នកពោលពាក្យកុហក ។ ចូរអ្នកត្រឡប់ទៅវិញចុះ អ្នកមិនអាចរក្សាមន្តគាថាទិព្វនោះបានទៀតឡើយ ។

បន្ទាប់មក នាយព្រាហ្មណ៍ ក៏លាគ្រូចេញទៅវិញ ដោយសេចក្តីអស់សង្ឃឹម និងសោកសៅជាខ្លាំង ។

ព្រាហ្មណ៍បានវិនាសបាត់បង់នូវទ្រព្យសម្បត្តិ និងកិត្តិយសដ៏ធំធេង ដោយសារភាពនៃខ្លួនជាមនុស្សអកតញ្ញូ ។

បុគ្គលមិនគួររមិលគុណចំពោះបុគ្គលណាមួយ ដែលមានឧបការៈគុណចំពោះខ្លួនឡើយ ។ បុគ្គលជ្រកក្រោមម្លប់ឈើណា មិនគួរកាប់បំផ្លាញនូវម្លប់ឈើនោះចោលឡើយ ។

គ្រូចណ្ឌាលនោះ បានមកជាព្រះអរហន្តសម្មាសម្ពុទ្ធនេះឯង ។ ចំណែកឯនាយព្រាហ្មណ៍ដែលវិនាសមន្តនោះ បានមកជាភិក្ខុទេវទត្ត ៕

## ៧. ប្រើសមាសសង្គ្រោះជីវិតព្រះបាទព្រហ្មទត្ត

មានរឿងតំណាលថា ថ្ងៃមួយព្រះបាទព្រហ្មទត្ត ទ្រង់យាងចេញទៅបរបាញ់សត្វជាមួយនឹងរេហ៍ពលជាច្រើន ។ ក្នុងពេលបរបាញ់សត្វនោះ អាជានេយ្យរបស់ព្រះបាទព្រហ្មទត្តរត់លឿនជាងគេ ។ ពេលនោះ ព្រះអង្គបានដេញតាមបាញ់សត្វប្រើសមួយដែលមានរោមភ្លឺដូចមាស ។ សត្វប្រើសមាស ក៏រត់យ៉ាងលឿនចូលព្រៃជ្រៅទៅៗ រហូតព្រះរាជាឃ្លាតដាច់ឆ្ងាយពីពលសេនាទាំងឡាយ ។ ដោយព្រះទ័យព្រះអង្គ ផ្តោតជាប់ក្នុងការតាមបាញ់ប្រើសមាសនោះពេក ទើបទ្រង់ពុំបានឃើញជ្រោះថ្មមួយដែលនៅបាំងផ្លូវពីមុខព្រះអង្គ ។ តែអាជានេយ្យរបស់ព្រះអង្គឃើញទាន់ ក៏ឈប់ផ្អាក់ជាបន្ទាន់ បណ្តាលឱ្យព្រះរាជាធ្លាក់ចូលទៅក្នុងជ្រោះតែម្តង ។ ប្រើសមាសក៏រត់តទៅមុខទៀត បន្តិចក្រោយមក ក៏ងាកមើលមកវិញ តែពុំឃើញស្តេចតាមប្រកិតដូចមុនទៀតឡើយ ។ ប្រើសមាសឆ្ងល់ជាខ្លាំង ក៏នឹកសង្ស័យថា ព្រះរាជាប្រហែលជាធ្លាក់ចូលក្នុងជ្រោះថ្មនោះជាមិនខាន ។ ភ្លាមនោះ ប្រើសមាសក៏រត់ត្រឡប់មកក្រោយវិញ ទើបឃើញស្តេចធ្លាក់ទៅក្នុងជ្រោះនោះមែន ។ ប្រើសមាសបានអើតទៅក្នុងជ្រោះ ហើយសួរព្រះរាជាថា :

ព្រះរាជាទ្រង់មានរបួសធ្ងន់ទេព្រះអង្គ? សូមព្រះអង្គគង់ស្ងៀមមួយកន្លែងសិន ទូលបង្គំនឹងចុះទៅជួយព្រះអង្គឱ្យគង់លើខ្នង ទូលបង្គំនឹងយាងព្រះអង្គឡើងចេញពីជ្រោះនេះ ក្រាបទូល! ។

ព្រះបាទព្រហ្មទត្តទ្រង់ព្រះសណ្ដាប់នូវពាក្យដ៏ផ្អែមពីរោះរបស់សត្វប្រើសដូច្នេះហើយ ទ្រង់មានការភ្ញាក់ស្រឡាំងកាំងជាខ្លាំង ហាក់ដូចជាពុំជឿព្រះកាណ៌របស់ព្រះអង្គឡើយ ។ ព្រះរាជាទ្រង់គិតថា :

ប្រើសនេះ មកជួយសង្គ្រោះអញ បើអញជាសត្រូវរបស់គេសោះ អម្បាញ់មិញនេះ ។ ឥឡូវ ស្រាប់តែត្រឡប់មកជួយជីវិតអញទៅវិញ គួរឱ្យអៀនខ្មាសណាស់ ។

គិតដូច្នេះហើយ ព្រះបាទព្រហ្មទត្តទ្រង់មានបន្ទូលតបទៅកាន់សត្វប្រើសមាសនោះវិញថា :

ម្នាលប្រើសមាសដ៏ឧត្ដម យើងធ្វើខុសចំពោះអ្នកធ្ងន់ណាស់ ព្រោះយើងព្យាយាមតាមសម្លាប់អ្នក ហេតុអ្វីក៏អ្នកត្រឡប់មកជួយសង្គ្រោះជីវិតយើងទៅវិញ ។

ប្រើសមាសឆ្លើយតបទៅកាន់ព្រះរាជាវិញ ដោយទន់ភ្លន់ថា :

បពិត្រព្រះរាជា ព្រះអង្គជាស្ដេចដ៏ខ្ពង់ខ្ពស់ក្នុងដែនកាសី ការជួយសង្គ្រោះជីវិតព្រះអង្គដែលមានទុក្ខ ជាភារៈរបស់ទូលព្រះបង្គំ ។ សូមព្រះអង្គកុំរង្កៀសព្រះរាជហឫទ័យធ្វើអ្វី ក្រាបទូល! ។

ក្រោយពេលបានយាងចេញពីជ្រោះរួចហើយ ព្រះបាទព្រហ្មទត្តក៏ថ្វាយបង្គំសូមខមាទោសមហាសត្វប្រើសមាស ហើយប្រកាសថា :

ចាប់ពីថ្ងៃនេះតទៅ យើងសូមប្រគល់រាជបល្ល័ង្កដែនកាសីដល់អ្នក ហើយសូមអ្នកអញ្ជើញទៅគ្រប់គ្រងរាជ្យជំនួសយើងចុះ ។ នេះជាការតបស្នងសងគុណរបស់យើងចំពោះអ្នក ដើម្បីឱ្យសមតាមគុណធម៌ដ៏ខ្ពង់ខ្ពស់របស់អ្នក ។ អ្នកមិនត្រូវរស់នៅក្នុងព្រៃនេះតទៅទៀតឡើយ ។

សត្វប្រើសមាស បានឆ្លើយតបព្រះរាជាដោយគោរពថា :

បពិត្រមហារាជ ខ្ញុំព្រះករុណាមានសេចក្ដីត្រេកអរ ចំពោះសន្ដានព្រះទ័យដ៏ល្អរបស់ព្រះអង្គណាស់ តែព្រៃនេះជានគររបស់ទូលព្រះបង្គំ ។ ទូលព្រះបង្គំបានសេចក្ដីសុខនៅទីនេះហើយ បើព្រះអង្គចង់តបគុណដល់ទូលបង្គំ សូមព្រះអង្គចាប់រក្សានិច្ចសីលពីពេលនេះតទៅ ។ សូមព្រះអង្គអនុគ្រោះបុត្រ មហេសី នាម៉ឺន មន្ត្រី ប្រជានុរាស្ត្រ

ប្រកបដោយធម៌ និងគ្រប់គ្រងរដ្ឋតាមគន្លងទសពិធរាជធម៌ និង ព្រហ្មវិហារធម៌ ។ ម្យ៉ាងទៀត សូមមហាបពិត្រទ្រង់មាននូវសង្គហវត្ថុ ទាំង ៤ ចំពោះប្រជាពលរដ្ឋរបស់ព្រះអង្គសព្វកាល ហើយញ៉ាំងរដ្ឋ របស់ព្រះអង្គ ឱ្យរីងរឹតតែចម្រើនរុងរឿងថ្កុំថ្កើងអស់កាលជាអង្វែង ។

ព្រះបាទព្រហ្មទត្តទ្រង់បានទទួលការប្រៀនប្រដៅរបស់មហាសត្វ ប្រើសមាសហើយ ស្ដេចក៏យាងត្រឡប់ទៅកាន់នគរវិញ ដោយសេចក្ដីសុខ ក្សេមក្សាន្ត ចម្រើនរុងរឿង រហូតតរៀងមក ៕

**សំណួរត្រិះរិះ**

១- តើមហាពោធិសត្វប្រើសមាស និងព្រះបាទព្រហ្មទត្ត បានអនុវត្តនូវ សីលធម៌អ្វី ទើបផ្សះផ្សារបួសនៃការព្យាបាទនេះបាន?

២- តើយើងមានវិធីយ៉ាងណាខ្លះ ដើម្បីប្រព្រឹត្តខ្លួនឱ្យល្អ ក្នុងពេលមាន បុគ្គលណាមួយមកព្យាបាទយើង?

## ៨. មហាពាណិជជាតក

ព្រះសម្មាសម្ពុទ្ធបរមគ្រូនៃយើង ទ្រង់សម្ដែងព្រះធម៌ទេសនាថា...

នាអតីតកាលដ៏យូរលង់អង្វែងមក ព្រះពោធិសត្វទ្រង់ចាប់កំណើតជាកូនអ្នកជំនួញម្នាក់ នៅក្រុងពារាណសី ។ ដោយព្រះពោធិសត្វមានឫកពាទន់ភ្លន់ ចរិយាសម្បត្តិប្រកបដោយធម៌ អ្នកផងទាំងពួងនិយមហៅលោកថា "**មហាពាណិជ**" ។ អ្នកជំនួញទាំងឡាយតែងគោរព និងលើកលោកជាមេដឹកនាំ ក្នុងការរកស៊ីរបស់ពួកគេ ។

ក្នុងសម័យថ្ងៃមួយ ពួកពាណិជនាំគ្នាធ្វើដំណើរជួញដូរ ឆ្លងកាត់ផ្លូវកន្តារៈដែលជាវាលខ្សាច់ដ៏ឆ្ងាយ ដាច់បាយ ដាច់ទឹក មានអាការៈហេវហត់អស់កម្លាំងយ៉ាងខ្លាំង ។ ការធ្វើដំណើរដោយការផ្សងព្រេង មានសភាពលំបាកបែបនេះ ទើបនាយមហាពាណិជនិយាយទៅកាន់ពួកពាណិជថា:

> ពួកយើងរកកន្លែងសមគួរសម្រាកសិន ព្រោះពួកយើង និងគោរបស់យើង មុខជាអស់កម្លាំងខ្លាំងណាស់ហើយ ។ ចាំពេលត្រជាក់បន្តិច យើងនឹងបន្តដំណើរទៅមុខទៀត ។ បើពួកយើងបានសម្រាកជាការប្រសើរណាស់ ។

ពួកឈ្មួញទាំងឡាយឆ្លើយតបមហាពាណិជ ដោយកង្វល់ថា :

ពួកយើងហត់ហេវខ្លាំងណាស់ តើពួកយើងនឹងឈប់នៅទីណាហ្ន
បើវាលធំល្វឹងល្វើយយ៉ាងនេះ?

មហាពាណិជ :

ខ្ញុំសង្ឃឹមថា យើងនឹងអាចរកជម្រកនាពេលខាងមុខនេះបានជាមិន
ខាន ។ សូមអ្នកទាំងអស់គ្នាទ្រាំអត់ធ្មត់បន្តិចសិនចុះ ។

ក្បួនរទេះជំនួញ ក៏បន្តដំណើរទៅមុខទៀតដោយការលំបាក ។ លុះយូរបន្តិចមក ក្បួនរទេះក៏បានជួបដើមជ្រៃដ៏ធំមួយ មានមែកសាខា និងម្លប់ត្រជាក់គួរជាទីរីករាយ ។ ពួកអ្នកជំនួញទាំងនោះ មានសេចក្ដីត្រេកអរផុតឧបមា ក៏នាំគ្នាបញ្ឈប់ក្បួនរទេះ សម្រាកយកកម្លាំងក្រោមម្លប់ជ្រៃនោះ ។

នៅពេលដែលអ្នកជំនួញទាំងអស់សម្រាកហើយ គេពិនិត្យឃើញមានឫសនិងមែកជ្រៃ ដែលធ្លាក់សំយុងចុះមកក្រោម ហាក់ដូចជាមានទឹកសើមៗ ហូរតក់ៗ បន្តិចៗមក ។

**កាប់មែកខាងកើត** : ដោយឃើញព្រឹត្តិការណ៍នេះ ទើបគេនាំគ្នាកាប់មែកខាងកើតទម្លាក់មក ។ រំពេចនោះ ស្រាប់តែមានទឹកដ៏ថ្លាធ្វង់ហូរចេញមក ហាក់ដូចទឹកភ្លៀងធ្លាក់ពីលើមេឃ ។ ពួកគេក៏នាំគ្នាផឹកផង ផ្ងូត

សម្អាតរូបរាងកាយផង និងឱ្យគោផឹកផង ដោយភាពសប្បាយរីករាយជាទីបំផុត ។

**កាប់មែកខាងត្បូង** : បន្ទាប់មក ឈ្មួញទាំងឡាយរឹតតែសង្ស័យផង និងចង់ដឹងផងថា តើមានអ្វីទៀតនៅមែកខាងត្បូង? ពិភាក្សាគ្នាដូច្នេះហើយ ឈ្មួញទាំងឡាយក៏នាំគ្នាកាប់មែកជ្រៃនៅទិសខាងត្បូងទៀត ។ គ្រាន់តែកាប់ភ្លាម ស្រាប់តែមានចំណីអាហារដ៏ឈ្ងុយឈ្ងប់ជាច្រើនមុខ ធ្លាក់ចុះមកពាសពេញក្រោមដើមជ្រៃ ហាក់ដូចជាចំណីធ្លាក់ពីសួគ៌ា ។ ដោយសេចក្តីស្រេកឃ្លានជាខ្លាំងក្នុងការធ្វើដំណើរ ឈ្មួញទាំងឡាយក៏បាននាំគ្នាបរិភោគចំណីអាហារទាំងនោះ ទាល់តែឆ្អែតយ៉ាងស្កប់ស្កល់ ។

**កាប់មែកខាងលិច** : ដោយសេចក្តីលោភៈ និងមោហៈបិទបាំង ពួកឈ្មួញទាំងឡាយ ក៏កាប់មែកខាងលិចទៀត ។ ពេលនោះហាក់ដូចជាទេពនិម្មិត គ្រាន់តែមែកជ្រៃធ្លាក់ចុះដល់ដីកាលណា ស្រាប់តែមានស្រីៗ ដ៏សែនស្អាតដូចទេពអប្សរជាច្រើន ចុះមកពីលើដើមឈើ រាំផង ច្រៀងផង យ៉ាងរីករាយ ។ ពួកឈ្មួញបាននាំគ្នាយកស្រីមួយម្នាក់ៗទៅសេពកាម ដោយក្តីសប្បាយត្រេកត្រអាលយ៉ាងក្រៃលែង ។ មានតែមហាពាណិជម្នាក់គត់ដែលគេចខ្លួនចេញពីស្រីៗទាំងនោះ ទោះបីស្រីៗមកចោមរោមលួងលោមសូមស្នេហ៍យ៉ាងណា ក៏មិនលុះក្នុងអំណាចកាមតណ្ហាដែរ ។

***កាប់មែកខាងជើង*** : បន្ទាប់មក ពួកឈ្មួញទាំងនោះជំនុំគ្នាសម្រេចចិត្តកាប់មែកខាងជើងទៀត ទោះមានការជំទាស់ពីមហាពាណិជ ជាមេដឹកនាំក្តី ។ គ្រាន់តែកាប់ភ្លាម ក៏ស្រាប់តែធ្លាក់នូវត្បូងពេជ្រ ចរណៃ កែវកង និងគ្រឿងអលង្ការមាសជាច្រើនឥតគណនា ។ ពួកគេម្នាក់ៗ បាននាំគ្នាលោតកញ្ឆេងប្រញាប់ប្រញាល់ជញ្ជូនមាស ប្រាក់ និងត្បូងចរណៃទាំងនោះ ផ្ទុកលើរទេះរៀងៗខ្លួន ។ មហាពាណិជបានសង្កេតមើលនូវអំពើលោភលន់របស់ពាណិជទាំងឡាយ ដោយសេចក្តីសង្វេគ ។

លុះជញ្ជូនកែវកងចរណៃទាំងអស់ ដាក់ក្នុងរទេះពេញបរិបូណ៌រៀងៗខ្លួនហើយ ពួកគេជំនុំគ្នាចង់កាប់ដើមឈើទាំងមូលតែម្តង ។ ភ្លាមនោះមានឈ្មួញម្នាក់ពោលឡើងថា :

> ពួកយើងត្រូវតែកាប់ដើមឈើទាំងមូលឱ្យរលំទៀត ព្រោះគ្រាន់តែមែកមួយៗសោះ យើងទទួលបានភោគផលដ៏សម្បើមណាស់ទៅហើយ ចុះចំណង់បើកាប់ដើមឈើទាំងមូលទៀត យើងមុខតែបានទ្រព្យដ៏សន្ធឹកសន្ធាប់ ហើយប្លែកជាងនេះជាមិនខាន ។

ពេលនោះ មហាពាណិជបានជញ្ជឹងគិតតែម្នាក់ឯង ក្នុងចិត្តថា :

សូម្បីបានបរិភោគទឹក អាហារ ត្រេកត្រអាលនឹងកាមគុណយ៉ាង ស្កប់ស្កល់ ព្រមទាំងបានមាសពេជ្រដ៏ច្រើនសន្ធឹកសន្ធាប់ហើយក្តី ពួកគេនៅតែចង់កាប់ដើមជ្រៃទាំងមូលថែមទៀត ។ នេះជាអំពើដ៏ សាហាវ យង់ឃ្នង់ខ្លាំងណាស់ ។

គិតដូច្នោះហើយ មហាពាណិជលើកដៃសំពះអង្វរឈ្មួញទាំងនោះថា :

នៃឈ្មួញទាំងឡាយ អ្នកបានជ្រកដោយសុខសាន្តនៅក្រោមម្លប់ជ្រៃ ហើយបានកាប់មែកយកទឹក ចំណីអាហារបរិភោគ ស្រីៗមកបំពេញ កាមដោយស្កប់ស្កល់ ហើយថែមទាំងបានយកត្បូង កែវកង មាស ប្រាក់គ្រប់បែបយ៉ាងធ្វើជាទ្រព្យរៀងៗខ្លួន ។ ប៉ុណ្ណឹងហើយ អ្នកនៅ មិនទាន់ឆ្អែតឆ្អន់ទៀត អ្នករាល់គ្នាចង់កាប់ទាំងដើមជ្រៃត្រង់គោល នេះថែមទៀត ។ នេះជាអំពើដ៏ព្រៃផ្សៃណាស់ សូមអ្នកទាំងឡាយ ឈប់ត្រឹមនេះហើយ ខ្ញុំសូមអង្វរ ។ អ្នកបានជ្រកហើយ មិនត្រូវកាប់ បំផ្លាញជម្រករបស់អ្នកទេ ។

ពេលនោះ គ្មានអ្នកណាម្នាក់បានយកត្រចៀកស្តាប់ឡើយ ។

**កាប់រំលំដើមជ្រៃទាំងមូល** : ឈ្មួញទាំងឡាយ ជាអ្នកងងឹតងងុល ដោយក្តីលោភពុំបានយកចិត្តទុកដាក់នឹងការអង្វររបស់មហាពាណិជឡើយ

ពួកគេក៏នាំគ្នាកាប់ដើមជ្រៃទាំងមូលឱ្យរលំគ្រេង ដោយសង្ឃឹមថា នឹងបានទ្រព្យសម្បត្តិជាច្រើនទៀត ។ ស្រាប់តែរំពេចនោះ មាននាគចំនួន ២៥ ក្បាលធំៗ ប្រដាប់ដោយលំពែង ធ្នូ ព្រួញភ្លើង ផុសលេចចេញមកពីផែនដី នាគលល់ជ្រៃដែលទើបរលំ ហើយស្រែកហ៊ោសន្ធាប់ សឹងរញ្ជួយផែនដី គួរឱ្យព្រឺព្រួចខ្លាចឥតឧបមាៗ នាគរាជបញ្ជាឱ្យកងសេនាទាំងនោះបាញ់ភ្លើងសម្លាប់ពួកឈ្មួញលួងខ្លៅស្លាប់វិនាសទាំងអស់ លើកលែងតែមហាពាណិជម្នាក់គត់ ដែលនៅពីចម្ងាយឈរមើលព្រឹត្តិការណ៍នេះ នៅមានជីវិតគង់វង្ស ហើយក៏ត្រឡប់ទៅកាន់គេហដ្ឋានវិញដោយសុវត្ថិភាព ។ រីឯកែវកង មាស ពេជ្រ ទាំងប៉ុន្មាន និងរទេះគោ ក៏ត្រូវវិនាសឆេះខ្ទេចខ្ទី គ្មានសល់បន្តិចឡើយ ។

មហាពាណិជ គឺជាតួអង្គព្រះពោធិសត្វ ដែលទ្រង់បានត្រាស់ដឹងជាព្រះសម្មាសម្ពុទ្ធបរមគ្រូនៃយើង នាភទ្ទកប្បនេះ ។

ព្រះសម្មាសម្ពុទ្ធទ្រង់បញ្ចប់រឿងមហាពាណិជដោយព្រះពុទ្ធវាទថា :

*បុគ្គល កាលបានអង្គុយ ឬជ្រកក្រោមម្លប់នៃឈើណា មិនត្រូវកាប់បំបាក់មែកឈើនោះឡើយ ព្រោះថាបុគ្គលអ្នកទ្រុស្តមិត្ត ជាមនុស្សអាក្រក់ឃោរឃៅពន់ពេកណាស់ ៕*

***ពិចារណា*** :

*សូមលោកអ្នកអានជាទីមេត្រី រកឧទាហរណ៍រឿងផ្សេងៗក្នុងជីវិតបច្ចុប្បន្ន ឬរឿងបុរាណ ដែលមានលំនាំដូចគ្នានឹងរឿងខាងលើនេះ ដើម្បីធ្វើការសិក្សាប្រៀបធៀប ។*

## ៩. សុវណ្ណហំសជាតក

## (សេចក្ដីលោភលន់រមែងនាំមកនូវក្ដីវិនាស)

ព្រះបរមសាស្ដា កាលគង់នៅក្នុងវត្តជេតពន ជាអារាមដែលសាង ដោយអនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ សម័យនោះឯង មានឧបាសក ម្នាក់ ជាអ្នកមានសេចក្ដីជ្រះថ្លាក្នុងព្រះរតនត្រ័យ បានបវារណាភិក្ខុនីសង្ឃ ដោយពាក្យថា :

បពិត្រព្រះនាងម្ចាស់ដ៏ចម្រើន ខ្ញុំព្រះករុណាសូមបវារណានូវខ្ទឹម ចំពោះភិក្ខុនីទាំងឡាយ បើព្រះនាងម្ចាស់ត្រូវការ សូមនិមន្ដទៅយក ពីផ្ទះខ្ញុំព្រះករុណាក៏បាន ឬនៅឯចម្ការក៏បាន ។

កាលនោះ ឧបាសកក៏បានប្រាប់ដល់នាយអ្នករក្សាចម្ការថា :

ប្រសិនបើមានភិក្ខុនីនិមន្ដមក ត្រូវការរបស់អ្វីមួយ ចូរអ្នកចាត់ចែង ប្រគេនចំពោះភិក្ខុនីនោះចុះ ។

ចាប់ពីពេលនោះមក ភិក្ខុនីទាំងឡាយតែងនិមន្ដទៅសុំខ្ទឹមពីផ្ទះ ឧបាសកនោះខ្វះ ពីចម្ការខ្វះ ។ មានភិក្ខុនីមួយក្រុម ដឹកនាំដោយភិក្ខុនី ព្រះ នាម **ថុល្លនន្ទា** នាំបរិវាររបស់ខ្លួនចូលទៅសុំខ្ទឹមនៅឯផ្ទះ រហូតដល់អស់ខ្ទឹម រលីងពីផ្ទះ ហើយបាននាំគ្នាទៅសុំនៅឯចម្ការទៀត រហូតអស់ខ្ទឹមរលីងពី

ចម្ការ មិនមានសេសសល់បន្តិចឡើយ ។ ការសុំខ្ទឹមមិនប្រមាណនេះ ធ្វើឱ្យនាយរក្សាចម្ការតិះដៀលយ៉ាងខ្លាំង ចំពោះក្រុមភិក្ខុនីថុល្លនន្ទាថា ជាអ្នកមិនស្គាល់ប្រមាណក្នុងការសូមសោះ ។ ការតិះដៀលនេះ ក៏ឮដល់ភិក្ខុនីទាំងឡាយ ។ ភិក្ខុនីណាជាអ្នកប្រាថ្នាតិច ក៏យករឿងរ៉ាវនោះប្រាប់ដល់ភិក្ខុទាំងឡាយ ។ ភិក្ខុទាំងឡាយក៏ក្រាបបង្គំទូលដល់ព្រះបរមសាស្តា ។ ព្រះពុទ្ធជាម្ចាស់ទ្រង់បានបន្ទោសភិក្ខុនីថុល្លនន្ទាថា :

ម្នាលភិក្ខុទាំងឡាយ បុគ្គលជាអ្នកប្រាថ្នាច្រើន មិនជាទីស្រឡាញ់ មិនជាទីពេញចិត្ត សូម្បីចំពោះម្តាយបង្កើតរបស់ខ្លួនឯង ។ អំពើនេះ មិនមែននាំឱ្យជ្រះថ្លាដល់បុគ្គលដែលមិនទាន់ជ្រះថ្លាទេ មិនមែនពង្រឹងសេចក្តីជ្រះថ្លាឡើង ដល់បុគ្គលដែលមានសេចក្តីជ្រះថ្លាហើយនោះទេ, មិនមែនញ៉ាំងលាភដែលមិនទាន់កើតឡើង ឱ្យកើតឡើងនោះទេ មិនមែនញ៉ាំងលាភដែលកើតឡើងហើយ ឱ្យតាំងនៅឡើយ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីថុល្លនន្ទានេះ មិនមែនជាអ្នកប្រាថ្នាច្រើនតែក្នុងបច្ចុប្បន្នជាតិនេះទេ សូម្បីក្នុងអតីតជាតិ ក៏ជាអ្នកប្រាថ្នាច្រើនផងដែរ ។

កាលព្រះពុទ្ធជាម្ចាស់ ទ្រង់ណែនាំភិក្ខុនីរូបនេះហើយ ព្រះអង្គបាននាំរឿងអតីតនិទានជាតក មកសម្តែងដូច្នេះថា :

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្តគ្រងរាជ្យក្នុងដែនកាសី ដែលមានទីក្រុងឈ្មោះ **ពារាណសី** ។ ក្នុងសម័យកាលនោះ ព្រះពោធិសត្វយោនយកកំណើតកើតក្នុងត្រកូលព្រាហ្មណ៍ ក្នុងក្រុងពារាណសីនោះ ។ កាលព្រះពោធិសត្វ មានវ័យពេញកំលោះ បានរៀបការជាមួយនឹងស្ត្រីដែលមានត្រកូលព្រាហ្មណ៍ដូចខ្លួនដែរឈ្មោះថា **ព្រាហ្មណី** ហើយបន្ទាប់មកក៏បានកូនស្រីបីនាក់គឺ **នន្ទា១ នន្ទាវតី១ សុន្ទរីនន្ទា១** ។ ក្រោយមក ព្រះពោធិសត្វបានធ្វើមរណកាលទាំងខ្លួននៅក្នុងមជ្ឈិមវ័យ ហើយទៅកើតក្នុងកំណើតជាសត្វហង្ស មានពណ៌ដូចជាមាស ហៅថា **សុវណ្ណហង្ស** ។ សុវណ្ណហង្សនោះ ក៏ពិចារណានូវអត្តភាពរបស់ខ្លួនកើតពីទីណា ទើបរលឹកជាតិថា ពីជាតិមុន ខ្លួនជាព្រាហ្មណ៍ដែលមានភរិយា និងកូនស្រី ៣ នាក់ ។ ចំណែកនាងព្រាហ្មណី និងកូនស្រីទាំង ៣ នាក់ មានជីវភាពសែនលំបាក ដោយធ្វើការស៊ីឈ្នួលអ្នកដទៃដើម្បីចិញ្ចឹមជីវិត ។ សុវណ្ណហង្សក៏កើតមានចិត្តករុណាគិតថា អាត្មាអញជាឪពុកស្លាប់ចោលកូនទាំង ៣ នាក់ និងភរិយា ឱ្យគ្នាកំព្រារងទុក្ខវេទនា ចិញ្ចឹមជីវិតសែនលំបាកពេកក្រៃ ។ បើដូច្នោះ គួរតែអាត្មាអញទៅជួយសង្គ្រោះដល់កូន និងភរិយានោះ ដើម្បីឱ្យមានជីវភាពរស់នៅសុខស្រួល ។ ក្នុងកាលនោះ សុវណ្ណហង្សបានហើរចុះក្នុងផ្ទះរបស់ភរិយា ។ ស្ត្រីទាំងនោះមានការភ្ញាក់ផ្អើល ហើយក៏សួរថា :

អ្នកជានរណា? ហើយមកពីណាដែរ?

សុវណ្ណហង្សប្រាប់ថា :

យើងត្រូវជាស្វាមី និងឪពុករបស់នាង ដែលស្លាប់ទៅបានកើតជាសត្វនេះឯង ។ យើងមកទីនេះ ដើម្បីផ្តល់ទ្រព្យដល់ពួកនាងសម្រាប់ចិញ្ចឹមជីវិត ។

សុវណ្ណហង្សក៏ជម្រុះស្លាបមួយដែលជាមាសសុទ្ធ ដល់ភរិយា និងកូនស្រី សម្រាប់យកទៅលក់យកប្រាក់ចិញ្ចឹមជីវិត ។ សុវណ្ណហង្ស តែងតែមកជម្រុះស្លាបមួយៗ ជារឿយៗ ហើយក៏ហើរទៅវិញបាត់ទៅ ។ ស្ត្រីទាំងនោះក៏ក្លាយជាអ្នកមានទ្រព្យសម្បត្តិស្តុកស្តម្ភ មានជីវភាពរស់នៅយ៉ាងខ្ពង់ខ្ពស់ លែងធ្វើការជាអ្នកស៊ីឈ្នួលគេ ដោយសេចក្តីករុណារបស់សុវណ្ណហង្ស ។ ស្រាប់តែថ្ងៃមួយ នាងព្រាហ្មណីជាម្តាយ និងធីតាទាំងបីនាក់ បានពិភាក្សាគ្នាដូច្នេះថា :

ធម្មតា សត្វតិរច្ឆានមានចិត្តអាក្រក់ណាស់ ថ្ងៃណាមួយ វាលែងយកស្លាបមាសមកឱ្យយើងទៀតហើយ ។ បើដូច្នោះ មានតែពួកយើងរកឧបាយចាប់សត្វហង្សនេះឱ្យហើយ រួចបោចយកស្លាបមាសឱ្យអស់ទុកជាទ្រព្យសម្បត្តិរបស់យើង ។

លុះដល់ថ្ងៃកំណត់យកស្លាបមាសមកជម្រុះ សុវណ្ណហង្សក៏ហើរមកចុះត្រង់គេហដ្ឋានរបស់ស្ត្រីទាំងនោះ ដូចកាលសព្វដង ។ កាលនោះនាងព្រាហ្មណីនិងកូនស្រី បាននាំគ្នាចាប់សុវណ្ណហង្ស រួចបោចយកស្លាបរហូតអស់ពីរាងកាយ ។ តែស្លាបដែលបោចទាំងនោះ មិនបានក្លាយមកជាមាសដូចមុនឡើយ  ក្លាយមកជាស្លាបធម្មតាវិញ ។

សុវណ្ណហង្សឈឺខ្លួនជាខ្លាំង ដោយស្ត្រីទាំងនោះ បោចស្លាបអស់ពីខ្លួន ហើយពុំអាចហើរត្រឡប់ទៅកាន់ព្រៃវិញបានឡើយ ។ បន្ទាប់មក ពួកស្ត្រីទាំងនោះក៏នាំគ្នាចិញ្ចឹមសុវណ្ណហង្សនោះ ដោយសង្ឃឹមថា សុវណ្ណហង្សនឹងដុះស្លាបមាសឡើងវិញ ។ ក្រោយមក ស្លាបសុវណ្ណហង្សដុះចេញមកសមល្មមអាចហើរ ក៏ហើរទៅកាន់លំនៅរបស់ខ្លួនក្នុងព្រៃជ្រៅបាត់ទៅ ។ ហើយសុវណ្ណហង្ស មិនបានត្រឡប់មកកាន់ទីនោះ រហូតដល់អស់ជីវិត ។

នាងព្រាហ្មណី និងកូនៗទាំងនោះ ជាអ្នកហិនហោចទ្រព្យសម្បត្តិដោយសារភាពលោភលន់ហួសព្រំដែន ជាអ្នកប្រាថ្នាច្រើនឥតពិចារណាខ្វះការសន្តោសចំពោះទ្រព្យសម្បត្តិដែលបានផ្តល់ឱ្យ ។

កាលព្រះពុទ្ធជាម្ចាស់ទ្រង់សម្តែងជាតកនេះចប់ហើយ ព្រះអង្គទ្រង់បានប្រជុំជាតកថា :

- សុវណ្ណហង្សនោះ គឺអង្គអរហន្តសម្មាសម្ពុទ្ធ
- នាងព្រាហ្មណីជាភរិយា បានមកជាភិក្ខុនីថុល្លនន្ទានេះឯង
- ចំណែកកូនស្រីទាំង ៣ នាក់ បានមកជាភិក្ខុនី ដែលជាប្អូនស្រីរបស់ភិក្ខុនីថុល្លនន្ទា គឺ ភិក្ខុនីនន្ទា១ ភិក្ខុនីនន្ទាវតី១ និងភិក្ខុនីសុន្ទរីនន្ទា១ ។

ព្រះបរមសាស្ដាទ្រង់ត្រាស់ថា :

ម្នាលភិក្ខុទាំងឡាយ ថុល្លនន្ទាភិក្ខុនីនេះ មិនមែនជាអ្នកប្រាថ្នាច្រើនតែក្នុងបច្ចុប្បន្ននេះទេ សូម្បីក្នុងអតីតជាតិ ក៏ជាអ្នកប្រាថ្នាច្រើន ហើយវិនាសនូវមាសដែលខ្លួនត្រូវបាន ព្រោះការលោភលន់នេះដែរ ។ ម្នាលភិក្ខុទាំងឡាយ ឥឡូវនេះក៏ជាអ្នកវិនាស ព្រោះភាពនៃខ្លួនជាអ្នកប្រាថ្នាច្រើនក្នុងខ្ទឹមនេះដែរ ព្រោះហេតុនោះ អ្នកទាំងឡាយបានរបស់ច្រើន ត្រូវស្គាល់ប្រមាណ អ្នកទាំងឡាយបានរបស់តិច ត្រូវជាអ្នកចេះសន្ដោសតាមអ្វីដែលខ្លួនមាន កុំជាអ្នកប្រាថ្នាច្រើនឱ្យសោះ ។ ជាការពិតណាស់ ការលោភលន់ តែងនាំមកនូវក្ដីវិនាស ។

ភិក្ខុទាំងឡាយក៏ទទួលព្រះពុទ្ធដីកាថា "សាធុ សាធុ សាធុ!" ៕

(ចប់សុវណ្ណហំសជាតក)

## ១០. ភិក្ខុនីមានគភ៌

កាលព្រះសាស្តាទ្រង់គង់នៅក្នុងវត្តជេតពន មានភិក្ខុនីមួយអង្គមានគភ៌[៦២] ធ្វើឱ្យផ្អើលជ្រួលច្របល់ក្នុងសម្នាក់ភិក្ខុសង្ឃ និងភិក្ខុនីសង្ឃ ។ ភិក្ខុនីទាំងឡាយបានចូលទៅសួរភិក្ខុនីនោះថា :

ម្នាលនាង នាងមានគភ៌ព្រោះហេតុអ្វី?

ភិក្ខុនីនោះឆ្លើយថា :

បពិត្រភិក្ខុនីដ៏ប្រសើរ ខ្ញុំមិនដឹងថា ហេតុអ្វីបានជាខ្ញុំមានគភ៌ទេ ។ ខ្ញុំម្ចាស់ជាអ្នកមានសីលបរិសុទ្ធ ខ្ញុំមិនដែលប្រព្រឹត្តខុសក្នុងធម៌ និងវិន័យឡើយ ។

ភិក្ខុនីទាំងឡាយក៏នាំភិក្ខុនីនោះ ទៅកាន់សម្នាក់ភិក្ខុទេវទត្ត ដែលជាមេគ្រប់គ្រងគណៈសង្ឃ ។ ភិក្ខុនីទាំងនោះបានពោលថា :

បពិត្រលោកម្ចាស់ កុលធីតានេះបានលះបង់ស្វាមី ហើយមកបួសស្រាប់តែមានគភ៌ ។ យើងខ្ញុំម្ចាស់មិនដឹងថា នាងមានគភ៌ក្នុងកាលនៅជាគ្រហស្ថ ឬបព្វជិតទេ, តើឱ្យយើងខ្ញុំម្ចាស់គួរធ្វើដូចម្តេច?

ភិក្ខុទេវទត្ត ជាបុគ្គលមិនមាននូវខន្តី និងមេត្តាធម៌ បានគិតថា :

---

[៦២] ភិក្ខុនីអង្គនេះគង់នៅវត្តរាជគ្រឹះ ជាសំណាក់របស់ភិក្ខុទេវទត្ត ។

គេនឹងតិះដៀលយើងថា ភិក្ខុនីក្នុងសម្នាក់ទេវទត្ត មានគភ៌គួរឱ្យ
ខ្ពើមរអើមណាស់ ទេវទត្តនេះជាអ្នកមិនចេះថែរក្សានូវពួកគណៈ
ខ្លួនសោះ ហេតុនេះយើងនឹងបណ្តេញភិក្ខុនីនេះចេញទើបបាន ។

ភិក្ខុទេវទត្តក៏បណ្តេញភិក្ខុនីនោះ ចេញតាមការគិតរបស់ខ្លួន, គ្រានោះភិក្ខុនីក៏គិតឡើងថា :

ភិក្ខុទេវទត្តនេះមិនមែនជាព្រះពុទ្ធឡើយ ហើយយើងក៏មិនមែនមកបួស ដោយសារយើងមានជំនឿលើភិក្ខុទេវទត្តនោះទេ គឺយើងបួសក្នុងសម្នាក់ព្រះសម្មាសម្ពុទ្ធ ជាព្រះអគ្គបុគ្គលដ៏ប្រសើរក្នុងលោក ។ ម្យ៉ាងទៀត ការបួសរបស់យើងដោយលំបាកខ្លាំងណាស់ យើងមិនអាចសឹកឡើយ យើងនឹងចូលទៅរកព្រះសាស្តាដើម្បីសូមឱ្យព្រះអង្គជួយដោះស្រាយនូវបញ្ហារបស់យើង ។

ភិក្ខុនីនោះ ក៏ធ្វើដំណើរចេញពីវត្តរាជគ្រឹះ ទៅកាន់វត្តជេតពន អស់ចម្ងាយផ្លូវ ៤០ យោជន៍ ។ ព្រះសាស្តា ទ្រង់ជ្រាបហេតុសព្វគ្រប់ ដោយសព្វញ្ញុតញ្ញាណថា ភិក្ខុនីនេះមានគភ៌តាំងពីនៅជាគ្រហស្ថមកម្ល៉េះ ។ តែព្រះអង្គ ក៏ទ្រង់ព្រះចិន្តាថា :

អធិករណ៍នេះ ត្រូវវិនិច្ឆ័យក្នុងបរិស័ទទាំង ៤ មួយអន្លើដោយព្រះរាជា ជាមុនសិន ។

លុះព្រឹកឡើង ព្រះអង្គទ្រង់ត្រាស់បង្គាប់ឱ្យយាងព្រះបាទបសេនទិ-កោសល មហាអនាថបិណ្ឌិកសេដ្ឋី ចុល្លអនាថបិណ្ឌិកសេដ្ឋី មហាឧបាសិកាវិសាខា និងឱ្យប្រជុំបរិស័ទទាំង ៤ ក្រោមអធិបតីភាពរបស់ព្រះឧបាលិ ដើម្បីជម្រះនូវអធិករណ៍របស់ភិក្ខុនីនោះ ។ ព្រះឧបាលិ គង់លើអាសនៈដ៏ប្រសើរ និងបានអញ្ជើញមហាឧបាសិកាវិសាខាមកក្នុងទីចំពោះមុខព្រះរាជាដើម្បីឱ្យជួយដោះស្រាយអធិករណ៍នេះ ។ ហើយព្រះឧបាលិ មានថេរដីកាថា :

ម្នាលនាងវិសាខា ចូរនាងសួរភិក្ខុនីនោះមើល តើនាងបួសក្នុងខែណាថ្ងៃណា ហើយត្រួតពិនិត្យមើលគភ៌របស់នាងផង តើនាងមានគភ៌មុន ឬក្រោយនៃការចូលសាងផ្នួស?

មហាឧបាសិកាវិសាខា ក៏បាំងវាំងននឱ្យភិក្ខុនីនោះអង្គុយ ហើយពិនិត្យមើលដៃជើង ផ្ចិត ពោះជាដើម ដោយសាកសួរថ្ងៃខែឆ្នាំ ដែលនាងបានចូលមកបួស ។ បន្ទាប់មក មហាឧបាសិកាទើបកំណត់ច្បាស់ថា :

"នាងមានផ្ទៃពោះតាំងអំពីនៅជាគ្រហស្ថមកម៉្លេះ";

ទើបមហាឧបាសិកាយករឿងនោះ ទូលដល់ព្រះឧបាលិឱ្យជ្រាប ។ ព្រះឧបាលិក៏ប្រកាសភាពបរិសុទ្ធរបស់ភិក្ខុនីនោះ ចំពោះមុខបរិស័ទទាំង ៤ ។ ភិក្ខុនីនោះក៏ថ្វាយបង្គំលាព្រះសាស្តា និងភិក្ខុសង្ឃទៅកាន់សម្នាក់របស់ខ្លួន

វិញ ។ មិនយូរប៉ុន្មាន ភិក្ខុនីក៏ប្រសូតនូវទារកមួយដ៏ស្អាត ហើយដាក់នាមថា **កស្សបៈ** ។ ខាងក្រោយមក ក៏មានឈ្មោះថា **កុមារកស្សបៈ** ។ ពេលដែលកុមារកស្សបៈចម្រើនវ័យបាន ៧ ឆ្នាំ ក៏ចេញទៅបួស ហើយសម្រេចជាព្រះអរហន្តមួយអង្គ ព្រះនាមថា **ព្រះកុមារកស្សបត្ថេរ** ។

សូមរំលឹកឡើងវិញថា ភិក្ខុនីនេះជាធីតារបស់លោកសេដ្ឋីម្នាក់ ដែលមានទ្រព្យសម្បត្តិជាច្រើន នៅក្នុងក្រុងរាជគ្រឹះ ។ សេដ្ឋីធីតានេះ មានសេចក្តីជ្រះថ្លាក្នុងព្រះពុទ្ធសាសនា នាងតែងតែសូមអង្វរមាតាបិតាជារឿយៗ ដើម្បីចេញទៅបួស តែមាតាបិតាតែងតែឃាត់ មិនអនុញ្ញាតឱ្យទៅបួសឡើយ ដោយលោកមានកូនស្រីតែមួយ ហើយនាងក៏គិតថា :

ប្រសិនបើអញមិនទៅបួសឥឡូវនេះទេ ដល់ពេលមានប្តី នឹងសុំប្តីទៅបួសឱ្យទាល់តែបាន ។

ពេលនាងពេញវ័យហើយ ក៏រៀបការជាមួយនឹងកូនសេដ្ឋីម្នាក់ដែលមានទ្រព្យសម្បត្តិស្តុកស្តម្ភដូចគ្នា ។ នាងជាអ្នកមានសីល មានកល្យាណធម៌ គោរពស្វាមីដូចជាទេវតា ។ ដោយការរួមរស់ជាមួយនឹងស្វាមី នាងក៏មានគភ៌ តែនាងមិនបានដឹងថា ខ្លួននាងមានគភ៌នោះទេ ។ គ្រានោះ នៅក្នុងនគរមានពិធីនក្ខត្តឫក្ស (បុណ្យចូលឆ្នាំ) ស្វាមីនាងបានឱ្យនាងតាក់តែងគ្រឿងអលង្ការដើម្បីឱ្យនាងដើរលេងកម្សាន្ត ដូចអ្នកស្រុកទូទៅ តែនាងពោលថា :

បពិត្រអយ្យបុត្ត ខ្ញុំមិនចូលចិត្តតាក់តែងគ្រឿងអលង្ការ និងរូបកាយ នេះទេ ព្រោះរូបកាយនេះជារបស់មិនស្អាត គួរឱ្យខ្ពើមរអើមណាស់..។

ពេលនោះ ស្វាមីក៏សួរថា :

ប្រសិនបើអូនបានឃើញទោសក្នុងរាងកាយយ៉ាងនេះ ហេតុអ្វីអូន មិនបួសទៅ?

នាងភរិយាឆ្លើយថា :

ប្រសិនបើអយ្យបុត្តអនុញ្ញាត ខ្ញុំនឹងទៅបួសក្នុងថ្ងៃនេះភ្លាម ។

សេដ្ឋីបុត្តក៏អនុញ្ញាតតាមសំណូមពររបស់នាង ដោយបានចាត់ចែង មហាទាន ធ្វើគ្រឿងសក្ការៈដ៏ធំ ហែហមនាងទៅបួសក្នុងសម្នាក់ភិក្ខុនីដែល ជាបក្សពួករបស់ភិក្ខុទេវទត្ត ។ កាលអធិករណ៍ស្ងប់រម្ងាប់តាមធម៌វិន័យហើយ ភិក្ខុទាំងឡាយ ក៏សរសើរព្រះដ៏មានព្រះភាគថា ព្រះសម្មាសម្ពុទ្ធព្រះអង្គជា ធម្មរាជ ព្រះអង្គបរិបូណ៌ដោយករុណាធម៌ និងមេត្តាធម៌ ទ្រង់អនុគ្រោះដល់ ភិក្ខុនី និងព្រះកុមារកស្សបៈ ឱ្យរួចផុតពីការគាបសង្កត់របស់ភិក្ខុទេវទត្ត ។ ខណៈនោះ ព្រះសាស្តាទ្រង់និមន្តមកកាន់ធម្មសភា ហើយគង់លើអាសនៈដ៏ ប្រសើរ រួចក៏ទ្រង់សួរភិក្ខុទាំងឡាយថា :

ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយកំពុងប្រជុំពិភាក្សាគ្នារឿងអ្វី?

ភិក្ខុទាំងឡាយក្រាបទូលព្រះសាស្តាថា :

បពិត្រព្រះដ៏មានព្រះភាគ យើងខ្ញុំព្រះករុណាកំពុងពិភាក្សានូវ មហាករុណាទិគុណរបស់ព្រះអង្គ ក្នុងរឿងអនុគ្រោះភិក្ខុនីដែល មានគភ៌ ។

ព្រះសម្មាសម្ពុទ្ធទ្រង់ឆ្លើយតបភិក្ខុទាំងឡាយថា :

ម្នាលភិក្ខុទាំងឡាយ តថាគតអនុគ្រោះអ្នកទាំងពីរនេះ មិនមែនត្រឹម តែក្នុងកាលឥឡូវនេះទេ សូម្បីក្នុងកាលជាតិមុន ក៏តថាគតអនុគ្រោះ ដល់អ្នកទាំងពីរនេះដែរ ។

បន្ទាប់មក ព្រះមានព្រះភាគ ក៏ទ្រង់និទានរឿងពីអតីតជាតិដូចតទៅ :

## និគ្រោធមិគជាតក

ក្នុងកាលកន្លងទៅ ព្រះបាទព្រហ្មទត្ត ទ្រង់បានសោយរាជ្យនៅក្នុងដែនកាសី ។ កាលនោះ ព្រះពោធិសត្វបានអន្ទោលកំណើតជាសត្វប្រើសឈ្មោះថា **និគ្រោធមិគរាជ** និងមានរោមពណ៌ល្អដូចជាមាស មានដួងនេត្រាដូចជាដុំនៃកែវមណី ហើយមានប្រើស ៥០០ ជាបរិវារ ។ នៅក្នុងព្រៃនោះដែរ មានក្រុមប្រើសដទៃ ៥០០ ទៀត ដឹកនាំដោយស្តេចប្រើសមួយ ឈ្មោះថា **សាខៈ** ។

សម័យនោះព្រះបាទព្រហ្មទត្ត ទ្រង់សព្វព្រះរាជហឫទ័យយកសាច់ប្រើសជាព្រះរាជក្រយាហារ ហើយទ្រង់តែងតែបញ្ជាប្រជារាស្ត្រ ឱ្យទៅបរបាញ់សម្លាប់សត្វប្រើសជារៀងរាល់ថ្ងៃ ។ ពួកពលទាំងនោះ តែងតែលះបង់ពេលវេលា ការងារផ្ទាល់ខ្លួនដែលត្រូវធ្វើ ដូចជាស្រែចម្ការជាដើម ។ ទង្វើនេះនាំឱ្យប្រជារាស្ត្រគិតគ្នាថា :

> ព្រះរាជាតែងតែធ្វើឱ្យការងារយើងវិនាស ព្រោះហេតុនោះ ពួកយើងនឹងដាំដើមឈើឱ្យច្រើនក្នុងឧទ្យានមួយ ហើយកៀរនូវពួកប្រើសឱ្យចូលទៅកាន់ឧទ្យាននោះ ។ បន្ទាប់មក យើងត្រូវធ្វើរបងឃាំងទុក សម្រាប់ព្រះរាជាបរបាញ់ដោយព្រះអង្គឯង កុំឱ្យរំខានដល់ការងារ និងផលដំណាំរបស់យើង ។

ប្រជារាស្ត្រទាំងនោះ ក៏ធ្វើដូចដែលពួកគេបានគិត ហើយឡោមព័ទ្ធព្រៃធ្វើជាឧទ្យានត្រឹមមួយយោជន៍ សម្រាប់ទុកថ្វាយព្រះរាជា ទ្រង់ក្រសាលបរបាញ់សត្វ ។ ក្រុមស្តេចប្រើសនិគ្រោធមិគរាជ និងក្រុមប្រើសសាខៈ ស្ថិតនៅក្នុងព្រៃឧទ្យានដែលមនុស្សបានធ្វើការឡោមព័ទ្ធនោះ ។

គ្រានោះ ព្រះរាជាមានព្រះទ័យរីករាយជាខ្លាំង ហើយបានសម្លឹងមើលពួកប្រើសក្នុងឧទ្យាន ក៏ទតឃើញប្រើស ២ គឺ **និគ្រោធមិគរាជ** និង**សាខៈ** ដែលមានពណ៌ល្អដូចមាស ទ្រង់ក៏ឱ្យអភ័យ[៦៣] ដល់សត្វទាំងពីរនោះ ។ ចាប់តាំងពីពេលនោះមក ពេលខ្លះព្រះរាជាក៏បរបាញ់សត្វដោយព្រះអង្គឯង ពេលខ្លះចុងភៅទៅបរបាញ់សត្វយកមកធ្វើក្រយាហារថ្វាយព្រះអង្គក៏មាន ។ ពួកប្រើសទាំងឡាយពេលបានឃើញធ្នូ តែងតែភិតភ័យតក់ស្លុតនឹងសេចក្តីស្លាប់ ហើយរត់ចុះរត់ឡើង ស្វែងរកទីពួន ។ សត្វខ្លះក៏មានរបួស សត្វខ្លះទៀតក៏ស្លាប់ ។ ក្រោយមក ពួកប្រើសទាំងនោះ យករឿងភ័យខ្លាចនេះ ទៅពិគ្រោះជាមួយនឹងនិគ្រោធមិគរាជតាមដំណើររឿង ។ ប្រើសព្រះពោធិសត្វក៏បានយករឿងនេះ ទៅពិគ្រោះជាមួយនឹងប្រើសសាខៈ ដោយពោលថា :

ម្នាលសម្លាញ់ ប្រើសជាច្រើនតែងតែវិនាស ហើយស្លាប់តែម្ខាងៗ

[៦៣] អភ័យ មានន័យថា ផុតគ្រោះភ័យពីមរណៈគឺព្រះរាជាលើកលែងមិនឱ្យគេសម្លាប់ ។

ហេតុនេះយើងត្រូវដាក់វេនដល់បរិវារខាងខ្ញុំ និងខាងអ្នក ដោយប្រចាំវេនថា សត្វណាដែលត្រូវស្លាប់ ត្រូវពាក់ចង្រ្កង់ត្រង់ក ហើយទៅដេកចាំនៅកន្លែងពិឃាតតែម្តង ។ កាលបើយើងធ្វើយ៉ាងនេះ សត្វដទៃនឹងមិនលំបាកភិតភ័យរត់គេចចុះឡើងឡើយ ។

សត្វប្រើសសាខៈ ក៏ទទួលយកនូវសំណើនេះ ។

តាំងពីនោះមក ប្រើសណាដែលដល់វេនត្រូវពិឃាត ប្រើសនោះត្រូវពាក់ចង្រ្កង់ត្រង់ក ហើយដើរទៅដេករង់ចាំនាយចុងភៅនៅកន្លែងពិឃាត ។ ដោយគ្រឿងសម្គាល់នេះ ព្រះរាជាក្តី នាយចុងភៅក្តី ដែលមកសម្លាប់សត្វធ្វើជាក្រយាហារ តែងតែសម្លាប់សត្វដែលពាក់ចង្រ្កង់ ។

សម័យថ្ងៃមួយ វេនប្រើសញីមួយដែលមានគភ៌មកដល់ ។ នាងមានឈ្មោះថា **មិគធេនុ** ត្រូវជាបរិវាររបស់ប្រើសសាខៈ ។ ប្រើសញីនោះ បានចូលទៅរកប្រើសសាខៈ ហើយពោលថា ៖

បពិត្រលោកម្ចាស់! នាងខ្ញុំមានគភ៌ត្រូវចូលទៅកាន់វេន ដូច្នេះខ្ញុំត្រូវស្លាប់ដល់ទៅពីរនាក់ ខ្ញុំសូមអង្វរលោកម្ចាស់ មេត្តាបង្អង់វេននាងខ្ញុំមួយរយៈសិន ។ កាលណាខ្ញុំម្ចាស់កើតកូនរួចហើយ នាងខ្ញុំនឹងទៅកាន់វេនមរណៈជាខាងក្រោយ ។

ប្រើសសាខៈពោលថា :

យើងមិនអាចផ្លាស់ប្តូរវេនឱ្យនាងបានទេ នាងត្រូវតែទៅកាន់វេនជាដាច់ខាត ។

កាលបើមិនបានទទួលការអនុគ្រោះពីប្រើសសាខៈជាមេ ប្រើសញីនោះ ក៏ធ្វើដំណើរចូលទៅរកប្រើសពោធិសត្វ ហើយប្រាប់រឿងរ៉ាវទាំងនោះដល់ប្រើសព្រះពោធិសត្វ ។ ប្រើសពោធិសត្វក៏ពោលថា :

នាងចូរទៅចុះ យើងនឹងដោះស្រាយបញ្ហាជូននាង ។

លុះព្រលឹមស្រាងៗ និគ្រោធមិគរាជពាក់ចង្រ្កង់ខ្លួនឯង ហើយដើរទៅកាន់ទីពិឃាត ។

នៅពេលដែលចុងភៅមកដល់ បានឃើញប្រើសមាសដែលមានអភ័យដេកនៅទីនោះ ក៏ប្រញាប់ទៅក្រាបទូលដល់ព្រះរាជា ។

ព្រះរាជាទ្រង់ឡើងព្រះរាជរថ មានបរិវារជាច្រើនហែហម បានចូលទៅរកប្រើសពោធិសត្វ ហើយសួរថា :

ម្នាលមិគរាជ ក្រែងយើងឱ្យអភ័យដល់អ្នកហើយឬ? ហេតុដូចម្តេចបានជាអ្នកមកដេកនៅទីនេះ រង់ចាំឱ្យគេពិឃាតអ្នកទៅវិញ?

ប្រើសព្រះពោធិសត្វក្រាបទូលព្រះរាជាថា :

បពិត្រមហារាជ មានប្រើសញីមួយមានគភ៌ ត្រូវដល់វេនគេសម្លាប់ ដោយខ្ញុំមានចិត្តអនុគ្រោះដល់ប្រើសញីនោះ ក៏យកជីវិតខ្លួនមកប្តូរ ជំនួសនាងវិញ ។

ព្រះរាជាទ្រង់មានព្រះរាជឱង្ការថា :

ម្នាលមិគរាជ ខ្ញុំមិនធ្លាប់ឃើញសោះ សូម្បីក្នុងមនុស្សដែលប្រកប ដោយករុណាធម៌ និងមេត្តាធម៌ប្រាកដដូចជាអ្នក រកបានដោយកម្រ ណាស់ យើងជ្រះថ្លានឹងអ្នកណាស់ អ្នកចូរក្រោកឡើង យើងឱ្យអភ័យ ដល់អ្នក និងប្រើសញីនោះ ។

ប្រើសពោធិសត្វពោលថា :

បពិត្រព្រះនរិន្ទរាជ ព្រះអង្គទ្រង់ឱ្យអភ័យដល់យើងទាំងពីរតែ ប៉ុណ្ណោះទេឬ? ចុះសត្វដទៃ តើព្រះអង្គនឹងធ្វើដូចម្តេច?

ព្រះរាជាទ្រង់ត្រាស់ថា :

ម្នាលមិគរាជ សូម្បីសត្វដទៃទៀត ក៏យើងឱ្យអភ័យដែរ ។

ប្រើសពោធិសត្វសួរទៀតថា :

បពិត្រព្រះមហារាជ ព្រះអង្គប្រទានអភ័យដល់ប្រើសតែក្នុងឧទ្យាន នេះប៉ុណ្ណោះទេឬ ចុះសត្វទាំងឡាយខាងក្រៅឧទ្យាន តើព្រះអង្គនឹងប្រទានអភ័យដែរឬទេ?

ព្រះរាជាទ្រង់តបថា :

ម្នាលមិគរាជ សូម្បីសត្វខាងក្រៅឯទៀត ក៏យើងផ្តល់អភ័យឱ្យដែរ ។

ប្រើសពោធិសត្វ បានសូមនូវអភ័យដល់សត្វទាំងអស់ រួមទាំងសត្វព្រៃ សត្វស្រុក សត្វស្លាប និងមច្ឆាគ្រប់ប្រភេទ ហើយបានញុំាងព្រះរាជាឱ្យសមាទានសីល ៥ រួចដាស់តឿនព្រះរាជាថា :

បពិត្រព្រះមហារាជ សូមព្រះអង្គប្រព្រឹត្តនូវធម៌ក្នុងមាតាបិតា បុត្រ-ធីតា ព្រាហ្មណ៍ គហបតី និងអ្នកនិគមជនបទចុះ កាលព្រះអង្គប្រព្រឹត្តឱ្យស្មើក្នុងបុគ្គលទាំងនោះ ក្រោយពីបែកធ្លាយរាងកាយទៅព្រះអង្គនឹងទៅកាន់សួគ៌ទេវលោក ។

ប្រើសពោធិសត្វបានឱ្យឱវាទដល់ព្រះរាជាយ៉ាងនេះ ហើយស្ថិតនៅក្នុងឧទ្យាននោះពីរបីថ្ងៃ ក៏នាំបរិវារចូលទៅកាន់ព្រៃវិញ ។ ចំណែកឯប្រើសញីក៏កើតកូនមានសម្បុរស្អាតដូចជាផ្កាកណិការ ។ កូនប្រើសនោះតែងតែទៅលេងក្នុងសម្នាក់ប្រើសសាខៈ ។ មេប្រើសញីក៏ពោលទៅកាន់កូនថា :

អ្នកចូរសេពគប់នូវប្រើសនិគ្រោធមិគរាជប៉ុណ្ណោះ កុំនៅជាមួយនឹង សាខៈឡើយ សេចក្ដីស្លាប់ក្នុងសម្នាក់ស្ដេចនិគ្រោធមិគរាជប្រសើរ ជាង ឯការរស់នៅក្នុងសម្នាក់សាខៈពុំប្រសើរឡើយ ។

ចាប់តាំងពីកាលនោះមក ពួកប្រើសបានទទួលអភ័យពីព្រះរាជា ហើយតែង តែទៅស៊ីសន្ទូងរបស់ប្រជារាស្ត្រ ហើយប្រជានុរាស្ត្រទាំងនោះ ក៏យករឿងរ៉ាវ ទៅក្រាបទូលដល់ព្រះរាជា ។ ព្រះរាជាមានព្រះរាជឱង្ការថា :

យើងមានសេចក្ដីជ្រះថ្លានឹងនិគ្រោធមិគរាជ យើងប្រទានពរហើយ ទោះបីជាយើងត្រូវលះបង់រាជសម្បត្តិចោល ក៏យើងមិនកែប្រែនូវ ពាក្យដែលយើងប្ដេជ្ញាហើយនោះឡើយ ។ អ្នកទាំងឡាយ ចូរទៅចុះ មិនត្រូវមាននរណាម្នាក់សម្លាប់សត្វទៀតឡើយ ។

និគ្រោធមិគរាជបានឮរឿងរ៉ាវទាំងនោះហើយ ក៏កោះប្រជុំពួកប្រើសទាំង ឡាយ ហើយឱ្យឱវាទថា :

ចាប់តាំងពីពេលនេះតទៅ អ្នកទាំងឡាយត្រូវឈប់ទៅបំពានជាន់ ឈ្លីស៊ីសន្ទូង ស្រូវដំណាំរបស់អ្នកស្រុកទៀតឡើយ ។

ពួកប្រើសទាំងនោះ ក៏នាំគ្នាស្ដាប់តាមពាក្យដាស់តឿនរបស់ប្រើស និគ្រោធមិគរាជគ្រប់ៗគ្នា ហើយក៏លែងចូលទៅស៊ីដំណាំអ្នកស្រុកទៀតដែរ ។

បន្ទាប់មក ទាំងមនុស្ស ទាំងសត្វទូទាំងនគរ ក៏រស់នៅដោយសុខសាន្ត ជាដរាបរៀងរហូតមក ។ រីឯប្រើសពោធិសត្វ បានរស់នៅតាមអាយុ-កាលរបស់លោក ហើយក៏ស្លាប់ទៅតាមយថាកម្ម ។ ចំណែកឯព្រះរាជា ក៏ទ្រង់សោយទិវង្គតទៅតាមអាយុកាលរបស់ព្រះអង្គដែរ ។

ព្រះបរមសាស្តានៃយើង ទ្រង់ប្រជុំជាតកថា :

"ប្រើសសាខៈក្នុងកាលនោះ បានអន្ទោលកំណើតមកជា **ភិក្ខុទេវទត្ត** ដែលជាមេរបស់ប្រើសញីមានគភ៌ **ជាភិក្ខុនីមានគភ៌** នេះឯង រីឯកូនប្រើស បានមកជា**ព្រះកុមារកស្សបៈ** ។ ចំណែកឯប្រើសនិគ្រោធ-មិគរាជបានយោនកំណើតមកជាតួអង្គតថាគតនេះឯង" ៕

**(ចប់និគ្រោធមិគជាតក)**

**សំណួរត្រិះរិះ**

១- តើអ្នកអានគិតឃើញដូចម្តេច បើព្រះរាជាទ្រង់កៀរគរមនុស្សឱ្យទៅបរបាញ់សត្វរាល់ៗថ្ងៃ?

២- តើប្រើសពោធិសត្វ មានគុណធម៌ដូចម្តេចចំពោះបរិវាររបស់ខ្លួន និងអ្នកដទៃ?

៣- តើព្រះពោធិសត្វនិគ្រោធមិគរាជបានសាងគុណធម៌ ឬបារមីអ្វីជាចម្បងក្នុងរឿងនេះ?

៤- តើព្រះរាជាទ្រង់ជាអ្នកកាន់សច្ចធម៌យ៉ាងណាដែរ?

៥- សូមធ្វើការប្រៀបធៀបបុគ្គលិកលក្ខណៈរបស់ព្រះរាជា ប្រើសនិគ្រោធមិគរាជ និងស្តេចប្រើសសាខៈ ក្នុងឋានៈនៃអ្នកទាំងនោះជាមេដឹកនាំ ។

## ១១. វណ្ណុបថជាតក

## (សេចក្ដីព្យាយាម)

កាលព្រះបរមសាស្ដា ទ្រង់គង់នៅក្នុងវត្តជេតពន មានកុលបុត្រមួយរូប រស់នៅក្នុងក្រុងសាវត្ថី បានស្ដាប់ព្រះធម្មទេសនាក្នុងសម្នាក់នៃព្រះដ៏មានព្រះភាគ ក៏មានចិត្តជ្រះថ្លា ហើយឃើញនូវទោសក្នុងកាមទាំងឡាយ ។ ក្រោយមក ក៏សម្រេចចិត្តចេញទៅបួស ប្រព្រឹត្តព្រហ្មចរិយធម៌ ។ លុះបួសបាន ៥ វស្សា រៀនយកមាតិកាទាំងពីរ[៦៤] ហើយសិក្សានូវកម្មដ្ឋានក្នុងសម្នាក់ព្រះពុទ្ធជាម្ចាស់ ។ ក្រោយមក ភិក្ខុអង្គនេះ ចូលទៅកាន់ព្រៃចម្រើនវិបស្សនាអស់ ៣ ខែ ។ ការចម្រើនកម្មដ្ឋាននេះ លោកមិនអាចញ៉ាំងសូម្បីត្រឹមឱភាសនិងនិមិត្ត[៦៥] ឱ្យកើតឡើងបានឡើយ ។ គ្រានោះ លោកក៏គិតថា :

> អាត្មាអញជាបុគ្គលអភព្វ មិនអាចសម្រេចនូវមគ្គផលឡើយ តើអាត្មាអញព្យាយាមនៅក្នុងព្រៃនេះធ្វើអ្វី? អញនឹងទៅគាល់ព្រះសាស្ដា ដើម្បីស្ដាប់ព្រះធម៌ដ៏ពីរោះវិញប្រសើរជាង ។

---

[៦៤] មាតិកាក្នុងទីនេះ សំដៅដល់ ភិក្ខុប្បាតិមោក្ខ និង ភិក្ខុនីបាតិមោក្ខ ជាសិក្ខាបទដែលព្រះពុទ្ធជាម្ចាស់ទ្រង់បានបញ្ញត្តដល់ភិក្ខុ និងភិក្ខុនី ។

[៦៥] ឱភាស និងនិមិត្ត សំដៅដល់ អ្នកចម្រើនកម្មដ្ឋានមានពន្លឺ ឬហេតុណាមួយកើតឡើងក្នុងអារម្មណ៍នៃកម្មដ្ឋាន ។

គិតដូច្នេះហើយ ភិក្ខុនោះក៏ត្រឡប់ទៅកាន់វត្តជេតពនវិញ ។ ភិក្ខុទាំងឡាយឃើញភិក្ខុនោះ ត្រឡប់មកវិញ ក៏សួរថា :

អាវុសោ[៦៦] ក្រែងអ្នករៀនយកកម្មដ្ឋាន ក្នុងសម្នាក់ព្រះដ៏មានព្រះភាគ ហើយចេញទៅធ្វើនូវសមណធម៌ ។ ចុះហេតុអ្វី ក៏អ្នកត្រឡប់មកនៅក្នុងពួកគណៈ[៦៧]វិញ? តើអ្នកមិនបានបំពេញនូវបព្វជិតកិច្ចឱ្យដល់ទីបំផុតទេឬ?

ភិក្ខុនោះឆ្លើយតបវិញថា :

អាវុសោ ខ្ញុំព្រះករុណា ប្រព្រឹត្តសមណធម៌ មិនសម្រេចមគ្គផលសោះ ខ្ញុំព្រះករុណាប្រាកដជាបុគ្គលអភព្វមិនខានទេ ។ ហេតុនេះទើបខ្ញុំព្រះករុណាលះបង់នូវសេចក្ដីព្យាយាម ហើយមកទីនេះ ។

ភិក្ខុទាំងឡាយពោលថា :

អាវុសោ អ្នកមិនគួរលះបង់នូវសេចក្ដីព្យាយាមនោះទេ អ្នកគួរតែប្រារព្ធនូវសេចក្ដីព្យាយាមឱ្យក្រៃលែងជាងនេះទៅទៀត ។ តោះ ! ចូរអ្នកទៅគាល់ព្រះសាស្ដាជាមួយនឹងខ្ញុំព្រះករុណា ។

---

៦៦ អាវុសោ ជាពាក្យប្រើក្នុងព្រះពុទ្ធសាសនា សម្រាប់ព្រះសង្ឃហៅគ្នាទៅវិញទៅមក ឬម៉្យាងទៀតហៅថា អ្នកដ៏មានអាយុ ។

៦៧ ពួកគណៈ សំដៅដល់ ការនៅជាក្រុម ជាពួក ឬនៅដោយច្របូកច្របល់គ្នា ។

ភិក្ខុទាំងឡាយ ក៏បាននាំភិក្ខុនោះចូលគាល់ព្រះសម្មាសម្ពុទ្ធ ។

ព្រះសាស្តាឃើញភិក្ខុនោះភ្ញាម ទ្រង់ត្រាស់សួរថា :

ម្នាលភិក្ខុទាំងឡាយ អ្នកនាំភិក្ខុនេះមកគាល់តថាគត ព្រោះហេតុអ្វី?

ភិក្ខុទាំងឡាយក្រាបទូលថា :

បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុនេះបានបួសក្នុងសាសនា ដែលនាំឱ្យរួចផុតចាកទុក្ខ មានសភាពយ៉ាងនេះ កាលធ្វើនូវសមណធម៌ ក៏លះបង់សេចក្តីព្យាយាមចោល ។

គ្រានោះ ព្រះសាស្តាទ្រង់សួរភិក្ខុនោះថា :

ម្នាលភិក្ខុ តើអ្នកលះបង់នូវសេចក្តីព្យាយាមពិតមែនឬ?

ភិក្ខុនោះក្រាបទូលថា :

បពិត្រព្រះអង្គដ៏ចម្រើន ពិតមែន! ។

ព្រះបរមសាស្តាទ្រង់ត្រាស់ថា :

ម្នាលភិក្ខុ អ្នកបួសក្នុងសាសនានៃតថាគត មានសភាពយ៉ាងនេះ គួរតែជាអ្នកប្រាថ្នាតិច សន្តោស មានសេចក្តីព្យាយាមតឹងតែង ហេតុអ្វីអ្នកលះបង់សេចក្តីព្យាយាមចោលទៅវិញ? ក្រែងអតីតកាល អ្នកជា

បុគ្គលមានសេចក្ដីព្យាយាមខ្លាំងក្លា មានមនុស្ស ៥០០ នាក់ និងគោ
បររទេះ ឆ្លងកាត់ក្នុងផ្លូវមរណៈបានដោយជោគជ័យ ។ អាស្រ័យ
សេចក្ដីព្យាយាមរបស់អ្នក មនុស្សនិងសត្វទាំងអស់ ក៏បាននូវទឹកផឹក
ដល់នូវសិរីសួស្ដីដ៏ប្រពៃ ។ ឥឡូវនេះ ហេតុអ្វីបានជាអ្នកលះបង់
សេចក្ដីព្យាយាមនេះទៅវិញ ។

ភិក្ខុទាំងឡាយស្ដាប់នូវកថា[៦៨]នោះហើយ ក៏សូមអារាធនាព្រះដ៏មានព្រះ
ភាគថា :

បពិត្រព្រះដ៏មានព្រះភាគ ក្នុងកាលឥឡូវនេះ ពួកទូលបង្គំឃើញ
ច្បាស់នូវការលះបង់សេចក្ដីព្យាយាមរបស់ភិក្ខុនេះ តែរឿងមនុស្ស
និងគោឆ្លងកាត់ផ្លូវមរណៈ បានផឹកនូវទឹក ដល់នូវសិរីសួស្ដី
អាស្រ័យសេចក្ដីព្យាយាមរបស់ភិក្ខុនេះ យើងខ្ញុំព្រះករុណាពុំទាន់
ដឹងនៅឡើយ សូមព្រះអង្គទ្រង់ត្រាស់សម្ដែងនូវដំណើររឿងនោះ
ដោយព្រះករុណាទិគុណដ៏ជ្រាលជ្រៅបំផុត ។

គ្រានោះ ព្រះបរមសាស្ដាទ្រង់ត្រាស់ថា :

ម្នាលភិក្ខុទាំងឡាយ បើដូច្នោះចូរអ្នកទាំងឡាយត្រងត្រាប់ស្ដាប់ចុះ។

[៦៨] កថា មានន័យថា ពាក្យពេចន៍ដែលព្រះអង្គទ្រង់សម្ដែង ។

# ឆ្លងផ្លូវខ្សាច់មរណៈ

ព្រះសម្មាសម្ពុទ្ធទ្រង់នាំអតីតនិទានមកសម្ដែងដូចតទៅ :

ក្នុងកាលកន្លងទៅ ព្រះបាទព្រហ្មទត្ត សោយរាជ្យនៅក្នុងដែនកាសី ។ ព្រះពោធិសត្វ បានកើតនៅក្នុងត្រកូលអ្នកជំនួញម្នាក់ ដែលមានទ្រព្យសម្បត្តិបង្គួរ តែងតែធ្វើការត្រាច់ចរជួញដូរ ហើយធ្វើជាមេដឹកនាំពួករទេះចំនួន ៥០០ ។ ព្រះពោធិសត្វ បានធ្វើដំណើរជាមួយនឹងក្រុមរទេះទាំងនោះឆ្លងកាត់វាលខ្សាច់នៃផ្លូវមរណៈ ដែលមានខ្សាច់ដ៏ល្អិតតូចៗ សូម្បីចាប់ដោយដៃក៏មិនបានផង ។ តាំងពីព្រះអាទិត្យរះឡើង គេពុំអាចដើរជាន់គំនរខ្សាច់ក្ដៅទេ ព្រោះហេតុនោះហើយ ការធ្វើដំណើរបានតែក្នុងពេលរាត្រីប៉ុណ្ណោះ ។ ក្នុងពេលអរុណរះឡើង អ្នកជំនួញទាំងនោះត្រូវតែឈប់សម្រាកដោយរៀបចំរទេះជារង្វង់មូល ហើយធ្វើមណ្ឌបចំកណ្ដាល ។ គេអង្គុយត្រង់ស្រមោលហើយរៀបចំ អាហារសម្រាប់បរិភោគពេលថ្ងៃត្រង់ និងសម្រាកបន្តទៀត ។ កាលព្រះសុរិយាអស្តង្គត គេក៏នាំគ្នាបរិភោគអាហារពេលល្ងាច រួចបន្តការធ្វើដំណើរពេលផ្ទៃដីត្រជាក់ ។ ការធ្វើដំណើររបៀបនេះ អស់ចម្ងាយផ្លូវ ៥៩ យោជន៍ ។ នៅពេលមុនចេញដំណើរ នាយពាណិជ បានប្រកាសប្រាប់អ្នកបររទេះទាំងអស់ឱ្យជ្រាបថា :

នៅសល់ត្រឹមតែមួយរាត្រីទៀតប៉ុណ្ណោះ យើងនឹងអាចឆ្លងផុតពីផ្លូវ

នេះហើយ ។

ឮដូច្នេះ ពួកអ្នកបររទេះមានចិត្តសប្បាយរីករាយយ៉ាងខ្លាំង ក៏នាំគ្នាបោះបង់ចោលនូវអុសនិងទឹក ហើយបររទេះទៅ ។ អ្នកនាំផ្លូវបានអង្គុយនៅលើរទេះខាងមុខគេ សម្លឹងមើលផ្កាយ[៦៩] លើអាកាស ដោយដេកផង ពោលផងថា "បរពីនេះទៅៗ" ។ ដោយអស់កម្លាំងក្នុងការធ្វើដំណើរលើផ្លូវឆ្ងាយដ៏លំបាកផង អ្នកបររទេះនាំមុខនោះក៏ដេកលក់ទៅ ។ គោចេះតែធ្វើដំណើរអូសរទេះអស់មួយរាត្រី ។ លុះព្រឹកឡើងអ្នកនាំផ្លូវភ្ញាក់ឡើង ដោយសម្លឹងមើលផ្កាយលើអាកាស ហើយក៏ពោលថា :

"រទេះត្រឡប់ក្រោយវិញៗ" ។

ពួកគេក៏បានមកដល់កន្លែងដែលពួកគេចេញពីក្បាលព្រលប់ ។ អ្នកជំនួញទាំងអស់នាំគ្នាពោលថា :

"ពីម្សិលមិញ ពួកយើងបានបោះបង់អុសនិងទឹកចោល ដោយគិតថា កុំឱ្យធ្ងន់រទេះ ។ ឥឡូវយើងជួបគ្រោះថ្នាក់ហើយ ព្រោះយើងគ្មានទឹក គ្មានអុសចម្អិនអាហារទេ" ។

[៦៩] ផ្កាយព្រឹក, North Star ។

ពោលរួច គេនាំគ្នាដោះរទេះដាក់ជារង្វង់មូលដូចលើកមុនទៀត ហើយក៏ដេកពិបាកចិត្ត ។ នៅពេលត្រូវជាក់ព្រលឹមស្រាងៗ នាយពាណិជ សង្កេតឃើញមានស្មៅ និងឈើដុះក្បែរនោះ ក៏គិតថា ស្មៅនេះដុះខៀវខ្ចី ប្រាកដជាមានទឹកនៅខាងក្រោមមិនខានឡើយ ។ នាយពាណិជក៏នាំគ្នាយកចបជីក មកជីកដីនៅទីនោះ ចុះទៅខាងក្រោមប្រវែង ៦០ ហត្ថ ក៏ដល់ផ្ទាំងថ្មមួយដ៏ធំ ។ អ្នកទាំងនោះអស់សង្ឃឹម ក៏ឈប់ជីកតទៅ តែពេលនោះ នាយពាណិជបានចុះទៅក្នុងរណ្ដៅ ផ្ទៀងត្រចៀកស្ដាប់ផ្ទាំងថ្ម ក៏ឮក្រសែទឹកហូរ ហើយឡើងមកវិញ ប្រាប់**ចូឡុបដ្ឋាក**ថា :

ម្នាលអ្នកដ៏ចម្រើន កាលបើអ្នកលះបង់នូវសេចក្ដីព្យាយាម មនុស្សនឹងដល់នូវសេចក្ដីវិនាសមិនខាន បើអ្នកមានសេចក្ដីព្យាយាមខំប្រឹងជីកបន្តទៀត នឹងជួបទឹកនៅខាងក្រោមជាមិនខាន ។

ចូឡុបដ្ឋាក ស្ដាប់ពាក្យនោះហើយ ក៏ខំប្រឹងព្យាយាមជីកទម្លាយនូវផ្ទាំងថ្មនោះទៀត រហូតធ្លុះផ្ទាំងថ្មចំពាក់កណ្ដាល ។ រំពេចនោះ ក្រសែទឹកមួយបាញ់ផុសឡើងយ៉ាងខ្លាំងពីក្នុងដី កម្ពស់មួយដើមត្នោត ធ្វើឱ្យមនុស្ស និងសត្វទាំងអស់ បានផឹកផង ងូតផង អាស្រ័យដោយសេចក្ដីព្យាយាមរបស់ចូឡុបដ្ឋាកនោះ ។ ពេលសុរិយាអស្ដង្គត ពួកគេនាំគ្នាចងទង់ដើម្បីធ្វើជាសញ្ញាត្រង់អណ្ដូងទឹកនោះ ហើយបររទេះធ្វើដំណើរបន្តទៅទៀត ក៏បានដល់គោលដៅតាមបំណងរៀងៗខ្លួន ។

កាលព្រះដ៏មានព្រះភាគទ្រង់សម្ដែងនូវជាតកនេះហើយ ព្រះអង្គត្រាស់បញ្ជាក់ថា :

ម្នាលភិក្ខុ អតីតកាល អ្នកធ្វើនូវសេចក្ដីព្យាយាមបានជីកថ្មយកទឹកទាល់តែបាន ចុះឥឡូវនេះ អ្នកបួសក្នុងសាសនានៃតថាគត ដែលនាំអ្នករួចផុតចាកទុក្ខ ហេតុដូចម្ដេចអ្នកលះបង់នូវសេចក្ដីព្យាយាមនេះចោលអ៊ីចឹង?

ពោលចប់កាលណា ព្រះសាស្ដាទ្រង់ត្រាស់សម្ដែងអរិយសច្ចធម៌ ភិក្ខុនោះក៏សម្រេចជាព្រះអរហន្ត ។ ព្រះសាស្ដាទ្រង់ប្រជុំជាតកថា :

- ចូឡុបដ្ឋាកអ្នកមានសេចក្ដីព្យាយាមនោះ សរជាតិមកបានជាភិក្ខុអ្នកលះបង់សេចក្ដីព្យាយាមនេះ ។
- ចំណែកឯនាយពាណិជ បានមកជាតថាគតនេះឯង ៕

**សំណួរត្រិះរិះ**

១- តើរឿងនេះបានបង្ហាញដល់អ្នកអាន នូវមេរៀនអ្វីប្រចាំជីវិត?

២- តើតួអង្គព្រះពោធិសត្វ បានបំពេញនូវបារមីអ្វី ជាធំនៅក្នុងការឆ្លងកាត់វាលខ្សាច់នៃផ្លូវមរណៈ?

៣- សូមកត់សម្គាល់នូវបុគ្គលិកលក្ខណៈនៃនាយពាណិជ ក្នុងឋានៈលោកជាអ្នកដឹកនាំក្បួនរទេះដំនួញ ។

## ១២. កុក្កុរជាតក

## (សុនខស្វែងរកយុត្តិធម៌)

កាលព្រះសម្មាសម្ពុទ្ធទ្រង់គង់ក្នុងវត្តជេតពន ព្រះអង្គបានប្រារព្ធនូវ **ញាតត្ថចរិយា**[៧០] របស់ព្រះអង្គ ក៏ទ្រង់សម្ដែងនូវកុក្កុរជាតក (សុនខស្វែងរកយុត្តិធម៌) ដូចតទៅ :

ក្នុងកាលកន្លងទៅ ព្រះបាទព្រហ្មទត្តសោយរាជ្យក្នុងដែនកាសី ។ កាលនោះ ព្រះបរមពោធិសត្វ យោនយកកំណើតជាសត្វ**សុនខ** នៅក្នុងព្រៃស្មសានធំមួយ ដែលមានសុនខគ្មានម្ចាស់រាប់ពាន់ជាបរិវារ ។ ក្នុងថ្ងៃមួយ ព្រះរាជាទ្រង់គង់លើរាជរថ ដែលប្រដាប់ដោយគ្រឿងអលង្ការទាំងពួង ទឹមដោយសេះស ទៅកម្សាន្តក្នុងព្រះរាជឧទ្យាន ។ ពេលព្រះរាជាទ្រង់ត្រឡប់ពីកម្សាន្តវិញ បានប្រើអាមាត្យឱ្យយកព្រះរាជរថទុកក្នុងព្រះលានហ្លួង ដោយមិនបានដោះគ្រឿងប្រដាប់ចេញពីព្រះរាជរថឡើយ ។ ចួនពេលនោះ មានភ្លៀងបង្អុរចុះមកយ៉ាងខ្លាំងធ្វើឱ្យទទឹករាជរថអស់ ។ ពេលនោះ មានពួកសុនខមួយក្រុម នាំគ្នាមកអង្កៀមស្បែក និងព្រត្រ[៧១] ដែលជាប់នៅព្រះរាជរថ

---

[៧០] ញាតត្ថចរិយា គឺការប្រព្រឹត្តនូវប្រយោជន៍ដល់ពួកញាតិ ។

[៧១] ខ្សែត្រកួញធ្វើដោយស្បែកគោ ក្របី ឬម្រឹគណាមួយ ប្រើសម្រាប់ជ្រាមនឹម ។ ពាក្យនេះអានថា "ព្រាត់" ហាមអាន "ព្រត់" មិនដាក់សំយោគសញ្ញា " ័" ព្រោះអក្សរខាងចុងត្រួតស្រាប់ហើយ ដូចពាក្យ ភទ្ទកប្ប, នន្ទ, សព្វ, ចន្ទ ជាដើម ។

ខ្ទេចខ្ទីអស់រលីង ។ លុះព្រឹកឡើង មានអាមាត្យម្នាក់បានចូលទៅក្រាបទូលព្រះរាជាថា :

"បពិត្រព្រះសម្មតិទេព ពួកសុនខចូលមកក្នុងវាំង បានអង្កៀមស្បែក និងព្រាត្រព្រះរាជរថអស់ហើយ កាលពីយប់មិញនេះ" ។

ពេលនោះ ព្រះរាជាក៏ទ្រង់ពិរោធយ៉ាងខ្លាំង ហើយមានព្រះរាជឱង្ការថា :

"អ្នកទាំងឡាយត្រូវសម្លាប់សុនខទាំងអស់ដែលប្រទះឃើញ មិនថានៅក្នុងក្រុងក្តី ក្រៅក្រុងក្តី ឬគ្រប់ច្រកល្ហកណានីមួយក្តី" ។

ចាប់ពីពេលនោះមក សុនខទាំងឡាយត្រូវទទួលនូវគ្រោះមហន្តរាយដល់ជីវិតយ៉ាងធំ ដោយត្រូវពួករាជអាមាត្យតាមសម្លាប់គ្រប់ទីកន្លែង ។ ពួកសុនខទាំងឡាយមានការភិតភ័យតក់ស្លុតនឹងសេចក្តីស្លាប់ ក៏នាំគ្នារត់ចូលទៅកាន់ព្រៃស្មសានដែលជាជម្រករបស់សុនខជាប្រមុខ និងជាព្រះពោធិសត្វ ។ សុនខព្រះពោធិសត្វ បានសាកសួរសុនខទាំងឡាយថា :

"ហេតុអ្វីអ្នកទាំងអស់គ្នាមកប្រជុំគ្នាក្នុងព្រៃនេះ?"

ពួកសុនខទាំងឡាយឆ្លើយតបថា :

"យើងខ្ញុំទាំងអស់គ្នាឮថា មានពួកសុនខមួយក្រុម ចូលស៊ីស្បែក និងព្រាត្រព្រះរាជរថរបស់ព្រះរាជានៅក្នុងរាជវាំង បណ្តាលឱ្យព្រះរាជា

ទ្រង់ពិរោធជាខ្លាំង ហើយបានបញ្ជាឲ្យពួករាជអាមាត្យតាមសម្លាប់ឆ្កែទាំងអស់ដែលឃើញតាមផ្លូវ ដោយគ្មានរើសមុខ" ។

ព្រះពោធិសត្វគិតថា :

"ធម្មតាក្នុងព្រះបរមរាជវាំង មានការយាមកាមតឹងរ៉ឹងណាស់ សុនខខាងក្រៅមិនអាចចូលទៅក្នុងវាំងបានទេ ហេតុនេះប្រាកដជាសុនខក្នុងវាំងអង្កៀមមិនខាន ។ រឿងនេះ ចោរមិនទទួលគ្រោះថ្នាក់ រីឯអ្នកសុចរិតត្រឹមត្រូវ ទទួលរងគ្រោះទៅវិញ ។ បើដូច្នេះ មានតែអាត្មាអញបង្ហាញមុខចំពោះព្រះរាជា ហើយជួយពពួកញាតិរបស់អាត្មាអញឱ្យរួចផុតពីមហន្តរាយនេះ" ។

ពេលនោះ សុនខព្រះពោធិសត្វបានលួងលោមញាតិថា :

"អ្នកទាំងឡាយកុំភ័យអី យើងនឹងជួយអ្នករាល់គ្នា ឱ្យរួចផុតពីមហន្តរាយដ៏ធំនេះ" ។

សុនខព្រះពោធិសត្វបានពិចារណានូវធម៌ដែលខ្លួនសាងមក រួចអធិដ្ឋានថា :

"ព្រះរាជាទ្រង់ស្ថិតនៅទីណា សូមឱ្យយើងចូលទៅកាន់ទីនោះ ឱ្យបានសម្រេចដោយសុវត្ថិភាព" ។

បន្ទាប់ពីផ្សាយនូវមេត្តាចិត្តហើយ សុនខព្រះពោធិសត្វអធិដ្ឋានថា :

"ដុំដីក្តី ដំបង់ក្តី កុំមានអ្វីមួយ អាចព្យាបាទដល់យើងឡើយ" ។

អធិដ្ឋានដូច្នេះហើយ សុនខព្រះពោធិសត្វក៏សម្រេចចិត្តចូលទៅក្នុងព្រះបរមរាជវាំងតែម្នាក់ឯង ។ ដោយតាំងមេត្តាធម៌ក្នុងខ្លួនដ៏ជ្រាលជ្រៅ និងសម្រួលឥរិយាបថយ៉ាងស្ងួតបូតរួចហើយ សុនខបានដើរឆ្វេងកាត់ក្រុងហើយចូលទៅក្នុងព្រះបរមរាជវាំង ដោយមិនមានអ្វី ឬអ្នកណាបៀតបៀនឡើយ រហូតដល់ប្រាសាទទេវវិនិច្ឆ័យ ហើយក៏រត់ចូលទៅខាងក្រោមបល្ល័ង្ករបស់ព្រះរាជា ដែលទ្រង់កំពុងគង់វិនិច្ឆ័យឱ្យអាមាត្យសម្លាប់សត្វសុនខ ។ ព្រះរាជាឃើញភ្លាម ទ្រង់ព្រះចិន្តាថា :

សត្វសុនខនេះមិនធម្មតាទេ បានជាហ៊ានចូលមកទីនេះ ព្រោះពេលនេះ ពួករាជអាមាត្យកំពុងតាមសម្លាប់ តែសុនខនេះហ៊ានចូលមកខាងក្រោមបល្ល័ង្កយើង ប្រាកដជាមានហេតុអ្វីមួយសំខាន់មិនខាន ។

ពេលនោះ ព្រះរាជាទ្រង់ហាមឃាត់មិនឱ្យអាមាត្យចាប់សុនខនោះឡើយ ។ ព្រះពោធិសត្វឃើញឱកាសល្អមកដល់ ក៏ចេញពីខាងក្រោមបល្ល័ង្កភ្លាម ហើយថ្វាយបង្គំព្រះរាជា ដោយបញ្ចេញវាចាថា :

បពិត្រព្រះសម្មតិទេពដ៏ខ្ពង់ខ្ពស់ សូមព្រះអង្គទ្រង់ព្រះរាជទានទោស ដល់ទូលព្រះបង្គំជាខ្ញុំ តើព្រះអង្គទ្រង់បញ្ជាឱ្យពួករាជអាមាត្យតាមសម្លាប់ពួកសុនខទាំងឡាយមែនឬទេ?

"ពិតមែន! យើងជាអ្នកបញ្ជា" ព្រះរាជាតប ។

សុនខពោធិសត្វសួរថា :

"បពិត្រព្រះអង្គជាធំលើជននានាក្នុងដែនកាសី តើពួកសុនខនោះ មានកំហុសអ្វី? ក្រាបទូល!" ។

ព្រះរាជាតប :

"សុនខទាំងនោះអង្កៀមស្បែក និងព្រាត្រ នៃរាជរថរបស់យើង" ។

សុនខពោធិសត្វ :

"តើព្រះអង្គទ្រង់ទតឃើញផ្ទាល់ព្រះនេត្រដែរឬទេ? ក្រាបទូល!" ។

ព្រះរាជា :

"យើងមិនបានឃើញទេ តែពួកអាមាត្យរាយការណ៍ឱ្យយើង" ។

សុនខពោធិសត្វ :

"ប្រសិនបើព្រះអង្គ ទ្រង់មិនបានទតឃើញផ្ទាល់ទេ តើហេតុអ្វីបាន ជាព្រះអង្គជ្រាបថា សុនខទាំងនោះជាអ្នកអង្កៀមស្បែកនិងព្រត្រ ព្រះរាជរថរបស់ព្រះអង្គ? តើសមគួរទេមហាបពិត្រ ដែលទ្រង់ បញ្ជាឱ្យគេតាមសម្លាប់សុនខទាំងឡាយ ដែលរាជបុរសឃើញ តាមផ្លូវក្នុងក្រុង និងក្រៅក្រុង" ។

សុនខពោធិសត្វសួរបន្តទៀតថា :

"តើព្រះអង្គទ្រង់បញ្ជាឱ្យគេសម្លាប់ សុនខទាំងអស់ដែលបានឃើញ ដោយគ្មានការលើកលែងមែនឬទេ? ក្រាបទូល!" ។

ព្រះរាជាទ្រង់តបថា :

"ពិតមែនហើយ យើងបញ្ជាឱ្យគេសម្លាប់សុនខទាំងអស់មែន លើក លែងតែសុនខក្នុងរាជវាំងតែប៉ុណ្ណោះ" ។

សុនខពោធិសត្វ :

"បពិត្រមហារាជ ព្រះអង្គបញ្ជាឱ្យគេសម្លាប់សុនខទាំងអស់ លើក លែងតែសុនខក្នុងវាំង ព្រះអង្គជាបុគ្គលលុះក្នុងឆន្ទាគតិ គឺលម្អៀង ព្រោះស្រឡាញ់ ។ ព្រះអង្គមិនគួរជាបុគ្គលលុះក្នុងឆន្ទាគតិទេ

ព្រះអង្គគួរតែធ្វើតុល្យការតាមហេតុពិតប្រាកដ ព្រោះព្រះអង្គជាស្តេចផែនដី" ។

ពេលនោះ សុនខព្រះពោធិសត្វពោលបន្តថា :

"ពួកសុនខណាកើតក្នុងរាជត្រកូល បរិបូណ៌ដោយសម្បុរ និងកម្លាំងចម្រើនហើយក្នុងរាជត្រកូល សុនខទាំងនោះគេមិនសម្លាប់ទេ ។ យើងទាំងឡាយជាសុនខអនាថា ត្រូវគេសម្លាប់យ៉ាងនេះមិនឈ្មោះថា សម្លាប់ដោយត្រឹមត្រូវឡើយ ។ នេះឈ្មោះថាសម្លាប់សុនខដែលជាអ្នកទន់ខ្សោយ" ។

ព្រះរាជាទ្រង់ព្រះសណ្តាប់ពាក្យសុនខពោធិសត្វ ដោយយកព្រះទ័យទុកដាក់ប្រកបដោយវិចារណញ្ញាណហើយ ក៏សួរថា :

"អ្នកជាបណ្ឌិត តើអ្នកមានដឹងទេថា សុនខឯណាដែលអង្កៀមស្បែកនៃរាជរថរបស់យើង?"

សុនខពោធិសត្វ :

"បពិត្រមហារាជ ទូលព្រះបង្គំជាខ្ញុំដឹងពិតណាស់ ក្រាបទូល!" ។

ព្រះរាជាសួរថា :

"តើសុនខណាហ៊ានអង្កៀមស្បែក និងព្រត្ររាជរថរបស់យើង?"

សុនខពោធិសត្វ :

"បពិត្រព្រះសម្មតិទេព គឺសុនខក្នុងវាំងរបស់ព្រះអង្គ បានអង្កៀមស្បែក និងព្រាត្រក្រពាជរថនេះ" ។

ព្រះរាជា :

"តើហេតុអ្វីបានអ្នកដឹងថា សុនខក្នុងរាជវាំងរបស់យើង វាអង្កៀមស៊ីព្រាត្រនិងស្បែករាជរថ?"

សុនខពោធិសត្វ :

"ទូលព្រះបង្គំជាខ្ញុំ នឹងបង្ហាញការពិតថ្វាយព្រះអង្គ ក្រាបទូល!" ។

"បើដូច្នោះ ចូរអ្នកបង្ហាញឱ្យយើងឃើញជាបន្ទាន់" ព្រះរាជាតប ។

សុនខពោធិសត្វ :

"បពិត្រមហារាជ សូមព្រះអង្គឱ្យរាជបុរសនាំសុនខ ក្នុងព្រះរាជវាំងទាំងអស់មក និងយកស្មៅកុស (ស្មៅស្បូវ) និងទឹកដោះជូរ មួយធុងមកផង" ។

ព្រះរាជាក៏ធ្វើតាមសំណើរបស់សុនខពោធិសត្វ ។ គ្រានោះ ព្រះពោធិសត្វប្រើឱ្យគេច្របល់ស្មៅជាមួយនឹងទឹកដោះជូរ ហើយឱ្យសុនខទាំង

នោះផឹក ។ ព្រះរាជាទ្រង់បានអនុញ្ញាតឱ្យរាជអាមាត្យធ្វើតាមបង្គាប់សុនខពោធិសត្វ ។ ក្រោយពេលសុនខទាំងនោះ ផឹកទឹកដោះឆ្អែតស្កប់ស្កល់រួចហើយ ក៏ក្អួតចេញមកនូវកម្ទេចស្បែកព្រាត្រារាជរថ មានពណ៌ស បៃតង ក្រហម នៅចំពោះព្រះភក្ត្រនៃព្រះរាជា ។ ការពិសោធដ៏អស្ចារ្យនេះ ធ្វើឱ្យព្រះរាជាមានសេចក្ដីជ្រះថ្លា នឹងប្រាជ្ញាដ៏វាង‌វៃរបស់សុនខពោធិសត្វ ។ ខណៈនោះ ព្រះរាជាមានព្រះរាជបន្ទូលកោតសរសើរដោយស្មោះថា :

"ខ្ញុំសូមសរសើរ ដល់អ្នកដែលមានបញ្ញានិងគតិបណ្ឌិតដ៏ប្រពៃនេះ ។ ដើម្បីឱ្យសមដល់គុណធម៌របស់អ្នក ខ្ញុំសូមប្រកាសជាឱឡារិកថា ចាប់ពីថ្ងៃនេះទៅ យើងសូមប្រគល់រាជសម្បត្តិដល់សុនខនេះ ដើម្បីគ្រប់គ្រងរដ្ឋជាស្ដេចផែនដី ចាប់ពីពេលនេះតទៅ" ។

សុនខពោធិសត្វឆ្លើយតបព្រះរាជាវិញថា :

"បពិត្រមហារាជ ទូលព្រះបង្គំពុំអាចទទួលនូវកិត្តិយស និងតួនាទីដ៏ខ្ពង់ខ្ពស់នេះឡើយ ។ សូមព្រះអង្គទ្រង់ប្រព្រឹត្តនូវធម៌ចំពោះប្រជា-នុរាស្ត្ររបស់ព្រះអង្គ ឱ្យដូចជាមាតាបិតាប្រព្រឹត្តធម៌ចំពោះបុត្រជាដើម ចាប់តាំងពីពេលនេះតទៅ ហើយសូមមហាបពិត្រ កុំមានសេចក្ដីប្រមាទឡើយ ។ សូមព្រះអង្គតាំងនៅក្នុងសីល ៥ ដើម្បីគ្រប់

គ្រប់ដែនដី ប្រកបដោយទសពិធរាជធម៌ ញ៉ាំងនគរព្រះអង្គឱ្យ
ប្រកបដោយសុខសន្តិភាព ចម្រើនរុងរឿងជានិរន្តរ៍ ។

បន្ទាប់មក សុនខព្រះពោធិសត្វបានផ្តល់ឱវាទដល់ព្រះរាជាថា :

អលសោ គិហី កាមភោគី ន សាធុ
អសញ្ញតោ បព្វជិតោ ន សាធុ
រាជា ន សាធុ អនិសម្មការី
យោ បណ្ឌិតោ កោធនោ តំ ន សាធុ ។

គ្រហស្ថបរិភោគកាមគុណ    កម្ជិលស៊ុនហៅថាពុំប្រពៃ
បព្វជិតឥតសង្រួមក្នុងវិន័យ    មិនជាវិស័យក្នុងសាសនា ។
មហាក្សត្រចាត់ការធ្វើអ្វីៗ    មិនមានក្តីគិតមុនដោយបញ្ញា
ប្រាជ្ញបណ្ឌិតប្រព្រឹត្តក្រេវក្រោធា    ការនោះជាប្រពៃទៅពុំបាន ។

ព្រះរាជាស្តាប់ធម្មកថានេះហើយ ក៏ប្រទានអភ័យដល់សត្វសុនខទាំងអស់ ហើយតាំងនៅក្នុងឱវាទនៃសុនខពោធិសត្វ ដរាបដល់អស់ព្រះជន្មហើយចាប់បដិសន្ធិក្នុងទេវលោក ។ ក្រោយមក ព្រះពោធិសត្វក៏អស់ជន្មាយុទៅតាមយថាកម្មរបស់លោក ។

ព្រះសាស្ដាទ្រង់ប្រជុំជាតកថា ព្រះរាជាក្នុងកាលនោះបានមកជា **ព្រះអានន្ទ** ចំណែកកុក្កុរបណ្ឌិត គឺសុនខពោធិសត្វនោះ បានយោនកំណើតមកជាតថាគតនេះឯង ៕

**(ចប់កុក្កុរជាតក)**

**សំណួរត្រិះរិះ**

១- សូមអ្នកអានស្រង់យកលក្ខណៈសំខាន់ៗ នៃសុនខពោធិសត្វ ។

២- សូមអ្នកអានស្រង់យកលក្ខណៈសំខាន់ៗ នៃព្រះរាជា ។

៣- ក្នុងរឿងខាងលើនេះ តើព្រះពោធិសត្វទ្រង់បានបំពេញបារមីអ្វីជាចម្បង?

៤- តើសុនខពោធិសត្វ បានបង្រៀនធម៌អ្វីខ្លះដល់ព្រះរាជា?

# ១៣. មហាកបិជាតក

## (ពានរសង្គ្រោះជីវិតមនុស្សរមិលគុណ)

ក្នុងកាលកន្លងទៅ ព្រះបាទព្រហ្មទត្តសោយរាជ្យសម្បត្តិ ក្នុងក្រុងពារាណសី ។ កាលនោះ មានបុរសម្នាក់កំពុងភ្ជួរស្រែ ។ បន្ទាប់ពីភ្ជួរស្រែរួច បុរសនោះលែងគោឱ្យស៊ីស្មៅ ហើយទៅជីកដីលើកភ្លឺស្រែ ។ គោរបស់គាត់ចេះតែដើរស៊ីស្មៅតាមលំដាប់ៗ រហូតចូលទៅក្នុងដងព្រៃមួយដ៏ធំបាត់ទៅ ។ កាលដែលបុរសនោះ ក្រឡេករកមើលគោមិនឃើញ ក៏ដើររកគោតាមដងព្រៃ ។ ការស្វែងរកគោនេះ ចេះតែធ្វើឱ្យបុរសនេះដើរជ្រុលទៅៗ វង្វេងផ្លូវចូលដល់ព្រៃហេមពាន្ត ។ ដោយអត់អាហារបរិភោគអស់ ៧ ថ្ងៃ បុរសនោះ ក៏ប្រទះឃើញដើមទន្លាប់មួយដើម ដុះប្រឈមនឹងជ្រលងជ្រោះ ក៏ឡើងទៅបេះផ្លែទន្លាប់យកមកបរិភោគ ។ កាលគាត់ទាញមែកទន្លាប់បេះផ្លែចុះឡើងៗ មែកទន្លាប់ក៏បាក់ធ្លាក់បុរសនោះ ទៅក្នុងជ្រោះជ្រៅ ៦០ ហត្ថ ។ គាត់មិនអាចរកឧបាយឡើងមកវិញទេ ។ ដោយអស់កម្លាំងផង អត់អាហារផង និងផ្លូវឡើងលំបាកទៀត បុរសនោះក៏ស្ថិតនៅទីនោះ អស់រយៈពេល ១០ ថ្ងៃ ជាហេតុធ្វើស្បែកគាត់ឡើងលឿង រាមដោយសរសៃ មុខស្លេកស្លាំងស្ទើរតែផុតដង្ហើមលាចាកលោក ។

គ្រានោះ មានពានរមួយ ដែលលោតពីដើមឈើមួយ ទៅដើមឈើមួយ ដើម្បីបេះផ្លែឈើបរិភោគ ក៏ប្រទះឃើញបុរសនោះនៅក្នុងជ្រោះ ។ ពានរក៏សាកសួរថា :

"តើអ្នកជាមនុស្ស ឬអមនុស្ស បានជាមកនៅទីនេះ?"

បុរសអ្នកស្រែក៏ប្រាប់ដំណើររឿងរបស់ខ្លួនដល់ពានរ ។ ពានរដែលជាតួអង្គព្រះពោធិសត្វ មានចិត្តករុណាដ៏មហាសាលចំពោះបុរសនោះ ជាខ្លាំង រួចក៏ជួយយកអាសា ដោយយកខ្សែមួយយ៉ាងមាំ ទៅចងនឹងដុំថ្មខាងលើ ហើយឱ្យបុរសនោះជិះលើខ្នងតោងកដោយដៃទាំងពីរ ខំប្រឹងព្យាយាមឡើងមកតាមជ្រលងជ្រោះ រហូតមកដល់ខាងលើដូចក្ដីបំណង។ ដោយការខំប្រឹងប្រែងដ៏មោះមុត ដើម្បីជួយបុរសនោះ ពានរមានការហត់នឿយអស់កម្លាំងជាពន់ពេក ក៏និយាយទៅកាន់បុរសនោះថា :

"ចូរអ្នកជួយការពារសត្វសាហាវឱ្យខ្ញុំផង ឥឡូវនេះខ្ញុំអស់កម្លាំងណាស់ ខ្ញុំត្រូវការសម្រាកមួយភ្លែតសិន" ។

នៅពេលពានរពោធិសត្វដេកលក់មួយសន្ទុះ ឯបុរសនោះស្រាប់តែមានចិត្តអាក្រក់ ដោយគិតថា :

"ស្វានេះ ជាអាហាររបស់ពួកមនុស្ស ដូចពួកម្រិគដទៃក្នុងព្រៃនេះ

ដែរ បើដូច្នេះអាត្មាអញឃ្លានហើយ គប្បីសម្លាប់ពានរនេះធ្វើជាចំណីធី រួចហើយនឹងយកសាច់ធ្វើជាស្បៀង ដើម្បីធ្វើដំណើរទៅផ្ទះវិញ" ។

កាលគិតរួចហើយ បុរសនោះក៏ចាប់ដុំថ្មគប់ក្បាលពានរនោះមួយទំហឹង តែដោយសារបុរសនោះមានកម្លាំងខ្សោយនៅឡើយ ហើយពានរមិនបានស្លាប់ទេ គ្រាន់តែមានរបួសបែកក្បាលហូរឈាម រួចភ្ញាក់ភ្ញាម ស្ទុះឡើងដើមឈើយ៉ាងរហ័ស ដោយស្មានថា មានសត្វដទៃមកបៀតបៀនខ្លួន តែរកមើលទៅមិនឃើញ ក៏ប្រាកដក្នុងចិត្តថា "បុរសនេះជាអ្នកធ្វើទេតើ!" ។ ពេលនោះ ពានរតិះដៀលបុរសនោះថា ៖

"នែមនុស្សអាក្រក់ យើងស្រង់ជីវិតអ្នកឱ្យរួចពីជ្រោះជ្រៅស្រទ្បង់បែបនេះ ដូចជានាំអ្នកមកពីលោកដទៃ ហេតុដូចម្ដេចបានជាអ្នកសម្គាល់ថា យើងជាបុគ្គលគួរអ្នកប្រទូស្ត អ្នកឯងជាមនុស្សលាមកជាមនុស្សដ៏អាក្រក់បំផុត ជាមនុស្សអកតញ្ញូ" ។

ដោយនៅតែមានចិត្តករុណារបស់ពានរពោធិសត្វ ក៏នាំបុរសនោះទៅរកផ្លូវត្រាច់ចររបស់មនុស្ស ឱ្យចេញរួចផុតពីការវង្វេងក្នុងព្រៃ ។ ពានរពោធិសត្វ ឃើញបុរសនោះ ដល់ទីសុវត្ថិភាពហើយ ក៏វិលត្រឡប់ទៅក្នុងព្រៃ

វិញ ។ ចំណែកបុរសនោះ ធ្វើដំណើរមកតាមផ្លូវ ឃើញអន្លង់ទឹកមួយ ក៏ចុះទៅក្បង់ទឹកផឹក ស្រាប់តែទឹកក្លាយទៅជាមានកម្ដៅ ហាក់ដូចជាភ្លើងឆេះទឹកនោះ ប៉ោងផ្ទុះមកប៉ះនឹងសាច់ ធ្វើឱ្យបុរសនោះកើតជំងឺឃ្លង់ស ឃ្លង់ពពាល កើតស្រែង មានសាច់លៀនចេញ ដូចជាផ្ការលួសផ្លុង មានដំបៅប៉ុនផ្លែព្នៅមួយចំហៀងខ្លួន ប្រៀបដូចជាសត្វប្រេត ។ បុរសនោះបានធ្វើដំណើរពីកន្លែងមួយទៅកន្លែងមួយ មានក្លិនស្អុយឆ្អាបគួរឱ្យខ្ពើមរអើម ធ្វើឱ្យមនុស្សម្នានៅគ្រប់ទីកន្លែង ដេញគប់បុរសនោះដោយដុំដី ដុំថ្ម និងដំបងជាដើម ។ បុរសនោះត្រាច់ចរពីកន្លែងមួយទៅកន្លែងមួយយ៉ាងនេះ អស់ ៧ ឆ្នាំ ក៏ទៅសម្រាកក្នុងមិគាជិនឧទ្យានរបស់ព្រះរាជានៃក្រុងពារាណសី ។ ព្រះរាជាទ្រង់បានសាកសួរបុរសនោះថា :

"តើហេតុអ្វី ឬមានអ្វីបៀតបៀន ទើបអ្នកក្លាយជាយ៉ាងនេះ?"

បុរសនោះនិយាយរឿងសព្វគ្រប់ដូចពោលខាងដើម ហើយផ្ដាំថា :

"ពួកអ្នកដែលមកជួបជុំគ្នាក្នុងទីនេះ សូមកុំប្រទូស្តពួកមិត្តឡើយ ព្រោះថា បុគ្គលប្រទូស្តមិត្តជាមនុស្សអាក្រក់" [៧២] ។

[៧២] បិដកលេខ ៦០ ទំព័រ ១៩៣ ។

ក្រោយពីបុរសនោះ ទូលថ្វាយព្រះរាជាចប់ ផែនដីក៏ស្រូបបុរសនោះទៅ ហើយកើតក្នុងអវិចីនរក ដោយឱបបាតិកកំណើត ។

ព្រះសាស្តាទ្រង់ប្រជុំជាតកថា បុរសរមិលគុណក្នុងកាលនោះយោនកំណើតមកជា **ភិក្ខុទេវទត្ត** ។ ចំណែកពានរជួយបុរសនោះ យោនកំណើតមកជាព្រះអរហន្តសម្មាសម្ពុទ្ធនេះឯង ៕

**(ចប់មហាកបិជាតក)**

## ១៤. សុវណ្ណមិគជាតក

(ភក្តីភាព)

ក្នុងកាលកន្លងទៅ ព្រះបាទព្រហ្មទត្តទ្រង់បានសោយរាជ្យក្នុងនគរពារាណសី ។ កាលនោះ ព្រះពោធិសត្វចាប់កំណើតជាសត្វប្រើស មានរូបឆោមទ្រង់ទ្រាយគួរជាទីរមិលមើល និងមានពណ៌ដូចជាមាស ។ កាលវ័យវឌ្ឍនាការមកតាមលំដាប់ ក៏បានយកប្រើសញីមួយជាភរិយា ដែលមានរូបស្រស់ប្រិមប្រិយ គួរជាទីស្រឡាញ់នៃប្រើសពោធិសត្វ ។ ព្រះពោធិសត្វ ជាមេនៃហ្វូងប្រើស ៨.០០០ ហើយតែងតែនាំបរិវារត្រាច់ចរស្វែងរកអាហារតាមកន្លែងផ្សេងៗក្នុងព្រៃ ។ ថ្ងៃមួយ នាយព្រានព្រៃដាក់អន្ទាក់ត្រង់ទីផ្លូវនៃប្រើស ដែលតែងតែស្វែងរកអាហារ ។ គ្រានោះ ប្រើសពោធិសត្វដើរពីខាងមុខដឹកនាំហ្វូង ក៏ដើរជាន់ជាប់អន្ទាក់ ហើយយកជើងទាញ ដោយគិតថា "អញជាប់អន្ទាក់ហើយ" ។ ពេលប្រើសពោធិសត្វខំទាញបន្តិចដំបូង ក៏មុតចូលទៅក្នុងស្បែក ទាញបន្តិចទៀត មុតចូលក្នុងសាច់ ទាញទៀតមុតចូលក្នុងសរសៃរហូតដល់ឆ្អឹង ទោះបីជាខំប្រឹងព្យាយាមកន្ត្រាក់ទាញយ៉ាងណាក៏មិនអាចរួចឡើយ ។ ដោយមានការភិតភ័យនឹងសេចក្តីស្លាប់ ប្រើសពោធិសត្វក៏ស្រែកសន្ធាប់ឡើងយ៉ាងខ្លាំង ។ កាលបើឮសម្រែកនោះ សត្វប្រើសដទៃក៏ប្រាកដក្នុងចិត្តថា មានសត្វជាប់អន្ទាក់ហើយ ក៏នាំគ្នារត់ប្រាស យក

អាយុសរៀងៗខ្លួន ។ ពេលនោះ ប្រើសញីជាកវិយារបស់ប្រើសពោធិសត្វ រត់បណ្ដើរ រកមើលប្រើសជាស្វាមីបណ្ដើរ ដោយមិនឃើញក៏សម្គាល់ក្នុងចិត្តថា ប្រើសជាប់អន្ទាក់នោះ ប្រហែលជាស្វាមីរបស់យើងទេដឹង! នាងបែរក្បាលត្រឡប់រត់មកកន្លែងស្រែកនោះវិញ ហើយឃើញប្រើសជាស្វាមីកំពុងជាប់អន្ទាក់យ៉ាងក្រៀមក្រំ សែនស្រងូតស្រងាត់ ។ ប្រើសញីជាកវិយានោះក៏ពោលពាក្យផ្អែមល្ហែមលួងលោមថា :

"បពិត្រស្វាមី សូមបងកុំភ័យឡើយ ខ្ញុំនឹងសូមអង្វរនាយព្រានឱ្យដោះលែងបងដោយសម្ដីដ៏ផ្អែមរបស់ខ្ញុំ ប្រសិនបើខ្ញុំមិនអាចអង្វរនាយព្រានទេ ខ្ញុំនឹងប្ដូរជីវិត សុខចិត្តស្លាប់ជំនួសបង" ។

កាលលួងលោមពោធិសត្វហើយ ក៏យកអណ្ដាតរបស់ខ្លួនលិទ្ធនូវឈាម ដែលប្រឡាក់ត្រង់ជើងប្រើសព្រះពោធិសត្វយ៉ាងស្អាត ហើយឈរក្បែរប្រើសស្វាមី រង់ចាំនាយព្រាន ។ មិនយូរប៉ុន្មាន នាយព្រានបានកាន់ដាវលំពែង ដើរចូលមកទីប្រើសជាប់អន្ទាក់ ។ គ្រានោះ ប្រើសជាកវិយាឃើញនូវព្រានភ្លាម ក៏ពោលនឹងប្រើសជាស្វាមីថា :

"បពិត្រស្វាមី នាយព្រានកំពុងដើរមកហើយ ខ្ញុំនឹងព្យាយាមអង្វរព្រានតាមសមត្ថភាពរបស់ខ្ញុំ សូមបងកុំមានការភិតភ័យអី" ។

ប្រើសញី ក៏ដើរតម្រង់ឆ្ពោះទៅខាងមុខនាយព្រាន លុតជង្គង់ថ្វាយបង្គំ ពោលសរសើរអំពីគុណស្វាមីរបស់ខ្លួនប្រាប់ព្រាននោះថា :

"បពិត្រព្រានដ៏មានឫទ្ធិ ប្រើសនេះជាស្វាមីរបស់នាងខ្ញុំ មានពណ៌សម្បុរដូចមាស ជាអ្នកដល់ព្រមដោយសីលាចារ ជាស្ដេចប្រើសទាំង ៨.០០០ ហើយបានគ្រប់គ្រងរក្សាហ្វូងប្រើសដ៏ច្រើន ។ បពិត្រព្រានដ៏ចម្រើន សូមលោកសម្លាប់នាងខ្ញុំវិញចុះ ហើយសូមទុកជីវិតដល់ប្រើសជាស្វាមីរបស់ខ្ញុំផង" ។

នាយព្រានឮសំឡេងនិយាយដូច្នេះ ក៏ប្លែកក្នុងចិត្តថា :

"សូម្បីមនុស្ស ក៏មិនងាយមានអ្នកដែលហ៊ានលះបង់ជីវិតខ្លួន ដើម្បីស្វាមីក្នុងគ្រាអាសន្នយ៉ាងនេះដែរ ហើយមានសូរសព្ទជាភាសាមនុស្សយ៉ាងពីរោះបែបនេះ អ៊ីចឹងថ្ងៃនេះ យើងនឹងផ្ដល់នូវអភ័យដល់ជីវិតសត្វទាំងពីរនេះ" ។

ពេលនោះ នាយព្រានបានពោលទៅកាន់ប្រើសញីនោះថា :

"ខ្ញុំមិនដែលឮ ឬឃើញមេប្រើសចេះនិយាយភាសាមនុស្សទេ ។ ម្នាលមេប្រើសដ៏ចម្រើន នាងចូរនៅជាសុខចុះ ទាំងមហាប្រើសនុ៎ះក៏សូមឱ្យនៅជាសុខផងដែរ" ។

នាងប្រើសញីត្រេកអរយ៉ាងខ្លាំង ក៏ឱ្យពរតបទៅនាយព្រានវិញថា ៖

"បពិត្រព្រានដ៏មានឫទ្ធិ ខ្ញុំត្រេកអរណាស់ ព្រោះឃើញមហាប្រើស ដែលរួចចាកអន្ទាក់ក្នុងថ្ងៃនេះយ៉ាងណា សូមអ្នកត្រេកអរជាមួយនឹងពួកញាតិទាំងឡាយយ៉ាងនោះដែរចុះ" ។

ប្រើសពោធិសត្វ ជ្រះថ្លានឹងគុណធម៌របស់នាយព្រាន ក៏បានបង្ហាញប្រាប់នូវដុំកែវមណី ដែលខ្លួនជួបប្រទះពេលស្វែងរកអាហារ ក្នុងកាលមុនឱ្យដល់ព្រាននោះ ហើយផ្តល់ឱវាទថា ៖

"បពិត្រនាយព្រាន ចាប់តាំងពីថ្ងៃនេះតទៅ ចូរលោកកុំធ្វើនូវអំពើដែលមានការកាប់សម្លាប់សត្វជាដើមឡើយ សូមលោករក្សានូវសីល ៥ សព្វកាល ពេលលោកទទួលនូវទ្រព្យនេះហើយ លោកអាចចិញ្ចឹមកូនប្រពន្ធ និងធ្វើបុណ្យសុន្ទរទានរក្សាសីលជាដើម រហូតដរាបអស់ជីវិត" ។

កាលផ្តល់ឱវាទរួចហើយ ស្តេចប្រើសក៏នាំប្រើសញីជាភរិយាចូលទៅក្នុងព្រៃវិញ ។

ព្រះសាស្តាប្រជុំជាតកថា នាយព្រានក្នុងកាលនោះ បានមកជាឆន្នភិក្ខុ ឯប្រេីសញីបានមកជា ភិក្ខុនីមួយរូប រីឯស្តេចប្រេីស គឺព្រះអរហន្តសម្មាសម្ពុទ្ធតថាគតនេះឯង ។

**(ចប់សុវណ្ណមិគជាតក)**

# ១៥. ខន្តិវាទីជាតក

សម័យមួយ នៅដែនកាសី មានស្តេចមួយអង្គព្រះនាម **កលាពុ** សោយរាជ្យនៅក្រុងពារាណសី ។ កាលនោះ ព្រះពោធិសត្វទ្រង់យោន យកកំណើតក្នុងត្រកូលព្រាហ្មណ៍មួយ ដែលមានទ្រព្យសម្បត្តិ ៨០ កោដិ ។ កាលនៅក្មេងមានឈ្មោះថា **កុណ្ឌលកុមារ** ។ បន្ទាប់ពីបានរៀនសូត្រសិល្ប៍-សាស្ត្រចប់សព្វគ្រប់នៅឯ **តក្កសីលា** ហើយ កុណ្ឌលកុមារក៏មកជួយបម្រើឪពុកម្តាយរបស់ខ្លួនវិញ ។ លុះឪពុកម្តាយទទួលមរណកាលទៅ លោកក៏សម្រេចចិត្តទៅបួសជាតាបសនៅព្រៃហេមពាន្ត ។ ជាធម្មតានៃតាបសដែលរស់នៅក្នុងព្រៃ តែងតែបរិភោគនូវផ្លៃឈើ និងដំឡូងជាដើម ដែលមិនមានរសជាតិប្រៃនោះឡើយ ។

ថ្ងៃមួយ តាបសបានចុះពីភ្នំ ធ្វើដំណើរត្រាច់ចរទៅបិណ្ឌបាត នៅក្រុងពារាណសី គោលបំណងដើម្បីរសជាតិប្រៃ និងស្ករ ។ល។ ក្នុងកាលកំពុងត្រាច់ចរបិណ្ឌបាតនោះ មានសេនាប្រមុខម្នាក់ ជ្រះថ្លាចំពោះឥរិយាបថដែលមានលក្ខណៈសមរម្យរបស់តាបស ។ លោកសេនាប្រមុខ ក៏មានចិត្តសោមនស្សរីករាយ បាននិមន្តតាបសឆាន់ចង្ហាន់នៅគេហដ្ឋានរបស់លោក។ បន្ទាប់មក លោកសេនាប្រមុខបានប្រគេនតាបសនូវម្ហូបអាហារ ដែលគេរៀបចំត្រៀមសម្រាប់លោកផ្ទាល់ ។

បន្ទាប់ពីតាបសឆាន់រួចរាល់ហើយ លោកសេនាប្រមុខក៏សួរតាបសថា :

"តើលោកម្ចាស់ នឹងនិមន្តទៅទីណាទៀត? ខ្ញុំព្រះករុណានឹងរៀបចំរថប្រគេន" ។

តាបសតបវិញថា :

"អាត្មានឹងទៅសម្រាកនៅឯឧទ្យានព្រះរាជា ក្រោមដើមសាលព្រឹក្ស" ។

តាបសនោះ ក៏ធ្វើដំណើរចូលទៅកាន់ព្រះរាជឧទ្យាន សម្រាកនៅខាងក្រោមដើមសាលព្រឹក្ស ដែលមានមែកសាខាត្រសាយត្រសុំ ត្រឈឹងត្រឈៃគួរជាទីមនោរម្យក្រៃលែង ។

ថ្ងៃនោះ ព្រះបាទ**កលាពុ** យាងមកកាន់សួនទាំងស្រវឹងផង ហែហមដោយពួកអ្នកភ្លេង និងអ្នកច្រៀងមួយហ្វូងធំ ។ ពួកគីលៀង ក៏បានរៀបចំខ្នើយថ្វាយព្រះអង្គសម្រាកព្រះកាយ ។ ពេលនោះ គីលៀងស្រីៗ ខ្លះច្រៀង ខ្លះរាំ ខ្លះលេងភ្លេងថ្វាយព្រះរាជាកម្សាន្ត ។ ព្រះរាជាទន់ដោយសុរាខ្លាំងពេក មិនយូរប៉ុន្មាន ព្រះអង្គក៏ផ្ទំលក់ទៅ ។ ពួកអ្នករាំច្រៀង និងអ្នកលេងភ្លេងទាំងអស់ កាលបើឃើញព្រះរាជាទ្រង់ផ្ទំលក់ហើយ ក៏នាំគ្នាគេចខ្លួនចេញអំពីទីនោះម្នាក់ម្តងៗ រហូតអស់គ្នាពីទីនោះ នៅសល់តែស្នំម្នាក់ ដែល

ព្រះរាជាផ្ទុំកើយភ្ញៅ ។ កាលពួករបាំទាំងនោះកំពុងដើរកម្សាន្តក្នុងសួនឧទ្យាន ក៏ឃើញតាបសកំពុងគង់ភាវនាធម៌ នៅក្រោមដើមសាលព្រឹក្ស ។ ពួកគេក៏នាំគ្នាទាំងប្រុសទាំងស្រីចូលទៅថ្វាយបង្គំតាបស ហើយក៏សូមអារាធនានិមន្តតាបសឱ្យសម្តែងធម៌ដោយវាចាថា :

"បពិត្រតាបសដ៏ចម្រើន សូមលោកមេត្តាសម្តែងធម៌អ្វី ដែលមានតម្លៃ និងជាប្រយោជន៍ដល់យើងខ្ញុំទាំងអស់គ្នាបានស្តាប់ផង" ។

តាបសក៏ចាប់ផ្តើមសម្តែងធម៌ ។ ពេលនោះ នាងស្នំឯកបានកម្រើកខ្លួន ធ្វើឱ្យព្រះរាជាតើនឡើង ។ ព្រះរាជាក៏ងើបសួរស្នំឯកដែលទ្រង់ផ្ទុំកើយភ្ញៅថា :

"ពួកវាទៅណាអស់ ហេតុអ្វីបានជាឈប់លេងភ្លេងនិងច្រៀងដូច្នេះ" ។

នាងស្នំឯកបានទូលតបព្រះរាជាវិញថា :

"បពិត្រព្រះសម្មតិទេព ពួកកីលៀងនិងស្នំឯទៀត បាននាំគ្នាទៅដើរលេង ហើយឥឡូវនេះ កំពុងអង្គុយស្តាប់ធម៌តាបសមួយអង្គ នៅក្រោមដើមសាលព្រឹក្ស ក្នុងឧទ្យាននេះឯង ក្រាបទូល!" ។

រំពេចនោះ ព្រះរាជាទ្រង់ខ្ញាល់ជាខ្លាំង ក៏ស្ទុះទៅកាន់ព្រះខ័ន យាងតម្រង់ទៅដើមសាលព្រឹក្សនោះ ។ កាលព្រះរាជាយាងទៅដល់ទីនោះ មាន

ស្នំម្នាក់ដែលជាទីពេញព្រះទ័យព្រះរាជា ក៏ចូលទៅចាប់ទាញព្រះខ័នទុក ។ ពេលនោះ ស្តេចកលាពុ ក៏សួរថា :

"នៃតាបស តើអ្នកឯងមានប្រក្រតីពោលពាក្យដូចម្តេច?"

តាបសពោលតបថា :

"បពិត្រមហារាជ អាត្មាមានប្រក្រតីពោលពីការអត់ធន់ គឺខន្តីធម៌" ។

ព្រះរាជាសួរបន្តទៀតថា :

"តើខន្តីនោះ យ៉ាងណាទៅ?"

តាបសឆ្លើយតប :

"បពិត្រមហារាជ ខ្លួនយើង ទោះបីបុគ្គលណាមួយជេរក៏ដោយ ដាក់បណ្តាសាក៏ដោយ វាយក៏ដោយ យើងមិនត្រូវប្រទូស្តតប ឬខឹងតបឡើយ" ។

ពេលនោះ ព្រះរាជាកាន់តែខ្វាល់ឡើង ទើបហៅនាយពេជ្ឈឃាតដែលប្រចាំនគរមក ដោយទ្រង់ចង់ដឹងពីពាក្យខន្តីចំពោះតាបសនោះ ។

ព្រះរាជាទ្រង់បានបញ្ជាឱ្យពួករាជបុរស ចាប់ទាញសំពត់កាសាវពស្ត្រ ចេញពីខ្លួនតាបស ហើយចាប់លោករុញផ្អឹបទៅនឹងផែនដី វាយលោក

ពីខាងមុខ ១.០០០ ដំបង ខាងក្រោយ ១.០០០ ដំបង ចំហៀងខាងស្តាំ ១.០០០ ដំបង និងចំហៀងខាងឆ្វេង ១.០០០ ដំបង ។

ក្នុងកាលនោះ តាបសបែកស្បែក ធ្លាយសាច់ហូរឈាម ក្រហមច្រាលស្រោចពេញខ្លួនប្រាណ ។

ពួករាជបុរស មន្ត្រីរាជការ ពួកស្នំទាំងឡាយ មានចិត្តក្តុកក្តួល ញាប់ញ័រក្នុងខ្លួន អាណិតតាបស ដែលគ្មានទោសអ្វីបន្តិចសោះ ត្រូវព្រះរាជាវាយធ្វើបាប ។

ព្រះរាជាក៏ទ្រង់សាកសួរបន្ត :

"តើអ្នកមានប្រក្រតីពោលដូចម្តេច?"

តាបសតបវិញថា :

"បពិត្រមហារាជ អាត្មាមានប្រក្រតីពោលអំពីការអត់ធន់គឺ **ខន្តិធម៌**, បពិត្រមហារាជ សូមព្រះអង្គកុំសម្គាល់សេចក្តីអត់ធន់ថា ស្ថិតនៅក្នុងចន្លោះស្បែករបស់អាត្មាឡើយ, សេចក្តីអត់ធន់ ស្ថិតនៅក្នុងបេះដូងដ៏ជ្រៅរបស់អាត្មាឯណោះទេ" ។

ព្រះរាជាកាន់តែខ្ញាល់ខ្លាំងឡើងៗ ទើបបញ្ជាឲ្យពេជ្ឈឃាតកាត់ដៃ កាត់ជើង កាត់ស្លឹកត្រចៀក កាត់ច្រមុះរបស់តាបសទៀត ។ ឈាមហូរចុះពី

កន្ទេងកាត់ទាំងឡាយ ប្រៀបដូចទឹកដែលហូរចេញពីក្អម ។ នៅទីលាន ក្រោមសាលព្រឹក្ស មានឈាមហូរពោរពេញទីនោះ ដូចជាកន្ទេងសម្លាប់ សត្វជ្រូក ឬសត្វគោអ៊ីចឹង ។

ទោះបីជាព្រះរាជាទ្រង់ត្រាស់សួរពាក្យដដែលៗ តាបសនៅតែពោល ពីខន្តីធម៌ថា ជាធម៌ដ៏ឧត្តមដដែល ។

ព្រះរាជាមិនអាចញុាំងតាបសឱ្យខឹងក្រោធឡើយ សូម្បីតែទឹកមុខ របស់តាបស នៅតែមានសភាពជាធម្មតា ។ ព្រះរាជាក៏លោតដោយជើង ទាំងពីរធាក់ចំកណ្តាលទ្រូងតាបសនោះ បណ្តាលឱ្យតាបសដួលផ្ងារក្រោយ ព្រោះគ្មានអ្វីទប់ជំហរទៀតទេ ដោយដៃជើងទាំងពីរនោះ ត្រូវព្រះរាជាបញ្ជា ឱ្យពេជ្ឈឃាតកាត់អស់រលីង ។

បន្ទាប់ពីលោតធាក់តាបសនោះហើយ ព្រះរាជាទ្រង់ក៏ធ្វើដំណើរ ចាកចេញពីទីនោះទៅ ។ ខណៈនោះ លោកសេនាប្រមុខបានចូលទៅចាប់ បីត្រកងតាបស ដោយសភាពអាណិតអាសូរយ៉ាងខ្លាំង ហើយពោលថា :

"បពិត្រលោកម្ចាស់ អ្នកមានព្យាយាមដ៏ធំ ព្រះរាជាដែលបានកាត់ ដៃទាំងពីរ ជើងទាំងពីរ ត្រចៀក និងច្រមុះរបស់លោក សូមលោក

ខឹងចំពោះតែព្រះរាជានោះចុះ សូមលោកកុំផ្ដាសាដែននេះឱ្យវិនាស

ឡើយ" ។

តាបសឆ្លើយតប :

យោ មេ ហត្ថេ ច បាទេ ច កណ្ណនាសញ្ច ឆេទយិ
ចិរំ ជីវតុ សោ រាជា ន ហិ កុជ្ឈន្តិ មាទិសា ។

ប្រែ : ព្រះរាជាដែលបានកាត់ដៃទាំងពីរ ជើងទាំងពីរ ត្រចៀក និងច្រមុះរបស់អាត្មា សូមឱ្យព្រះរាជានោះ ទ្រង់មានព្រះជន្មយឺនយូរ ដ្បិតថាពួកអ្នកប្រាជ្ញដូចយ៉ាងអាត្មា មិនបានខឹងក្រោធឡើយ[៧៣] ។

ក្រោយពីព្រះរាជាបានយាងចេញពីឧទ្យានមិនឆ្ងាយប៉ុន្មានផង ក៏ត្រូវផែនដីស្រូបលិចចូលទៅបាត់ស្រមោល ។ ក្រោយចូលទិវង្គតហើយ ក៏បានទៅកើតក្នុងមហានរកឈ្មោះអវិចី[៧៤] ។

ចំណែកលោកតាបសបានហូរឈាមអស់ពីខ្លួន ក៏ធ្វើមរណកាលក្នុងថ្ងៃនោះដែរ ។

[៧៣] សុត្តន្តបិដក លេខ ៥៨ ទំព័រ ១៩៩ ។

[៧៤] ពាក្យបាលីថា **អវីចិ** តែប្រើជាទម្លាប់នៃការនិយាយក៏ក្លាយជា **អវិចី**, មហានរកដែលមានភ្លើងឆេះជានិច្ច ហើយត្រូវទទួលទុក្ខវេទនាយ៉ាងខ្លាំង ។

កាលតាបសរូបនោះធ្វើមរណកាលហើយ ពួកអ្នកនគរមានសេចក្តីជ្រះថ្លាចំពោះគុណធម៌របស់លោក ក៏នាំគ្នាយកគ្រឿងសក្ការៈគោរពបូជាសពតាបស ហើយបាននាំគ្នាហៅលោកថា **ខន្តិវាទីតាបស** ។

កាលចប់ធម្មទេសនា ព្រះពុទ្ធជាម្ចាស់ប្រជុំជាតកថា :

- ស្តេចកលាពុ បានមកជាភិក្ខុទេវទត្ត
- ឯលោកសេនាប្រមុខ បានមកជាព្រះសារីបុត្រអគ្គសាវ័កស្តាំ
- ឯលោកតាបសបានមកជាតថាគតនេះឯង ៕

**(ចប់ខន្តិវាទីជាតក)**

## ១៦. ផលជាតក

ក្នុងកាលដ៏យូរលង់អង្វែងមក នៅក្រុងពារាណសី ព្រះពោធិសត្វបានយោនកំណើតជាពាណិជ្ជកម្នាក់ ដែលតែងតែនាំរទេះជំនួញរាប់រយ ចូលកាត់ព្រៃផង វាលខ្សាច់ផង ទៅជួញដូរនៅស្រុកឆ្ងាយ ។ នៅពេលដែលចូលកាត់ព្រៃម្តងៗ នាយពាណិជតែងតែណែនាំសមាជិករបស់ខ្លួនថា :

"ម្នាលអ្នកទាំងឡាយ ចូរអ្នកប្រុងប្រយ័ត្នកុំទទួលទានផ្លែឈើ មើមឬស្លឹកឈើ ដោយមិនពិគ្រោះជាមួយនឹងខ្ញុំជាមុនឱ្យសោះ ព្រោះក្នុងព្រៃនេះ មានរុក្ខជាតិដែលមានជាតិពុលជាច្រើន" ។

ពួកពាណិជទាំងអស់តែងយកចិត្តទុកដាក់ស្តាប់ឱវាទនាយ ពាណិជជានិច្ច ហើយបានជួបប្រសព្វសេចក្តីសុខដរាបរៀងមក ។ ថ្ងៃមួយក្បួនរទេះបានចេញផុតពីព្រៃ ហើយក៏មកឈប់សម្រាកនៅក្បែរភូមិមួយ ។ កាលរាត្រីបានចូលមកដល់ ក្បួនរទេះក៏ត្រូវឈប់សម្រាកនៅទីនោះ ។

អ្នករទេះខ្លះ ក៏ទៅឈប់សម្រាកនៅក្រោមដើមស្វាយព្រៃមួយដើមដ៏ធំ ដែលពោរពេញដោយផ្លែដ៏ច្រើន មិនខ្ពស់ប៉ុន្មានពីដី ។ ពេលនោះ អ្នកដែលមកមុនគេសប្បាយចិត្តណាស់ ដោយបានឃើញផ្លែស្វាយទុំច្រើន ។ មិនត្រឹមប៉ុណ្ណោះទេ សូម្បីមែកស្វាយនោះទាបៗ ឯផ្លែស្វាយបានធ្លាក់សំយុងមកខាងក្រោម ធ្វើឱ្យងាយក្នុងការបេះដោយស្រួល ពុំចាំបាច់នាំគ្នាឡើងទៅ

លើដើមស្វាយនោះឡើយ ។ រំពេចនោះ បុរសម្នាក់ស្រែកឃាត់ថា អ្នកមិន អាចទទួលទានស្វាយនេះទេ យើងត្រូវពិគ្រោះជាមួយនឹងនាយពាណិជជា មុនសិន ។ យឺតពេលបន្តិចហើយ អ្នកខ្លះទទួលទានស្វាយរួចទៅហើយ នៅ ពេលដែលនាយពាណិជមកដល់ ឈ្នួញខ្លះកំពុងចាប់ផ្ដើមក្អួត និងចុកពោះ ននៀលក្រោមដើមស្វាយ ។ នាយពាណិជប្រញាប់ប្រញាល់យកថ្នាំមក ព្យាបាលអ្នកទាំងនោះឱ្យជាសះស្បើយពីជំងឺពុល ។ នៅពេលយប់ងងឹត នាយពាណិជបញ្ជាឱ្យឈ្នួញទាំងឡាយដុតភ្លើងគប់ ហើយនៅជាក្រុមៗ ដើម្បីការពារសុវត្ថិភាព ។ លោកហាមផ្ដាច់មិនឱ្យអ្នកណាម្នាក់ទទួលទាន ស្វាយ ឬផ្លែឈើទាំងឡាយណា ដែលនៅជុំវិញបរិវេណនោះ ។ ដោយនឿយ ហត់ក្នុងដំណើរផ្លូវឆ្ងាយ ឈ្នួញទាំងឡាយក៏ដេកលក់ស្កប់ស្កល់អស់ទៅ ។

នៅពេលព្រលឹមស្រាងៗ នាយពាណិជបានឮសូរសំឡេងអ្នកភូមិនាំ គ្នារត់តម្រង់ជំរំ ហើយអ្នកខ្លះស្រែកថា គោនិងរទេះផ្នែកខាងលិចដើមស្វាយ ជារបស់អញ ឯពួកឯងទៅយករទេះខាងកើតចុះ រីឯម្នាក់ទៀតស្រែកឡើង ថា រទេះធំ ហើយល្អជាងគេគឺជារបស់អញ... ។ ដោយព្រះពោធិសត្វលោក យល់អំពីហេតុការណ៍ដ៏ចម្លែកនេះ លោកក៏ប្រាប់ឈ្នួញទាំងឡាយឱ្យនៅ សំងំធ្វើពុតជាដេកលក់ ។ នៅពេលអ្នកភូមិបានមកដល់ជំរំ ស្រាប់តែពួក

ពាណិជ្ជករទាំង ៥០០ នាក់ បានក្រោកឡើងទាំងអស់គ្នា ធ្វើឱ្យអ្នកភូមិភ្ញាក់ស្រឡាំងកាំងជាពន់ពេក ។ អ្នកភូមិម្នាក់ភ្ញាក់មាត់ឡើងថា :

"គេនៅរស់ទាំងអស់គ្នាហេតុអ្វីបានជាគេដឹង?"

ពាណិជ្ជករម្នាក់សួរទៅអ្នកភូមិថា: "ដឹងពីអ្វី?"

អ្នកភូមិអេះអុះហើយឆ្លើយថា :

"ហេតុអ្វីបានជាអ្នកដឹងថា ផ្លែនេះមិនមែនជាផ្លែស្វាយពិត?"

ពាណិជ : "ខ្ញុំមិនដឹងទេ អ្នកឯងសួរមេរបស់ខ្ញុំចុះ" ។

ពេលនោះ នាយពាណិជឆ្ពោះទៅកាន់ក្រុមអ្នកភូមិហើយ លោកក៏បានចង្អុលទៅដើមស្វាយព្រៃ រួចពោលថា :

"គ្មានអ្វីដែលជាការពិបាកយល់សោះ ចូរអ្នកសម្លឹងមើលដើមឈើនេះ មិនមែនជាដើមស្វាយពិតប្រាកដទេ វាមានរាងនិងដើមដូចស្វាយមានផ្លែជាច្រើន ហើយមែកក៏ទាប មានអ្នកស្រុកអ្នកភូមិនៅជិតនេះ ហេតុអ្វីបានជាគេមិនបេះយកទៅទទួលទាន? ព្រោះផ្លែឈើនេះមានជាតិពុល ។ អ្នកភូមិទាំងអស់គ្នា មានគំនិតអាក្រក់ ទុកផ្លែឈើនេះ ជានុយសម្រាប់ឱ្យអ្នកដំណើរពុលស្លាប់ ហើយក៏នាំគ្នាដណ្តើមយកទ្រព្យសម្បត្តិរបស់អ្នកដំណើរ ។ អ្នកទាំងឡាយធ្វើអំពើ

នេះ ជាទង្វើបាបកម្ម ពីព្រោះអ្នកទាំងអស់គ្នាមានបំណងសម្លាប់មនុស្ស ហើយទ្រព្យសម្បត្តិទាំងប៉ុន្មានដែលអ្នករៀបចំផែនការសម្លាប់គេយកទ្រព្យនេះ ពុំនាំមកនូវសេចក្តីសុខដល់អ្នកទាំងអស់គ្នាឡើយ ចូរអ្នកបញ្ឈប់នូវអំពើបាបកម្មនេះ ហើយត្រូវរក្សាសីលចាប់ពីពេលនេះតទៅ" ។

ពួកអ្នកភូមិ យល់អំពីកំហុសរបស់ខ្លួន ហើយបានសុំអភ័យទោសពីនាយពាណិជ ។

នាយពាណិជក៏បានអត់ទោសឱ្យដល់អ្នកស្រុកទាំងនោះ ហើយនាំពួកឈ្មួញរទេះធ្វើដំណើរទៅកាន់លំនៅរបស់ខ្លួន ប្រកបដោយសេចក្តីសុខរហូតចែកឋានគ្រប់ៗគ្នា ៕

**(ចប់ផលជាតក)**

# ១៧. រឿងមាតុបោសកភិក្ខុ

## (ភិក្ខុកតញ្ញូ)

កាលព្រះសម្មាសម្ពុទ្ធគង់នៅវត្តជេតពន មានភិក្ខុមួយចំនួនបាន លើករឿងភិក្ខុមួយអង្គ ដែលតែងតែឆ្លៀតពេលចេញពីវត្តទៅភូមិកំណើត ដើម្បីធ្វើការបម្រើមនុស្សចាស់ពីររូប ។ ព្រះសម្មាសម្ពុទ្ធទ្រង់បញ្ជាឱ្យភិក្ខុ អង្គនោះចូលមកជួប ហើយទ្រង់ត្រាស់សួរថា :

"ការលើកឡើងរបស់ភិក្ខុទាំងឡាយថា អ្នកបានទៅធ្វើការបម្រើ គាំទ្រជីវភាពសាច់ញាតិរបស់អ្នក តើមែនឬទេ?"

ភិក្ខុឆ្លើយតបថា :

"បពិត្រព្រះដ៏មានព្រះភាគ នេះជាការពិតមែនព្រះអង្គ" ។

ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់សួរបន្តទៀតថា :

"តើញាតិទាំងនោះត្រូវជាអ្វីនឹងអ្នកដែរ?"

ភិក្ខុឆ្លើយទូលថា :

"គឺជាមាតាបិតាចាស់ជរារបស់ខ្ញុំព្រះករុណា" ។

ព្រះសម្មាសម្ពុទ្ធទ្រង់បានត្រាស់ប្រកាសឡើងថា :

"ប្រសើរណាស់ ប្រសើរណាស់! អ្នកធ្វើនេះត្រូវហើយ សូម្បីតែតថាគត កាលកើតជាសត្វសេកក៏រកស៊ីចិញ្ចឹមមាតាបិតាចាស់ជរារបស់ខ្លួនដូច្នេះដែរ ។ ម្នាលភិក្ខុ អ្នកជាបុត្រកតញ្ញូ កម្ររកបានណាស់" ។

បន្ទាប់មក ភិក្ខុទាំងឡាយក៏អារាធនាព្រះសម្មាសម្ពុទ្ធឱ្យសម្តែងនូវរឿងអតីតកាលរបស់សត្វសេកនោះតទៅ :

# សាលិកេទារជាតក

## (សត្វសេកកតញ្ញូ)

កាលពីអតីតជាយូរកន្លងមក ព្រះពោធិសត្វយោនកំណើតជាសត្វសេកមួយឈ្មោះថា **សាលិកេទារ** រស់នៅតាមព្រៃមួយ ក្បែរភ្នំហេមពាន្ត ។ បន្ទាប់ពីបានទទួលការគ្រប់គ្រងហ្វូងសត្វសេកដ៏ធំមួយជាបរិវារ បន្តពីឪពុកចាស់ជរានោះមក ស្ដេចសេកក្មេងតែងតែនាំហ្វូងសេកទាំងឡាយជាបរិវារទៅរកចំណីដោយសុខក្សេមក្សាន្ត គឺតាមវាលរាប ចន្លោះភ្នំ ដែលសម្បូរដោយស្រូវសាលីព្រៃដុះពាសពេញ ជាចំណីរបស់បក្សាបក្សីទាំងឡាយ ។

ថ្ងៃមួយ ពួកសត្វសេកជាបរិវារ ចូលមកជួបស្ដេចសេកក្មេង ហើយលើកសំណូមពរថា :

"បពិត្រលោកម្ចាស់ជាទីគោរព ពេលនេះជារដូវដែលស្រូវសាលីនៅនគរមគធ: ទុំបរិបូរហើយ ។ ពួកយើងគួរនាំគ្នាទៅរកស៊ីនៅទីនោះ ព្រោះស្រូវសាលីនគរមគធ:នោះ មានរសជាតិឆ្ងាញ់ ប្រសើរជាងស្រូវសាលីព្រៃ ដែលយើងយកជាចំណីអាហាររាល់ថ្ងៃនេះ" ។

ថ្ងៃបន្ទាប់មក ពួកហ្វូងសេកទាំងឡាយ ក៏នាំគ្នាទៅរកស៊ីជារៀងរាល់ថ្ងៃ នៅនគរមគធ: ។ ដោយហ្វូងសេកមានគ្នាច្រើនដ៏លើសលប់ ពេលចុះស៊ី

ស្រូវម្តងៗ ឆ្មាំយាមស្រែពុំអាចដេញសេកទាំងនោះ ឱ្យហើរចេញឡើយ បណ្តាលឱ្យខូចខាតស្រូវជាច្រើន ។ ដោយខ្លាចទទួលពិន័យកាត់ភោគផល ពីម្ចាស់ស្រែ មេឆ្មាំក៏នាំដំណឹងនេះទៅជូនលោកសេដ្ឋី**កោសិយគោត្ត** ជាចៅហ្វាយនាយរបស់ខ្លួនថា :

"បពិត្រលោកម្ចាស់ ឆ្នាំនេះផលស្រូវសាលីល្អណាស់ តែខ្ញុំសូមជម្រាបលោកម្ចាស់មេត្តាជ្រាបថា មានហ្វូងសត្វសេកជាច្រើន បានចុះមកស៊ីស្រូវសាលី ដោយខ្ញុំពុំអាចការពារបាន ក៏បណ្តោយឱ្យពួកវាស៊ីតាមចិត្តទៅ ។ តែគួរឱ្យចម្លែកណាស់ នៅក្នុងបណ្តាសត្វសេកទាំងនោះ មានសេកមួយមាឌធំជាងគេ មានរូបឆោមពណ៌សម្បុរល្អប្លែក គួរឱ្យចាប់អារម្មណ៍ ។ ជាងនេះទៅទៀត ជារៀងរាល់ថ្ងៃ សេកនេះ នៅពេលស៊ីស្រូវសាលីឆ្អែតហើយ តែងពាំស្រូវសាលីជាច្រើនកួរ យកទៅទុកស៊ីថ្ងៃក្រោយទៀត" ។

ឮដូច្នេះហើយ លោកសេដ្ឋី**កោសិយគោត្ត** គិតថា "សេកនេះ ពិតជាមេគេ... ជាស្តេចសេក អញចង់ឃើញវាណាស់" រួចក៏បញ្ជាទៅនាយឆ្មាំថា :

"នែនាយឆ្មាំ ចូរអ្នកទៅដាក់អន្ទាក់ចាប់សេកនោះឱ្យបាន ហើយយកទាំងរស់មកឱ្យខ្ញុំនៅទីនេះ" ។

ទទួលបញ្ជាដូច្នេះហើយ នាយធ្នាក៏ទៅរៀបចំដាក់អន្ទាក់នៅត្រង់កន្លែងដែលមេសេកនោះ តែងតែចុះស៊ីស្រូវសាលីរាល់ៗដង ។ នៅថ្ងៃបន្ទាប់នាពេលព្រលឹមស្រាងៗ ហ្វូងសេកដ៏ធំនោះ ក៏មកដល់ស្រែរបស់លោកសេដ្ឋី **កោសិយគោត្ត** ហើយបាននាំគ្នាចុះស៊ីស្រូវសាលី ដូចសព្វដង ។ ពេលនោះ **សាលិកេទារ** ក៏ចុះស៊ីស្រូវសាលីនៅកន្លែងដដែល រំពេចនោះ ជើងក៏ធ្លាក់ជាប់នឹងអន្ទាក់ ហើយមានការឈឺចុកចាប់ជាខ្លាំង ទោះបីខំរើបម្រះយ៉ាងណាក៏ពុំរួច ។ ដោយខ្លាចសេកទាំងឡាយភ័យផ្អើលទៅឡើ ខានស៊ីចំណីស្ដេចសេកក្មេងក៏ខំអត់ទ្រាំនឹងការចុកចាប់ ហើយពិចារណាថា :

"តើខ្ញុំធ្វើបាបកម្មអ្វី បានជាមកជាប់អន្ទាក់នេះ?"

លុះដល់ពេលសមល្មមថា សត្វសេកទាំងអស់ជាបរិវារ ស៊ីចំណីឆ្អែតហើយ ទើបស្ដេចសេក ចាប់ស្រែកយំឡើងយ៉ាងគ្រលួចឱ្យជាសញ្ញាដល់ពួកសេកទាំងអស់ថា ខ្លួនមានគ្រោះថ្នាក់ដោយជាប់អន្ទាក់ហើយ ។ ឮសម្រែកនេះហើយ សត្វសេកជាបរិវារទាំងអស់ក៏ភិតភ័យភ្ញាក់ផ្អើលជាខ្លាំង ហើយនាំគ្នាហោះហើរឈ្មុលពេញមេឃលើវាលស្រែ ។ ស្ដេចសេកនៅជាប់អន្ទាក់តែម្នាក់ឯង ដោយពោលក្នុងចិត្តថា :

"ពួកគេស៊ីឆ្អែត ផឹកឆ្អែត រួចហើរទៅបាត់អស់ហើយ មានតែខ្ញុំទេ
នៅជាប់អន្ទាក់តែម្នាក់ឯង តើខ្ញុំបានសាងបាបកម្មអ្វីទៅហ្ន៎?"

ពេលនោះ នាយឆ្មាំក៏មកដល់កន្លែងដាក់អន្ទាក់តែម្តង គេមានសេចក្តីរីករាយណាស់ ដោយបានឃើញស្តេចសេកជាប់អន្ទាក់របស់ខ្លួនដូចបំណងមែន ។ នាយឆ្មាំក៏ពោលថា :

"នេះពិតជាសេកធំ ដែលយើងចង់បានមែន" ។

ពោលដូច្នេះហើយ នាយឆ្មាំបានដោះសេកចេញពីអន្ទាក់ ហើយចងជើងទាំងពីរជាប់គ្នា រួចក៏ធ្វើដំណើរដោយប្រញាប់ប្រញាល់ទៅកាន់ភូមិគ្រឹះ **លោកសេដ្ឋីកោសិយគោត្ត** នៅភូមិសាលិន្ទិយគ្រាម ។

ឃើញស្តេចសេកភ្លាម **លោកសេដ្ឋី** មានចិត្តរំភើបត្រេកអរជាខ្លាំង និងបានទទួលយកសេកមកកាន់ដោយថ្នមៗ ហើយក៏ស្រាយចំណងពីជើងចេញ រួចលោកសួរសត្វសេកថា :

"អ្នកមានមាឌធំ ពោះធំជាងគេ អ្នកស៊ីស្រូវសាលីយើងឆ្អែតហើយ ចាំបាច់ពាំស្រូវយើងយកទៅទៀត តើអ្នកស្អប់យើងដោយប្រការអ្វីមួយ ឬក៏អ្នកមានជង្រុកធំប៉ុន្មានទៅ សម្រាប់ទុកស្រូវនោះ? ចូរអ្នកប្រាប់យើងឱ្យត្រង់មកចុះ តើអ្នកយកស្រូវសាលីនោះ ទៅគរទុកនៅកន្លែងណា?"

ពេលនោះ ស្តេចសេកនិយាយជាភាសាមនុស្សដ៏ផ្អែមល្ហែម ទៅកាន់លោកសេដ្ឋីថា :

"បពិត្រលោកកោសិយៈ ខ្ញុំពុំស្អប់លោកម្ចាស់ ដោយប្រការណាមួយឡើយ ហើយខ្ញុំក៏ពុំមានឃ្លាំងសម្រាប់គរទុកនូវស្រូវសាលីទាំងនោះដែរ ។ នៅពេលដែលខ្ញុំទៅដល់ក្នុងព្រៃរបស់ខ្ញុំហើយ ខ្ញុំត្រូវយកគ្រាប់ស្រូវសាលីនេះទៅសងបំណុលចាស់ផង ទៅបណ្តាក់បំណុលថ្មីផង (ឱ្យគេខ្ចី) ហើយមួយចំណែកទៀត ខ្ញុំទុកក្នុងឃ្លាំងសម្រាប់ពេលក្រោយ ។ នេះគឺជាចម្លើយ ដោយសច្ចៈរបស់ខ្ញុំ" ។

លោកកោសិយៈសួរបញ្ជាក់ថា :

"ចូរអ្នកពន្យល់ខ្ញុំឱ្យច្បាស់មក ខ្ញុំពុំយល់ពីអត្ថន័យនៃចម្លើយរបស់អ្នកឡើយ" ។

ស្តេចសេកឆ្លើយតបថា :

"ខ្ញុំមានមាតាបិតាចាស់ជរា ដែលលោកហើររកចំណីពុំរួច ទើបខ្ញុំយកក្ចួរស្រូវសាលីនេះ ទៅចិញ្ចឹមលោក នេះជាការសងបំណុលចាស់ដែលលោកបានចិញ្ចឹមថែរក្សានិងស្រឡាញ់ខ្ញុំដរាបរៀងមក"។

"ខ្ញុំមានកូនតូចៗ ដែលមានស្លាបទន់ខ្ចីនៅឡើយ ហើររកចំណីខ្លួនឯងពុំទាន់កើត ខ្ញុំមានកាតព្វកិច្ចចិញ្ចឹមពួកគេឱ្យធំឡើងដោយគ្រាប់ស្រូវសាលីនេះ ។ នេះហើយជាការបណ្តាក់បំណុលថ្មីរបស់ខ្ញុំ" ។

"នៅក្នុងព្រៃជាមួយនឹងខ្ញុំ មានសត្វសេកដទៃមួយចំនួនទៀត ដែលចាស់ជរា ខ្វះខ្វិន ខ្វះខ្វាក់ភ្នែក ហើររកចំណីដោយខ្លួនឯងពុំបាន ទើបខ្ញុំរំលែកស្រូវសាលីមួយផ្នែក សម្រាប់ចិញ្ចឹមពួកគេ ជាទានរបស់ខ្ញុំសម្រាប់អនាគត ។ ខ្ញុំបានជម្រាបលោកម្ចាស់ នូវការពិតទាំងអស់ហើយ ទានប្រោស!" ។

ពេលនោះលោកកោសិយៈ បានស្តាប់ចម្លើយរបស់សត្វសេក ដោយរន្ធត់ចិត្តក៏មានការស្រឡាញ់ ហើយកោតសរសើរស្តេចសេកជាខ្លាំង រួចលោកបានឆ្លើយតបទៅស្តេចសេកវិញថា :

"នេះជាឧត្តមគតិដ៏ខ្ពង់ខ្ពស់នៃជីវិត ចូរអ្នកមានសេចក្តីសុខចុះ ស្តេចសេកដ៏ប្រសើរ! សូម្បីមនុស្សទាំងឡាយ ដែលរស់នៅលើផែនដីនេះក៏ខ្ញុំពុំដែលឮនូវឧត្តមគតិ និងពាក្យពេចន៍ដ៏ពីរោះយ៉ាងនេះឡើយ ចូរអ្នកមកចុះ និងនាំទាំងបរិវារអ្នកទាំងអស់មកផង យើងនឹងប្រគល់ស្រូវសាលីនៃផ្ទៃដីចំនួន ១.០០០ អារ សម្រាប់ពួកអ្នកមកស៊ីចុកតាម

សេចក្តីត្រូវការចុះ ហើយយើងនឹងជួបគ្នាទៀត និងរក្សាមិត្តភាពដ៏យូរអង្វែងតទៅ" ។

បន្ទាប់មក លោកកោសិយៈ ក៏យកថ្នាំមកលាបជើងសេកទាំងពីរ ដែលត្រូវរបួស និងបានឱ្យចំណីដ៏ឆ្ងាញ់ៗដល់ស្តេចសេក មានពោតផ្អែម និងទឹកអំពៅជាដើម ។ ស្តេចសេកក៏ថ្លែងអំណរគុណចំពោះលោកកោសិយៈ ហើយថ្លែងថា :

"ខ្ញុំទទួលនូវចំណីអាហារ និងមិត្តភាពដ៏ប្រសើរនេះអំពីលោកម្ចាស់ សូមលោកម្ចាស់ថែរក្សាឪពុកម្តាយដែលចាស់ជរា ហើយខំធ្វើបុណ្យទាន ដើម្បីបានចម្រើនគុណធម៌សម្រាប់ខ្លួនលោក ។ ចំពោះអំណោយដ៏ថ្លៃថ្លានូវស្រែ ១.០០០ អារនោះ ជាអំណោយដ៏ធំធេងណាស់ ខ្ញុំសូមទទួលយកតែ ៨ អារ ក៏គ្រប់គ្រាន់សម្រាប់ពួកយើងខ្ញុំទាំងឡាយហើយ" ។

កោសិយៈបានជូនពរដល់សត្វសេកថា :

"ចូរអ្នកត្រឡប់ទៅវិញដោយសុវត្ថិភាពចុះ ហើយលួងលោមឪពុកម្តាយអ្នក ដែលកំពុងសោកសៅ ដោយបានបាត់រូបអ្នក" ។

បន្ទាប់មក សត្វសេកក៏លាលោកកោសិយៈ ដោយមេត្រីភាពដ៏ស្មោះសរជាទីបំផុត ថែមទាំងបាននាំយកមកជាមួយនូវកួរស្រូវសាលីមួយចំនួនជាអំណោយរបស់លោកកោសិយៈ ត្រឡប់មកកាន់ព្រៃវិញទៀតផង ។

នៅពេលដែលពួកសត្វសេកទាំងឡាយ កំពុងជួបជុំគ្នាជាមួយនឹងមាតាបិតាចាស់ជរា យំសោកព្រោះការបាត់ស្តេចសេក ។ រំពេចនោះ ស្រាប់តែស្តេចសេកត្រឡប់មកវិញ ដល់ទីកន្លែងដោយសុវត្ថិភាព ។

នៅអវសានកថា ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់បញ្ចប់ព្រះធម៌ទេសនាដូច្នេះថា "**ម្នាលភិក្ខុទាំងឡាយ ការបីបាច់ថែរក្សាមាតាបិតា ជាប្រពៃណីសម្រាប់អ្នកមានបញ្ញា និងមនុស្សល្អទាំងឡាយ**" ។

ព្រះសាស្តាទ្រង់ប្រជុំជាតកថា :

- នាយឆ្មាំចាំស្រែក្នុងរឿងនេះ បានកើតមកជា ឆន្នភិក្ខុ
- សេដ្ឋីកោសិយគោត្ត បានមកជាព្រះអានន្ទត្ថេរ
- មាតាបិតាស្តេចសេកចាស់ជរាទាំងពីរនោះ គឺជាមាតាបិតារបស់តថាគត នាបច្ចុប្បន្នជាតិនេះ
- រីឯស្តេចសេកនោះ ជាតួអង្គតថាគតនេះឯង ៕

**(ចប់សាលិកេទារជាតក)**

## ឧបសម្ពន្ធ

### ក. ធម៌ជំពូកទី ១ : ទសពិធរាជធម៌

ទសពិធរាជធម៌ ជាធម៌សម្រាប់ថ្នាក់ដឹកនាំកំពូលរបស់រដ្ឋ មានជាអាទិ៍ ព្រះរាជា ប្រធានាធិបតី នាយករដ្ឋមន្ត្រី... ដើម្បីយកមកប្រតិបត្តិ ស្របតាមរបបគ្រប់គ្រងរដ្ឋ ទោះជាតាមទំនៀមទម្លាប់ក្តី តាមរដ្ឋធម្មនុញ្ញក្តី ។

ក្នុងនាមជាម្ចាស់ផែនដីមួយរូប, អ្នកដឹកនាំរដ្ឋ ឬអ្នកគ្រប់គ្រងរដ្ឋ មិនថាជាស្តេចចក្រពត្តិ, បទេសរាជ ឬអ្នកដឹកនាំកំពូល ត្រូវមានលក្ខណសម្បត្តិសម្រាប់ដឹកនាំ ដូចពាក្យថា **រាជា** មានន័យថា "អ្នកដែលអនុគ្រោះមហាជនដោយសង្គហធម៌ ៤" ដោយមានបទវិគ្រោះ[៧៥] ជាភាសាបាលីថា :

**ទានញ្ច បិយវចនញ្ច អត្ថចរិយា ច សមានត្តតា ចាតិ ឥមេហិ ចតូហិ សង្គហវត្ថូហិ អត្តនិ មហាជនំ រញ្ជេតីតិ រាជា ។**

ប្រែ: បុគ្គលញុំាងខ្លួនដើម្បីអនុគ្រោះនូវមហាជនដោយសង្គហវត្ថុ ៤ នេះគឺ ទាន បិយវាចា អត្ថចរិយា និង សមានត្តតា ព្រោះហេតុនោះ បុគ្គលនោះ ឈ្មោះថា **រាជា** ។

ព្រះរាជា ឬអ្នកដឹកនាំ ត្រូវប្រតិបត្តិនូវធម៌ ៤ ជំពូក ដូចតទៅ :

---

[៧៥] គម្ពីរសទ្ទនីតិ, គម្ពីរវិនយវិនិច្ឆយដីកា ។

ថ្នាក់ដឹកនាំកំពូលនៃរដ្ឋ ដែលគេតែងឧទ្ទេសនាមថា ព្រះរាជា, ប្រមុខរដ្ឋ, អគ្គមគ្គុទ្ទេសក៍ ត្រូវប្រកបដោយធម៌ទាំងឡាយ ១០ ប្រការ ដែលលោកហៅថា **ទសពិធរាជធម៌** គឺ

**១. ទាន** គឺការលះបង់ទេយ្យវត្ថុ ឬទ្រព្យសម្បត្តិ ដើម្បីប្រយោជន៍ដល់ប្រជានុរាស្ត្រ ។ ស្តេច ឬអ្នកដឹកនាំរូបនោះឯង ជាអ្នកធ្វើនូវឧបការៈ គឺធ្វើគុណប្រយោជន៍ចំពោះអ្វីដែលខ្លួនគ្រប់គ្រង គឺថា ត្រូវធ្វើនូវអ្វីដើម្បីលះបង់ មិនមែនដើម្បីប្រមូលយកកម្រៃចំណេញឡើយ ។ លោកត្រូវឧទ្ទិសខ្លួនចំពោះអ្វីដែលខ្លួនបម្រើការដល់ប្រទេស ហើយក៏ត្រូវផ្តល់ភាពសុកស្គម្ភ និងជំនួយដល់ប្រជាជន ដើម្បីជានានូវការរស់នៅជាសុខស្រួល និងសុវត្ថិភាព ។ អ្នកដឹកនាំនោះឯង ត្រូវជួយសង្គ្រោះអ្នកដែលរងទុក្ខ និងមានសេចក្តីលំបាកក្នុងការរស់នៅ ហើយជួយគាំទ្រអ្នកដែលធ្វើល្អឱ្យរីងរឹតតែល្អជាងមុនថែមទៀត (ដូចមានសេចក្តីចែងទុកក្នុងព្រះត្រៃបិដកលេខ ១៥ ទំព័រ ២០ បានពណ៌នាពី **ស្តេចមហាវិជិតរាជ** ដែលទ្រង់បានផ្តល់ទ្រព្យសម្រាប់ទ្រទ្រង់វិស័យសេដ្ឋកិច្ច និងពាណិជ្ជកម្ម) ។

**២. សីល** គឺការសង្រួមកាយវាចា បានដល់ការសង្រួម ឬរក្សានូវការប្រព្រឹត្តខាងសីលធម៌ (គឺវិន័យប្រចាំជីវិត) ឱ្យប្រពៃ ។ អ្នកដឹកនាំរូបនោះមានការប្រព្រឹត្តឥតខ្ចោះ គឺជៀសវាងការប្រព្រឹត្តខុសផ្លូវកាយ និងវាចា ។ អ្នក

ដឹកនាំនោះត្រូវមានទង្វើល្អ និងត្រូវធ្វើឱ្យមានកិត្តិយសខ្ពង់ខ្ពស់ ហើយត្រូវធ្វើជាគំរូសម្រាប់ប្រជាជន (ប្រព្រឹត្តខ្លួនឱ្យជាទិដ្ឋានុគតិ) ដើម្បីទទួលនូវការគោរពរាប់អានពីសម្នាក់ប្រជាជន និងជៀសវាងពីការមើលងាយដោយប្រការណាមួយ ។

**៣. បរិច្ចាគ** ការលះបង់ គឺធ្វើការដោយមិនគិតពីខ្លួនឯង ពោលគឺត្រូវលះបង់នូវភាពស្រួលស្រណុកផ្ទាល់ខ្លួន សូម្បីតែជីវិតរបស់ខ្លួនក៏ហ៊ានលះបង់ ដើម្បីជាប្រយោជន៍ដល់ប្រជាជន និងដើម្បីសន្តិភាព និងស្ថិរភាពប្រទេសជាតិ ។

**៤- អជ្ជវ** ភាពស្មោះត្រង់ គឺជាការប្រតិបត្តិតួនាទីដោយមានភាពស្មោះត្រង់ ។ អ្នកដឹកនាំនោះ ត្រូវមានភាពស្មោះត្រង់ ហើយត្រូវរក្សាសច្ចធម៌, និងមិនមានមានះ ពោលគឺការលើកតម្កើងខ្លួន ក្នុងការចាត់ចែងការងាររបស់ខ្លួនឡើយ ។ អ្នកដឹកនាំនោះ ជាអ្នកស្មោះស្មគ្រ ទៀងត្រង់ និងមិនដំឡើងមានះរបស់ខ្លួន ដើម្បីគំរាមកំហែងអ្នកក្រោមបង្គាប់ និងប្រជាជនជាដើម ។

**៥. មទ្ទវ** ភាពទន់ភ្លន់ គឺការដាក់ខ្លួនឱ្យសុភាពទន់ភ្លន់ និងការទទួលខុសត្រូវរបស់អ្នកដឹកនាំ ពោលគឺជាអ្នកមិនមានភាពច្រឡោងខាម ។ អ្នកដឹកនាំនោះត្រូវមានភាពជាអភិជន រក្សាកិត្តិនាមដែលផ្អែកទៅលើអាការៈ

ដ៏សុភាពរាបសា ដែលជំរុញឱ្យមានការបូជា (ពលិកម្ម) និងភក្តីភាព តែមិនមានភាពទន់ជ្រាយឡើយ ។

**៦. តប** ការដុតកម្តៅកិលេស គឺច្រានចោលនូវការប្រកាន់ទោស តាមរយៈការប្រព្រឹត្តតឹងរ៉ឹង ។ អ្នកដឹកនាំត្រូវកម្ចាត់បង់នូវកិលេសតណ្ហា និងមិនឱ្យគ្រឿងសៅហ្មងទាំងនោះមកគ្របសង្កត់ចិត្តរបស់ខ្លួន ហើយក៏មិនបណ្តោយកិលេសទាំងនោះ មកបំផ្លាញសេចក្តីសុខខាងផ្លូវចិត្តឡើយ ព្រមទាំងមិនឱ្យក្លាយខ្លួនទៅជាអ្នកប្រព្រឹត្តអបាយមុខទៀតផង ។ អ្នកដឹកនាំនោះជាមនុស្សសាមញ្ញធម្មតាក្នុងមាគ៌ាជីវិត និងបូជាខ្លួនដើម្បីការបំពេញតួនាទី ។

**៧. អក្កោធ** មិនខឹងក្រោធ គឺការទទួលដឹងនូវហេតុផល ដោយមិនមានសេចក្តីក្រោធ ។ អ្នកដឹកនាំ មិនត្រូវបញ្ចេញកំហឹងចេញមកក្រៅទាំងកំរោល, មិនត្រូវវិនិច្ឆ័យអ្វីទាំងកំហឹងឡើយ ហើយត្រូវមានចិត្តធូន់ និងសង្កត់កំហឹងនោះមិនឱ្យចេញមកខាងក្រៅ ។ លោកមិនសម្រេចចិត្តណាមួយ នៅពេលមានកំហឹងក្នុងខ្លួនលោកនោះទេ ។ លោកតែងប្រព្រឹត្តឱ្យសុក្រឹតត្រឹមត្រូវក្នុងចិត្ត ដែលមានភាពល្អិតល្អន់ និងត្រជាក់ជានិច្ច ។

**៨. អវិហឹសា** ការមិនបៀតបៀន បានដល់ការធ្វើឱ្យមានស្ថិរភាពតាមបែបអហិង្សា ។ លោកមិនបានវង្វេងនឹងអំណាច ឬក៏ប្រើប្រាស់អំណាចដើម្បីសង្កត់សង្កិនអ្នកក្រោមបង្គាប់ឡើយ ។ លោកជាអ្នកមានសន្តានចិត្តល្អ

មិនស្វែងរកកំហុសដើម្បីចោទប្រកាន់អ្នកក្រោមបង្គាប់ ព្រោះការសងសឹក ឬសេចក្តីមិនពេញចិត្តដោយប្រការណាមួយឡើយ ។

**៩. ខន្តី** សេចក្តីអត់ធន់ បានដល់ការយកឈ្នះឧបសគ្គដោយភាពអំណត់ ។ លោកមានភាពអំណត់ចំពោះកិច្ចការលំបាក ហើយតស៊ូរាល់ភារកិច្ច ដោយមិនគិតពីភាពនឿយហត់ មិនថាកិច្ចការនោះ លំបាក ឬស្មុគស្មាញយ៉ាងណាក្តី ។ លោកមិនបានចុះចាញ់ ឬចុះញ៉មនឹងអំពើអាក្រក់ដែលគេប្រព្រឹត្តចំពោះខ្លួន មិនថាជារឿងចំអក ដោយពាក្យអសុរោះ ឬពាក្យគួរឱ្យធុញទ្រាន់យ៉ាងណាក្តី ។ លោកមិនអាក់អន់ចិត្ត ហើយក៏មិនបានបោះបង់ចោលនូវភារកិច្ចដ៏ត្រឹមត្រូវ ដែលលោកគួរធ្វើ ឬបំពេញឡើយ ។

**១០. អវិរោធន** ការមិនធ្វើអ្វីដែលប្រាសចាកពីសច្ចធម៌ ។ លោកមិនបំពាននូវច្បាប់ ។ រាល់សកម្មភាពដឹកនាំរដ្ឋ លោកតែងតែគោរពគោលការណ៍នៃការគ្រប់គ្រងរដ្ឋ ដោយផ្អែកលើសុខុមាលភាព និងឧត្តមប្រយោជន៍របស់ប្រជាពលរដ្ឋ និងជាតិមាតុភូមិជាធំ ។ លោកបានតម្កល់ខ្លួនដោយប្រពៃក្នុងគោលការណ៍ត្រឹមត្រូវ និងមិនបានងាកចេញ ឬបង្វែរចេញពីភាពយុត្តិធម៌, ភាពត្រឹមត្រូវ, ភាពជាផ្លូវការ និងគោលការណ៍នៃការគ្រប់គ្រង រួមបញ្ចូលទាំងទំនៀមទម្លាប់ និងប្រពៃណីដែលល្អ ។ លោកមិនជំទាស់នឹងបំណងស្របច្បាប់សមហេតុផលរបស់ប្រជាពលរដ្ឋឡើយ ។ លោកមិនរារាំង

នូវសកម្មភាពទាំងឡាយណា ដែលជាសេចក្ដីល្អ និងតម្រូវការសាធារណៈ ទេ ។ លោកមានជំហររឹងមាំក្នុងភាពត្រឹមត្រូវ, សច្ចធម៌ មិនញាប់ញ័រនឹង ពាក្យពីរោះ, អសុរោះ, ការបានលាភ ឬការមិនបានលាភ, ការចូលចិត្ត និង ការមិនចូលចិត្ត, សេចក្ដីគាប់ចិត្ត និងសេចក្ដីមិនគាប់ចិត្ត គឺលោកតាំងចិត្ត ជាឧបេក្ខា ក្នុងការបំពេញតួនាទីដ៏ឧត្ដុង្គឧត្ដមនេះ ។

គួរកត់សម្គាល់ថា ក្នុងទសពិធរាជធម៌នេះ មានធម៌ខ្លះមានលក្ខណៈ ដូចគ្នានឹងបារមី ដែលជាពុទ្ធការកធម៌ដែរ ដូចជា ទាន សីល ខន្តី ជាដើម ។ ព្រះរាជា ទ្រង់បានប្រារព្ធធម៌នេះ ក្នុងតួនាទីរបស់ព្រះអង្គ រីឯព្រះពោធិសត្វ ព្រះអង្គប្រតិបត្តិធម៌នេះ ដោយឆន្ទៈរបស់ព្រះអង្គ ដើម្បីត្រាស់ដឹងនូវសម្មា-សម្ពោធិញ្ញាណ ៕

## ខ. ធម៌ជំពូកទី ២ : ការបំពេញនូវភារកិច្ចរបស់ស្ដេចចក្រពត្តិ

អគ្គមគ្គុទ្ទេសក៍រដ្ឋ ឬប្រមុខរដ្ឋ មានកាតព្វកិច្ចបំពេញតួនាទី៥ ប្រការ របស់ស្ដេចចក្រពត្តិ ដូចខាងក្រោម :

**១. ធម្មាធិបតេយ្យ** ការកាន់យកធម៌ជាធំ គឺថាលោកប្រកាន់នូវ សច្ចធម៌, ភាពត្រឹមត្រូវ, សេចក្ដីល្អ, ហេតុផល, គោលការណ៍ និងច្បាប់ត្រឹម

ត្រូវ ។ លោកគោរពលើកតម្កើងរក្សាខ្លួន និងតាំងខ្លួន នៅក្នុងសច្ចភាព និង ប្រតិបត្តិតាមគោលការណ៍ទាំងនោះ ។

**២. ធម្មិការក្ខា** ការរក្សាដែលប្រកបដោយធម៌ គឺជាផ្តល់ការ ការពារយ៉ាងត្រឹមត្រូវ ។ លោកផ្តល់ការការពារប្រកបដោយយុត្តិធម៌ ដល់ មនុស្សទាំងអស់នៅលើផែនដី ពោលគឺ មន្ត្រីរាជការ, កងទ័ព, នគរបាល, មន្ត្រីបម្រើការតាមមូលដ្ឋាន, សិស្ស, និស្សិត, បញ្ញវន្ត, អាជីវករ, កម្មករ, កសិករ ព្រមទាំងមនុស្សទូទៅគ្រប់ស្រទាប់វណ្ណៈ ទាំងអ្នករស់នៅតាមជាយ ដែន, ព្រះសង្ឃ និងអ្នកកាន់សាសនាផ្សេងៗ ដែលប្រកាន់នូវសីលធម៌ និង ចរិយាធម៌ ដោយហោចទៅ សូម្បីតែសត្វសត្វ និងបក្សាបក្សី ក៏ត្រូវការអភិ- រក្ស គឺការអភ័យឱ្យមានជីវិតរស់នៅដោយសុខសាន្ត ។

**៣. មា អធម្មការ** ហាមឃាត់នូវរាល់ទង្វើ ដែលប្រាសចាកពីគន្លង ធម៌ ។ លោករៀបចំវិធានការការពារ និងកែខៃ មិនអនុញ្ញាតឱ្យមាននូវទង្វើ អយុត្តិធម៌, ការកេងប្រវ័ញ្ច, ការគាបសង្កត់, អំពើពុករលួយ ឬក៏ភាព ចលាចលកើតឡើងនៅក្នុងប្រទេសជាដើម ។ លោកជំរុញមនុស្សទាំងអស់ ឱ្យតម្កល់ខ្លួននៅក្នុងភាពស្មោះត្រង់ និងគុណធម៌ ហើយនិងបង្កើតនូវប្រព័ន្ធ វិធីសាស្ត្រកាត់បន្ថយមនុស្សអាក្រក់ និងបណ្តុះបណ្តាលមនុស្សឱ្យល្អ កាន់តែច្រើនឡើង ។

**៤. ធនានុប្បទាន** ចែកចាយធនធានដល់អ្នកក្រីក្រ ។ លោកធានាថា មិនឱ្យមានភាពអត់ឃ្លាននៅក្នុងដែនដីរបស់លោក ដូចជា មានការរៀបចំឱ្យមនុស្សគ្រប់គ្នា មានឱកាសប្រកបរបរចិញ្ចឹមជីវិត ដោយភាពសុចរិតទៀងត្រង់ និងត្រឹមត្រូវ ។

**៥. បរិបុច្ឆា** បទេសរាជ, ប្រមុខរដ្ឋតែងតែសាកសួរញយៗ សុំយោបល់ពីអ្នកប្រាជ្ញបណ្ឌិត ។ លោកមិនបានលះបង់ចោលនូវកិច្ចពិភាក្សាឡើយ ។ លោកស្វែងរកនូវឧត្តមភាពក្នុងប្រាជ្ញា និងគុណធម៌ ដោយមានទីប្រឹក្សាជាអ្នកចេះដឹងច្រើន និងមានគុណធម៌ខ្ពស់ និងចរិយាធម៌ ជាអ្នកដែលលើកតម្កើងនូវសីលធម៌ មិនមានសេចក្តីប្រមាទ ឬវង្វេងភ្លេចខ្លួននឹងយសសក្តិ ជាមនុស្សដែលអាចជួយឱ្យចម្រើននូវបញ្ញា និងកុសលធម៌ទាំងឡាយ ។ លោកចូលទៅរកព្រះសង្ឃ និងពហុស្សូត ហើយសន្ទនាសាកសួរដើម្បីស្វែងរកចំណេះវិជ្ជា សេចក្តីល្អ និងសច្ចធម៌ ។ លោកពិភាក្សាបញ្ហាផ្សេងៗ នៅក្នុងពេលដ៏សមគួរ និងទៀងទាត់ ដើម្បីលោកអាចតាមដាន និងអភិវឌ្ឍខ្លួនលោកបាន ហើយនិងអនុវត្តនូវគោលការណ៍ដ៏ល្អ ក្នុងការស្វែងរកសេចក្តីសុខក្សេមក្សាន្ត និងការរីកចម្រើនដោយពិតប្រាកដ ៕

## គ. ធម៌ជំពូកទី ៣ : ការអនុវត្តនូវសង្គហធម៌របស់អ្នកដឹកនាំ

*អគ្គមគ្គុទ្ទេសក៏ តែងទំនុកបម្រុងពលរដ្ឋរបស់លោក ឱ្យរស់នៅក្នុងសាមគ្គីភាព ដោយរាជសង្គហធម៌ ៤ យ៉ាង ដែលយើងបច្ចុប្បន្ននេះ ហៅថា* "***ឯកភាពជាតិ***" មានដូចខាងក្រោម :

**១. សស្សមេធ** *កិរិយាយល់ដឹងក្នុងការអភិវឌ្ឍនូវសេដ្ឋកិច្ច និងមុខជំនួញផ្សេងៗ ។ លោកជាអ្នកឈ្វេងយល់ និងមានសុភវិនិច្ឆ័យ ក្នុងការផ្សព្វផ្សាយពាណិជ្ជកម្ម កសិកម្ម ដែលអាចផ្តល់ផលយ៉ាងច្រើន សម្រាប់ពលរដ្ឋភាគច្រើន ។*

**២. បុរិសមេធ** *លោកជាអ្នកដឹកនាំប្រកបដោយសេចក្តីឈ្លាសវៃស្គាល់លក្ខណៈ និងសមត្ថភាពមន្ត្រីរាជការដែលបម្រើរដ្ឋ ។ លោកបានប្រគល់តួនាទី និងការទទួលខុសត្រូវ ឱ្យសមតាមសមត្ថភាពរបស់មន្ត្រីទាំងនោះ ។ លោកបង្កើតគោលនយោបាយគាំទ្រ ពង្រឹងសមត្ថភាព និងលើកទឹកចិត្តដល់មន្ត្រីស្មោះត្រង់ និងត្រឹមត្រូវ ក្នុងការបម្រើប្រទេសជាតិ ។*

**៣. សម្មាបស** *ការបង្រួបបង្រួមប្រជានុរាស្ត្រដោយប្រពៃ ដល់ការចងសម្ពន្ធភាពរវាងពលរដ្ឋទាំងអស់ ។ លោកជួយមនុស្សទាំងឡាយដោយនយោបាយដែលអាចឱ្យមានលទ្ធភាពចិញ្ចឹមជីវិត ដូចជាផ្តល់ឱកាសសម្រាប់*

អ្នកក្រីក្រខ្វះ ដើម្បីប្រកបអាជីវកម្មផ្សេងៗ ដើម្បីពង្រឹងសេដ្ឋកិច្ច និងហិរញ្ញវត្ថុគ្រួសារ ដែលអាចលើកកម្ពស់ជីវភាពគ្រួសារ ។

**៤. វាចាមេយ្យ** សម្ដីជាទីស្រឡាញ់, លោកស្គាល់របៀបនៃការនិយាយបកស្រាយ និងការណែនាំ ។ លោកចាប់អារម្មណ៍ក្នុងការស្វាគមន៍មនុស្សគ្រប់ឋានៈ ហើយចង់ដឹងអំពីសុខុមាលភាពរបស់មនុស្សទូទៅ មានសម្ដីពីរោះគួរឱ្យចង់ស្ដាប់ គឺពោរពេញដោយខ្លឹមសារ និងមានហេតុផលព្រមទាំងមានអត្ថប្រយោជន៍ ។ សម្ដីទាំងនោះ អាចនាំទៅរកភាពរីកចម្រើន, ការដោះស្រាយនូវបញ្ហា, បង្កើតសាមគ្គីភាពយ៉ាងស្អិតល្មួត យល់គ្នាទៅវិញទៅមក, ពង្រឹងការទុកចិត្ត និងការគោរពស្រឡាញ់គ្នាក្នុងសង្គម ៕

## ឃ. ធម៌ជំពូកទី ៤ : រាជសង្គហវត្ថុ ៤ របស់អ្នកដឹកនាំ

**១. ទាន** ការបំពេញទាន ដែលខ្លួនអាចធ្វើដោយបូជាទានក្ដី ដោយសង្គហទានក្ដី ។

**២. បិយវាចា** វាចាជាទីស្រឡាញ់ មានពាក្យសម្ដីគួរជាទីចូលចិត្តជាទីគាប់ចិត្ត ផ្អែមល្ហែម មិនពោលពាក្យគ្រោតគ្រាតអសុរោះ ។

**៣. អត្ថចរិយា** ការប្រព្រឹត្តជាប្រយោជន៍ក្នុងសង្គមជាធំ, ជាអ្នកមិនគិតតែប្រយោជន៍ផ្ទាល់ខ្លួន ។

**៤. សមានត្តតា** ភាពនៃបុគ្គលមានខ្លួនប្រព្រឹត្តស្មើ ក្នុងជេដ្ឋាបចាយនធម៌ គឺមានការគោរពស្រឡាញ់ដល់រៀមច្បង ដែលប្រកបដោយវុឌ្ឍិ គឺជាអ្នកចម្រើនដោយសេចក្ដីល្អ ៕

## ខ. ធម៌ជំពូកទី ៥ : ការវៀសវាងអគតិធម៌ ៤

នៅពេលដែលអ្នកដឹកនាំរដ្ឋអនុវត្តនូវភារកិច្ច លោកមិនបណ្ដោយឱ្យមានអគតិធម៌ ឬការប្រាសចាកពីយុត្តិធម៌ ដែលជ្រៀតជ្រែកដោយអគតិ ៤ យ៉ាងគឺ

**១. ឆន្ទាគតិ** លម្អៀងព្រោះប្រយោជន៍ ព្រោះស្រឡាញ់ ចូលចិត្តដោយសារបងប្អូន សាច់ញាតិ មិត្តភក្ដិ ជាដើម ។

**២. ទោសាគតិ** លម្អៀងព្រោះស្អប់ ដោយគំនិតគុំកួន មិនចូលចិត្តនិងរើសអើងជាដើម ។

**៣. មោហាគតិ** លម្អៀងព្រោះល្ងង់ មិនយល់ពីជម្រៅបញ្ហា ។

**៤. ភយាគតិ** លម្អៀងព្រោះភ័យខ្លាចដោយការគោរពសង្កត់ ដោយផលវិបាកដែលអាចធ្លាក់មកលើខ្លួន ។

បុគ្គលម្នាក់ៗ ទោះបីជាមេគ្រួសារក្តី ជានាយដឹកនាំសហគមន៍ដ៏តូចមួយក្តី, ជាអ្នកដឹកនាំថ្នាក់ទាបក្តី អាចព្យាយាមអនុវត្តនូវទសពិធរាជធម៌គ្រប់ៗគ្នា ដើម្បីបណ្តុះ និងបំប៉ននូវគុណធម៌របស់ខ្លួន ៕

## សេចក្តីអធិប្បាយអំពី អសង្ខេយ្យ និង កប្ប

ពុទ្ធសាសនិកជនតែងបានឮពាក្យថា **អសង្ខេយ្យ** និងពាក្យថា **កប្ប** នេះជារឿយៗក្នុងព្រះពុទ្ធសាសនា ។ តែមិនបានប្រាកដជាក់ច្បាស់ថា អ្វីទៅជាអសង្ខេយ្យនោះ និងអ្វីទៅជាកប្បនោះ ។

ពាក្យថា **អសង្ខេយ្យ** មកពីពាក្យ **ន + សង្ខ្យា + ណេយ្យ** ។ មានន័យថា មិនអាចរាប់បន្តទៀតបាន ដូចមានបទវិគ្រោះបញ្ជាក់ថា **សង្ខ្យាតុមសក្កុណេយ្យតាយ អសង្ខេយ្យំ**, សង្ខ្យា ឈ្មោះថា អសង្ខេយ្យ ព្រោះមិនអាចនឹងរាប់ទៀតបាន ។

នៅក្នុងអភិធានប្បទីបិកាបាឋៈ លោកបានពន្យល់ពីរបៀបរាប់ រហូតដល់អសង្ខេយ្យយ៉ាងនេះថា :

សតំ សហស្សំ និយុតំ    លក្ខំ កោដិ បកោដិយោ
កោដិបកោដិ នហុតំ    តថា និន្នហុតម្បិ ច ។
អក្ខោភិនីត្ថិយំ ពិន្ទុ    អព្ពុទញ្ច និរព្ពុទំ
អហហំ អពពំ ចេវា-    ដដំ សោគន្ធិកុប្បលំ ។
កុមុទំ បុណ្ឌរីកញ្ច    បទុមំ កថានម្បិ ច
មហាកថានាសង្ខេយ្យា-    និច្ចេតាសុ សតាតិ ច ។

| | |
|---|---|
| ១០ រយ | ស្មើនឹង ១ ពាន់ |
| ១០ ពាន់ | ស្មើនឹង ១ ម៉ឺន |
| ១០ ម៉ឺន | ស្មើនឹង ១ សែន |
| ១០ សែន | ស្មើនឹង ១ លាន |
| ១០ លាន | ស្មើនឹង ១ កោដិ |
| រយសែនកោដិ | ស្មើនឹង ១ បកោដិ |
| រយសែនបកោដិ | ស្មើនឹង ១ កោដិបកោដិ |
| រយសែនកោដិបកោដិ | ស្មើនឹង ១ នហុត |
| រយសែននហុត | ស្មើនឹង ១ និន្នហុត |

| | |
|---|---|
| រយសែននិន្នហុត | ស្មើនឹង ១ អក្ខោភិនី |
| រយសែនអក្ខោភិនី | ស្មើនឹង ១ ពិន្ទុ |
| រយសែនពិន្ទុ | ស្មើនឹង ១ អព្វុទៈ |
| រយសែនអព្វុទៈ | ស្មើនឹង ១ និរព្វុទៈ |
| រយសែននិរព្វុទៈ | ស្មើនឹង ១ អហហៈ |
| រយសែនអហហៈ | ស្មើនឹង ១ អពពៈ |
| រយសែនអពពៈ | ស្មើនឹង ១ អដដៈ |
| រយសែនអដដៈ | ស្មើនឹង ១ សោគន្ធិកៈ |
| រយសែនសោគន្ធិកៈ | ស្មើនឹង ១ ឧប្បលៈ |
| រយសែនឧប្បលៈ | ស្មើនឹង ១ កុមុទៈ |
| រយសែនកុមុទៈ | ស្មើនឹង ១ បុណ្ឌរិកៈ |
| រយសែនបុណ្ឌរិកៈ | ស្មើនឹង ១ បទុមៈ |
| រយសែនបទុមៈ | ស្មើនឹង ១ កថានៈ |
| រយសែនកថានៈ | ស្មើនឹង ១ មហាកថានៈ |
| រយសែនមហាកថានៈ | ស្មើនឹង ១ អសង្ខេយ្យ ។ |

# តារាងរាប់គណិតសង្ខ្យា

| សង្ខ្យាគោល | គុណដោយ | ជា | លេខ | ចំនួនសូន្យ | រូបមន្តគណិត |
|---|---|---|---|---|---|
| ទស (ដប់) | ទស (ដប់) | សតំ (មួយរយ) | ១ | ២ | $១០^{២}$ |
| សតំ (១០០) | ទស (ដប់) | សហស្សំ (មួយពាន់) | ១ | ៣ | $១០^{៣}$ |
| សហស្សំ | ទស (ដប់) | ទសសហស្សំ (មួយម៉ឺន) | ១ | ៤ | $១០^{៤}$ |
| ទសសហស្សំ | ទស (ដប់) | សតសហស្សំ, លក្ខំ (មួយសែន) | ១ | ៥ | $១០^{៥}$ |
| សតសហស្សំ | ទស (ដប់) | ទសសតសហស្សំ (មួយលាន) | ១ | ៦ | $១០^{៦}$ |
| ទសសតសហស្សំ | ទស (ដប់) | កោដិ (១០លាន) | ១ | ៧ | $១០^{៧}$ |
| កោដិ | កោដិ(១០លាន) | បកោដិ | ១ | ១៤ | $១០^{១៤}$ |
| បកោដិ | កោដិ(១០លាន) | កោដិបកោដិ | ១ | ២១ | $១០^{២១}$ |
| កោដិបកោដិ | កោដិ(១០លាន) | នហុតំ | ១ | ២៨ | $១០^{២៨}$ |
| នហុតំ | កោដិ(១០លាន) | និន្នហុតំ | ១ | ៣៥ | $១០^{៣៥}$ |
| និន្នហុតំ | កោដិ(១០លាន) | អក្ខោភិនី | ១ | ៤២ | $១០^{៤២}$ |

| | | | | | |
|---|---|---|---|---|---|
| អក្ខោភិនី | កោដិ(១០លាន) | ពិន្ទុ | ១ | ៤៩ | $១០^{៤៩}$ |
| ពិន្ទុ | កោដិ(១០លាន) | អព្វុទំ | ១ | ៥៦ | $១០^{៥៦}$ |
| អព្វុទំ | កោដិ(១០លាន) | និរព្វុទំ | ១ | ៦៣ | $១០^{៦៣}$ |
| និរព្វុទំ | កោដិ(១០លាន) | អហហំ | ១ | ៧០ | $១០^{៧០}$ |
| អហហំ | កោដិ(១០លាន) | អពពំ | ១ | ៧៧ | $១០^{៧៧}$ |
| អពពំ | កោដិ(១០លាន) | អដដំ | ១ | ៨៤ | $១០^{៨៤}$ |
| អដដំ | កោដិ(១០លាន) | សោគន្ធិកំ | ១ | ៩១ | $១០^{៩១}$ |
| សោគន្ធិកំ | កោដិ(១០លាន) | ឧប្បលំ | ១ | ៩៨ | $១០^{៩៨}$ |
| ឧប្បលំ | កោដិ(១០លាន) | កុមុទំ | ១ | ១០៥ | $១០^{១០៥}$ |
| កុមុទំ | កោដិ(១០លាន) | បុណ្ឌរិកំ | ១ | ១១២ | $១០^{១១២}$ |
| បុណ្ឌរិកំ | កោដិ(១០លាន) | បទុមំ | ១ | ១១៩ | $១០^{១១៩}$ |
| បទុមំ | កោដិ(១០លាន) | កថានំ | ១ | ១២៦ | $១០^{១២៦}$ |
| កថានំ | កោដិ(១០លាន) | មហាកថានំ | ១ | ១៣៣ | $១០^{១៣៣}$ |
| មហាកថានំ | កោដិ(១០លាន) | អសង្ខេយ្យំ | ១ | ១៤០ | $១០^{១៤០}$ |

តាមនៅក្នុងគម្ពីរអភិធានប្បទីបិកា បានបញ្ជាក់ថា ១ អសង្ខេយ្យ គឺសរសេរលេខ ១ ហើយថែមសូន្យឱ្យបាន ១៤០ សូន្យទៀត ។

## កប្បមាន ៤ យ៉ាងគឺ

១. អាយុកប្ប

២. អន្តរកប្ប

៣. អសង្ខេយ្យកប្ប

៤. មហាកប្ប

**១. អាយុកប្ប** សម័យណាដែលមនុស្សមានអាយុឡើងដល់ ១ អសង្ខេយ្យឆ្នាំ ឬថយចុះមករហូតដល់ ១០ ឆ្នាំ ជាអាយុក្ខ័យ កាន់យកតាមកេណ្ឌអាយុរបស់មនុស្សក្នុងសម័យនោះ ហៅថា អាយុកប្ប ។ ដូចក្នុងសម័យពុទ្ធកាល អាយុក្ខ័យរបស់មនុស្សមានចំនួន ១០០ ឆ្នាំ រាប់ថា ១០០ ឆ្នាំ ជាអាយុកប្ប ។ ក្នុងបច្ចុប្បន្នកាលនេះ អាយុក្ខ័យរបស់មនុស្សមាន ៧៥ ឆ្នាំ បាត់ថា អាយុ ៧៥ ឆ្នាំនេះ ជាអាយុកប្ប ។

**២. អន្តរកប្ប** ពិធីរាប់អន្តរកប្បដូច្នេះគឺ ក្នុងសម័យដើមកប្ប មនុស្សមានអាយុវែងរហូត ១ អសង្ខេយ្យឆ្នាំ ជាអាយុកប្ប រហូតថយចុះមកដល់ ១០ ឆ្នាំ ហើយក៏ឡើងទៅវិញរហូត ១ អសង្ខេយ្យឆ្នាំទៀត រួចហើយក៏បានថយចុះមកដល់ ១០ ឆ្នាំវិញ ហើយឡើងពី ១០ ឆ្នាំ ទៅដល់ ១ អសង្ខេយ្យ ១ គូនេះ ហៅថា **១ អន្តរកប្ប** ។

**៣. អសង្ខេយ្យកប្ប** ចំនួនអន្តរកប្បដូចបានពោលមកហើយ កាលគ្រប់ ៦៤ អន្តរកប្ប រាប់ជា ១ អសង្ខេយ្យកប្ប ។

អាចារ្យខ្លះពោលថា ២០ អន្តរកប្ប ជា ១ អសង្ខេយ្យកប្ប, អាចារ្យខ្លះទៀតពោលថា ៨០ អន្តរកប្ប ជា ១ អសង្ខេយ្យកប្ប, អាចារ្យហោរាសាស្ត្របុរាណថា ១៤ អន្តរកប្ប ជា ១ អសង្ខេយ្យ ។ អសង្ខេយ្យកប្បមាន ៤ យ៉ាង[៧៦] គឺ

១- សំវដ្តអសង្ខេយ្យកប្ប

២- សំវដ្តដ្ឋាយីអសង្ខេយ្យ

៣- វិវដ្តអសង្ខេយ្យ

៤- វិវដ្តដ្ឋាយីអសង្ខេយ្យ ។

**១. សំវដ្តអសង្ខេយ្យកប្ប** ខណៈដែលចក្រវាលមានចំនួន ១ សែនកោដិចក្រវាលកំពុងវិនាស ហៅថា **សំវដ្តអសង្ខេយ្យកប្ប** មានវចនត្ថៈ[៧៧]ថា **សំវដ្តធំ វិនស្សធំ សំវដ្តោ** កប្បកំពុងវិនាសឈ្មោះថា **សំវដ្តៈ** ។

**២. សំវដ្តដ្ឋាយីអសង្ខេយ្យ** ចក្រវាលដែលត្រូវវិនាសអស់ ដោយមិន

[៧៦] វិសុទ្ធិមគ្គបាលី ២/៨៣១, បរមត្ថទីបនី អដ្ឋកថា ឥតិវុត្តកៈ តេវិជ្ជសូត្រ ។

[៧៧] សារត្ថមញ្ជូសា អង្គុត្តរអភិនវដីកា កប្បសុត្តាទិវណ្ណនា ។

មានអ្វីសេសសល់ មានតែភាពទទេ ហៅថា **សំវដ្តដ្ឋាយីអសង្ខេយ្យ** មានវចនត្ថៈថា **សំវដ្តតោ ឧទ្ធំ តថា ឋាយី សំវដ្តដ្ឋាយី** "ចក្រវាលដែលវិនាសទៅហើយ មានតែភាពវិនាសតាំងនៅ ហៅថា **សំវដ្តដ្ឋាយី**" ។

៣. **វិវដ្តអសង្ខេយ្យ** កាលចក្រវាលត្រូវវិនាសអស់រលីង ហើយក៏ផ្តើមមកកើតឡើងថ្មី ហៅថា **វិវដ្តអសង្ខេយ្យ** មានវចនត្ថៈថា **វិវដ្តនំ និព្វត្តនំ វឌ្ឍនំ វា វិវដ្តោ** កប្បដែលកើតឡើង ឬចម្រើនកើតឡើងតាមលំដាប់ ហៅថា **វិវដ្តៈ** ។

៤. **វិវដ្តដ្ឋាយីអសង្ខេយ្យ** ចក្រវាលដែលផ្តើមឡើងសាជាថ្មីនោះ បានតាំងនៅជាប្រក្រតី សែនកោដិចក្រវាល ផែនដី ភ្នំ ដើមឈើ មហាសមុទ្រ ស្ទឹង ព្រះអាទិត្យ ព្រះចន្ទ តារាផ្សេងៗ មនុស្ស សត្វ ក៏មានប្រាកដគ្រប់យ៉ាង ហៅថា វិវដ្តដ្ឋាយីអសង្ខេយ្យ មានវចនត្ថៈថា **វិវដ្តោ ហុត្វា តិដ្ឋតីតិ វិវដ្តដ្ឋាយី** "កប្បដែលចម្រើនឡើងព្រមហើយ ដោយស្ថានផ្សេងៗ និងតាំងនៅជាប្រក្រតី ហៅថា **វិវដ្តដ្ឋាយី**" ។

ការរាប់ឱ្យគ្រប់ទាំង ៤ អសង្ខេយ្យកប្ប ដូចពោលមកនេះឯង ស្មើនឹង ១ **មហាកប្ប** ។

កប្បមានពីរប្រភេទ[៧៨]គឺ សុញ្ញកប្ប ១ អសុញ្ញកប្ប ១ ។ រីឯសុញ្ញ-កប្ប មាន ៤ យ៉ាងគឺ

១. **សុញ្ញមហាកប្ប** បានដល់ មហាកប្បដែលមិនមានព្រះពុទ្ធត្រាស់ដឹង ។

២. **សុញ្ញអសង្ខេយ្យ** បានដល់ សំវដ្តអសង្ខេយ្យកប្ប សំវដ្តដ្ឋាយីអសង្ខេយ្យ វិវដ្តអសង្ខេយ្យ ។

៣. **សុញ្ញអន្តរកប្ប** បានដល់ អន្តរកប្បដែលមិនមានព្រះពុទ្ធត្រាស់ដឹង ។

៤. **សុញ្ញអាយុកប្ប** បានដល់ ក្នុងរវាងមនុស្សមានអាយុវែង ច្រើនជាងមួយសែនឆ្នាំឡើងទៅ និងតិចជាងមួយរយឆ្នាំចុះមក ។

តើសុញ្ញកប្ប សំដៅដល់កប្បយ៉ាងណាដែរ?

ក្នុងអដ្ឋកថាបានបញ្ជាក់ច្បាស់ថា :

**តត្ថ សុញ្ញកប្បេ ពុទ្ធបច្ចេកពុទ្ធចក្កវត្តិនោ ន ឧប្បជ្ជន្តិ ។**

ប្រែ : ដែលឈ្មោះថា **សុញ្ញកប្ប** សំដៅដល់ កប្ប ដែលមិនមានព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ និងស្តេចចក្រពត្តិ កើតក្នុងកប្បនោះ ។

[៧៨] ក្នុងអដ្ឋកថាពុទ្ធវំស វិសុទ្ធជនវិលាសិនី ។

ចំណែក**អសុញ្ញកប្ប** មានន័យថា កប្បដែលមិនសូន្យចាកបុគ្គលសម្បូរដោយគុណធម៌ មានព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ និងស្តេចចក្រពត្តិ តែងកើតក្នុងកប្បនោះ ។

**អសុញ្ញកប្បនេះ** មាន ៥ យ៉ាងគឺ **សារកប្ប១ មណ្ឌកប្ប១ វរកប្ប១ សារមណ្ឌកប្ប១ ភទ្ទកប្ប១** ។

សមដូចបរមត្ថទីបនីអដ្ឋកថាក្នុងអបទានបានបញ្ជាក់ថា :

**សារកប្បោ មណ្ឌកប្បោ សារមណ្ឌកប្បោ តថា**

**វរកប្បោ ភទ្ទកប្បោ កប្បា បញ្ចវិធា សិយុំ ។**

ប្រែ : កប្បមាន ៥ យ៉ាងគឺ សារកប្ប១ មណ្ឌកប្ប១ វរកប្ប១ សារមណ្ឌកប្ប១ ភទ្ទកប្ប១ ។

និងសមដូចបោរាណាចារ្យប្រព័ន្ធជាគាថាដូច្នេះថា :

**ឯកោ ពុទ្ធោ សារកប្បេ មណ្ឌកប្បេ ជិនា ទុវេ**

**វរកប្បេ តយោ ពុទ្ធា សារមណ្ឌេ ចតុរោ ពុទ្ធា**

**បញ្ច ពុទ្ធា ភទ្ទកប្បេ តតោ ឧត្តាជិកា ជិនា ។**

ប្រែ : ក្នុង**សារកប្ប** មានព្រះពុទ្ធ ១ អង្គកើតឡើង

ក្នុង**មណ្ឌកប្ប** មានព្រះពុទ្ធ ២ អង្គកើតឡើង

ក្នុង**វរកប្ប** មានព្រះពុទ្ធ ៣ អង្គកើតឡើង

ក្នុង**សារមណ្ឌកប្ប** មានព្រះពុទ្ធ ៤ អង្គកើតឡើង

ក្នុង**ភទ្ទកប្ប** មានព្រះពុទ្ធ ៥ អង្គកើតឡើង

ហើយក្នុងកប្បដែលមានព្រះពុទ្ធលើសពីចំនួន ៥ អង្គនោះ មិនមានឡើយ ។

នៅក្នុងអដ្ឋកថាអនាគតវង្សបានចែងថា :

**ន ហិ ឯកស្មិំ កប្បេ ឆដ្ឋោ វា សត្តមោ វា ឧប្បជ្ជតិ ។**

ប្រែ : ពិតណាស់ ព្រះពុទ្ធត្រាស់ដឹងក្នុងកប្បមួយ (យ៉ាងច្រើនមានត្រឹម ៥ អង្គប៉ុណ្ណោះ) ពុំមានដល់ ៦ ឬ ៧ អង្គនោះឡើយ ។

## បទសិក្សាពិចារណា

***អនាគតវង្ស***[៧៩] *កើតឡើងក្នុងសម័យខាងក្រោយ បានពោលអះអាងយ៉ាងដាច់ខាតថា បន្ទាប់ពីភទ្ទកប្បនេះទៅ សុញ្ញកប្ប មានរហូតដល់ទៅ ១ អសង្ខេយ្យកប្ប ដូចមានពាក្យបាលីថា :*

**ភទ្ទកប្បេ អតិក្កន្តេ សុញ្ញកប្បោ ឯកោ អសង្ខេយ្យា ឧបជាតិ ។**

*ប្រែ : កាលភទ្ទកប្បកន្លងទៅ* ***សុញ្ញកប្ប*** *នឹងកើតឡើង រហូតដល់ទៅ ១ អសង្ខេយ្យទៀត ។*

*កាលប្រើសព្ទភាសាបាលីថា* ***សុញ្ញកប្ប*** *មានរហូតដល់ទៅ ១ អសង្ខេយ្យយ៉ាងនេះ ជាការជំទាស់នូវព្រះពុទ្ធដីកា និងអដ្ឋកថា ដីកា ដោយពិតប្រាកដ ។ ព្រោះព្រះពុទ្ធដីកា អដ្ឋកថា និងដីកា បានសម្តែងយ៉ាងជាក់ច្បាស់ថា មានអសុញ្ញកប្ប បន្ទាប់ពីភទ្ទកប្បនេះទៅ ។*

*យើងត្រូវសិក្សាមើលពាក្យថា* ***សុញ្ញកប្ប*** *តើមានអត្ថន័យយ៉ាងណា?*

***សុញ្ញកប្ប*** *មានន័យថា កប្បដែលមិនមានព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ ស្តេចចក្រពត្តិកើតឡើង ព្រោះជាកប្បដែលសូន្យចាកបុគ្គលអ្នកមានគុណ*

---

[៧៩] *អនាគតវង្សភាសាបាលី ទំព័រ ២៩ ។*

*វិសេស ។ សមដូចមធុរត្ថវិលាសិនី អដ្ឋកថា ពុទ្ធវំស បញ្ជាក់ច្បាស់ថា :*

**តត្ថ សុញ្ញកប្បេ ពុទ្ធបច្ចេកពុទ្ធចក្កវត្តិនោ ន ឧប្បជ្ជន្តិ ។**

*ប្រែ : ព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ ស្តេចចក្រពត្តិ នឹងមិនកើតឡើងក្នុងសុញ្ញ-កប្បឡើយ ។*

*នៅក្នុងអដ្ឋកថា និងដីកា មានបញ្ជាក់ថា បន្ទាប់ពីកប្បនេះទៅ មានព្រះបច្ចេកពុទ្ធបានសម្រេចជាបច្ចេកពោធិញ្ញាណពិតប្រាកដ ។ បើមានព្រះបច្ចេកពុទ្ធពិតមែន បន្ទាប់ពីកប្បនេះទៅនោះ ដូច្នេះសឱ្យឃើញថា កប្បនោះ គឺជា* ***អសុញ្ញកប្ប ។ ធម្មនិយាម ព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ ស្តេចចក្រពត្តិ មិនមានសោះឡើយ ក្នុងសុញ្ញកប្ប*** *។ នៅក្នុងអដ្ឋកថាធម្មបទ យមកវគ្គ ទេវទត្តវត្ថុអដ្ឋកថា បានបញ្ជាក់ថា :*

**សោ ហិ ឥតោ សតសហស្សកប្បមត្ថកេ អដ្ឋិស្សរោ នាម បច្ចេកពុទ្ធោ ភវិស្សតិ ។**

*ប្រែ : ពិតណាស់ ភិក្ខុទេវទត្តនោះ នឹងបានជាព្រះបច្ចេកពុទ្ធ ព្រះនាម* ***អដ្ឋិស្សរៈ*** *ក្នុងទីបំផុតនៃមួយសែនកប្ប អំពីភទ្ទកប្បនេះទៅ ។*

*នៅក្នុងមិលិន្ទបញ្ហាបានបញ្ជាក់ថា :*

**តតោ មុច្ចិត្វា អដ្ឋិស្សរោ នាម បច្ចេកពុទ្ធោ ភវិស្សតីតិ ។**

តតោ និរយតោ មុច្ចិត្វា ឥតោ បរស្ស អាពេហនកប្បស្ស អាទិម្ហិយេវ ឧសវសអាយុកប្បតោ វស្សសតសហស្សេ អាយុកប្បមត្ថកោ អដ្ឋិស្សរោ ឯាម បច្ចេកពុទ្ធោ ភវិស្សតិ ។

ប្រែ : ត្រង់ពាក្យថា ភិក្ខុទេវទត្ត កាលរួចផុតអំពីនរកនោះហើយ នឹងបានជាព្រះបច្ចេកពុទ្ធព្រះនាម **អដ្ឋិស្សរៈ**, សេចក្តីថា ភិក្ខុទេវទត្តនឹងបានជាព្រះបច្ចេកពុទ្ធព្រះនាមអដ្ឋិស្សរៈ ក្នុងទីបំផុតអាយុកប្ប ដែលមនុស្សមានអាយុ ១ សែនឆ្នាំ អំពីមនុស្សមានអាយុកប្ប ១០ ឆ្នាំ ក្នុងខាងដើមនៃអាពោហនកប្ប ដទៃអំពីភទ្ទកប្បនេះទៅ ។

***ខ្ញុំសូមបញ្ជាក់ថា*** : ក្នុង ១ កប្ប មាន ២ គឺ **អាពោហនកប្ប** និង **ឱពោហនកប្ប** ចែកចេញជា ៦ ចំណែកយ៉ាងនេះ គឺចាប់តាំងពីមនុស្សមានអាយុ ១០ឆ្នាំ រហូតដល់ ១ អសង្ខេយ្យ ឈ្មោះ**អាពោហនកប្ប** មាន ៣ ចំណែក, ចាប់តាំងពីមនុស្សមានអាយុ ១ អសង្ខេយ្យធ្លាក់ចុះមក ដល់មនុស្សមានអាយុ ១០ ឆ្នាំ ឈ្មោះថា **ឱពោហនកប្ប** មាន ៣ ចំណែក ។ ភិក្ខុទេវទត្តនឹងបានជាព្រះបច្ចេកពុទ្ធ បន្ទាប់ពីភទ្ទកប្បនេះទៅ ១ សែនកប្ប ។

ក្នុងអដ្ឋកថា ខុទ្ទកនិកាយ មង្គលសូត្រ និងអដ្ឋកថាសុត្តនិបាត ចូឡវគ្គ បានបញ្ជាក់ថា :

ភគវា អាហ "ឯសោ អានន្ទ មាលាការោ ឥមិស្សា បូជាយ អានុភាវេន សតសហស្សកប្បេ ទេវេសុ ច មនុស្សេសុ ច សំសរិត្វា បរិយោសានេ សុមនិស្សរោ នាម បច្ចេកពុទ្ធោ ភវិស្សតី" តិ ។

ប្រែ: ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលអានន្ទ មាលាការនុ៎ះ នឹងត្រាច់ទៅក្នុងមនុស្សលោក ទេវលោក ក្នុងទីបំផុតមួយសែនកប្ប នឹងបានសម្រេចជាព្រះបច្ចេកពុទ្ធមួយអង្គ មានព្រះនាមថា សុមនិស្សរៈ ដោយអានុភាពនៃការបូជាចំពោះតថាគតនេះឯង ។

អយំ អានន្ទ មយ្ហំ ជីវិតំ បរិច្ចជិត្វា បុប្ផបូជំ កត្វា កប្បសហស្សំ ទុគ្គតឹ អគន្ត្វា ទេវមនុស្សេសុ សំសរិត្វា សុមនោ នាម បច្ចេកពុទ្ធោ ភវិស្សតិ ។

ប្រែ: ម្នាលអានន្ទ សុមនមាលាការបានបូជាជីវិតចំពោះតថាគត តែងធ្វើនូវការបូជាផ្កា នឹងមិនបានទៅកាន់ទុគ្គតិអស់ ១ សែនកប្ប ហើយត្រាច់ទៅក្នុងទេវតា និងមនុស្ស បន្ទាប់មកនឹងបានជាព្រះបច្ចេកពុទ្ធ ព្រះនាម សុមនៈ ។

*ក្នុងអដ្ឋកថាសទ្ធម្មប្បជ្ជោតិកា អដ្ឋកថាចូឡនិទ្ទេស និងក្នុងអភិធម្មា-វតារអភិនវដីកា បានបញ្ជាក់ថា :*

**អនាគតេ អជ្ជិស្សរោ នាម បច្ចេកសម្ពុទ្ធោ ភវិស្សតីតិ ច, សុមនិស្សរោ នាម បច្ចេកសម្ពុទ្ធោ ភវិស្សតីតិ ច ។**

*ប្រែ : ក្នុងអនាគតកាល នឹងមានព្រះបច្ចេកពុទ្ធព្រះនាម* ***អជ្ជិស្សរៈ*** *និង មានព្រះបច្ចេកពុទ្ធព្រះនាម* ***សុមនិស្សរៈ*** *។*

*ក្នុងបបញ្ចសូទនី អដ្ឋកថាមូលបណ្ណាសក សីហនាទវគ្គ ចូឡសីហ-នាទសូត្រ បានបញ្ជាក់ថា :*

**បស្សានន្ទ ឥមំ ឧលូកសកុណំ, អយំ មយិ ច ភិក្ខុសង្ឃេ ច ចិត្តំ បសាទេត្វា សតសហស្សកប្បេ ទេវេសុ ច មនុស្សេសុ ច សំសរិត្វា សោមនស្សោ នាម បច្ចេកពុទ្ធោ ភវិស្សតិ ។**

*ប្រែ : ម្នាលអានន្ទ អ្នកចូរមើលសត្វទីទុយនេះចុះ, សត្វទីទុយនេះបាន ញ៉ាំងចិត្តឱ្យជ្រះថ្លាចំពោះតថាគតផង ចំពោះភិក្ខុសង្ឃផង កាល ត្រាច់ទៅហើយក្នុងទេវតា និងមនុស្សទាំងឡាយ នឹងបានជាព្រះ បច្ចេកពុទ្ធព្រះនាម* ***សោមនស្ស*** *ក្នុង ១ សែនកប្ប (បន្ទាប់អំពី ភទ្ទកប្បនេះទៅ) ។*

ក្នុងគម្ពីរមូលបណ្ណាសកដីកា ឈ្មោះលីនត្ថប្បកាសិនី បានពន្យល់ថា :

**នមស្សមានោ អដ្ឋាសីតិ ទ្វេ អសង្ខ្យេយ្យានិ បច្ចេក-ពោធិចារមីនំ បូរណេន តត្ថ ពុទ្ធសាសនេ បរិចរិយេន ច ភគវតិ បសន្នចិត្តតាយ ច ។**

ប្រែ : ត្រង់ពាក្យថា កាលឈរនមស្ការ សេចក្តីថា សត្វទីទុយនោះ តែងនមស្ការថ្វាយបង្គំ ដោយការបំពេញបច្ចេកពោធិបារមីអស់ ២ អសង្ខេយ្យ (រួចមកហើយ) ផង តែងនមស្ការដោយបំពេញវត្តប្រតិបត្តិក្នុងព្រះពុទ្ធសាសនាផង និងដោយសេចក្តីជ្រះថ្លាចំពោះព្រះដ៏មានព្រះភាគផង ។

ការពិនិត្យសង្កេតឱ្យច្បាស់លាស់តាម អដ្ឋកថា ដីកាទាំងអស់នេះទៅឃើញថា **បន្ទាប់ពីភទ្ទកប្បនេះទៅ មិនមានសុញ្ញកប្ប រហូតដល់មួយអសង្ខេយ្យនោះឡើយ ៕**

# ពុទ្ធវង្សតារាងទី ១

| ល.រ | នាមព្រះពុទ្ធ | មានជាតិជា | ឈ្មោះព្រះនគរ | ព្រះបិតា | ព្រះមាតា |
|---|---|---|---|---|---|
| ១ | ព្រះពុទ្ធទីបង្ករ | ក្សត្រ | រម្មាវតី | សុទេវៈ | សុមេធា |
| ២ | ព្រះពុទ្ធកោណ្ឌញ្ញៈ | ក្សត្រ | រម្មវតី | សុនន្ទៈ | សុជាតាទេវី |
| ៣ | ព្រះពុទ្ធមង្គលៈ | ក្សត្រ | ឧត្តរៈ | ឧត្តរៈ | ឧត្តរា |
| ៤ | ព្រះពុទ្ធសុមនៈ | ក្សត្រ | មេខលៈ | សុទត្តៈ | សិរិមា |
| ៥ | ព្រះពុទ្ធរេវតៈ | ក្សត្រ | សុធញ្ញកៈ | វិបុលៈ | វិបុលា |
| ៦ | ព្រះពុទ្ធសោភិតៈ | ក្សត្រ | សុធម្មៈ | សុធម្មៈ | សុធម្មា |
| ៧ | ព្រះពុទ្ធអនោមទស្សី | ក្សត្រ | ចន្ទវតី | យសវា | យសោធរា |
| ៨ | ព្រះពុទ្ធបទុមៈ | ក្សត្រ | ចម្បកៈ | អសមៈ | អសមា |
| ៩ | ព្រះពុទ្ធនារទៈ | បុត្រស្តេចចក្រ | ធញ្ញវតី | សុទេវៈ | អនោមា |
| ១០ | ព្រះពុទ្ធបទុមុត្តរៈ | ក្សត្រ | ហង្សវតី | អានន្ទៈ | សុជាតា |
| ១១ | ព្រះពុទ្ធសុមេធៈ | ក្សត្រ | សុទស្សនៈ | សុទត្តៈ | សុទត្តា |
| ១២ | ព្រះពុទ្ធសុជាតៈ | ក្សត្រ | សុមង្គលៈ | ឧគ្គតៈ | បភាវតី |
| ១៣ | ព្រះពុទ្ធបិយទស្សី | ក្សត្រ | សុធញ្ញៈ | សុទត្តៈ | សុចន្ទា |
| ១៤ | ព្រះពុទ្ធអត្ថទស្សី | ក្សត្រ | សោភណៈ | សាគរៈ | សុទស្សនា |
| ១៥ | ព្រះពុទ្ធធម្មទស្សី | ក្សត្រ | សរណៈ | សរណៈ | សុនន្ទា |
| ១៦ | ព្រះពុទ្ធសិទ្ធត្ថៈ | ក្សត្រ | វេភារៈ | ឧទេនៈ | សុផស្សា |
| ១៧ | ព្រះពុទ្ធតិស្សៈ | ក្សត្រ | ខេមកៈ | ជនសន្ធៈ | បទុមា |
| ១៨ | ព្រះពុទ្ធបុស្សៈ | ក្សត្រ | កាសិកៈ | ជយសេន | សិរិមា |
| ១៩ | ព្រះពុទ្ធវិបស្សី | ក្សត្រ | ពន្ធុមតី | ពន្ធុមៈ | ពន្ធុមតី |
| ២០ | ព្រះពុទ្ធសិខី | ក្សត្រ | អរុណវតី | អរុណៈ | បភាវតី |
| ២១ | ព្រះពុទ្ធវេស្សភូ | ក្សត្រ | អនោម | សុប្បតិតៈ | យសវតី |
| ២២ | ព្រះពុទ្ធកកុសន្ធៈ | ព្រាហ្មណ៍ | ខេមបូរី | អគ្គិទត្តព្រាហ្មណ៍ | វិសាខា |
| ២៣ | ព្រះពុទ្ធកោនាគមនៈ | ព្រាហ្មណ៍ | សោភវតី | យញ្ញទត្តព្រាហ្មណ៍ | ឧត្តរា |
| ២៤ | ព្រះពុទ្ធកស្សបៈ | ព្រាហ្មណ៍ | ពារាណសី | ព្រហ្មទត្តព្រាហ្មណ៍ | ធនវតី |
| ២៥ | ព្រះពុទ្ធគោតម | ក្សត្រ | កបិលពស្តុ | សុទ្ធោទនៈ | មាយាទេវី |

# ពុទ្ធវង្សតារាងទី ២

| នាមព្រះពុទ្ធ | គ្រប់គ្រងផ្ទះ | មានប្រាសាទដ៏ប្រសើរ ៣ ខ្នង | | |
|---|---|---|---|---|
| | | ទី១ ឈ្មោះ | ទី២ ឈ្មោះ | ទី៣ ឈ្មោះ |
| ព្រះពុទ្ធទីបង្ករ | ១ ម៉ឺនឆ្នាំ | ហង្សប្រាសាទ | កោញ្ចប្រាសាទ | មយុរប្រាសាទ |
| ព្រះពុទ្ធកោណ្ឌញ្ញៈ | ១ ម៉ឺនឆ្នាំ | រុចិ | សុរុចិ | សុភ |
| ព្រះពុទ្ធមង្គលៈ | ៩ ពាន់ឆ្នាំ | យសវ | សុចិម | សិរិម |
| ព្រះពុទ្ធសុមនៈ | ៩ ពាន់ឆ្នាំ | ចន្ទ | សុចន្ទ | វដំស |
| ព្រះពុទ្ធរេវតៈ | ៦ ពាន់ឆ្នាំ | សុទស្សន | រតនគ្ឃិ | អាវេឡ |
| ព្រះពុទ្ធសោភិតៈ | ៩ ពាន់ឆ្នាំ | កុមុទ | នឡិនី | បទុម |
| ព្រះពុទ្ធអនោមទស្សី | ១ ម៉ឺនឆ្នាំ | សិរី | ឧបសិរី | វឌ្ឍ |
| ព្រះពុទ្ធបទុមៈ | ១ ម៉ឺនឆ្នាំ | នន្ទ | វសុ | យសុត្តរ |
| ព្រះពុទ្ធនារទៈ | ៩ ពាន់ឆ្នាំ | ជិត | វិជិត | អភិរាម |
| ព្រះពុទ្ធបទុមុត្តរៈ | ៩ ពាន់ឆ្នាំ | នារី | ពាហន | យសវតី |
| ព្រះពុទ្ធសុមេធៈ | ៩ ពាន់ឆ្នាំ | សុចន្ទ | កញ្ចន | សិរិវឌ្ឍ |
| ព្រះពុទ្ធសុជាតៈ | ៩ ពាន់ឆ្នាំ | សិរិ | ឧបសិរិ | ចន្ទ |
| ព្រះពុទ្ធបិយទស្សី | ៩ ពាន់ឆ្នាំ | សុនិម្មល | វិមល | គិរិគុហា |
| ព្រះពុទ្ធអត្ថទស្សី | ៩ ពាន់ឆ្នាំ | អមរគិ | សុរគិ | គិរិពាហន |
| ព្រះពុទ្ធធម្មទស្សី | ៨ ពាន់ឆ្នាំ | អរជ | វិរជ | សុទស្សន |
| ព្រះពុទ្ធសិទ្ធត្ថៈ | ១ ម៉ឺនឆ្នាំ | កោកាស | ឧប្បល | កោកនុទ |
| ព្រះពុទ្ធតិស្សៈ | ៧ ពាន់ឆ្នាំ | គុណសេលៈ | អនាទិយ | និសភ |
| ព្រះពុទ្ធបុស្សៈ | ៩ ពាន់ឆ្នាំ | គរុឡ | ហំស | សុវណ្ណតារ |
| ព្រះពុទ្ធវិបស្សី | ៨ ពាន់ឆ្នាំ | នន្ទ | សនន្ទ | សិរិម |
| ព្រះពុទ្ធសិខី | ៧ ពាន់ឆ្នាំ | សុវឌ្ឍក | គិរី | នារីវាហន |
| ព្រះពុទ្ធវេស្សភូ | ៦ ពាន់ឆ្នាំ | រុចិ | សុរតិ | វឌ្ឍក |
| ព្រះពុទ្ធកកុសន្ធៈ | ៤ ពាន់ឆ្នាំ | កាមវឌ្ឍ | កាមសុទ្ធិ | រតិវឌ្ឍន |
| ព្រះពុទ្ធកោនាគមនៈ | ៣ ពាន់ឆ្នាំ | ទុសិត | សន្តុសិត | សន្តុដ្ឋ |
| ព្រះពុទ្ធកស្សបៈ | ២ ពាន់ឆ្នាំ | ហំស | យស | សិរិចន្ទ |
| ព្រះពុទ្ធគោតម | ២៩ ឆ្នាំ | សុចន្ទ | កោកនុទ | កោញ្ច |

# ពុទ្ធវង្សតារាងទី ៣

| នាមព្រះពុទ្ធ | ស្រ្តីបម្រើ | អគ្គមហេសី | ព្រះឱរស | យាងទៅបួសដោយ |
|---|---|---|---|---|
| ព្រះពុទ្ធទីបង្ករ | ៣ សែនរូប | បទុមា | ឱសភក្ខន្ធ | យានដំរី |
| ព្រះពុទ្ធកោណ្ឌញ្ញៈ | ៣ សែនរូប | រុចិទេវី | ជិវិតសេន | យានរថ |
| ព្រះពុទ្ធមង្គលៈ | ៣ ម៉ឺនរូប | យសវតី | សវលៈ | យានសេះ |
| ព្រះពុទ្ធសុមនៈ | ៦៣ សែនរូប | វដំសកី | អនូបមំ | យានដំរី |
| ព្រះពុទ្ធរេវតៈ | ៣៣ សែនរូប | សុទស្សនា | វរុណៈ | យានរថ |
| ព្រះពុទ្ធសោភិតៈ | ៤ ពាន់រូប | កិមិលា | សីហៈ | ប្រាសាទ |
| ព្រះពុទ្ធអនោមទស្សី | ២៣ ពាន់រូប | សិរិមា | ឧបសាលៈ | គ្រែស្នែង |
| ព្រះពុទ្ធបទុមៈ | ៣៣ ពាន់រូប | ឧត្តរា | រម្ម | យានរថ |
| ព្រះពុទ្ធនារទៈ | ៣-៤ ពាន់រូប | វិជិតសេនា | ណនុត្តរ | ព្រះបាទផ្ទាល់ |
| ព្រះពុទ្ធបទុមុត្តរៈ | ៣-៤ ពាន់រូប | វសុលទត្តា | ឧត្តរៈ | ប្រាសាទ |
| ព្រះពុទ្ធសុមេធៈ | ១៦ ពាន់រូប | សុមនា | បុនព្វៈ | យានដំរី |
| ព្រះពុទ្ធសុជាតៈ | ២៣ ពាន់រូប | សិរិនន្ទា | ឧបសេន | យានសេះ |
| ព្រះពុទ្ធបិយទស្សី | ៣៣ ពាន់រូប | វិមលា | កញ្ចនាវេឡុៈ | យានរថ |
| ព្រះពុទ្ធអត្ថទស្សី | ៣៣ ពាន់រូប | វិសាខា | សេលៈ | យានសេះ |
| ព្រះពុទ្ធធម្មទស្សី | ៤០ ពាន់រូប | វិចិកោសី | បុញ្ញវឌ្ឍនៈ | ប្រាសាទ |
| ព្រះពុទ្ធសិទ្ធត្ថៈ | ៤៨ ពាន់រូប | សុមនា | អនុបមៈ | គ្រែស្នែង |
| ព្រះពុទ្ធតិស្សៈ | ៣០ ពាន់រូប | សុភទ្រា | អានន្ទៈ | យានសេះ |
| ព្រះពុទ្ធបុស្សៈ | ២៣ ពាន់រូប | កីសាគោតមី | អានន្ទៈ | យានដំរី |
| ព្រះពុទ្ធវិបស្សី | ៤៣ ពាន់រូប | សុទស្សនា | សមវត្តក្ខន្ធៈ | យានរថ |
| ព្រះពុទ្ធសិខី | ២៤ ពាន់រូប | សព្វកាមា | អតុលៈ | យានដំរី |
| ព្រះពុទ្ធវេស្សភូ | ៣០ ពាន់រូប | សុចិត្តា | សុប្បពុទ្ធៈ | គ្រែស្នែង |
| ព្រះពុទ្ធកក្កុសន្ធៈ | ៣០ ពាន់រូប | រោចិនី | ឧត្តរៈ | យានរថ |
| ព្រះពុទ្ធកោនាគមនៈ | ១៦ ពាន់រូប | រុចិគត្តា | សត្ថវាហៈ | យានដំរី |
| ព្រះពុទ្ធកស្សបៈ | ៤៨ ពាន់រូប | សុនន្ទា | វិជិតសេនៈ | ប្រាសាទ |
| ព្រះពុទ្ធគោតម | ៤០ ពាន់រូប | យសោធរា | រាហុល | យានសេះ |

# ពុទ្ធវង្សតារាងទី ៤

| នាមព្រះពុទ្ធ | ព្យាយាមអស់ | ឈើព្រះអង្គត្រាស់ដឹង | ព្រះរស្មីប្រមាណ |
|---|---|---|---|
| ព្រះពុទ្ធទីបង្ករ | ១០ ខែគត់ | ដើមលៀប | ១០ យោជន៍សព្វកាល |
| ព្រះពុទ្ធកោណ្ឌញ្ញៈ | ១០ ខែគត់ | សាលកល្យាណិព្រឹក្ស[៨០] | រស្មីប្រមាណមិនបាន |
| ព្រះពុទ្ធមង្គលៈ | ៨ ខែគត់ | នាគព្រឹក្ស (ដើមខ្លឹង) | ១ម៉ឺនលោកធាតុសព្វកាល |
| ព្រះពុទ្ធសុមនៈ | ១០ ខែគត់ | នាគព្រឹក្ស (ដើមខ្លឹង) | រស្មីប្រមាណមិនបាន |
| ព្រះពុទ្ធរេវតៈ | ៧ ខែគត់ | នាគព្រឹក្ស (ដើមខ្លឹង) | ១ យោជន៍សព្វកាល |
| ព្រះពុទ្ធសោភិតៈ | ៧ ថ្ងៃ | នាគព្រឹក្ស (ដើមខ្លឹង) | រស្មីប្រមាណមិនបាន |
| ព្រះពុទ្ធអនោមទស្សី | ១០ ខែគត់ | អជ្ជុនព្រឹក្ស (ដើមអង្គ្រង) | រស្មីប្រមាណមិនបាន |
| ព្រះពុទ្ធបទុមៈ | ៨ ខែគត់ | មហាសោណៈ (ដើមម្រុំ) | រស្មីប្រមាណមិនបាន |
| ព្រះពុទ្ធនារទៈ | ៧ ថ្ងៃ | មហាសោណៈ (ដើមម្រុំ) | ១ យោជន៍សព្វកាល |
| ព្រះពុទ្ធបទុមុត្តរៈ | ៧ ថ្ងៃ | (ដើមស្រល់) | រស្មីប្រមាណមិនបាន |
| ព្រះពុទ្ធសុមេធៈ | ៨ ខែគត់ | និម្ពព្រឹក្ស (ដើមស្ដៅ) | ១ យោជន៍សព្វកាល |
| ព្រះពុទ្ធសុជាតៈ | ៩ ខែគត់ | (ឫស្សីធំ) | រស្មីប្រមាណមិនបាន |
| ព្រះពុទ្ធបិយទស្សី | ៦ ខែគត់ | កកុធព្រឹក្ស (ដើមថ្វាន់ | រស្មីប្រមាណមិនបាន |
| ព្រះពុទ្ធអត្ថទស្សី | ៨ ខែគត់ | ចម្បកព្រឹក្ស (ដើមចម្ប៉ា) | ១ យោជន៍សព្វកាល |
| ព្រះពុទ្ធធម្មទស្សី | ៧ ថ្ងៃ | (ដើមទន្ទាប់) | រស្មីប្រមាណមិនបាន |
| ព្រះពុទ្ធសិទ្ធត្ថៈ | ១០ ខែគត់ | កណិការព្រឹក្ស | រស្មីប្រមាណមិនបាន |
| ព្រះពុទ្ធតិស្សៈ | កន្លះខែគត់ | អសន (ដើមធ្នង់) | រស្មីប្រមាណមិនបាន |
| ព្រះពុទ្ធបុស្សៈ | ៧ ថ្ងៃ | (ដើមកន្ទួតព្រៃ) | រស្មីប្រមាណមិនបាន |
| ព្រះពុទ្ធវិបស្សី | ៨ ខែគត់ | បាដលិព្រឹក្ស (សង្កែ) | ៧ យោជន៍សព្វកាល |
| ព្រះពុទ្ធសិខី | ៨ ខែគត់ | បុណ្ឌរិកព្រឹក្ស (ស្វាយស) | រស្មី ៣ យោជន៍ជានិច្ច |
| ព្រះពុទ្ធវេស្សភូ | ៦ ខែ | មហាសាលព្រឹក្ស | រស្មីប្រមាណមិនបាន |
| ព្រះពុទ្ធកកុសន្ធៈ | ៨ ខែគត់ | សិរិសព្រឹក្ស (ច្រេស) | ១០ យោជន៍សព្វកាល |
| ព្រះពុទ្ធកោនាគមនៈ | ៦ ខែ | ឧទុម្ពរព្រឹក្ស (ល្វា) | រស្មីប្រមាណមិនបាន |
| ព្រះពុទ្ធកស្សបៈ | ៧ ថ្ងៃ | និគ្រោធព្រឹក្ស (ជ្រៃ) | រស្មីប្រមាណមិនបាន |
| ព្រះពុទ្ធគោតម | ទុក្ករកិរិយា ៦ វស្សា | (ពោធិ៍បាយ) | រស្មី ១ ព្យាមជានិច្ច |

[៨០] ដើមភ្លៅនាង ។

# ពុទ្ធវង្សតារាងទី ៥

| នាមព្រះពុទ្ធ | សម្ដែងធម្មចក្កក្នុងទី | ញុំាងពពួកសត្វឱ្យត្រាស់ដឹង ៣ លើក | | |
|---|---|---|---|---|
| | | លើកទី១ ចំនួន | លើកទី២ ចំនួន | លើកទី៣ ចំនួន |
| ព្រះពុទ្ធទីបង្ករ | នន្ទារាម | ១០០កោដិទេវតា | ៩០ កោដិ | ៩០កោដិទេវតា |
| ព្រះពុទ្ធកោណ្ឌញ្ញ: | | ១ សែនកោដិ | ៩០ ពាន់កោដិ | ៨០ ពាន់កោដិ |
| ព្រះពុទ្ធមង្គល: | | ១ សែនកោដិ | ១ សែនកោដិ | ៩០ កោដិឯហិភិក្ខុ |
| ព្រះពុទ្ធសុមន: | | ១ សែនកោដិ | ១ សែនកោដិ | ៩០ ពាន់កោដិ |
| ព្រះពុទ្ធរេវត: | | មិនអាចរាប់បាន | ១ ពាន់កោដិ | ១ រយកោដិ |
| ព្រះពុទ្ធសោភិត: | | មិនអាចរាប់បាន | ៩ ម៉ឺនកោដិ | ១ ពាន់កោដិ |
| ព្រះពុទ្ធអនោមទស្សី | ឧទ្យានសុទស្សន: | ១ រយកោដិ | ៨០ កោដិ | ៧៨ កោដិ |
| ព្រះពុទ្ធបទុម: | | ១ រយកោដិ | ៩០ កោដិ | ៨០ កោដិ |
| ព្រះពុទ្ធនារទ: | ឧទ្យានធនញ្ជ: | ១ សែនកោដិ | ៩០ ពាន់កោដិ | ៨០ កោដិ |
| ព្រះពុទ្ធបទុមុត្តរ: | ឧទ្យានមិថិលា | ១ សែនកោដិ | ៣៧ ពាន់ | ៥ លាន |
| ព្រះពុទ្ធសុមេធ: | ឧទ្យានសុទស្សន: | ១ សែនកោដិ | ៩០ ពាន់កោដិ | ៨០ ពាន់កោដិ |
| ព្រះពុទ្ធសុជាត: | ឧទ្យានសុមង្គល | ៨០ កោដិ | ៣៧ សែន | ៦០ សែន |
| ព្រះពុទ្ធបិយទស្សី | ឧទ្យានឧសភ: | ១ សែនកោដិ | ៩ ពាន់កោដិ | ៨០ កោដិ |
| ព្រះពុទ្ធអត្ថទស្សី | ឧទ្យាន | ១ សែនកោដិ | ១ សែនកោដិ | ១ សែនកោដិ |
| ព្រះពុទ្ធធម្មទស្សី | មិគទាយវ័ន | ១ សែនកោដិ | ៩០ កោដិ | ៨០ កោដិ |
| ព្រះពុទ្ធសិទ្ធត្ថ: | មិគទាយវ័ន | ១ សែនកោដិ | ៩០ កោដិ | ៩០ កោដិ |
| ព្រះពុទ្ធតិស្ស: | មិគទាយវ័ន | ១ រយកោដិ | ៩០ កោដិ | ៦០ កោដិ |
| ព្រះពុទ្ធបុស្ស: | មិគទាយវ័ន | ៨០ សែន | ៩០ សែន | ៨០ សែន |
| ព្រះពុទ្ធវិបស្សី | មិគទាយវ័ន | មិនអាចរាប់បាន | ៨២ ពាន់ | ៨២ ពាន់ |
| ព្រះពុទ្ធសិខី | មិគទាយវ័ន | ១ សែនកោដិ | ៩០ ពាន់កោដិ | ៨០ ពាន់កោដិ |
| ព្រះពុទ្ធវេស្សភូ | | ៨ ម៉ឺនកោដិ | ៧០ ពាន់កោដិ | ៦០ កោដិ |
| ព្រះពុទ្ធកកុសន្ធ: | មិគទាយវ័ន | ៤ ម៉ឺនកោដិ | ៣ ម៉ឺនកោដិ | មិនអាចរាប់បាន |
| ព្រះពុទ្ធកោនាគមន: | មិគទាយវ័ន | ៣ ម៉ឺនកោដិ | ២ ម៉ឺនកោដិ | ១ ម៉ឺនកោដិ |
| ព្រះពុទ្ធកស្សប: | មិគទាយវ័ន | ២ ម៉ឺនកោដិ | ១ ម៉ឺនកោដិ | ៥ ពាន់កោដិ |
| ព្រះពុទ្ធគោតម | ឥសិបតន: | ១៨ កោដិ | មិនអាចរាប់បាន | មិនអាចរាប់បាន |

# ពុទ្ធវង្សតារាងទី ៦

| នាមព្រះពុទ្ធ | សាវកសន្និបាត ៣ លើក | | | ភិក្ខុជាឧបដ្ឋាក |
|---|---|---|---|---|
| | លើកទី១ ចំនួន | លើកទី២ ចំនួន | លើកទី៣ ចំនួន | |
| ព្រះពុទ្ធទីបង្ករ | ១ សែនកោដិ | ១ រយកោដិ | ៩០ កោដិ | សាគតៈ |
| ព្រះពុទ្ធកោណ្ឌញ្ញៈ | ១ សែនកោដិ | ១ ពាន់កោដិ | ៩០ កោដិ | អនុរុទ្ធៈ |
| ព្រះពុទ្ធមង្គលៈ | ១ កោដិ | ១ សែនកោដិ | ៩០ កោដិ | បាលិតៈ |
| ព្រះពុទ្ធសុមនៈ | ១ សែនកោដិ | ៩០ កោដិ | ៨០ កោដិ | ឧទេនៈ |
| ព្រះពុទ្ធរេវតៈ | មិនអាចរាប់បាន | ១ សែនកោដិ | ១ សែនកោដិ | សម្ភវៈ |
| ព្រះពុទ្ធសោភិតៈ | ១ រយកោដិ | ៩០ កោដិ | ៨០ កោដិ | អនោមៈ |
| ព្រះពុទ្ធអនោមទស្សី | ៨ សែន | ៧ សែន | ៦ សែន | វរុណៈ |
| ព្រះពុទ្ធបទុមៈ | ១ សែនកោដិ | ៣ សែន | ២ សែន | វរុណៈ |
| ព្រះពុទ្ធនារទៈ | ១ សែនកោដិ | ៩០ ពាន់កោដិ | ៨០ សែន | វាសេដ្ឋៈ |
| ព្រះពុទ្ធបទុមុត្តរៈ | ១ សែនកោដិ | ៩០ ពាន់កោដិ | ៨០ ពាន់កោដិ | សុមនៈ |
| ព្រះពុទ្ធសុមេធៈ | ១ រយកោដិ | ៩០ កោដិ | ៨០ កោដិ | សាគរៈ |
| ព្រះពុទ្ធសុជាតៈ | ៦០ សែន | ៥០ សែន | ៤ សែន | នារទៈ |
| ព្រះពុទ្ធបិយទស្សី | ១ សែនកោដិ | ៩០ កោដិ | ៨០ កោដិ | សោភិតៈ |
| ព្រះពុទ្ធអត្ថទស្សី | ៩៨ ពាន់អង្គ | ៨៨ ពាន់ | ៧៨ ពាន់ | អភយៈ |
| ព្រះពុទ្ធធម្មទស្សី | ១ ពាន់កោដិ | ១ រយកោដិ | ៨០ កោដិ | សុទត្តត្ថេរៈ |
| ព្រះពុទ្ធសិទ្ធត្ថៈ | ១ រយកោដិ | ៩០ កោដិ | ៨០ កោដិ | រេវតៈ |
| ព្រះពុទ្ធតិស្សៈ | ១ សែនអង្គ | ៩០ សែន | ៨០ សែន | សមគៈ |
| ព្រះពុទ្ធបុស្សៈ | ៦០ សែន | ៥០ សែន | ៤០ សែន | សភិយៈ |
| ព្រះពុទ្ធវិបស្សី | ៦៨ សែន | ១ សែន | ៨ ម៉ឺន | អសោកៈ |
| ព្រះពុទ្ធសិខី | ១ សែន | ៨ ម៉ឺន | ៧ ម៉ឺន | ខេមង្ករៈ |
| ព្រះពុទ្ធវេស្សភូ | ៨០ ពាន់កោដិ | ៧០ ពាន់កោដិ | ៦០ ពាន់កោដិ | ឧបសន្តៈ |
| ព្រះពុទ្ធកកុសន្ធៈ | ៤ ម៉ឺន | | | ពុទ្ធិជៈ |
| ព្រះពុទ្ធកោនាគមនៈ | ៣ ម៉ឺន | | | សោត្ថិជៈ |
| ព្រះពុទ្ធកស្សបៈ | ២ ម៉ឺន | | | សព្វមិត្ត |
| ព្រះពុទ្ធគោតម | ១២៥០ អង្គ | | | អានន្ទៈ |

# ពុទ្ធវង្សតារាងទី ៧

| នាមព្រះពុទ្ធ | អគ្គសាវ័ក | | អគ្គសាវិកា | |
|---|---|---|---|---|
| | ទី១ ព្រះនាម | ទី២ ព្រះនាម | ទី១ ព្រះនាម | ទី២ ព្រះនាម |
| ព្រះពុទ្ធទីបង្ករ | សុមង្គលៈ | តិស្សៈ | នន្ទា | សុនន្ទា |
| ព្រះពុទ្ធកោណ្ឌញ្ញៈ | ភទ្ទៈ | សុភទ្ទៈ | តិស្សា | ឧបតិស្សា |
| ព្រះពុទ្ធមង្គលៈ | សុទេវៈ | ធម្មសេនៈ | សីវលា | អសោកា |
| ព្រះពុទ្ធសុមនៈ | សរណៈ | ភាវិតត្តៈ | សោណា | ឧបសោណា |
| ព្រះពុទ្ធរេវតៈ | វរុណៈ | ព្រហ្មទេវៈ | ភទ្ទា | សុភទ្ទា |
| ព្រះពុទ្ធសោភិតៈ | អសមៈ | សុនេត្តៈ | នកុលា | សុជាតា |
| ព្រះពុទ្ធអនោមទស្សី | និសភៈ | អនោមៈ | សុន្ទរា | សុមនា |
| ព្រះពុទ្ធបទុមៈ | សាលៈ | ឧបសាលៈ | រាធា | សុរាធា |
| ព្រះពុទ្ធនារទៈ | ភទ្ទសាលៈ | ជិតមិតៈ | ឧត្តរា | ភគ្គនី |
| ព្រះពុទ្ធបទុមុត្តរៈ | ទេវិល | សុជាតៈ | អមិតា | អសមា |
| ព្រះពុទ្ធសុមេធៈ | សរណៈ | សព្វកាមៈ | រាមា | សុរាមា |
| ព្រះពុទ្ធសុជាតៈ | សុទស្សនៈ | សុទេវៈ | នាគា | នាគសមានា |
| ព្រះពុទ្ធបិយទស្សី | បាលិតៈ | សព្វទស្សី | សុជាតា | ធម្មទិន្នា |
| ព្រះពុទ្ធអត្ថទស្សី | សន្តៈ | ឧបសន្តៈ | ធម្មា | សុធម្មា |
| ព្រះពុទ្ធធម្មទស្សី | បទុមត្ថេរ | បុស្សទេវត្ថេរ | ខេមា | សច្ចនាមា |
| ព្រះពុទ្ធសិទ្ធត្ថៈ | សម្ពលត្ថេរ | សុមិត្តត្ថេរ | សីវលា | សុរាមា |
| ព្រះពុទ្ធតិស្សៈ | ព្រហ្មទេវត្ថេរ | ឧទយត្ថេរ | ផុស្សា | សុទត្តា |
| ព្រះពុទ្ធបុស្សៈ | សុរក្ខិតៈ | ធម្មសេនៈ | ចាលា | ឧបចាលា |
| ព្រះពុទ្ធវិបស្សី | ខន្ធៈ | តិស្សៈ | ចន្ទា | ចន្ទមិត្តា |
| ព្រះពុទ្ធសិខី | អភិភូ | សម្ភវៈ | មខិលា | បទុមា |
| ព្រះពុទ្ធវេស្សភូ | សោណៈ | ឧត្តរៈ | រាមា | សមានា |
| ព្រះពុទ្ធកកុសន្ធៈ | វិធុរៈ | សញ្ជីវៈ | សាមា | ចម្បា |
| ព្រះពុទ្ធកោនាគមនៈ | ភិយ្យោសៈ | ឧត្តរៈ | សមុទ្ទា | ឧត្តរា |
| ព្រះពុទ្ធកស្សបៈ | តិស្សៈ | ភារទ្វាជៈ | អនុលា | ឧរុវេលា |
| ព្រះពុទ្ធគោតម | កោលិតៈ | ឧបតិស្សៈ | ខេមា | ឧប្បលវណ្ណា |

# ពុទ្ធវង្សតារាងទី ៨

| នាមព្រះពុទ្ធ | ឧបាសកជាឧបដ្ឋាក | | ឧបាសិកាជាឧបដ្ឋាយិកា | | បល្ល័ង្កកម្ពស់ |
|---|---|---|---|---|---|
| | នាម | នាម | នាម | នាម | |
| ព្រះពុទ្ធទីបង្ករ | តបុស្សៈ | ភល្លុកៈ | សិរិមា | សោណា | ៥៣ ហត្ថ |
| ព្រះពុទ្ធកោណ្ឌញ្ញៈ | សោណៈ | ឧបសោណៈ | នន្ទា | សិរិមា | ៥៧ ហត្ថ |
| ព្រះពុទ្ធមង្គលៈ | នន្ទៈ | វិសាខៈ | អនុឡា | សុមនា | ៥៧ ហត្ថ |
| ព្រះពុទ្ធសុមនៈ | វរុណៈ | សរណៈ | ចាលា | ឧបចាលា | ៦០ ហត្ថ |
| ព្រះពុទ្ធរេវតៈ | វរុណៈ | សុរកៈ | បាលា | ឧបបាលា | ៥៣ ហត្ថ |
| ព្រះពុទ្ធសោភិតៈ | រម្មៈ | សុនេត្តៈ | នកុលា | ជិត្តា | ៣៨ ហត្ថ |
| ព្រះពុទ្ធអនោមទស្សី | នន្ទិវឌ្ឍៈ | សិរិវឌ្ឍៈ | ឧបលា | បទុមា | ៣៨ ហត្ថ |
| ព្រះពុទ្ធបទុមៈ | សភិយៈ | អសមៈ | រុចិ | នន្ទិមារា | ៣៨ ហត្ថ |
| ព្រះពុទ្ធនារទៈ | ឧគ្គរិន្ទៈ | វសភៈ | ឥន្ទវរី | គណ្ឌី | ៥៧ ហត្ថ |
| ព្រះពុទ្ធបទុមុត្តរៈ | អមិតៈ | តិស្សៈ | ហត្ថា | សុចិត្តា | ៣៨ ហត្ថ |
| ព្រះពុទ្ធសុមេធៈ | ឧរុវេលៈ | យសវៈ | យសា | សិរិវា | ៥៧ ហត្ថ |
| ព្រះពុទ្ធសុជាតៈ | សុទត្តៈ | ចិត្តៈ | សុភទ្រា | បទុមា | ៣២ ហត្ថ |
| ព្រះពុទ្ធបិយទស្សី | សន្ទកៈ | ធម្មិកៈ | វិសាខា | ធម្មទិន្នា | ៥៣ ហត្ថ |
| ព្រះពុទ្ធអត្ថទស្សី | អកុឡៈ | សិនកៈ | មកិលា | សុនន្ទា | ៥៣ ហត្ថ |
| ព្រះពុទ្ធធម្មទស្សី | សុភទ្ទៈ | កដិស្សៈ | សាឡិសា | កឡិស្សា | ៥៣ ហត្ថ |
| ព្រះពុទ្ធសិទ្ធត្ថៈ | សុប្បិយៈ | សម្ពុទ្ធៈ | រម្មា | សុរម្មា | ៤០ ហត្ថ |
| ព្រះពុទ្ធតិស្សៈ | សម្ពលៈ | សិរី | កិសាគោតមី | ឧបសេនា | ៤០ ហត្ថ |
| ព្រះពុទ្ធបុស្សៈ | អនញ្ញៈ | វិសាខៈ | បទុមា | សិរិនាគា | ៣៨ ហត្ថ |
| ព្រះពុទ្ធវិបស្សី | បុនព្វសុមិត្តៈ | នាគៈ | សិរិមា | ឧត្តរា | ៥៣ ហត្ថ |
| ព្រះពុទ្ធសិខី | សិរិវឌ្ឍៈ | នន្ទៈ | ចិត្តា | សុចិត្តា | ៣២ ហត្ថ |
| ព្រះពុទ្ធវេស្សភូ | សោត្ថិកៈ | រម្មៈ | គោតមី | សិរិមា | ៤០ ហត្ថ |
| ព្រះពុទ្ធកកុសន្ធៈ | អច្ចុគ្គតៈ | សុមនៈ | នន្ទា | សុនន្ទា | ២៦ ហត្ថ |
| ព្រះពុទ្ធកោនាគមនៈ | ឧគ្គៈ | សោមទេវៈ | សីវលា | សាមា | ២០ ហត្ថ |
| ព្រះពុទ្ធកស្សបៈ | សុមង្គលៈ | ឃដិការៈ | វិជិតសេនា | ភទ្រា | ១៥ ហត្ថ |
| ព្រះពុទ្ធគោតម | ចិត្តៈ | ហត្ថាឡវកៈ | នន្ទមាតា | ឧត្តរា | ១៤ ហត្ថ |

# ពុទ្ធវង្សតារាងទី ៩

| នាមព្រះពុទ្ធ | កម្ពស់ | ព្រះជន្ម | កន្លែងបរិនិព្វាន | ព្រះធាតុចេតិយ |
|---|---|---|---|---|
| ព្រះពុទ្ធទីបង្ករ | ៨០ ហត្ថ | ១ សែនឆ្នាំ | នន្ទារាម | កម្ពស់ ៣៦ យោជន៍ |
| ព្រះពុទ្ធកោណ្ឌញ្ញៈ | ៨៨ ហត្ថ | ១ សែនឆ្នាំ | នន្ទារាម | កម្ពស់ ៧ យោជន៍ |
| ព្រះពុទ្ធមង្គលៈ | ៨៨ ហត្ថ | ៩ ម៉ឺនឆ្នាំ | ឧទ្យានវេស្សរៈ | កម្ពស់ ៣០ យោជន៍ |
| ព្រះពុទ្ធសុមនៈ | ៩០ ហត្ថ | ៩ ម៉ឺនឆ្នាំ | អង្គារាម | កម្ពស់ ៤ យោជន៍ |
| ព្រះពុទ្ធរេវតៈ | ៨០ ហត្ថ | ៦ ម៉ឺនឆ្នាំ | | ព្រះធាតុចែកជាចំណែក |
| ព្រះពុទ្ធសោភិតៈ | ៥៨ ហត្ថ | ៩ ម៉ឺនឆ្នាំ | សីហារាម | ព្រះធាតុចែកជាចំណែក |
| ព្រះពុទ្ធអនោមទស្សី | ៥៨ ហត្ថ | ១ សែនឆ្នាំ | ធម្មារាម | កម្ពស់ ២០ យោជន៍ |
| ព្រះពុទ្ធបទុមៈ | ៥៨ ហត្ថ | ១ សែនឆ្នាំ | ធម្មារាម | ព្រះធាតុចែកជាចំណែក |
| ព្រះពុទ្ធនារទៈ | ៨៨ ហត្ថក្រពុំ | ៩ ម៉ឺនឆ្នាំគត់ | សុទស្សនបុរី | កម្ពស់ ៤ យោជន៍ |
| ព្រះពុទ្ធបទុមុត្តរៈ | ៥៨ ហត្ថក្រពុំ | ១ សែនឆ្នាំ | នន្ទារាម | កម្ពស់ ១២ យោជន៍ |
| ព្រះពុទ្ធសុមេធៈ | ៨៨ ហត្ថក្រពុំ | ៩ ម៉ឺនឆ្នាំគត់ | មេធារាម | ព្រះធាតុចែកជាចំណែក |
| ព្រះពុទ្ធសុជាតៈ | ៥០ ហត្ថក្រពុំ | ៩ ម៉ឺនឆ្នាំគត់ | សេលារាម | កម្ពស់ ៣ គាវុត |
| ព្រះពុទ្ធបិយទស្សី | ៨០ ហត្ថ | ៩ ម៉ឺនឆ្នាំ | អស្សត្ថារាម | កម្ពស់ ៣ យោជន៍ |
| ព្រះពុទ្ធអត្ថទស្សី | ៨០ ហត្ថ | ១ សែនឆ្នាំ | អនោមារាម | ព្រះធាតុចែកជាចំណែក |
| ព្រះពុទ្ធធម្មទស្សី | ៨០ ហត្ថ | ១ សែនឆ្នាំ | កេសរាម | កម្ពស់ ៣ យោជន៍ |
| ព្រះពុទ្ធសិទ្ធត្ថៈ | ៦០ ហត្ថ | ១ សែនឆ្នាំ | អនោមារាម | កម្ពស់ ៤ យោជន៍ |
| ព្រះពុទ្ធតិស្សៈ | ៦០ ហត្ថ | ១ សែនឆ្នាំ | នន្ទារាម | កម្ពស់ ៣ យោជន៍ |
| ព្រះពុទ្ធបុស្សៈ | ៥៨ ហត្ថ | ៩ ម៉ឺនឆ្នាំ | សេនារាម | ព្រះធាតុចែកជាចំណែក |
| ព្រះពុទ្ធវិបស្សី | ៨០ ហត្ថ | ៨ ម៉ឺនឆ្នាំ | សុមិត្តារាម | កម្ពស់ ៧ យោជន៍ |
| ព្រះពុទ្ធសិខី | ៧០ ហត្ថ | ៧ ម៉ឺនឆ្នាំ | អស្សារាម | កម្ពស់ ៣ យោជន៍ |
| ព្រះពុទ្ធវេស្សភូ | ៦០ ហត្ថ | ៦ ម៉ឺនឆ្នាំ | ខេមារាម | ព្រះធាតុចែកជាចំណែក |
| ព្រះពុទ្ធកកុសន្ធៈ | ៤០ ហត្ថ | ៤ ម៉ឺនឆ្នាំ | ខេមារាម | កម្ពស់ ១ គាវុត |
| ព្រះពុទ្ធកោនាគមនៈ | ៣០ ហត្ថ | ៣ ម៉ឺនឆ្នាំ | បព្វតារាម | ព្រះធាតុចែកជាចំណែក |
| ព្រះពុទ្ធកស្សបៈ | ២០ ហត្ថ | ២ ម៉ឺនឆ្នាំ | សេតព្យារាម | កម្ពស់ ១ យោជន៍ |
| ព្រះពុទ្ធគោតម | ១៦ ហត្ថ | ១០០ ឆ្នាំ | នគរកុសិនារា | ព្រះធាតុចែកជាចំណែក |

## ពុទ្ធវង្សតារាងទី ១០
## ព្រះសមណគោតមបរមពោធិសត្វ កើតជួបនឹងព្រះពុទ្ធ ២៤ ព្រះអង្គ

| នាមព្រះពុទ្ធ | ព្រះបរមពោធិសត្វ | កប្បត្រូវត្រាស់ដឹង |
|---|---|---|
| ព្រះពុទ្ធទីបង្ករ | ជាព្រាហ្មណ៍ នាម សុមេធបណ្ឌិតតាបស | ៤អសង្ខៃយ្យ ១សែនកប្ប |
| ព្រះពុទ្ធកោណ្ឌញ្ញៈ | ជាក្សត្រ នាម វិជិតាវី បានបួស | កប្បប្រមាណមិនបាន |
| ព្រះពុទ្ធមង្គលៈ | ជាព្រាហ្មណ៍ នាម សុរុចិ បានបួស | កប្បប្រមាណមិនបាន |
| ព្រះពុទ្ធសុមនៈ | ជាស្តេចនាគ នាម អតុលៈ រក្សាសីល | កប្បប្រមាណមិនបាន |
| ព្រះពុទ្ធរេវតៈ | ជាព្រាហ្មណ៍ នាម អតិទេវ រក្សាសីល | កប្បប្រមាណមិនបាន |
| ព្រះពុទ្ធសោភិតៈ | ជាព្រាហ្មណ៍ នាម សុជាត រក្សាសីល | កប្បប្រមាណមិនបាន |
| ព្រះពុទ្ធអនោមទស្សី | ជាយក្ស មានឫទ្ធិច្រើន រក្សាសីល | កប្បប្រមាណមិនបាន |
| ព្រះពុទ្ធបទុមៈ | ជាសត្វសីហៈ រក្សាសីល | កប្បប្រមាណមិនបាន |
| ព្រះពុទ្ធនារទៈ | ជាតាបស | កប្បប្រមាណមិនបាន |
| ព្រះពុទ្ធបទុមុត្តរៈ | ជាជដិល (តាបស) | កប្បទី ១ សែន |
| ព្រះពុទ្ធសុមេធៈ | ជាមាណព នាម ឧត្តរៈ បានបួស | កប្បទី ៣០ ពាន់ |
| ព្រះពុទ្ធសុជាតៈ | ជាស្តេចចក្រពត្តិ បានបួស | កប្បទី ៣០ ពាន់ |
| ព្រះពុទ្ធបិយទស្សី | ជាមាណព នាម កស្សបៈ រក្សាសីល | កប្បទី ១៨០០ |
| ព្រះពុទ្ធអត្ថទស្សី | ជាតាបស នាម សុសិមៈ មានឫទ្ធិ អភិញ្ញា | កប្បទី ១៨០០ |
| ព្រះពុទ្ធធម្មទស្សី | ជាព្រះឥន្ទ នាម បុរិន្ទទៈ | កប្បទី ១៨០០ |
| ព្រះពុទ្ធសិទ្ធត្ថៈ | ជាតាបស នាម មង្គលៈ មានកម្លាំងអភិញ្ញា | កប្បទី ៩៤ |
| ព្រះពុទ្ធតិស្សៈ | ជាក្សត្រ នាមសុជាតៈ បួសជាឥសីមានអភិញ្ញា | កប្បទី ៩២ |
| ព្រះពុទ្ធបុស្សៈ | ជាក្សត្រ នាម វិជិតៈ បានបួស | កប្បទី ៩២ |
| ព្រះពុទ្ធវិបស្សី | ជាស្តេចនាគ នាម អតុលៈ រក្សាសីល | កប្បទី ៩១ |
| ព្រះពុទ្ធសិខី | ជាក្សត្រ នាម អរិន្ទមៈ រក្សាសីល | កប្បទី ៣១ |
| ព្រះពុទ្ធវេស្សភូ | ជាក្សត្រ នាម សុទស្សនៈ បានបួស | កប្បទី ៣១ |
| ព្រះពុទ្ធកកុសន្ធៈ | ជាក្សត្រ នាម ខេមៈ បានបួស | ក្នុងភទ្ទកប្បនេះ |
| ព្រះពុទ្ធកោនាគមនៈ | ជាក្សត្រ នាម បព្វតៈ បានបួស | ក្នុងភទ្ទកប្បនេះ |
| ព្រះពុទ្ធកស្សបៈ | ជាមាណព នាម ជោតិបាល បានបួស | ក្នុងភទ្ទកប្បនេះ |

# ពុទ្ធប្បត្តិកណ្ឌកកណ្ឌ

| ព្រះពុទ្ធ ២៨ ព្រះអង្គ | កប្បដែលព្រះពុទ្ធសមណគោតមបរមគ្រូ ទទួលការព្យាករ រហូតត្រាស់ដឹង | កប្បទី |
|---|---|---|
| | | |
| សារមណ្ឌកប្ប៤ | តណ្ហង្ករៈ មេធង្ករៈ សរណង្ករៈ ទីបង្ករៈ | |
| ប្រមាណជា ១ អសង្ខេយ្យកប្បនេះ គ្មានព្រះពុទ្ធត្រាស់ដឹងទេ | | |
| សារកប្ប១អង្គ | កោណ្ឌញ្ញៈ | |
| ប្រមាណជា ១ អសង្ខេយ្យកប្បនេះ គ្មានព្រះពុទ្ធត្រាស់ដឹងទេ | | |
| សារមណ្ឌកប្ប៤ | មង្គលៈ សុមនៈ រេវតៈ សោភិតៈ | |
| ប្រមាណជា ១ អសង្ខេយ្យកប្បនេះ គ្មានព្រះពុទ្ធត្រាស់ដឹងទេ | | |
| វរកប្ប៣អង្គ | អនោមទស្សី បទុមៈ នារទៈ | |
| ប្រមាណជា ១ អសង្ខេយ្យកប្បនេះ គ្មានព្រះពុទ្ធត្រាស់ដឹងទេ | | |
| សារកប្ប១អង្គ | បទុមុត្តរៈ | ១សែន |
| ៧០០០០ កប្បនេះ គ្មានព្រះពុទ្ធត្រាស់ដឹងទេ | | |
| មណ្ឌកប្ប២អង្គ | សុមេធៈ សុជាតៈ | ៣ម៉ឺន |
| ២៨,២០០ កប្បនេះ គ្មានព្រះពុទ្ធត្រាស់ដឹងទេ | | |
| វរកប្ប៣អង្គ | បិយទស្សី អត្ថទស្សី ធម្មទស្សី | ១៨០០ |
| ១៧០៦ កប្បនេះ គ្មានព្រះពុទ្ធត្រាស់ដឹងទេ | | |
| សារកប្ប១អង្គ | សិទ្ធត្ថៈ | ៩៤ |
| ១ កប្បនេះ គ្មានព្រះពុទ្ធត្រាស់ដឹងទេ | | |
| មណ្ឌកប្ប២អង្គ | តិស្សៈ បុស្សៈ | ៩២ |
| សារកប្ប១អង្គ | វិបស្សី | ៩១ |
| ៥៩ កប្បនេះ គ្មានព្រះពុទ្ធត្រាស់ដឹងទេ | | |
| មណ្ឌកប្ប២អង្គ | សិខី វេស្សភូ | ៣១ |
| ២៩ កប្បនេះ គ្មានព្រះពុទ្ធត្រាស់ដឹងទេ | | |
| ភទ្ទកប្ប៥អង្គ | កកុសន្ធៈ កោនាគមនៈ កស្សបៈ គោតម (មេត្តេយ្យ) | |

(៤ អសង្ខេយ្យ ១ សែនមហាកប្ប)

# អង្គ ៦ របស់បណ្ឌិត

សុ-ចិ-បុ-កា-វិ-លិ-មុត្តោ ឥ ហិ សោ បណ្ឌិតោ ភវេ
ឥរណ្ឌោ ឥ ឥមេ ឥម្មេ បុណ្ណាចណ្ដោរ សោភតិ ។

សុ- មានក្នុងនរជនណា ព្យាយាមសិក្សាយ៉ាងហ្មត់ចត់
ចិ- ត្រិះរិះគិតយ៉ាងប្រាកដ ត្រិះរិះកំណត់យ៉ាងត្រឹមត្រូវ ។
បុ- ដេញដោលចោទជាពាក្យសួរ លើកនូវសំណួរដែលមាននៅ
ក្នុងចិត្តជាមន្ទិលដ៏សែនជ្រៅ អាចបើកជាផ្លូវឱ្យយល់បាន ។
កា- ជួយបង្រៀនឬក៏ប្រាប់ តាមក្បួនតាមច្បាប់ជាលំអាន
ដល់អ្នកដទៃឬមិត្រកល្យាណ នាំឱ្យថ្កើងថ្កានទូវបញ្ញា ។
វិ- វិនិច្ឆ័យយ៉ាងលម្អិត ត្រិះរិះពិនិត្យពិចារណា
នូវពាក្យដែលខ្លួនបានសិក្សា នាំកាត់សង្កាទាំងនេះបាន ។
លិ- ពេលរៀនឬធ្វើការ ត្រូវតែកត់ត្រាពាក្យប៉ុន្មាន
កុំអាងសញ្ញាខ្លួនចាំបាន ក្បួនច្បាប់លំអានជាគ្រូពិត ។
ជនដែលមានធម៌ទាំង ៦ នេះអាចលើកស្ទួយជាបណ្ឌិត
រុងរឿងថែងចាំងក្នុងជីវិត នឹងមិនវិបរិតវិបល្លាស ។

| | |
|---|---|
| ព្រះចន្ទពេញបូណ៌មី | មានរស្មីថែងចាំងរះ |
| ពន្លឺភ្លឺថែងច្បាស់ | មានឱភាសពេញលោកា ។ |
| នរជនជាបណ្ឌិត | ភ្លឺមែនពិតដោយបញ្ញា |
| រុងរឿងក្នុងលោកា | សែនអស្ចារ្យជាងព្រះចន្ទ ៕ |

## អត្ថន័យរបស់ពាក្យ

| | | |
|---|---|---|
| សុ | = សុត | = ការស្តាប់, ការរៀន |
| ចិ | = ចិន្តន | = ការត្រិះរិះគិត |
| បុ | = បុច្ឆន | = ការសាកសួរ |
| ភា | = ភាសន | = ការបង្រៀន |
| វិ | = វិនិច្ឆយ | = ការពិចារណា |
| លិ | = លិខន | = ការសរសេរ, ការកត់ត្រា ។ |

ប្រែចាលី-តែងជាកាព្យដោយ

**លោកគ្រូ ធម្មានន្ទ**

## ពុទ្ធគុណសម្រាប់សូត្ររំលឹកបារមីក្នុងពិធីអភិសេកពុទ្ធប្បដិមា

*បារមីមាន ១០ ចែកដោយពិស្តារមាន ៣០ គឺ*

១-
ឥតិបិ ទានបារមីសម្បន្នោ សោ ភគវា ។
ឥតិបិ ទានឧបបារមីសម្បន្នោ សោ ភគវា ។
ឥតិបិ ទានបរមត្ថបារមីសម្បន្នោ សោ ភគវា ។

*ព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់បរិបូណ៌ដោយទានបារមី១ ទានឧបបារមី១ ទានបរមត្ថបារមី១ ។*

២-
ឥតិបិ សីលបារមីសម្បន្នោ សោ ភគវា ។
ឥតិបិ សីលឧបបារមីសម្បន្នោ សោ ភគវា ។
ឥតិបិ សីលបរមត្ថបារមីសម្បន្នោ សោ ភគវា ។

*ព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់បរិបូណ៌ដោយសីលបារមី១ សីលឧបបារមី១ សីលបរមត្ថបារមី១ ។*

៣-
ឥតិបិ នេក្ខម្មបារមីសម្បន្នោ សោ ភគវា ។
ឥតិបិ នេក្ខម្មឧបបារមីសម្បន្នោ សោ ភគវា ។
ឥតិបិ នេក្ខម្មបរមត្ថបារមីសម្បន្នោ សោ ភគវា ។

*ព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់បរិបូណ៌ដោយនេក្ខម្មបារមី១ នេក្ខម្មឧបបារមី១ នេក្ខម្មបរមត្ថបារមី១ ។*

៨- ឥតិបិ បញ្ញាចារមីសម្បន្នោ សោ ភគវា ។
ឥតិបិ បញ្ញាឧបចារមីសម្បន្នោ សោ ភគវា ។
ឥតិបិ បញ្ញាបរមត្ថចារមីសម្បន្នោ សោ ភគវា ។

*ព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់បរិបូណ៌ដោយបញ្ញាបារមី១ បញ្ញាឧបបារមី១ បញ្ញាបរមត្ថបារមី១ ។*

៩- ឥតិបិ វីរិយចារមីសម្បន្នោ សោ ភគវា ។
ឥតិបិ វីរិយឧបចារមីសម្បន្នោ សោ ភគវា ។
ឥតិបិ វីរិយបរមត្ថចារមីសម្បន្នោ សោ ភគវា ។

*ព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់បរិបូណ៌ដោយវីរិយបារមី១ វីរិយឧបបារមី១ វីរិយបរមត្ថបារមី១ ។*

៦- ឥតិបិ ខន្តិចារមីសម្បន្នោ សោ ភគវា ។
ឥតិបិ ខន្តិឧបចារមីសម្បន្នោ សោ ភគវា ។
ឥតិបិ ខន្តិបរមត្ថចារមីសម្បន្នោ សោ ភគវា ។

*ព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់បរិបូណ៌ដោយខន្តិបារមី១ ខន្តិឧបបារមី១ ខន្តិបរមត្ថបារមី១ ។*

៧- ឥតិបិ សច្ចបារមីសម្បន្នោ សោ ភគវា ។
ឥតិបិ សច្ចឧបបារមីសម្បន្នោ សោ ភគវា ។
ឥតិបិ សច្ចបរមត្ថបារមីសម្បន្នោ សោ ភគវា ។

*ព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់បរិបូណ៌ដោយសច្ចបារមី១ សច្ចឧបបារមី១ សច្ចបរមត្ថបារមី១ ។*

៨- ឥតិបិ អធិដ្ឋានបារមីសម្បន្នោ សោ ភគវា ។
ឥតិបិ អធិដ្ឋានឧបបារមីសម្បន្នោ សោ ភគវា ។
ឥតិបិ អធិដ្ឋានបរមត្ថបារមីសម្បន្នោ សោ ភគវា ។

*ព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់បរិបូណ៌ដោយអធិដ្ឋានបារមី១ អធិដ្ឋានឧបបារមី១ អធិដ្ឋានបរមត្ថបារមី១ ។*

៩- ឥតិបិ មេត្តាបារមីសម្បន្នោ សោ ភគវា ។
ឥតិបិ មេត្តាឧបបារមីសម្បន្នោ សោ ភគវា ។
ឥតិបិ មេត្តាបរមត្ថបារមីសម្បន្នោ សោ ភគវា ។

*ព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់បរិបូណ៌ដោយមេត្តាបារមី១ មេត្តាឧបបារមី១ មេត្តាបរមត្ថបារមី១ ។*

១០- **ឥតិបិ ឧបេក្ខាបារមីសម្បន្នោ សោ ភគវា ។**
**ឥតិបិ ឧបេក្ខាឧបបារមីសម្បន្នោ សោ ភគវា ។**
**ឥតិបិ ឧបេក្ខាបរមត្ថបារមីសម្បន្នោ សោ ភគវា ។**

*ព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់បរិបូណ៌ដោយឧបេក្ខាបារមី១ ឧបេក្ខាឧបបារមី១ ឧបេក្ខាបរមត្ថបារមី១ ។*

**ឥតិបិ សមត្តឹស បារមីសម្បន្នោ សោ ភគវា ។**

*ព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់បរិបូណ៌ដោយបារមី ៣០ ដោយប្រការយ៉ាងនេះ ៗ៚*

# ឯកសារពិគ្រោះ

- ព្រះត្រៃបិដក, ពុទ្ធសាសនបណ្ឌិត្យ
- អដ្ឋកថា សុមង្គលវិលាសិនី ទីឃនិកាយ, ពុទ្ធិកបណ្ឌិត្យសភា
- អដ្ឋកថា បបញ្ចសូទនី មជ្ឈិមនិកាយ, ពុទ្ធិកបណ្ឌិត្យសភា
- អដ្ឋកថា សារត្ថប្បកាសិនី សំយុត្តនិកាយ, ពុទ្ធិកបណ្ឌិត្យសភា
- អដ្ឋកថា មនោរថបូរណី អង្គុត្តរនិកាយ, ពុទ្ធិកបណ្ឌិត្យសភា
- អដ្ឋកថា មធុរត្ថវិលាសិនី ពុទ្ធវំស, ពុទ្ធិកបណ្ឌិត្យសភា
- អដ្ឋកថា បរមត្ថទីបនី ចរិយាបិដក, ពុទ្ធិកបណ្ឌិត្យសភា
- អដ្ឋកថា វិសុទ្ធជនវិលាសិនី អបទាន, ពុទ្ធិកបណ្ឌិត្យសភា
- សីលក្ខន្ធវគ្គដីកា
- អង្គុត្តរអភិនវដីកា
- សោតត្ថកីមហានិទាន
- អនាគតពុទ្ធវំស
- ជិនមាលីបករណ៍
- ទសកថា ដោយព្រះនារទភិក្ខុ នៅស្រុកលង្កា ប្រែពីភាសាបាលី ដោយព្រះឧត្តមមុនី **អ៊ុម ស៊ូរ** អធិបតីរង់ក្រុមជំនុំព្រះត្រៃបិដក
- ស្ត្រីក្នុងព្រះពុទ្ធសាសនា ដោយលោកអគ្គបណ្ឌិត **ប៊ុត សាវង្ស** ។

# Reference


- Birth-Stories of The Ten Bodhisattas and The Dasabodhisattuppattikathā (Translated by H . Sadhatissa, MA Ph.D., Tripititkācārya Pandita from a post-canonical work known as Anāgatavamsa -- Anāgatavongsa) published by The Pali Text Society, London;
- Development of Buddhist Ethics by G.S.P. Misra, Published and Printed by Munshiran Manoharlal;
- The Bodhisattva Wow, The Essential Practices of Mahayana Buddhism by Geshe Kelsang Gyatso;
- The Bodhisattva Doctrine in Buddhist Sankskrit Literature by Har Dayal, M.A. Ph.D., Motilal Banarisidass Publishers, Private Limited, Delhi;
- The Long Discourses of the Buddha - A Translation of the Digha Nikāya by Maurice Walshe;
- The Bodhicaryāvatāra by Sāntideva, Oxford, New York, Oxford University Press;
- The Coming Buddha Ariya Metteyya by Saygyi U Chit Tin;
- Buddhist Birth-Stories, Jakata Tales Translated from V. Fausboll's edition of the Pali text by Mrs. Rhys Davids, D. Litt., M.A., Sristhti Publishers & Distributors
- Buddhist Scriptures Selected and Translated by Edward Conze, Penguin Books;
- Stories of the Buddha, Being Selected from Jataka, Translated and Edited by Caroline A.E. Rhys Davids;
- Buddhānusmrti: A Glossary of Buddhist Terms by Dr. Kala Acharya;
- The Jātaka or Stories of the Buddha's Former Births, Under the Editorship of Professor E.B. Cowell, translated by Robert Chalmers, Published by the Pali Text Society, Oxford 1990;
- Analysis of Perfections by Ven. Rerukane Chandavimala Mahathera, Buddhist Publication Society.












ISBN 9789995094621

PUC Press

មាគ៌ាជីវិតនៃព្រះពោធិសត្វ

កុល ផេង

ព.ស. ២៥៥២